# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ



ជាព្រះនាងឱរ៉ៃ

ឆ្នាំទី ៥៦ លេខ ១ ខែ មករា - កុម្ភៈ - មិនា

ព.ស. ២៥៤៥ គ.ស. ២០០២

ភ្នំពេញ

## សូមថ្លែងអំណរគុណចំពោះ

- លោក **ម៉ៅ សោភ័ណ** ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តពោធិសាត់ ព្រមទាំងសហការី ។
- លោក **អន បញ្ញា** សាស្ត្រាចារ្យសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ដែលបានជួយឧបត្ថម្ភដល់ការចុះស្រាវជ្រាវ និងថតរូបភាព អំពីប្រវត្តិ "**ជាព្រះនាងខ្ញុំអើ** " សម្រាប់ការបោះពុម្ពក្នុងទស្សនាវដ្តីកម្ពុជសុរិយាលេខ ១ ខែមករា កុម្ភៈ មិនា ឆ្នាំ ២០០២ នេះ ។



# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ

ចេញរាល់ត្រីមាស ពី វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

ចាត់ចែងបោះពុម្ពផ្សាយដោយគណៈកម្មការមួយ មាន :

នាយកការផ្សាយ : **ខួន ទ៉ាន់ចន្ទី**

និពន្ធនាយក : **ខៀវ បញ្ញាធុរ្យ**

គណៈកម្មការនិពន្ធ

លោកបណ្ឌិតទស្សនវិជ្ជា **ឆយ យីហ៊ាង**. លោក **ម៉ែន ប្រាង**

លោក **ខង់ សុធារ៉ា**. លោក **ឆន់ ហ៊ិន**.

លោក **មៀច ប៉ុណ្ណ**. លោក **ពិ ប៊ុន្នីន**

## គណៈកម្មការពិគ្រោះយោបល់

- លោកព្រឹទ្ធាចារ្យ **ឆេង ផុន** ប្រធានមជ្ឈមណ្ឌលវប្បធម៌ និងវិបស្សនា
- ឯកឧត្តម **នុត ណារ៉ាង** ប្រធានមជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ
- ឯកឧត្តម **ខាវ សារឿន** រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា
- ឯកឧត្តម **ឈន អៀម** រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា
- លោកបណ្ឌិតសាស្ត្រាចារ្យ **ឡុង សៀម** នាយកវិជ្ជាស្ថានជាតិខាងភាសា
- លោកបណ្ឌិតទស្សនវិជ្ជា **ឆយ យីហ៊ាង** ទីប្រឹក្សារាជរដ្ឋាភិបាល ទទួលបន្ទុកការងារអប់រំ, ព្រឹទ្ធបុរសដេប៉ាតឺម៉ង់ទស្សនវិជ្ជា និងក្រុមការងាររាជបណ្ឌិតសភាកម្ពុជា
- លោកបណ្ឌិត **នេត ឆាំម** សកលវិទ្យាធិការរង នៃសកលវិទ្យាល័យភូមិន្ទភ្នំពេញ។

---


- បោះពុម្ពផ្សាយដោយប្រើថវិកាបានពីការលក់សៀវភៅនានា ដែលក្រុមប្រឹក្សាពិភពលោកដើម្បីសាសនា និងសន្តិភាព ( WCRP ) នៃប្រទេសជប៉ុន បានឧបត្ថម្ភ។
- **The puplication of this issue has been made possible by the fund earned the sale of books supported by the WCRP/Japan.**

# មាតិកាអត្ថបទ

## I. អក្សរសិល្ប៍ពុទ្ធសាសនា :


- ជីវិតមនុស្ស និងបញ្ហា (ត) ............... (ឈួន អៀម) ១
- ព្រះបរមត្ថមញ្ជុសា វិសុទ្ធិមគ្គមហាដីកា (ត) ... (សួន ឱសថ) ១៥


## II. អក្សរសាស្ត្រទូទៅ និង អក្សរសិល្ប៍ខ្មែរ :


- វិជ្ជាគុណធម៌ សីលធម៌ និងគតិបណ្ឌិត ...(ព្រឹទ្ធាចារ្យ ឆេង ផុន) ២០
- ព្រះវិហារវាសនាខ្មែរ ......................(នុត ណារ៉ាង) ៣២
- ការវិវឌ្ឍន៍នៃអាពាហ៍ពិពាហ៍ខ្មែរ (ត) ......(ឆយ យីហ៊ាង) ៤៣
- ការរីកចម្រើននៃព្រះពុទ្ធសាសនា (ត) ..........(ខ្លូត ធីតា) ៥៥
- កំណត់សម្គាល់ និងការប្រើប្រាស់ (ត)........ (វ៉ង់ សុធារ៉ា) ៦០
- ឱសថបុរាណខ្មែរ (ត) ....................(សួន ឱសថ) ៧២
- កាព្យសាស្ត្រសង្ខេប (តចប់) .......... ... (ខៀវ យ៉ុន) ៧៨
- ដាព្រះនាងឱរ៉ៃ ........................ (ម៉ៅសោភ័ណ) ៨៧
- កំណាព្យ អាវចិត្តល្អ ...................(អ៊ុក សៅបុល) ៩៧


## III. កំណត់ និងប្រវត្តិការណ៍ :


- សិក្ខាសាលាជាតិលើកទី ៤ ........................ ៩៩


## IV. ទំព័រឆ្លើយឆ្លងជាមួយកម្ពុជសុរិយា


- លិខិតថ្លែងអំណរគុណ .......................... ១០២
- លិខិតរបស់លោក សួន ឱសថ ...................... ១០៤

# ជីវិតមនុស្ស និង បញ្ហា

(ត)

ព្រះតេជព្រះគុណ បណ្ឌិត ក. ស្រី ធម្មានន្ទ
បកប្រែដោយ : **ឈន អឿម**

## ការសន្សំទ្រព្យធន

មានមនុស្សខ្លះគិតថា ដោយការសន្សំទ្រព្យធនបានកាន់តែច្រើនឡើងៗ គេអាចជំនះបញ្ហាទាំងឡាយរបស់គេបាន ។ ដូច្នេះហើយ ទើបគេខិតខំ ដើម្បីបានក្លាយខ្លួនជាអ្នកមានទ្រព្យធនដ៏ច្រើន ដោយធ្វើការយ៉ាងនឿយហត់. ប៉ុន្តែ ក្រោយពេលបានក្លាយជាមហាសេដ្ឋីហើយ. គេត្រូវប្រឈមមុខ បញ្ហាដែលមិនបានគិតទុកមុនដ៏ច្រើនថែមទៀត គឺដូចជា អសន្តិសុខ, កោលាហល, សត្រូវ និងការលំបាកក្នុងការរក្សាទ្រព្យធនឱ្យគង់វង្ស ។ នេះបង្ហាញឱ្យឃើញច្បាស់ថា ការសន្សំ ឬការបង្គរទ្រព្យធនតែម្យ៉ាងមិនមែនជាដំណោះស្រាយបញ្ហារបស់មនុស្សទេ ។ ទ្រព្យធន តាមពិតអាចជួយជម្នះបញ្ហាបានខ្លះៗ ប៉ុន្តែមិនមែន សុភមង្គលរបស់ពិភពលោកទាំងអស់ សុទ្ធតែអាចសម្រេចបានតាមរយៈប្រាក់ទេ ។ ប្រាក់មិនអាចលុបបំបាត់បញ្ហាពីធម្មជាតិបានទេ ។

ទស្សនវិទូ. មហាចិន្តវិទូ និងវិចារណវិទូទាំងឡាយបានចង្អុលប្រាប់ នូវធម្មជាតិនៃភាពទន់ខ្សោយរបស់មនុស្ស និងវិធីជំនះលើភាពទន់ខ្សោយទាំងនោះ ។ ប៉ុន្តែ មានមនុស្សជាច្រើន ចាត់ទុកទស្សនៈទាំងនោះថាជា ទ្រឹស្តីសុទ្ធសាធ និងមិនមែនជាដំណោះស្រាយបញ្ហារបស់ពួកគេទេ ។ មានពេលខ្លះ បញ្ញា ឬពុទ្ធិ បង្កើតឱ្យមានបញ្ហាកាន់តែច្រើនដោយពិត. ពិព្រោះវាបង្កើនមតិយោបល់អាត្មានិយមអំពីខ្លួន.

យើងផ្ទាល់ ។

## ដំបូន្មានរបស់ព្រះពុទ្ធ ចំពោះការស្វែងរកទ្រព្យ

ផ្ទុយទៅនឹងមតិយល់ខុសប្រកាន់យកដោយមនុស្សខ្លះថា ពុទ្ធសាសនាជាមួយនឹងស្មារតីសន្តោស, ហើយជាពិសេស នៅក្នុងការហាត់ធ្វើភាវនា, មិនបានលើកទឹកចិត្តសាវ័ករបស់ខ្លួនឱ្យខិតខំធ្វើការងារ និងឱ្យឧស្សាហ៍ព្យាយាមទេ ។ ព្រះពុទ្ធនៅក្នុងធម៌ទេសនាដ៏ច្រើនរបស់ព្រះអង្គ តាមពិតទៅ បានជម្រុញយ៉ាងខ្លាំងមិនឱ្យសាវ័ករបស់ព្រះអង្គតំអក់, ទម្រន់, ខ្ជិលច្រអូស ប៉ុន្តែ ឱ្យខិតខំធ្វើការងារ ហើយឧស្សាហ៍ព្យាយាម ដើម្បីសន្សំទ្រព្យធនតាមរយៈមធ្យោបាយត្រូវសម្រាប់ជួយទ្រទ្រង់ស្ថេរភាពសេដ្ឋកិច្ច ។ នៅពេលលើកទឹកចិត្តឱ្យខំសន្សំទ្រព្យធន, ព្រះពុទ្ធទ្រង់បានហាមប្រាមសាវ័ករបស់ព្រះអង្គផងដែរ មិនឱ្យរំលោភបំពានលើគោលការណ៍អភិសមាចារ ឬគោលការណ៍សាសនាណាមួយ នៅក្នុងការងារនោះទេ ។ ព្រះអង្គបានទូន្មានថែមទៀតថា មនុស្សមិនគប្បីក្លាយខ្លួនជាខ្ញុំកញ្ជះចំពោះការសន្សំទ្រព្យធនដ៏សាមញ្ញ សម្រាប់តែគុណប្រយោជន៍នៃការសន្សំទ្រព្យធននោះទេ, ប៉ុន្តែត្រូវការពារទ្រព្យធននោះដោយមិនធ្វេសប្រហែស និងមិនខ្ជះខ្ជាយ ។ ព្រះអង្គបានទូន្មានថា ទ្រព្យធនគប្បីប្រើជាមធ្យោបាយសមស្របមួយសម្រាប់ចិញ្ចឹមជីវិតគ្រួសារ, គប្បីប្រើប្រាស់សម្រាប់ឧបត្ថម្ភញាតិ-មិត្តនៅពេលមានការចាំបាច់ និងដើម្បីជួយជនក្រីក្រ និងជនទុរគតទាំងឡាយ ទុកជាអំពើសប្បុរសធម៌ ។

នៅក្នុធម៌ទេសនារបស់ព្រះអង្គស្តីពីប្រភេទផ្សេងៗ នៃសុភមង្គលក្នុងទំនាក់ទំនងទៅនឹងទ្រព្យធន, ព្រះពុទ្ធបានផ្តល់ចំណាត់ថ្នាក់ជាក់ស្តែងបួនយ៉ាងនៃសុភមង្គលដូចតទៅនេះ ÷

• សុភមង្គល ក្នុងការរកបានទ្រព្យធន តាមរយៈមធ្យោបាយត្រូវ និងស្របច្បាប់;

• សុភមង្គល តាមរយៈការប្រើប្រាស់ត្រូវ និងម៉ត់ចត់ នូវទ្រព្យធនដែលបានសន្សំទុក;

• សុភមង្គល ក្នុងការរួចចាកផុតពីជំពាក់បំណុលគេ;

• សុភមង្គល ក្នុងការដឹងថា គ្មានមធ្យោបាយទុច្ចរិត ឬមិនស្របច្បាប់ណាមួយ ត្រូវបានប្រើប្រាស់ក្នុងដំណើរស្វែងរកទ្រព្យធន និងគ្មាននរណាម្នាក់ត្រូវបានរងការខូចខាត ឬរងគ្រោះថ្នាក់ ក្នុងដំណើរស្វែងរកទ្រព្យធន នេះទេ។

## ឱកាសរបស់មនុស្ស នៅលើពិភពលោកនេះ

តាមទស្សនវិស័យរបស់ពុទ្ធសាសនា, មនុស្សខុសគ្នាពីសត្វ ពីព្រោះថា មានតែមនុស្សប៉ុណ្ណោះ បានអភិវឌ្ឍញាណសត្តិ (Intelligence) និងសេចក្តីយល់ដឹងរបស់ខ្លួន ដើម្បីបញ្ចាំងចេញនូវវិចារណញ្ញាណរបស់ខ្លួន ។ មនុស្សមានន័យថា "បុគ្គលដែលមានចិត្តដើម្បីគិត " គោលបំណងរបស់សាសនា គឺជួយមនុស្សឱ្យចេះគិតដោយត្រឹមត្រូវ, លើកមនុស្សឱ្យខ្ពស់ជាងសត្វ, ជួយមនុស្សឱ្យយល់ទំនាក់ទំនងរបស់គេជាមួយនឹងសកលលោកធាតុរបស់គេ ហើយរស់នៅក្នុងភាពសុខដុមជាមួយសកលលោកធាតុនេះ ដើម្បីឱ្យគេបានដល់គោលដៅចុងក្រោយបង្អស់ នៃបរមសុខ ឬសុភមង្គលកំពូល និងបរិបុណ្ណភាព ។

សំនួរបីយ៉ាង ដែលបានធ្វើឱ្យមនុស្សខកចិត្តជានិច្ច ចាប់តាំងពីពេលគេមានសមត្ថភាពបំពេញសេចក្តីត្រូវការជាមូលដ្ឋានបីយ៉ាង ដើម្បីការរស់រានរបស់គេ

គឺ សេចក្តីត្រូវការអាហារ, ជម្រក និងការបន្តពូជ ។ សំនួរទាំងបីយ៉ាងគឺ : អាត្មាអញជាអ្នកណា ? តើអាត្មាអញកំពុងធ្វើអ្វីក្នុងទីនេះ ? តើគេត្រូវការអាត្មាអញឬទេ? ឆ្លងកាត់ប្រវត្តិសាស្ត្ររបស់មនុស្សពីដើមរៀងមក, ប្រព័ន្ធត្រិះរិះជាច្រើន បានវិវត្តជាមួយនឹងសាសនា ដ៏ជាប្រព័ន្ធឈានមុខបំផុតក្នុងចំណោមប្រព័ន្ធទាំងនោះ ដើម្បីផ្តល់ចម្លើយចំពោះសំនួរទាំងនោះ ។ តាមធម្មតា ដោយហេតុថា មនុស្សបានចោទសំនួរទាំងនេះឡើងមុនគេ, ចម្លើយទាំងឡាយ ត្រូវបានគេមើលឃើញទាំងអស់ចេញពីទស្សនវិស័យរបស់មនុស្សខ្លួនឯង ។

## មនុស្សនៅក្នុងសកលលោកធាតុ

ជាយូរយារណាស់មកហើយ មនុស្សបានមើលឃើញខ្លួនឯងថា ជាអ្នកឋិតនៅមណ្ឌលកណ្តាលនៃសកលលោកធាតុ, ជានិវាសី ឬអ្នកស្នាក់អាស្រ័យ (inha-betant) ដ៏សំខាន់បំផុតរបស់សកលលោកធាតុ ។ យោងតាមទស្សនវិស័យនេះ, ពិភពលោកបង្កើតឡើងគឺ សម្រាប់តែមនុស្ស, សម្រាប់តែពួកគេដណ្តើមយក ទន្ទ្រានយក អំពីសកលលោកធាតុនេះ នូវអ្វីៗដែលពួកគេចង់បាន ពិព្រោះពួកគេគឺជាពពួកសត្វមានជីវិតទទួលបានភាពអនុគ្រោះបំផុត នៅលើសកលលោកធាតុនេះ, ហើយអ្វីៗទាំងអស់ ដែលមាននៅលើផែនដីនេះ គឺសម្រាប់តែសេចក្តីសប្បាយរបស់ពួកគេទាំងស្រុង ។

ទស្សនៈដែលគេហៅថា " មនុស្សនិយម " នេះ អាចជាទស្សនៈទទួលខុសត្រូវផ្ទាល់ចំពោះការរំលោភបំពានដ៏គួរឱ្យខ្លាច មកលើពិភពលោករបស់យើង ជាមួយនឹងទស្សនៈមើលរំលងទាំងស្រុងរបស់យើងមកលើ សិទ្ធិរបស់សត្វឯទៀត ដែលមានជីវិតរស់រានជាមួយយើង ។ ជាឧទាហរណ៍, ដូចមានកើតករណីសោកនាដកម្មជា

ច្រើន ដែលនៅក្នុងនេះ ប្រភេទសត្វខ្លះ បានផុតពូជសាបសូន្យតាមរយៈការសម្លាប់ ដែលមិនចាំបាច់ ដោយពពួកមនុស្សខ្លះសមានចិត្តអាណិតអាសូរ ក្នុងការដេញតាម សេចក្តីសប្បាយជាល្បែងរបស់ពួកគេ ឬក៏សម្រាប់គោលបំណងជំនួញ ។ សូម្បីសព្វ ថ្ងៃនេះ ការរាតត្បាតលើធម្មជាតិ ដោយវិទ្យាសាស្ត្រ និងបច្ចេកវិជ្ជាក៏ត្រូវបានគេ កំពុងអបអរ ។ យើងត្រូវបង្កើនចំនួនមនុស្សក្នុងចំណោមគ្នាយើង ដែលបានដឹង ច្បាស់រួចហើយ នូវការបំផ្លិចបំផ្លាញដ៏ធំធេង ដែលត្រូវបានមនុស្សធ្វើឡើងក្នុងនាម "វឌ្ឍនភាព " ។ រហូតមកដល់ពេលនេះ ធម្មជាតិ កំពុងបន្តអត់ធ្មត់. ធន់ទ្រាំបំផុត ដែលនាំឱ្យមនុស្សបន្តគិតថា ពិភពលោកនេះត្រូវបានបង្កើតឡើងសម្រាប់តែឱ្យ មនុស្សឆក់ប្លន់តាមចិត្ត ដើម្បីបំពេញចំណង់លោភលន់ឥតចេះឆ្អែតសម្រាប់ការមាន បានខាងសម្ភារៈ និងសេចក្តីរីករាយខាងផ្លូវចិត្ត ។ សព្វថ្ងៃមានសញ្ញាព្រមានជាច្រើន ហើយដែលចង្អុលប្រាប់ថា ពេលវេលាសុខស្រួលជិតបានបញ្ចប់ហើយ ។ យើងនៅ មានសេចក្តីសង្ឃឹមថា ប្រសិនបើមេត្តា និងសម្មាទិដ្ឋិ មិនអាចសង្គ្រោះពិភពលោក បានទេ. ក៏យ៉ាងហោចណាស់. អត្តទត្តភាព និងចំណង់អត្តទត្តភាពដដែលនេះ សម្រាប់ស្វ័យរក្សា និងស្វ័យ-ប្រាមោទ្យផ្ទាល់ខ្លួន នឹងបង្ខំមនុស្សឱ្យចេះគិតគូរបាន ត្រឹមត្រូវខ្លះចំពោះបរិដ្ឋាន ដែលកាន់តែក្រខ្សត់របស់យើង និងចំពោះសត្វមានជីវិត ទាំងឡាយ ដែលកំពុងរងគ្រោះផុតពូជនៅលើផែនដីនេះដែរ ។

ដើម្បីយល់ពីទីតាំងរបស់មនុស្សនៅក្នុងសកលលោកធាតុ តាមទស្សន វិស័យពុទ្ធសាសនា យើងត្រូវដំបូងបង្អស់ក្រឡេកមើលទស្សនៈរបស់ព្រះពុទ្ធស្តីពី អវកាស ។ តាមទស្សនៈរបស់ព្រះអង្គ សកលលោកធាតុ ត្រូវតែយល់ក្នុងឋានៈ ជាលំហអវកាសដ៏ទូលំទូលាយមួយ ។ ការប្រៀនប្រដៅរបស់ព្រះអង្គ បានចាត់ថ្នាក់

សកលលោកធាតុទាំងមូលទៅជាបីក្រុម : ពិភពទាំងឡាយដែលមានសត្វមានជីវិតរស់នៅ. ពិភពទាំងឡាយដោយមានតែវត្ថុធាតុ. ហើយនឹងលំហអាកាសផ្ទាល់តែប៉ុណ្ណោះ ។

យើងអាចមើលឃើញមនុស្សជាសត្វមានជីវិត ដែលទទួលបានភាពអនុគ្រោះយ៉ាងពិសេស ដែលបានកើតមានអត្ថិភាពឡើង ដើម្បីសោយសេចក្ដីសុខនៃពិភពលោកនេះ ដែលកើតមានឡើងយ៉ាងពិសេសនៅចំកណ្ដាលនៃសកលលោកធាតុ ។ ពុទ្ធសាសនាមើលឃើញមនុស្សថា ជាសត្វតូចល្អិតទន់ខ្សោយមួយ មិនគ្រាន់តែក្នុងកម្លាំងពលំប៉ុណ្ណោះទេ ប៉ុន្តែ នៅក្នុងអាយុកាលថែមទៀត ។ មនុស្សគ្មានអ្វីក្រៅ គ្រាន់តែជាសត្វមួយដោយឡែក ប៉ុន្តែមានញាណសត្តិ ( Intelligence ) ដែលស្នាក់អាស្រ័យនៅក្នុងសកលលោកធាតុ ។

ផ្អែកតាមសរីរកាយ. មនុស្សគឺជាសត្វទន់ខ្សោយជាងសត្វមានជីវិតឯទៀត ទោះជាសត្វធំ ឬតូច។ សត្វទាំងឡាយដទៃទៀត កើតមកប្រដាប់ដោយអាវុធបែបណាមួយ សម្រាប់ការពារខ្លួន និងការរស់រានផ្ទាល់ខ្លួនរបស់វា ។ ចំណែកឯមនុស្សវិញ មានចិត្តរបស់ខ្លួន សម្រាប់អ្វីៗគ្រប់យ៉ាង ប៉ុន្តែមិនមែនជាអាវុធទេ។ មនុស្សត្រូវបានចាត់ទុកដូចជា សត្វមានជីវិតប្រដាប់ដោយវប្បធម៌ ពីព្រោះគេត្រូវចេះរស់នៅជាសុខដុមជាមួយសត្វដទៃ ប៉ុន្តែមិនបំផ្លិចបំផ្លាញសត្វដទៃទេ។ សាសនាត្រូវបានមនុស្សបង្កើតឡើងសម្រាប់បំរើគោលដៅនេះ។ អ្វីដែលរស់រានមានជីវិត រមែងចែករំលែកកម្លាំងជីវិត ( ជីវពល ) ជាមួយគ្នា ដែលផ្តល់ឋាមពលឱ្យមនុស្ស។ មនុស្សទាំងឡាយគឺជាផ្នែកនៃឋាមពលអវកាសជាមួយគ្នា ដែលកើតចេញជារូប ឬទ្រង់ទ្រាយប្លែកៗ ក្នុងអំឡុងជាតិនានាដ៏ច្រើនអនេក. ដោយអន្ទោលពីមនុស្ស ទៅកើត

ជាសត្វ. ទៅកើតជាទេវតា ហើយអន្ទោលត្រឡប់មកវិញជាថ្មីទៀត. បង្កឡើងដោយភវតណ្ហា ( សភាវតតិដើម្បីមានជីវិត ) ដ៏មានកម្លាំងខ្លាំងក្លា ដែលដឹកនាំមនុស្សនេះពី កើត ទៅស្លាប់ និងទៅកាន់កំណើតថ្មីទៀត ក្នុងវដ្តៈគ្មានទីបញ្ចប់ ដែលលោកហៅថា " សង្សារ "។ ប្រភពជាអកុសលបីយ៉ាងរបស់មនុស្ស ដែលចងភ្ជាប់គេទៅនឹងសង្សារ គឺលោភៈ ទោសៈ និងមោហៈ។

វដ្តៈ នេះ អាចបំបាក់បែងឱ្យវិលបានតែតាមរយៈការអរិយ្យន៏បញ្ញា ដែលបំផ្លាញផ្តាច់ផ្តិលចំណងទាំងឡាយនេះ ហើយរំលត់តណ្ហា។ វាសនារួមគ្នារបស់យើងក្នុងឋានៈជាសត្វមានជីវិតរស់នៅលើពិភពលោកនេះ គឺថា យើងទាំងអស់គ្នាមានចំណង់ខ្លាំងក្លា ដើម្បីបន្តជីវិតរស់រាន។

សត្វទាំងអស់ញ័ររន្ធត់នៅចំពោះមុខដំបង ( ទណ្ឌៈ ),

សត្វទាំងអស់ភ័យខ្លាច សេចក្តីស្លាប់.

ដោយបានដឹងប្រការនេះហើយ

បុគ្គលមិនត្រូវវាយប្រហារ ( សម្លាប់ )

ទាំងមិនត្រូវញ៉ុំងគេឱ្យវាយប្រហារ ( សម្លាប់) ឡើយ។ ( ធម្មបទ)

អ្វី១ទាំងអស់ អាស្រ័យគ្នាទៅវិញទៅមក ដើម្បីមានជីវិតរស់រានរបស់វា។ មនុស្សម្នាក់ មិនអាចមើលឃើញ ថាជាតួអង្គមួយផ្សេងដោយឡែកអំពី ( មិនទាំងនិយាយដល់ជាតួអង្គខ្ពស់ជាង ) សត្វទាំងឡាយឯទៀតទេ ពីព្រោះខ្លួនប្រាណរបស់គេពឹងផ្អែកទាំងស្រុងលើអាហារ ដែលមានន័យថា គេពឹងផ្អែកលើគិណជាតិទឹក. ខ្យល់អុកស៊ីហ្សែន. -ល- សម្រាប់ជីវិតរស់រានរបស់គេ។ នៅពេលជាមួយគ្នា

នេះ ចិត្តរបស់គេ កើតមានឡើងដោយពឹងផ្អែកផងដែរ ពីព្រោះអត្ថិភាពនៃគំនិតផ្អែកលើទិន្នន័យវិញ្ញាណ ( sense data ) ដែលចេញមកពីពិភពខាងក្រៅនៃវត្ថុ ឬមនុស្ស។ សកលលោកធាតុទាំងមូលត្រូវបានមើលឃើញដូចជាបណ្ដាញ (ឬសំណាញ់) ដ៏ធំមួយ : ប្រសិនបើមានតែតំណណាមួយរញ្ជួយ, បណ្ដាញ (ឬសំណាញ់) ទាំងមូលរមែងញ័រ។ មនុស្សជំពាក់គុណបំណាច់ចំពោះពិភពលោក, ពិព្រោះគេពឹងផ្អែកលើពិភពលោក ដើម្បីគេមានជីវិតរស់រាន ទាំងតាមផ្លូវកាយ ទាំងតាមផ្លូវចិត្ត។ ដោយហេតុនេះ ឥរិយាបថរបស់គេចំពោះពិភពលោក មិនត្រូវព្រហើនដូចកូនក្មេងទោលម្នាក់ឯងទំយើនោះទេ, ប៉ុន្តែគេត្រូវសុភាពរាបសា : ពិភពលោកមិនមែនកើតឡើងសម្រាប់តែមនុស្សម្នាក់ឯងទេ, មិនមែនពិភពលោកកើតមានឡើងសម្រាប់តែអនុគ្រោះមនុស្សជានិច្ចនោះទេ។ ល័ក្ខខ័ណ្ឌនៃលោក (worldly conditions ) មិនមានអនុគ្រោះនិយមទេ។ សភាវនៃលោក មិនស្លូត មិនកាច, ប៉ុន្តែ អព្យាក្រិត។ មនុស្សមានអត្ថិភាពឡើង ពិព្រោះពិភពលោកទាំងអស់ អនុញ្ញាតឱ្យគេមានអត្ថិភាព។

ដោយហេតុនេះ មនុស្សមិនគប្បីខិតខំកៀបច្របាច់យកវត្ថុទាំងឡាយចេញពីពិភពលោកសម្រាប់តែអត្តប្រយោជន៍ផ្ទាល់ខ្លួននោះទេ។ គេត្រូវរក្សាស្មារតីកោតខ្លាច និងគោរពចំពោះធម្មជាតិ និងសត្វទាំងអស់។ មនុស្សគឺជាអ្នកមកដល់ថ្មីតាមការប្រៀបធៀបនៅលើពិភពផែនដីនេះ។ មនុស្សត្រូវចេះគោរពសហភាតរៈដទៃទៀត ដែលមានជីវិតរស់នៅជាមួយ។ មនុស្សត្រូវចេះប្រព្រឹត្តធ្វើខ្លួនឱ្យដូចជាភ្ញៀវម្នាក់ ជាជាងតាំងខ្លួនជាអ្នកលេងល្បែងម្នាក់នៅក្នុងវង់ល្បែងស៊ីសង ដែលអ្នកឈ្នះប្រមូលយកទាំងអស់។

គឺនៅក្នុងការទទួលស្គាល់អន្តរសម្ព័ន្ធនេះហើយ ដែលព្រះពុទ្ធបានប្រៀនប្រដៅបរិស័ទរបស់ព្រះអង្គឱ្យហ្វឹកហាត់ <u>**មេត្តាធម៌**</u> ចំពោះមនុស្ស-សត្វទាំងអស់. ដើម្បីផ្សព្វផ្សាយសេចក្ដីអាណិតអាសូរនោះ ចំពោះសព្វសត្វ។ ព្រះពុទ្ធមិនមានបន្ទូលសំដៅឱ្យមនុស្សទាំងឡាយត្រូវផ្សាយមេត្តាធម៌របស់ខ្លួន ចំពោះមនុស្សជាញាតិមិត្តប៉ុណ្ណោះទេ (ព្រះអង្គមិនបានបង្គាប់បញ្ជាឱ្យមានសេចក្ដីរាប់អានពិសេសសម្រាប់ "ញាតិ-មិត្តជាពុទ្ធសាសនិក" របស់ពួកគេទេ)។ នៅពេលណាព្រះអង្គទេសនា អំពីសេចក្ដីស្រឡាញ់រាប់រកអ្នកដទៃ ព្រះអង្គតែងមានពុទ្ធដីកាសំដៅដល់សព្វសត្វទាំងអស់ (<u>សព្វេ សត្តា</u>), សូម្បីពពួកសត្វអទិស្សមានកាយ, ពពួកសញ្ញីសត្វ, ពពួកអតិសញ្ញីសត្វ ( The super conscious ) ក៏សំដៅដល់ដែរ។

មានកំណើតបួនយ៉ាងគឺ សត្វមានជីវិតដែលកើតពី <u>សំសេទជៈ</u> កំណើត (គឺពពួកសត្វកើតពីសំណើម " moiture-born "), <u>អណ្ឌជៈ</u> កំណើត ( ពពួកសត្វកើតចេញពីស៊ុត " egg-born "),<u>ជលាពុជៈ</u> កំណើត ( ពពួកសត្វកើតអំពីផ្ទៃ "womb-born " ) និង <u>ឱបបាតិកៈ</u> កំណើត គឺជាពពួកសត្វកើតឯង " Spontaneous born " នៅក្នុងភពនៃជីវិតដទៃទៀត។ ច្បាស់លាស់ណាស់ ព្រះពុទ្ធទ្រង់បានប្រៀនប្រដៅថា បើមនុស្សម្នាក់មានជីវិតរស់នៅលើភពផែនដីនេះ, គេត្រូវតែពង្រីកឥរិយាបថនៃមេត្តា-ករុណា មិនមែនតែចំពោះមនុស្សដូចគ្នាប៉ុណ្ណោះទេ, ប៉ុន្តែចំពោះសត្វទាំងអស់ ដែលរស់នៅលើភពផែនដីនេះ ក៏ដូចជានៅក្នុងភពនៃជីវិតដទៃទៀតដែរ គឺមានតែធ្វើយ៉ាងនេះទេ ទើបគេយកឈ្នះលើគំនិតអាត្មានិយម ដែលដាក់សេចក្ដីត្រូវការនិងចំណង់ចង់រស់រានរបស់ខ្លួន លើសេចក្ដីត្រូវការរបស់មនុស្ស-សត្វ ដទៃទៀតទាំងអស់។

នៅក្នុងលោកនិម្មាណវិជ្ជាពុទ្ធសាសនា, មនុស្សគឺគ្រាន់តែជាអ្នករស់នៅលើភពមួយក្នុងបណ្ដាភពជីវិតឯទៀត ដែលគេអាចទៅរស់នៅ បន្ទាប់ពីការស្លាប់ទៅ ។ ភពទាំងនេះ រាប់តាំងពី អតិសសញ្ញីភព ( superconscious level ) រហូតដល់កាមភពដ៏ខ្ពស់ចុះដល់ទុគ្គតិភពទាំងបួន។ មនុស្សកាន់កាប់ទីតាំងពាក់កណ្ដាលផ្លូវក្នុងចន្លោះភពទាំងនោះ ។ ទេវលោក ឬទេវភព គឺជាសុគតិភព ប៉ុន្តែភពទាំងនោះ ក៏មិនឋិតថេរចិរកាលដែរ ។ ទោះបីមានសញ្ញាខ្លះ ដែលនាំឱ្យយើងជឿថា មានជីវសត្វប្រកបដោយប្រាជ្ញាវាងវៃបែបណាមួយកំពុង មានជីវិតរស់នៅក្នុងប្រព័ន្ធពិភពលោកផ្សេងក្ដី, ក៏គេមិនទាន់បញ្ជាក់អះអាងបានថា មានសត្វដូចមនុស្សរស់នៅក្នុងពិភពដ៏ទទៃនៃសកលចក្រវាលដែរ។ គឺនៅក្នុងអត្ថន័យ នៃសកលលោកធាតុដ៏ទូលំទូលាយ ឥតព្រំដែននោះហើយ ដែលព្រះពុទ្ធសាសនាបានខិតខំស្វែងយល់ទីតាំងរបស់មនុស្ស នៅក្នុងសកលលោកធាតុ។ នៅក្នុងអត្ថន័យនៃបរិបទនេះ មនុស្សហាក់ដូចជាតូចតាចទេ ។ យើងត្រូវបន្ថែមទៅលើនិន្នាការរបស់មនុស្សនេះ នូវអំពើឃោរឃៅ, នូវភាពប៉ិនប្រសប់របស់គេ ដើម្បធ្វើឱ្យអ្នកដទៃឈឺចាប់ ដែលធ្វើឱ្យមនុស្សនៅពេលខ្លះ អន់ថយជាងសត្វដែលចេះតែវាយប្រហារ ដើម្បីបំពេញសេចក្ដីត្រូវការជាមូលដ្ឋានរបស់វា សម្រាប់ស្វែងរកចំណីអាហារ, ជម្រកស្នាក់អាស្រ័យ ឬការរួមភេទ ។

## ទីតាំងឯករបស់មនុស្ស

គេអាចជជែកតវ៉ាថា នេះគឺជាទស្សនៈអវិជ្ជមានពេកណាស់ អំពីមនុស្ស ដោយដាក់មនុស្សនេះឱ្យឋិតនៅក្នុងទីតាំងទាប ហើយមើលរំលងនូវសមិទ្ធផល

ដ៏ត្រចះត្រចង់របស់មនុស្ស ក្នុងការបង្កើតឡើងនូវទស្សនវិជ្ជាសាសនា, ចិត្តវិជ្ជា, វិទ្យាសាស្ត្រ, សិល្បៈ, ស្ថាបត្យកម្ម, អក្សរសាស្ត្រ និងការអភិវឌ្ឍន៍វប្បធម៌ និងអ្វីៗដទៃទៀត។ វែងឆ្ងាយជាងនេះទៀត, នៅក្នុងបរិបទសកលលោកធាតុនេះ, មនុស្សបានកាន់កាប់ទីតាំងតែមួយគត់ ពិព្រោះគេមានបុព្វសិទ្ធិពិសេសបំផុតដើម្បីទទួលបានការសង្គ្រោះយ៉ាងងាយស្រួល ។ ហេតុបានជាដូច្នោះ, ពិព្រោះមានហេតុផលបីយ៉ាង :

ហេតុផលទីមួយគឺ ពិភពមនុស្ស គឺជាទីបញ្ចុះជ្រុំដ៏ល្អ និងមានតុល្យភាពជាមួយសេចក្ដីសប្បាយនិងសេចក្ដីឈឺចាប់។ កាលណាសេចក្ដីសប្បាយកើនឡើងខ្លាំង (នៅក្នុងទេវលោក) ឬសេចក្ដីឈឺចាប់គ្របសង្កត់ខ្លាំង (នៅក្នុងពិភពខាងក្រោម), ចិត្តរបស់សត្វមិនងាកទៅរកភាពបរិសុទ្ធផ្ទៃក្នុង ( spirituality ) ទេ។ ពុទ្ធសាសនិកជន អះអាងថា តបកម្ម ឬការប្រព្រឹត្តតឹងរឹងហួសហេតុ ឬសេចក្ដីសប្បាយហួសហេតុ, មិននាំទៅរកការអភិវឌ្ឍន៍ខាងបញ្ញា និងសេចក្ដីយល់ដឹងទេ។ គេបានទូន្មានឱ្យប្រកាន់យកមជ្ឈិមបដិបទា (ផ្លូវកណ្ដាល ) រវាងការប្រព្រឹត្តតបកម្មហួសហេតុ និងសេចក្ដីសប្បាយ (កាមសុខ) ហួសហេតុ។ ពិភពមនុស្សផ្ដល់ឱកាសដល់មនុស្សឱ្យដើរតាមមជ្ឈិមបដិបទា។ ហេតុផលទីពីរ គឺការមិនអាចទស្សទាយពេលវេលា នៃមរណភាពបាន។ នៅចំពោះមុខមរណភាពហៀបនឹងមកដល់ គេច្រើនតែទោរទន់ទៅរកភាពបរិសុទ្ធផ្ទៃក្នុង ( spirituality ) ។ ហេតុផលទីបី គឺថា ក្នុងអំឡុងពេលឋិតនៅក្នុងភពដទៃៗ អ្នករស់នៅក្នុងភពនោះៗ គឺជាអ្នកចាំតែសោយផលនៃ*កម្មអតីត:* របស់ខ្លួនសុទ្ធសាធ, ឯមនុស្សវិញឋិតនៅក្នុងទីតាំងអនុគ្រោះមួយដើម្បីបង្កើត*កម្មថ្មីៗ*ទៀត, ហើយដោយប្រការនេះ មនុស្សអាចចាត់ចែងវាសនា

ផ្ទាល់របស់ខ្លួនបាន ។

ទាំងអស់នេះ ផ្តល់ដល់មនុស្ស នូវការទទួលខុសត្រូវ ដើម្បីសម្រេចនូវការសង្គ្រោះរបស់ខ្លួនផ្ទាល់ នៅក្នុងពិភពមនុស្ស ។ ដូច្នេះ គេគឺជាអ្នកបង្កើត និងជាអ្នកសង្គ្រោះរបស់ខ្លួនគេផ្ទាល់ ។ មនុស្សឯទៀតជឿថា សាសនាបានធ្លាក់ចុះមកពីឋានសួគ៌ ប៉ុន្តែ ពុទ្ធសាសនិកដឹងថា ពុទ្ធសាសនាបានចេញដំណើរពីលើផែនដី ហើយបានទៅដល់ឋានសួគ៌ ។

អ្វីដែលពាក្យនេះ សំដៅដល់នោះគឺថា មនុស្សម្នាក់ៗមាននៅព្ធដ៏ផ្ទៃក្នុងរបស់ខ្លួននូវពន្លកព្រះពុទ្ធ ឬពុទ្ធង្កូរ (គឺសក្តានុភាពដើម្បីបានសម្រេចបារមី ) ដែលគេអាចអភិវឌ្ឍបាន ដោយមិនចាំបាច់មានជំនួយពីខាងក្រៅ ។ គេអាចក្លាយខ្លួនជាព្រះពុទ្ធមួយអង្គ តាមរយៈកំណើតនៅក្នុងពិភពមនុស្ស. ពិព្រោះគឺនៅទីនេះឯងដែលគេអាចពិសោធជីវិតរស់នៅក្នុងសកលភាពរបស់វាបាន ។ ពុទ្ធសាសនិកជនអាចយល់ព្រមទាំងស្រុងជាមួយទស្សនៈប្រតិមតិ ( paradox ) អំពីមនុស្សរបស់លោក សេកស្ពៀរ ( Shakespeare ) ថា :

មនុស្ស គឺជាស្នាដៃបង្កើតមួយដ៏អស្ចារ្យ.

មានវិចារណ្ណាណដ៏ឧត្តុង្គឧត្តម.

មានញាណសត្តិ ទូលំទូលាយ ហើយវាងវៃគ្មានព្រំដែន;

ធ្វើអំពើល្អគួរឱ្យកោតសរសើរក្រៃលែង.

យល់ដឹងដ៏អស្ចារ្យ បីដូចទេវតា.

បីដូចទេវស្ថាន : សោភណភាព ពិភពលោក.

គំរូនៃសត្វទាំងឡាយ ( animals ) ល្អអ្វីម្លេះទេ;

ក៏ប៉ុន្តែចំពោះខ្ញុំ តើអ្វីទៅជាសារជាតិនៃធូលី ( គឺមនុស្ស ? ) នេះ ?

នៅក្នុងបែបបទជាច្រើន មនុស្សគឺល្ងង់ខ្លៅ, ប៉ុន្តែថា គេមានពន្លក (ឬពូជ) ដើម្បីក្លាយទៅជាសត្វ ( bieng ) មួយដ៏ខ្ពង់ខ្ពស់បំផុតជាងសត្វទាំងអស់ : គឺជាតួអង្គមួយត្រាស់ដឹងពេញលេញ។ មនុស្សខ្លះនិយាយថា ជីវិតមនុស្ស ឋិតនៅចន្លោះទេវលោក និងឋាននរក ពីព្រោះចិត្តរបស់មនុស្សអាចអភិវឌ្ឍបានងាយ ដើម្បីសោយបរមសុខក្នុងទេវលោក. ប៉ុន្តែ បើកាលណា បរមសុខ ត្រូវបានបំពាន, ចិត្តរបស់មនុស្សនោះ អាចរងទុក្ខទោសយ៉ាងងាយនៅក្នុងនរក។

"មនុស្ស គឺជា មនុស្ស ប្រសិនបើគេមានចិត្តជាប់ជំពាក់ជាមួយមនុស្ស ឬមានហឫទ័យមនុស្ស :

មនុស្សក្រអើតក្រអោង គ្មានឋានសួគ៌;

មនុស្សច្រណែន គ្មានញាតិជិតខាង;

មនុស្សក្រេវក្រោធ សូម្បីតែខ្លួនឯង ក៏គ្មានដែរ "។

( ទស្សនវិជ្ជាចិន )

"បុគ្គលម្នាក់ឯង គឺអនាថា (គ្មានទីពឹង )។ ដូច្នេះ ជីវភាពសង្គមរបស់មនុស្ស រមែងនាំមកនូវកម្លាំងសហប្រតិបត្តិការ។ មនុស្សមិនអាចជាមនុស្សដោយគ្មានសង្គមបានទេ។ មនុស្ស គឺសត្វមួយរស់នៅជាមួយធម្មជាតិ " ។

( ទស្សនវិទូក្រិក )

នៅក្នុងពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ, មានសេចក្តីថ្លែងថាមនុស្ស

សោយបរមសុខក្នុងឋានសួគ៌ កាលណាវត្ថុទាំងឡាយ ដែលជះឥទ្ធិពលទៅលើវិញ្ញាណទាំងប្រាំ បានជាទីពេញចិត្ត និងធ្វើឱ្យអារម្មណ៍ស្ងប់ស្ងាត់។

ម្យ៉ាងទៀត មនុស្សរងទុក្ខដូចនៅក្នុងឋាននរកផងដែរ ប្រសិនបើកម្មវត្ថុទាំងឡាយបង្កសេចក្តីក្តៅក្រហាយ និងរង្កៀសចិត្ត ។

( នៅមានត )

*រូបរាងយើងសព្វថ្ងៃ*

*គិតអាល័យឱបតែខ្មោច*

*អសុភសាកអសោចិ៍*

*ឥតញញើតញញោចញញើតឡើយ*

សម្តេចព្រះសុមេធាធិបតី សង្ឃនាយក

គណៈមហានិកាយចន្ទត្ថេរោ ជួន ណាត

# ព្រះវិសុទ្ធិមគ្គមហាដីកា

(ត)

ប្រែសម្រួលដោយៈ **សួន ឱសថ**
ផ្ទៀងផ្ទាត់ស័ព្ទព្រះបាលីដោយៈ
ឧទ្ទេសាចារ្យ **រិទ្ធ សោរឌឿ**

"មានដំណើរការទៅនៃព្រះញាណមិនមានអ្វីឃាត់ឃាំងក្នុងធម៌ទាំងពួង" នេះសំរាប់សេចក្ដីងឿងឆ្ងល់ថា ព្រះដ៏មានព្រះភាគ ស្ដេចទ្រង់អាចព្យាករណ៍ពាក្យបុច្ឆាសួម្បីរបស់ពួកទេវតា បានយ៉ាងជំនាញ ឬប្រសិនបើហាមឃាត់សេចក្ដីងឿងឆ្ងល់នោះបាន លោកអាចារ្យនឹងពោលថា "ទេវទេវោ" ។

ស្ដេចសក្កទេវរាជ ជាទេពប្រសើររបស់ទេពទាំងឡាយ តែងវិសជ្ជនាបញ្ហាកម្មរបស់ទេវតាទាំងឡាយបាន, ដូចមនុស្សទាំងឡាយគិតថា "ព្រះដ៏មានព្រះភាគអង្គនេះ" នឹងមានអ្វីពិសេសលើសស្ដេចសក្កទេវរាជនោះ "ប្រសិនបើហាមឃាត់គំនិតនោះបាន "លោកអាចារ្យនឹងពោលថា "ទ្រង់ជាសក្កៈដ៏ប្រសើររបស់សក្កៈទាំងឡាយ"។

ព្រហ្មទាំងឡាយមានសនង្កុមារព្រហ្មជាដើម តែងវិជ្ជនាអាថិសេចក្ដីដែលស្ដេចសក្កៈទូលសួរ ដូចមនុស្សទាំងឡាយគិតថា "ព្រះដ៏មានព្រះភាគអង្គនេះ នឹងមានអ្វីប្រសើរលើសព្រហ្មនោះ " ប្រសិនបើមិនគិតដល់សេចក្ដីនោះទេ លោកអាចារ្យនឹងពោលថា " ទ្រង់ជាព្រហ្មដ៏ប្រសើររបស់ព្រហ្មទាំងឡាយ " ។ បើនឹងសំដែងថា "ក៏សេចក្ដីវិសេសរបស់ព្រះដ៏មានព្រះភាគដូច្នេះនោះ ប្រាកដហើយដោយវេសារជ្ជញ្ញាណ ៤ និងជាអ្នកប្រកបដោយទសពលញ្ញាណដូច្នេះឯង ។ បើនឹងសំដែងថា

ប្រកបដោយញាណដូច្នេះ សំរេចព្រមដោយការទំលុះញាណទាំង២ នោះ លោកអាចារ្យ និងពោលថា "ទ្រង់ជាព្រះអនាវរណញ្ញាណ ( មានព្រះញាណរកទីបំផុតគ្មាន ) ទ្រង់មាន **សមន្តចក្ខុ** ( មានចក្ខុដោយជុំវិញ ) " ។ លោកអាចារ្យបើនឹងសំដែងថា "ញាណទាំង ២" ដូច្នេះនោះ កំណត់ជាស្រេចព្រោះសេចក្តីថា ព្រះដ៏មានព្រះទ្រង់ជាអ្នកមានទោសៈ កំចាត់បង់ហើយ ដូចដែលសំរេចបានមកដោយការសន្សំ **បុញ្ញសម្ភារៈ** និង **ញាណសម្ភារៈ** នឹងមាន ព្រះនាមថា " **ព្រះដ៏មានព្រះភាគ** " ហ្នឹងឯង ។ បណ្ឌិតគប្បី ជ្រាបនូវប្រយោជន៍ និងលំដាប់ក្នុងការកាន់យកតាមបទទាំងឡាយ នោះដោយប្រការដូច្នេះចុះ ។

ចំពោះញាណទាំង ២ នោះ គឺដោយអត្ថមិនផ្សេងពីគ្នាឡើយ ។ តាមពិតញាណនោះឯងជាញាណតែមួយគត់ គ្រាន់តែលោកអាចារ្យសំដែងធ្វើឱ្យជា ២ យ៉ាង ដើម្បីសំដែងសេចក្តីជាញាណមិនសាធារណៈទូទៅដល់ជនដ៏ទៃ និងជាដំបូងបំផុត គឺសេចក្តីប្រព្រឹត្តទៅដោយវិសេសនោះឯង ។

ឈ្មោះថា **សព្វញ្ញុតញ្ញាណ** ព្រោះជាធម្មជាតិមានសង្ខតធម៌ អសង្ខតធម៌ និង សម្មុត្តិធម៌ [១] មិនមានចំណែកក្រៅពីនោះជាអារម្មណ៍. លោកនឹងហៅថា **អនាវរណញ្ញាណ** " ដូច្នេះក៏មាន ព្រោះសេចក្តីប្រព្រឹត្តទៅមិនមានទីបំផុត មិនមានការលោតសន្ទឹងបានក្នុងសព្វញ្ញុតញ្ញាណនោះ ។ ក៏ពាក្យណាដែលគួរពោលនៅក្នុងទីនេះនោះ ពាក្យនោះខ្ញុំម្ចាស់នឹងពោលក្នុង ពុទ្ធានុស្សតិនិទ្ទេសនៅខាងមុខ ។

២ - ព្រះដ៏មានព្រះភាគបានស្វែងរកហើយ គឺស្វែងរកហើយនូវគុណដ៏ធំបានដល់គុណមានសីលខ័ន្ធជាដើម ហេតុនោះព្រះដ៏មានព្រះភាគអង្គនោះ ឈ្មោះថា

---

១ - មូលនៃព្រះបារមីថា សម្មុតិធម្មារម្មណកាយ ...។ ជាដើម ។

**មហេសី** ( អ្នក ស្វែងរកគុណដ៏ធំ ) ។ ដូចដែលព្រះដ៏មានព្រះភាគអង្គនោះទ្រង់ជាអ្នកស្វែងរកគុណដ៏ធំនោះ ។

ពាក្យថា បើនឹងពណ៌នា គឺថានឹងបំបែកចេញ បានដល់នឹងធ្វើឱ្យពិស្តារ ។ ពាក្យថា តាមសេចក្តីពិត គឺមិនវិបរិត ។ ពាក្យថា ដែលផ្សេងដោយគុណមានសីលជាដើម គឺចំណែកដោយគុណនោះមានសីល សមាធិ និងបញ្ញា ។ ពាក្យថា ដែលបានមកដោយសែនលំបាក គឺ បានមកដោយលំបាកក្រៃលែង ព្រោះត្រូវបានដោយខណៈទី ៩ វៀរអស់ ៨ ខណៈ ។ ពាក្យថា ដែលសង្គ្រោះដោយគុណមានសីលជាដើម គឺសង្គ្រោះដោយខ័ន្ធ ៣ មានសីលខ័ន្ធ ជាដើម ។

តាមពិត អរិយមគ្គសង្គ្រោះជាខ័ន្ធ ៣ ព្រោះធម៌មានចំណែក ដែលអាងបាន តួយ៉ាងដូច នគរសង្គ្រោះដោយសេចក្តីជាព្រះរាជា. ខ័ន្ធ ៣ មិនបានសង្គ្រោះដោយអរិយមគ្គ ព្រោះមិនមានចំណែកដែលអាងបាន ។ សមដូចពាក្យដែលព្រះធម្មទិន្នាថេរីសំដែងដូចតទៅនេះថា " ម្នាលអាវុសោវិសាខៈ! ខ័ន្ធ ៣ ព្រះដ៏មានព្រះភាគមិនបានទ្រង់សង្គ្រោះ ដោយអរិយមគ្គមានអង្គ ៨ . ម្នាលអាវុសោវិសាខៈ! ក៏ឯអរិយមគ្គមានអង្គ ៨ ទ្រង់មិនបានសង្គ្រោះដោយខ័ន្ធ ៣ ដូច្នេះជាដើមឡើយ ។

ឈ្មោះថា " **របស់ក្សេម** " ព្រោះសេចក្តីជាប្រធាននៃចោរ គឺពួកកិលេសទាំងឡាយ ដែលធ្វើអន្តរាយមិនបាន ។ ឈ្មោះថា " ត្រង់ " ព្រោះវៀរចាកទីបំផុតទាំងពីរ និងការលះមាយាជាដើម និងការវៀរចាកតាមផ្លូវកាយជាដើម ។ ឈ្មោះថាមគ្គ ព្រោះអត្ថថាទៅ គឺថាការប្រព្រឹត្តទៅដោយអំណាចការសម្លាប់សង្កិលេស ធម៌ទាំងពួង ព្រោះការស្វែងរក ។ ពាក្យថា " វិសុទ្ធិ " គឺ ដើម្បី

ព្រះនិព្វាន ឬដើម្បីភាព នៃសេចក្តីបរិសុទ្ធិ អធិប្បាយថា ដើម្បីព្រះអរហត្ត ។

ពាក្យថា " បើមិនដឹងតាមសេចក្តីពិត " មានន័យថា មិនទាន់ដឹងតាមសេចក្តីពិតថា " វិសុទ្ធិមគ្គ ដែលព្រះយោគីត្រូវទំលុះបានដោយការកើតបន្តគ្នារបស់វិសុទ្ធិមានសីលវិសុទ្ធិជាដើមយ៉ាងនេះ ឃើញបានយ៉ាងនេះ មានកិច្ចយ៉ាងនេះ មានអត្ថយ៉ាងនេះ ដូច្នេះឯង "។

ព្រះយោគីទាំងឡាយណាប្រាថ្នា គឺតែងប្រាថ្នាសេចក្តីបរិសុទ្ធិ គឺសេចក្តីផុតចាកសង្កិលេសទាំងអស់ និងចាកសង្ខារ ហេតុដូច្នោះ ព្រះយោគីទាំងនោះឈ្មោះថា " **សុទ្ធិកាមា** " អ្នកប្រាថ្នាសេចក្តីបរិសុទ្ធិ ។ អបិស័ព្ទ [២] ចុះក្នុងភាវៈ ។ ដោយ អបិស័ព្ទនោះ លោក អាចារ្យបានសំដែងថា ពុំមែនរីករាយដោយចំពោះសីលតែម្យ៉ាងនោះទេ ជាទូទៅសូម្បី ជាអ្នកប្រាថ្នាសេចក្តីបរិសុទ្ធិ ។ បទថា **ឥធ** សេចក្តីដូចគ្នា **ឥមស្មឹំ យោ សាសនេ** ប្រែថា ក្នុងព្រះពុទ្ធសាសនានេះ ។

ពាក្យប្រកបសេចក្តីថា ឈ្មោះថា យោគី ព្រោះអត្ថថា ជាអ្នកប្រកបហើយ ខ្វល់ខ្វាយហើយ ក្នុងភាវនា សូម្បីសេចក្តីព្យាយាម គឺថា សូម្បីធ្វើការព្យាយាមតស៊ូចំពោះសេចក្តីបរិសុទ្ធិ ក៏ពុំដែលទំលុះសេចក្តីបរិសុទ្ធិ ព្រោះពុំទាន់ទំលុះ (នូវបញ្ញា) ជាឧបាយ ។ បទថា **តេសំ យោគីនំ** ប្រែថា ចំពោះយោគីទាំងនោះ ។

ក៏បរិសុទ្ធិមគ្គនេះ ធ្វើសេចក្តីប្រាមោទ្យ ( បាមោជ្ជ ) ដល់បុគ្គលទាំងពួងជាអ្នកខ្វល់ខ្វាយដោយការស្តាប់ ការទទួលយក និងការសន្ទ្យជាដើម ព្រោះជាសេចក្តីស្អាតស្របតាមការណ៍ពិត ដល់សភាពយ៉ាងនោះ ក៏ជាបាមោជ្ជយ៉ាងពិសេសណាស់ចំពោះយោគីទាំងឡាយព្រោះហេតុនោះបានជាលោកអាចារ្យសំដែងថា " ធ្វើសេចក្តី

---

១ - អបិស័ព្ទ លោកបញ្ជាក់សេចក្តីក្នុងបទព្រះបាលីថា វិសុទ្ធិកាមាបិ ក៏បានស័ព្ទថាអបិ ។

ប្រាមោទ្យដល់យោគីទាំងឡាយនោះ " ។ ឈ្មោះថា មានវិនិច្ឆ័យយ៉ាង ហ្មតចត់ល្អ ព្រោះមានសេចក្តីវិនិច្ឆ័យយ៉ាងហ្មត់ចត់ដោយល្អ ដោយការពុំជឿតាមនិកាយខាងក្រៅ និងលទ្ធិដទៃ ។ ពាក្យថា "របស់ព្រះថេរៈផ្នែកមហាវិហារ" លោកអាចារ្យ តែងសំដែងនិកាយដែលជាទីពឹងអាស្រ័យនៃខ្លួន ។ ពាក្យថាអាស្រ័យ តិចដោយទេសនា គឺអាស្រ័យតិច នៃសំវរប្បធានធម៌ ។

ក៏ក្នុងអធិការនេះ ដោយពាក្យថា " ធ្វើសេចក្តីប្រាមោទ្យដល់ព្រះយោគីទាំងឡាយនោះ " ជាដើម. លោកអាចារ្យតែងសំដែងថា **ភាវនាមគ្គ** របស់ព្រះថេរៈសំណាក់មហាវិហារទាំងឡាយ ឈ្មោះថា មានវិនិច្ឆ័យបរិសុទ្ធិដោយល្អប្រពៃ ព្រោះព្រះថេរៈ ទាំងឡាយ ជាអ្នកមានញាណ ដ៏ប្រសើរថ្លៃថ្លា ជាអ្នកបដិបត្តិដោយប្រពៃ បានទំលុះហើយ ធ្វើសេចក្តីប្រាមោទ្យព្រោះនាំមកនូវភាពបរិសុទ្ធិនោះ ដោយចំណែកតែមួយ ដល់យោគីទាំងឡាយជាអ្នកប្រាថ្នាសេចក្តីបរិសុទ្ធិ គឺព្រះនិព្វាន ព្រោះជាធម្មជាតិដ៏បរិសុទ្ធិចាកមន្ទិល គឺសង្កិលេសទាំងពួង ។ ដូចមានពាក្យថា បើខ្ញុំម្ចាស់ពោល ដោយសេចក្តីគោរព សូមលោកទាំងឡាយតាំងចិត្តស្តាប់ដោយគោរពចុះ ។

(នៅមានត)

# វិជ្ជាគុណធម៌ សីលធម៌ និង គតិបណ្ឌិត តាមរយៈប្រាសាទ និង វត្ត វប្បធម៌ សិល្បៈ

ដោយ: ព្រឹទ្ធាចារ្យ លេខ ឆុន

## I- ចរន្តវប្បធម៌ខ្មែរ :

*១ - ចរន្តវប្បធម៌បញ្ញាជន :* (Courant intellectuel )

ប្រាសាទទាំងឡាយ សិលាចារឹកទាំងឡាយ រូបសំណាកទាំងឡាយ គ្រឹះស្ថានសិក្សាទាំងឧត្តម ទាំងមធ្យម ទាំងវិទ្យាសាស្ត្រ ទាំងបច្ចេកទេស ពីសតវត្សទី ១២ សុទ្ធតែបានបញ្ជាក់ពីការលូតលាស់ នៃចរន្តវប្បធម៌ បញ្ញាជន ដែលមានឧត្តមសិក្សាពីរ គឺ ស្រីជ័យ និង រាជវិហារ ។

មានសាស្ត្រាចារ្យ ២.៧៤០ នាក់ មានបណ្ឌិត ១៨ អង្គ មានអ្នកប្រាជ្ញ និង បញ្ញាជន ៣៨៥.៧៣៧ នាក់ ។

ប្រាសាទទាំងឡាយសុទ្ធតែជាកន្លែង សក្ការៈបូជា ជាកន្លែងតម្កល់ឯកសារ សំខាន់ៗ ប្រាសាទណាក៏មានបណ្ណាល័យដែរ ។ ជាន់នីមួយៗសុទ្ធតែមានបណ្ណាល័យ ប្រាសាទទាំងឡាយនោះ ជាកន្លែងសិក្សារៀនសូត្រ ស្រាវជ្រាវផ្តល់ចំណេះដឹង ផ្តល់បទពិសោធន៍ឱ្យគ្នាទៅវិញទៅមក *ជាកន្លែងផ្តល់កំណើត ឱ្យអ្នកដទៃ កើត* ។

ភូមិ ឃុំ ស្រុកដាច់ស្រយាល ឬ ខេត្តនានា អាចមកយោងយកកំណើត ពីប្រាសាទទាំងឡាយ ហើយធ្វើខ្លួនឱ្យលូតលាស់រីកចម្រើនស្មើៗគ្នា ហេតុនេះបាន ជាយើងឃើញមានប្រាសាទស្ទើរគ្រប់ខេត្តនៅ ទូទាំងប្រទេស ។ នេះជាភស្តុតាង បញ្ជាក់ថា ប្រទេសមួយលូតលាស់ ហើយមិនមែនលូតលាស់នៅតែទីក្រុងនោះទេ ។

*២ - ចរន្តវប្បធម៌ប្រជាជន* (Courant populaire)

ប្រទេសជាតិ ទោះបីស្ថិតនៅក្នុងកាលៈទេសៈណាក៏ដោយ ក៏ប្រាសាទ និង វត្ត នៅតែមានតួនាទីជាមជ្ឈមណ្ឌលវប្បធម៌ដដែល ហើយមានភារកិច្ចបន្តថែរក្សា ផ្សព្វផ្សាយ និង ធ្វើឱ្យរីកចម្រើនតទៅមុខជានិច្ច ឱ្យតែព្រលឹងជាតិនៅមានកម្លាំង អត្តសញ្ញាណជាតិនៅច្បាស់លាស់ ។

ឯកសារចិន សិលាចារឹកវ៉ូកាញ់ សិលាចារឹកតាព្រហ្ម (ទន្លេបាទី ) បាន បញ្ជាក់ថា ព្រះពុទ្ធសាសនា (ថេរវាទ) បានត្រូវប្រជាជន គេគោរព រាប់អាន តាំងពីសតវត្សទី ៦ នៃ គ.ស មកម្ល៉េះ ។

- មានពេលខ្លះវត្តមួយសម្រាប់ប្រជាជន ៨០០ នាក់
- មានពេលខ្លះ ព្រះសង្ឃមួយអង្គ សម្រាប់ប្រជាជន ៦៦ នាក់

ឆ្នាំ ១៩១៦ មានវត្ត ២.៩០៥

ឆ្នាំ ១៩៦៩ មានវត្ត ៣.៣៦៩ = វត្តមួយសម្រាប់ប្រជាជន ១.៧៨០ នាក់ ព្រះសង្ឃមួយអង្គសម្រាប់ប្រជាជន ៩២ នាក់ ។

- ឆ្នាំ ១៩៩៤ មានវត្ត ៣.០៨៧ វត្តមួយសម្រាប់ប្រជាជន ២.២៦៧ នាក់
- មានព្រះសង្ឃ ២៧. ៩៣៩ អង្គព្រះសង្ឃមួយអង្គ សម្រាប់ ប្រជាជន ៤៥៤ នាក់

ហេតុដូចម្តេច បានជាប្រាសាទ វត្ត ព្រះសង្ឃច្រើនម្ល៉េះ ?

អ្នកខ្លះទៀតសួរថា នៅមានការលំបាក (នៅក្នុងជំរុំភៀសសឹក ) ជីវភាព បច្ចុប្បន្នមានភាពស្មុគស្មាញ ហេតុដូចម្តេចបានជាទាមទារឱ្យបង្កើត វត្ត កសាងព្រះវិហារ ច្រើនជាងកសាងមន្ទីរពេទ្យ និងសាលារៀន ?

ព្រោះប្រាសាទទាំងឡាយ ជាជីវិតខាងស្មារតីរបស់គេព្រោះ វត្ត ព្រះសង្ឃ ជា

ប្រភពនៃថាមពល ជាសេចក្ដីសង្ឃឹម និងជំនឿនៃជីវិតរបស់គេ ។

ព្រោះគេយល់ថា ឋានសួគ៌ និងឋានមនុស្ស នៅមិនឃ្លាតឆ្ងាយពីគ្នាឡើយ ។

- ធ្វើមនុស្សឱ្យទៅជា ទេវៈ (Diviniser les hommes )

- ធ្វើទេវៈឱ្យមកជាមនុស្ស ( Humaniser les dieux )

## II- តួនាទីវប្បធម៌របស់វត្តនិងព្រះសង្ឃ :

### *១ - តួនាទីវប្បធម៌របស់ព្រះសង្ឃ និងវត្ត :*

វត្តទាំងឡាយ ព្រះសង្ឃគ្រប់អង្គមានតួនាទី និងភារកិច្ចជួយបន្ដុមតិក វប្បធម៌តាំងពីសម័យបុរាណកាលមក នៅពេលរុងរឿង ក៏ដូចជានៅពេលអន់ថយ ។ វត្ត និងព្រះសង្ឃនៅតែឱ្យតម្លៃខ្ពស់ខាងស្មារតីរបស់មនុស្ស ខ្មែរនៅតែជឿថា ជ័យជំនះលើខ្លួនឯង ដោយខ្លួនឯង មិនមានកម្លាំងខាងក្រៅណា អាចធ្វើឱ្យប្រែក្រឡាស់ទៅជាបរាជ័យវិញបានឡើយ ។

ឧទាហរណ៍ : ប្រាសាទអង្គរវត្តមានរូបចម្លាក់ សមាធិ តាមព្រហ្មញ្ញសាសនា ជាច្រើន ។

នៅប្រាសាទបាយ័ន ព្រះខ័ន តាព្រហ្ម ក៏មានរូបចម្លាក់សមាធិបែបមហាយានជាច្រើនដែរ ។

នៅសម័យលង្វែក សម័យឧដុង្គ ក៏មានវិធីធ្វើសមាធិតាមបែបហីនយានស្ទើរតែគ្រប់វត្តដែរ ។

ពេលណាក៏ដូចពេលណា ខ្មែរនៅតែគិតដល់ភាពថ្លៃថ្នូរ ភាពរុងរឿងម៉ឹងម៉ាត់ ម៉ត់ចត់មានគុណធម៌ មានឧត្តមគតិ មានវិជ្ជា ចង់ធ្វើអ្វី ក៏អាចធ្វើកើត និងស័ក្តិសមជាពូជ ឱ្យពូជកំណើតទៅអ្នកដទៃ តែឥឡូវនេះបែរទៅជាអ្នកយោងយកកំណើតយកភព ពីអ្នកដទៃទៅវិញ ។

២ - វត្តជាស្រែបុណ្យ វត្តជាថ្នាលដ៏ល្អ វត្តជាផ្លូវកែងសំរាប់មនុស្ស សត្វ ជ្រើសរើសផ្លូវជីវិតរបស់ខ្លួន ( ផ្លូវបុណ្យ ផ្លូវបាប ពូជកុសល ពូជអកុសល ល្អ អាក្រក់ ។ល។ )

វត្តជាមជ្ឈមណ្ឌលពិសោធន៍ សំរាប់មនុស្ស សត្វ ជ្រើសរើសរកភព ។

៣ - វត្តជាសាលារៀនមូលដ្ឋានបំផុត ប្រសិទ្ធិភាពខ្ពស់បំផុត ក្នុងការកំចាត់គ្រោះមិនចេះអក្សរ និងគ្រោះអវិជ្ជា :

- អវិជ្ជា ជាសត្រូវនៃជីវិត
- អវិជ្ជា ជាហេតុនៃទុក្ខទាំងឡាយ
- អវិជ្ជា ជាសត្រូវរបស់បញ្ញា

៤ - វត្តជាសាលារៀន ឱ្យចេះរស់ មានវិជ្ជាជីវិត និងវិជ្ជាជីវៈ ចេះអត់ធ្មត់ ស៊ូទ្រាំ ព្យាយាម ខន្តី ទ្រាំទ្រការលំបាកសព្វបែបយ៉ាងក្នុងជីវិត ។ ឈ្លាសវៃប៉ិនប្រសប់ ស្គាល់ប្រយោជន៍ ដឹងសេចក្ដីសុខរបស់ខ្លួន និងអ្នកដទៃ ។

- មិនសុទិដ្ឋិនិយម ពេលជួបការសប្បាយ
- មិនទុទិដ្ឋិនិយម ពេលជួបការលំបាក

សាលាវត្ត អប់រំបានអ្នកស្នេហាជាតិច្រើនណាស់ និងអ្នកទទួលជ័យជំនះក្នុងជីវិតច្រើនណាស់ដែរ ។

*៥ - វត្តជាឃ្លាំងអក្សរសាស្ត្រ អក្សរសិល្ប៍ :*

របៀបសរសេរកាព្យ មាន ៥៣ ( រកឃើញ ៤៨ ខ្វះ ៥ )

របៀបសូត្រកំណាព្យ មាន ៦០ ( រកឃើញ ៤៨ ខ្វះ ១២ )

ឧទាហរណ៍ : អ្នកកវី អ្នកនិពន្ធជាច្រើនបានប្រសូត្រចេញពីវត្ត ដូចជា :

១ - ព្រះនាងឥន្ទ្រទេវី នៅសម័យអង្គរ ( សតវត្សទី ១២ )

២ - បណ្ឌិតជ័យនន្ទ ( សិលាចារឹកនគរវត្ត )

៣ - អ្នកប៉ាង (ល្បើកអង្គរវត្ត )

៤ - ព្រះឃ្លាំងនង ( លោកនេយ្យជាតក )

៥ - ម៉ឺនភក្តីអក្សរតន់ ( រឿងសព្វសិទ្ធ )

៦ - ព្រះអរិយគាមនី ហ៊ីង ( រឿងព្រះជិនវង្ស )

៧ - សន្ធរម៉ុក ( រឿងទេវទត្ត )

៨ - ព្រះបទុមថេរសោម ( រឿងទុំទាវ )

៩ - សុតន្តប្រីជាឥន្ទ ( គតិលោក និរាសនគរវត្ត )

១០ - អ្នកព្រះភិរម្យភាសាអ៊ូ ហៅ ង៉ុយ ( ច្បាប់ល្បើកថ្មី )

១១ - សម្តេចព្រះសង្ឃរាជ ជួន ណាត ជោតញ្ញាណោ( វចនានុក្រមខ្មែរ ) ។ល។

ដូចនេះយើងឃើញថា វត្តអារាមនេះហើយ ជាកន្លែងថែរក្សា ទ្រទ្រង់វប្បធម៌ខ្មែរឱ្យបានគង់វង្ស និងរីកចម្រើនរហូតមក ។

*៦ - វត្តជាស្ពានតភ្ជាប់បច្ចុប្បន្ន អតីតៈ និងអនាគត :*

- តភ្ជាប់ឋានកណ្តាល ឋានក្រោម និង ឋានលើ

- ពេលកើត ពេលបួស ពេលរៀបការ ពេលឈឺ និងពេលស្លាប់ទៅវិញ ប្រជាជនសុទ្ធតែត្រូវការវត្ត និងព្រះសង្ឃ ព្រោះប្រជាជនយល់ថាសុខ ទុក្ខទាំងឡាយ ពេលខ្លះយើងមិនអាចម្ចាស់ការបានឡើយត្រូវពឹងកម្លាំងខាងក្រៅ និងកម្លាំងខាងក្នុង បូកបញ្ចូលគ្នា ទើបឈ្នះលើអសីលធម៌ខាងក្រៅ និងអសីលធម៌ខាងក្នុង ។

*៧ - វត្តជាសារៈមន្ទីរសិល្បៈ*

- ក្បួនខ្នាត គំនូរ ចម្លាក់ តន្ត្រី ចម្រៀង សំណង់ក្បូរក្បាច់ ទាំងឡាយ ត្រូវបានថែរក្សាក្នុងវត្ត

- សំណង់ទាំងឡាយក្នុងវត្ត ការតុបតែង រៀបចំលំអរចនា ពណ៌សម្បុរទាំងឡាយនៅក្នុងវត្តច្រើនតែរក្សាបាន តំណាងបាន ឱ្យអ្វីដែលជាចរិតជាតិ ជាពណ៌សម្បុរជាតិ និង ជាអត្តសញ្ញាណជាតិ ។

*៨ - វត្តជាមជ្ឈមណ្ឌលកែប្រែ និងអប់រំមនុស្ស :*

មនុស្សគ្រប់វ័យ ប្រជាជនគ្រប់ប្រភេទ :

មនុស្សប្រមឹក មនុស្សពាល រហូតដល់ឧក្រិដ្ឋជន នៅក្នុងភូមិចំណុះជើងវត្តត្រូវបានទទួលការអប់រំ និងកែប្រែ ឬផ្លាស់ប្តូរ ដោយសារចៅអធិការវត្ត គ្រូសូត្រឆ្វេង ស្តាំ ដែលធ្លាប់មានឥទ្ធិពលខ្លាំង តាំងពីជីដូនជីតា រហូតដល់កូនចៅ ។ ព្រះសង្ឃទាំងអស់នោះ តំណាងឱ្យភាពបរិសុទ្ធ តំណាងគុណធម៌ និងសីលធម៌ព្រះពុទ្ធ តំណាងសច្ចធម៌ ព្រមទាំងតំណាងឱ្យយុត្តិធម៌ក្នុងលោកនេះ ទើបអាចធ្វើឱ្យជនមានកំហុសទាំងនោះកែប្រែខ្លួនឯង ដោយខ្លួនឯង ដោយមិនចាំបាច់ប្រើហិង្សា និងការចាប់បង្ខំទាំងឡាយជាតំនាបឡើយ ។

*៩ - វត្តជាមុខតំណវប្បធម៌ពីអតីត: បច្ចុប្បន្ន និងទៅអនាគត :*

និយមន័យ ទីតាំង មុខងារ ភារកិច្ចនៃវប្បធម៌ សិល្បៈ ត្រូវបានបន្តតាំងពីសម័យអង្គរ មកដល់សព្វថ្ងៃនេះ ហើយនឹងបន្តទៅអនាគតទៅទៀត ។

ឧទាហរណ៍:

ស្នាដៃសិល្បៈនាសម័យអង្គរ ក៏ដូចជាស្នាដៃសិល្បៈក្រោយៗមក សុទ្ធតែបានបញ្ជាក់ពីជ័យជំនះដោយហត្ថពលកម្ម និងបញ្ញាពលកម្មរបស់មនុស្សលើអវិជ្ជាលើភាពអន្ធការ លើធម្មជាតិ ពិសេសលើចំណុចខ្សោយរបស់មនុស្សដោយខ្លួនឯង ។

ទីតាំងនៃវប្បធម៌ វប្បធម៌ជាការងារដោយផ្ទាល់ រវាងមនុស្ស និងខ្លួនឯង រវាងមនុស្ស និងមនុស្ស មនុស្ស និងធម្មជាតិ ពិសេសគឺមនុស្ស និងវាសនាអនាគត

របស់មនុស្ស ។

១០ - *វត្តជាឡ ជាត្បាល់កិន :*

- វត្តស្ល អត្តនោម័ត ឱ្យស្របនឹងសត្យានុម័ត

- វត្តប្រែក្លាយគំនិតមនុស្ស ទ្រឹស្តីរបស់មនុស្ស ឱ្យក្លាយទៅជាការជាក់ស្តែង ទៅជាប្រាកដនិយម ជីវិតនិយម បច្ចុប្បន្ននិយម ។

- វត្តជួយបណ្តុះបញ្ញាមនុស្ស ហើយនឹងយកបញ្ញាធ្វើជាប្រទីប ដើម្បីដើរឆ្លងអន្តរកាលនៃជីវិត ។

III - **តួនាទីសង្គមរបស់វត្តនិងព្រះសង្ឃ :**

*១ - តួនាទីសេដ្ឋកិច្ច :*

វត្តទាំងឡាយ ព្រះសង្ឃគ្រប់ព្រះអង្គ ត្រូវបានទទួលការឧបត្ថម្ភសព្វបែបយ៉ាងពីប្រជាជន ប្រជាជនជាអ្នកកសាងវត្ត ប្រជាជនជាអ្នកចិញ្ចឹមព្រះសង្ឃ ហេតុនេះវត្ត និង ព្រះសង្ឃត្រូវតែធ្វើយ៉ាងណាឱ្យមានប្រយោជន៍ ដល់ប្រជាជន ជីវភាពប្រជាជនកាន់តែរីកចម្រើន វត្តនិងព្រះសង្ឃ ក៏រីកចម្រើនដែរ បើវត្តនិងព្រះសង្ឃមានសេចក្តីសុខស្ងប់នោះប្រជាជនក៏បានសេចក្តីសុខស្ងប់ដែរ ហេតុនេះ ព្រះសង្ឃប្រមូលជំនឿប្រជាជន មកជីកស្រះ លើកផ្លូវ ជីកអណ្តូងធ្វើប្រឡាយ ធ្វើប្រព័ន្ធធារាសាស្ត្រ សង់សាលា សង់មន្ទីរពេទ្យ សង់សាលាសំណាក់ សាលាឆទាន ធ្វើឱ្យមានតុល្យភាពរវាងសេចក្តីត្រូវការ ខាងសម្ភារៈនិងស្មារតីរបស់អ្នកស្រុកភូមិ ។

២ - វត្តជាមន្ទីរពេទ្យ ព្យាបាលខាងផ្លូវកាយ តាមវិធីឱសថបុរាណ និងតាមផ្លូវធម៌ដទៃទៀត ដែលអាចធ្វើឱ្យអ្នកជំងឺបានធូរស្រាលពីការភ័យព្រួយ ។ វត្តទាំងឡាយរមែងមានកន្លែងអ្នកជំងឺស្នាក់នៅសម្រាប់ព្យាបាលជំងឺដោយមិនគិតតម្លៃ ហើយក៏មានព្រះសង្ឃជំនាញខាងឱសថបុរាណ និងព្យាបាលជំងឺតាមវិធីពេទ្យបុរាណ ។

៣ - វត្ត និងព្រះសង្ឃ ជាមន្ទីរពេទ្យព្យាបាលជំងឺខាងផ្លូវចិត្តរបស់ប្រជាជន នៅពេលដែលជីវិតប្រព្រឹត្តទៅជួបនឹងផលវិបាក អស់សេចក្ដីសង្ឃឹម បាត់ជំនឿ អស់ទីពឹង ច្រើនតែរត់ទៅវត្ត ។ ព្រះសង្ឃទេសនាទូន្មានប្រដៅពីហេតុផលពីបច្ច័យដែលនាំឱ្យកើតទុក្ខ និងបង្ហាញនូវផ្លូវដែលអាចរំលត់ទុក្ខតាមផ្លូវធម៌ ធ្វើឱ្យចិត្តស្ងប់រម្ងាប់ និងកើតសេចក្ដីសង្ឃឹមចង់រស់តទៅទៀត ។

៤ - វត្តជាជម្រករបស់ជនកំសត់ ទុគ៌ត ជនក្រីក្រ ឥតទីពឹង កូនអ្នកក្រទាំងនៅទីក្រុង ទាំងនៅជនបទ អាចទៅជ្រកនឹងវត្តបាន ដើម្បីបន្តវិជ្ជាទៅមុខទៀត ។ មនុស្សចាស់ជរាឥតទីពឹង គ្មានផ្ទះស្នាក់នៅ គ្មានគ្រួសារ គ្មានញាតិមិត្ត ក៏រត់ទៅពឹងវត្ត និងព្រះសង្ឃដែរ ។ អ្នកដំណើរចុះឡើងខកខានពេលវេលា ក៏អាចទៅសុំស្នាក់នៅ សុំការជួយឧបត្ថម្ភពីវត្ត និងព្រះសង្ឃដែរ ។

*៥ - វត្តជាមជ្ឈមណ្ឌលទំនាក់ទំនង និងផ្សព្វផ្សាយ :*

ទំនាក់ទំនងសមរម្យរវាងមនុស្ស និងមនុស្សខ្លួនឯង មនុស្សនិងអ្នកដទៃ រវាងមនុស្ស សត្វ និងធម្មជាតិ ។

មនុស្សទាំងឡាយ សត្វទាំងឡាយ និងរុក្ខជាតិទាំងឡាយ អាចរកសេចក្ដីសុខបាននៅក្នុងវត្ត ព្រោះវត្តហាមសម្លាប់សត្វ ហាមកាប់ឈើ ហាមធ្វើបាបមនុស្ស សត្វ និង ឆក់ លួច ប្លន់ អ្នកដទៃ ។

រាល់ថ្ងៃសីលមនុស្សទាំងឡាយច្រើនជួបជុំគ្នានៅឯវត្ត ដំណឹងទាំងឡាយទាំងអាក្រក់ ទាំងល្អតែងតែ ផ្សព្វផ្សាយយ៉ាងរហ័សបំផុត រវាងមនុស្សនិងមនុស្សរហូតដល់មនុស្ស និងអមនុស្ស មានប្រេត អសុរកាយ និងទេវតា ជាដើម ។

*៦ - វត្តជាគ្រឹះ នៃសាមគ្គីធម៌ របស់ប្រជាជន :*

ប្រជាជនទាំងឡាយ មានជំនឿលើព្រះសង្ឃ និងវត្ត ទុកចិត្តព្រះសង្ឃព្រម

សារទុក្ខ ទទួលកំហុស កប់ចោលគំនុំ លះបង់ការប្រកាន់ទាំងឡាយ កំចាត់ក្ដីក្រោធខឹង ព្រមព្រៀងរស់ជាមួយគ្នាដោយចិត្តសន្ដោស អធ្យាស្រ័យគ្នាទៅវិញទៅមក ។

*៧ - វត្ត និងព្រះសង្ឃ ជាប្រភពនៃសមភាពធម៌ :*

ព្រះសង្ឃដែលពោរពេញទៅដោយទសពិធរាជធម៌ ព្រហ្មវិហារធម៌ ប្រាសចាកលោកធម៌ និងអគតិធម៌រមែងជាគ្រឹះនៃសាមគ្គីធម៌ និងសមភាពធម៌ លើកលែងកំហុសគ្នាទៅវិញទៅមក លែងប្រកាន់វណ្ណៈ លែងប្រកាន់ឋានៈសង្រ្គោះធម៌កើត សង្គហធម៌កើត ព្រោះមេត្តាធម៌កើត ។

*៨ - វត្តជាប្រភពនៃសេរីភាព និងសិទ្ធិរស់នៅរបស់មនុស្ស សត្វទាំងឡាយ :*

- បាណាតិបាត : ជាច្បាប់ការពារ និងសិទ្ធិរស់នៅរបស់មនុស្សសត្វ
- អទិន្នាទាន : ជាច្បាប់ការពារសិទ្ធិ រក្សាទ្រព្យសម្បត្តិដោយសមស្រប
- កាមេសុមិច្ឆាចារ : ជាច្បាប់ការពារសិទ្ធិរស់នៅដោយសមរម្យខាងភេទ ។

*៩ - វត្តជាតុលាការយុត្តិធម៌បំផុត :*

ច្បាប់កម្មផលរបស់ព្រះពុទ្ធ យុត្តិធម៌បំផុត សូម្បីតែព្រះពុទ្ធអង្គឯង ក៏ច្បាប់មិនលើកលែងឱ្យដែរ ។

ច្បាប់ចរិយាធម៌ សីលធម៌ ធ្វើឱ្យមនុស្សគ្រប់រូបព្រមទទួលដោយរីករាយ ហើយនិងព្រមទទួលកែប្រែកំហុសដោយស្ម័គ្រចិត្ត ។

១០ - វត្តនិងព្រះសង្ឃ ជារចនាសម្ពន្ធ័ គ្រប់គ្រងមនុស្សខាងផ្លូវចិត្ត ផ្លូវស្មារតី តុល្យភាពសមរម្យរវាង កាយ និង ចិត្ត និង បញ្ញា មនុស្ស និង មនុស្ស និងសង្គមមនុស្ស និងធម្មជាតិ ?

**IV - សភាពការណ៍ខប្បធម៌បច្ចុប្បន្ន :**

អស់លោក អ្នកនាង ធ្លាប់បានស្ដាប់អ្នកប្រាជ្ញជាតិ និង អន្តរជាតិ ព្រមទាំង

អ្នកប្រាជ្ញជប៉ុន បានបញ្ជាក់ពីមូលហេតុ នៃការលូតលាស់ ការកើតឡើងការរីកចម្រើន និងការវិនាសចុះអន់ថយនៃអរិយធម៌អង្គរ ហើយអស់លោក អ្នកនាងក៏បានស្ដាប់ហើយដែរ បានយល់ច្រើនពីចរន្តបញ្ញាជន របស់សិល្បៈវប្បធម៌ខ្មែរ តាមឯកសារឯទៀតៗជាច្រើន ពេលនេះខ្ញុំបានយកឯកសារសាកល្បងស្រាវជ្រាវមួយស្ដីពីរចនាសម្ព័ន្ធ ប្រព័ន្ធចាត់តាំងគ្រប់គ្រង វប្បធម៌ មហាជនដោយប្រជាជនខ្លួនឯង ឯកសារនេះ ក៏បានបញ្ជាក់ពីតួនាទី ភារកិច្ចសង្គមធម៌ និង វប្បធម៌របស់វត្ត និងព្រះសង្ឃដាក់ជូនដើម្បីជួយពិភាក្សា ពិចារណាថា តើចរន្តបញ្ញាជន និងចរន្តប្រជាជនពិតជាជើងស្ដាំ ជាជើងឆ្វេង នៃដំណើរលូតលាស់ របស់អរិយធម៌មួយមែន ឬទេ ? ។

ក្រោយពីបាត់បង់បន្ទាយលង្វែកមក នៅចុងសតវត្សទី ១៦ គឺជាការបាត់បង់ឃ្លាំងចុងក្រោយនៃមរតកអង្គរ ?

អ្នកប្រាជ្ញ កវី អ្នកនិពន្ធ សិល្បករ ចំណានៗ នៅជុំវិញស្ដេចក្នុងចរន្តបញ្ញាជនធុញទ្រាន់នឹងសង្គ្រាម ក៏រត់ទៅជ្រកកោន នឹងចរន្តប្រជាជន គឺវត្តទាំងឡាយនោះហើយ ដែលធ្វើឱ្យចលនាវប្បធម៌ប្រជាជន មានកម្លាំងរីកចម្រើនមួយរយៈក្នុងសម័យឧត្តុង្គ នៃរជ្ជកាលព្រះបាទអង្គឌួង ( ១៨៤០ ដល់ ១៨៥៩ ) ។

ទោះបីមានសង្គ្រាមឈ្លានពានពីក្រៅ ឬសង្គ្រាមផ្ទៃក្នុងក៏ដោយ ចរន្តវប្បធម៌ប្រជាជន មិនមានការប៉ះពាល់ខូចខាតច្រើនឡើយ ទើបតែពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩ របបខ្មែរក្រហមបានគាស់រំលើងឫសគល់នៃចរន្តវប្បធម៌ប្រជាជន គឺបំផ្លាញវត្តអារាមសម្លាប់ព្រះសង្ឃ អ្នកប្រាជ្ញ កវីនិពន្ធ សិល្បករប្រជាប្រិយស្ទើរទាំងអស់ ធ្វើឱ្យចលនាវប្បធម៌ធ្លាក់ខ្លួនពិការជើងទាំងពីររហូតដល់សព្វថ្ងៃនេះ ។

សង្គ្រាមគឺវិនាសកម្ម សង្គ្រាមគឺហិង្សា សង្គ្រាមគឺអមនុស្សធម៌ អសីលធម៌ គឺជាការផ្ទុយស្រឡះពីការងារវប្បធម៌ និងសីលធម៌ ។

សង្គ្រាមជាង ២០ ឆ្នាំ ចុងក្រោយនេះ បានបន្សល់នូវវិបត្តិជាច្រើនដល់សង្គមខ្មែរ ។

ឧទាហរណ៍ : វិបត្តិសីលធម៌ វិបត្តិកាមគុណ វិបត្តិគតិបណ្ឌិត និងការយល់ដឹង វិបត្តិក្នុងការរស់នៅ វិបត្តិការងារ វិបត្តិវប្បធម៌ ខ្វះគុល្យភាពរវាងសេចក្តីត្រូវការខាងសម្ភារៈ និងស្មារតី ។

V - **ទិសដៅទៅអនាគត :**

នៅពេលដែលយើងដឹងថា ចរន្តវប្បធម៌ទាំងពីរ (ជើងស្តាំ ជើងឆ្វេង) មានសារសំខាន់ចាំបាច់ចំពោះជីវិតរស់នៅរបស់ខ្មែរដូចជា ជើងទាំងពីរដែលធ្វើឱ្យរូបរាងកាយរបស់យើងមានលំនឹងនៅពេល ដែលដងខ្លួនធ្វើដំណើរទៅមុខ ។

បើចង់ឱ្យប្រជាជាតិមួយ បុគ្គលម្នាក់ងើបពីភាពទន់ខ្សោយ និងការភ័យព្រួយតក់ស្លុត បាត់ការចងចាំ ថាខ្លួនជាអ្នកណា ហើយមកពីណា កំពុងតែធ្វើអ្វី ត្រូវធ្វើអ្វី ដើម្បីអ្វី គ្រូពេទ្យ និងអ្នកជំងឺបែបនេះត្រូវស្មោះត្រង់ជិតស្និទ្ធ ស្មោះស្មគ្រ ព្រមព្រៀងថា នឹងប្រឹងប្រែងវះកាត់ជំងឺនេះ ឱ្យបានជាសះស្បើយ ។

១ - ស្រាវជ្រាវឱ្យដឹងច្បាស់លាស់ តើប្រជាជាតិនេះ ពីដើមមក ធ្លាប់មានអ្វីខ្លះ ហើយត្រូវការអ្វីខ្លះ ជាចាំបាច់ក្នុងជីវិត ទាំងតម្រូវការ សម្ភារៈ និងស្មារតី ហើយឥឡូវនេះបាត់បង់អ្វីខ្លះ នៅសល់អ្វីខ្លះ គួរធ្វើអ្វីមុន ទុកអ្វីសិន ដូចជាជំងឺស្មុគ្រស្មាញមួយ ដែលមានមេរោគចម្រុះ តើត្រូវប្រើថ្នាំណាមុន សម្រាប់សម្លាប់មេរោគណាមុន ។

២ - សិក្សាចងក្រង ថែរក្សារទុកតាមគ្រប់វិធី និងគ្រប់មធ្យោបាយ នូវមរតកវប្បធម៌ទាំងឡាយ ដែលបានបាត់បង់ទៅ និងស្ថិតគង់នៅ ។

៣ - រកឱ្យឃើញនូវតម្លៃពិត ទាំងតម្លៃសោភណ័ភាព រូបភាព និង

បច្ចេកទេស ទាំងតម្លៃខាងសារៈខាងស្មារតី ខាងគុណធម៌ និងសីលធម៌ ។

៤ - ធ្វើឱ្យរស់ឡើងវិញ នូវអ្វីៗដែលចាំបាច់ចំពោះជីវិត ធ្វើឱ្យជីវិតមានលំនឹង មានតុល្យភាព មានភាពសមរម្យ ប្រព្រឹត្តទៅធូរស្រាល មិនស្មុគ្រស្មាញ មិនតានតឹង ធ្វើឱ្យការថែរក្សាទាំងឡាយ នៅតែមានប្រយោជន៍ដល់ជីវិតរស់នៅប្រចាំថ្ងៃ ។

៥ - ការសាកល្បងអភិវឌ្ឍន៍ថ្មី គឺវប្បធម៌ថ្មី លើខឿនវប្បធម៌ចាស់ ការរៀនសូត្រពីបរទេសទាំងឡាយគឺសម្រាប់បំពេញនូវការខ្វះខាត ដែលជាចំណុចអន់ថយទាំងឡាយរបស់ខ្លួន និងជាជំនួយដល់ការលូតលាស់នៃចរិតជាតិ និងពណ៌សម្បុរជាតិ ។

VI - **ការសន្និដ្ឋាន :**

អ្វីដែលប្រជាជនខ្មែរចង់បានឱ្យវប្បធម៌ជួយបំពេញនោះគឺ :

១ - សច្ចៈទៀងត្រង់ ( សច្ចៈទាំង ៦ ) យ៉ាងណា យ៉ាងហ្នឹង ប៉ុនណា ប៉ុនហ្នឹង ។

២ - ភាពប្រាកដនិយម ( ថ្ងៃនេះ ពេលនេះ ទីនេះ ជាតិនេះ )

៣ - ភាពយុត្តិធម៌ ( វៀរចាក អគតិទាំង ៤ )

៤ - សង្គម យោគយល់គ្នាទៅវិញទៅមក ( ព្រហ្មវិហារធម៌ ៤)

៥ - ជួយសង្គ្រោះគ្នាទៅវិញទៅមក ( សង្គហៈធម៌ )

៦ - ចង់បានស្ងប់ក្នុង ស្ងប់ក្រៅ ( សមាធិ )

៧ - ចង់បានសុខកាយ សុខចិត្ត ( វិបស្សនា )

៨ - ចង់បានការធានារ៉ាប់រងទាំងផ្លូវកាយ និងផ្លូវចិត្ត ( ច្បាប់ )

៩ - ចង់បានវប្បធម៌ និងសង្គមធម៌ ( លូតលាស់ ដែលមានតុល្យភាព )

១០ - ចង់បានរស់នៅក្នុងធម៌ ចៀសវាងអធម៌ ( សុខរហូតដល់ព្រះនិញ្វាន ) ។

# ព្រះវិហារ វាសនាខ្មែរ

ដោយ : **នុត ណារ៉ាង**

១ ~ នគរគោកធ្លកចាប់ពន្លកក្នុងចុងជ្រោយឥណ្ឌូចិន ត្រង់តំបន់អាសន្ន ធម្មជាតិពីយូរលង់ទម្រង់ជាឈូងសមុទ្រចាស់មួយ ។ ទឹកខះរីងស្ងួតហួតហែងបន្តិចម្តងៗ រយពាន់ឆ្នាំកន្លងទៅ នៅសល់ជាសំណាក សំណល់ ដល់សព្វថ្ងៃ គឺដងទន្លេសាប ឈូងទ្រនាបទ្រនាប់ស្រុកខ្មែររាល់ថ្ងៃនេះឯង ។ ឯច្រាំងសមុទ្រចាស់ ក៏ផ្លាស់រាងទៅជាជួរភ្នំដងរែក ចែកតំបន់ភូមិសាស្ត្រជាពីរផ្នែកធំៗ :

- ទឹកសមុទ្រគោកអស់ ដោយអំណាចភុជង្គនាគ ក៏ក្លាយទៅជាវាលទំនាប រៀបជាថ្នាលប្រទេសខ្មែរខាងត្បូង ។

- រីឯច្រាំងសមុទ្រ ក៏ក្លាយទៅជាខ្ពង់រាប រៀបរាលដល់ទន្លេមេណាម ទន្លេសាលូអង់ខាងលិច និងជួរភ្នំព្រំប្រទល់ចិនខាងជើង ។ ទីនេះហើយជាតំបន់ដីគោកនៃស្រុកខ្មែរ ។

២ ~ តំបន់ទាំងពីរ ជើង ត្បូង យោងគ្នាទៅវិញទៅមកដូចទឹកនិងដី ស្រីនិងប្រុស ផុសចេញពីយូរលង់ ទ្រទ្រង់មនុស្សម្នាចងជាក្រុមគ្រួសារ ស្ថាបនាសង្គមតាមដំណើរអាកាសធាតុ ទឹក ដី បង្កជាស្រុកមួយ ប្រកបដោយលក្ខណៈជាក់ស្តែងចែងជាខ្នាត បាតសង្គម ដឹកនាំដំណើររបស់ខ្លួនពីដំណាក់កាលមួយទៅដំណាក់កាលមួយ តាមបែបបទកំណត់ដោយទេពកោសល្យរបស់ខ្លួន ។ ស្រុកខ្មែរ មេ និង បា អ្នកតា ចាស់ស្រុក សុទ្ធសឹង ជាជំហរគ្រឹះ ឬសកែវជាតិ ណែនាំការរៀបចំទឹកដី គំនិតចរិតមនុស្សម្នា តាំងជាគន្លងទំនៀមទម្លាប់ភ្ជាប់ជំនាន់ បណ្តាលឱ្យកសាងបាននូវ

អារ្យធម៌ ដ៏បវរ ល្អខ្ពស់ ក្លាយទៅជាមហានគរ ខ្មែរវទ្ធី ពូជាងគេ ចាប់តាំងពីសតវត្ស ទី ៩ មកៈ សម័យដ៏អស្ចារ្យវិសេសវិសាលនេះ ទៅជាមរតកសម្បត្តិ សម្បើមរបស់ មនុស្សលោកសព្វថ្ងៃនោះ គឺសម័យអង្គរនេះឯង ។

៣ ‑ ចាប់ពីសតវត្សទី ៩ មកៈ សម័យអង្គរ ! អង្គរខ្មែរក្នុងលោក ស្រុក ខ្មែរក៏មានឫទ្ធិឥទ្ធិពលជះពេញលើដីទំនាបជ្រាបទៅដល់តំបន់ខ្ពង់រាប រៀបជាអង្គភាព មួយ ចុងជ្រោយអាស៊ីអាគ្នេយ៍ដីគោក មានអំណាចកិត្តិយសខ្ពស់ត្រដែតក្នុងលោក ទាំងសាកល ។

៤ ‑ *អង្គរ* បន្ត *ចេនឡា* ។ វាសនាខ្មែរបានខ្ពស់ ដល់កំពូល ទាំងសេដ្ឋកិច្ច ទាំងនយោបាយ ទាំងមនោគមវិជ្ជា រចនាសម្ព័ន្ធមួយដោយឡែក ផ្អែកលើជំហរ *ទេវរាជ* មនុស្សម្នាខ្ជាប់ខ្ជួន *អំណាច សម្ភារៈ* ឆ្លាក់ឡើងជាប្រាសាទវិហារធំធេង តាក់តែងជាក្បាច់រចនាប្រណីតមួយឥតខ្ចោះគ្មានពីរ ផ្សំគ្នាពីមួយទៅមួយដោយថ្ម ដាមហិមា សាងជាឋានសួគ៌លើលោកិយ ដើម្បីព្រះរាជាធានាជាវត្ថុសក្តិសិទ្ធ *ឫទ្ធិ អំណាចទិព្វ* ដោយគោរពជាក់លាក់ តាមលក្ខណៈភ្នំព្រះសុមេរុក្រុងខ្មែរ និមិត្តដោយ គូទឹកព័ទ្ធជុំវិញ ជា *ភ្នំប្រាសាទ* ខ្នាត *មេឃា* ជាទីសក្ការៈរៀងរហូតមក ។

៥ ‑ ដំណើរអង្គរនេះបានរៀបចំចាប់ពីព្រះបាទជ័យវរ្ម័ន ទី ២ នាឆ្នាំ ៨០២ ក្រោយពីព្រះអង្គបានរំដោះប្រទេសជាតិពីអាណានិគម ជំនាន់នោះពីប្រទេសជ្វា ហើយ ផ្សះផ្សាគ្រួសារខ្មែរបានក្លាយរលាយជាផ្លុងមួយ រៀបចំស្ថេរភាព សណ្តាប់ធ្នាប់ជាប់ លាប់ ហើយក៏រៀបចំអភិវឌ្ឍន៍សង្កត់លើទំនប់ ប្រឡាយ បារាយណ៍ធ្វេងស្តាំ ដំណាំ ដាំដុះ បំផុសសុភមង្គលដល់មនុស្សខ្មែរផងទាំងឡាយ ស្រុកក៏ក្លាយទៅ *មហានគរ* គំនរក្តីសុខនាំគ្នាសម្រុកស្ថាបនាសង្គមធំធេង ស្ញប់ស្ញែងពេញក្នុងលោកលើថ្មីដៃច្នៃ ប្រឌិត កិរិតខ្ពស់គ្របវិស័យសិល្បៈរូបចម្លាក់ ក្បូរក្បាច់រចនាសំណង់ ទម្រង់សាសនា

សាលារៀនសិល្បវិជ្ជា មានល្បឿនរីកចម្រើនខ្លាំងពន់ពេក បែកសុះសាយក្លាយជាមហាអំណាចក្នុងអាស៊ី ។

៦ ~ ព្រះរាជាសម័យនោះសុទ្ធសឹងជាក្សត្រ *វរ្ម័ន* ( Varman ) មានថ្វីដៃវិស័យខ្ពស់លើកកំពស់ប្រទេសជាតិ លាតសន្ធឹងធំអស្ចារ្យនាសម័យនោះ ។ ខាងជើងគឺទល់នឹងស្រុកចិន ខាងលិចទល់នឹងទន្លេសាល្វូអង់ ឯខាងកើតទល់នឹងស្រុកចាម ។ ព្រះរាជា និមួយៗ តែងតែមានស្នាដៃមួយប្រណីត និមិត្តដោយប្រាសាទភ្នំ មណ្ឌលនគរ ឈរ ជារាជធានី ទីសក្ការៈបញ្ជាក់នូវប្រភពថ្មីនៃចក្រវាលគ្រងរាជ្យ ។

៧ ~ ក្រោយពីសំបូរព្រៃគុហ៍ មណ្ឌលនគរក៏ឈរជាប់នៅតំបន់សៀមរាបរាជធានីចម្រុះពីលើគ្នា ពីជំនាន់មួយទៅជំនាន់មួយ តាំងជាស្ទូលប្រព័ន្ធប្រាសាទផ្សេងៗ នៅតាមខេត្ត ឬខ័ណ្ឌ ឬសីមា ស្ថាបនាជា របៀបរៀបចំដែនដីប្រសិទ្ធភាពលាតសន្ធឹងពោរពេញដោយឥទ្ធិពលគ្រប់វិស័យ ។

៨ ~ ក្នុងចំណោមប្រាសាទទាំងឡាយរាយប៉ាយសព្វថ្ងៃ ពាសពេញផ្ទៃដីអាស៊ីអាគ្នេយ៍ដីគោក ដែលបានសង់ឡើង ដើម្បីជាទីសក្ការៈផង និងនិមិត្តឫទ្ធិសង្គមផង មានជាអាទិ៍ ប្រាសាទភ្នំជីសូរ ភ្នំវត្តភូ ( លាវ ) ... ហើយជាពិសេសនោះគឺប្រាសាទព្រះវិហារ ដែលមានលក្ខណៈជាក់ស្ដែង កំណត់វាសនាខ្មែរ យើងសព្វថ្ងៃនេះឯង ។

៩ ~ ដូច្នេះយើងត្រូវដឹង និងយល់អំពីហេតុផល ដែលនាំឱ្យយើងមានវាសនា ធានារក្សាសង្គមជាតិមិនឃ្លាតពីឫស ហើយបន្តជាថាមពលផ្ដល់ឱ្យខ្មែរធ្វើការអភិវឌ្ឍន៍ ពង្រោះបន្តពូជពង្សជារៀងរហូត យើងបន្តវាសនានេះមិនឱ្យឃ្លាត ។ យ៉ាងណាមិញ ចំណី ចំណោះ ចំណូល ចូលមកបំប៉នដល់សាច់ឈាមខ្មែរសព្វថ្ងៃក៏មិនខុសពីបុព្វឡើយ កាលណាយើងរំលាយអាហារថ្មីថ្មោឱ្យទៅជាសារជាតិខ្លួនយើងបានល្អប្រពៃ ។

យើងនឹងមិនឆ្ងល់ឡើយ អំពីឥទ្ធិពលឥណ្ឌា លើបញ្ហានេះថា មានដំណើរយ៉ាងណា បានជាធ្វើឱ្យយើងខ្លាំងដល់ម្ល៉ឹង ។ យើងក៏មិនដឹងផងដែរថា ឥទ្ធិពលនេះលាតសន្ធឹងលើមនោគមន៍វិជ្ជា សាសនា ទស្សនៈវិជ្ជា អក្សរ ភាសា និងការរៀបចំស្រុកខ្មែរឱ្យមានប្រព័ន្ធនយោបាយ ក្លាយមកពីជំហរទេវរាជនៃព្រះរាជា ក្នុងលទ្ធិព្រហ្មញ្ញសាសនា មានជាអាទិ៍ គ្រូបាធ្យាយ ជាអាចារ្យ ឬព្រាហ្មណ៍បុរោហិតដែលជានិស្សិត ដែលបានទៅបំពេញវិជ្ជានាស្រុកក្លឹង្គ ឬមួយក៏មានជាតិឥណ្ឌាចូលមករស់ក្នុងស្រុកខ្មែរនេះដែរ បានចូលមកអប់រំពង្រីកធនធានមនុស្សខ្មែរឱ្យពង្រីកខ្លួនឯងផង ហើយឈានទៅរកការរីកចម្រើនថ្មីផង ។ អ្នកទាំងនោះមិនខុសពីសាស្ត្រាចារ្យ ដែលបានទៅរៀនឯបរទេសចេះ ហើយចូលមកផ្សព្វផ្សាយ បណ្តុះបណ្តាលក្នុងស្រុកវិញឡើយក្នុងសម័យកាលនិមួយៗ ។ ព្រាហ្មណ៍បុរោហិតស្ថិត ក្នុងព្រះនគរ ជំហរនយោបាយ សាសនា ធានាព្រះរាជាក្នុងការគ្រប់គ្រងប្រទេស មានងារពិសេសជា *ព្រះរាជគ្រូ* ។ យូរៗ អ្នកអស់នោះក៏តាំងជាវណ្ណៈថ្នាក់ដឹកនាំ មានអំណាចខ្លាំងក្លា អ្នករក្សាទម្លាប់ឥណ្ឌា សំដែងតែងជាជំហរទស្សនៈសិល្បៈ គោរពសក្ការៈលើលិង្គព្រះឥសូរ សូត្ររៀនតាមភាសាសំស្ក្រឹត ហើយសំអិតសំអាងតាំងឫទ្ធិជាព្រះគ្រូទីប្រឹក្សាចាស់ទុំ សាងសង់គម្រោងប្រាសាទធំៗ ល្អប្រណីត ចំណូលចិត្តថ្វាយ ព្រះរាជាដូចជាប្រាសាទអង្គរ បឹងមាលា បន្ទាយស្រី និងព្រះវិហារយើងនេះឯង ។

១០ ‐ ព្រះរាជគ្រូដ៏ល្បីម្នាក់ឈ្មោះ ទិវាករបណ្ឌិត តាំងពីជីតាព្រះបាទសូរិយាវរ្ម័នទី ២ រហូតមកដល់ព្រះអង្គនេះ ជាអ្នកស្ថាបនាបង្ហើយប្រាសាទព្រះវិហាររក្សាបានមកដល់រាល់ថ្ងៃនេះ ។ ឯប្រវត្តិសាស្ត្រ ក៏បានបញ្ជាក់ផងដែរថា ប្រាសាទនេះបានស្ថាបនាឡើងលើសំណង់ព្រះវិហារចាស់គោរពតេជៈព្រះសិវៈ ដាក់នាមជាស្រីសិខៈរេស្វរៈ " **អាទិទេពនៃកំពូលភ្នំ** " ។ តែក្នុងរជ្ជកាលព្រះបាទសូរិយវរ្ម័នទី ១

( ១០០២ - ១០៥០ ) ទើបប្រាសាទនេះមានទ្រង់ទ្រាយ បង្ហើយដោយព្រះបាទសូរិយវរ្ម័នទី ២ ( ១១១២ - ១១៤៤ ) ។

១១ ~ ប្រាសាទដ៏ប្រណីតលើកំពូលភ្នំ ជាទីប្រជុំបារមីល្បីមហិមា ធានាកម្ពុជាពីត្បូងទៅជើងក្រោមឫទ្ធិ លិង្គព្រះភទ្រេស្វរៈ ដែលសិលាចារឹក បានបញ្ជាក់ថាបានដង្ហែយកមកតាំងពីទីក្រុងអង្គរ ។ ឯសិលាចារឹកនៅជើងសរសរស្តម្ភគោបុរៈក៏បញ្ជាក់ផងដែរថា វិហារសាសនានេះ បានចាប់សាងនៅឆ្នាំ ១០២៤ ព្រះស្រីសិខៈរេស្វរៈនេះ ក៏ប្រសូត្រចេញមកពីព្រះថា ជ្រៃស្វារៈ នៃលិង្គបុរៈ ។

១២ ~ អាទិទេពកំពូលភ្នំ ជាកំពូលសក្ការៈ បញ្ជាក់គ្រប់រូបមន្តទាំងប៉ុន្មានដែលបានសាងឡើងក្នុងអាណាចក្រខ្មែរឱ្យចូលរួមផ្គុំជុំគ្នាវិញ ជុំវិញមនោគមវិជ្ជាថ្មីនៃព្រះសិវៈ ដែលប្រាសាទយើងនេះឆ្លាក់ឱ្យឃើញគ្រប់បែបបទ ចងជាអំណាចទិព្វមណ្ឌលសាធារណៈ សម្រាប់ព្រះរាជាស្នងក្រោយៗ ឱ្យចេះថែរក្សាវាសនាជាតិកុំឱ្យសាបសូន្យ ។ បណ្តាំនេះបានចែងតាំងនៅឯប្រាសាទ វត្តភូ ដោយព្រះបាទសូរិយាវរ្ម័នទី ២ លើសិលាចារឹករំឭកបណ្តាំ ឱ្យក្សត្រខ្មែររក្សាត្រកូលឱ្យបានជាអមតៈរៀងរហូតគឺ រក្សាលិង្គរាជឱ្យបានជាប់លាប់ ។ ដូច្នេះ ទើបព្រះរាជាក្រោយតែងតែយាងមកគោរព បន់ស្រន់ រំឭកជានិច្ចជាកាលដល់ ជូនតា ជាតិជាព្រះសិវៈនាពេលនោះ ផ្សព្វផ្សាយជូនប្រជារាស្ត្រ ដាស់ឱ្យចងចាំ នូវភារៈកិច្ចរក្សាមរតកគ្រួសារឱ្យបានគង់វង្សជារៀងរហូត ។

១៣ ~ ទីនេះហើយជាកំពូលសីវៈ សាសនាដែលមានមុខងារធានា *រក្សាអង្គភាពជាតិ* រក្សាទឹកដី ទោះជាមានគ្រោះភូមិសាស្ត្រ ជូរភ្នំដងរែក និងទំនាបទន្លេសាបនេះក៏ដោយ ។

១៤ ~ ពិស្តុការខ្មែរ បានរិះរកទីកន្លែងល្អប្រណិត ទាំងទម្រង់ព្រមទាំង

អត្ថន័យ ថ្មែនិមិត្តអង្គភាពខ្មែរ ( Symbolique unitaire ) ឱ្យមានប្រសិទ្ធិភាពថា ស្ថានទិព្វ រឹតនគរពីទន្លេសាបទៅដល់ដងទន្លេសេមូន ឯណោះ ។ ហេតុនេះ ទើបយើង យល់អំពីទីតាំង ព្រមទាំងរបៀបរៀបចំស្ថាបនាតាមបំណង ទាំងមន្តគាថា ទាំងទម្រង់រូបភាពខាងក្រៅ ក្បាច់រចនាក្លោងទ្វារពីមួយទៅមួយ យោងគ្នាជារជីក ថ្វាយព្រះសីរៈ អ្នកតាចាស់ស្រុករបស់ខ្មែរឱ្យមាន ព្រះ*បារមីទិព្វ* រឹតនគរកុំឱ្យបែក *តាមសណ្ឋានដី* ។ ដូច្នេះក្បាច់រចនាសំអិតសំអាង សុទ្ធតែតាំងឱ្យ អត្ថន័យពាក់ព័ន្ធ គ្មានចន្លោះលើទេវកថាទាំងឡាយ ដែលក្លាយចេញពីព្រះឥសូរ ។

១៥ ~ យ៉ាងណាមិញ តួប្រាសាទស្អាតប្រណីតសង់តាមជម្រាលនៃកំពូល ខ្ពស់ក្នុងជ្រោះភ្នំដងរែកនាតំបន់ខាងលើបង្អស់ ប្រៀបបាន នឹង*ព្រះវិស្ណុកំពុងផ្ទំ ផ្ទុំ* អារម្មណ៍លើមន្តសិល្បសាស្ត្រ រំលាយស្រុកខ្មែរខាងត្បូង វាលទំនាបឱ្យជ្រាបជាប់ជា សាច់មួយទៅនឹងស្រុកខ្មែរខាងជើងរហូតដល់ព្រំប្រទល់ចិន ។ ដូច្នេះយើងប្រៀប ប្រាសាទនេះទៅនឹងបន្ទំព្រះអាទិទេព វិស្ណុ ព្រះកេសកើយលើប្រាសាទព្រះនគរ ទីក្រុង អង្គរសៀមរាបខាងត្បូងបណ្ដោយដងខ្លួនជំរាលភ្នំ សំយុងជើងទៅទិសខាងជើងរបស់ ខ្មែរដូច្នោះ ។ ពីខាងជើងនេះឯងហើយ ដែលជាផ្លូវចេញចូលស្រួលនាំឱ្យយើងធ្វើការ រៀបរាប់តាមដំណើរបន្តិចម្តងៗឡើងទៅលើដល់កំពូលទីសក្ការៈ ។

១៦ ~ សព្វថ្ងៃអកុសលណាស់ ដោយយើងមិនបានធានាបណ្តាំ មរតក ដូនតា ឱ្យបានគង់វង្សដូចដើមឡើយ ។ ពីដងទន្លេសេមូន យើងបោះបង់ចោល គ្រួសារខ្មែរមួយចំនួន ឱ្យកណ្តោចកណ្តែងឥតមេបា អនាថាក្រខ្សត់ អស់សង្ឃឹម កំព្រាក្លាយជាពលរបស់គេ ។ គេប្រើប្រាស់គ្មានលំនឹងជារហូតមក យើងក៏បាត់ទឹកដី ខាងជើងអស់ ។ ប្រាសាទព្រះវិហារក៏ស្ទើរបាត់រលត់អស់ទៀត តែវាសនាល្អ យើង បានរក្សាគោលសីមាជាប់ត្រឹមជើងជណ្តើរ វាសនាជាតិនេះឯង ។

១៧ ‐ ដើម្បីងាយយល់ដល់រចនាសម្ព័ន្ធប្រាសាទព្រះវិហារនេះ យើងអាចប្រៀបបានទៅនឹងរាងកាយមនុស្ស ដេកសន្ធឹងក្បាលបែរទៅខាងត្បូងកើយទៅនឹងរាជធានីអង្គរ ឯជើងសណ្ដូកបែរទៅជើង ឆ្ពោះទៅរកទន្លេសេមូន ។ យ៉ាងនេះដងខ្លួនប្រាសាទចែកជា ៣ចំណែកសំខាន់ៗ ដែលយើងនឹងអធិប្បាយរៀបរាប់តាមលំដាប់ពីជើងទៅត្បូង ឬពីក្រោមទៅលើ ឬជាពិសេសនោះគឺពីសាមញ្ញទៅដល់ទីសក្ការៈ ។






១៨ ‐ *ផ្នែកទី ១ គឺអវយវៈ* ជាជើងគឺចាប់ពីទ្វារចូលទៅដល់ក្លោងទ្វារទី ១ ។ *ផ្នែកទី ២ គឺចង្កេះ* ដែលមានក្លោងទ្វារទី ២ ជាល់នឹងទប់ដើម្បីសាងឱ្យផ្នែកទី ៣ គឺដងខ្លួន និងក្បាលមានជាអាទិ៍ក្លោងទ្វារ ។ *ផ្នែកទី ៣ ជាវាំងព្រះរាជា* ព្រះអង្គគង់ដើម្បីធ្វើពិធីបូជាគោរពដល់ព្រះអាទិទេព *ស្រីសិខៈរេស្វរៈ* ជាថ្នាក់ខ្ពស់បំផុតទាំងបុណ្យ ទាំងបារមី ក៏ដូចជាការគ្រប់គ្រងដែរ ។ ទីនោះហើយ ដែលទេវតារក្សាកំពូលនគរលើអាកាស ក្ដាប់ចាប់បានទូទាំងចក្រវាលជើង និងត្បូង ។

១៩ ~ *ផ្នែកទី ១* មនុស្សចូលតាមដីទំនាបខាងជើង ( ក្នុងប្រទេសថៃ) ស្មើររាបស្មើតាមទ្វារមួយធំ មានសឹង្ហមួយគូអមចាំទទួលដំណើរបញ្ជាក់ នូវបរិវេណខាងក្រៅហើយ ។ វិថីក្រាលថ្មល្អបន្តចំអ័ក្សប្រាសាទ នាំយើងឱ្យទៅដល់ជើងជណ្តើរ ឡើងមួយគន្ទាក់ទើបដល់ថ្នាក់ វិថីរាបស្មើនាំទៅរកជើងក្លោងទ្វារ យ៉ាងចោត (គោបុរៈទី ១ ) ។ ពស់នាគរាជមួយគូរ ក្បាលបើកពពារសង្ហាអស្ចារ្យ កំពស់ប្រហែល ២ ម ដាស់យើងម្នាក់ៗឱ្យបានដឹងថាយើងចាប់ចូលមណ្ឌលសក្ការៈហើយ ។ យើងត្រូវរៀបចំខ្លួន ប្រាណ តមមាត់ក គោរពដល់ព្រះចេស្តានៃភ្នំនេះ ។ អស់មួយដងខ្លួននាគ យើងក៏ត្រូវ ឡើងជណ្តើរមួយថ្នាក់ទៀត ទើបចូលដល់ក្លោងទ្វារដ៏ឆ្នើម មានរាងខ្វែងជើងក្អែក ចែកជាក្លោងទ្វារចូលបែរទៅគ្រប់ជ្រុងទាំងបួនទិស ។ ដំបូលបាក់បែកអស់នៅសល់តែផ្នែកខាងកើត ប្រកបដោយក្បាច់ក្បូររចនាជាភ្ញីកម្រងដូចបន្ទាយស្រី ។ ខាងចុងដំបូលជាន់ខ្ពស់បង្អស់មានទេពអប្សររាំទ្រទ្រង់ ដោយចម្លាក់ជានាគបើកពពារក្បាលប្រាំ ។

២០ ~ *ផ្នែកទី ២* គឺចង្កេះភ្នំមានវិថីទី ២ ប្រវែង ៣៥០ម ទទឹង ១០ម រៀបចំក្រាលថ្ម លំអដោយថ្មគោល រលំអស់ តាំងពីក្លោងទ្វារទី ១ ចូលទៅរកទី ២ ដែលធំស្កឹមស្កៃសម្បើមថែមទៀត ។ ជិតដល់ក្លោងទ្វារទី ២ ប្រហែលជា ៨០ម នៅខាងឆ្វេងដៃប្រហែលជា ១០ម មានស្រះទឹកមួយបួនជ្រុងទ្រវែង ទំហំប្រហែល ៣៣ម x ២០ម ( កើតទៅលិច ) ជ្រុងម្ខាងជីកលើថ្មតែម្តង ជ្រុងទាំង ៣ ទៀតគេជីកដីទប់ជាមាត់ស្រះ ។ គេរៀបជាជណ្តើររហូតដល់ក្រោម កំពស់ទាំងអស់ ១០ម ។ ក្លោងទ្វារទី ២ នេះខ្ពស់ជាងក្លោងទ្វារទី ១ ប្រហែលជា ៥៩ម លេចត្រដែតចំចង្កេះប្រាសាទភ្នំព្រះវិហារនេះ ។ ជណ្តើរឡើងទៅតាមក្លោងទ្វារកណ្តាលនៅល្អប្រណីតថ្វីបើដំបូលគោបុរៈនេះបានត្រូវរលំអស់ហើយក៏ដោយ ។ អាគារនេះមានសាលធំ

មួយអមដោយសាលពីរបួនជ្រុងទ្រវែង ឆ្វេង ស្ដាំ ទាំងសងខាង ខាងកើត និងខាងលិច ព្រមទាំងទ្វារចូលទាំង ៨ ថ្នាក់ ប្រកបដោយក្បូរក្បាច់គោរពទៅដល់លទ្ធិព្រហ្មញ្ញសាសនាទាំងអស់ វិស្ណុព្រាហ្មណ៍ ជាពិសេសរឿងសមុទ្រទឹកដោះជំហរខ្មែរ មេ និងបា រចនាថ្មី ។

២១ ‐ វិថីទី ៣ ប្រវែង ១១០ម ចម្លងយើងពីគោបុរៈទី ២ ចូលទៅដល់គោបុរៈទី៣ ជាផ្លូវនៃរាជវាំង ។ តាមដងផ្លូវធំនេះមានលំអដោយសរសរគោល ៤ ម មួយៗព្រមទាំងជញ្ជាំងដី អមរហូតដល់កំផែងវាំង ។ ទ្វារទី ៣ នាំចូលទៅក្នុងគោបុរៈនេះមានជណ្ដើរមួយលយចេញជាងគេចំកណ្ដាល ហើយមានអាគារឆ្វេងស្ដាំ ពាងព្រះរាជវាំង ។ ទ្វារទាំងប៉ុន្មាន សុទ្ធសឹងតែលំអដោយក្បាច់រចនាប្រណីតខ្ពស់ លើសសម័យមុនទៅទៀត ។ វិថីមួយទៀតតុបតែងដោយសរសរគោលព្រមទាំងនាគទាំងសងខាង អមនាំយើងចូលទៅដល់ទីសក្ការៈ ដែលចែកជាពីរផ្នែក ។ គេចូលក្នុងបរិវេណទី ១ តាមទ្វារលយពីខាងជើងអមដោយទ្វារឆ្វេងស្ដាំ ។ គោបុរៈធំមួយទៀតមានទ្វារ ៣ មានតែទ្វារមួយទេ ដែលអនុញ្ញាតិឱ្យយើងចូលទៅក្នុងបរិវេណទី ២ ដែលជាទីតាំងព្រះអាទិទេពបង្គោលព្រះវិហារ ។ គោបុរៈនេះមានបណ្ណាល័យពីរអមសងខាង ដើម្បីគោរពតាមទម្រង់ប្រាសាទខ្មែរ ។

ព្រះវិហារស្នូលនេះសាងឡើងចំកណ្ដាលទីលាន មានកំផែងព័ទ្ធជុំវិញជាបួនជ្រុង ។ គេចូលទៅដល់ ទៅគោរពព្រះអាទិទេពតាមអាគារមុខប្រាសាទមួយយ៉ាងវែងមានដំបូលស្រួចខ្ពស់ប្រវែង ៦ម ពន្លឺចូលតាមចន្លោះបង្អួចរួចភ្ជាប់ទៅនឹងទ្វារព្រះវិហារតែម្ដង ។ គោបុរៈជើងត្បូងដូចគ្នា តែខាងត្បូងកើយទៅលើវាលទំនាបទន្លេសាបគ្មានទ្វារទេ ដែលជាហេតុបញ្ជាក់បន្ថែមថា *អារម្មណ៍របស់ព្រះរាជាគឺរំលាយកុំឱ្យមានជ្រោះខ្ពស់ទាប ដើម្បីជាអង្គភាពតែមួយនៃនគរ* ។ ខាងក្រៅបរិវេណក្រោយ

នេះ មានអាគារពីរអមពីខាងកើតលើជ្រោះ និងពីខាងលិចគ្មានការតុបតែងលំអអ្វីប៉ុន្មានទេ ដែលនាំឱ្យគេស្មានថាទីកន្លែងសម្រាប់ទទួលភ្ញៀវធ្វើដំណើរមកកាន់ទីនេះ ។

២២ ‐ ប្រាសាទព្រះវិហារ ជាប្រភេទប្រាសាទបណ្តោយមានលក្ខណៈដោយឡែក ផ្អែកលើជំរាលភ្នំខ្ពស់ៗ ឬវាលទំនាប តែមានមុខងារផ្សារភ្ជាប់ស្ថានភាពមិនចុះសម្រុងគ្នា ដោយប្រការណាមួយជាពិសេសពីធម្មជាតិ ឱ្យជ្រាបជាសាច់មួយកុំឱ្យបង្កឡើងជាការបំបែក ។ ចាប់ពីអាណាចក្រខ្មែរបានរីកសុះសាយជាអង្គភាពមួយ ផ្ជួបគ្នារវាងអ្នកខាងលើ ខាងជើង និងអ្នកខាងក្រោម ខាងត្បូង ប្រាសាទ ភ្នំព្រះវិហារនេះ មានតួនាទីជាស្ពានបានរំលាយជញ្ជាំងភ្នំឱ្យក្លាយទៅជាផ្លូវស្ថានសួគ៌ឡើងពីក្រោមទៅលើ ជួបជុំគ្នាជាមហាគ្រួសារគោរពបូជាសម្បូងសង្រួងសុំសេចក្តីសុខសេចក្តីចម្រើនដល់មនុស្សម្នា ចងកម្ពុជាទាំងមូលខាងជើងក៏ដូចខាងត្បូង ក្រោមឫទ្ធិអំណាចបារមីនៃព្រះសីវៈជា*អាទិទេពនៃកំពូលភ្នំ ស្រីសិខៈ រេស្វរៈ* ។ កាលពីដើមតំបន់នេះ ជាទីប្រជុំជនធំធេងតាមជើងភ្នំ ខ្នងភ្នំទូលំទូលាយ តែក្លាយទៅជាតំបន់រហោស្ថានគ្មានមនុស្សនៅ គួរឱ្យអាណោចពន់ពេក ដោយការបែកបាក់រវាងខ្មែរ នឹងខ្មែរគោរពមិនបាននូវបណ្តាំដូនតា ធ្វើឱ្យប្រាសាទព្រះវិហាររក្សាមិនបានទ្រង់ទ្រាយដើម កាត់បាត់អស់ស្រះមួយទៀងខាងជើងទៀតឯណោះ តែឥឡូវរសាត់បាត់អស់រួញមកនៅត្រឹមច្រកចូលសព្វថ្ងៃប៉ុណ្ណោះ ។

២៣‐ ចាប់តាំងពីមានអាណាចក្រខ្មែរកាលណាមកប្រាសាទ "*អាទិទេពកំពូលភ្នំ* "នេះជាដំបូលសក្ការៈ រក្សានគរ ដែលព្រះរាជាខ្មែរគ្រប់អង្គតែងតែមកគោរពរំឭកបន្តវេនជានិច្ចនិរន្តរ៍ ។ ការចាប់ផ្តើមសាងទីនេះ គឺក្រោមព្រះរាជបញ្ជារបស់ព្រះបាទយសោវរ្ម័ន នាឆ្នាំ ៩០០ តែលក្ខណៈជាក់ស្តែ គឺព្រះបាទសូរិយាវរ្ម័នទី ១ ( ១០០២ - ១០៥០ ) ព្រះអង្គសម្រេចទម្រង់សព្វថ្ងៃ ដែលបង្ហើយដោយរាជ្យ

ព្រះបាទសូរិយាវរ្ម័នទី ២ ( ១១១៣ - ១១៤៤ ) ។ ឯព្រាហ្មណ៍បុរោហិតជាអ្នករៀបចំដឹកនាំការងារនេះ បានធ្វើរចនាជារៀងរហូតដល់អាយុ ៨០ ឆ្នាំ តាំងពីព្រះបាទសូរិយាវរ្ម័នទី ១ មកដល់ជ័យវរ្ម័នទី ៦ ( ១០៨០ - ១១០៧ ) ហើយក៏បានទទួលងារប្រាកដជា *អាចារ្យព្រះគ្រូ* រហូតដល់ *តាគ្រូ* និង*ស្រីទិវាករបណ្ឌិត* (Divakarapandita ) ។ នៅរាល់បុណ្យរំឭកគុណម្តងៗ គេតែងតែរំឭកដល់ព្រះបាទជ័យវរ្ម័នទី ២ ជានិច្ច បំភ្លេចមិនបាន ព្រោះព្រះអង្គនេះឯងហើយ ដែលជាអ្នកសាងអាណាចក្រខ្មែរ ។

**២៤** ‑ សព្វថ្ងៃវាសនាខ្មែរ ខាងជើងបានខើចអស់ពីដងទន្លេសេមូនមកនៅត្រឹមជើងជណ្តើរប្រាសាទព្រះវិហារ ហើយតួអង្គប្រាសាទនេះក៏បានរបេះម្តងៗហើយដែរ ។

**២៥** ‑ ខ្មែរអើយភ្ញាក់ឡើង ! នាំគ្នារក្សាសង្គមជាតិ ចងគ្នាជាញាតិមហាគ្រួសារ ទោះនៅទីណាក៏ដោយ នៅក្នុងខ្លួនខ្មែរយើង មានឈាមតែមួយដូចគ្នា ធានាពូជខ្មែរ មិនឱ្យសាបសូន្យ ។ សូមសច្ចា បូជាប្រយុទ្ធ គ្រប់មុខសញ្ញាបំផ្លិចបំផ្លាញ រក្សាឱ្យបាននូវ ព្រលឹងរបស់យើង ទើបធ្វើការបណ្តុះបណ្តាលបានចម្រើន នឹងនរជំហារសុភមង្គលដល់ មនុស្សខ្មែរគ្រប់រូបតរៀងទៅ ។

# ការវិវឌ្ឍន៍នៃអាពាហ៍ពិពាហ៍ខ្មែរ

The evolution of Khmer wedding

(ត) ដោយបណ្ឌិត: ឆយ យីហាង

រាជបណ្ឌិតសភាកម្ពុជា

## ៤. អាពាហ៍ពិពាហ៍១ថ្ងៃ

នៅក្នុងសម័យសាធារណរដ្ឋខ្មែរ (សម័យលន់ណុល) សង្គ្រាមស៊ីវិលកាន់តែមានលក្ខណៈព្រៃផ្សៃឡើង។ ការស្ដីដណ្ដឹងមានលក្ខណៈឆក់កណ្ដៀត។ ហេតុនេះ អាពាហ៍ពិពាហ៍ ត្រូវបានបង្រួញមកត្រឹមតែមួយថ្ងៃប៉ុណ្ណោះ។ អាពាហ៍ពិពាហ៍ត្រូវបញ្ចប់នៅពេលរសៀល ព្រោះអ្នកស្រុកប្រញាប់ប្រញាល់រកកន្លែងជ្រកពួន ដូចជាពួនក្នុងលេណដ្ឋានជាដើម ដើម្បីជៀសវាងគ្រាប់រំសេវពីខាងរដ្ឋអំណាច និងពីខាងកំលាំងក្នុងព្រៃ។ ជួនកាល ឪពុកម្ដាយបង្កើត ដែលនៅឆ្ងាយពីកូនពុំបានដឹងថា កូនរៀបមង្គលការឡើយ។

## ៥. អាពាហ៍ពិពាហ៍១ព្រឹក

នៅចុងសម័យសាធារណរដ្ឋខ្មែរ កំលាំងទ័ពព្រៃបានហ៊ុមព័ទ្ធទីក្រុង និងទីរួមខេត្តនានា។ ដំណឹងផ្សេងៗត្រូវកាត់ផ្ដាច់។ ហេតុនេះ ការរៀបអាពាហ៍ពិពាហ៍មានលក្ខណៈប្រញាប់ប្រញាល់ពេក។ ឯការស្ដីដណ្ដឹងក៏មានលក្ខណៈបែបនោះដែរ។ ការប្រកាន់ប្រពៃណីក្នុងការស្ដីដណ្ដឹងត្រូវបានបន្ធូរបន្ថយជាច្រើន គឺសំរួលយ៉ាងណាដើម្បីឱ្យកូនប្រុស និងកូនស្រីងាយស្រួលក្នុងការរស់នៅជាមួយគ្នា។ អាពាហ៍-

ពិពាហ៍មានលក្ខណៈជារបៀបសែនព្រេន។

តាមការរៀបរាប់ខាងលើនេះ យើងឃើញថា អាពាហ៍ពិពាហ៍ខ្មែរកាន់តែមានលក្ខណៈសាមញ្ញឡើង១។ យើងអាចធ្វើការពិចារណាដូចខាងក្រោម ៖

- ការបង្រួញពេលវេលាពី ៧ថ្ងៃ ៧យប់ មកត្រឹម ៣ថ្ងៃ ៣យប់ ក្នុងការរៀបមង្គលការអាចបណ្ដាលមកពីហេតុសំខាន់ ២ យ៉ាងគឺ :
  - ហេតុសេដ្ឋកិច្ច
  - ហេតុពេលវេលា។

  ហេតុសំខាន់ទាំង២យ៉ាងនេះ ទាក់ទងគ្នាទៅវិញ ទៅមក។ ក្នុងករណីដែលគេអនុវត្ត ៧ថ្ងៃ ៧យប់ គេបានចំណាយពេលវេលា និងប្រាក់កាសជាច្រើន បើប្រៀបធៀបនឹងការណ៍ដែលគេអនុវត្ត ៣ថ្ងៃ ៣យប់។

- រីឯការបង្រួញពេលវេលាពី ៣ថ្ងៃ ៣យប់ មកត្រឹម១ថ្ងៃ ១យប់ បន្ទាប់មកត្រឹម១ថ្ងៃ ហើយបន្ទាប់មកទៀត ត្រឹមតែ ១ព្រឹក កើតឡើងដោយសារហេតុសំខាន់ ៣យ៉ាងគឺ :
  - ហេតុសង្គ្រាម
  - ហេតុសេដ្ឋកិច្ច
  - ហេតុពេលវេលា។

  ក្នុងចំណោមហេតុសំខាន់ទាំង ៣យ៉ាងនេះ ហេតុដែលមានតួនាទីកំណត់បំផុត គឺហេតុសង្គ្រាម ។ ហេតុសេដ្ឋកិច្ច

និងហេតុពេលវេលាក៏ទាក់ទងនឹងហេតុទី ១ ដែរ ។

- នេះជាស្ថានការណ៍បរានុម័ត ដែលបង្ខំឱ្យប្រជាជនខ្មែរអនុវត្តបែបនេះ ដោយមិនអាចរកផ្លូវណាផ្សេងទៀតឡើយ ។ ការអនុវត្តក្នុងគ្រានោះមិនមែនបង្ហាញថា ខ្មែរមានចរិតខ្ជីខ្ជាក្នុងការរៀបអាពាហ៍ពិពាហ៍ទេ ។ ផ្ទុយទៅវិញ កត្តានេះបញ្ជាក់ច្បាស់ថា ទោះបីស្ថិតនៅក្នុងស្ថានការណ៍លំបាកយ៉ាងណាក៏ដោយ ក៏ខ្មែរភាគច្រើន នៅតែរក្សាព្រលឹង និងស្មារដៃដូនតាដូចបានរៀបរាប់ក្នុងការរៀបមង្គលការនេះជាដើម ។ នៅក្នុងស្ថានភាពដ៏លំបាកយ៉ាងណាក៏ដោយ ក៏ខ្មែរនៅតែរក្សាការរៀបមង្គលការឱ្យបុត្រធិតា បង្ហាញឱ្យឃើញថា ខ្មែរស្រលាញ់ទំនៀមទម្លាប់ប្រពៃណី ចង់ជៀសវាងការពេបជ្រាយពីសង្គម និងយល់ថា អាពាហ៍ពិពាហ៍មានតំលៃខ្ពស់ក្នុងការរួមចំណែកកសាងសុភមង្គល ។

## ៦‐ អាពាហ៍ពិពាហ៍នៅក្នុងរបបប៉ុលពត

របបនេះ ជារបបមួយធ្វើបដិវត្តន៍វប្បធម៌ ដើម្បីកំទេចចោលមូលដ្ឋាននៃអាពាហ៍ពិពាហ៍ខ្មែរ និងបង្កើតមូលដ្ឋាននៃអាពាហ៍ពិពាហ៍ថ្មីមួយ ក្រោមការចាត់ចែងរបស់ "អង្គការ" មិនមែនក្រោមការចាត់ចែងរបស់ឪពុកម្ដាយទេ ។ កូនកំលោះ និងកូនក្រមុំមិនអាច រើសគូស្រករតាមបំណងប្រាថ្នារបស់ខ្លួនបានឡើយ ។ ឪពុកម្ដាយក៏មិនអាចរួមចំណែកក្នុងការរើសគូស្រករឱ្យកូនបានដែរ ។ អាពាហ៍ពិពាហ៍ត្រូវកំណត់ដោយ "អង្គការ" ។ ដំណើរប្រព្រឹត្តទៅនៃអាពាហ៍ពិពាហ៍ មានដូចតទៅ ៖

- ការរៀបអាពាហ៍ពិពាហ៍ត្រូវប្រព្រឹត្តទៅនៅពេលល្ងាច និងពេលយប់។ ការជ្រើសពេលបែបនេះប្រហែលជាបណ្តាលមកពីការសន្សំសំចៃពេលវេលាសំរាប់ធ្វើការងារផ្សេងៗ នៅតាមស្រែ ចំការ ឬនៅក្នុងរោងជាង។
- ការរៀបអាពាហ៍ពិពាហ៍គ្មានលក្ខណៈឱឡារិកទេ។ គេប្រារព្ធពិធីនេះស្ងាត់ៗ ដែលជូនកាលសាមីខ្លួនទើបនឹងដឹងភ្លាមៗ ថាខ្លួនត្រូវរៀបការ។
- សាមីខ្លួនប្រុស និងសាមីខ្លួនស្រីត្រូវធ្វើតាម "អង្គការ" ដោយឥតប្រកែកបាន។ គ្មានការជូនពរស័ព្ទសាធុការទេ។ មានតែការប្រៀនប្រដៅឱ្យគោរពស្រលាញ់ "អង្គការ" ប៉ុណ្ណោះ។
- ក្នុងករណីដែលហ៊ានជំទាស់ចំពោះ "អង្គការ" សាមីខ្លួនអាចត្រូវយកទៅសម្លាប់ ឬយកទៅធ្វើបាបគ្រប់បែបយ៉ាង។ ឧទាហរណ៍ : ស្ត្រីក្រមុំម្នាក់ឈ្មោះ *នាង សាយ* ត្រូវបានលើកងារជាប្រធានមន្ទីរពេទ្យនៅភូមិស្រះ ឈើទ្បើង ចំណុះសហករណ៍ស្វាយដូនកែវ ស្រុកបាកាន ខេត្តពោធិ៍សាត់ ចាប់តាំងពីឆ្នាំ ១៩៧៥។ លុះដល់ឆ្នាំ ១៩៧៧ "អង្គការ" បានបង្ខំឱ្យនាងនេះរៀបអាពាហ៍ពិពាហ៍ជាមួយបុរសម្នាក់ដែលមានវ័យចំណាស់ និងកំបុតដៃម្ខាង។ លោកជាអតីតយោធានៅក្នុងកងទ័ពប៉ុលពត។ នាងប្រកែកមិនព្រមទទួលយកបុរសនេះជា ប្តី ។ "អង្គការ" បានទំលាក់នាងពីប្រធាន

មន្ទីរពេទ្យមកជាភាស្ត្រសាមញ្ញ ។ នាងត្រូវទៅស្ទូងស្រូវ លើកភ្លឺស្រែ ... ដូចប្រជាជនដទៃទៀតដែរ។ ថ្ងៃមួយ "អង្គការ" បានបញ្ជាឱ្យបុរសនោះ ចាប់នាងរំលោភ ...។ នៅពេលនោះ កងឈ្លប ៣ នាក់ បានយាមយ៉ាងម៉ឺងម៉ាត់ ដើម្បីកុំឱ្យនាងគេចផុតពីបុរស ដែលមានបំណងធ្វើជាប្តីនាង។ ប៉ុន្មានថ្ងៃក្រោយមក នាងសាយបានសំរេចចិត្តធ្វើអត្តឃាត ដោយចងកនៅក្នុងផ្ទះស្បូវមួយខ្នង ដែលទើបនឹងសង់នៅក្នុងភូមិទួលអ្នកគ្រូ ចំណុះសហករណ៍ស្វាយដូនកែវ ស្រុកបាកាន ខេត្តពោធិ៍សាត់។ សូមបញ្ជាក់ថា ភូមិទួលអ្នកគ្រូ និងភូមិស្រះឈើនៀងស្ថិតនៅជិតគ្នាប្រហែល ៣០០ ម៉ែត្រ។

នៅក្នុងរបបប្រល័យពូជសាសន៍ អាពាហ៍ពិពាហ៍ត្រូវរៀបចំជាច្រើនគូ អាចចាប់ពី ២គូ រហូតដល់ ២០០គូ ក៏មានដែរ។ នៅចុងឆ្នាំ ១៩៧៨ មុនពេលរំដោះ ពួកខ្មែរក្រហមបានបង្គាប់ឱ្យយុវជន និងយុវនារីរៀបការជាមួយគ្នារាប់រយគូ ក្នុងពេលតែមួយ។ ឧទាហរណ៍ : នៅលើជួរភ្នំក្រវាញ ខេត្តពោធិ៍សាត់ នាខែវិច្ឆិកា ១៩៧៨ ក្នុងយប់មួយ យុវជន និងយុវនារីត្រូវរៀបការជាមួយគ្នាចំនួនប្រហែល ២០០គូ ក្រោមពន្លឺភ្លើងចន្លុះ។ ពេលនោះ មានភាពច្របូកច្របល់យ៉ាងខ្លាំង ដោយយុវជន និងយុវនារីមិនស្គាល់មុខគ្នា ដែលអាចច្រលំគូគ្នា ជាច្រើន។

ចំពោះបញ្ហានេះ យើងពិចារណា ដូចខាងក្រោម ៖

- "អង្គការ" ដែលជាស្ថាប័នកំពូលនៃរបបប្រល័យពូជសាសន៍ មានចេតនាកំទេចចោលប្រពៃណី និងទំនៀមទម្លាប់រស់នៅ

របស់ប្រជាជនកម្ពុជា។ នេះជាការធ្វើបដិវត្តន៍វប្បធម៌មួយ ដែលមានលក្ខណៈប្របាក់ ប្រហែលនឹងបដិវត្តន៍វប្បធម៌នៃសាធារណៈរដ្ឋប្រជាមានិតចិន កាលពីឆ្នាំ ១៩៦៥។

- ពិតណាស់ នាងសាយ បានរីកចំរើននៅក្នុងរបបនេះ។ នាងបានទទួលមុខងារមួយជាទីពេញចិត្ត គឺប្រធានមន្ទីរពេទ្យ កែវស្អាត។ ប៉ុន្តែ នៅពេលដែល "អង្គការ" បង្ខំឱ្យនាងរៀបការជាមួយមនុស្សដែលនាងមិនពេញចិត្ត នាងមានគំនិតប្រតិកម្មយ៉ាងធំចំពោះ "អង្គការ" វិញ។ នៅពេលដែលនាងមិនអាចយកឈ្នះលើ "អង្គការ" បាននាងបែរជាសំរេចចិត្តធ្វើអត្តឃាត ដើម្បីបញ្ចប់ជីវិតរបស់ខ្លួន។ ការណ៍នេះ ប្រហែលជាធ្វើឱ្យ "អង្គការ" គិតពិចារណាតិចតួចដែរ ចំពោះអាពាហ៍ពិពាហ៍នៅជំនាន់នោះ។ ហេតុនេះហើយ បានជាក្រោយពេលដែលនាងសាយសំលាប់ខ្លួន អាពាហ៍ពិពាហ៍ត្រូវបានរៀបចំជាច្រើនគូ ដែលហាក់ដូចជាមានលក្ខណៈបន្ធូរបន្ថយខ្លះ។

## ៧‿ អាពាហ៍ពិពាហ៍ជាមួយសំលៀកបំពាក់

យើងសង្កេតឃើញថា នៅប្រទេសកម្ពុជាមានទំរង់អាពាហ៍ពិពាហ៍មួយបែបដែលហៅថា អាពាហ៍ពិពាហ៍ជាមួយសម្លៀកបំពាក់ ។ នៅក្នុងអាពាហ៍ពិពាហ៍បែបនេះ មានតែកូនក្រមុំទេ ដែលត្រូវអនុវត្តម្នាក់ឯង។ ចំណែកកូនកម្លោះពុំមានមុខនៅក្នុងពិធីនោះទេ។ កត្តានេះ បណ្តាលមកពីហេតុច្រើនយ៉ាង ៖

ក- បុរសដែលបានស្តីដណ្តឹងកូនក្រមុំហើយ មានឆន្ទៈរៀប

អាពាហ៍ពិពាហ៍ពិតប្រាកដ។ ការរៀបអាពាហ៍ពិពាហ៍ ត្រូវបានគ្រោងទុកមុនជាច្រើនថ្ងៃ។ ស្រាប់តែនៅថ្ងៃរៀបអាពាហ៍ពិពាហ៍នោះ កូនកម្លោះត្រូវទៅសមរភូមិ ដែលមិនអាចខានបាន ព្រោះនៅជំនាន់ដើម ការចុះបំពេញកាតព្វកិច្ចនៅសមរភូមិមានលក្ខណៈដាច់ខាត មិនអាចប្រកែកបាន។

ខ- បុរសមួយចំនួនមានប្រពន្ធកូនរួចហើយ។ ដើម្បីបិទបាំងកុំឱ្យពួខ្វះខ្វាយក្នុងការរៀបការជាមួយប្រពន្ធថ្មី បុរសនោះគ្រាន់តែផ្ញើសម្លៀកបំពាក់ដែលមានខោ អាវ និងស្បែកជើង ដើម្បីឱ្យផ្ទឹមជាមួយកូនក្រមុំ។ បុរសច្រើន តែជាអ្នកមានបុណ្យសក្តិខ្ពស់ និងមានទ្រព្យសម្បត្តិច្រើន។ ស្ត្រីច្រើនតែជាកូនអ្នកក្រីក្រ។ គេឃើញមានអាពាហ៍ពិពាហ៍បែបនេះ នៅក្នុងសម័យសាធារណរដ្ឋខ្មែរ ឬអាចមានមុនសម័យសាធារណរដ្ឋខ្មែរ។

ក្នុងការពិចារណា យើងយល់ដូចខាងក្រោម ៖

- ក្នុងករណីទី១

  អាពាហ៍ពិពាហ៍ត្រូវបានសំរួលដោយសារកូនកម្លោះ ជាប់បំពេញកាតព្វកិច្ចយោធា ដែលមិនអាចជៀសវាងបាន។ រីឯកូនក្រមុំ និងមាតាបិតាញាតិមិត្តខាងស្រី ក៏ពុំមានសេចក្តីខ្មាស់អៀនអ្វីឡើយ។ នេះក៏បញ្ជាក់ឱ្យឃើញសេចក្តីស្មោះស្ម័គ្ររបស់កូនស្រីចំពោះកូនប្រុសដែរ។

- ក្នុងករណីទី២ អាពាហ៍ពិពាហ៍មានលក្ខណៈរអាក់រអួលច្រើន ព្រោះកូនក្រមុំ មាតាបិតា និងញាតិមិត្តខាងស្រី មិនមានអារម្មណ៍ស្ងប់ស្ងាត់ឡើយ ។ នៅពេលដែលគូស្វាមីភរិយារស់នៅជាមួយគ្នា ការរស់នៅរបស់គេក៏មានលក្ខណៈលួចលាក់ដែរ ដែលខ្មែរហៅថា "រស់នៅមិនពេញមុខ" ។

## ៨_ អាពាហ៍ពិពាហ៍ឆ្លងឆ្លាយ

អាពាហ៍ពិពាហ៍នេះ ប្រហែលជាចាប់កើតឡើងនៅសម័យសព្វថ្ងៃ ក្រោយរំដោះពីរបបប្រល័យពូជសាសន៍ និងក្រោយពីមានទំនាក់ទំនងជាមួយប្រទេសសេរីវិញ ដូចជាប្រទេសបារាំង អូស្ត្រាលី និងសហរដ្ឋអាមេរិក ជាដើម ។ បងប្អូនកម្ពុជាមួយចំនួនបានទៅរស់នៅឯបរទេស ហើយបានចូលសញ្ជាតិជាបរទេស ។ ពួកគេមានបំណងទាក់ទាញសមាជិកគ្រួសារ ឬបងប្អូនរបស់គេដែលកំពុងរស់នៅក្នុងប្រទេសកម្ពុជាឱ្យទៅរស់នៅឯបរទេសវិញ ។ ប៉ុន្តែ ច្បាប់នៅបរទេសបានហាមឃាត់មិនឱ្យយកអ្នកចំណូលថ្មីទៅរស់នៅជាមួយ ។ ច្បាប់នោះ អនុញ្ញាតឱ្យយកតែប្រពន្ធ ឬប្តីពេញច្បាប់ប៉ុណ្ណោះ ។

ចំនុចសំខាន់ៗគឺ :

ក- ក្នុងករណីនេះ អ្នកនៅបរទេស និងអ្នកនៅកម្ពុជា បានទាក់ទងគ្នាដោយយកអាពាហ៍ពិពាហ៍ធ្វើជាលេស ដើម្បីបំភាន់ភ្នែកអាជ្ញាធរនៅក្នុងប្រទេសផង និងបំភាន់ភ្នែកអាជ្ញាធរបរទេសផង ។ អាពាហ៍ពិពាហ៍បែបនេះកើតឡើងជាញឹកញាប់នៅក្នុងប្រទេសយើង ទាំងនៅក្នុងក្រុង និងជនបទ ។

លុះកូនកំលោះ និងកូនក្រមុំបានរៀបអាពាហ៍ពិពាហ៍ហើយ គេមានសិទ្ធិចុះអេតាស៊ីវិល (état civil) នៅចំពោះមុខសមត្ថកិច្ច។ ប៉ុន្តែ គេពុំបានរួមដំណេកជាមួយគ្នាទេ។ បន្ទាប់មកអ្នកនៅបរទេសវិលត្រឡប់មកវិញ ហើយរត់លិខិតស្នាម ឬធ្វើបែបបទឱ្យស្របច្បាប់ ដើម្បីយកអ្នកនៅក្នុងប្រទេសទៅដែរ។ អ្នកទី ២ ដែលទៅរស់នៅឯបរទេសអាចផ្សងសំណាងតាមយថាកម្មក្នុងការរស់នៅ។ ឯអ្នកនៅបរទេសដែលស៊ីឈ្នួលរៀបការនោះអាចជាប្រុស ឬអាចជាស្រី។

ខ- ក្នុងករណីទី២ មានជនបរទេសខិលខូចមួយចំនួនបានឆ្លៀតឱកាសនេះ ទាក់ទងនឹងជនខិលខូចនៅកម្ពុជា ដោយឱ្យប្រាក់មកជនខិលខូចនៅកម្ពុជា រៀបអាពាហ៍ពិពាហ៍ជាមួយកូនក្រមុំអ្នកស្រុក ដើម្បីយកកូនក្រមុំនោះទៅលក់ឯបរទេស ក្នុងនាមជាស្ត្រីពេស្យា។ ដោយសារអំណាចទឹកប្រាក់ អ្នកស្រុកជាច្រើនរូបបានចាញ់ឧបាយកលពួកនេះ។ រីឯស្ត្រីដែលបានរៀបការហើយនោះ តែងទទួលផលអាក្រក់ជារឿយៗ ក្នុងសភាពជាអ្នកត្រូវគេបោកបញ្ឆោត។

គ- នៅមានករណីមួយទៀត ដែលត្រូវលើកយកមកពិភាក្សា។ មានខ្មែរនៅឯបរទេសមួយចំនួន ដែលយើងឱ្យឈ្មោះថា "អាណិកជន" បានចូលមកស្ដីដណ្ដឹងកូនអ្នកស្រុក។ គេបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា។

គេបានរស់នៅជាមួយគ្នាក្នុងមួយរយៈពេល។ បន្ទាប់មក គេបានវិលត្រលប់ទៅបរទេសវិញ (កូនប្រុស)។ គេបានប្រាប់ថា គេរត់ការនាំកូនស្រីទៅតាមក្រោយ។ តាមពិត គេមិនបានរត់ការអ្វីទាំងអស់។ ចំណែកកូនស្រីក្លាយជាស្រីមេម៉ាយរហូតទៅ។ ប៉ុន្តែជួនកាលកូនស្រីក៏បានទៅរស់នៅឯបរទេសដែរ។ លុះផុតកំណត់ទិដ្ឋាការឆ្លងដែន មិនអាចពន្យាបានទៀត កូនស្រីត្រូវបង្ខំចិត្តមករស់នៅក្នុងប្រទេសកម្ពុជាវិញក៏សឹងមាន។ និយាយបែបនេះ មិនមែនមានន័យថា ការរៀបអាពាហ៍ពិពាហ៍ជាមួយអាណិកជនសុទ្ធសឹងមានផលអាក្រក់ទេ។ មានអាណិកជនច្រើនណាស់ ដែលបានជួយដល់ស្ត្រី ឬបុរសខ្មែរឱ្យមានសុភមង្គល ក្នុងការរៀបអាពាហ៍ពិពាហ៍នេះ។

ក្នុងការពិចារណា យើងយល់ដូចខាងក្រោម ៖

- បញ្ហានេះកើតឡើងដោយសារខ្មែរមួយចំនួនមានបំណងទៅរស់នៅឯបរទេស និងដោយសារសេចក្ដីលោភលន់ហួសប្រមាណក្នុងការស្វែងរកប្រាក់ រួមផ្សំជាមួយនឹងសេចក្ដីឆោតល្ងង់របស់ខ្លួន។
- បុគ្គលខិលខូច បានយកច្បាប់នៅកម្ពុជា និងនៅបរទេសមកទ្រាប់អង្គុយ បំភាន់ភ្នែកអាជ្ញាធរទាំងសង្ខាង។ នេះក៏បញ្ជាក់ឱ្យឃើញពីកង្វះចន្លោះនៃច្បាប់ ដែលមិនផ្ដន្ទាទោសចំពោះជនណាដែលរំលោភលើច្បាប់នោះ។

- ខ្មែរនៅបរទេសជាច្រើននាក់បានផ្ដាំថា "ប្រយ័ត្នចាញ់បោកជនខិលខូចនៅបរទេស។ មុននឹងទុកដាក់កូនចៅ សូមមើលផៅសន្ដានឱ្យច្បាស់លាស់"។ ជាញឹកញាប់ណាស់ ដែលបងប្អូនខ្មែរនៅបរទេស ដែលមានសេចក្ដីអាណិតអាសូរចំពោះបងប្អូននៅក្នុងប្រទេសតែងនិយាយបែបខាងលើនេះ។

## ៩‐ ការស្ម័គ្រចិត្តទៅរស់នៅឯបរទេសក្នុងនាមជាភរិយា

មានចលនាមួយនៅក្នុងទីក្រុងភ្នំពេញជាពិសេស ដែលមេអណ្ដើកនៅកម្ពុជាហៅកូនក្រមុំអ្នកស្រុកមកតំរៀបជួរគ្នា ដើម្បីឱ្យគេជ្រើសរើសទៅធ្វើជាភរិយារបស់ជនបរទេស ដូចជានៅប្រទេសតៃវ៉ាន់ជាដើម។ មេអណ្ដើកតែងបានទទួលប្រាក់ (commission) ជាទីពេញចិត្ត។ ឧទាហរណ៍ : កូនក្រមុំខ្មែរ ២០ នាក់ ឈរតំរៀបជួរគ្នា។ គេតុបតែងលំអតាមលទ្ធភាពរបស់គេ។ ជនបរទេសបានសំលឹងមើលម្ដងមួយៗ។ បើគេមិនពេញចិត្ត គេអាចមិនយកម្នាក់ណាឡើយ។ បើគេពេញចិត្ត គេជ្រើសរើសយក ១ នាក់ ឬ ២ នាក់ ទៅបរទេស។

នៅពេលដែលទៅរស់នៅឯបរទេស គេច្រើនតែក្លាយទៅជាភរិយាដែលរស់នៅក្នុងកសិដ្ឋាន (ធ្វើស្រែ ចំការ)។ មួយចំនួនតូច មានភព្វសំណាងត្រូវបានគ្រួសារខាងប្ដីថ្នាក់ថ្នម។ តែមួយចំនួនធំក្លាយជាទាសីភរិយា ហើយបានសរសេរលិខិតផ្ដាំផ្ញើកុំឱ្យអ្នកស្រុកប្រព្រឹត្តបែបនេះទៀត។

ក្នុងការពិចារណា យើងយល់ដូចខាងក្រោម :

នៅក្នុងករណីនេះ សាមីខ្លួនហាក់ដូចជាធ្វើឱ្យបាត់បង់កិត្តិយសផ្ទាល់ខ្លួនកិត្តិយសគ្រួសារ និងប្រទេសជាតិ ។ គេហាក់លែងគិត អំពីប្រពៃណីរបស់ខ្លួន

ដោយសេចក្តីក្រខ្សត់ និងដោយមានចំណូលចិត្តទៅរស់នៅឯបរទេស ។ នេះជាសេរីភាពក្នុងការជ្រើសរើស ដែលមិនមែនស្ថិតនៅក្នុងទំនៀមទម្លាប់ខ្មែរ ដែលយើងអាចឱ្យឈ្មោះថា យើងងាយនឹងបំភ្លេចអ្វីដែលល្អរបស់យើង ។ ចំលើយដោះស្រាយតែម្យ៉ាងគត់របស់សាមីខ្លួន គឺថាបណ្តាលមកពីសេចក្តីក្រខ្សត់ ។

( នៅមានត )

*មិនត្រូវធ្វេសប្រហែសភ្លេចខ្លួនឡើយ.*

*ត្រូវប្រុងប្រយ័ត្នឱ្យមានស្មារតីនៅប្រចាំខ្លួនជានិច្ច*

*ព្រោះស្មារតីអាចឱ្យនឹកឃើញល្អអាក្រក់ក្នុងខ្លួន ។*

**ព្រះពោធិវង្ស ហួត តាត**

# ការរីកចម្រើននៃពុទ្ធសាសនាក្នុងជីវិតខ្មែរ

(ត) ដោយអ្នកស្រី **ខ្លូត ធីតា**
បណ្ឌិតទស្សនវិជ្ជា

ការវិវឌ្ឍន៍នៃព្រះពុទ្ធសាសនាក្នុងកម្ពុជរដ្ឋ

ក- សាលាបាលីជាន់ខ្ពស់ (ឥឡូវហៅថាពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត )
សាលាបាលីរង (ហៅពុទ្ធិកបឋមសិក្សា )

អ្វីជាភាសាបាលី? បុព្វហេតុដែលកើតភាសាបាលី !។ ភាសាបាលីកើតនៅប្រទេសឥណ្ឌា។ កាលមុននឹងជំនាន់ពុទ្ធកាលភាសានេះ គ្មានរបៀបវេយ្យាករណ៍ទេ ដូចគម្ពីរបាលីព្រះត្រៃបិដក ដែលយើងទើបនឹងបោះពុម្ពនៅប្រទេសយើង ឃើញពាក្យច្រំដែលជាច្រើន។ បើអ្នកប្រាជ្ញសម័យថ្មីអាចកាត់ពាក្យច្រំដែលនេះចោលចេញបាន គម្ពីរព្រះត្រៃបិដក នឹងមានសភាពខ្លីៗ ស្រួលអានស្រួលស្តាប់ ឆាប់យល់ផង។

តាមសេចក្តីក្នុងសន្និសីទ នៃឯកឧត្តម វ៉ាយ-ល្មុត អតីតរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ឧស្សាហកម្ម ធ្វើក្នុងនាមនៃសមាគមមិត្តសាលាបាលី ពីថ្ងៃទី ៦ មេសា ១៩៥១ ថា « ការរៀនភាសាបាលីនេះ មិនមែនទើបនឹងមានទេ »។ តាមប្រវត្តិសាស្ត្រ ភាសាបាលីបានចូលមកប្រទេសយើងតាំងពីសតវត្សទី ១៧ (ព.ស).(គ.ស. ទី១២ ) ម្ល៉េះ នាកាលព្រះពុទ្ធសាសនាមហាយាន បានចូលមកក្នុងប្រទេសយើងជាលើកដំបូង។ តមកក្នុងសតវត្សទី ២០ នៃ ព.ស (គ.ស. ទី ១៥ ) ព្រះពុទ្ធសាសនាហិនយាន បានចូលមកប្រទេសយើងទៀត ភាសាបាលីក៏ចេះតែល្ងូតលាស់

ចម្រើនឡើងជាលំដាប់ ។ យើងឃើញការរៀនសូត្របាលីមានរូបរាងប្រាកដតាំងពីក្នុង រជ្ជកាលព្រះបាទសម្តេចព្រះហរិរក្សរាមាឥស្សរាធិបតី ( ព្រះអង្គឌួង ) គឺតាំងពីក្នុងសតវត្សទី ២៤ នៃ ព.ស ។ តមកទៀតក្នុងសតវត្សទី ២៥ នៃ ព.ស ក្នុងរជ្ជកាលនៃព្រះបាទសម្តេចព្រះនរោត្តម យើងឃើញមានពិធីដេញប្រយោគប្រែបាលី ។ បន្ទាប់មកទៀតក្នុង ព.ស ២៤៥២ (គ.ស ១៩០៩ ) មានបង្កើតសាលាបាលីនៅនគរវត្ត។ ក្រោយពីនោះមកទៀត ក្នុង ព.ស ២៤៥៧ (គ.ស ១៩១៤ ) សាលាបាលីជាន់ខ្ពស់យើងសព្វថ្ងៃ បានបង្កើតឡើងជាជំនួសសាលាបាលីនៅនគរវត្ត គិតទៅសាលាបាលីជាន់ខ្ពស់នេះ មានអាយុ ៣៧ ឆ្នាំ ហើយ ។ បន្ទាប់មកតាំងពី ព.ស ២៤៧៦ ( គ.ស ១៩៣៣ ) រហូតដល់សព្វថ្ងៃ គឺក្នុងរយៈវេលា ១៧ ឆ្នាំប៉ុណ្ណោះ មានបង្កើតសាលាបាលីរងក្នុងព្រះរាជាណាចក្រមានចំនួន ២៤៨ សាលា មានសិស្សប្រឡងចេញមួយឆ្នាំៗ ជាងមួយពាន់រូប[១] ។

សរុបសេចក្តីថា ក្នុងកម្ពុជរដ្ឋសព្វថ្ងៃមានវត្តចំនួន ២៦៥៦ (១៩៥៣ មានវត្ត ២៧៦៣ ) សាលាបាលីរងចំនួន ២៤៨ ( ១៩៥៣ មានជាង ៣០០ ) មានភិក្ខុសង្ឃប្រហែល ៣៨០០០ រូប ជាអ្នកពេញចិត្តរៀនសូត្របាលី រៀនសូត្រព្រះពុទ្ធសាសនាភាសាខ្មែរឱ្យបានជ្រៅជ្រះ ... ។

សាលាបាលីជាន់ខ្ពស់ ដែលជាក្រុមសាធារណរដ្ឋបារាំងៗ បានផ្ទេរសាលានេះមករដ្ឋាភិបាលខ្មែរនៅថ្ងៃទី ៣១ ធ្នូ ១៩៤៧ ។

ខ- ពុទ្ធសាសនបណ្ឌិត្យ

ពុទ្ធសាសនបណ្ឌិត្យ កើតពីក្នុង គ.ស ១៩៣០ ដោយបានកែប្រែ ព្រះរាជ

---

១- វ៉ាយ ប៉ុក ព្រះពុទ្ធសាសនានៃប្រទេសកម្ពុជាភ្នំពេញ ១៩៥៧

បណ្ណាល័យ ដែលបានស្ថាបនាតាមព្រះរាជប្រកាស ១៩២១។ តាំងពីនោះមកពុទ្ធសាសនបណ្ឌិត្យ ដែលមានលោកស្រី កាប៉ីឡេស ជាអគ្គលេខាធិការ, មានដំណើរការតមកបានចម្រើនតាមលំដាប់។

ពុទ្ធសាសនបណ្ឌិត្យ មានកិត្យានុភាពត្រង់រក្សាទុកនូវលទ្ធិវិសេសវិសាលនៃពិភពលោកព្រមទាំងកេរ្តិ៍មរតកអារ្យធម៌បុរាណ។ ក្រុមនេះគឺស្ថាបនាដោយស្នាព្រះហស្តនៃព្រះប្រិយមហាក្សត្រប្រទេសកម្ពុជា និងជាវិជ្ជាស្ថាន តមកពីសាលាបាលីជាន់ខ្ពស់ និងព្រះរាជបណ្ណាល័យ។ វិជ្ជាស្ថាននេះពីដើមគេហៅថា «វិជ្ជាស្ថានអប់រំការសិក្សាខាងព្រះពុទ្ធសាសនាហិនយាន » មានបេសកកម្មត្រង់ណែនាំ និងរៀបចំការសិក្សាព្រះពុទ្ធសាសនាហិនយាន។ នៅខែកុម្ភៈ ១៩៤៣ វិជ្ជាស្ថាននេះបានប្រែនាមជា «វិជ្ជាស្ថានពុទ្ធសាសនាឥណ្ឌូចិន » ហើយបានទទួលពីព្រះរាជបណ្ណាល័យនូវសៀវភៅ និងឯកសារជាច្រើន មានអក្សរសាស្ត្រ, សាសនា, ប្រវត្តិសាស្ត្រ, បុរាណសាស្ត្រ ព្រមទាំងបោះពុម្ពសៀវភៅព្រះរាជបណ្ណាល័យ និងសាលាបាលីជាន់ខ្ពស់ថែមទៀត។ ពិតមែនតែមានមហាសង្គ្រាមលោកទាំងពីរ និងកងទ័ពជប៉ុនចូលមកប្រទេសកម្ពុជា ពុទ្ធសាសនបណ្ឌិត្យនៅតែមានដំណើរទៅតាមលំអាន[២] ។

ក្រុមជំនុំព្រះត្រៃបិដក បានស្ថាបនាឡើង តាមព្រះរាជប្រកាសលេខ ១០៦ ចុះថ្ងៃទី ១៤ ធ្នូ ១៩២៩។ ការបោះពុម្ពព្រះត្រៃបិដក ក៏បានចាប់ផ្តើមធ្វើតមក។ ព្រះត្រៃបិដកជាស្នាដៃពួកក្រុមជំនុំព្រះត្រៃបិដក ដែលមានសម្តេចព្រះធម្មលិខិត ល្វី-ឯម (វជិរបញ្ញោ) កាលនៅជាព្រះសិរីសម្មតិវង្ស ចាងហ្វាងសាលាបាលីជាន់ខ្ពស់ ជាអធិបតី ព្រមទាំងការព្យាយាមនៃព្រះសពឧត្តមមុនី អ៊ុំ-ស៊ូ និងសម្តេច

២- រ៉ាយ ប៉ុក ព្រះពុទ្ធសាសនានៃកម្ពុជា ភ្នំពេញ ឆ្នាំ ១៩៥៧ ទំព័រ ២១

ព្រះមហាសុមេធាធិបតីសង្ឃនាយក ជួន ណាត (ជោតញ្ញាណោ ) កាលនៅជាព្រះសង្ឃសត្ថា។ ព្រះត្រៃបិដកមាន ១១០ ក្បាល បើបោះពុម្ពរួចស្រេច ទាំងព្រះសូត្រ ព្រះវិន័យ និងព្រះអភិធម្ម[៣] ។

រថយន្ត បណ្ណាល័យបាននាំដំណឹងសកម្មភាពនៃពុទ្ធសាសនបណ្ឌិត្យ ទៅផ្សាយពាសពេញភូមិ និគម ជនបទ ខេត្ត ព្រមទាំងលក់សៀវភៅគតិធម៌-លោកគ្រប់យ៉ាង។ តែឥឡូវនេះ ដោយអសន្តិសុខ រថយន្តនោះក៏ត្រូវផ្អាកបណ្តោះអាសន្ន លែងចេញទៅឃោសនាផ្សាយ រង់ចាំពេលឱកាសតទៅថ្ងៃក្រោយ។

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ ដោយមានលោកស្រី ប៉ូរ៉េ-ម៉ាស្ប៉េរ៉ូ សមាជិកាវិជ្ជស្ថានបូព៌ាប្រទេសជាអ្នកណែនាំ ក៏បានដំណើរការទៅរកវឌ្ឍន៍ធម៌ ដោយឆាប់រហ័ស មានរក្សាទុកឯកសារជាច្រើន។ ឆ្នាំ ១៩៤៩ មានឯកសារ ៣៦០០ ដែលបានថតទុក។ ១៩៥០ មានឯកសារ ៤០០០។ .

បណ្ណាល័យពុទ្ធសាសបណ្ឌិត្យ មានសៀវភៅប្រហែលជាងមួយម៉ឺនក្បាល ព្រមទាំងសាស្ត្រាស្លឹករឹត។

សទ្ទពិម្ពាល័យមានថាសជាងបីរយ។ ការបោះពុម្ពទស្សនាវដ្ដី «កម្ពុជ-សុរិយា » ក៏បានធ្វើជាលំដាប់តមក។ សារមន្ទីរតូចដែលមានព្រះពុទ្ធរូបខ្លះ ទេវរូប អាទិទេវរូប និងបុរាណវត្ថុ ដែលមានមន្ទីរ គីល-មេត៍ បានធ្វើអំណោយមានក្បាច់ចម្លាក់សិល្បៈជាដើម រចនាឱ្យចិន្តាបស្ចិមប្រទេស និងចិន្តាបូព៌ាប្រទេសលាយឡំគ្នាទៅជាសាមគ្គីភាពដ៏ប្រសើរ។

បើតាមពិនិត្យឱ្យច្បាស់លាស់ ពុទ្ធសាសនបណ្ឌិត្យ ជាស្នាដៃនៃលោកស្រី

---

៣- រ៉ាយ ប៊ុក ព្រះពុទ្ធសាសនានៃកម្ពុជា ភ្នំពេញ ឆ្នាំ ១៩៥៧ ទំព័រ ២១-២២

ស៊ុយ សានកាប៉ីឡែស លោកពីយែរឌុយម៉ុង លោក ប្រង់ ស្វាម៉ាទេីនី លោក យឿន ចឹម ដែលបានព្យាយាមរចនាវិជ្ជាស្ថាននេះ ទៅជាវិជ្ជាស្ថានវិទ្យាសាស្ត្រសម័យនិយម មានកិត្តិនាមល្បីល្បាញក្នុងពិភពលោក ។

ពុទ្ធសាសនបណ្ឌិត្យ ពីដើមជាក្រុមនៃរាជការសហរដ្ឋ ឥឡូវបានផ្ទេរមកឱ្យរដ្ឋាភិបាលខ្មែរពីថ្ងៃទី ១៤ តុលា ១៩៥០ ដោយអនុវត្តន៍ទៅតាមសន្ធិសញ្ញា បារាំង-ខ្មែរ ៨ វិច្ឆិកា ១៩៤៩ និងកិច្ចព្រមព្រៀងចុះថ្ងៃទី ១៥ មិថុនា ឆ្នាំ ១៩៥០[៤] ។

( នៅមានត )

*គ្មានសុខដទៃក្រៃលែងជាងសន្តិភាព ។*

*សេចក្តីលោភនាំឱ្យអន្តរាយសន្តិភាព ។*

ព្រះមុនីកោសល **សោម ឈុន**

៤- រ៉ាយ ប៊ុក ព្រះពុទ្ធសាសនានៃកម្ពុជា ភ្នំពេញ ឆ្នាំ ១៩៥៧ ទំព័រ ២៣

# កំណត់សម្គាល់ និង ការប្រើប្រាស់ នាមព្រះមហាក្សត្រខ្មែរ នាសម័យបុរាណ : តាមរយៈសិលាចារឹក

## Note on the Name of Ancient Khmer King and Its Orthographical Usage: Through Inscriptions

ខង់ សុធាវ៉ា

សាស្ត្រាចារ្យដេប៉ាតឺម៉ង់ប្រវត្តិវិទ្យា

នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ

### គ សម័យក្រោយអង្គរ

នៅសម័យនេះ សិលាចារឹកដែលនិយាយអំពីឈ្មោះរបស់ព្រះរាជា មានចំនួនតិចតួច ដូចជានៅអង្គរវត្ត និង លើភ្នំបាខែង ។ តាមរយៈសិលាចារឹក ទាំងនេះ យើងអាចដឹងបានខ្លះអំពីឋានន្តរនាម ឬ បច្ចេកស័ព្ទ ដើម្បីស្គាល់ព្រះរាជា ។ ចំណែកពាក្យ *វម្ម៌* ឬ *ពម្ម៌* ដែលយើងធ្លាប់ឃើញប្រើជារហស្សនាម(epithet)ព្រះ‑រាជាគ្រប់អង្គនាសម័យអង្គរ ត្រូវបានគេបន្តប្រើខ្លះៗទៀត នៅសម័យក្រោយអង្គរ (សម័យកណ្ដាល) ។ ប៉ុន្តែសព្វថ្ងៃ យើងឃើញគេប្រើច្រឡំ ដោយសរសេរថា : "ពណិ" ទៅវិញ[១] ដូចជា ព្រះបាទ ស្រីសុរិយោពមិ (១៦០៣‑១៦១៨គ.ស.) គេសរសេរជា "សុរិយោពណិ" បែបនេះ ។[២]

---

[1] សូមមើល. វង់ សុធារ៉ា *ឯកសារដដែល* ទំព័រ ៤៨ ។

[2] សូមមើល. សួរ អឿ *ប្រវត្តិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា ជាមួយអណ្ណាម និងសៀម ចាប់ពីសតវត្សទី១៦* ភ្នំពេញ ទំព័រ ១៦. ២៥ ។

រីឯឋានន្តរនាមរបស់ព្រះរាជាវិញ ខ្ញុំ ដែលមានដូចជា *សំតេចព្រះ* ឬ *ព្រះបាទ* ឬ *អ្នកព្រះ* ឬ *សំតេចព្រះបាទព្រះ* បន្ទាប់មក គឺ ឈ្មោះរបស់ព្រះរាជា ដែលបន្តដោយរាជបរិវារស័ព្ទដ៏ខ្ពង់ខ្ពស់យ៉ាងវែងអនេក ក្នុងនោះ ដែលជាសំខាន់បំផុតសម្រាប់សម្គាល់ជាព្រះរាជា គឺ *(អ)ធិរាជ ព្រះឱង្ការ* និង *(បរម)បពិត្រ* ដែលពាក្យចុងក្រោយនេះ យើងឃើញគេប្រើចាប់តាំងពីរាជ្យព្រះបាទ សូរ្យវម៌ ទី១ មកម្ល៉េះ ។

ឧទាហរណ៍ *សំតេចព្រះ ជៃយ្យជេដ្ឋាធិរាជឱង្ការ បរមរាជាធិរាជ រាមាធិបតី ត្រីត្រិភវនាទិត្យ "ពម្ម" ធម្មិករាជ មនុវង្សោត្តរ មហាបរមចក្រពត្តិ រាជកម្ពុជ្ជេស្វរ សុរិន្ទតេជោជេយ្យ ត្រៃរត្នមកុដវិសុទ្ធ ជិនសាស្នធរ បរមក្ខុ បថម្ពករាជ......* ព្រះរាជាអង្គនេះ សោយរាជ្យនៅអំឡុងពាក់កណ្ដាលទី២ នៃសតវត្សរ៍ទី១៦ ដែលត្រូវនឹងចុងសម័យលង្វែក ដែលមានរជ្ជទាយាទមួយព្រះអង្គ នាម *សម្ដេចព្រះបរមរាជាធិរាជបពិត្រ* ប្រសូត្រនៅឆ្នាំ១៥៧៩គ.ស. ។[៣]

[3] សូមមើល. មហាពិទូរ ក្រសេម *សិលាចារឹកនគរវត្ត* លេខ ៣ បន្ទាត់ទី៩-១៣ ទំព័រ ៥ ។ តាមក្បួនពង្សាវតារ ដែលមានរហូតដល់សព្វថ្ងៃនេះ ព្រះរាជាកំពុងសោយរាជ្យ នាពេលនោះ នាម ព្រះ*សត្ថាទី១* ដែលមានរាជបុត្រាពារអង្គ ។ បុត្រាច្បង លើកឡើងឱ្យគ្រងរាជ្យនៅឆ្នាំ១៥៨៥គ.ស. ក្នុងជន្មាយុ១១វស្សា នាម ព្រះ*ជ័យជេដ្ឋាទី១* ដែលបើតាមចារឹកពេលជាមួយនោះ ព្រះ*ជ័យជេដ្ឋា* មានមហេសីពីរអង្គ និងរាជបុត្រនាមព្រះ*បរមរាជា* ដែលប្រសូត្រកាលពីគ.ស.១៥៧៩ ។ បញ្ហានេះមិនមានអ្នកស្រាវជ្រាវណាដោះស្រាយរួចនៅឡើយ ដោយសារខ្វះខាតពត៌មានបន្ថែម គឺមានតែបណ្ឌិត មិក់ វឿនប៉ុណ្ណោះ ដែលសន្និដ្ឋានថា នាម *ជៃយ្យជេដ្ឋា* ក្នុងសិលាចារឹកនេះ ប្រហែលគ្រាន់តែជា "រហស្សនាម(épithète)" សម្រាប់រាជ្យ ។ ប្រៀបដូចជា ព្រះបាទអង្គឌួង ទ្រង់មានបរមនាមសម្រាប់រាជ្យថា *ហរិរក្សរាមា* ផ្ទុយទៅវិញ បរមនាមនេះកម្រឃើញមានគេប្រើ ឃើញមានប្រើតែនាមពេលនៅជាអ្នកអង្គម្ចាស់ដដែល ។ ចំណែក ព្រះសត្ថាទី១ ក៏ប្រហែលជាដូចគ្នានេះដែរ គឺជា

*ព្រះបាទ ជេយជេដ្ឋាធិរាជ ឱង្ការបពិត្រ* គឺព្រះរាជាមួយអង្គ ដែលសោយរាជ្យនៅអំឡុងពាក់កណ្តាលទី២សតវត្សរ៍ទី១៦( ១៥៨៣គ.ស.) ។[៤]

*រាជអ្នកព្រះបរមរាជាធិរាជ* គឺព្រះមហាក្សត្រព្រះនាម *បរមរាជា* ដែលរជ្ជកាលរបស់ ព្រះអង្គនៅអំឡុងឆ្នាំ ១៦៣៥គ.ស. ។[៥]

*សំតេចព្រះបាទព្រះជៃ្យជេស្ឋាធិរាជ រាមាធិប្បតិ បរមនាដ្ឋ ព្រះបាទបរំមបុពិត្រ* ដែលរជ្ជកាលព្រះអង្គមានសង្គ្រាមក្នុងស្រុកកើតឡើង ហើយព្រះអង្គក៏បានភៀសព្រះកាយទៅស្រុកសៀម ។ ក្រោយពីមន្ត្រីរបស់ព្រះអង្គ ជួយច្បាំងដណ្តើមអំណាចប្រកបដោយជោគជ័យ ព្រះអង្គត្រឡប់មកគ្រងរាជ្យវិញ នៅអំឡុងឆ្នាំ១៧៤៧គ.ស. ។[៦]

---

នាមពេលនៅជាព្រះអង្គម្ចាស់ ។ រីឯរហស្សនាមបន្ទាប់ *បរមរាជា* បណ្ឌិត ភឿន ថា គួរអោយយកជាការបាន ។ ព្រោះឆ្លើយត្រូវគ្នានឹងនាមមួយទៀត របស់ព្រះបាទ*សត្ថាទី១* នៅក្នុងពង្សាវតារ ។ Cf, Mak Phoeun, *Histoire du Cambodge* de la fin du XVI^e siècle au début du XVIII^e, Paris 1995, pp. 28-35.

[4] Cf, Khin Sok, Deux Inscriptions Tardives du Phnom Bàkhèng K 465 et K 285, dans *BEFEO*, t. LXV (I), 1978, pp.271-80. គឺព្រះរាជា *ជ័យជេដ្ឋា* ដដែល ដូចបានអធិប្បាយខាងលើ ។

[5] Cf, ម. ក្រសេម *Ibid*, pp. 52-4. តាមសៀវភៅពង្សាវតារ អំឡុងពេលនោះនៅក្នុងរាជ្យ ព្រះបាទ *ធម្មរាជា (ចៅពញាតូ)* ឬ *ធម្មរាជាព្រះរាជសម្ភារ* ដែលជារជ្ជទាយាទព្រះបាទ *ជ័យជេដ្ឋា ទី២* (១៦១៨-១៦២៨គ.ស.) ។ តាមការពិនិត្យផ្ទៀងផ្ទាត់គ្នាជាមួយឯកសារជាច្រើនផ្សេងៗគ្នា យើងរកឃើញថា ព្រះពញាតូ នៅពេលឡើងសោយរាជ្យ គ្មាននាមអ្វីក្រៅពី*ធម្មរាជាព្រះរាជ សម្ភារ* នេះឡើយ ។ អក្សរដែលគេចារឹកលើថ្មនោះមិនអាចខុសទេ ដោយសារគេចារឹកនៅពេល ស្តេចអង្គនេះគង់ជាធរមាននៅឡើយ ។ ចំណែក អ្នកចារពង្សាវតារ ក៏តែងចម្លងតាមគ្នា ឬ តាមការទន្ទេញចេះចាំមាត់របស់ខ្លួន ហេតុនេះយើងជឿថា ងាយធ្វើអោយមានការ ភ្លាំងភ្លាត់ខុសឆ្គង បានឬមួយក៏ មកពីមានព្រះរាជាពីរអង្គសោយរាជ្យលើទឹកដីខ្មែរ ក្នុងពេលដំណាលគ្នា ? ។

[6] Cf, *Ibid*, pp. 111-7.

ដោយសារភាពសម្បូណិបែបនៃការប្រើប្រាស់ឋានន្តរនាម របស់ព្រះរាជា ដូចនេះហើយ ទើបធ្វើអោយសព្ទនាមសម្គាល់ព្រះរាជាក៏សម្បូណិបែបដែរ ។ ព្រោះភាគច្រើននៃរាជសព្ទនាម គេច្រើនប្រើប្រាស់ឋានន្តរនាមទាំងនោះ ផ្សំជាមួយរាជស័ព្ទខ្ពង់ខ្ពស់មួយចំនួនទៀត ។

ដូចជាពាក្យ *ធូលីវ្រះបាទធូលីជេងវ្រះកម្រតេងអញ្ជបរមបវិត្រ*[7] ឬ *វ្រះករុណាតបរមបវិត្រ*[8] ជាដើម ។ ប្រពៃណីបែបនេះ ត្រូវបានបន្សល់ទុករហូតដល់សព្វថ្ងៃ ជាក់ស្តែងក្នុងការហៅ "ព្រះរាជា" យើងអាចប្រើសព្ទនាមបានជាច្រើនបែប ។

## ២- អំពីពាក្យ "វម៌្ម varmma" និង "វម៌្មទេវ varmmadeva"

ពាក្យទាំងពីរនេះ យើងបានបង្ហាញជូនពីខាងដើមរួចហើយ បើនិយាយដោយសង្ខេបឡើងវិញ គឺនៅពេលណា នរនាមមួយបញ្ចប់ដោយពាក្យ "--វម៌្ម" សម្គាល់ថា "ជានាមព្រះមហាក្សត្រនៅសម័យមុនអង្គរ" ចំណែក នរនាមណាបញ្ចប់ដោយពាក្យ "---វម៌្មទេវ ឬ ---វម៌្មទេព" សម្គាល់ថា "ជានាមព្រះមហាក្សត្រនៅសម័យអង្គរ" ។

### ក- ពាក្យ វម៌្ម varmma

បើនៅលើសិលាចារឹក បុព្វបុរសខ្មែរបុរាណសរសេរថា "--វម៌្ម" ហេតុអ្វីបានជាជនជាតិខ្មែរសព្វថ្ងៃ ស្គាល់ និងប្រើជា "--វរ្មន varman" ទៅវិញ? តាមសម្តេចសង្ឃរាជ ជួន ណាត "វរ្មន" ជាភាសាសំស្ក្រឹត(វម៌ន) មានន័យថា:

[7] Sambor inscrip. K 125, in *BEFEO, t. XXVIII:* 140-1.
[8] Cf, Banteay Chmar, new inscrip. K 1183B: 7-8 dated 928śaka (= 1006A.D.)

គ្រោះ ឬ អាវគ្រោះ[៩] (សម្រាប់ពាក់ការពារដើមទ្រូង ឬ ខ្លួន) ឬ ជា អ្នកការពារ ។ វាជានាម ដែលមិនទាន់បំបែក ឬ ជាពាក្យដើម (infinitive) ។

លោក ឈឹម ក្រសេម ក៏បានបញ្ចេញមតិលើពាក្យ វរ្ម័ន នេះដែរ ។ ដោយលោកបានពន្យល់ថា ពាក្យ "វរម័ន" ដែលគេប្រើនាពេលសព្វថ្ងៃ(នៅសម័យអាណាព្យាបាលបារាំង) ពីដើមខ្មែរយើង សរសេរជា "វម្ម៌" ឬ "ពម្ម៌" បន្ទាប់មកតាមពង្សាវតារជាន់ក្រោយ(អង្គរ) សរសេរជា "ពា៌" ឬ "ពាណ៌" ដូចយ៉ាងព្រះនាមស្ដេចមួយអង្គ ថា សុរិយោពាណ៌ ដែលនេះគឺ សុរិយវម្ម៌ ឬ សុរិយពម្ម៌ ។[១០]

បើតាមអ្នកស្រីបណ្ឌិត ពៅ សាវរស ថាពាក្យ "វម៌"នេះ អ្នកប្រាជ្ញបារាំងបុរាណ (មាន Louis Finot, G. Coedès... etc.)[១១] ចាប់អារម្មណ៍ក៏ភ្ជាប់ភ្ជាមទៅនឹងអក្សរតាមិល(Tamil) គឺ varman ដាច់ខាត ។ ដោយសារ ពួកគាត់គ្មានពេលពិចារណាលើឯកសារដ៏ច្រើនអនេកនោះទេ ។ រីឯពាក្យ ដែលខ្មែរបុរាណបានខ្ចី (វមិន)មក ប្រើត្រឹមតែ "វម្ម៌" ប៉ុណ្ណោះ ដែលពាក្យ នេះ អាចអានថា : វ៌ ឬ ព៌ bar, bɔɔr ដូចគ្នានឹងពាក្យ ធម៌ ពណ៌ គភ៌ និង ព្រះនាម សុរិយោពម៌ (មហាក្សត្រខ្មែរនៅដើមសតវត្សរ៍ទី១៧) ។ បើតាមភាសាខ្មែរមានតែប៉ុណ្ណឹង[១២] ចំណោក

[9] វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ. ១៩៦៧. *វចនានុក្រមខ្មែរ* ភ្នំពេញ បោះពុម្ពលើកទី៥ ទំព័រ១១៩៤។

[10] មហាទេពពិទូរ ក្រសេម. ១៩៥៨. *សិលាចារឹកនគរវត្ត* ពុទ្ធសាសនបណ្ឌិត្យ បោះពុម្ពលើកទី២ ភ្នំពេញ ទំព័រ ១៣៣-៤ ។

[11] គឺអ្នកស្រាវជ្រាវជាតិបរទេសទាំងអស់ ។

[12] Cf, *Journal Asiatique,* Année 1971, Recherche sur le vocabulaire cambodgien, par POU Saveros, pp. 123-4. លើសពីនេះ គាត់បានពន្យល់ខ្ញុំ តាមរយៈសំបុត្រមួយ ចុះថ្ងៃទី ៣០ កក្កដា ឆ្នាំ ២០០០ ។

នៅក្នុងវចនានុក្រមរបស់អ្នកស្រី varma ថាជាភាសាសំស្ក្រឹត [១៣] ។

រីឯក្នុងវចនានុក្រមភាសាសំស្ក្រឹត varman មានន័យថា ស្រោមសំបុត្រ (envelope) ឬអាវក្រោះការពារ (defensive armour) ។ បើតាមឫគ្មេទ ថា varman ជា ក្រោះ(shelter) ការពារ(defense) និង ការថែរក្សាការពារ (protection) ដែលជាញឹកញាប់គេប្រើនៅខាងចុងនាមក្សត្រិយ៍ ឬ ជាឈ្មោះនៃរូបមន្តគាំពារ និង អ្នកបួងសួងពិសេស ហើយ varma ជាពាក្យនៅក្នុងសមាស-ធាតុពាក្យ(in compound for) varman បើជាvarmā វិញ សម្គាល់ភេទស្រី ។[១៤]

តាមការពិត អ្នកប្រាជ្ញខ្មែរបុរាណមានចំណេះដឹងជ្រៅជ្រះ សុខុម លើបញ្ហាភាសាសំស្ក្រឹត ទើបលោកទាំងនោះ អាចនិពន្ធជាអត្ថបទកំណាព្យសំស្ក្រឹតបានយ៉ាងល្អ រហូតធ្វើអោយអ្នកប្រាជ្ញសំស្ក្រឹតជាតិឥណ្ឌាសព្វថ្ងៃ *កមលេស្វរ ភត្តចរិយៈ* (KAMALESWAR BHATTACHARYA) អះអាងថា អត្ថបទទាំងនោះ មានអត្ថន័យ អត្ថរូប និង អត្ថរសល្អវិសេស មិនចាញ់ស្នាដៃរបស់អ្នកប្រាជ្ញនៅស្រុកឥណ្ឌា ដែលជាម្ចាស់ភាសាផ្ទាល់ នាសម័យជាមួយគ្នានោះឡើយ ។ ដូចជា អត្ថបទកំណាព្យសំស្ក្រឹតមួយផ្ទាំងដ៏ធំ-វែង ចារឹកនាឆ្នាំ៩៦១ នៅប្រាសាទប្រែរូប ជា *បទមនោហរៈ* ដែលគេមិនដែលឃើញមានសោះ នៅស្រុកឥណ្ឌា[១៥] ។

ហេតុនេះ ការខ្ចីពាក្យឥណ្ឌា"វមិន" មកសរសេរជា "វម្ម៌" ដោយមានការផ្លាស់ប្តូរវិភត្តិបែបនេះ មិនមែនជាការ "ខុស" នោះទេ ត្បិតសំស្ក្រឹតតែងមាន

[13] Cf, Saveros POU, *Dictionnaire Vieux Khmer-Français-Anglais*, Paris, Cedoreck 1992, p. 433.

[14] See, M. Monier Williams, *A SANSKRIT-ENGLISH DICTIONARY*, New Delhi, 1995, p. 926.

[15] Hema Goonatilake, ***The discourse stated in the occasion of opening the first Socio-Cultural Research Training Seminar***, **13-18 January 1997 at RUPP II (Professor meeting hall).**

ការផ្លាស់ប្តូរវិភត្តិទៅតាមបុរិសៈ និងកាលស្របតាមក្បួនវេយ្យាករណ៍ជាក់លាក់ ដែលការនេះមិនខុសគ្នាពីក្បួនវេយ្យាករណ៍ភាសាឥណ្ឌូ-អឺរ៉ុបនោះទេ ។ បើតាមលោក ព្រហ្មចារីយ សាស្ត្រាចារ្យភាសាសំស្ក្រឹត នៅពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ថា varman ជានាមដើម(infinitive)ក្នុងភាសាសំស្ក្រឹត ។ ប្រសិនបើគេយកពាក្យនេះមកប្រើសម្រាប់ហៅឈ្មោះមនុស្ស វាត្រូវតែមានការផ្លាស់ប្តូរវិភត្តិជាចាំបាច់ ដើម្បីតម្រូវតាមក្បួនវេយ្យាករណ៍ varman ត្រូវក្លាយជា varmma វម្ម៌(ទម្រង់បុរាណ) ឬ varma វម៌(ទម្រង់ថ្មី) ឬ varmā វម៌ា (សម្រាប់ភេទស្រី)[១៦] ។

ដូច្នេះ ប្រការដែលខ្មែរសព្វថ្ងៃសរសេរ និងហៅពាក្យ *វ៉ាន* តាមគេ (បារាំង)យ៉ាងនេះ មិនត្រឹមត្រូវទេ ព្រោះបុព្វបុរស ធ្លាប់បានប្រើប្រាស់ពាក្យនេះជាយូរមកហើយថា *វម្ម៌* ឬ ពម៌(នៅចុង និងក្រោយសម័យអង្គរ) ។ ហេតុនេះគប្បីអ្នកស្រាវជ្រាវខ្មែរទាំងអស់គ្នា ជួយពិចារណាឡើងវិញ ។

## ខ‐ ពាក្យ វម្ម៌ទេវ varmmadeva

ដូចបានបង្ហាញពីខាងលើហើយ ថា នាមរបស់ព្រះមហាក្សត្រសម័យ អង្គរតែងតែបញ្ចប់ដោយពាក្យ "ទេវ deva" ទាំងអស់ ។ ប៉ុន្តែ បុព្វអ្នកប្រាជ្ញបារាំងបានកាត់ពាក្យ "ទេវ"នេះចោល ហើយដាក់ត្រឹមតែពាក្យ "វ៉ាន" នៅខាងចុង ដូចដែលលោក អ្នក ឃើញនាពេលបច្ចុប្បន្ន ។ ប្រការនេះធ្វើអោយអ្នកអាន ឬ អ្នកសិក្សាមួយចំនួនមានការងឿងឆ្ងល់ ឬ ភ័ន្តច្រឡំ នៅពេលអានផ្ទាំង

---

[16] បទសន្ទនារបស់ខ្ញុំជាមួយលោក ព្រហ្មចារីយ នៅ UNESCO Phnom Penh ព្រឹកថ្ងៃទី ៣១ កក្កដា ២០០០ ។

សិលាចារឹកដើម ពេលនោះគេក៏មិនអាចបែងចែកបាន ចំពោះនាមរបស់មន្ត្រីទាំងឡាយ និងរបស់ព្រះរាជា ។ ពីព្រោះតែនៅសម័យអង្គរ ងារ "វម្ម" ត្រូវបានគេបំពាក់អោយដល់មន្ត្រីទាំងឡាយ ឋានៈចាប់ពីមេតម្រួតពលថ្នាក់ស្រុកឡើងទៅ ហើយម្យ៉ាងទៀតដោយសារ គេមិនបានយល់អំពីអ្វីជា "ទេវរាជា" (កម្រតេងជគតតរាជ) ដែលបានផ្តើមសម្ពោធឡើង ចាប់ពីរាជ្យព្រះបាទជយវម៌្មទី២ ឆ្នាំ ៨០២គ.ស. ។

តាមចារឹកស្តុកកក់ធំ បានអោយដឹងថា ក្រោយពីផ្លាស់រាជធានីអស់ជាច្រើនដង ប្រយោជន៍បង្កលក្ខណៈងាយស្រួលដល់កិច្ចបង្រួបបង្រួមជាតិ ធ្វើសន្តិភាព និងឯកភាវូបនីយកម្មនយោបាយ ចុងក្រោយបង្អស់ព្រះអង្គបានលើក រាជធានីទៅតាំងនៅលើមហេន្ទ្របវត ឬ ភ្នំគូលេន ។ នៅទីនោះព្រះអង្គបាន អញ្ជើញព្រាហ្មណ៍ម្នាក់ឈ្មោះ *ហិរណ្យទាម* ដែលជាអ្នកប្រាជ្ញមានចំណេះវិជ្ជា ខ្ពង់ខ្ពស់ខាងមន្តអាគមមកធ្វើ *ពិធីបន្ថែម*[១៧] (វិធិលេហ=Supplementary Ceremony) ប្រឡេះប្រទេសកម្ពុជា (Kambujadeśa) កុំអោយវិលទៅនៅក្រោមអំណាចរបស់ជ្វាទៀត និង ធ្វើអោយមានតែព្រះមហាក្សត្រ(ជយវម៌្មទី២)មួយអង្គប៉ុណ្ណោះ ជា "ស្តេចចក្រពត្តិ" ឬ ចក្រវរតិន (Sovereign ruler = Cakravartin) ដោយព្រាហ្មណ៍នោះ សែកមន្តអាគមគាថាខាងសាសនា (magic-religious) តាមគម្ពីរវិនាសិខ (Vināśikha) ប្រតិស្ឋាន *កម្រតេង ជគត តរាជ* (Kamrateṅ jagat ta rāja = the Master of the Universe who is the King[18] or Dieu-Roi[19]) គឺ *ទេវរាជា* ។ ពីព្រោះ បើតាមភាសាខ្មែរបុរាណ *កម្រតេងជគត* =អាទិទេព ឬ ទេវ. *ត រាជ* = ដែលជាព្រះមហាក្សត្រ ឬ ព្រះរាជា ។ បន្ទាប់មក ព្រាហ្មណ៍ *ហិរណ្យទាម*

---

[17] Adhir Chakravarti 's translation.
[18] Cf, *Sdok Kak Thom II*: 95-8.
[19] Cf, *APK II:* 198,220.

និង ព្រះរាជាបានបញ្ញត្តិអោយ បច្ឆាជននៃវង្សរបស់ ព្រាហ្មណ៍ *សិវកៃវល្យ* តែមួយគត់ ជាអ្នកគ្រប់គ្រងថែរក្សា *កម្រតេង ជគត តរាជ* និងមាននាទីប្រតិបត្តិពិធីសាសនាតាមធម្មភាព ដែលខ្លួនបានរៀនចេះពី ព្រាហ្មណ៍ ហិរណ្យទាម ។ មិនតែប៉ុណ្ណោះអ្នកនេះឯង ត្រូវបានទទួលឋានៈជា អគ្គរាជបុរោហិត (អាចារ្យ ប្រធាន ឬ ហោតរតអគ្រ) របស់ព្រះរាជាផងដែរ ។

ចំណែកព្រះរាជា ដែលសោយរាជ្យជាបន្តបន្ទាប់មកក៏យកតម្រាប់តាមមាគ៌ារបស់ព្រះអង្គ រហូតដល់រាជ្យ ព្រះបាទហសិវម៌ទី៣ និង ជយវម៌ទី៦ ទើបយើងលែងឃើញមាននិយាយដល់ *កម្រតេង ជគត តរាជ* ហើយរាជបុរោហិតដែលមាននាទីជា ហោតរតអគ្រ ក៏មិនមែនជាបច្ឆាជនរបស់សិវកៃវល្យដែរ តែជាគ្រួសារមួយនៃវណ្ណៈ[២០] ទី៣ "កម្មាន្តរ" ដែលមានដើមកំណើតនៅភូមិវ្នុរទ្នង (ស្រុកវ្នុរទ្នង=ទួលធ្នង់?) ស្រុកសទ្យា(វិសយសទ្យា) ។ បុព្វបុរសនៃសន្តាននោះ *វ្រះកម្រតេងអញវិទ្នុទេវ* ជាបុរោហិតនៅឯប្រាសាទស្រីជលាង្គេស្វរ (ប្រាសាទព្រះធាតុទឹកឆា ស្រុកព្រៃឈរ) និងបងប្អូនប្រុសជាច្រើននាក់ទៀត ជា បុរោហិតនៅទីសក្ការបូជាដទៃទៀត តាំងអំពីរាជ្យព្រះបាទ ជយវម៌ទី៣ ។ នៅក្នុងត្រកូលនោះគ្រប់ជំនាន់មានអ្នកល្បីល្បាញ ជារាជបុរោហិតសំខាន់ៗ សម្រាប់ព្រះរាជា ដែលរហូតដល់ដំណាច់សតវត្សរ៍ទី១១ មាន វាគីស្វរបណ្ឌិត[២១] និង ទិវាករបណ្ឌិត ដែលជាអ្នកបានដឹកនាំធ្វើពិធីបូជាសំខាន់ៗ នៅក្នុងរាជ្យព្រះបាទ ឧទយាទិត្យវម៌ទី២ ហសិវម៌ទី៣ និងជាពិសេស ជាអ្នកធ្វើពិធីរាជាភិសេក ព្រះបាទ ជយវម៌ទី៦ ធរណិន្ទ្រវម៌ទី១

[20] លោក សឺដេស បកប្រែពាក្យ "វណ្ណ-varṇṇa" នៅក្នុងសិលាចារឹកថា ជា "ក្រុមសាជីវកម្ម= la corporation" ។

[21] Cf, Kuk Trapeang Sruk inscrip. K 91d:1-2, *C II:* 130.

និង សូរ្យវម៌្មទី២ ឡើងសោយរាជ្យ ។[២២]

ទោះជាមានការប្រែប្រួលខ្លះ នៅចុងសតវត្សរ៍ទី១១យ៉ាងនេះក្តី ក៏នាមរបស់ព្រះរាជា ដែលបញ្ចប់ ដោយពាក្យ *-វម៌្មទេវ* មិនបានប្រែប្រួល ឬ ត្រូវគេបោះបង់ចោលដែរ ។

នេះជាទឡ្ហីករណ៍មួយ បង្ហាញអំពីមូលហេតុនៃការប្រើពាក្យ "ទេវៈ" របស់ព្រះរាជាខ្មែរនៅសម័យអង្គរ ។ ចំណែកបញ្ហាមួយទៀត ដែលគួរលើកយកមកពិចារណាដែរនោះ គឺពាក្យ *-វម៌្មទេវ* នេះ យើងឃើញមានប្រើតាំងពីសម័យមុនអង្គរមកម៉្លេះ គឺប្រហែលជាក្នុងរាជ្យ ព្រះបាទ *ជយវម៌្មទី១ស្ងួន* នៅអំឡុងពាក់កណ្តាលទី២នៃសតវត្សរ៍ទី៨ ដែលសិលាចារឹកពីរជាភាសាសំស្ក្រឹត ស្តីអំពីពតិមានរបស់ព្រះអង្គ ត្រូវបានគេបានរកឃើញ នៅប្រាសាទព្រះធាតុព្រះស្រី ក្នុងស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ដែលមានកាលបរិច្ឆេទឆ្នាំ ៧៧០គ.ស.[២៣] ។ មួយទៀតនៅល្បើកស្រុត ទិសឥសាននៃខេត្តក្រចេះ ចម្ងាយប្រមាណ៤០គីឡូម៉ែត្រ ដែលមានកាលបរិច្ឆេទឆ្នាំ ៧៨១គ.ស. ។

បើតាមចារឹកទាំងពីរនេះ យើងមិនអាចអះអាងថា នាមព្រះអង្គមានភ្ជាប់ដោយពាក្យ "ទេវ" នៅខាងចុងនោះទេ ។ ប៉ុន្តែដោយ ផ្អែកលើភស្តុតាងនៃសិលាចារឹកពីរទៀត នៅក្នុងអំឡុងសតវត្សរ៍ទី៨នោះដែរ មួយនៅព្រៃចារែកស្រុកកំពង់ត្របែក ខេត្តព្រៃវែង ដែលមានអក្សរតែពីរបន្ទាត់ប៉ុណ្ណោះ ជាភាសា ខ្មែរបានចារឹកនាមព្រះរាជាមួយព្រះអង្គ នាម *វ្រះកម្រតេងអញ្ឆ្រីជយវម៌្មទេវ*

[22] Cf, *Ibid* and Phnom Sandak and Phnom Preah Vihear inscrips. K 194 and K 383 in *APK II*: 245-65.
[23] Cf, K 103N: 2, in *C V*: 33-4.

ដែលលោក សឺដេស សន្និដ្ឋាន ថាប្រហែលជាព្រះបាទ ជយវម៌្មទី១ស្ទួន ។[២៤]

ចារឹកមួយទៀតនោះ ដែលខ្ញុំទើបនឹងរកឃើញកាលពីចុងឆ្នាំ១៩៩៧ នៅលើកំពូលភ្នំពោធិញាន (ភ្នំដែលនៅខាងកើត ជាប់នឹងភ្នំបាយ៉ង់កោ) ស្រុកគីរីវង់ ខេត្តតាកែវ ជាភាសាសំស្រ្កឹត លាយខ្មែរ ។ អត្ថបទផ្នែក ភាសាខ្មែរមាននាមព្រះរាជាមួយអង្គ គឺ *វ្រះកម្រតាងអញ ស្រីជយវម៌្មទេវ* ដែលយើងសន្និដ្ឋានថានោះពិតជានាម របស់ព្រះបាទ ជយវម៌្មទី១ស្ទួន ត្បិតចារឹកនេះមានកាលបរិច្ឆេទនៅអំឡុងសតវត្សរ៍ទី៨ដែរ តែគួរស្តាយនោះគឺ យើងមិនអាចដឹងឆ្នាំពិតប្រាកដ ព្រោះតែអក្សរខាងដើមដាច់បាត់ នៅសល់តែផ្នែកពាក់កណ្តាល ដែលអាចអោយដឹងថា វាត្រូវនឹងមហាសករាជ៦០០ប្លាយ ។[២៥]

នេះសរអោយឃើញថា ធម្មភាព"ទេវរាជា" មិនមែនជាលទ្ធិមួយថ្មីស្រឡាង ដែលទើបបង្កើតឡើងនៅឆ្នាំ៨០២គ.ស.ដោយព្រះបាទ ជយវម៌ទី២ ឬក៏ត្រូវព្រះអង្គនាំយកមកពីស្រុកជ្វា ដូចលោក Bosch បាននិយាយថា នៅស្រុកជ្វាមាន*ទេវរាជា* ស្រដៀងគ្នានេះដែរ[២៦] ឬមួយក៏យកតម្រាប់តាមចាម្បនោះទេ ។ អាចនិយាយបានថា ព្រលឹងនៃទេវរាជា មានការជាប់ទាក់ទងនឹងប្រពៃណីនៃការគោរពបូជាចំពោះអាទិទេពនៅលើកំពូលភ្នំធម្មជាតិ ឬភ្នំសិប្បនិម្មិត ដែលមានតាំងពីយូរយារមកហើយ (អាចដើមគ.ស. សម្រាប់ខ្មែរ=នគរភ្នំ!) សម្រាប់បណ្តារដ្ឋដែលទទួលឥទ្ធិពលសាសនាព្រាហ្មណ៍ លោកសាស្រ្តាចារ្យ R.C. Majumdar ក៏យល់ឃើញយ៉ាងនេះដែរ ។[២៧] ចំណែក ព្រះបាទជយវម៌ទី២ គ្រាន់តែបានធ្វើអោយលទ្ធិ

---

[24] Cf, K 48 in *C.VI:* 27.
[25] Ka 63 in the new inventory organized by Dr. Michel Tranet.
[26] *BEFEO,* XXV, p. 391.
[27] Cf, Majumdar, *KAMBUJA-DE⌒A or An Ancient Hindu Colony in CAMBODIA,* Madras 1944, p.77.

នេះមានលក្ខណៈកាន់តែច្បាស់ ឡើង (Realization)តែប៉ុណ្ណោះ ។[២៨]

ហេតុដូច្នេះ ការបន្ថែមពាក្យ "ទេវ" បន្ទាប់ពាក្យ "វម្ម" បែបនេះ គឺ ជានយោបាយចាំបាច់មួយរបស់ព្រះរាជា ក្នុងកំណែទម្រង់របបគ្រប់គ្រង ប្រយោជន៍ប្រមូលផ្តុំទឹកដី ប្រជារាស្ត្រ ការជឿទុកចិត្ត មហាកម្លាំងសាមគ្គី[២៩] និងអំណាចរបស់ព្រះអង្គក្នុងកាលៈទេសៈប្រទេសជាតិមានវិបត្តិផ្ទៃក្នុង ដោយការបាក់បែក និងកោលាហល ក្រោយពីក្រុមចោរបរទេស (ជ្វា) ឈ្លានពាន ។

*កើតមកជាកូនប្រុស*
*ត្រូវតែខំប្រឹងបំពេញករណីកិច្ច*

*លុះត្រាតែបាន សម្រេច ។*
*ការអ្វីមិនទាន់ សម្រេច*
*កុំអាលប្រញាប់ ពោលអួត ។*

សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយក
គណៈមហានិកាយ ជោតញ្ញាណោ **ជួន ណាត**

---

28 សូមមើល. ត្រឹង ងា *ប្រវត្តិសាស្ត្រខ្មែរ* ភាគ១ ភ្នំពេញ ១៩៧៣ ទំព័រ ១៣៧-៨ ។

29 សូមមើល. លី គឹមឡុង "អ្វីជាកំលាំងនៃសាមគ្គីខ្មែរសម័យអង្គរ?" ក្នុង *ទស្សនាវដ្តី មហាវិទ្យាល័យអក្សរសាស្ត្រ-មនុស្សសាស្ត្រ* ឆ្នាំទី២ លេខ៣ ឆ្នាំ១៩៧២ ភ្នំពេញ ទំព័រ ៥០ ។

# ឱសថបុរាណខ្មែរ

( ត )

ដោយ សួន ឱសថ

## ២ _ ជំពូកវល្លិ៍

បានដល់រុក្ខជាតិ ដែលមានពូជប្រភេទជា " វល្លិ៍ " មានឈ្មោះទម្លាប់ហៅមកពីបុរាណ មានដុះនៅតាមព្រៃភ្នំខ្លះនៅតាមព្រៃរនាមខ្លះ នៅតាមភូមិខ្លះ និងការដាំដុះ ( កសិកម្ម )ខ្លះដូចជា :

| | |
|---|---|
| វល្លិ៍ ត្រដិតស | វល្លិ៍ ត្របែងជើងក្អែង |
| វល្លិ៍ ត្រដិតក្រហម | វល្លិ៍ ដំឡូងព្រៃ |
| វល្លិ៍ កំបោរស | វល្លិ៍ ដំឡូងជ្រូក |
| វល្លិ៍ តាអើក | វល្លិ៍ ដំឡូងទឹក |
| វល្លិ៍ ប្រេងស | វល្លិ៍ ដំឡូងទៀន |
| វល្លិ៍ ប្រេងក្រហម | វល្លិ៍ ដំឡូងដៃខ្លា |
| វល្លិ៍ ត្រសក់ក្អែក | វល្លិ៍ ប្រហៀវខ្មុត ( កណ្ដៀវខ្មុត ) |
| វល្លិ៍ ផ្ទោម | វល្លិ៍ ដំឡូងខ្យា |
| វល្លិ៍ ជុយ | វល្លិ៍ ដំឡូងពស់ |
| វល្លិ៍ ស្លត | វល្លិ៍ ដំឡូងដូង |
| វល្លិ៍ បាស់ | វល្លិ៍ ដំឡូងកាយពីង |
| វល្លិ៍ ននោងព្រៃ | វល្លិ៍ ស្ដាំព្រៃ |
| វល្លិ៍ ននោងជ្រុង | វល្លិ៍ ស្ដាំស្រុក |

| | |
|---|---|
| វល្លិ៍ ននោងប្រហើរ | វល្លិ៍ ឱជុំតូច |
| វល្លិ៍ ត្រី | វល្លិ៍ ឱជុំធំ |
| វល្លិ៍ អណ្តាតត្រគួត | វល្លិ៍ ឡ |
| វល្លិ៍ ខ្ទួត | វល្លិ៍ ឆ្អឹងពស់ |
| វល្លិ៍ ភ្នំ | វល្លិ៍ រេ |
| វល្លិ៍ រមៀត | វល្លិ៍ ទទុង |
| វល្លិ៍ យាវ | វល្លិ៍ ទទឹងក្រហម |
| វល្លិ៍ វ៉ាក់វើក | វល្លិ៍ មាស |
| វល្លិ៍ អាណោ | វល្លិ៍ ត្រណោតត្រី |
| វល្លិ៍ ទ្រនុំបង្គួយ | វល្លិ៍ រពាក់ |
| វល្លិ៍ ពស់ | វល្លិ៍ ផ្តៅ |
| វល្លិ៍ ដែក | វល្លិ៍ ក្របីព្រោស |
| វល្លិ៍ គុយ | វល្លិ៍ ក្អែប |
| វល្លិ៍ ជណើរ | វល្លិ៍ កាប |
| វល្លិ៍ អង្កុញ | វល្លិ៍ កណ្តឹងដីរ |
| វល្លិ៍ វ៉ាយ | វល្លិ៍ ក្បៀសធំ |
| វល្លិ៍ ដក់ពាយ | វល្លិ៍ កន្ទុយហនុមាន |
| វល្លិ៍ ដូងព្រះ | វល្លិ៍ កុកសោម |
| វល្លិ៍ លិច | វល្លិ៍ ឃ្នាយ |
| វល្លិ៍ កំបោរភ្នំ | វល្លិ៍ ជីងចក់ |
| វល្លិ៍ ដៃខ្មោច | វល្លិ៍ ដីរប្រាំដក |

| | |
|---|---|
| វល្លិ៍ ជ្រលុងស | វល្លិ៍ ទ្រាលស្វា |
| វល្លិ៍ ជ្រលុងក្រហម | វល្លិ៍ ទ្រាលដោះក្របី |
| វល្លិ៍ យិតថ្ងលឿង | វល្លិ៍ ទាត់បោះ |
| វល្លិ៍ ជើងក្អាម | វល្លិ៍ បណ្ដូលពេជ្រ |
| វល្លិ៍ ត្នោត | វល្លិ៍ ប្រក្រុង |
| វល្លិ៍ ម្រះ | វល្លិ៍ អំបោះព្រះ |
| វល្លិ៍ កុមារពេជ្រ | វល្លិ៍ ទាស់ |
| វល្លិ៍ ម្រេច ស្រុក | វល្លិ៍ ក្រូច |
| វល្លិ៍ ម្រេច ព្រៃ | វល្លិ៍ ដោះគុន |
| វល្លិ៍ ដីប្អី | វល្លិ៍ ឃ្មេ |
| វល្លិ៍ ឈាម | វល្លិ៍ ស្នែងពណិ |
| វល្លិ៍ ផ្ដៃម | វល្លិ៍ ស្ពឹង |
| វល្លិ៍ ក្រេមក្រម | វល្លិ៍ សណ្ដែកគួរ |
| វល្លិ៍ សេដាព្រៃ | វល្លិ៍ ដីស |
| វល្លិ៍ សំបុកស្រមោច | វល្លិ៍ ក្ដូច |
| វល្លិ៍ ស្នែង | វល្លិ៍ ប្រង់ |
| វល្លិ៍ ឡេវអាវ | វល្លិ៍ ពស់ |
| វល្លិ៍ អានសេះ | វល្លិ៍ ក្អែក |
| វល្លិ៍ គ្រប់( គ្រប់វល្លិ៍) | វល្លិ៍ ត្រសក់ក្អែក |
| វល្លិ៍ ឪឡឹក | វល្លិ៍ ននោងពស់ |
| វល្លិ៍ ត្រសក់ | វល្លិ៍ សាឡិត |

| | |
|---|---|
| វល្លិ ល្ពៅ | វល្លិ ម្លូ |
| វល្លិ ត្រឡាច | វល្លិ សាំវម៉ាវព្រៃ |
| វល្លិ ឃ្លោក (បន្លែ) | វល្លិ សាមសិប |
| វល្លិ ពពាយ | វល្លិ ខ្សែល្វស |
| វល្លិ រំជាន់ | វល្លិ ទំពាំងបាយជូ (ព្រៃ-ស្រុក) |
| វល្លិ តាឡុង | វល្លិ ដំឡូងជ្វា |
| វល្លិ ពោះអំបែក | វល្លិ ក្របីជល់ដី ... ជាដើម ។ |

## ៣ ~ ជំពូកមើម

ជាប្រភេទរុក្ខជាតិ មានពូជជាមើម ដុះដោយការដាំដុះ(កសិកម្ម) ដុះតាមធម្មជាតិ មាននៅតាមព្រៃភ្នំ ព្រៃរនាម ខ្ពស់រាប ក្នុងទឹក ដូចជា :

| | |
|---|---|
| មើម ខ្នាយ | មើម ក្តួចស្វិត |
| មើម ខ្ទឹមស | មើម ប៉ប្រក |
| មើម ខ្ទឹមក្រហម | មើម ឆ្អឹងនាគ |
| មើម ខ្ទឹមបារាំង | មើម ដំឡូងឈើ |
| មើម ខ្ទឹមគុយទាវ | មើម ដំឡូងទៀន |
| មើម កាឆាយ | មើម ដំឡូងដៃខ្លា |
| មើម រំដេង | មើម ដំឡូងដូង |
| មើម ខ្ញី | មើម ដំឡូងជ្វា |
| មើម តាថុក | មើម ដំឡូងឈាមមាន់ |
| មើម ក្តាត | មើម ដំឡូងពស់ |
| មើម ត្រាវ | មើម ដំឡូងទឹក |

| | |
|---|---|
| មើម ដំឡូងព្រៃ | មើម ដំឡូងខ្យា |
| មើម សាមសិប | មើម ឆៃថាវ |
| មើម កុមារពេជ្រ | មើម ការ៉ុត |
| មើម ម្រោច | មើម ដំឡូងបារាំង |
| មើម តាកោ | មើម ស្ពាំព្រៃ |
| មើម តាកី | មើម ស្ពាំស្រុក |
| មើម ភ្លៅមាន់ | មើម អាចម៍ជ្លីស |
| មើម ដឹស | មើម ទាល់ |
| មើម ក្ដួច | មើម ម៉ូវ |
| មើម ប្រង់ | មើម ត្រាវព្រៃ |
| មើម ក្រវ៉ាញ | មើម ស្មៅក្រចាប់ |
| មើម កាប (វល្លិកាប) | មើម ប្រទាលសារិកា |
| មើម ក្បៀសធំ | មើម ប្រទាលជម្ពូពាន |
| មើម កន្ទ្រាំធារី | មើម ប្រទាលត្រសក់ |
| មើម កំភ្លឹង | មើម ប្រទាលគីង្គក់ |
| មើម ឃ្លាយ | មើម ប្រទាលកំពត |
| មើម ចែង | មើម ប្រទាលលុង |
| មើម ចាចុះ | មើម ប្រទាលព្រះអង្គោល |
| មើម ជុយ | មើម ប្រទាលមហាជម្ពូ |
| មើម ឈើទាលត្រាញ់ | មើម ចន្ទ |
| មើម ឈូក | មើម ទំពាំងបាយជូរ |

| | |
|---|---|
| មើម ប្រលិត | មើម រំចង់ |
| មើម តៅហួក | មើម រលកកែវ ( ប៊ុគក់ព្រៃ ) |
| មើម បង្គីរ | មើម រង្វាយទិល |
| មើម ត្រស់ធំ | មើម រង្វាយទិលភ្លើង |
| មើម ប្រស់ស្វា | មើម រមៀត |
| មើម ប៊ុគក់ | មើម លាចផ្ទុះ (ស្មៅ) |
| មើម ប្រទាលពានជញ្ជាំង | មើម អាណោ |
| មើម ថ្នាំជាតិ | មើម ននោងក្អែក |
| មើម រពាក់ | មើម តាជិត |
| មើម ផ្តៅ | មើម ស្មៀន |
| មើម ប្រទាលស្បូន | មើម សង្រែកនាងមេទ្រី |
| មើម ប្រទាលរង្វង់ព្រះអាទិត្យ | មើម ស្លែង (វល្លិ ) |
| មើម ក្រចាប់ | មើម ក្រវាញជ្រូក |
| | មើម ការ៉ុត .....ជាដើម ។ |

( នៅមានត )

# កាព្យសាស្ត្រខ្មែរ

( តចប់ )

ដោយ : ខៀវ យ៉ុន

## គ~ កំណាព្យសម័យឧត្តុង្គ~ភ្នំពេញ

សម័យឧត្តុង្គ-ភ្នំពេញ មានប្រភេទកំណាព្យថ្មីៗ ដែលក្នុងមួយរបះៗ សុទ្ធតែមាន ៤ ឃ្លា ហើយឃ្លានិមួយៗ ក៏មានចំនួនព្យាង្គស្មើគ្នាតាមប្រភេទដែរ។ ម្យ៉ាងទៀតកវីជំនាន់នេះបានឱ្យឈ្មោះបទតាមចំនួនព្យាង្គ ក្នុងឃ្លានិមួយៗ គឺបទពាក្យ ៦, បទពាក្យ ៧, ពាក្យ ៨, ៩, ១០, ...។ កវីខ្លះបានយកបទទាំងនេះមកបំភ្លែ ដោយរក្សាចំនួនព្យាង្គដដែល ប៉ុន្តែដាក់ឈ្មោះថ្មី ( តាមអត្តនោម័ត្ត )។ វាអាចជាការល្អម្យ៉ាងដែរ (ប៉ុន្តែ វាបានបង្កការលំបាកស្មុគ្រស្មាញច្រើនទៅវិញក៏ថាបាន )។

ក្នុងចំណោមបទកាព្យ ក្រោយសម័យអង្គរនេះ បទដែលមានប្រជាប្រិយភាពពេញនិយមជាងគេ គឺ បទពាក្យប្រាំពីរ, ពាក្យ៨, និងពាក្យ៩។

### I- បទពាក្យប្រាំពីរ

បទនេះក្នុងមួយរបះមាន ៤ ឃ្លា ហើយឃ្លានិមួយៗមាន ៧ ព្យាង្គដូចគ្នា។ ខ្ញុំសូមអនុញ្ញាតពាក់តែងជូននូវអត្ថបទខ្លី ដែលមានតែបីរបះ ជាឧទាហរណ៍ដូចតទៅ :

<u>កម្រងអត្ថបទ :</u>

ស៊ីងជីវិត

១- ចរន្តបាតស៊ីង ហូរវេញៗវេញ
កូចអង្កាញ់វេញ វល់ព្រមាន
ហូរហាក់កំហែង ហូតវិញ្ញាណ
ចាប់កាយព្រមាន ភានស្មារតី ។

២- ហូរទៅនៅអាក់ ហាក់ដង្ហោយ
តែមិនងាកក្រោយ សង្ឃឹមអ្វី
ម៉ែអើយទុក្ខកូន ប៉ុនផែនដី
ម្ដេចម៉ែមិនបី យកទៅផង ។

៣- ស៊ីងព្រហ្មវិហារ ថ្នាត្រជាក់
ជាទីពំនាក់ គាប់បំណង
ក្នុងដៃដែលឪ ឱបត្រកង
ម៉ែអើយកូនប៉ង ជួបម៉ែទៀត ។

<u>ខ-បញ្ជាក់ :</u>

ឃ្លានិមួយៗនៃបទពាក្យប្រាំពីរ ពុំមានន័យថាមាន ៧ ពាក្យទេ ប៉ុន្តែ មាន ៧ ព្យាង្គ ( ៧ ម៉ាត់ ) ។ ដូចជា :

- ហូរ : ១ ពាក្យ មាន ១ ព្យាង្គ;
- សង្ឃឹម : ១ ពាក្យ មាន ២ ព្យាង្គ;
- ព្រហ្មវិហារ : ១ ពាក្យ មាន ៣ ព្យាង្គ. ... ។

ម្យ៉ាងទៀត ដើម្បីអាចអានបទពាក្យប្រាំពីរនេះ គប្បីជ្រាបថា ក្នុង ១ឃ្លា មាន ៧ ព្យាង្គ ដែលចែកជា ៣ ចង្វាក់ ដូចជា :

ឃ្លាខាងដើម « ចរន្ត - បាតស្ទឹង - ហូររេញ.រេញ »

ចង្វាក់ : ទី១មាន ទី២មាន ទី៣មាន = ៣ ចង្វាក់

ពីរព្យាង្គ ពីរព្យាង្គ បីព្យាង្គ = ៧ ព្យាង្គ

ស្គាល់ចំនួនចង្វាក់ និងចំនួនព្យាង្គដើម្បីអាចអាន ឬតាក់តែងកាព្យបានត្រឹមត្រូវ " បង្អន់ ឬបន្ធូរសម្លេងនៅរាល់ចុងចង្វាក់ " (ពុំមែនឈប់ ឬបង្អង់ឱ្យដាច់សម្លេងទេ ) ។

គ- កម្រងកាព្យបទពាក្យ ៧



ឃ- អំពីចំណាប់ចុងចួន

ដើម្បីអាចអានបានត្រឹមត្រូវ និងអាចតាក់តែង អត្ថបទកាព្យពាក្យ ៧ នេះ គប្បីផ្ទៀងផ្ទាត់ ប្រៀបធៀបអត្ថបទគំរូ និងកម្រងកាព្យ រហូតដល់អាចកត់សម្គាល់បានច្បាស់ថា :

- ក្នុងមួយវគ្គ ដែលបញ្ចប់ដោយសញ្ញា " ។ " មានបួនឃ្លា. មួយឃ្លាមាន ៧ ព្យាង្គដូចៗគ្នា ។
- ឃ្លានិមួយៗចែកជា ២ ចង្វាក់ខ្លី និង ១ ចង្វាក់វែង ដែលក្នុង ១ ចង្វាក់ខ្លី មាន ២ ព្យាង្គ ឯ ១ ចង្វាក់វែង មាន ៣ ព្យាង្គ ។
- ពិនិត្យលើកម្រងកាព្យ យើងឃើញច្បាស់ថា :
  - ព្យាង្គខាងចុងបំផុតវគ្គទី ១ " គី " (ចុងឃ្លាទី៤នៃវគ្គទី១) ចួននឹងព្យាង្គទី ៧ នៃឃ្លាទី ២ " អ្វី " ផង. ចួននឹងព្យាង្គទី៧ នៃឃ្លាទី ៣ "ដី " ផង. ហើយចួននឹងព្យាង្គទី ៤ នៃឃ្លាទី ៤ "បី " ទៀត (ក្នុងវគ្គទី២) ។
  - ព្យាង្គខាងចុងបំផុតនៃវគ្គទី២ ក៏មានចំណាប់ចួនក្នុងវគ្គទី៣ តាមទំនងដូចខាងលើដែរ ។
  - ដោយឡែក. ព្យាង្គទី៧ នៃឃ្លាទី១ "ហោយ " ក៏ត្រូវចួននឹងព្យាង្គទី៤ នៃឃ្លាទី២ " ក្រោយ " ដែរ ។

## II- បទពាក្យប្រាំបី

បទនេះ ក្នុងមួយវគ្គមាន ៤ ឃ្លា ហើយក្នុងមួយឃ្លាៗ មាន ៨ ព្យាង្គ

ស្មើគ្នាទាំងអស់ ។ ខ្ញុំសូមតាក់តែងជូននូវអត្ថបទខ្លី ដែលមានតែបីវបះ ជាឧទាហរណ៍ ដូចតទៅ :

ក- កម្រងអត្ថបទ

គិតសិនសឹមគួរ

| | | |
|---|---|---|
| ១- ចិត្តជនពាល | ញ៉ាំងកម្ម | អកុសល |
| ដែលហុចផល | រងទុក្ខ | ក្នុងអបាយ |
| បានកើតមក | ជាមនុស្ស | គួរឱ្យស្តាយ |
| ជនទាំងឡាយ | គួរវៀរ | កុំសេពគប់ ។ |
| ២- ឯបណ្ឌិត | ញ៉ាំងកម្ម | ជាកុសល |
| ដែលហុចផល | សោយសុខ | សុគតិភព |
| ជាកល្យាណ- | បុគ្គល | គួរគោរព |
| ត្រូវសេពគប់ | ត្រងត្រាប់ | ដំបូន្មាន ។ |
| ៣- អាក្រក់ល្អ | ខ្មៅ-ស | ពាល-បណ្ឌិត |
| ផ្សេងគ្នាពិត | សង្កេត | កុំបំពាន |
| បើមិនច្បាស់ | មើលសិន | មុននឹងឈាន |
| បញ្ញាញាណ | ជាសើន | បំភ្លឺផ្លូវ ។ |

ខ- សេចក្តីបញ្ជាក់ :

យើងបានដឹងថាបទ " បវ្យាវត្ត " ក៏មាន ៨ ព្យាង្គក្នុង ១ ឃ្លា ហើយវបះនិមួយៗ ក៏មាន ៤ ឃ្លាដែរ ។ ប៉ុន្តែគប្បីចំណាំឱ្យបានច្បាស់នូវបណ្តាលក្ខណៈ ដែលខុសគ្នាពីបទ " ពាក្យ ៨ ធម្មតា " ដែលខ្ញុំសូមជម្រាបជូនដូចតទៅ :

## គ- កម្រងកាព្យបទពាក្យប្រាំបី




## ឃ- អំពីចំណាប់ចុងចួន

បទពាក្យប្រាំបីនេះ ក្នុងមួយរបះមាន ៤ ឃ្លា ហើយក្នុងមួយឃ្លាមាន ៨ ព្យាង្គ។ រីឯចំណាប់ចួន ដូចតទៅនេះ :

- ព្យាង្គខាងចុងបំផុតនៃរបះទី ១ "គប់" ចួននឹងចុងឃ្លាទី ២ "ភព" ផង, ចុងឃ្លាទី៣ "រព" ផង រួចចួននឹងព្យាង្គទី ៣ "គប់" នៃឃ្លាទី ៤ ទៀត ( ក្នុងរបះទី ២ ) ។
- រីឯព្យាង្គចុងបំផុតនៃរបះទី ២ ក៏មានទំនាក់ទំនងខាងចំណាប់ក្នុង

របះ ទី ៣ ដូចក្នុងរបះទី ២ ដែរ ។

- ដោយខ្សែកព្យាង្គខាងចុងនៃឃ្លាទី ១ " សល " ចួននឹងព្យាង្គទី ៣ នៃឃ្លាទី ២ " ផល " ។

## III-បទពាក្យប្រាំបួន

បទនេះ ក្នុងមួយរបះមាន ៤ ឃ្លា ហើយក្នុងមួយឃ្លាៗ មាន ៩ ព្យាង្គស្មើគ្នាទាំងអស់ ។ ខ្ញុំសូមតាក់តែងជូន នូវអត្ថបទខ្លី ដែលមាន ៣ របះ ជាឧទាហរណ៍ដូចតទៅ :

ក- <u>ក្បួនអត្ថបទ</u>

ទំនាក់ទំនងត្រៃភព

១- ខែផល្គុន ឥតភ្លៀងផ្គរ ស្ងួតស្អាតដី
នារាត្រី ដប់ប្រាំកើត មេឃស្រឡះ
ច័ន្ទពេញវង់ បង្ហាញរាង តាមទឹកស្រះ
ឱ្យឃើញច្បាស់ ជ្រៅសន្ធឹម ឆ្ងាយសែនឆ្ងាយ ។

២- កាលពីថ្ងៃ នៅត្រង់ហ្នឹង ព្រះអាទិត្យ
សំដែងឫទ្ធ អគ្គីនេត្រ ដុតរោលកាយ
សឹងខ្លោចស្បែក តាំងពីព្រឹក ជះចំហាយ
ទើបរំសាយ ឥទ្ធិពល អស់រស្មី ។

៣- ព្រះអាទិត្យ និងព្រះច័ន្ទ ភពទាំងពីរ
តួនាទី វៀងដោយខ្សែក ជួយផែនដី

ឥតប្រកែក ចែកទិវា និងរាត្រី
ដូចស្វាមី និងភរិយា ចិញ្ចឹមបុត្រ ។

ខ- <u>កម្រងកាព្យបទពាក្យប្រាំបួន</u>

លោក-អ្នកសិក្សាចាំបាច់ត្រូវមានអត្ថបទ និងកម្រងកាព្យបទពាក្យប្រាំបួនដូចគ្នា ដើម្បីពិនិត្យផ្ទៀងផ្ទាត់។ ត្រូវហ្វឹកហាត់ដោយសាកល្បងតាក់តែងអត្ថបទខ្លីៗ ដោយសេចក្ដីព្យាយាម ។




គ- <u>អំពីចំណាប់ចួន</u>

- ព្យាង្គខាងចុងបំផុតនៃវបះទី ១ " ឆ្ងាយ " ចួននឹងព្យាង្គខាងចុងនៃឃ្លា

ទី ២ "កាយ " ផង.ចួននឹងព្យាង្គខាងចុងនៃឃ្លាទី ៣ " ហាយ " ផង រួចចួននឹងព្យាង្គទី៣ "សាយ " នៃឃ្លាទី ៤ ទៀត ( ក្នុងរបះទី ២ )

- ដោយឡែក ព្យាង្គខាងចុងនៃឃ្លាទី ១ " ទិត្យ " ចួននឹងព្យាង្គទី ៣ "បួទ្ធ " នៃឃ្លាទី ២ ។

- រីឯព្យាង្គខាងចុងបំផុត នៃរបះទី២ ក៏មានទំនាក់ទំនងខាងចំណាប់ចួនក្នុងរបះទី៣ ដូចក្នុងរបះទី១ និងទី២ ដែរ ។

---

សូមគោរពជូនពរ លោកអ្នកដែលស្វែងយល់ផ្នែកកាព្យសាស្ត្របានសម្រេច ជោគជ័យក្នុងស្នាដៃកំណាព្យកាបឃ្លោង តាមសំណូមពរ ។

* * *

# ជារអារ៉ៃ ឬ ជារព្រះនាងឱរ៉ៃ



*លោកតា* **ហ៊ាន ចាន់**
*អាយុ ៦៩ ឆ្នាំ*
*រស់នៅ ភូមិរកាត*
*ជាអ្នក ផ្តល់ពត៌មាន*

ដោយៈ **ម៉ៅ សោភ័ណ**
**រស់ សំណាង**
*សមាជិកឆ្លើយឆ្លង*
*របស់វិទ្យាស្ថានពុទ្ធសាសន-*
*បណ្ឌិត្យ*

**ជារអារ៉ៃ** ឬ **ជារព្រះនាងឱរ៉ៃ**មានទីតាំងស្ថិតនៅជួរភ្នំអារ៉ៃ មានចម្ងាយផ្លូវប្រវែងសាមសិបគីឡូម៉ែត្រពីទីរួមស្រុកភ្នំក្រវ៉ាញ ។ ជារអារ៉ៃគឺជារមណីយដ្ឋានធម្មជាតិមួយ ដ៏ស្រស់ត្រកាល ក្នុងចំណោមរមណីដ្ឋានជាច្រើននៅលើទឹកដី នៃខេត្តពោធិ៍សាត់ ។ ក្នុងការសិក្សាស្រាវជ្រាវសម្រង់ពត៌មានដែលយើងទទួលបានពីលោកតា ហ៊ាន ចាន់ ហៅ មឿន មានអាយុហុកសិបប្រាំបួនឆ្នាំ អ្នកចាស់ស្រុកភូមិរកាតឪពុកជាហ្មជំរ៉ ( **ពូជអ្នកខារអាចគ្រហម** ) បានធ្វើការរៀបរាប់តាមដែលលោកធ្លាប់ឮចាស់ៗនិទានប្រាប់បន្ត មានលោកយាយម៉ី និងលោកយាយសក់( ស្លាប់ ) ត្រូវជាម្តាយ និងម្តាយមីងលោកមេឃុំរកាត ដែលគាត់មានដើមកំណើត នៅភូមិអារ៉ៃតែម្តង បានរៀបរាប់ប្រាប់ហួរហែមកថា ÷

- កាលពីព្រេងនាយនៅក្នុងនគរកម្ពុជា ( ក្នុងសម័យកាលនៃក្សត្រគ្រងរាជមិនប្រាកដនាម និងកាលវេលា) ទ្រង់មានព្រះរាជបុត្រាមួយព្រះអង្គប្រកបដោយលក្ខណៈសម្បត្តិល្អព្រម ជារាជឱរសមានព្រះកាយសម្បទាមាំមួនស្រស់ស្អាត ថែមទាំងមានព្រះឪស្ថទិព្វថែមទៀតផង **(មាត់ទិព្វ)** ។ កាលនោះព្រះអង្គជាបិតាទ្រង់សព្វព្រះរាជហឫទ័យនឹងផ្សំផ្គុំព្រះរាជឱរសបុត្រាព្រះអង្គ ជាមួយនឹងបុត្រី នៃរាជទាយាទទ្រង់មួយអង្គទៀតដែលមានព្រះនាមថា **ព្រះនាងឱរ៉ៃ** ពិធីភ្ជាប់ពាក្យនេះគឺធ្វើឡើងតាំងពីព្រះរាជឱរស និងព្រះនាងឱរ៉ៃនៅជារាជកុមារម្ល៉េះ ទាំងទ្រង់បានឱ្យហោរាគន់គូរជើងលេខដឹងច្បាស់ថាព្រះកុមារទាំងពីរមិនមែនជាគូនឹងគ្នាក៏ដោយ ។ កាលវេលាចេះតែកន្លងផុតទៅ ។ ថ្ងៃរៀបអភិសេករាជកុមារទាំងពីរបានខិតមកដល់ ។ ដោយសារនិស្ស័យពីបុព្វជាតិ គ្រោះអាក្រក់មិនដឹងជាហេតុភេទអ្វី ស្រាប់តែបណ្ដាលឱ្យនៅលើរាងកាយព្រះរាជកុមារពោរពេញទៅដោយរោគឃ្លង់ បែកពីរកសព្វព្រះកាយ ( ត្រង់ចំណុចនេះ មិនមានឯកសារ ឬអ្នកណាម្នាក់ហ៊ានអះអាងថាមកអំពីហេតុអ្វីឡើយ ) ភាពជ្រួលច្របល់កើតឡើងពេញក្នុងនគរ ។ និយាយពីព្រះនាងឱរ៉ៃ កាលបើក្សត្រីបានទ្រង់ជ្រាបអំពីហេតុការនេះ ព្រះនាងមានការខកព្រះទ័យយ៉ាងខ្លាំង ។ ការនឹកតូចព្រះទ័យ លាយឡំនឹងអារម្មណ៍ខ្ពើមរអើម មកលងបន្លាចព្រះនាងរៀងរាល់រាត្រីឱ្យកើតចិត្តនឹក ស្រមៃចង់ចាកចេញពីនគរ ព្រោះមិនចង់រៀបអភិសេកនឹងរាជឱរសដែលមានរោគឃ្លង់ ព្រះនាងក៏បែកគំនិតប្រើឧបាយសុំព្រះមាតាបិតាចេញទៅក្រសាលព្រៃ ។ ដំបូងព្រះមាតាបិតាទ្រង់មិនអនុញ្ញាតទេ តែដោយការទទូចសុំរបស់បុត្រី ទ្រង់ក៏អនុញ្ញាតឱ្យបរិវារស្រីស្នំក្រមការរៀបក្បួនជូនព្រះនាងឱរ៉ៃទៅក្រសាលព្រៃតាមប្រាថ្នា ។ ការចេញដំណើរកំសាន្តត្រូវប្រព្រឹត្តដោយសំពៅ ដែលធ្វើដំណើរដោយប្រញាប់ប្រញាល់ក្នុងបំណងចោលដាន ។ សំពៅបានបោះពួយលឿនលយ

តម្រង់បឹងទន្លេសាប ហើយបត់គេចឆ្ពោះឡើងតាមព្រែកកាត់ឡើងមកកាន់ខេត្តពោធិ៍សាត់ ។ ក្នុងការធ្វើដំណើរ ក្រៅពីបរិវារជំនិត ព្រះនាងឱរ៉ៃនៅមានសត្វចិញ្ចឹមជំនិតមួយទៀត គឺក្រពើមួយក្បាលឈ្មោះ **នាយធន់** ។ នាយធន់ជាសត្វក្រពើមួយក្បាលចេះស្ដាប់បង្គាប់ និងស្រឡាញ់ព្រះនាងឱរ៉ៃណាស់ ក្នុងការធ្វើដំណើរជួនកាលព្រះនាងយាងចុះមកគង់លេងកំសាន្តលើខ្នងនាយធន់ ជួនកាលព្រះនាងគង់នៅលើសំពៅ ហើយយកឫស្សីលបចាក់ចង្កេះក្រពើ ឱ្យភ្ញាក់លោតឡើងពីទឹកជាការកំសាន្តព្រះទ័យ ។ ការលេងសើចនេះ មិនហុចលទ្ធផលល្អឱ្យព្រះនាងឡើយ ។ មកដល់ភូមិផ្សារក្រោម ស្រុកបាកាន ខេត្តពោធិ៍សាត់ នៅពេលដែលព្រះនាងលបចាក់ចង្កេះក្រពើៗក៏ភ្ញាក់ហើយវាត់កន្ទុយមកចំសំពៅ ជាហេតុបណ្ដាលឱ្យសំពៅលិចគៀងធ្វើដំណើរទៅមុខលែងកើត ( ក្រោយមកសំពៅត្រូវដីពូនដុះគ្របជិតក្លាយជាកោះមួយដែលសព្វថ្ងៃគេឱ្យឈ្មោះថា **កោះសំពៅមាស** ) ។ ក្រពើនាយធន់ក៏នៅចាំសំពៅនៅទីនោះទៅ ។ ដោយមានការបារម្ភខ្លាចមន្ត្រីក្នុងរាជវាំង តាមទាន់ព្រះនាងឱរ៉ៃក៏សម្រេចព្រះទ័យឱ្យបរិវារលើកជញ្ជូន លីសែង ភ័ស្ដុភារ ហើយយាត្រាដោយថ្មើរជើង តាមបណ្ដោយផ្លូវខាងកើតស្ទឹង បន្តទៅមុខទៀត កាត់តាមវត្ត ឯក ហើយបាន ស្នាក់សម្រាកព្រះកាយនៅលើទីទួលមួយ ដែលជាប់ឈ្មោះមកដល់សព្វថ្ងៃគឺ **ភូមិសាលាសំណាក់** ឬ **ទីសាលាសំណាក់** ។ អាស្រ័យដោយសម្ភារៈជាប់ទៅជាមួយច្រើនពិបាកក្នុងការធ្វើដំណើរដោយថ្មើរជើងបន្តទៅមុខទៀតនោះ ព្រះនាងសម្រេចឱ្យលាក់ សម្ភារៈមួយចំនួនមានគ្រែជាដើម ដែលកន្លែងកប់គ្រែនោះសព្វថ្ងៃជាប់ឈ្មោះថា **ទួលលាក់គ្រែនាង** ។ ហើយបន្តដំណើរមកមុខបន្តិចស្រាប់តែបានជួបនឹងសូរសព្ទចម្លែកដោយការភ្ញាក់ផ្អើលរបស់ហ្វូងសត្វស្លាបព្រះនាង-ឱរ៉ៃក៏គេចទៅសំកុកលាក់ខ្លួនពួនសំងំតែឯង ខ្លាចក្រែងមានគេតាមមកទាន់ ទីនោះ

ជាប់ឈ្មោះមកថា **ទួលសំរុកពួន** ហៅយាៗមកនៅត្រឹមពាក្យថា **ទួលក្រុកពោន**។ ក្នុងការធ្វើដំណើរតាមផ្លូវវាងគេចចេញពីស៊ឹងធ្វើឱ្យមានការ លំបាកហេវហត់ ដោយការស្រេកទឹក លុះមកដល់ភូមិមួយ ដែលស្ថិតជាប់នឹងមាត់បឹង ព្រះនាង ក៏សម្រេចព្រះទ័យឱ្យសម្រាកកម្លាំងនៅទីនោះមួយរយៈ ។ ដោយការសប្បាយត្រេកត្រអាលនឹងទឹកពេលនោះមានស្នំម្នាក់បានយកពែងមាសទៅលាងប្រឡែងគ្នាជ្រុះកប់បាត់ទៅក្នុងបឹងទោះនាំគ្នាភាវ ក៏រកមិនឃើញ ហេតុនេះហើយទើបទីនោះមានឈ្មោះមកដល់សព្វថ្ងៃហៅថា **បឹងបាត់ពែង** ហៅយាៗមកថា **បឹងកំពែង** ។ ព្រឹកព្រាង ស្វាងព្រះសុរិយា ព្រះនាងក៏បន្តព្រះដំណើរយាងទៅមុខទៀត ម្តងនេះព្រះនាងធ្វើដំណើរឆ្លងកាត់ភូមិមួយរបស់ស្រុកភ្នំក្រវាញ ។ ក្បួនដំណើរទៅមុខ មានមនុស្សម្នាជាបរិវារជាច្រើនជដែកគ្នាអឹងកង អ្នកស្រុកនៅទីនោះ គេមិនភ្ញាក់ផ្អើល អើពើអ្វីឡើយ គឺគេធ្វើព្រងើយ ហេតុនេះហើយទើបស្រុកនោះគេឱ្យឈ្មោះថា **ភូមិព្រងើយ** កម្លាយក្រោយមកហៅថា **ភូមិព្រងិល** វិញ ។ ទៅដល់ទីនោះទ្រង់គ្រាន់តែសម្រាកព្រះកាយបន្តិច ដោយអ្នកស្រុកមិនយកចិត្តទុកដាក់ព្រះនាងក៏បន្តដំណើរទៅមុខទៀត ។ គួរឱ្យអនិច្ចា ក្បួនដង្ហែព្រះនាងឱរ៉ៃ ដែលពុះពារធ្វើដំណើរក្រោមកំដៅថ្ងៃនារដូវប្រាំងរីងរាំង គ្មានទឹកហេវហត់អស់កម្លាំង តាំងជើងធ្វើដំណើរទៅមុខទៀតលែងរួច ឃើញដូចនោះព្រះនាងនឹកអាណិតខ្លោចចិត្ត ក៏តាំងលើកព្រះហស្តឡើងបួងសួងអធិដ្ឋានសុំទឹកពីព្រះឥន្ទ្រ គ្រាន់តែចប់ពាក្យបួងសួងភ្លាមព្រះនាងក៏ឮសម្លេងសត្វអកឈរយំនៅក្នុងទីទំនាបវាលស្មៅមួយ ។ ដោយការនឹកសង្ស័យព្រះនាងក៏ចាត់ឱ្យបាវប្រុសស្រុះគ្នាជីកជាអណ្តូងមួយ នៅទីដែលអកឈរយំ អំណាចនៃការបួងសួង អណ្តូងជីកបានប្រមាណមួយលូកក៏មានទឹកហូរចេញពេញអណ្តូងប្រើប្រាស់បានយ៉ាងច្រើនបរិបូណ៌ ទីនោះគេឱ្យឈ្មោះថា **អណ្តូងព្រះចៅ** រហូតមកដល់សព្វថ្ងៃ

ស្ថិតនៅក្នុងភូមិស្បូវរីក ស្រុកភ្នំក្រវ៉ាញ ។ ដោយការហេវហត់ ខកដំណើរផងព្រះនាងក៏ស្នាក់នៅទីនោះមួយរយៈ ។ ការបារម្ភខ្លាចគេតាមមកឃើញ តែងលងបន្លាចព្រះនាងរឿងរាល់រាត្រីនៅមិនសុខ ព្រះនាងក៏រៀបចំបន្តដំណើរទៅមុខទៀតរហូតស្រូតដល់ភូមិរកាត ។ អ្នកស្រុកភូមិរកាត កាលបើបានដឹងដំណើររឿងសព្វគ្រប់របស់ព្រះនាងឱរ៉ៃហើយ ក៏មានចិត្តអាណិតស្រឡាញ់រាប់អានស្ម័គ្របម្រើគ្រប់ៗគ្នា ហើយបាននាំព្រះនាងយកទៅលាក់ទុកនៅភូមិមួយទៀតក្បែរនោះ ឈ្មោះថាភូមិ **ស្ទូទិន** មានចម្ងាយប្រមាណពីរគីឡូម៉ែត្រពីភូមិរកាត ។ ជាអកុសលនៅក្នុងភូមិស្ទូទិនព្រះនាងសង្ឃឹមថាបានសុខតែផ្ទុយស្រឡះប្រែជាមានទុក្ខព្រួយទៅវិញ ព្រោះមនុស្សជំនិតទាំងពីរគឺនាងជំទាវម៉ា និងនាងទំទាវខៀវមានជំងឺ មកបៀតបៀនជាទម្ងន់ ទោះបីគ្រូហ្មដែលស្ទាត់ជំនាញក្នុង ូមិជួយជ្រោមជ្រែងយ៉ាងណាក៏មិនអាចជួយឃាត់សង្ខារជំទាវម៉ាបានឡើយ ។ គឺជួយបានតែជំទាវខៀវម្នាក់គត់ សពជំទាវម៉ាត្រូវបានអ្នកស្រុកភូមិអាណិតគ្រប់ៗគ្នា ហើយនាំយកទៅបញ្ចុះទុកនៅលើកោះមួយក្បែរភូមិស្ទូទិននោះ ដែលក្រោយមកកោះនោះអ្នកស្រុកប្រសិទ្ធិនាមថា **កោះជំទាវម៉ា** ។ ពីមួយថ្ងៃទៅមួយថ្ងៃ តាំងពីថ្ងៃដែលព្រះនាងភាសព្រះកាយចេញពីក្នុងរាជវាំងមកសេចក្ដីទុក្ខព្រួយចេះតែតាមញ៉ាំញីគ្មានស្រាកស្រាន សេចក្ដីទុក្ខធំបំផុតគឺការភ័យខ្លាចគេតាមមករកព្រះនាងឃើញ ដូចនេះហើយទើបគ្រាន់តែរៀបចំទុកដាក់សពនាង ជំ‐ទាវម៉ារួចភ្លាម ព្រះនាងក៏រៀបចំដំណើរចាកចេញពីភូមិស្ទូទិនទៅមុខទៀត ម្ដងនេះគឺក្បួនទាំងអស់ត្រូវចេញដំណើរដោយមានក្រុមដំរីជាយានជំនិះ តែអាសូរនាងជំទាវ ‐ ខៀវ ដោយសារជំងឺមិនទាន់បានជាសះស្បើយធ្វើដំណើរបានប្រមាណប្រាំគីឡូម៉ែត្រមកទន្ទឹមនឹងភ្នំរកាត ជំងឺនាងខៀវក៏ចាប់រើឡើងវិញក្រុមអ្នកស្រុករកាត ដែលទទួលយកអាសារជូនដំណើរព្រះនាងទៅនោះ ខំជួយព្យាបាលយ៉ាងណាក៏គ្មានប្រយោជន៍

ឡើយ ទីបំផុតនាងខៀវបានផុតសង្ខារ នៅក្បែរជើងភ្នំរកាតនាទិសខាងត្បូងនោះទៅ សពត្រូវបានរៀបចំទុកដាក់ទៅតាមបណ្តាំរបស់ជំទាវខៀវនៅទីនោះ ព្រមទាំងមាន ធ្វើខ្ទមអ្នកតាទុកសម្រាប់អ្នកស្រុកគោរពបូជាទៀតផង ក្រោយមកវិញ្ញាណនាង-ខៀវ បានក្លាយជាអ្នកតានៅថែរក្សាអ្នកស្រុកភូមិនៅទីនោះតាមពាក្យបណ្តាំ ទើប អ្នកស្រុកឱ្យឈ្មោះថា **អ្នកតាជំទាវខៀវ** រៀងរហូតមក ។ ក្រោយពីបានរៀបចំ ទុកដាក់សពជំទាវខៀវរួចរាល់ហើយ ដំណើរភាសព្រះកាយរបស់ព្រះនាងក៏ចាប់ផ្តើម ជាថ្មីបន្តទៀត លើកនេះក្បួនដំណើររបស់ព្រះនាងគឺមានលោកមេស្រុកម្នាក់ជាអ្នកនាំ ផ្លូវគាត់ឈ្មោះ **មេស្រុកជួប** មេស្រុកជួបថ្វីបើគាត់ជាអ្នកព្រៃភ្នំនឹងគេដែរ តែគាត់ ជាមនុស្សមិនមានជំនឿ ទៅលើខ្មោច, ព្រាយ, បីសាច, អារក្ស, អ្នកតាព្រៃភ្នំ ឡើយ ។ ទីដៅរបស់លោកមេស្រុកគឺនាំទៅលាក់ខ្លួននៅក្នុងព្រៃជ្រៅ ដូចនេះដំណើរ ឆ្ពោះទៅកាន់ទីនោះ មានផ្លូវពីរ មួយជាផ្លូវកាត់ស្រួលតែគ្មានសុវត្ថិភាព ព្រោះត្រូវ ដើរកាត់វាល រីឯមួយទៀតជាផ្លូវវាងតែលំបាក ព្រោះមានថ្ម,មានព្រៃ ងាយនឹងគេច ពួនតាមផ្លូវ ។ ដោយលោកមេស្រុកយល់ថាបើទៅផ្លូវស្រួលខ្លាចគេតាមមករកឃើញ ដូចនេះត្រូវ សម្រេចដើរទៅតាមផ្លូវលំបាក ( ផ្លូវវាង ) ។ ក្នុងការធ្វើដំណើរ ដោយស្គាល់ផ្លូវមិនច្បាស់ មកដល់ភូមិមួយឈ្មោះ **ភូមិស្រែចាយ** ( ឈ្មោះភូមិនេះ ហៅសំដៅលើឈ្មោះ **ម្ចាស់ស្រែ** ) ក៏ស្រែកសួរបញ្ជាក់បន្ថែមទៀតឱ្យតាចាយ ប្រាប់ឈ្មោះទីតាំងតាមផ្លូវ ។ តាចាយបញ្ជាក់ប្រាប់ថា ផ្លូវវាងមានភូមិជំនាប់ខ្សាច់, ថ្មក្អែ, ខ្សាំង, កានម, រាំងខយ, តាសែ, និងភូមិចុងក្រោយគឺភូមិចំឡាយ ។ ការធ្វើដំណើរតាមផ្លូវវាងមានការយឺតយ៉ាវជាច្រើនអន្លើ ព្រោះតែលោកមេស្រុក នេះឯង ។ រឿងរ៉ាវមាននៅ ទួលថ្មក្អែ នៅទីនោះមានថ្មមួយដុំយ៉ាងធំ ( កំពស់បួនម៉ែត្របួនជ្រុង ) ។ ជាទំនៀមទម្លាប់ បើដើរកាត់មុខដុំថ្មនោះ គឺត្រូវ

កាច់ស្លឹកឈើឧបកិច្ចថ្វាយនៅចំពោះមុខដុំថ្ម ចំណែកលោកមេស្រុកជួបមិនត្រឹមតែមិនកាច់ស្លឹកឈើដាក់ទេ ថែមទាំងជេរបញ្ចោរត្មិះដៀលអ្នកតានោះថែមទៀតផង ។ អំពើរបស់តាជួបមេស្រុក ធ្វើឱ្យលោកតាថ្មក្ដៅខឹង តាមធ្វើបាបមេស្រុកជួបរហូតតាមផ្លូវមកដល់ភូមិកានម មេស្រុកជួបត្រូវអ្នកតា ច្រានទម្លាក់ពីលើខ្នងដំរីបាក់ដៃ ។ អាស្រ័យដោយគ្មានអ្នកចេះស្ដោះផ្លុំទៅជាមួយ ក្បួនត្រូវត្រឡប់ក្រោយជូនមេស្រុកមកភូមិខាងក្រោយវិញ ទើបបន្តដំណើរ ជូនព្រះនាងឱរ៉ៃ ចេញទៅមុខទៀត ។ ក្បួនដំណើររបស់ព្រះនាងឱរ៉ៃ បន្តទៅមុខរហូតមកដល់ត្រឹមភូមិចំឡាយ ជាផ្លូវទាល់ ។ ព្រះនាងក៏ឱ្យគេរៀបចំទីសំណាក់លាក់ខ្លួននៅទីនោះទៅ ។ នៅបានមួយរយៈ ដោយអារម្មណ៍ចេះតែនឹកគិតភ័យខ្លាចដោយគ្មានហេតុផល នៅមិនបានប៉ុន្មានព្រះនាងក៏ឱ្យបរិវាររើសំណាក់ធ្វើដំណើរ ឡើងទៅមុខទៀតរហូតដល់ភូមិមួយដែលមិនស្គាល់ឈ្មោះ បច្ចុប្បន្នគឺ **ភូមិអារ៉ែ** មានព្រៃ មានជ្រោះ គួរជាទីចង់ស្នាក់នៅ ។ ស្លេះអំពីដំណើររើចុះឡើងរបស់ព្រះនាង ឱរ៉ៃមួយរយៈ នឹងនិទានអំពីកិច្ចការនៅក្នុងព្រះនគរ ព្រះមាតា ព្រះបិតា របស់ព្រះនាងវិញម្ដង ។ ដោយការទន្ទឹងមើលផ្លូវបុត្រីយូរទៅៗទើបមាតាបិតាព្រះនាងឱរ៉ៃ កាត់យល់ថា នេះប្រាកដជាល្បិចរបស់បុត្រី ចង់គេចចាកចេញពីគូដណ្ដឹង ដែលកើតរោគឃ្លង់យ៉ាងពិតប្រាកដគិតស្រេចហើយ ដោយក្ដីអាណិតស្រឡាញ់បុត្រី ទ្រង់ក៏សម្រេចព្រះទ័យជ្រើសរើសរកអ្នកដែលមានជំនាញខាងដើរព្រៃ ឱ្យចេញដំណើរ ស្វែងរកបុត្រីត្រឡប់ចូលទៅក្នុងព្រះនគរវិញ ។ រីឯព្រះគម្លង់ទៀតសោតទ្រង់ក៏សព្វព្រះទ័យដកពាក្យមិនយកព្រះនាងជាមហេសីតទៅទៀតដែរ សូមឱ្យតែព្រមចូលទៅព្រះនគរវិញចុះ ។ ពេលនោះមានមន្ត្រីមួយរូបបានស្ម័គ្រចិត្តធានាតាមរក ព្រះនាងឱ្យវិលត្រឡប់ចូលទៅក្នុងព្រះនគរវិញឱ្យខាងតែបាន ដោយសុំយកតែសេះមួយក្បាលដែលរត់លឿន និងដាវ

អាជ្ញាសឹកមួយគ្រាន់ទុកជាភស្តុតាង សម្រាប់បញ្ជាក់ឱ្យព្រះនាងឱរ៉ៃជឿទុកចិត្ត ។ បុរសក្លាហានក្រោយពីបានព្រះរាជអនុញ្ញាតហើយ ក៏តាំងបំបោលសេះយ៉ាងលឿន ស៊ើបសួរគ្រប់ច្រកល្ហក រកព្រះនាងឱរ៉ៃ ។ ហេតុនៃផលកម្មពីបុព្វេទើបបណ្តាល នាំផ្លូវបុរសយើង ឱ្យធ្វើដំណើរតម្រង់មកចំផ្លូវ ដែលព្រះនាងឱរ៉ៃទ្រង់ធ្វើដំណើរភាសព្រះកាយ មិនចន្លោះឡើយ ។ មកដល់ភូមិរកាតបុរសបានសួរអ្នកស្រុកតាមដំណើររឿង គ្រប់ប្រការតែពុំទទួលបានដំណឹងអំពីព្រះនាងឱរ៉ៃឡើយ ។ ដោយការនឹកសង្ស័យ បុរសនោះចេះតែខំបំបោលសេះស៊ើបសួរតាមផ្លូវ ក្បែរៗភូមិទីបំផុត ជាចៃដន្យ ស្រាប់តែបានជួបនឹងតាចាយ តាចាយគាត់លាក់លៀមមិនចង់ប្រាប់ដែរ តែដោយបុរសនោះប្រើល្បិចលួងលោម អង្វរករ បញ្ចុះបញ្ចូល បញ្ជោរ ទីបំផុតតាចាយ ក៏ព្រមប្រាប់កន្លែងស្នាក់ និងផ្លូវទៅកាន់កន្លែងលាក់ព្រះកាយរបស់ព្រះនាងឱរ៉ៃ ។ ដោយក្តីត្រេកអរជាពន់ពេកបុរសនោះខំបំបោលសេះយ៉ាងលឿនជាហេតុបណ្តាលឱ្យមាន បន្សល់នូវដានជើងសេះ ជាប់នឹងថ្មរហូតមកដល់សព្វថ្ងៃ ។ និស្ស័យល្អ មាណព យើងបានមកជួបព្រះភ័ក្រ្តព្រះនាងឱរ៉ៃដូចបំណងមែននៅក្នុងភូមិចំឡាយ មាណព បានទូលថ្វាយព្រះនាងឱរ៉ៃ តាមព្រះរាជបន្ទូល ព្រះបិតា និងស្តេចគម្លង់គ្រប់ប្រការ តែព្រះនាងឱរ៉ៃនៅតែប្រកែកដាច់អហង្ការ មិនព្រមវិលត្រឡប់ចូលទៅក្នុងព្រះនគរវិញ ។ ដោយទ្រាំលាក់ក្តីបំណង ដែលបានបង្កជាយូរមកហើយមិនបាន មាណពដាច់ចិត្តសារភាពពីចិត្តស្មោះរបស់ខ្លួន ដែលលាក់ពួនលួចស្រឡាញ់ព្រះនាងជាយូរមកហើយ ថ្វាយព្រះនាងទ្រង់សណ្តាប់ ហើយព្រមសារភាពថា ការដែលខ្លួនខិតខំតាមមកនេះគឺមិនមានបំណងយាងព្រះនាងវិលត្រឡប់ចូលនគរវិញដែរ គឺគ្រាន់តែតាមមករកព្រះនាងឱ្យឃើញ ហើយសុខចិត្តមករួមរស់នៅបម្រើជាមួយព្រះនាង ជារៀងរហូត ។ មាណពខិតខំរកមធ្យោបាយលួងលោម

ព្រះនាងឱរ៉ៃ តែទីបំផុតព្រះនាងនៅតែប្រកែកមិនព្រមស្រឡាញ់មាណពដដែល ។ ដោយដឹងថា អស់មធ្យោបាយហើយនោះ មាណព ក៏ប្រើកម្លាំងចាប់បង្ខំ ។ ពេលនោះ ពួកបរិវារទាំងអស់ក៏ចូលមកជួយដោយក្តីក្រេវក្រោធយ៉ាងខ្លាំង មាណពប្រើកម្លាំង បាយទៅតាមអំណាចនៃចិត្តពាលរបស់ខ្លួន កាប់ចាក់គ្មានប្រណី ទីបំផុត មាណព កំណាចលើកដាវដ៏មុតដេញតាមប្រហារជីវិតព្រះនាងឱរ៉ៃ ដោយគ្មានញញើតដៃ ។ កាប់ផុត១ព្រះនាងឱរ៉ៃ ប្រឹងរត់ទាំងត្រដាបត្រដួស លើជ្រោះថ្មជួនរអិលដួលបោក ព្រះកាយទៅលើផែនថ្ម រលាត់ដៃបែកជង្គង់ហូរឈាមរហាម ។ មាណពកំណាច នៅតែខំព្យាយាមតាមសម្លាប់ព្រះនាងឱរ៉ៃយ៉ាងសាហាវ ។ ដោយការភិតភ័យ ខ្លាំងពេក ព្រះនាងឱរ៉ៃខំប្រវារត់ឡើងមកទីសំណាក់ចាស់ ហួសផ្លូវទាល់ភូមិចំឡាយ ទៅទៀត ។ អនិច្ចាដោយសារផលកម្ម ដែលព្រះនាងបានសាងពីអតីតជាតិ មិនបានល្អ ពេលដែលមាណពកំណាចតាមមកទាន់ អ្វី១ត្រូវបានប្រព្រឹត្តទៅហួស វិការស្មាន ។ ដោយអំណាចពាល ផ្លែដាវដែលមានមុខសស្វាច ត្រូវមាណព កំណាចបញ្ជាឱ្យផ្តាច់ ព្រះសិរសាររបស់ព្រះនាងឱរ៉ៃ ចេញពីព្រះសុរង ។ ទឹកជ្រោះដ៏ថ្លាយង់ពេលនោះ បានក្លាយទៅជាពណ៌ក្រហមហូរកាត់ថ្មដា ព្រះកាយ ដ៏ទន់ល្វតល្វន់បន្ទន់ដួលចុះយ៉ាងថ្នម ចំពោះក្រសែភ្នែកដ៏សាហាវដូចខ្លានៃមិច្ឆាជន ។ ទីជ្រោះថ្មដាដែលបានទ្រព្រះកាយព្រះនាងឱរ៉ៃមកដល់សព្វថ្ងៃ កាលណោះត្រូវបាន អ្នកស្រុកប្រសិទ្ធនាមថា **ជ្រោះដាព្រះនាងឱរ៉ៃ** យូរ១មក ក្លាយត្រឹមជាអារ៉ៃនេះឯង ។ និយាយអំពីមាណពកំណាច ក្រោយពីបានប្រហារជីវិត ព្រះនាងឱរ៉ៃរួចមកវា ក៏បានយកផ្លែដាវ ទៅលាងនៅកន្លែងមួយ មិនឆ្ងាយប៉ុន្មានពីទីប្រហារជីវិត ព្រះនាង ឱរ៉ៃ ដែលទីនោះមានឈ្មោះថា **ដាវលាងឈាម** ហើយក៏គេចខ្លួន ចេញបាត់ ពីនគររវៀងរហូតទៅ ។ ក្រោយពីរូបភាពដ៏សាហាវឃោរឃៅបានកន្លងផុតទៅ

ភាពសោកសៅ នៃស្រីស្នំក្រមការជាបរិវារព្រះនាង ដែលរួចរស់ផុតពីសេចក្ដីស្លាប់ ព្រមទាំងអ្នកស្រុក រកាតទាំងអស់ បាននាំគ្នាកាប់ចាំងឈូសឈើមួយដើមយ៉ាងធំ លុងធ្វើមឈូសដ៏ប្រណីត រួចលើកព្រះសពលាងជំរះព្រះកាយថ្វាយព្រះនាងឱរ៉ៅ ដាក់ក្នុងមឈូស ហើយដង្ហែព្រះសពទៅតម្កល់ទុកនៅក្នុងរូងថ្មមួយ ដែលក្រុមអ្នកស្រុកស្រុះគ្នា កាប់ចោះផែនថ្ម លុងជារូង ធ្វើជាល្អាង ដោយប្រុងប្រយ័ត្នបំផុត ទីនោះមាន ឈ្មោះថា **ល្អាងរំលោង** ។រីឯព្រៃដែលនៅក្បែរនោះ មានឈ្មោះថា **ព្រៃរំលឹក** ព្រោះអ្នក ស្រុកតែងនាំគ្នាទៅរំលឹកធ្វើបុណ្យ ឧទ្ទិសកុសលដល់ព្រះនាងជារាង រាល់ឆ្នាំ ។ ឯទីភូមិដែលព្រះនាងឱរ៉ៅសំណាក់នោះ ក្រោយមកគេឱ្យឈ្មោះភូមិនោះថា ភូមិនាងឱរ៉ៅ, ឬភូមិអារ៉ៅ, ស្ទឹងអារ៉ៅ, ភ្នំអារ៉ៅ, ជាអារ៉ៅជារឿងរហូតដល់សព្វថ្ងៃនេះឯង ។



*ច្រោះជាព្រះនាងឱរ៉ៅ ជាទីកន្លែងដែលព្រះនាងឱរ៉ៅសោយព្រះទិវង្គត*

<u>កំណាព្យ</u>

# អាវចិត្តល្អ...

(បទកាកគតិ)

រូបរាងស្អាតបាត ស្បៀកពាក់ហាក់ស្រោត មើលឃើញទាបទូល
ឃើញជ្រោះញូកជ្រៅ ច្រកផ្លូវជ្រើមជ្រួល ផ្តួចចិត្តដិតដួល
ព្រឺព្រួចល្ងួចភ្នក ។

វាលខ្សាច់សក្បុស រលោងចាំងឆ្នុះ ឆ្នេរនទលគក
ភ្នំតូចទាំងតូ ទទូរពពក ចិត្តចង់ចូលជ្រក
ទន្ទៀលកំសាន្ត ។

អារម្មណ៍នាំនឹក ក្តៅខ្លួនទាំងព្រឹក ប្រុសព្រើលព្រឺប្រាណ
ចង់ដេកសំដិល រំកិលកើយឋាន នៃបនិត្យគិតស្មាន
បានចិត្តស្ងប់ស្ងាត់ ។

ស្បៀករីបចេញរាង ខើចណាស់នួននាង ជាងណាវាស់កាត់
ដេរតឹងតូចខ្នាត ខ្នាចខាតក្រណាត់ មិនសមបំបាត់
ពន្លេចអាក្រាត ។

ហៅអាវចិត្តល្អ បញ្ចេញសាច់ស ជូនចចកត្មាត
ព្រានប្រមាញ់ឃ្លាន ហៅហ៊ានប្រមាថ ក្តីក្តាំងបង់ខាត
កាមរាគបុស្សា ។

ស្បៀកសំពត់ផែក ឆ្វុតចូលរហែក កៀកកើ្តមេបា

វាយោបក់ប៉ើយ បើកសើយភូសា[១] ប្រុសព្រីលនេត្រា
ប្រាណព្រឺពេកពន់ ។
នែ! នួនមាសមេ ប្រយ័ត្នយាយជេរ ម៉ែគាត់រិះគន់
ខ្មែរមានអៀនខ្មាស់ ផ្ដេសផ្ដាសស៊ីយស៊ុន ភ្នែកប្រជាជន
គយគន់ពុំគាប់ ។
ស្នៀកពាក់ពេញសិទ្ធិ នាងអើយចូរគិត ទៅតាមទម្លាប់
ប្រពៃណីជាតិ ដែលញាតិកាន់ខ្ជាប់ ល្អគន់ល្អគាប់
អារ្យធម៌ខ្មែរ ។
ទៅបុណ្យវត្តវ៉ា ស្លៀកដូចចូលបារ រាំឱបគូស្នេហ៍
ត្រូវចែកឱ្យដាច់ ស្លៀកពាក់ទៅស្រែ គួរគិតគួរកែ
កាលពេលលកលៃ ។
« លោកថាឱ្យគ្រាប់ នូវសត្វកុកសាប[២] អំពើប្រពៃ
កុំគ្រាប់កុក ស ភោគាវសព្វថ្ងៃ ហើរទំអាស្រ័យ
ពុំមានប្លែកប្រាណ[៣] » ។

ដោយ អ៊ុក សៅចុល

សមាជិកឆ្លើយឆ្លងរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

---

១- (រាជសព្ទ) សំពត់អាវសាវស្បៃ ។

២- កុកសាប់ : ឈ្មោះសត្វកុកមួយប្រភេទ ពេលហើរពណ៌ស, ពេលចុះរកស៊ីមានពណ៌សំបកទំពាំង។

៣- ល្បះចុងបញ្ចប់ ខ្ញុំដកស្រង់ពីច្បាប់ផ្សេង១ របស់កវីខ្មែរយើងពីបុរាណ។

# សិក្ខាសាលាជាតិលើកទី ៤ ស្តីអំពី " ការលើកកំពស់ការប្រតិបត្តិតាមពុទ្ធោវាទ និងការប្រើប្រាស់គម្ពីរព្រះត្រៃបិដក "




*សិក្ខាសាលាជាតិ លើកទី ៤ (២៤-២៧ ខែធ្នូ ឆ្នាំ ២០០១ )*

កាលពីថ្ងៃទី ២៤ ដល់ ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០១ នៅវត្តឥន្ទ្រីយសំវរៈទីរួមខេត្តកំពង់ធំ បានរៀបចំធ្វើសិក្ខាសាលា ជាតិលើទី៤ ដោយមានការជួយឧបត្ថម្ភពីព្រះតេជគុណ មូចាគី សីក្យូ និងអ្នកស្រី មូចាគី តូគី និង ឯកឧត្តម នូ ភឿង អភិបាលខេត្តកំពង់ធំ ព្រមទាំងការឧបត្ថម្ភរបស់ព្រះគ្រូអនុគណ គ្រប់ស្រុក ព្រះចៅអធិការវត្ត លោកអាចារ្យ គណកម្មការគ្រប់វត្ត និងពុទ្ធបរិស័ទ មន្ត្រីរាជការក្នុងខេត្តកំពង់ធំ ។

អង្គសិក្ខាសាលាបានប្រព្រឹត្តទៅ ក្រោមអធិបតីភាពនៃព្រះសត្ថាបារមី មេគណខេត្តកំពង់ធំ នៃមន្ត្រីជាន់ខ្ពស់របស់ក្រសួងធម្មការ និងសាសនា និងមន្ត្រីជាន់ខ្ពស់នៃខេត្តកំពង់ធំ ។

ចូលរួមជាសមាជិកនៃសិក្ខាសាលានោះ មានព្រះសង្ឃចំនួន ២១២ អង្គ និមន្ត មកពី ២១២ វត្ត នៃខេត្តកំពង់ធំ មន្ត្រីធម្មការស្រុក លោកអាចារ្យនិងគណៈកម្មការ វត្ត ចំនួន ១០៩ រូប ព្រមទាំងព្រះមេគណ និងតំណាងព្រះមេគណខេត្ត លោកប្រធាន មន្ទីរធម្មការ និងសាសនា ចំនួន ៤៤ រូប និមន្ត និងអញ្ជើញមកពីខេត្ត-ក្រុងទាំង ២៣ នៃប្រទេស និងអ្នកសង្កេតការ ២១ រូប ។

ចូលរួមជាអធិបតីក្នុងពិធីនោះមាន :

១- ព្រះមហាសុមេធាធិបតី សម្តេចព្រះសង្ឃរាជគណៈមហានិកាយ

២- ព្រះសត្ថាបារមី **អាន ន័យ** មេគណខេត្តកំពង់ធំ

៣- ព្រះមហា **សេខ សុខុនី** អធិការរងនៃពុទ្ធិកសិក្សា រាជធានីភ្នំពេញ

៤- បណ្ឌិត **មុនិតា** ព្រះសង្ឃជាតិស្រីលង្កា សាស្ត្រាចារ្យពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ភ្នំពេញ

៥- បណ្ឌិត **បញ្ញាតិស្សៈ** ព្រះសង្ឃជាតិស្រីលង្កា សាស្ត្រាចារ្យពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ភ្នំពេញ

៦- ឯកឧត្តម **ខាំ សាវឿន** រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

៧- ឯកឧត្តម **ឈន អៀម** រដ្ឋលេខាធិការ ក្រសួងធម្មការ និងសាសនា

៨- ឯកឧត្តម **នូ គឿន** អភិបាលខេត្តកំពង់ធំ

៩- លោក **ឆៃនតូ ភូរីយូ** នាយកអង្គការសន្តិស៊ុគ្រិចិត្តកម្ពុជា SVA

១០ - លោក **យី ធន់** ទីប្រឹក្សាវប្បធម៌ និងទំនៀមទម្លាប់ខ្មែរ នៃអង្គការ

សន្និស្ស័ក្រចិត្តជប៉ុន ប្រចាំកម្ពុជា

១១ - លោក **ឡិម ខែម** ទីប្រឹក្សាអមក្រសួងធម្មការ និងសាសនា ។

១២- លោក **គីម ស្ងួរ** នាយកមន្ទីរធម្មការ និងសាសនា ខេត្តកំពង់ធំ

លទ្ធផលនៃ អង្គសិក្ខាសាលាក្នុងរយៈពេល ៤ ថ្ងៃ បានសម្រេចជាឯកច្ឆ័ន្ទ ថ្លែងសេចក្តី ប្រកាសរួម ដូចខាងក្រោម :

**ប្រការ ១** : បន្តខិតខំទ្រទ្រង់លើកតម្កើងប្រតិបត្តិពុទ្ធសាសនា គឺការ ប្រតិបត្តិ ធម្មវិន័យ និងអភិសមាចាររបស់ព្រះសង្ឃ និងពុទ្ធបរិស័ទ ។

**ប្រការ ២** : ខិតខំពង្រឹងគុណភាពខាងអភិបាលគ្រប់គ្រងវត្តអារាមឱ្យ បានល្អ មានសណ្តាប់ធ្នាប់ និងមានបែបបទរដ្ឋបាលត្រឹមត្រូវ ព្រមទាំងអនុវត្តឱ្យបាន ហ្មត់ចត់ តាមប្រព័ន្ធនៃការគ្រប់គ្រងផ្នែកពុទ្ធចក្រ ស្តីពីករណីកិច្ចនៃចៅអធិការ អនុគណ និងមេគណ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ៣** : ខិតខំជំរុញវិស័យពុទ្ធិកសិក្សា ដោយប្រមូលចងក្រងសាលា ពុទ្ធិកបឋមសិក្សា និងសាលាធម្មវិន័យ ឱ្យទៅជាប្រព័ន្ធសាលា និងកម្រងវត្តតាម ចំនួន តិច - ច្រើន ដែលអាចប្រមូលផ្តុំគ្នាបាន ។

**ប្រការ ៤** : វត្តនិមួយៗ ក្នុងទូទាំងខេត្តជួយទ្រទ្រង់ និងឧបត្ថម្ភថវិកា

តាមរយៈហិបប្រាក់ពុទ្ធិកសិក្សា របស់គណៈកម្មការពុទ្ធិកសិក្សាមួយ ដែល មានព្រះ តេជព្រះគុណ ព្រះមេគណ ជាទីប្រឹក្សា ។

**ប្រការ ៥** : ខិតខំបង្កើនសមត្ថកិច្ចបំពេញនាទីជាពុទ្ធបរិស័ទ គឺនាទី ការពារ នាទីកំចាត់ នាទីបង្កើន និងនាទីរក្សា ដើម្បីការពារតម្លៃព្រះពុទ្ធសាសនា និងការគង់វង្សនៃពុទ្ធសាសនា ។

ទំព័រឆ្លើយឆ្លងជាមួយកម្ពុជសុរិយា



## លិខិតថ្លែងអំណរគុណ

វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោក, លោកស្រី ជាសមាជិកឆ្លើយឆ្លង ដែលបានផ្ញើអត្ថបទស្រាវជ្រាវ ដ៏មានសារៈប្រយោជន៍ជាច្រើន មកតម្កល់ទុកជាឯកសារ សម្រាប់ការបោះពុម្ពផ្សាយ ។ ទង្វើដ៏ប្រពៃនេះ បានបញ្ជាក់ច្បាស់ពីទឹកចិត្តស្រឡាញ់វប្បធម៌ ប្រពៃណីទំនៀមទម្លាប់ខ្មែរ និងរួមចំណែកថែរក្សាអត្តសញ្ញាណជាតិ ពិសេសទៅទៀតនោះ គឺជាគំរូដ៏ល្អសម្រាប់កូនខ្មែរជំនាន់ក្រោយ ។ យើងខ្ញុំសូមថ្លែងអំណរគុណជាពន្លឹក ជាថ្មីម្តងទៀត ដល់អស់លោក លោកស្រី ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ដើម្បីចូលរួមបន្តគាស់កកាយប្រមែប្រមូលនូវរឿងរ៉ាវប្រវត្តិសាស្ត្រ ទំនៀមទម្លាប់ប្រពៃណីខ្មែរនេះ ដែលបានកប់បាត់ដោយខ្វះការគិតគូរ ។ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យរង់ចាំទទួលដោយរីករាយ នូវអត្ថបទស្រាវជ្រាវថ្មីៗ ទៀត ។

## អត្ថបទដែលទទួលបានលើកទី២

| ល.រ | នាមគោត្តនាម | ខេត្ត-ក្រុង | អត្ថបទ |
|---|---|---|---|
| ១ | លោក ប៉ាន់ សិង្ហុន | បាត់ដំបង | - ជីវប្រវត្តិសង្ខេបនៃសម្តេចព្រះវន្ន័តរាជាគណៈថ្នាក់ឯកមេគណ ( បាត់ដំបង) |
| ២ | ជួប ឃាន | ក្រចេះ | - សិលាចារឹក<br>- ពិធីជូនដំណើរអ្នកជំងឺពេលជិតស្លាប់<br>- របាយការណ៍ស្តីពីសកម្មភាពសមាជិកឆ្លើយឆ្លងនៃវិទ្យាស្ថានពុទ្ធសាសបណ្ឌិត្យប្រចាំខេត្ត ក្រចេះ<br>- ពតិមានបន្ថែម<br>- ប្រវត្តិអ្នកតាសាកង្កែប<br>- ឧបករណ៍ខ្មែរ ( សម្រាប់ស្រែចំការ និងប្រើប្រាស់នៅផ្ទះ)<br>- របៀបឆ្លងទន្លេតាមទំនៀមទម្លាប់ខ្មែរបុរាណ<br>- ប្រវត្តិភូមិ |
| ៣ | ស្រី កែ | ព្រះវិហារ | - ពិធីអាវាហៈវិវាហៈមង្គល |
| ៤ | ញាណ ភឿន | ព្រៃវែង | - ប្រវត្តិអង្គព្រះពាន់ ក្នុងស្រុកព្រះស្តេច<br>- របៀបសែនស្នង |
| ៥ | សុខ ចេង | ស្វាយ រៀង | - ពិធីបង្កក់ប្រសិទ្ធិ |
| ៦ | ស៊ី សួន | ស្ទឹងត្រែង | - នំអន្សមចេកខ្មែរ<br>- ម្ហូបកន្តាំខ្មែរ |

| ល.រ | នាមគោត្តនាម | ខេត្ត-ក្រុង | អត្ថបទ |
|---|---|---|---|
| ៧ | វ៉ាយ វិបុល | តាកែវ | - រទេះសម្រាប់កសិករខ្មែរ<br>- ម្ហូបឡាប<br>- ការចូលម្លប់របស់ស្ត្រីខ្មែរ<br>- បុព្វកថា<br>- របៀបកោរជក់ ឬកោរបង្កើយ |
| ៨ | រស់ ណុល | កំពង់ធំ | - អាចិកំបាំង និងអត្ថន័យនៃប្រាសាទបាយន្ត័ |
| ៩ | ស៊ុម កួយ | តាកែវ | - ពិធីទម្លាក់ចង្ក្រាន្ត<br>- ពិធីការឡើងផ្ទះថ្មី<br>- ពិធីឡើងអ្នកតា<br>- កីឡាហ៊ឹង<br>- ឡើងអ្នកតាជំទាវបាននៅភ្នំបុរី |

## សារៈប្រយោជន៍របស់គម្ពីរ បរមត្ថបញ្ជសា វិសុទ្ធិមគ្គមហាដីកា

ព្រះគម្ពីរដ៏បរិសុទ្ធរបស់ព្រះពុទ្ធសាសនា (ថេរវាទ) គឺសំដៅលើព្រះគម្ពីរទាំងឡាយណា ដែលព្រះអរហន្តទាំងឡាយបាននាំមក ហើយក្នុងឧទ្ទេសនៃសង្គាយនាទាំង៦គ្រា ដើម្បីជំរះចេញនូវអធម៌ អវិន័យក្នុងព្រះពុទ្ធសាសនាឱ្យបានបរិសុទ្ធ ព្រះគម្ពីរទាំងនោះ សុទ្ធសឹងជាលក្ខដ្ឋានសម្រាប់ពុទ្ធបរិស័ទអ្នកប្រាថ្នាគោរពប្រតិបត្តិ ដើម្បីញ៉ាំងប្រយោជន៍ឱ្យសម្រេចតាមសទ្ធាគ្រប់យ៉ាងដោយប្រពៃពិត។

ព្រះគម្ពីរបរមត្ថមញ្ជុសា វិសុទ្ធិមគ្គមហាដីកា ជាព្រះគម្ពីរមួយដែលព្រះធម្មបាលថេរជាព្រះអរហន្ត ស្ថិតនៅក្នុងសំណាក់មហាវិហារ ( ប្រទេសស្រីលង្កា) បានរចនាឡើង តាមសេចក្តីនៃមូលព្រះបាលីពីព្រះគម្ពីរដើម គឺវិសុទ្ធិមគ្គដែលជាអដ្ឋកថាបានរចនាជាស្រេច ដោយព្រះពុទ្ធឃោសាចារ្យនោះ ក៏ព្រះគម្ពីរវិសុទ្ធិមគ្គនេះត្រូវបានខេមរៈពុទ្ធបរិស័ទយើង និយមគោរពប្រតិបត្តិតាមស្ទើរគ្រប់ទីកន្លែង ដោយព្រះគម្ពីរនេះជាអដ្ឋកថាមានការពន្យល់ខែពីព្រះត្រៃបិដក ងាយយល់ចូលចិត្ត ។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ក៏ពុំអស់អត្ថសេចក្តីក្នុងមូលនៃព្រះបាលីឡើយ ដរាបណាមានគម្ពីរឈ្មោះបរមត្ថមញ្ជុសាវិសុទ្ធិមគ្គមហាដីកា ដែលមានការពន្យល់សេចក្តីពីមូលព្រះបាលីបន្ថែមទៀត ទើបកាន់យកសេចក្តីបានល្អប្រសើរ ។

អាស្រ័យហេតុនេះ ទើបទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំបាទ មានឆន្ទៈបកប្រែព្រះគម្ពីរនេះ ទុកដាក់ជាសម្បត្តិព្រះពុទ្ធសាសនាក្នុងកម្ពុជរដ្ឋ ដើម្បីបានជាប្រទីបសម្រាប់ទ្រាលផ្លូវ ក្នុងការបដិបត្តិឱ្យបានប្រសើរត្រឹមត្រូវតាមគន្លងថេរវាទពិតៗ និងកុំគប្បីប្រែក្លាយទៅជាប្រការដទៃឡើយ ។ ម្យ៉ាងវិញទៀត បើការប្រែសេចក្តីនៃទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំបាទមិនត្រឹមត្រូវ ឬឃ្លៀងឃ្លាតចាកពីច្បាប់ដើមព្រោះប្រការណា សូមមេត្តាជួយទិទៀនស្ថាបនានូវអត្ថបទធមិក្នុងប្រការនោះ ឱ្យកាន់តែមានសុក្រិត្យភាពឡើងថែមទៀត តាមរយៈទំព័រមិត្តអ្នកអានក្នុងទស្សនាវដ្តីកម្ពុជសុរិយាយើង ដោយសោមនស្សជ្រះថ្លា ក្នុងភាពកល្យាណមិត្តរួមរស់ក្រោមម្លប់ជាតិនិងសាសនាតែមួយដូចគ្នា ។

សូមអរព្រះគុណ និងសូមអរគុណ

ភ្នំពេញ ថ្ងៃទី ១ ខែមិនា ឆ្នាំ ២០០២

**សួន ឱសថ**

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ



រូបចម្លាក់ជាប់ឥទ្ធិពលក្លឹង្គនៅប្រាសាទ យាយព័ន្ធ ( សម្បូរព្រៃគុហ៍ ស.ត ៦-៧ )


ឆ្នាំទី ៥៦ លេខ ២ ខែ មេសា - ឧសភា - មិថុនា

ព.ស. ២៥៤៦ គ.ស. ២០០២

ភ្នំពេញ

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ

ចេញរាល់ត្រីមាស ពីវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

ចាត់ចែងបោះពុម្ពផ្សាយដោយគណៈកម្មការមួយ មាន :

នាយកការផ្សាយ : **ខួន វ៉ាន់ចន្ធី**

និពន្ធនាយក : **ខៀវ បញ្ញាខុឡ្យ**

គណៈកម្មការនិពន្ធ

លោកបណ្ឌិតទស្សនវិជ្ជា **ឆយ យីហ៊ាង**. លោក **ម៉ែន ច្រាង**

លោក **ខង់ សុធារ៉ា**. លោក **ឆន់ ហ៊ិន**.

លោក **មៀច ប៊ុណ្ណ**. លោក **ពិ ប៊ុន្នីន**

គណៈកម្មការពិគ្រោះយោបល់

- លោកព្រឹទ្ធាចារ្យ **ឆេង ផុន** ប្រធានមជ្ឈមណ្ឌលវប្បធម៌ និងវិបស្សនា
- ឯកឧត្តម **នុត ណារ៉ាង** ប្រធានមជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ
- ឯកឧត្តម **ជា សាវឿន** រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា
- ឯកឧត្តម **ឈន អៀម** រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា
- លោកបណ្ឌិតសាស្ត្រាចារ្យ **ឡុង សៀម** នាយកវិជ្ជាស្ថានជាតិខាងភាសា
- លោកបណ្ឌិតទស្សនវិជ្ជា **ឆយ យីហ៊ាង** ទីប្រឹក្សារាជរដ្ឋាភិបាល ទទួលបន្ទុកការងារអប់រំ. ព្រឹទ្ធបុរសដេប៉ាតឺម៉ង់ទស្សនវិជ្ជា និងក្រុមការងាររាជបណ្ឌិតសភាកម្ពុជា
- លោកបណ្ឌិត **នេត បារ៉ុម** សកលវិទ្យាធិការរង នៃសកលវិទ្យាល័យភូមិន្ទភ្នំពេញ ។

---


- បោះពុម្ពផ្សាយដោយប្រើថវិកាបានពីការលក់សៀវភៅនានា ដែលក្រុមប្រឹក្សាពិភពលោកដើម្បីសាសនា និងសន្តិភាព ( WCRP ) នៃប្រទេសជប៉ុន បានឧបត្ថម្ភ។
- **The puplication of this issue has been made possible by the fund earned the sale of books supported by the WCRP/Japan.**

# មាតិកាអត្ថបទ

## I. អក្សរសិល្ប៍ពុទ្ធសាសនា :


- ជីវិតមនុស្ស និងបញ្ហា (ត) .............. (ឈុន អៀម) ១


## II. អក្សរសាស្ត្រទូទៅ និង អក្សរសិល្ប៍ខ្មែរ :


- ថាមពលស្មាបនា................ (ព្រឹទ្ធាចារ្យ ឆេង ផុន) ១៥
- ការវិវឌ្ឍន៍នៃអាពាហ៍ពិពាហ៍ខ្មែរ (តចប់) ... (ឆយ យីហ៊ាង) ២៣
- វិធីសាស្ត្រក្នុងការស្រាវជ្រាវវប្បធម៌........ (នេត បារ៉ុម) ៣៨
- ការរីកចម្រើននៃព្រះពុទ្ធសាសនា (ត) .......... (ខួត ធីតា) ៤៩
- កំណត់សម្គាល់ និងការប្រើប្រាស់នាមព្រះមហាក្សត្រខ្មែរ
  នាសម័យបុរាណ (ត)...................... (វ៉ង់ សុធារ៉ា) ៥៥
- ក្រុងភាពណ៍ .......................... (ធន់ ហ៊ិន) ៧២
- ឱសថបុរាណខ្មែរ (ត) .................. (សួន ឱសថ) ៧៩
- ការបរបាញ់សត្វ.......................... (ជាវ ហ៊ន) ៨៤
- កំណាព្យ ខ្ញុំចង់រស់ ................ (ខៀវ បញ្ញាវុឌ្ឍ) ៩៥


## III. កំណត់ និងប្រវត្តិការណ៍ :


- កិច្ចប្រជុំការងារធម្មការ និងសាសនា...................... ៩៧


## IV. ទំព័រឆ្លើយឆ្លងជាមួយកម្ពុជសុរិយា


- សំណើផ្អាកការចុះផ្សាយអត្ថបទព្រះបរមត្ថមញ្ជុសា
  វិសុទ្ធិមគ្គមហាដីកា ................................ ១០០

# ជីវិតមនុស្ស និង បញ្ហា

(ត)

ព្រះតេជព្រះគុណ បណ្ឌិត ក. ស្រី ធម្មានន្ទ
បកប្រែដោយ : **ឈន អៀម**

## អ្វីខ្លះដែលពុទ្ធសាសនាទាមទារ អំពីមនុស្ស

តើពុទ្ធសាសនាទាមទារអ្វីខ្លះអំពីមនុស្ស ? មានម្ដងនោះ អ្នកប្រាជ្ញចិនម្នាក់ បានចោទសួរភិក្ខុមួយអង្គថា តើអ្វីខ្លះ បានកផ្គុំកើតជាខ្លឹមសារនៃពុទ្ធសាសនា ហើយភិក្ខុអង្គនោះ បានឆ្លើយតបថា ÷

ធ្វើអំពើល្អ, មិនធ្វើអំពើអាក្រក់

សម្អាតចិត្តឱ្យបរិសុទ្ធ.

នេះគឺជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធគ្រប់ព្រះអង្គ ។

តាមពិតអ្នកប្រាជ្ញនេះ បានគិតទុកមុនថា គាត់នឹងបានទទួលចម្លើយយ៉ាង "គម្ពីរភាព " ច្រើនជាងនេះ, គឺជាអ្វីមួយដែលជ្រាលជ្រៅ ហើយពិបាកយល់ ។ បន្ទាប់មកគាត់បានធ្វើការកត់សម្គាល់ថា សូម្បីតែកូនក្មេងអាយុបីឆ្នាំ អាចយល់គំនិតនេះបាន។ ប៉ុន្តែព្រះភិក្ខុ បានឆ្លើយតបថា នៅពេលកូនក្មេងអាយុបីឆ្នាំ អាចយល់គំនិតនេះបាន, ប៉ុន្តែមនុស្សចាស់អាយុប៉ែតសិបឆ្នាំ មិនអាចប្រតិបត្តិតាមពាក្យនេះបានទេ !

ព្រះពុទ្ធបានទូន្មានដូចគ្នាដល់សាវ័កជាអ្នកបំរើព្រះអង្គ ព្រះនាមអានន្ទ មិនឱ្យចាត់ទុកពាក្យប្រៀនប្រដៅ (ព្រះធម៌) មើលឃើញដូចជាងាយ ថាជាអ្វីមួយ

ស្រួលប្រតិបត្តិតាម នោះឡើយ។

នេះគឺជាខ្លឹមសារនៃព្រះពុទ្ធសាសនា-មនុស្សត្រូវបានពុទ្ធសាសនាទាមទារឱ្យប្រតិបត្តតាមសិក្ខាបទ "ងាយៗ" បំផុត ក្នុងការស្វែងរកការរំដោះខ្លួន (អត្តាធិនភាព). ប៉ុន្តែ ការកាន់តាមសិក្ខាបទទាំងនេះ អាចជាកិច្ចការពិបាកក្រៃលែង។ ដើម្បីចាប់ផ្តើម :

- គេមិនត្រូវផ្តាច់ជីវិតសត្វមានជីវិត ដោយដឹងថាសត្វនោះមានជីវិត;
- គេមិនត្រូវកាន់យកអ្វីមួយ ដែលគេមិនបាឱ្យ;
- គេត្រូវវៀរចាកការនិយាយកុហក និងពាក្យសំដីទ្រគោះ រោយរាយគ្មានប្រយោជន៍;
- គេត្រូវប្រុងប្រយ័ត្ន កុំប្រព្រឹត្តខុសក្នុងមេថុនធម្ម;
- គេមិនត្រូវផឹក ឬក្រេបរសជាតិអ្វីមួយ (ដូចជាគ្រឿងញៀន ស្រវឹង និងម៉េរ័យ) ដែលបណ្តាលឱ្យគេឡប់សតិរបស់គេ។

នេះគឺជាសិក្ខាបទដ៏សំខាន់ របស់ពុទ្ធសាសនា ដែលគេត្រូវប្រកាន់យក។

សិក្ខាបទទាំងនេះ មិនមែនមានន័យសម្រាប់តែការនិយាយជាពាក្យសំដីទេ. ប៉ុន្តែត្រូវដាក់ជាការអនុវត្តជាក់ស្តែង ប្រកបដោយសេចក្តីយល់ដឹង។ បញ្ហាស្នូលនៃជីវភាពខាងស្មារតី គឺជាបញ្ហាមួយអនុវត្តជាក់ស្តែង និងសកម្ម. មិនមែនជាបញ្ហានៃចំណេះដឹងខាងបញ្ញាទេ។

គោលបំណងចុងក្រោយរបស់មនុស្ស នៅក្នុងពុទ្ធសាសនា គឺដើម្បីកាត់ផ្តាច់ជាអវសាន ហើយគ្មានត្រឡប់មកវិញ នូវចំណងដែលចងគេភ្ជាប់ទៅនឹងការកើត (ជាតិ) ជាថ្មីជាប្រចាំ នៅក្នុងការកើត-ស្លាប់ៗ នៃវដ្តសង្សារ។ គេត្រៀមចាំតែការកើត ហើយកើតទៀតគ្មានទីបំផុត ពីព្រោះនៅក្នុងស្ថានភាពរ៉ិតដោយអវិជ្ជា

មនុស្សគិតឃើញថា មានអង្គធាតុមួយឋិតថេរ មានឈ្មោះថា "អត្តៈ" ឬ "អាត្មា" ។

ដោយការប្រកាន់យកអត្តៈបោកបញ្ឆោតថា ជាអត្តៈពិត, មនុស្សរមែងអភិវឌ្ឍចំណង់អាត្មានិយម។ ដូច្នេះមនុស្សបន្តប្រយុទ្ធគ្មានទីបញ្ចប់ ដើម្បីបំពេញតណ្ហារបស់គេ ប៉ុន្តែ គេនៅតែមិនឆ្អែតសោះឡើយ។ បីដូចគេអេះកន្លែងរមាស់ដើម្បីបន្ថយសេចក្តីឈឺចាប់បណ្តោះអាសន្ន, គឺគ្រាន់តែបានធ្វើឱ្យគេឃើញថា ក្នុងការអេះដូច្នេះ សេចក្តីរមាស់កាន់តែរមាស់ឡើង ពិព្រោះកន្លែងរមាស់កាន់តែអាក្រក់ និងធ្ងន់ធ្ងរខ្លាំងឡើង។

## ស្ថាប័នអាពាហ៍ពិពាហ៍

អាពាហ៍ពិពាហ៍ គឺភាពជាដៃគូមួយ ដែលនៅក្នុងនេះ បុគ្គលពីររូបមានភេទផ្ទុយគ្នា ប៉ុន្តែមានតម្លៃស្មើគ្នាក្នុងឋានៈជាមនុស្ស បានស្ម័គ្រចិត្តជ្រើសយកការរួមរស់នៅជាមួយគ្នា។ អាពាហ៍ពិពាហ៍ដ៏មានសុភមង្គល និងឋិតថេរទាមទារនូវការងារ និងសេចក្តីប្តេជ្ញាចិត្តដ៏ម៉ឺងម៉ាត់យ៉ាងច្រើន ដែលនៅក្នុងនេះ ស្នេហាត្រូវបានថែបំប៉នដោយការចែករំលែកកាតព្វកិច្ចផ្ទាល់ខ្លួន, សេចក្តីសប្បាយ និងសេចក្តីទុក្ខព្រួយជាមួយគ្នា។

អាពាហ៍ពិពាហ៍ គឺជាចំណុចកំពូល នៃសេចក្តីស្នេហា ដោយបុគ្គលពីរនាក់ប្តេជ្ញារួមរស់ជាមួយគ្នា ទៅវិញទៅមក ដោយចំណងរួមមួយ។ "តើបងស្រឡាញ់អូនប៉ុនណា ? បងសូមរាយរាប់ប្រាប់ទិដ្ឋភាពទាំងឡាយនោះថា បងស្រឡាញ់អូនដល់ទីជម្រៅ និងដល់ទំហំ និងដល់កំពស់ ដែលព្រលឹងបងអាចហោះហើរទៅដល់... " (Robert Browning ) ។ យើងជឿដូចលោក ព្រោវនីង (Browning) បានជឿថា ស្នេហាគឺជា សារជាតិនៃជីវិតផ្ទាល់, ជាអ្វីមួយដែលឆ្លងហួសពីព្រំដែនប្រទេស, សញ្ជាតិ, និងជំនឿសាសនា។

អាពាហ៍ពិពាហ៍ បានទទួលបរាជ័យដើម្បីបំពេញគោលបំណងរបស់ខ្លួនសព្វថ្ងៃនេះ ក៏ព្រោះតែមនុស្សបានខកខានមិនបានទទួលស្គាល់សារសំខាន់នៃសមភាព និងសេចក្តីគោរពចំពោះស្ត្រី។ បុព្វសិទ្ធទាំងនេះ ត្រូវបានស្ត្រីជាច្រើនទទួលស្គាល់ និងប្រើប្រាស់នៅក្នុងវិស័យជាច្រើននៃសកម្មភាពរបស់មនុស្ស។ ចម្លែកពេកណាស់ កាលណាគេបានរៀបអាពាហ៍ពិពាហ៍រួចហើយ ស្ត្រីទាំងឡាយនៅតែត្រូវបានគេប្រព្រឹត្ត និងចាត់ទុកមិនសមស្រប។ សារប្រយោជន៍នៃតួនាទីស្ត្រីនៅក្នុងសង្គម ត្រូវបានពង្រីកយ៉ាងទូលំទូលាយ ក្រោយពេលពុទ្ធសាសនាបានកើតឡើងនៅក្នុងប្រទេសឥណ្ឌា. ដោយបានផ្តល់ឱ្យស្ត្រីទាំងឡាយនូវឱកាសដ៏ទូលំទូលាយដើម្បីចូលរួមក្នុងមុខរបរទាំងឡាយក្រៅពីកិច្ចការថែទាំផ្ទះ។ ទោះជាយ៉ាងនេះក្តី. សម្រាប់ស្ត្រីភាគច្រើនលើសលប់, ការរៀបអាពាហ៍ពិពាហ៍ និងការចិញ្ចឹមកូនបានឋិតនៅជាជម្រើសមុខរបរជាធម្មតា។ ប៉ុន្តែ មានការប្លែកគ្នាមួយ; ជីវិតអាពាហ៍-ពិពាហ៍ត្រូវបានធ្វើឱ្យប្រសើរឡើង ដោយការផ្តល់ឋានៈដ៏ខ្ពង់ខ្ពស់ដល់ជីវិតអាពាហ៍-ពិពាហ៍នេះ ដោយព្រះពុទ្ធអង្គឯងទ្រង់បានបំពេញកិច្ចការនេះ។ ព្រះអង្គបានលើកកិត្តិយសស្ត្រីរៀបអាពាហ៍ពិពាហ៍ហើយពីភាពជាទាសី មកកាន់ភាពមានការទទួលខុសត្រូវ និងភាពមានឥទ្ធិពលខ្លាំង។ ដូចមានការចង្អុលប្រាប់ពីសេចក្តីជាប់ជំពាក់ព្រះទ័យរបស់ព្រះពុទ្ធ ដើម្បីទ្រទ្រង់ឱ្យមានសុភមង្គលតាមរយៈអាពាហ៍ពិពាហ៍. ព្រះអង្គបានបញ្ញត្តសេចក្តីណែនាំជាក់លាក់មួយចំនួន ដើម្បីទូន្មានប្តី និងប្រពន្ធ។

ព្រះពុទ្ធទ្រង់បានសរសើរចំពោះគូស្រករដ៏មានសុភមង្គល។ ក្នុងចំណោមបរិស័ទជាគ្រហស្ថរបស់ព្រះអង្គ គឺមាន *នកុលមាតា* និង *នកុលបិតា* ដែលត្រូវបានគេចាត់ទុកជាគូស្រករល្បីល្បាញបំផុត ដោយសារការបានរស់នៅជាមួយគ្នាជាមិត្ត

ជិតស្និទ្ធអស់កាលដ៏យូរ ។ ព្រះពុទ្ធទ្រង់បានសរសើរអ្នកទាំងពីរ ហើយបានផ្តល់សេចក្តីណែនាំដល់បរិស័ទឯទៀតថា តើគេអាចរស់នៅដោយសេចក្តីសប្បាយរីករាយក្នុងអាពាហ៍ពិពាហ៍យ៉ាងដូម្តេច ។ ដំបូន្មានទាំងនោះត្រូវបានព្រះពុទ្ធផ្តល់ឱ្យជាងពីរពាន់ប្រាំរយឆ្នាំកន្លងទៅហើយ, ក៏នៅតែត្រឹមត្រូវដដែលរហូតមកដល់សព្វថ្ងៃនេះ ។ ទុក្ខវេទនាជាច្រើនបានធ្លាក់មកលើបុរស និងស្ត្រី ក្នុងសម័យកាលបច្ចុប្បន្ននេះ ពិព្រោះស្ត្រី និងបុរសទាំងនោះ ដើរខុសគន្លងពីការណែនាំទាំងនោះ ។

ស្ថាប័នអាពាហ៍ពិពាហ៍ ក្នុងប្រទេសឥណ្ឌាបុរាណ ត្រូវបានគ្របដណ្តប់និងគ្រប់គ្រងដោយទស្សនៈនៃវណ្ណៈ, ឋានៈរបស់ស្ត្រី, សិទ្ធិរបស់បុរស និងដំណាក់កាលបួនយ៉ាងនៃជីវិតរបស់បុគ្គល ។ ការបដិសេធរបស់ព្រះពុទ្ធចំពោះទស្សនៈនៃប្រព័ន្ធវណ្ណៈមានន័យថា ស្ថាប័នអាពាហ៍ពិពាហ៍របស់ពុទ្ធសាសនា បានរំដោះខ្លួនផុតពីច្បាប់, ផុតពីបទបញ្ញត្តិ និងបូជានិយាមដ៏រឹងត្អឹង និងមិនអាចបត់បែនបានទាំងនោះដែលបានក្លាយទៅជាឧបសគ្គដ៏ធំចំពោះចរិយាសេរី និងគ្មានបុរេនិច្ឆ័យរបស់សមាជិកសង្គមទាំងប្រុស ទាំងស្រី ។

ព្រះសូត្រស្តីពីគ្រឹះនៃអភិសមាចារសង្គមរបស់ពុទ្ធសាសនា (សិគាលោវាទសូត្រ) បានបញ្ញត្តគំរូជាមូលដ្ឋាននៃទំនាក់ទំនងរវាងប្តី និងប្រពន្ធ, រវាងឪពុកម្តាយនិងបុត្រ-ធីតា, ហើយបានរៀបរាប់ពីករណីកិច្ចទៅវិញទៅមក ដែលចងភ្ជាប់ពួកគេជាមួយគ្នា ដោយសង្កត់ធ្ងន់លើទិដ្ឋភាពជាសារវ័ន្តបំផុតនៃជីវភាពរួមរបស់ពួកគេ ។

ការសិក្សាម៉ត់ចត់ អំពីស្ថាប័នអាពាហ៍ពិពាហ៍របស់ពុទ្ធសាសនា ដែលបាននិយាយដោយសង្ខេបនៅក្នុងការប្រៀនប្រដៅរបស់ព្រះពុទ្ធ បានបង្ហាញយ៉ាងច្បាស់ថា ដំបូន្មានទាំងនោះ គឺសម្រាប់បង្កឱ្យមានសេចក្តីសប្បាយ, ការលើកស្ទួយ និងការធ្វើឱ្យមានសីលធម៌ សម្រាប់សេចក្តីត្រូវការខាងជីវសាស្ត្រ, សេចក្តីសោមនស្សខាង

ចិត្តសាស្ត្រ និងសុខមាលភាព ខាងសម្ភារៈរបស់ប្តី និងប្រពន្ធទាំងពីរនាក់ ដោយមិនចាំបាច់រវល់ដល់ការពាក់ព័ន្ធនឹងទំនៀមទម្លាប់ពិសេសណាមួយ, ពិធីសាសនា ឬមនោគមវិជ្ជាសាសនា ឬក៏អ្វីផ្សេងបែបណាមួយឡើយ ។

អនុលោមតាមព្រះពុទ្ធអង្គ, ការចុះសម្រុងគ្នាខាងវប្បធម៌រវាងប្តី និងប្រពន្ធ ត្រូវបានគេចាត់ទុកជាកត្តាមួយ នៃបណ្តាកត្តាដ៏ជោគជ័យក្នុងជីវិតអាពាហ៍-ពិពាហ៍ ។ បញ្ហាជាច្រើន ក្នុងចំណោមបញ្ហាអាពាហ៍ពិពាហ៍សព្វថ្ងៃ កើតចេញមកពីអសមត្ថភាព នៃភាគីពាក់ព័ន្ធដើម្បីទទួលស្គាល់ពលិកម្មដ៏ជាប់ជំពាក់ស្មុគ្រស្មាញ ។ អាពាហ៍ពិពាហ៍មិនមែនគ្រាន់តែជារឿងកាមតណ្ហា និងរឿងស្នេហាអណ្តែតអណ្តូងដ៏សាមញ្ញនោះទេ ។ រឿងស្នេហាក៏មិនមែនជារឿងអាក្រក់ទាំងស្រុងទេ, ប៉ុន្តែវាជារឿងរំភើបអារម្មណ៍ ហើយត្រូវមានកំណត់ព្រំដែន ។

វានឹងមានភាពស្រមើស្រមៃតិចជាង និងសេចក្តីឈឺចាប់ក្នុងចិត្តតិចតួចនៅក្នុងអាពាហ៍ពិពាហ៍ ប្រសិនបើយើងយល់ថា ចេញពីភាពស្រមើស្រមៃនៃរឿងស្នេហានេះទៅ, សេចក្តីស្នេហាដ៏ជ្រាលជ្រៅ និងមិត្តថេរមួយអាចកើតឡើងបាន ។ សេចក្តីស្នេហា គឺជាចំណង់ពោរពេញដោយតណ្ហា និងមិត្តថេរយូរអង្វែង អំពីចំណែកនៃមនុស្សពីរនាក់ ដើម្បីបង្កើតរួមគ្នានូវល័ក្ខខ័ណ្ឌទាំងឡាយ, ដែលនៅពីក្រោមល័ក្ខខ័ណ្ឌទាំងនេះ ម្នាក់ៗអាចបង្ហាញអត្តៈពិតរបស់ខ្លួន, និងដើម្បីបង្កើតរួមគ្នានូវទឹកដីពុទ្ធិវិស័យ និងអាកាសធាតុចិត្តវេត ដែលនៅក្នុងនេះម្នាក់ៗអាចចំរើនដុះដាលវែងឆ្ងាយជាងអ្វីៗ ដែលម្នាក់ៗ អាចសម្រេចបានម្នាក់ឯង ។

នៅក្នុងអតីតកាល យើងបានឮអំពីគូស្រកររៀបអាពាហ៍ពិពាហ៍ប្រកបដោយសុភមង្គល ដែលបានចែករំលែករសជាតិផ្អែមល្ហែមនៃសេចក្តីស្នេហា, តាមរយៈការរស់នៅជាមួយគ្នាជាច្រើនឆ្នាំ, ទាំងពេលមានសុខ ទាំងពេលមានទុក្ខ ។

ចំពោះមនុស្សជាច្រើន ដែលបានរៀបការជាប្តីប្រពន្ធជាយូរឆ្នាំហើយ "សុភមង្គល ក្រោយពេលរៀបអាពាហ៍ពិពាហ៍ " មិនមែនទើបតែកើតមានទេ។ គូស្រករទាំងឡាយក្នុងអាពាហ៍ពិពាហ៍ដ៏យូរហើយមានសុភមង្គល បានបញ្ជាក់ហេតុពិតនៃជីវិត កាលណាមានគេសួរថា តើអ្វីដែលនាំឱ្យទំនាក់ទំនងរបស់ពួកគេបានជោគជ័យ។ "យើងបានធ្វើអ្វីៗគ្រប់យ៉ាង ដើម្បីរក្សាសេចក្តីស្នេហារបស់យើងឱ្យរស់ជានិច្ច។ យើងមានសេចក្តីសប្បាយចំពោះគំនិតផ្សេងគ្នាៗរបស់យើង ហើយរៀនសូត្រអំពីភាពផ្សេងគ្នាទាំងនេះ "។

"យើងនិយាយឱ្យឮ នូវសេចក្តីថ្នាំងថ្នាក់ចិត្តរបស់យើងដោយសេរី ហើយដោះស្រាយសេចក្តីថ្នាំងថ្នាក់ចិត្តទាំងនោះភ្លាមៗ ជាជំនួសទុកវាឱ្យគរទៅជាដុំពពកខ្មៅងងឹត"។ ប៉ុន្តែ នៅក្នុងករណីខ្លះ រឿងដែលគូស្រករដ៏ជោគជ័យទាំងអស់មានរួមគ្នា ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងការសង្កេតនេះថា : "ប្រសិនបើពេលណាកើតមានរឿងរ៉ាវអាក្រក់មែនទែន យើងទាំងពីរនាក់ត្រូវមានចិត្តមានះឱ្យខ្លាំង ដើម្បីដើរចេញ "។ ប្រហែលអ្វីដែលបង្ហាញឱ្យឃើញនូវចរិតលក្ខណៈនៃគូស្រករសម័យថ្មី ចំពោះមុខបញ្ហា គឺថាពួកគេចង់ឱ្យរឿងរ៉ាវទាំងឡាយត្រូវបានដោះស្រាយ យ៉ាងឆាប់និងងាយបំផុត ដូចដែលការដោះស្រាយនោះបានបង្ហាញឱ្យឃើញនៅលើកញ្ចក់ទូរទស្សន៍។ មិនមែនដូច្នោះទេ. អ្វីៗសព្វយ៉ាងដែលល្អ គឺត្រូវតែបានមកតាមរយៈការងារដ៏លំបាក។

ចំពោះស្ត្រីជាច្រើន ផ្លូវនាំទៅកាន់អាយុអាពាហ៍ពិពាហ៍បានវែង មិនទាន់បានជាផ្លូវរាបល្អទេ។ ការប៉ះទង្គិចអារម្មណ៍រួមមានរឿងរ៉ាវជាច្រើនដូចជា : អសមត្ថភាពដើម្បីមានកូន. មរណភាពកូន. កូនកើតមកពិការ. វិបត្តិសេដ្ឋកិច្ចធ្ងន់ធ្ងរ និងការផ្លាស់ប្តូរមុខរបរដែលមានស្ត្រេស (stress) ខ្ពស់។

ទោះបីជាគ្មានគូស្រករណាមួយ ពេលធ្វើការអង្កេតស្រាវជ្រាវបាននិយាយដោយចំៗក្តី ក៏វាជាការជាក់ស្តែងនោះគឺថា មានកត្តាពីរយ៉ាងផ្សេងទៀត មានសារសំខាន់ចំពោះជោគជ័យអាពាហ៍ពិពាហ៍របស់ពួកគេ។ ទីមួយ សូម្បីមានគូស្រករខ្លះប្រឈមមុខនឹងការមិនព្រមព្រៀងគ្នាដ៏ធំធេងនៅក្នុងរឿងផ្ទាល់ខ្លួនក្តី ហើយមានពេលខ្លះ ត្រូវរែកពុនបន្ទុកផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរក្តី, ក៏ពួកគេតែងបានរក្សាសេចក្តីគោរពចំពោះគ្នាទៅវិញទៅមកជានិច្ច ហើយបានវៀរចាកការប៉ុនប៉ងដើម្បីរើសរកដៃគូថ្មី។ មានពេលមួយ, ស្ត្រីជាប្រពន្ធនិយាយទៅកាន់ប្តីរបស់នាងថា "បងឯងបានរៀបការជាមួយខ្ញុំ ព្រោះសម្លឹងឃើញខ្ញុំឥឡូវហ្នឹង "។ ប្តីបានឆ្លើយតបថា " ទេ. បងបានរៀបការជាមួយអូន ព្រោះសម្លឹងឃើញរូបអូនដែលនឹងប្រែក្លាយនៅក្នុងអនាគត "។ តាមពិតទៅឥឡូវនេះ ភាគីទាំងពីរខុសដូចគ្នា ពិព្រោះសេចក្តីសង្ឃឹមរបស់ពួកគេផ្សេងពីគ្នា ហើយពួកគេមិនមានបំណងចង់ធ្វើសម្បទានទេ។ ទីពីរ គ្មានអាពាហ៍ពិពាហ៍ណាមួយ ត្រូវអន្តរាយដោយសារតែសេចក្តីចង្អៀតចង្អល់ចិត្តខ្លាំងក្លាណាស់ទៅ រហូតដល់ធ្វើឱ្យភាពជាដៃគូពិតប្រាកដមិនអាចកើតឡើងបាននោះទេ។ មានស្ត្រីជាប្រពន្ធគេម្នាក់ ធ្លាប់តែជេរប្រទេចប្តីនាងជានិច្ច សូម្បីតែមានកំហុសតូចតាចក៏ដោយ ដោយពាក្យពោលថា : "គាត់ឯងជាមនុស្សភ្លើ "។ ចំណែកឯប្តីវិញគឺជាមនុស្សមានអំណត់អត់ធ្មត់ណាស់។ ប៉ុន្តែ ថ្ងៃមួយពេលដែលខ្លួនគាត់ត្រូវបានប្រពន្ធប្រទេចផ្តាសាប្រើពាក្យដដែលៗ ប្តីក៏បានឆ្លើយតបវិញថា : " បងគិតថា អូនឯងនិយាយត្រូវ។ ប្រសិនបើបងមិនមែនជាមនុស្សភ្លើទេ តើអូនឯងគិតថា បងមុខតែមករៀបការជាមួយស្ត្រីម្នាក់ដូចអូនឯង ? "។ ចាប់តាំងពីពេលនោះរៀងមក នាងជាប្រពន្ធលែងហ៊ានជេរប្រទេចពាក្យនោះទៀតហើយ។

ដើម្បីឱ្យអាពាហ៍ពិពាហ៍សម្រេចជោគជ័យ, ប្តី-ប្រពន្ធត្រូវការយោគយល់

គ្នាផងដែរ ហើយព្រមទទួលយកភាពផ្សេងគ្នា រវាងភេទទាំងពីរ ។ មានពេលខ្លះ ប្ដី-ប្រពន្ធក្លាយទៅជាអាក់អន់ចិត្តនឹងគ្នាទៅវិញទៅមក ហើយប្រាថ្នាចង់ឱ្យដៃគូរបស់គេយោគយល់គ្នាឱ្យបានច្រើន ។ ការយល់ដឹង និងការចេះសន្ដោសប្រណីចំពោះភាពផ្សេង១គ្នា រវាងបុរស និងស្ត្រី ជួយឱ្យអាពាហ៍ពិពាហ៍មានជោគជ័យ ។

មិត្រ ដែលមានឆន្ទៈអត់ធ្មត់ទ្រាំទ្រពេលមានសេចក្ដីលំបាក ហើយចេះសម្របសម្រួលខ្លួនពេលមានកូន, ពេលមានការងារប្រែប្រួល, ពេលមានការលំបាកខាងហិរញ្ញវត្ថុ, ឬគ្រាន់តែយល់ដឹងច្រើនអំពីមនុស្សដែលគេត្រូវរៀបការជាមួយគឺជាអាថិកំបាំងពិតប្រាកដចំពោះអាពាហ៍ពិពាហ៍ដ៏ជោគជ័យ ។

មានពាក្យពោលមួយទៀតស្ដីពីជីវិតអាពាហ៍ពិពាហ៍ថា " ប្រពន្ធត្រូវក្លាយជាអ្នកគ្រូម្នាក់ចំពោះប្ដីវ័យក្មេង, ជាមិត្រម្នាក់ចំពោះប្ដីវ័យកណ្ដាល ហើយជាឧបដ្ឋា-យិកាម្នាក់ចំពោះប្ដីវ័យចាស់ " ។

គូស្រករជាច្រើនដែលមានកូនបានសម្រេចចិត្តរស់នៅជាមួយគ្នា យ៉ាងហោចណាស់រហូតដល់កូនរបស់ពួកគេ ធំពេញវ័យ ។ ដោយមានសេចក្ដីប្រឹងប្រែងតែបន្តិចប៉ុណ្ណោះរយៈពេលប៉ុន្មានឆ្នាំនេះ អាចជាពេលដ៏ជោគជ័យបំផុតក្នុងជីវិតអាពាហ៍ពិពាហ៍ ។

អាពាហ៍ពិពាហ៍ជាពរដ៏ពិសិដ្ឋមួយ ប៉ុន្តែមនុស្សជាច្រើនប្រែក្លាយជីវិតអាពាហ៍ពិពាហ៍ទៅជាភាពទុរគតតោតយ៉ាក និងជាភាពបណ្ដាសា ។ ភាពក្រីក្រមិនមែនជាមូលហេតុនៃជីវិតអាពាហ៍ពិពាហ៍ដ៏វេទនាទេ ។ ទាំងប្ដី ទាំងប្រពន្ធ ត្រូវចេះចែករំលែកសេចក្ដីសប្បាយ និងសេចក្ដីឈឺចាប់នៃអ្វី១ទាំងអស់ក្នុងជីវភាពរាល់ថ្ងៃរបស់ពួកគេ ។

ក្នុងអាពាហ៍ពិពាហ៍ពិត បុរស និងស្ត្រី ត្រូវគិតឱ្យច្រើនអំពីភាពជាដៃគូ

ជាងពួកគេគិតតែអំពីខ្លួនឯងជាបុគ្គលម្នាក់ៗ។ អាពាហ៍ពិពាហ៍គឺជាទោចក្រយាន មួយកសាងឡើងសម្រាប់មនុស្សពីរនាក់។ អារម្មណ៍មានសន្តិសុខ និងមានសេចក្តីសប្បាយកើតចេញមកពីរការប្រឹងប្រែងជួយគ្នាទៅវិញទៅមក។

ប្រពន្ធមិនមែនជាខ្ញុំបំរើរបស់ប្តីទេ។ នាងស័ក្តិសមនឹងទទួលសេចក្តីគោរពក្នុងឋានៈជាមនុស្សស្មើគ្នា។ ថ្វីបើបុរសត្រូវបានគេចាត់ទុកជាទូទៅ សូម្បីនៅពេលសព្វថ្ងៃនេះក៏ដោយ ថាជាអ្នករកប្រាក់ចិញ្ចឹមគ្រួសារ, ក៏ការជួយធ្វើការងារផ្ទះជាធម្មតាមិនបន្ថោកបន្ទាបសេចក្តីថ្លៃថ្នូរ នៃភាពជាបុរសរបស់ប្តីទេ។ ដោយប្រការយ៉ាងនេះ, សូម្បីប្រពន្ធកាចឆ្នាសពូកែជេរប្រទេច ក៏មិនអាចពូតផ្តុំរឿងនៅក្នុងផ្ទះបានដែរ។ ប្រពន្ធក៏គ្មានសេចក្តីសង្ស័យអ្វីមកលើប្តីដែរ។ នេះនឹងជួយធ្វើឱ្យអាពាហ៍ពិពាហ៍មានសេចក្តីសុខ ។ ប្រសិនបើប្តីនាងមានចំណុចខ្វះខាត, គឺមានតែសេចក្តីសន្តោស និងពាក្យទន់ភ្លន់ប៉ុណ្ណោះ អាចជួយឱ្យប្តីមើលឃើញផ្លូវត្រូវឡើងវិញ។ នៅក្នុងចំណងអាពាហ៍ពិពាហ៍ ការរក្សាសេចក្តីសន្តោសឱ្យឆេះងុំជារៀងរហូត គឺមានសារសំខាន់ខ្លាំងណាស់។ រឿងនេះតូចតាចទេ ប៉ុន្តែអាចមានន័យទូលាយវែងឆ្ងាយ។ សេចក្តីយល់ដឹងត្រឹមត្រូវ និងចរិយាមានសីលធម៌ គឺជាផ្នែកអនុវត្តជាក់ស្តែងនៃបញ្ញា (ឬគតិបណ្ឌិត)។

តាំងពីសម័យកាលយូរយារមកហើយ ផ្កា ឬបុប្ផា ត្រូវបានគេចាត់ទុកជាភាសាស្នេហា។ វាមិនថ្លៃច្រើនទេ។ ភរិយាទាំងឡាយ, ឬស្ត្រីភេទទាំងអស់ជាប់ចិត្តយ៉ាងខ្លាំងចំពោះសារៈសំខាន់នៃថ្ងៃកំណើត ឬខួបកំណើត, ហើយប្តីដែលយកចិត្តទុកដាក់ចំពោះប្រពន្ធ មិនគួរខ្ជិលពេក ដើម្បីធ្វើឱ្យសេចក្តីស្នេហាបានឆេះងុំជានិច្ចជាមួយរង្វាន់តិចតួច និងសេចក្តីថ្នាក់ថ្នមនេះទេ។ របស់កំប៉ិចកំប៉ុក ដូចជាផ្កាជាដើមនេះ គឺជាចាត ឬជាគ្រឹះនៃសេចក្តីសុខបំផុតរបស់ជីវិតអាពាហ៍ពិពាហ៍។ ភរិយាទាំង

ឡាយតែងត្រេកអរណាស់ចំពោះសេចក្តីថ្នាក់ថ្នមបន្តិចបន្តួចបែបនេះ អំពីស្វាមីដ៏ជាទីស្រឡាញ់របស់គេ។ គឺសុឆន្ទៈអស់មួយជីវិតដូចនេះហើយ ដែលធ្វើឱ្យភ្លើងគ្រួសារបន្តឆេះជារៀងរហូតទៅ។

សេចក្តីស្នេហាក្នុងគ្រួសាររីកចំរើនដោយប្រយ័ត្នប្រយែង គឺជារូបមន្តមួយដ៏សាមញ្ញ ដែលមានប្រសិទ្ធភាពសម្រាប់ថែរក្សាជីវិតអាពាហ៍ពិពាហ៍ឱ្យគង់វង្ស និងបីបាច់ចិញ្ចឹមកូនឱ្យមានចរិតល្អ។ ស្នេហាពិតមានន័យថា មានឆន្ទៈចង់ផ្តល់តម្លៃដល់ដៃគូរបស់គេ ហើយគ្មានឆន្ទៈចង់បន្ថយតម្លៃដៃគូជាប្តី ឬប្រពន្ធនៅចំពោះមុខជនដទៃឡើយ។ ឆន្ទៈនេះត្រូវដុះចេញពីក្រអៅបេះដូង។ ភាពផ្សេងគ្នាដែលជាគន្លឹះរវាងអាពាហ៍ពិពាហ៍ដ៏ជោគជ័យ និងអាពាហ៍ពិពាហ៍មិនជោគជ័យ នោះគឺឋិតនៅត្រង់ថា តើបុរស-ស្ត្រីជាស្វាមីភរិយា ចេះឱ្យតម្លៃដល់គ្នាទៅវិញទៅមកច្រើនយ៉ាងណា។ ការរិះគន់, ការមើលងាយ ឬការមើលស្រាល សហព័ទ្ធ (ប្តី ឬប្រពន្ធ) ជាពិសេសនៅចំពោះមុខមនុស្សដទៃ រមែងបង្ខូចបន្តិចម្តងៗ នូវទំនាក់ទំនងប្តី-ប្រពន្ធ។ ការជៀសវាងបាននូវប្រការនេះ មិនទាន់គ្រប់គ្រាន់ទៀត, ម្នាក់ៗត្រូវចេះឱ្យតម្លៃគ្នាទៅវិញទៅមក. បីដូចប្តី ឬប្រពន្ធ គឺជាត្បូងពេជ្រមួយគ្រាប់ដ៏កម្រ។

មានពេលខ្លះ ពាក្យសំដីមិនជាការចាំបាច់ពេកទេ ប្រសិនបើមានសេចក្តីយោគយល់គ្នា។ មានពេលមួយនោះ ឪពុកជរាម្នាក់ បានសារភាពប្រាប់កូនៗរបស់គាត់ថា ខ្លួនគាត់ស្រឡាញ់ម្តាយរបស់គេខ្លាំងណាស់ ហើយបានប្រាប់ឱ្យពួកគេខិតខំថែរក្សាម្តាយពួកគេជានិច្ច សូម្បីក្រោយពេលខ្លួនគាត់ស្លាប់ទៅហើយក៏ដោយ។ គាត់បានប្រាប់ជាសម្ងាត់ដល់ពួកគេថា ម្តាយរបស់ពួកគេ គឺជាស្ត្រីម្នាក់ប្រសើរណាស់ក្នុងលោកនេះ ហើយគ្រួសារមានភ័ព្វសំណាងណាស់ ដោយមានគាត់រស់នៅជាមួយ។ ស្ត្រីជាភរិយា ឥឡូវនេះមានអាយុ ៦០ ឆ្នាំ ហើយ, គាត់មានកូនធំៗអស់ហើយ

ប្រាំពីរនាក់ និងមានចៅៗ យ៉ាងច្រើន។ ប៉ុន្តែ គាត់បាននិយាយសារភាពថា គាត់មិនដែលបានឮពាក្យថ្នាក់ថ្នមម្តងណាថា " បងស្រឡាញ់អូន " ពោលចេញពីមាត់ ឬខ្សឹបប្រាប់គាត់សោះឡើយ សូម្បីតែពាក្យលួងលោមជុំវិញសេចក្តីស្នេហាក៏គ្មានដែរ។ ស្ត្រីជាភរិយាដែលជាអ្នកប្រតិបត្តិតាមទស្សនវិជ្ជាចិនបុរាណ គឺពេញចិត្តពេញថ្លើមជាមួយនឹងបែបបទថែទាំផ្ទាល់របស់ប្តីគាត់ ដែលយកចិត្តទុកដាក់ចំពោះសុភមង្គលរបស់គាត់នៅក្នុងជីវិតអាពាហ៍ពិពាហ៍ដ៏មានសុភមង្គល របស់គេទាំងពីរនាក់។ សហជ្ញាណ ឬអន្តោញាណជាស្ត្រីភេទរបស់គាត់ (her female intuition ) បានប្រាប់ឱ្យគាត់ដឹងថា នៅក្នុងជម្រៅបេះដូងនៃប្តីរបស់គាត់, គឺប្តីរបស់គាត់ស្រឡាញ់គាត់ដោយពិតប្រាកដ ហើយគាត់មិនអាចរកបានស្ថានភាពណាប្រសើរជាងនេះបានទេ។ គឺនៅក្នុងចរិតរបស់មនុស្សខ្លះ មិនបាននិយាយប្រាប់អំពីអារម្មណ៍របស់គេទេ, ប៉ុន្តែ គេយកចិត្តទុកដាក់ថែទាំ។ យើងត្រូវសង្កេតមើលសកម្មភាពរបស់គេ។ គន្លឹះ ឬកូនសោបន្ទាប់មកទៀត សម្រាប់អាពាហ៍ពិពាហ៍ដ៏មានភាពសុខដុមរមនា គឺត្រូវធ្វើការសំដៅសម្រេចគោលបំណងរបស់គេ។ វាជាច្បាប់ធម្មជាតិ ដែលថាបើគ្មានសេចក្តីព្យាយាមថែទាំទេ យកជាឧទាហរណ៍ សួនផ្កាមួយ, នោះស្មៅព្រៅ នឹងដុះទ្រុបទ្រុលជាជំនួសផ្កាល្អៗហើយ។ ប្រការនេះមានន័យដូចគ្នាចំពោះអាពាហ៍ពិពាហ៍។

ជំនឿមិនចាំបាច់ណាស់ណាទេនៅក្នុងន័យសាសនា, (ទោះបីជំនឿនេះជួយយ៉ាងច្រើន, ប្រសិនបើប្តី-ប្រពន្ធមានជំនឿសាសនាដូចគ្នា), នេះក៏ជាគ្រឿងផ្សំដ៏សំខាន់មួយទៀត នៅក្នុងការធ្វើឱ្យទំនាក់ទំនងឋិតថេរគង់វង្ស។

តើការរួមរ័ក្សក្នុងអាពាហ៍ពិពាហ៍ មានសារសំខាន់យ៉ាងណា ? ការរួមរ័ក្ស (sex) គឺជាសភាវគតិធម្មជាតិ ប្រសិនបើការសប្បាយសេពសោយនេះឋិតក្នុងព្រំដែនផ្ទាល់របស់វា នោះវាអាចនាំមកនូវសុភមង្គលធំធេង។ ការរួមរ័ក្សជួយថែ

រក្សាអាពាហ៍ពិពាហ៍ឱ្យដង្ហុំដង្ហោលឡើង. ហើយក៏ជាវិស័យមួយមានសារៈសំខាន់ជាអាយុជីវិត ដែលថែរក្សាអាពាហ៍ពិពាហ៍ឱ្យគង់វង្ស។ វាបង្កើតឱ្យមានភាពជិតស្និទ្ធ. ជាបទពិសោធន៍រួមរវាងមនុស្សពីរនាក់ ដែលគ្មាននរណាផ្សេងចែករំលែកពិសោធន៍នេះបាន។ វាធ្វើឱ្យទំនាក់ទំនងមានតម្លៃអនេក ហើយជាឯកជន។

រឿងដ៏សំខាន់ដើម្បីវាយតម្លៃក្នុងទីនេះ គឺការណ៍ពិតដែលថា បុរស និងស្ត្រីទាំងឡាយ មើលឃើញការរួមរ័ក្សខុសៗគ្នា។ នៅពេលដែលបុរសអាចមើលឃើញការរួមរ័ក្សថាជាសកម្មភាពផ្លូវកាយដ៏ខ្លាំងក្លាមួយ. ឯស្ត្រីវិញ ពុំមើលឃើញដូចនោះទេ។ ចំពោះនាង ការរួមរ័ក្ស គឺជាអន្តរកម្ម (interaction) ជាមួយមនុស្សប្រុសដែលនាងស្រឡាញ់. ពោលគឺជាមួយនឹងការថ្នាក់ថ្នម. ការបបោសអង្អែល និងការលួងលោមរបស់គេ។ ការយល់ដឹងការណ៍ពិត ដែលថា ស្ត្រីទាំងឡាយត្រូវការភាពកៀកកិត និងភាពជិតស្និទ្ធ រមែងធ្វើឱ្យសកម្មភាពរួមរ័ក្ស កាន់តែមានអត្ថន័យពេញលេញប្រសើរឡើង។

ការរួមរ័ក្សជាសកម្មភភាពលើសលប់ ជាងការបំពេញចំណង់ស្រេកឃ្លានទៅទៀត។ វាជាគ្រឹះនៃមិត្តភាពប្រចាំជីវិតដ៏ជិតស្និទ្ធមួយ ហើយក៏ជាមធ្យោបាយបង្កើតកូនប្រុស-ស្រី ដែលយើងស្រឡាញ់ថ្នាក់ថ្នមនៅក្នុងជីវិតរស់នៅរបស់យើង។

អស់កាលដ៏យូរលង់ហើយ យើងបានដឹងថា ស្នេហា និងការគោរពគ្នាទៅវិញទៅមក គឺជាគ្រឹះនៃភាពស្និទ្ធស្នាលជិតដិតរវាងភេទផ្សេងគ្នា។ ការរួមភេទក៏ដូចជាទំនោរចិត្តណាមួយផ្សេងទៀតនៅក្នុងមនុស្ស ត្រូវតែបានគ្រប់គ្រងដោយវិចារណញ្ញាណ។ មនុស្ស មិនមែនគ្រប់គ្រងដោយសភាវគតិ ដូចជាសត្វថ្នាក់ទាបទេ. គេមុខជាមើលឃើញទំនោចិត្តរបស់គេរត់ពាសវាលពាសកាល ប្រសិនបើគេមិនគ្រប់គ្រងទំនោរចិត្តទាំងនោះ ដោយវិចារណញ្ញាណទេ។

មានសុភាសិតមួយនិយាយថា : "បីដូចជាភ្លើង, ការរួមភេទ គឺជាអ្នកបំរើដ៏ល្អម្នាក់ ប៉ុន្តែជាចៅហ្វាយនាយដ៏អាក្រក់មួយ "។

សង្គមមួយដុះដាលឡើងតាមរយៈបណ្តាញនៃទំនាក់ទំនង ដែលឆ្វាក់ចាក់ស្រេះគ្នា និងពឹងពាក់គ្នាទៅវិញទៅមក។ គ្រប់ទំនាក់ទំនង គឺជាការប្តេជ្ញាស្រុះចិត្តគំនិតគ្នាដើម្បីគាំទ្រ និងការពារអ្នកទាំងឡាយឯទៀតនៅក្នុងក្រុម ឬសហគមន៍។

អាពាហ៍ពិពាហ៍ ដើរតួដ៏សំខាន់មួយក្នុងការត្បាញសរសៃទំនាក់ទំនងផ្តល់ឱ្យការគាំទ្រ និងកិច្ចការពារ។ អាពាហ៍ពិពាហ៍ដ៏ល្អត្រូវតែដុះដាល និងធំធាត់ជាលំដាប់ចេញពីការយោគយល់គ្នា ហើយមិនមែនជាចិត្តវេត ( សន្ទុះចិត្ត ) ទេ, ចេញពីភក្តីភាពពិត ហើយមិនមែនគ្រាន់តែជាការអនុគ្រោះដ៏សាមញ្ញទេ។

ស្ថាប័នអាពាហ៍ពិពាហ៍ ផ្តល់គ្រឹះដ៏រឹងមាំមួយ សម្រាប់ការអភិវឌ្ឍន៍វប្បធម៌, ជាសមាគមដ៏រីករាយមួយរបស់មនុស្សពីរនាក់ ដែលត្រូវបានថែបំប៉ន និងរំដោះផុតពីភាពត្រម៉ងត្រមោច, ឯកោ, និងភ័យខ្លាច។ ក្នុងអាពាហ៍ពិពាហ៍, ដៃគូម្នាក់ៗត្រូវពង្រីកតួនាទីបំពេញបន្ថែម, ផ្តល់កម្លាំង និងការលើកទឹកចិត្ត ដល់គ្នានិងគ្នា ដោយម្នាក់ៗត្រូវសំដែងនូវការគាំទ្រ និងការទទួលស្គាល់តម្លៃចំពោះជំនាញរបស់អ្នកឯទៀត។

មិនត្រូវគិតថាមនុស្សប្រុស ឬស្រីមានឧត្តមភាពជាងគ្នានោះទេ ម្នាក់ៗបំពេញឱ្យគ្នាទៅវិញទៅមក, ជាដៃគូមានភាពស្មើគ្នា, បង្ហូរចេញនូវភាពទន់ភ្លន់, សប្បុរសធម៌, ភាពស្វាត់ស្មៀម និងភក្តីភាព ហើយសំខាន់បំផុតគឺ អត្តបរិច្ចាគ (self sacrifice) ។

( នៅមានត )

# ថាមពលស្ថាបនា

ដោយ : **ព្រឹទ្ធាចារ្យ ឆេខ ផុន**

- ការកសាងគ្រឹះអរិយធម៌មួយឱ្យបានរឹងមាំ :

- ការស្រុតចុះ បាក់បែក បាត់បង់ ខឿនវប្បធម៌មួយ និងខឿនសង្គមធម៌មួយ ,

- ការស្តារ និងការធ្វើឱ្យរស់រានមានជីវិតឡើងវិញ នូវអតីតកាលដ៏រុងរឿងមួយ ,

- ការថែរក្សាស្នាដៃនៃបញ្ញាញាណរបស់មនុស្សជំនាន់មុនឱ្យបានគង់វង្ស .

- នៅលើលោកនេះ អ្វីៗដែលកើតឡើង ស្ថិតស្ថេរ វិវត្តរីកចម្រើន និងសាបសូន្យទៅវិញ សុទ្ធតែមានហេតុបច្ច័យចាំបាច់ និងគ្រប់គ្រាន់ ( Condition necessaire et Suffisante ),

- ការផ្លាស់ប្តូរនិងការប្រែប្រួលទាំងឡាយ សុទ្ធតែមានលក្ខណៈសម្បត្តិសត្យានុម័តិរបស់ធម្មជាតិ និងអត្តនោម័តិរបស់មនុស្សចាំបាច់ ( Condition objective et subjective ) ។

កត្តាដែលនាំឱ្យស្រុតចុះ និងរស់ឡើងវិញមានច្រើនណាស់ យើងសូមដកស្រង់តែបទពិសោធន៍ខ្លះមកធ្វើរបាយការណ៍ជូន និងទុកជាមេរៀនទៅអនាគតតែប៉ុណ្ណោះ ។

I- **កត្តាដឹកនាំ** ( ថាមពលដឹកនាំ )

មេដឹកនាំត្រូវមានឧត្តមគតិខ្ពស់ រក្សាបានផលប្រយោជន៍ទាំងអស់គ្នា ពង្រឹងបានសេចក្តីសង្ឃឹម ប្រមូលបានជំនឿជឿជាក់ របស់ប្រជាពលរដ្ឋទាំងមូល សាមគ្គីឯកភាពជុំវិញបំណងតែមួយ ។ នេះជាកម្លាំងដ៏ខ្លាំងក្លាបំផុត ។

មេដឹកនាំដែលមានគុណធម៌ខ្ពស់ មានចិត្តគិតគេ ស្វែងរកសុខឱ្យគេ ព្យាយាមមិនផ្តល់ទុក្ខឱ្យគេ រក្សាបានទាំងប្រយោជន៍ផ្ទាល់ខ្លួន និងប្រយោជន៍រួមរបស់ជាតិ ។

មេដឹកនាំត្រូវមានបំណង និងផែនការច្បាស់លាស់ មានវិធានការសម្បូរបែប ប៉ាន់ស្មានលទ្ធភាព ប្រាកដនិយម ឱ្យបានត្រឹមត្រូវ និងគ្រប់គ្រាន់ ព្រោះរាល់ស្នាដៃដឹកនាំសុទ្ធតែមានសារៈកើតមុនកំណើត ។ គឺសារៈនេះហើយដែលជាកម្លាំងជំនឿមោះមុត ដែលជាសេចក្តីសប្បាយរីករាយពេញចិត្តរបស់ប្រជាពលរដ្ឋ ។

**កម្លាំងចិត្តនេះនាំឱ្យកើត:**

១ - ឆន្ទៈ = បំណងចង់ធ្វើ ពេញចិត្តនឹងធ្វើ .

២ - វិរិយៈ = អត់ធ្មត់ និង ព្យាយាមនឹងធ្វើ .

៣ - ចិត្តៈ. = ស្រឡាញ់ប្តូរផ្តាច់ .

៤ - វិមំសា = បញ្ញាឆ្លាតឈ្លាសវៃ .

អ្វីដែលគួរខ្លាច និងគួរអស់សង្ឃឹមនោះ គឺការបាត់បង់ជំនឿរបស់ប្រជាជនមកលើខ្លួនឯង និងលើអ្នកដឹកនាំ ។

ជីវិត គឺជាការឆ្លងសមុទ្រមួយដ៏ធំធេង ដែលមានពពួកអមនុស្ស និងសត្វកាចសាហាវច្រើនណាស់រង់ចាំបៀតបៀន និងយាយីរាល់ពេល ។

តើត្រូវរើសយកនរណាជាអ្នកដឹកនាំ ?

- រើសយកឧត្តមគតិជាមេដឹកនាំ .

យកអ្នកណាជាអ្នករួមដំណើរ ?

- យកអ្នកចេះជាង ឬ ចេះស្មើ.

យកអ្វីជាមធ្យោបាយ ?

- យកភាពអំណត់ និង ការព្យាយាមជាមធ្យោបាយ,

យកអ្វីជាថាមពល ?

- យកសេចក្តីសង្ឃឹម និងជំនឿ,

យកអ្វីជាអាវុធសម្រាប់កាប់ឆ្ការ និង ការពារ ?

- យកបញ្ញាជាអាវុធដ៏មោះមុតបំផុត ។

***ឧបសគ្គធំប៉ុណ្ណា ការលំបាកធំប៉ុណ្ណា ឱ្យតែមានជំនឿ និង ក្តីសង្ឃឹម អាចពុះពារទៅបានទាំងអស់ ៗ***

II - **កម្លាំងកាយជាថាមពល:**

តើមនុស្សមានថាមពលអ្វីខ្លះ? ប្រភពថាមពលទាំងនោះចេញពីណាមក ? តើត្រូវប្រើកម្លាំងកាយសុទ្ធសាធដើម្បីកសាងប្រាសាទថ្មរាប់ពាន់បានឬទេ ? រំលាយភ្នំធម្មជាតិមួយយកថ្មរាប់លានតោនមកកសាងប្រាសាទភ្នំ, ប្រាសាទថ្មខ្លះត្រូវបានសាងសង់នៅលើកំពូលភ្នំ .... តើមានកម្លាំងអ្វីដែលអាចនាំឱ្យជញ្ជូនថ្មឡើងទៅលើភ្នំ ដាប់ ឆ្លាក់ ជាក្បាច់យ៉ាងល្អប្រណីតបាន ?

- តើត្រូវការកម្លាំងប៉ុន្មាន ? ចាត់តាំងកម្លាំងយ៉ាងណា ? គ្រប់គ្រងកម្លាំងយ៉ាងណា ? ឧបត្ថម្ភលើកទឹកចិត្តកម្លាំង អប់រំបំពាក់បំប៉នបច្ចេកទេស និងស្មារតីយ៉ាងណា ?

- មានប្លង់ មានផែនការ មានកម្មវិធីការងារច្បាស់លាស់ទេ ?

- លទ្ធភាពសម្ភារៈ សមត្ថភាពជំនាញ បញ្ញាឧបនិស្ស័យ គំនិតច្នៃប្រឌិតកម្រិតណា ?

- សមត្ថភាពសេដ្ឋកិច្ចទ្រទ្រង់ពលកម្មសាងសង់ត្រៀមបម្រុងទុកយ៉ាងណា ?

- ប្រតិទិនបែងចែកពេលវេលា សម្រេចតាមផែនការទេ ?

- មានការប្រែប្រួល ផ្លាស់ប្តូរ កែប្រែយ៉ាងណាដែរ ?

~ ***ឆាំងអស់នេះ ជាចម្ងល់របស់មនុស្សសតវត្សទី២១ សួរទៅកាន់មនុស្សសតវត្សទី ១០ ។***

III. **កម្លាំងចិត្តជាថាមពល :**

ដោយការងារធ្វើថ្មនេះ ជាការងារធ្ងន់ធ្ងរពេក ហួសពីសមត្ថភាពមនុស្សធ្វើកើត ថែមទាំងខ្វះបច្ចេកទេស ខ្វះសម្ភារៈ ខ្វះវិទ្យាសាស្ត្រទំនើបផងនោះ ភាពអស្ចារ្យនេះបានចោទជាសំណួរជាច្រើន ÷

- ខ្លះថាធ្វើដោយចាប់បង្ខំ ប្រើទាសករ ប្រើទណ្ឌកម្ម កេណ្ឌប្រមូលកៀរគរពលករ រាប់ម៉ឺនសែន ដើម្បីសម្រេចមហិច្ឆតានយោបាយ ។

- ខ្លះថាធ្វើដោយជោរ និង អំនួតបុគ្គល ។

- ខ្លះថាធ្វើព្រោះរក្សាជីវិត ឬព្រោះចិញ្ចឹមជីវិត ។

- ខ្លះថាធ្វើដោយប្រាថ្នាប្រយោជន៍អ្វី ក្រៅពីប្រយោជន៍លោកីយ៍នេះ ។

- ខ្លះថាធ្វើដោយស្រឡាញ់ពេញចិត្ត សប្បាយរីករាយនឹងធ្វើ ព្រោះជាស្នាដៃ ជាអាយុជីវិតគេ ជាសេចក្តីត្រូវការខានមិនបាន ។

- ខ្លះថាធ្វើដោយជំនឿមោះមុត បំណងឧទ្ទិសស្នាដៃគេថ្វាយទេវៈ ថ្វាយអាទិទេព ដែលផ្តល់សេចក្តីសុខឱ្យគេរាល់ៗជាតិ ។

- ខ្លះបាក់នពលីកម្លាំងកាយ កម្លាំងចិត្ត រហូតដល់ពលីជីវិត ព្រោះតែឃើញតម្លៃស្នាដៃនេះ ថ្លៃជាងជីវិតខ្លួនទៅទៀត ។

***ក៏ប៉ុន្តែជាការពិតជាក់ស្តែង ស្នាដៃចាប់បង្ខំ និងស្នាដៃស្រឡាញ់ស្មោះស្ម័គ្រ ខុសគ្នាឆ្ងាយណាស់ ។***

IV - **បញ្ហាជាតកម្លាំង :**

កម្លាំងប្រាំ ឬ ធម្មពលៈ គឺ ÷

១ - សទ្ធាពលៈ = ជំនឿមោះមុត ជាកម្លាំង ។

២ - វិរិយពលៈ = ព្យាយាម អត់ធ្មត់ ជាកម្លាំង ។

៣ - សតិពលៈ = សតិរលឹកទាន់គ្រប់កាល ជាកម្លាំង ។

៤ - សមាធិពលៈ = ការតាំងចិត្តឱ្យនឹងនរ មិនសួន់ស្មោរ ជាកម្លាំង ។

៥ - បញ្ញាពលៈ = បញ្ញាដឹងទាន់ ស្គាល់ទាន់ ជាកម្លាំង ។

V - **អត្តសញ្ញាណជាតិ ជាថាមពលរួម និងថាមពលដោយឡែក :**

- អ្វីដែលជាលក្ខណៈសរុប លក្ខណៈរួមប្រមូលផ្តុំ សំខាន់ចាំបាច់ខ្វះមិនបាន :
- អ្វីដែលស្ថិតស្ថេរយូរអង្វែង មិនងាយប្រែប្រួលផ្លាស់ប្តូរឡើយ.
- ជាសញ្ញាសម្គាល់រួមរបស់ខ្មែរទាំងអស់គ្នា ក៏ជាសញ្ញាសម្គាល់ដោយឡែករបស់បុគ្គលខ្មែរម្នាក់ៗ.
- បុគ្គលម្នាក់ៗមើលឃើញដោយឡែកនៅក្នុងរួមរៀងៗខ្លួន ។

ឧទាហរណ៍ :

- ប្រសាទបាយន័ ÷
- ពួកព្រាហ្មណ៍ មើលឃើញមុខព្រះព្រហ្មក្នុងបាយ័ន.
- ពួកកាន់ព្រះពុទ្ធសាសនា មើលឃើញព្រហ្មវិហារធម៌ ក្នុងព្រហ្មបាយ័ន.
- ព្រះរាជា ប្រជារាស្ត្រ នាម៉ឺន មន្ត្រី កងទ័ព មើលឃើញស្នាដៃរៀងៗខ្លួននៅក្នុងប្រាសាទបាយ័ន.
- អំណាចកណ្តាល អំណាចខេត្ត ស្រុក ឃុំ ភូមិ សុទ្ធតែមានមុខដូចៗគ្នាមានញញឹមរួម ញញឹមដោយឡែក .

- តម្លៃដោយឡែករបស់ខ្មែរម្នាក់ៗ ស្ថិតនៅក្នុងតម្លៃរួមរបស់ជាតិ :
- មោទនភាពជាតិ ជាមោទនភាពរបស់បុគ្គលម្នាក់ៗ :
- ភាពអាម៉ាស់របស់ជាតិ ជាភាពអាម៉ាស់របស់ខ្មែររាល់រូប (**ខ្មែរឈឺចាប់ ខ្មែរណាក៏ឈឺចាប់ដែរ** ) ៕
- ស្គាល់ខ្លួនឯងឱ្យច្បាស់ រកខ្លួនឯងឱ្យឃើញ វាយតម្លៃវប្បធម៌ ឱ្យត្រូវ ។
- ធ្វើឱ្យមានចិត្តពលី ស៊ូស្លាប់ដើម្បីការពារ និង ស្តារឱ្យរស់ឡើងវិញ ។
- ចំណុចសំខាន់ ចំណុចពិសេស ចំណុចរួម នៃវប្បធម៌នេះហើយ ដែលជាមូលដ្ឋានសាមគ្គី ឯកភាព ជុំវិញលក្ខណៈសម្គាល់ដោយឡែក និងទូទៅរបស់ ជាតិនេះឯង ( ស្គាល់តម្លៃឱ្យច្បាស់ ទើបការពារបានល្អ *ស្គាល់គោទើបឃ្វាលគោបានល្អ* )។
- មេដឹកនាំមានតួនាទីប្រមូលផ្តុំជំនឿ ពង្រឹងសទ្ធា ធ្វើឱ្យបំណងរួមក្លាយទៅជាបំណងដោយឡែក របស់បុគ្គលម្នាក់ៗ ព្រមព្រៀងគ្នាស្រុះស្រួលគ្នាជឿជាក់លើគ្នា សម្រេចបំណងរៀង១ខ្លួន ។

ឧទាហរណ៍ :

សិល្បករដាប់ថ្ម ៦៤៦៥ នាក់ ខំប្រឹងសម្រេចភារកិច្ចរៀង១ខ្លួន ដោយសប្បាយរីករាយ បានបន្សល់ប្រាសាទថ្មរាប់ពាន់ រូបចម្លាក់រាប់ម៉ឺន ទុកឱ្យកូនខ្មែរជំនាន់ក្រោយ ដោយឥតស្តាយស្រណោះ ។

## VI - ភាពតំណរបស់វប្បធម៌ :

ការបាត់បង់ ផ្លាស់ប្តូរប្រែប្រួល ឬការរស់ឡើងវិញនៃផ្នែកឯទៀតៗរបស់សង្គម មានការជាសះស្បើយឡើងវិញយ៉ាងឆាប់រហ័ស ។ ផ្ទុយទៅវិញការបាត់បង់បាក់បែកបាត់ភាពតំណរបស់វប្បធម៌មួយ មិនងាយស្តារ មិនងាយផ្សះផ្សាមុខរបួស

ជួសជុលអ្វីដែលបាក់ ដាច់ លិច ទៅក្នុងប្រវត្តិសាស្ត្របានឡើយ ។

ប្រជាជាតិកម្ពុជាបច្ចុប្បន្ន ស្ថិតនៅក្នុងភាពបាត់វប្បធម៌ រស់នៅក្នុងអន្ធង់អន្ធការ ស្ថិតនៅក្នុងភាពប្រទាញប្រទង់នៃវប្បធម៌ ។

ពេលខ្លះងាកក្រោយមើលឃើញស្នាដៃស្ដឹមស្ដៃពេក អស្ចារ្យពេក លែងហ៊ានជឿថាខ្លួនឯងជាអ្នកធ្វើ ។ នេះជាគ្រោះថ្នាក់ខ្លាំងណាស់ ជាប្រធាននៃសេចក្ដីវិនាស ។ លែងជឿខ្លួនឯង លែងជឿលើសមត្ថភាពខ្លួនឯង លែងជឿលើអ្នកដទៃ លែងទុកចិត្តគ្នា សងចែក ចែកសង យូរៗទៅ ខ្សោយទៅៗ តិចទៅៗ ឈានទៅផុតពូជអ្នកលេងថ្ម ។ នេះជាការបាត់បង់វប្បធម៌របស់ជាតិមួយ ។

ប្រទេសជាតិទាំងឡាយនៅអាស៊ី ពិសេសប្រទេសជប៉ុន ដែលបានផ្តួចផ្តើមធ្វើឱ្យមានរង្វាន់ អាស៊ី Fukuoka បានដប់ឆ្នាំមកហើយ មានតួនាទីភារកិច្ច សិក្សាស្រាវជ្រាវ អ្វីដែលជាដោយឡែក អ្វីដែលជារួម របស់វប្បធម៌អាស៊ី ៖ អ្វីជាដោយឡែកនៅក្នុងរួម ( Du particulier au general ) ៖ តម្លៃពិសេស របស់ជាតិនិមួយៗស្ថិតនៅត្រង់ណា ? តម្លៃមនុស្សជាតិស្ថិតនៅត្រង់ណា ? បុគ្គលិកលក្ខណៈពិសេស ជាតិមួយៗស្ថិតនៅត្រង់ណា ? បុគ្គលិកលក្ខណៈសម្បត្តិរួមរបស់អាស៊ីស្ថិតនៅត្រង់ណា ? តើដោយឡែក ពង្រឹងរួម ហើយរួមពង្រឹងដោយឡែក យ៉ាងដូចម្តេច ? តើត្រូវជួយឧបត្ថម្ភគ្នា ជួយបំពេញឱ្យគ្នាទៅវិញទៅមកយ៉ាងណា ? សង្គ្រោះអ្វីមុន ? ទុកអ្វីក្រោយ ? សួនច្បារអាស៊ី ត្រូវមានផ្កាអ្វីខ្លះ ? រូបភាពផ្កាយ៉ាងណា ? ក្លិនផ្កាយ៉ាងណា ? មានពណ៌សម្បុរយ៉ាងដូចម្តេច ? លាយចម្រុះគ្នាយ៉ាងណា? មានន័យយ៉ាងដូចម្តេច? មានប្រយោជន៍អ្វី ? ខ្លឹមសារ និង រូបភាព សមស្របគ្នាទេ ? ទំនាស់គ្នា ឬ ឯកភាពគ្នា ? ឬឯកភាពក្នុងទំនាស់ ? ពូជផ្កាដុះក្នុងព្រៃបានប្រមូលមកទុកដាក់ហើយឬនៅ ? (វប្បធម៌ជនជាតិភាគតិច សូម្បីមានគ្នាតែ ៣០ នាក់ក៏ត្រូវថែរក្សាទុកដែរ ) ៖

- សន្តិភាពនៅអាស៊ីកើតមានបានអាស្រ័យដោយ ទប្បធម៌សន្តិភាពកើតមាននៅក្នុងប្រទេសអាស៊ីនិមួយៗ ។ សន្តិភាពកើតនៅអាស៊ីនិមួយៗ ទាល់តែពលរដ្ឋ អាស៊ីម្នាក់ៗ មានការអប់រំបណ្តុះបណ្តាលទប្បធម៌សន្តិភាពក្នុងចិត្តម្នាក់ៗឱ្យបានរឹងមាំ ។
- សន្តិភាពក្នុងចិត្ត កំណត់សន្តិភាពខាងក្រៅ
- មេត្តាកើត សន្តិភាពកើត ,
- មេត្តាកើត ទោសៈរលត់ ,
- មេត្តាកើត គំនុំបុគ្គលរលាយ ,
- មេត្តាកើត ការបៀតបៀនថយចុះ
- បើទប្បធម៌អហិង្សាខ្លាំង, ទប្បធម៌ហិង្សាទន់ខ្សោយ, សន្តិភាពកើត ។
- សន្តិភាពពិភពលោកមាន អាស្រ័យដោយសន្តិភាពក្នុងចិត្តមនុស្ស ក្នុងពិភពលោកម្នាក់ៗ មាន ។

ទាំងអស់នេះជាថាមពល សម្រាប់ស្ពានមនោគមន៍យុគសម័យស្មារតី ដើម្បីសន្តិភាព វិបុលភាព របស់មនុស្សលោក និង មនុស្សជាតិទាំងមូល ។

*បើជឿព្រះ ធ្វើតាមព្រះពិតប្រាកដ*
*ទៅបួសក៏ចម្រើន ទៅជាគ្រហស្ថក៏ចម្រើន ។*

*សម្តេចព្រះធម្មលិខិត ឧត្តមប្រឹក្សា*
*វជិរប្បញ្ញោ ល្វី ឯម*

# ការវិវឌ្ឍន៍នៃអាពាហ៍ពិពាហ៍ខ្មែរ

The evolution of Khmer wedding

(តចប់) ដោយបណ្ឌិត: **នយ យ៉ីហ៊ាន**

រាជបណ្ឌិតសភាកម្ពុជា

## ១០‐ អាពាហ៍ពិពាហ៍ដើម្បីរួមចំណែកកសាងសង្គម

នេះជាអាពាហ៍ពិពាហ៍មួយបែប ដែលតែងត្រូវបានគេយកមកអនុវត្ត នៅក្នុងវត្ត និគ្រោធវង្សី ហៅវត្តរូងជ្រៃ ក្នុងភូមិរូងជ្រៃ ឃុំរូងជ្រៃ ស្រុកថ្មគោល ខេត្តបាត់ដំបង។ អាពាហ៍ពិពាហ៍នេះប្រព្រឹត្តទៅនៅក្នុងពិធីបុណ្យចូលឆ្នាំខ្មែរ។ គោលបំណងនៃការរៀបមង្គលការនេះ គឺ ៖

- ទាក់ទាញអ្នកដើរកំសាន្តឱ្យចូលរួមក្នុងពិធីបុណ្យចូលឆ្នាំថ្មីនៅក្នុងវត្ត ,
- ប្រមូលប្រាក់ឱ្យបានច្រើន ដើម្បីកសាងវត្ត។

លោកតា *ជ្រឹង ជ្រាង* នៅភូមិរូងជ្រៃ[១] មានប្រសាសន៍ថា ដូនតារបស់យើងបានរៀបអាពាហ៍ពិពាហ៍នេះយូរណាស់មកហើយ។ គេពុំអាចដឹងច្បាស់អំពីអ្នកផ្ដើមគំនិត និងកាលបរិច្ឆេទនៃការរៀបមង្គលការនេះឡើយ។ ក្រោយមកគេបញ្ឈប់ការ រៀបមង្គលការនេះក្នុងរយៈពេលយ៉ាងយូរ។

លុះដល់ ឆ្នាំ ១៩៨៦ ក្នុងពិធីបុណ្យចូលឆ្នាំខ្មែរ លោកតា *ជ្រឹង ជ្រាង* និង

---

១‐ លោកតា *ជ្រឹង ជ្រាង* នៅភូមិរូងជ្រៃ ឃុំរូងជ្រៃ ស្រុកថ្មគោល ខេត្តបាត់ដំបង ជាអ្នកផ្ដើមគំនិតបង្កើតអាពាហ៍ពិពាហ៍នេះឡើងវិញ បន្ទាប់ពីបាត់មួយរយៈពេល ( ជួបពីថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០១ )។

គណៈកម្មការវត្តបានផ្តើមរៀបអាពាហ៍ពិពាហ៍នេះវិញ ដោយមានការឧបត្ថម្ភពីសំណាក់មេឃុំ មេភូមិ និងប្រជាជនចំណុះជើងវត្ត និគ្រោធវង្ស។ របៀបរៀបមង្គលការ មានដូចខាងក្រោម ៖

ក- លក្ខណៈវិនិច្ឆ័យក្នុងការធ្វើជាកូនកំលោះ និងកូនក្រមុំ គឺ :

- កូនក្រមុំត្រូវបានយល់ព្រមពីឪពុកម្តាយ ឱ្យរៀបអាពាហ៍ពិពាហ៍នេះ
- កូនកំលោះ និងកូនក្រមុំត្រូវចុះកិច្ចសន្យា ដោយមានផ្តិតមេដៃនៅក្នុងនោះផង ក្រោមការទទួលស្គាល់របស់ គណៈកម្មាធិការឃុំដែលអះអាងថា គ្មានភាគីណាមួយទាមទារយកកូនកំលោះជាប្តី ឬយកកូនក្រមុំជាប្រពន្ធ ពិតប្រាកដឡើយ។

ហេតុនេះ អាពាហ៍ពិពាហ៍ប្រភេទនេះ ជាអាពាហ៍ពិពាហ៍កំសាន្តមួយប៉ុណ្ណោះ។ ប៉ុន្តែ យើងគួរចោទសួរថា ៖

តើមានកូនកំលោះ កូនក្រមុំណាដែលធ្លាប់បំពានលើកិច្ចសន្យានេះ ?

តាំងពីឆ្នាំ ១៩៨៦ មក ទើបនឹងមាន ១គូ ដែលទាមទារយកធ្វើជាប្តីប្រពន្ធមែនទែន គឺបំពានលើកិច្ចសន្យា។ បន្ទាប់ពីមានការទាមទារបែបនេះហើយ ខាងកូនប្រុស និងខាងកូនស្រីបានស្រុះស្រួលគ្នា រៀបចំស្តីដណ្តឹងរៀបមង្គលការតាមធម្មតាឡើងវិញ។ កូនប្រុសឈ្មោះ *ចាន់ ឌី* កូនក្រមុំឈ្មោះ *ភឿន ស្រីមុំ* រស់នៅក្បែរវត្តរូងជ្រៃ។ មកដល់ពេលនេះ គេមានកូនបីនាក់ហើយ។

ខ- អំពីរបៀបរៀបមង្គលការ

- កូនប្រុស និងកូនស្រីបានផ្ដិតមេដៃរួចស្រេច។ លុះដល់ពេលគេហៅកូនស្រីឡើងលើឆាក ដើម្បីឱ្យយុវជនមើល។ បន្ទាប់មក គេលក់ឆ្នោតដើម្បីឱ្យយុវជនផ្សងសំណាងថា តើនរណាមានវាសនារៀបការជាមួយនាង។ សន្លឹកឆ្នោតដែលត្រូវគឺមានតែមួយសន្លឹកទេ។ យុវជនទាំងឡាយ ដែលមានបំណងរៀបអាពាហ៍ពិពាហ៍ ជាមួយនាងខិតខំទិញឆ្នោត។ អ្នកខ្លះទិញជាច្រើនសន្លឹក។
- ក្រោយពីបានបើកសន្លឹកឆ្នោតហើយ យុវជនដែលមានសំណាងត្រូវឡើងលើឆាក ដើម្បីប្រារព្ធពិធី។ គេអនុវត្តដូចតទៅ ៖
    - កូនកំលោះ និងកូនក្រមុំសំពះគ្នាទៅវិញទៅមក និងសំពះភ្ញៀវដែលបានចូលរួម
    - កូនក្រមុំពាក់កម្រងផ្កាជូនកូនកំលោះ
    - ភ្លេងលេងកំដរ
    - ពិធីសំខាន់ដែលត្រូវអនុវត្ត គឺ ៖
        - កាត់សក់
        - ផ្ទឹមសំពះ
        - ចងដៃ
        - បាចផ្កាស្លា។

លោកតា *ជ្រឹង ជ្រាង* ធ្លាប់អញ្ជើញភ្ញៀវឱ្យពិសារភោជនាហារដែរ។ តែក្រោយមក ដោយឃើញថា ការចំណាយច្រើនពេក លើម្ហូបអាហារ លោកក៏បញ្ឈប់បញ្ហានេះវិញ។

កំណត់សម្គាល់ : កូនកំលោះត្រូវបានរៀបចំទុកមុន។ ប៉ុន្តែ បើមានយុវជនណាម្នាក់ហ៊ានចំណាយប្រាក់ច្រើនជាង គណៈកម្មការវត្តលើកយុវជននោះឱ្យធ្វើជាកូនកំលោះវិញ។ ឯកិច្ចសន្យាត្រូវធ្វើភ្លាមៗ នៅពេលនោះដែរ។

យើងយល់ថា នេះជាអាពាហ៍ពិពាហ៍មួយបែប ដែលបង្កឱ្យមានលក្ខណៈសប្បាយរីករាយ ដោយមានបំណងទាក់ទាញអារម្មណ៍របស់ប្រជាជន ជាពិសេសយុវជន និងយុវនារីឱ្យចូលកំសាន្តនៅក្នុងវត្តនាឱកាសចូលឆ្នាំថ្មីរបស់ប្រជាជនកម្ពុជា។ ម្យ៉ាងទៀត ប្រាក់ចំណងដៃទាំងប៉ុន្មានត្រូវបានយកទៅកសាងវត្ត ដូចជាធ្វើព្រះវិហារ កុដិ សាលាឆាន់ និងរបងវត្តជាដើម។ កត្តានេះបង្ហាញឱ្យឃើញថា ពិធីអាពាហ៍ពិពាហ៍នៅវត្តរូងជ្រៃ ជាអាពាហ៍ពិពាហ៍ដែលបានរួមចំណែកកសាងសង្គម ឬធ្វើឱ្យជីវិតលោកីយ៍នៃបព្វជិតនៅក្នុងវត្តនោះ កាន់តែរីកចម្រើនឡើង។ អាពាហ៍ពិពាហ៍នេះ បង្ហាញឱ្យឃើញផងដែរ នូវសាមគ្គីភាពយ៉ាងទូលំទូលាយរវាងបព្វជិត និងគ្រហស្ថចំណុះជើងវត្ត បង្ហាញឱ្យឃើញដំណើរទន្ទឹមគ្នានៃពុទ្ធចក្រ និងអាណាចក្រ។

## ១១ អាពាហ៍ពិពាហ៍ខ្មែរចិន

នៅប្រទេសកម្ពុជា មានខ្មែរជាច្រើននាក់ដែលមានសញ្ជាតិដើមជាចិន ពោលគឺជីដូន ជីតា ឬឪពុកម្តាយជាជនជាតិចិនសុទ្ធ ។ សព្វថ្ងៃ ចិនមានសាសន៍ ៥

នៅក្នុងប្រទេសកម្ពុជា គឺ :

- ទាជីវ (Teachiv)
- កន្តាំង (កង់តុង : Canton)
- ហុកគៀន (Hockiean)
- ហៃណាំ (Hainam)
- ខិ (Khe)

ពួកទាជីវ កន្តាំង និងហុកគៀន សុទ្ធសឹងគោរពព្រះគន់ កុង (Kon Kong) តំណាងឱ្យមេទ័ព។ ពួកហៃណាំ និងខិ គោរពព្រះនាង ម៉ា ច (Ma Chor) តំណាងឱ្យអ្នកនេសាទ។ ជនជាតិចិនទាំង ៥ បែបនេះ បានកសាងសមាគមរៀង១ខ្លួន ដើម្បីពង្រឹង និងពង្រីកពូជអម្បូរបស់ខ្លួន ជាពិសេសបង្កើនវិស័យសេដ្ឋកិច្ច។ ពួកគេពិភាក្សាអំពីបញ្ហាជំនួញជាងបញ្ហាដទៃទៀត។ ហេតុនេះ គេឈានចូលជ្រៅទៅក្នុងវិស័យសេដ្ឋកិច្ច [២]។

ពិតមែនតែពួកគេមានជំនឿដូចបានពោលខាងលើមែន តែពួកគេបានរួមចំណែកកសាងព្រះពុទ្ធសាសនាយ៉ាងសកម្ម។ គេកំពុងរួមចំណែកគោរពពិធីបុណ្យផ្សេង១ ជាមួយប្រជាជនខ្មែរតាំងពីរៀបអាពាហ៍ពិពាហ៍ឡើងទៅ។

ក្នុងការរៀបអាពាហ៍ពិពាហ៍ ប្រជាជនចិនទាំងនោះបានធ្វើឱ្យមានការចម្រុះរវាងអាពាហ៍ពិពាហ៍ខ្មែរ និងអាពាហ៍ពិពាហ៍ចិន តាំងពីទម្រង់ និងខ្លឹមសារ។ ឧទាហរណ៍ : នៅក្នុងអាពាហ៍ពិពាហ៍នីមួយ១ គេបិទផ្លាកអក្សរចិនផ្សេង១ គេប៉ាយ

---

២- ជួបជាមួយលោក *ផាន ម៉េង*, លោក *តាំង អេងហួរ* និងលោក *ស៊ីវ ហួត* នៅក្នុងសមាគមចិន ហុក-គៀន នៅ ស្រុកចក ដូនពេញ ភ្នំពេញ, ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០០១

(សំពះបែបចិន) ឬសែន ព្រេនបែបចិន។ តែនៅពេលនោះដែរ គេក៏ផ្ទឹមសំពះចងដៃ បង្វិលពពិល មានអាចារ្យជូនពរ ឬមានពិធីកាត់សក់ដូចអាពាហ៍ពិពាហ៍ខ្មែរដែរ។ កត្តានេះក៏ជះឥទ្ធិពលដល់ខ្មែរដែរ។ បងប្អូនខ្មែរជាច្រើន ដែលជាខ្មែរសុទ្ធបានទទួលយកចំណុចខ្លះរបស់ចិនមកអនុវត្ត ដូចជា ប៉ាយ និងបិទផ្លាកអក្សរចិនជាដើម។

យើងយល់ថា បើប្រៀបធៀបនឹងជនជាតិភាគតិចដទៃទៀតនៅក្នុងប្រទេសកម្ពុជា ជនជាតិចិនទាំង ៥ សាសន៍នេះ ងាយទទួលយកអរិយធម៌ខ្មែរជាងគេ។ មិនតែប៉ុណ្ណោះ ខ្មែរក៏ទទួលយកអរិយធម៌របស់គេវិញដែរ។ ពួកគេរួមចំណែកក្នុងការកសាងពុទ្ធសាសនា និងរួមចំណែកកសាងអាណាចក្រយ៉ាងសកម្ម ដូចជាសាលារៀន ផ្លូវថ្នល់ មន្ទីរពេទ្យជាដើម។

III. ការរស់នៅជាមួយគ្នាមុនរៀបអាពាហ៍ពិពាហ៍

សព្វថ្ងៃនេះ ចលនារស់នៅជាមួយគ្នាមុនរៀបអាពាហ៍ពិពាហ៍ មានកាន់តែច្រើន ដោយសារកង្វះខាតប្រាក់ ដោយសារគ្មានការទំនុកបម្រុងពីមាតាបិតា ឬអាណាព្យាបាល។ គេសង្កេតឃើញមានបញ្ហានេះនៅក្នុងចំណោមអតីតកុមារកំព្រាទាំងឡាយ។ នៅពេលដែល កុមារកំព្រាទាំងនោះពេញកំលោះ ពេញក្រមុំ គេបានបង្កើតសង្គមដោយឡែកមួយ ដោយមានបំណងរៀបការជាមួយគ្នា ដោយមិនចាំបាច់មានការស្ដីដណ្ដឹងឡើយ។ នេះជាការស្រឡាញ់ឯកឯង ដែលគ្មានការផ្គូរផ្គងពីអាណាព្យាបាល។ គេស្វែងរកមុខរបរផ្សេងៗ និងបង្កើតកូនដើម្បីស្ទងគ្រួសារ។ គេធ្វើបែបនេះ ព្រោះគេគ្មានឪពុកម្ដាយ ឬអាណាព្យាបាលជាអ្នកគ្រប់គ្រង។

គូស្វាមីភរិយាមួយចំនួនអាចមិនរៀបអាពាហ៍ពិពាហ៍រហូត ទោះបីគេរក

ប្រាក់បានក៏ដោយ។ គេមិនខ្វល់ចំពោះបញ្ហាប្រពៃណីទេ។ ប៉ុន្តែ គូស្វាមីភរិយាមួយចំនួនទៀត បន្ទាប់ពីមានកូន និងរកប្រាក់បានសមល្មមហើយ គេចាត់តាំងរៀបអាពាហ៍ពិពាហ៍ដោយខ្លួនគេ ដើម្បីប្រារព្ធប្រពៃណីខ្មែរ។ អ្នកខ្លះទៀតដែលគ្មានប្រាក់គ្រប់គ្រាន់បានរៀបចំសែនព្រេនជំនួសអាពាហ៍ពិពាហ៍។ គួរកត់សំគាល់ថា នៅពេលរៀបអាពាហ៍ពិពាហ៍ម្តងៗ ពួកយុវជន និងយុវនារី ដែលជាអតីតកុមារកំព្រាទាំងឡាយសម្តែងឱ្យឃើញពីសាមគ្គីភាពយ៉ាងទូលំទូលាយ និងជួយគ្នាយ៉ាងសស្រាក់សស្រាំគួរកោតសរសើរ។

យើងយល់ថា អតីតកុមារកំព្រាដែលបានរៀបចំសែនព្រេន ឬរៀបអាពាហ៍ពិពាហ៍ពេញច្បាប់បញ្ជាក់ឱ្យឃើញថា គេមានបំណងប្រកាន់ខ្ជាប់នូវទំនៀមទម្លាប់ខ្មែរ និងចង់ឱ្យញាតិមិត្តជិតឆ្ងាយទទួលស្គាល់ថា ពួកគេជាគូស្វាមីភរិយាដែលមាន "ខាន់ស្លា" ពេញច្បាប់។ ការណ៍នេះ ពិតជាធ្វើឱ្យគេមានសតិអារម្មណ៍ស្ងប់ស្ងាត់នៅពេលដែលគេនឹកឃើញថ្ងៃរៀបអាពាហ៍ពិពាហ៍ ដែលជាថ្ងៃរីករាយមួយ ក្នុងជីវិតរបស់គេ។

IV. ការសង្កេតទូទៅចំពោះអាពាហ៍ពិពាហ៍ខ្មែរសព្វថ្ងៃ

សព្វថ្ងៃ អាពាហ៍ពិពាហ៍ខ្មែរមានលក្ខណៈប្លែកគ្នាជាច្រើនយោលតាមតំបន់នីមួយៗ។ នៅជនបទដាច់ស្រយាល អាពាហ៍ពិពាហ៍ ច្រើនប្រព្រឹត្តទៅក្នុងរយៈពេល ២ថ្ងៃ២យប់។ នៅទីក្រុង និងទីរួមខេត្តនានា អាពាហ៍ពិពាហ៍ច្រើនប្រព្រឹត្តទៅក្នុងរយៈពេល ១ថ្ងៃ ១យប់។ អាពាហ៍ពិពាហ៍ ២ថ្ងៃ ២យប់ បានបន្សល់ទុកជាច្រើននូវខ្លឹមសារដើម តាំងពីការលេងភ្លេងកាត់ផ្កាស្លា ការហែកូនកំលោះទៅជំរាបអ្នកតា

ចាស់ស្រុក ការរាំសាកន្ទេលឡើងទៅ។ អាពាហ៍ពិពាហ៍ក្នុងរយៈពេល១ថ្ងៃ ១យប់ ជាអាពាហ៍ពិពាហ៍ដែលមានលក្ខណៈច្រូតកាត់ ធ្វើឱ្យឆាប់ហើយ ដើម្បីជៀសវាងការចំណាយពេលវេលា និងការចំណាយប្រាក់ច្រើន។

នៅក្នុងទីក្រុង និងទីរួមខេត្តនានា អាពាហ៍ពិពាហ៍កាន់តែឃ្លាតចេញពីប្រភពដើមរបស់ខ្លួន។ សម្លៀកបំពាក់តាមបែបអឺរ៉ុប និងពិធីកាត់នំបញ្ចាក់ពីថ្ងៃកំណើតនៃអាពាហ៍ពិពាហ៍កំពុងរីករាលដាល។ អ្នកសំអាងតែងឆក់ឱកាសផ្សព្វ-ផ្សាយអំពីម៉ូតសម្លៀកបំពាក់គ្រប់បែបយ៉ាង ទាំងខាងកូនកំលោះ ទាំងខាងកូនក្រមុំ។ ក្នុងពេលទទួលភ្ញៀវ ដើម្បីលៀងភោជនាហារក្នុងរយៈពេលពី ៤ ទៅ ៥ ម៉ោង កូនក្រមុំអាចតម្រូវឱ្យប្តូរសម្លៀកបំពាក់ពី ៥ ទៅ ៦ ដង។ កូនក្រមុំអវត្តមានញឹកញាប់នៅចំពោះមុខភ្ញៀវ ព្រោះអ្នកសម្អាងតម្រូវឱ្យផ្លាស់ប្តូរសម្លៀកបំពាក់។ ឯអ្នកជូសមុខឱ្យកូនក្រមុំនោះគឺ អ្នកកំដរ ពោលគឺ អ្នកកំដរ ជាអ្នកជូនផ្កាដល់ភ្ញៀវ។

នៅក្នុងឱកាសលៀងភោជនាហារ គេបង្កើតពិធីកាត់នំ។ អ្នកចាត់ចែងកម្មវិធីពុំមែនជាលោកតាអាចារ្យទេ ហើយក៏ពុំមែនជាចៅមហា ឬមេបាដែរ តែជាពិធីករម្នាក់នៅក្នុងវង់តន្ត្រីសម័យ ដែលប្រគុំកំដរពេលនោះ។ ពិធីករជាអ្នកបញ្ជាអង្គពិធីជប់លៀងទាំងមូល ដូចជាយកនំទៅបៀកនៅថ្ពាល់ឪពុកម្តាយ ទាំងសង្ខាង ដើម្បីឱ្យកូនប្រុសស្រីទៅលិទ្ធពីថ្ពាល់ ដែលគេអះអាងថា ទង្វើបែបនេះជាការសម្តែងពីការដឹងគុណចំពោះមាតាបិតា។ ពិធីករខ្លះនិយាយប៉ប៉ាច់ប៉ប៉ោចច្រើនរបៀបជាតុ្លកកំប្លែងលេងសើច ដែលខុសស្រឡះពីពាក្យ ទូន្មានរបស់លោកអាចារ្យ។ អាកប្បកិរិយាបែបនេះ កំពុងតែជះចូលទៅដល់ជាយក្រុងជាបណ្តើរៗ ហើយអាចធ្វើឱ្យខ្មែរជំនាន់ក្រោយ ភ្លេចអស់នូវប្រភពដើមនៃអាពាហ៍ពិពាហ៍របស់ខ្លួន។ គួរកត់

សម្គាល់ថា សព្វថ្ងៃ ស្ទើរតែគ្មានពិធីគោងជាយស្បៃចូលបន្ទប់ទៀតទេ។

V. យោបល់ផ្សេងៗជុំវិញបញ្ហាអាពាហ៍ពិពាហ៍

ជុំវិញបញ្ហារៀបអាពាហ៍ពិពាហ៍ខ្មែរ មានការផ្តល់យោបល់មួយចំនួនដែលយើងគួរពិចារណា។ "យោបល់ខ្លះ អាចមិនស្របនឹងយោបល់អ្នកអានទេ តែទោះបីយ៉ាងណាក៏ដោយ ក៏យើងគួរចាត់ទុកថា យោបល់ទាំងនេះមានលក្ខណៈវិះគន់ស្ថាបនា ដើម្បីឱ្យខ្មែររក្សាវប្បធម៌ប្រពៃណីតទៅទៀត នៅក្នុងពហុវប្បធម៌ដែលកំពុងលាយចម្រុះគ្នានេះ"[៣]។

១- លោក *មាស ញ៉ឹល* ប្រធានការិយាល័យធម្មការ និងសាសនា មន្ទីរធម្មការ និងសាសនារាជធានីភ្នំពេញ យល់ថា នៅរាជធានីភ្នំពេញសព្វថ្ងៃ ការរៀបអាពាហ៍ពិពាហ៍មានការខុសប្លែកពីការរៀប អាពាហ៍ពិពាហ៍នៅតាមបណ្តាខេត្ត ... ដោយសារមានជាតិសាសន៍ជាច្រើនបានមករស់នៅ។

២- លោក *យក់ សាន់* នាយករងមន្ទីរធម្មការ និងសាសនា ខេត្តកំពង់ធំ យល់ថា ការរៀបអាពាហ៍ពិពាហ៍ខ្មែរសព្វថ្ងៃនេះ មានលក្ខណៈខុសប្លែកពីជំនាន់ដើមឆ្ងាយណាស់។ លោកបញ្ជាក់ថា អាពាហ៍ពិពាហ៍ជំនាន់ដើមអាចឱ្យគូស្វាមីភរិយារស់នៅជាមួយគ្នាយូរអង្វែង មិនសូវលែងលះគ្នាដូចសព្វថ្ងៃនេះ។

៣- ស្រង់មតិសិក្ខាកាមនៅក្នុងសិក្ខាសាលាមួយ ស្តីពី *ការរក្សាប្រពៃណីខ្មែរ* ដែលរៀបចំដោយវិទ្យាស្ថានខ្មែរពុទ្ធសាសនបណ្ឌិត្យ នាថ្ងៃទី ១៨ ឧសភា ២០០១

៣- លោក *សុខ ឡាង* អនុប្រធានមន្ទីរធម្មការ និងសាសនា ក្រុងព្រះសីហនុ និងលោក *សាង សុមេន* គ្រូពុទ្ធិកបឋមសិក្សា ក្រុងភ្នំពេញ មានយោបល់រួមថា អាពាហ៍ពិពាហ៍សព្វថ្ងៃ មានប្រពៃណីបែបចម្រុះគ្នា គឺប្រពៃណីខ្មែរ ប្រពៃណីចិន និង ប្រពៃណីគ្រីស្តសាសនា។ លោកគូសបញ្ជាក់ថា ជនជាតិខ្មែរសុទ្ធ ក៏រត់តាមដំណើរនេះដែរ។ លោកធ្វើសំណូមពរដល់ប្រជាជនខ្មែរថា : ទោះអាពាហ៍ពិពាហ៍ ១ថ្ងៃក្តី ឬ ១ព្រឹកក្តី សូមធ្វើឱ្យមង្គលការមានលក្ខណៈជាខ្មែរពិតប្រាកដ។

៤- លោក *គីម ងួនជា* គ្រូបង្រៀនពុទ្ធិកបឋមសិក្សាវត្តកែវ ខេត្តបាត់ដំបង លោក *យី សារិត* អនុប្រធានការិយាល័យ ធម្មការ និងសាសនា ខេត្តបាត់ដំបង និងលោក *សួន ប៊ុនជឿន* គ្រូបង្រៀនពុទ្ធិកបឋមសិក្សាវត្តឈើទាល ខេត្តបាត់ដំបង យល់ថា អាពាហ៍ពិពាហ៍សព្វថ្ងៃមានផលវិបាកខ្លាំង ដែលទាក់ទងនឹងទំនៀមទម្លាប់ខ្មែរ ... បុគ្គលខ្លះបំភ្លេចប្រពៃណីរបស់ខ្លួន ... អាពាហ៍ពិពាហ៍ខ្លះយកប្រាក់ជាធំ ... អ្នកខ្លះចាញ់បោកអ្នកដទៃដោយសារប្រាក់ ... ធ្វើឱ្យកូនស្រីរងទុក្ខវេទនា ... កត្តានេះពិតជាជះឥទ្ធិពលអាក្រក់ដល់សង្គមកម្ពុជា ...។

៥- លោក *សារ គុយ* ប្រធានមន្ទីរធម្មការ និងសាសនា ខេត្តឧត្តរមានជ័យ ធ្វើសំណូមពរថា ... ក្រោយពីព្រះសង្ឃសូត្រមន្តចប់ គួរនិមន្តធម្មកធិកមួយអង្គ សម្តែងធម្មទេសនាអំពី *សង្គហធម៌* សំដៅទូន្មានដល់គូស្វាមីភរិយាថ្មី ដើម្បីរស់នៅជាមួយគ្នាលុះអវសាននៃជីវិត។ លោកបញ្ជាក់ថា សង្គហធម៌នេះពិតជាធ្វើឱ្យកូនប្រុស និងកូនស្រីស្គាល់តួនាទី

និងភារកិច្ចរៀង១ ខ្លួន។

៦- លោក *ជួប យាន* គ្រូពុទ្ធិកបឋមសិក្សាវត្តក្រចៅ ខេត្តក្រចេះ ស្នើឱ្យមានការផ្សព្វផ្សាយ អំពីអាពាហ៍ពិពាហ៍ជំនាន់ដើមមួយបែប ដែលសព្វថ្ងៃមាននៅក្នុងជនបទខ្លះ។ ក្នុងអាពាហ៍ពិពាហ៍នេះ មានការបាចផ្កាស្លា ការបង្វិលពពិល ការចងដៃ និងមានការលើកត្រៃ ការវេរចង្ហាន់ប្រគេនព្រះសង្ឃ។ បន្ទាប់មក ព្រះសង្ឃសម្តែងធម្មទេសនាស្តីពី *សង្គហធម៌* ...។ នេះ ជាយោបល់ ដែលស្របនឹងយោបល់របស់លោក *សារ គុយ*។

៧- លោក *ស៊ីម គួយ* ប្រធានការិយាល័យធម្មការ និងសាសនា មន្ទីរធម្មការ និងសាសនា ខេត្តតាកែវ ស្នើថា ជនជាតិខ្មែរ មិនគួរយកប្រពៃណីបរទេសមកលាយឡំក្នុងការរៀបអាពាហ៍ពិពាហ៍ ដែលនាំឱ្យបាត់បង់ប្រពៃណីខ្មែរ។ លោកសម្តែង ការព្រួយបារម្ភម្យ៉ាងទៀតថា សព្វថ្ងៃ អ្នកសម្អាង អ្នកថត និងពិធីករកាត់នំ ជាអ្នកចាត់ចែងការរៀបអាពាហ៍ពិពាហ៍ គឺមិនមែនអាចារ្យ មេបា ចៅមហា និងអ្នកផ្លូវឡើយ។

៨- លោក *សុខ ចេង* ប្រធានការិយាល័យបេតិកភ័ណ្ឌនៃមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តស្វាយរៀង បាននិយាយពីស្ត្រី ឈ្មួញម្នាក់ ដែលរត់ការខាងរៀបអាពាហ៍ពិពាហ៍ រវាងអ្នកនៅក្នុងប្រទេស និងអ្នកនៅបរទេស។ មធ្យោបាយសម្រាប់ទាក់ទងពីកម្ពុជាទៅបរទេស គឺទូរស័ព្ទ។ កូនកំលោះ និងកូនក្រមុំស្គាល់មុខគ្នាតាមរយៈរូបថត។ លោក

តួសបញ្ជាក់ថា នេះជាអាពាហ៍ពិពាហ៍តាមបែបផ្សងព្រេង ដែលកូនស្រីត្រូវឆ្លងកាត់។ ប៉ុន្តែ ទោះបីយ៉ាងណាក៏ដោយ ក៏អ្នករត់ការបានទទួលប្រាក់ពីខាងប្រុសផង និងពីខាងស្រីផង។ ជាពិសេស អ្នករត់ការនោះអាចបានទៅបរទេសទៀតផង។ ជាចុងក្រោយ លោកបន្ថែមថា អ្នកនៅបរទេសដែលត្រូវមករៀបការ ឬមកស៊ីឈ្នួលរៀបការ អាចជាមនុស្សប្រុស ឬជាមនុស្សស្រី ...។

៩- លោក *សិល សុខសារ៉ន* អនុប្រធានមន្ទីរធម្មការ និងសាសនាខេត្តតាកែវ ស្នើសុំឱ្យមានការផ្សព្វផ្សាយជាញឹកញាប់ តាមវិទ្យុទូរទស្សន៍ និងទស្សនាវដ្ដី ... ស្ដីពីអាពាហ៍ពិពាហ៍ខ្មែរ ដែលប្រព្រឹត្តទៅក្នុងរយៈពេលសមស្របមួយ ដើម្បីឱ្យខ្មែររក្សាប្រពៃណីរបស់ខ្លួន។

យើងយល់ថា មតិទាំងអស់នេះសុទ្ធសឹងជាមតិល្អៗ ដែលបង្ហាញឱ្យឃើញថា លោកទាំងអស់មានបំណងចង់ឱ្យប្រជាជនខ្មែរ រួមចំណែកថែរក្សាទំនៀមទម្លាប់ប្រពៃណីខ្មែរឱ្យនៅគង់វង្ស កុំឱ្យបាត់បង់ពីទឹកដីកម្ពុជា និងចង់ឱ្យខ្មែររក្សាកិត្តិយសក្នុងការរៀបមង្គលការរបស់ខ្លួន ជាពិសេស ចំពោះគ្រួសារខាងស្រី។

## សេចក្ដីសន្និដ្ឋាន

យើងអាចស្មានថា នៅជំនាន់ដើម ដូចជានៅសម័យនគរភ្នំ ឬនៅសម័យចេនឡាជាដើម អាពាហ៍ពិពាហ៍អាចប្រព្រឹត្តទៅក្នុងរយៈពេល ៧ថ្ងៃ ៧យប់។ យ៉ាងហោចណាស់ ក៏ទម្រង់អាពាហ៍ពិពាហ៍បែបនេះ កើតឡើងនៅក្នុងត្រកូលក្សត្រ និងនាម៉ឺន មន្ត្រី ដែលមានទ្រព្យសម្បត្តិស្ដុកស្ដម្ភដែរ។ នៅក្នុងរឿងទុំទាវ ដែលបាន

ឆ្លុះបញ្ចាំងឱ្យឃើញអរិយធម៌សម័យលង្វែក អាពាហ៍ពិពាហ៍រវាង *ហ៊ីន ងួន* និង នាង *ទាវ* ដែលរៀបចំដោយស្តេចត្រាញ់ *អជិន* បានបង្ហាញឱ្យឃើញពីការរៀបចំយ៉ាងមហោឡារិក តាំងពីពិធីសែនអ្នកតាចាស់ស្រុកឡើងទៅ។ ក្រោយមក អាពាហ៍ពិពាហ៍ត្រូវស្ថិតនៅក្នុងរង្វង់ ៣ថ្ងៃ ៣យប់។ អាពាហ៍ពិពាហ៍បែបនេះ បានអូសបន្លាយយ៉ាងយូរនៅក្នុងសង្គមខ្មែរ រហូតមកដល់ចុងសម័យសង្គមរាស្ត្រនិយម។

លុះដល់សម័យសាធារណរដ្ឋខ្មែរ ចលាចលបានកើតឡើងពាសពេញប្រទេសកម្ពុជា។ គ្រប់វិស័យត្រូវស្រុតចុះ ជាពិសេសវិស័យសេដ្ឋកិច្ចដុនដាបយ៉ាងខ្លាំង។ សន្តិសុខសង្គមមានលក្ខណៈទន់ជ្រាយ។ ការចែចូវ ការស្ដីដណ្ដឹង និងការរៀបមង្គលការត្រូវបំព្រួញកាន់តែខ្លី ដោយលោកអាចារ្យ និងមេបារក្សាទុកតែខ្លឹមសារសំខាន់ៗ មួយចំនួនប៉ុណ្ណោះ។ ទោះចង់ក្ដី ឬមិនចង់ក្ដី សភាពការណ៍នោះ ពិតជាមិនអនុញ្ញាតឱ្យប្រើពេលវេលាយូរបានឡើយ។ សភាពការណ៍បានជំរុញឱ្យអាពាហ៍ពិពាហ៍ប្រព្រឹត្តទៅក្នុងរយៈពេល ១ព្រឹក ក៏មានដែរ។

ក្នុងដើមសម័យកម្ពុជាប្រជាធិបតេយ្យ ពេលដែលពួកគេដេញប្រជាជនចេញពីលំនៅស្ថាន គ្រួសារខាងស្រីខ្លះបានអនុញ្ញាតឱ្យកូនប្រុសរស់នៅជាមួយកូនស្រី ដោយមិនបាច់សែនព្រេន ឬរៀបការ ព្រោះអ្នកទាំងពីរធ្លាប់ភ្ជាប់ពាក្យជាមួយគ្នាតាំងពីសម័យមុនម្ល៉េះ។ គ្មានច្រកណាផ្សេងទៀត ក្រៅពីធ្វើបែបនេះទេ ប្រសិនបើចង់ឱ្យកូនប្រុស និងកូនស្រីបានជួបគ្នាជាប្ដីប្រពន្ធ។ ចំពោះចិត្តគំនិតនៃ "អង្គការ" របស់ពួក *ប៉ុល ពត* វិញ គេមានបំណងកសាងវប្បធម៌ថ្មីមួយទៀតក្នុងការរៀបអាពាហ៍ពិពាហ៍ : "អង្គការ" ជាអ្នកចាត់ចែង ដោយមិនសួរទឹកចិត្តកូនកំលោះ ឬកូនក្រមុំ និងគ្មានអន្តរាគមន៍ពីឪពុកម្ដាយឡើយ។

ពីឆ្នាំ១៩៧៩ មកដល់សព្វថ្ងៃនេះ អាពាហ៍ពិពាហ៍ខ្មែរមានលក្ខណៈចម្រុះពណ៌។ ទំនៀមទម្លាប់ខ្មែរជាច្រើនកំពុងរលាយបាត់បង់។ យើងកំពុងទទួលយកអ្វីដែលមកពីក្រៅ មកប្តូរជំនួសអ្វីដែលនៅខាងក្នុង មានន័យថា យើងកំពុងធ្វើឱ្យអាពាហ៍ពិពាហ៍ឃ្លាតឆ្ងាយពីទម្រង់ និងខ្លឹមសារដើមរបស់វា ហើយធ្វើឱ្យបាត់បង់នូវបណ្តាំសំខាន់ៗ ដែលព្រះសង្ឃ និងលោកអាចារ្យបានផ្តាំសម្រាប់ដំណើរជីវិតនៃស្វាមី និងភរិយាថ្មី។

ពិតណាស់ យើងមិនអាចទប់ស្កាត់កុំឱ្យចលនាសាកលភាវូបនីយកម្ម និងទំនើបភាវូបនីយកម្មចូលមកប្រទេសយើងបានឡើយ។ ចលនាទាំងពីរពិតជាមានប្រយោជន៍ដល់សង្គមយើងផង និងផ្តល់ផលអាក្រក់ដល់សង្គមយើងផង។ ហេតុនេះយើងមិនគួរទទួល យកទាំងដុលនូវចលនាទាំងនោះឡើយ។ យើងពិតជាមិនអាចរាំងស្កាត់កុំឱ្យវប្បធម៌បរទេសចូលមកបានទេ តែយើងក៏មិនគួរបណ្តែតបណ្តោយឱ្យវប្បធម៌យើងលិចបាត់ក្នុងពហុវប្បធម៌នោះដែរ។ ហេតុនេះ យើងគួរតែខិតខំធ្វើឱ្យវប្បធម៌យើងរស់នៅជាមួយពហុវប្បធម៌។

ម្យ៉ាងទៀត យើងក៏បានមើលឃើញអំពីកត្តាអវិជ្ជមានទាំងឡាយនៅក្នុងវប្បធម៌របស់យើងផងដែរ។ យើងគួរខិតខំលុបបំបាត់ កត្តាអវិជ្ជមានទាំងនោះ។ ការរៀបអាពាហ៍ពិពាហ៍ក្នុងរយៈពេលវែងពេក ការបន្លឺងពេកក្នុងការស្តីដណ្តឹង ការចំណាយប្រាក់ច្រើន ដើម្បីបង្អួតគ្នាទៅវិញទៅមក ... សុទ្ធសឹងជាកត្តាអវិជ្ជមាន។ ក្រៅពីនេះ យើងសង្កេតឃើញថា នៅលើតុសែនដូនតា យើងមិនសរសេរអក្សរខ្មែរតែយើងបែរជាសរសេរអក្សរចិន ដែលយើងមិនយល់អ្វីបន្តិចសោះនោះ។ ចម្លែកណាស់ នៅពេលដែលបរទេសកោតសរសើរអង្គរវត្តខ្មែរ កោតសរសើរអរិយធម៌ខ្មែរ

តែខ្មែរបែរជាមិនស្គាល់តម្លៃនៃវប្បធម៌ខ្លួនទៅវិញ ...។ ការរៀបអាពាហ៍ពិពាហ៍ ២ថ្ងៃ ២យប់ ឬ ១ថ្ងៃ ១យប់ តាមលទ្ធភាពដែលអាចធ្វើបាន តាមប្រពៃណីខ្មែរពិតប្រាកដ គឺជាការរក្សាដោយប្រុងប្រយ័ត្ននូវអត្តសញ្ញាណជាខ្មែរ ។ ប៉ុន្តែ ការលាយចម្រុះពណ៌ក្នុងការរៀបអាពាហ៍ពិពាហ៍ គឺជាការបន្ថយអត្តសញ្ញាណជាខ្មែរ ទោះមានចេតនាក្ដី ឬគ្មានចេតនាក្ដី ។ មិនគួរសប្បាយនឹងកាត់នំ ដែលចាត់ចែងដោយពិធីករជាងសង្គហធម៌ ដែលជូនពរដោយលោកអាចារ្យ ឬព្រះសង្ឃ ដែលប្ដីប្រពន្ធត្រូវចងចាំឡើយ ។

(ចប់)

*លាភ មិនឈ្នះ លោភ*

*ល្មោភ មិនឈ្នះ ល្មម*

*ព្រម មិនឈ្នះ ព្រេង ។*

ព្រះវិភទ្ទញ្ញាណ **សោម ឡុច**

# វិធីសាស្ត្រក្នុងការស្រាវជ្រាវ វប្បធម៌ (ប្រពៃណី ទំនៀមទម្លាប់)

ដោយៈ **បណ្ឌិត នេត បារ៉ុម**

## ១. ធម្មជាតិ និងលក្ខណៈសម្គាល់នៃការស្រាវជ្រាវ វប្បធម៌

## ១១. មនុស្សគ្រប់ៗរូបបច្ចុប្បន្នគួរធ្វើការស្រាវជ្រាវ

ការស្រាវជ្រាវបានក្លាយទៅជាធាតុភូតមួយ មាននៅក្នុងអារ្យធម៌ពិភពលោកយើងសព្វថ្ងៃនេះ ដែលបញ្ចេវ័ន្ត និងអ្នកប្រកបមុខវិជ្ជាជីវៈនៅគ្រប់កម្រិត នៃសង្គមជឿនលឿនបានប្រកាន់យក ។ ជាពិសេសចំពោះនិស្សិត ដែលមិនបានគិតគូរដល់ការចាំបាច់ដើម្បីធ្វើការស្រាវជ្រាវទេ ពួកគេមិនអាចរៀនសូត្របានវែងឆ្ងាយឡើយនៅក្នុងប្រព័ន្ធអប់រំយើងបច្ចុប្បន្ននេះ ។ កន្លងមកយើងអាចភាន់ច្រឡំថា ការស្រាវជ្រាវអាចធ្វើឡើងតែដោយអ្នកជំនាញការកម្រិតខ្ពស់ប៉ុណ្ណោះ គឺវាហួសពីជីវភាពប្រចាំថ្ងៃរបស់យើង ។ ការស្រាវជ្រាវពុំមែនសុទ្ធតែមានទម្រង់ការលំបាកស្មុគ្រស្មាញទាំងអស់ទេ ។ មនុស្សជាច្រើនកំពុងមានសកម្មភាពពាក់ព័ន្ធជាប់នឹងការស្រាវជ្រាវហើយអាចចាប់ផ្តើមធ្វើការស្រាវជ្រាវនោះដោយងាយស្រួល ។ ពាក្យ "ស្រាវជ្រាវ" អាចប្រើក្នុងស្ថានភាព និងកម្រិតជាច្រើនខុសៗគ្នាទៅតាមបញ្ញត្តិ និងវិធីដែលយកមកប្រើ ។

ដំបូងបង្អស់ ការស្រាវជ្រាវអាចមានន័យថា ជាការជំរុញទៅមុខនូវចំណេះដឹង និងការយល់ដឹងអំពីអ្វីមួយ ។ វាពុំចាំបាច់ទាល់តែពាក់ព័ន្ធទៅនឹងការរកឃើញដ៏អស្ចារ្យ ឬសំខាន់អំពីចំណេះដឹងវិទ្យាសាស្ត្រទេ ។ ការស្រាវជ្រាវក៏អាចជាការ

ដោះស្រាយនូវបញ្ហាស្មុគ្រស្មាញអ្វីមួយ ដែលបានចោទឡើងជាយូរមកហើយ ។ ជាទូទៅការស្រាវជ្រាវចែកចេញជាពីរប្រភេទ គឺការស្រាវជ្រាវមូលដ្ឋាន និងការស្រាវជ្រាវអនុវត្ត ។ ប្រភេទទាំងពីរនេះខុសគ្នាអំពីគោលបំណងរបស់វា ។ គោលបំណងចំបងបំផុតរបស់ការស្រាវជ្រាវមូលដ្ឋាន គឺពង្រីកនូវចំណេះដឹងបន្ថែម ហើយគោលបំណងរបស់ការស្រាវជ្រាវអនុវត្ត គឺដើម្បីដោះស្រាយចំពោះមុខ និងជាក់ស្តែង ។ ជាងនេះទៅទៀត ការស្រាវជ្រាវក៏មានធ្វើឡើងដើម្បីបកស្រាយ និងព្យាករណ៍ទុកមុននូវបាតុភូតទាំងឡាយ ដែលបម្រុងនឹងកើតឡើងនៅក្នុងអនាគតជាមួយនឹងការរៀបចំអំពីគោលនយោបាយ និងសេចក្តីសម្រេចចិត្ត ។

ការលំបាកដែលតែងតែកើតមានចំពោះការស្រាវជ្រាវ គឺការកំណត់ស្ថានភាពស្រាវជ្រាវ និងលំនាំដែលអនុវត្តក្នុងការស្រាវជ្រាវ ។ ការសិក្សានូវវិធីសាស្ត្រស្រាវជ្រាវ គឺជាការលំបាកមួយ ដើម្បីជំនះនូវការលំបាកទាំងនេះ ។ ក៏ប៉ុន្តែវិធីសាស្ត្រស្រាវជ្រាវ ពុំអាចផ្តល់នូវភាពជំនាញនិងបទពិសោធន៍ក្នុងការស្រាវជ្រាវទេ គឺគ្រាន់តែបានប្រាប់នូវទិសដៅ និងជំហានដែលត្រូវដើរ ដើម្បីឱ្យមានលក្ខណៈជាប្រព័ន្ធ ឬតាមបែបវិទ្យាសាស្ត្រសម្រាប់ការស្រាវជ្រាវប៉ុណ្ណោះ ។

## ១.២ គោលបំណងនៃការស្រាវជ្រាវ

ជាទូទៅការស្រាវជ្រាវប្រមូលផ្តុំលើគោលបំណងមួយឬច្រើនដូចតទៅដើម្បី

- *ពណ៌នា ( Description ):* គឺការស្រាវជ្រាវពណ៌នា (descriptive research) សំដៅស្វែងរកព្រឹត្តការណ៍ ឬតថភាពបែបពណ៌នា ។ ឧទាហរណ៍ ពិធីរៀបអាពាហ៍ពិពាហ៍ របស់ជនជាតិគ្រើង ។
- *ទស្សន៍ទាយ (Prediction):* គឺការស្រាវជ្រាវទស្សន៍ទាយ (Predictive research)ឬធ្វើចំណោលអំពីអ្វីដែលអាចកើតឡើងនៅពេលអនាគត ឬនៅកន្លែង

ផ្សេងទៀត ។

ឧទាហរណ៍ សិក្សាស្រាវជ្រាវអំពីដំណើរវិវត្តន៍នៃរបាំប្រពៃណីខ្មែរបច្ចុប្បន្នចំពោះមុខវប្បធម៌បរទេស ដែលកំពុងមានឥទ្ធិពលមកលើ ។ លទ្ធផលពតិមានដែលបានមកអាចប្រើជាមធ្យោបាយដើម្បីរកវិធានការទប់ស្កាត់ ការស្រុតចុះ នៃវិស័យរបាំប្រពៃណីរបស់យើង ហើយនិងការអភិវឌ្ឍន៍វាឱ្យមានលក្ខណៈប្រកួតប្រជែងបាន ។

- *ការបកស្រាយពន្យល់ (Explanation)* : គឺការស្រាវជ្រាវបកស្រាយពន្យល់ (Explanatory research) ឬការកំណត់រកហេតុផលអ្វី ឬយ៉ាងដូចម្ដេចបានជាហេតុការណ៍នោះកើតឡើង ។

ឧទាហរណ៍ ការស្រាវជ្រាវបកស្រាយពន្យល់អំពី អាកប្បកិរិយាចូលសាងផ្នួសក្នុងផ្លូវព្រះពុទ្ធសាសនា របស់ប្រជាពលរដ្ឋខ្មែរ និង កម្រិតរឹងមាំនៃជំនឿខាងពុទ្ធសាសនារបស់ខ្មែរ ប្រៀបធៀបជាមួយប្រជាពលរដ្ឋថៃ ។ គោលបំណងនៃការបកស្រាយពន្យល់ ហាក់ស្រដៀងគ្នាទៅនឹងការទស្សន៍ទាយបន្តិច ក៏ប៉ុន្តែវាខុសគ្នាត្រង់ ការទស្សន៍ទាយ អាចធ្វើឡើងដោយមិនចាំបាច់មានការបកស្រាយពន្យល់មក ជាមួយបាន ។

- *ការវាយតម្លៃ (Evaluation)* : គឺការស្រាវជ្រាវវាយតម្លៃ (Evaluation research ) ឬការប្រើវិធីស្រាវជ្រាវវិទ្យាសាស្ត្រ ដើម្បីរៀបចំកម្មវិធីអន្តរាគមន៍តាមដានការអនុវត្តន៍កម្មវិធីថ្មី និងប្រត្តិបត្តិការកម្មវិធីដែលកំពុងមាន ហើយនិងកំណត់រកកម្មវិធីដែលមានប្រសិទ្ធភាព ដែលបណ្ដាលឱ្យឈោងចាប់គោលបំណងទាំងនោះបាន ។ ឧទាហរណ៍ ការស្រាវជ្រាវវាយតម្លៃអំពីការបាត់បង់គម្ពីរធម៌នៅតាមវត្តអារាមខ្មែរ ។

## ១.៣ ធម្មជាតិនៃការស្រាវជ្រាវ

ការស្រាវជ្រាវ គឺជាសកម្មភាព ឬលំនាំមួយ ហើយទម្រង់ការស្រាវជ្រាវមានច្រើននិងប្រែប្រួល ដែលលក្ខណៈសម្គាល់ទូទៅមួយចំនួនអាចជួយកំណត់ធម្មជាតិរបស់វា ។ ការស្រាវជ្រាវវប្បធម៌មានលក្ខណៈសម្គាល់ទូទៅមួយចំនួនអាចជួយកំណត់ធម្មជាតិរបស់វា ។ ការស្រាវជ្រាវវប្បធម៌ក៏មានលក្ខណៈសម្គាល់ទាំងនេះដែរ ។ លក្ខណៈសម្គាល់ទូទៅទាំងនោះមានដូចតទៅ ÷

- *ការស្រាវជ្រាវ គឺសំអាងលើពិសោធន៍ ឬសង្កេត (Empirical)*
- *ការស្រាវជ្រាវ គប្បីមានលក្ខណៈជាប្រព័ន្ធ (Systematic)*
- *ការស្រាវជ្រាវ គប្បីត្រឹមត្រូវអាចយកជាការបាន (Valid)*
- *ការស្រាវជ្រាវ គប្បីអាចជឿទុកចិត្តបាន (reliable)*
- *ការស្រាវជ្រាវ អាចប្រព្រឹត្តឡើងជាសណ្ឋានផ្សេងៗ (a variety of forms)*

*** លំនាំផ្អែកលើពិសោធន៍ ឬសង្កេត (Empirical process)**

មាគ៌ា ឬវិធីផ្អែកលើពិសោធន៍ ហើយជាពិសេស " សង្កេត " ជាលក្ខណៈសម្គាល់ឱ្យការស្រាវជ្រាវវប្បធម៌ ឬប្រពៃណី ទំនៀមទម្លាប់នៃជនជាតិមួយ ។ ការនិយមពិសោធន៍ (empiricism) គឺជាបញ្ញត្តិ ដែលចំណេះដឹងទាំងអស់ត្រូវបានដកស្រង់ពីពិសោធន៍ ឬសង្កេតរបស់ញាណ ។ លទ្ធផលនៃការពិសោធន៍ឬសង្កេតទាំងនោះ ត្រូវធ្វើឡើងជាសណ្ឋានទិន្នន័យ (data) ។ អាចមានសណ្ឋានទិន្នន័យជាច្រើនយ៉ាង ដូចជាកំណត់ត្រាចុះផ្ទាល់កន្លែង (field notes) ចម្លើយទៅនឹងកម្រងសំណួរ (questionnaire) ពត៌មានបានពីសន្ទនា ឬសម្ភាស (interview) ខ្សែអាត់ថតសម្លេង ឬរូបភាពទុកជាដើម ។ អ្នកស្រាវស្រាវធ្វើកិច្ចការជាមួយទិន្នន័យទាំងនេះ ។ កិច្ចការទាំងនេះអាចមានដូចជា រៀបចំទិន្នន័យ ( organizing data ) បង្កើតសម្មតិកម្ម ( generating

hypotheses) ទិន្នន័យទាំងនោះ សាកល្បងសម្មតិកម្ម -ល-និង-ល- ។

*** លំនាំមានលក្ខណៈប្រព័ន្ធ (Sytematic process)**

ដើម្បីលើកកំពស់ការធ្វើការស្រាវជ្រាវ យើងគប្បីធ្វើលំនាំស្រាវជ្រាវរបស់យើងឱ្យមានលក្ខណៈជាប្រព័ន្ធទៅតាមការ ដែលអាចធ្វើទៅបាន ។ មានអ្នកស្រាវជ្រាវជាច្រើនបានពណ៌នាថា ការស្រាវជ្រាវគឺជាលំនាំមួយដែលមានលក្ខណៈជាប្រព័ន្ធដូចជា McMillan Schumacher (1997) " ការស្រាវជ្រាវ ជាលំនាំ ដែលមានលក្ខណៈជាប្រព័ន្ធមួយនៃការប្រមូល និងវិភាគពត៌មាន ឬទិន្នន័យ ដើម្បីគោលបំណងមួយចំនួន " ។ យើងក៏ចង់បានការស្រាវជ្រាវវប្បធម៌ឱ្យមានលក្ខណៈជាប្រព័ន្ធដែរ ប៉ុន្តែតើយើងត្រូវធ្វើដូចម្តេចដើម្បីបានបែបនេះ ? គឺយើងប្រើមាគ៌ា ឬវិធីរិះរកតាមបែបវិទ្យាសាស្ត្រ ចំពោះការស្វែងរកចំណេះដឹងតាមរយៈវិធីប្រមូលវិភាគ និង បកស្រាយទិន្នន័យ ដែលគេទទួលស្គាល់ ។ វិធីវិទ្យាសាស្ត្រនៅក្នុងលំនាំស្រាវជ្រាវមួយយ៉ាងហោច គឺយើងបានគិតអំពីវិសាលភាពរបស់វា ត្រឹមកម្រិតណាហើយមានជំហានបន្តបន្ទាប់អ្វីខ្លះ ។ គំនិតអាចប្រែប្រួលខុស១គ្នា អំពីចំនួនជំហានជាក់លាក់នៅក្នុងវិធីវិទ្យាសាស្ត្រ ដែលជាទូទៅអាចមានពីប្រាំ ដល់ ប្រាំពីរជំហាន ។ ជំហានទាំងនេះតែងចាប់ផ្តើមឡើងពីការកំណត់រកនូវបញ្ហាស្រាវជ្រាវ ឆ្លងកាត់ការប្រមូលទិន្នន័យ វិភាគ សន្និដ្ឋាន និងបញ្ចប់ដោយការផ្សព្វផ្សាយជាសាធារណៈនូវលទ្ធផល ។ នៅទីនេះក្នុងការប្រៀបធៀមជាមួយវិទ្យាសាស្ត្រ យើងស្នើឡើងជាប្រាំមួយជំហាន ដែលមានលក្ខណៈជាទូទៅ និងជាប្រព័ន្ធចំពោះការស្រាវជ្រាវវប្បធម៌ ។

រូប.ជំហានក្នុងការស្រាវជ្រាវវប្បធម៌




ជំហានទីមួយនៃការស្រាវជ្រាវជាប្រព័ន្ធគឺ ធម្មជាតិនៃបញ្ហាស្រាវជ្រាវត្រូវតែបានកំណត់ ទោះបីវាមានន័យទូលំទូលាយសិនក៏ដោយ ។ បន្ទាប់មកគម្រោងការងារមួយសម្រាប់ធ្វើការស្រាវជ្រាវ ត្រូវរៀបចំឡើងជាមួយនឹងការកំណត់នូវលក្ខខណ្ឌខ្លះ ដែលទាក់ទងទៅនឹងបញ្ហាស្រាវជ្រាវនោះ ។

មុននឹងឈានដល់ការប្រមូលទិន្នន័យពិតប្រាកដ ការប្រមែប្រមូលពត៌មានដែលអ្នកដទៃបានដោះស្រាយ ឬ វែកញែកនូវបញ្ហាស្រដៀងគ្នានេះពីមុន មានសារៈសំខាន់បំផុត ។ ជាការពិតណាស់គេអាច ឬគប្បីទាញយកផលចំណេញពីស្នាដៃការងារអ្នកដទៃ ហើយពុំចាំបាច់ និងគ្មានប្រយោជន៍អ្វីនឹងប្រឌិតឡើងវិញនូវការងារដដែលៗទេ នៅក្នុងការស្រាវជ្រាវ ។ ឯកសារស្រាវជ្រាវ គឺជាប្រភពនៃពត៌មានបែបនេះ ។

ការប្រមូលទិន្នន័យ គឺជាជំហានទីបីនៅក្នុងការងារស្រាវជ្រាវ ដែលត្រូវមានលក្ខណៈជាប្រព័ន្ធ ។ យ៉ាងណាក៏ដោយ ទិន្នន័យពុំអាចប្រមូលបានជារបៀបមានស្រាប់ ឥតលំដាប់លំដោយ ឬដោយពិសេសបានឡើយ ។ លំនាំប្រមូលទិន្នន័យ

ទាមទារនូវការចាត់ចែង និងត្រួតពិនិត្យត្រឹមត្រូវយ៉ាងណា ដែលទិន្នន័យទាំងនោះអាចឱ្យយើងសម្រេចយកជាការបាន ។

ជំហានទីបួន គឺការវិភាគទិន្នន័យ តាមរបៀប ឬ វិធីសមស្របទៅនឹងបញ្ហា ។

ជំហានទីប្រាំ គឺការដកស្រង់ចេញនូវសេចក្ដីសន្និដ្ឋាន ឬការធ្វើឱភាសកម្មនូវទ្រឹស្ដីបន្ទាប់ពីការធ្វើវិភាគរួច ។ សេចក្ដីសន្និដ្ឋានត្រូវផ្អែកលើមូលដ្ឋានទិន្នន័យ និងការវិភាគនៅក្នុងគម្រោងនៃការស្រាវជ្រាវ ។

លទ្ធផលនៃការស្រាវជ្រាវវប្បធម៌ មានតម្លៃតិចតួចណាស់ បើគេទុកនៅជាកម្មសិទ្ធិផ្ទាល់ខ្លួនរបស់បុគ្គលអ្នកស្រាវជ្រាវរកឃើញនោះ ។ ជំហានសំខាន់មួយរបស់ការស្រាវជ្រាវវប្បធម៌ គឺការផ្សព្វផ្សាយជាសាធារណៈនូវការរកឃើញនោះតាមការបោះពុម្ពជាសៀវភៅ ចុះក្នុងទស្សនាវដ្ដីជំនាញ បង្ហាញនៅមុខអង្គការ ឬការប្រជុំវិជ្ជាជីវៈ ឬតាមប្រព័ន្ធផ្សព្វផ្សាយដទៃទៀត ។ ការផ្សព្វផ្សាយស្នាដៃស្រាវជ្រាវថ្មីៗ អាចរួមចំណែកដល់ការផ្ដល់ចំណេះដឹងថ្មីដល់អ្នកទាំងឡាយ ដែលគេត្រូវការប្រើប្រាស់ចំណេះដឹងនោះ ឬដល់អ្នកដែលអាចជួយស្ថាបនាវាបន្តតាមរយៈការស្រាវជ្រាវបន្ថែមទៀត ។ ជាការពិតណាស់ ការផ្សព្វផ្សាយជាសាធារណៈនូវចំណេះដឹង គឺជាយន្តការសំខាន់មួយចំពោះការរីកចម្រើននៃវិទ្យាសាស្ត្រ ។ មិនត្រឹមតែប៉ុណ្ណោះការផ្សាព្វផ្សាយសាធារណៈផ្ដល់លទ្ធភាពដល់អ្នកដទៃជួយវិភាគ ឬ ធ្វើឡើងវិញនូវការ ស្រាវជ្រាវនោះ ដើម្បីអះអាងបន្ថែមនូវការរកឃើញ ឬជួយរកចំណុចខ្សោយ ឬកង្វះខាតរបស់វា ដើម្បីបំពេញបន្ថែម ។

ជំហានទាំងប្រាំមួយនេះ សម្គាល់ឱ្យធម្មជាតិជាប្រព័ន្ធនៃលំនាំស្រាវជ្រាវ ។ លំនាំនេះគ្រាន់តែរៀបជាលក្ខណៈប្រព័ន្ធ និងលំដាប់លំដោយប៉ុណ្ណោះ ប៉ុន្តែមិនគប្បី

ត្រូវការគិតថា ការស្រាវជ្រាវជាលំនាំមួយរឹងស្អកនោះទេ ។ ជំហានទាំងនេះអាចជាន់គ្នា ឬបញ្ចូលគ្នាទៅតាមស្ថានការណ៍ ។

*** ភាពអាចយកជាការបាននៃការស្រាវជ្រាវវប្បធម៌** **(The Validity of Cultural Research)**

ការស្រាវជ្រាវមួយអាចយកជាការបាន កាលណាវាវាស់ (ឬប្រមូលទិន្នន័យ ) នូវអ្វីដែលអ្នកស្រាវជ្រាវចង់វាស់ ឬប្រមូល គឺត្រឹមត្រូវតាមការចង់បាន ។ ការវាស់នៅទីនេះគឺប្រព្រឹត្តឡើងចំពោះមុខសញ្ញា.កម្មវត្ថុ អថេរស្រាវជ្រាវ ។ គេចែកថ្នាក់ភាពអាចយកជាការបានដូចតទៅ ÷

- *ភាពអាចយកជាការបានផ្ទាល់មុខ (Face validity)*: ទាក់ទងនឹងការវាយតម្លៃថាតើទំនាក់ទំនងសមស្របកើតមានរវាងអថេរ និងការវាស់ដែលធ្វើឡើងដែរ ឬទេ ។
- *ភាពអាចយកជាការបានលើខ្លឹមសារ (Content validity)*
- *ភាពអាចយកជាការបានលើការជ្រើសរើសគំរូតាង (Sampling validity)*
- *ភាពអាចយកជាការបានលើការទស្សន៍ទាយ (Predictive validity)* ។
- *ភាពអាចយកជាការបានលើការរៀបចំ (Construct validity )* ។

ភាពអាចយកជាការបាននៃការស្រាវជ្រាវ គឺហេតុការណ៍ ឬការជាក់ស្តែងទាំងនោះ "អាចបង្ហាញភ័ស្តុតាងបាន " ។ វាក៏ទាក់ទងទៅនឹងបញ្ញត្តិពីរព្រមគ្នាគឺ ÷

- *ភាពអាចយកជាការបានខាងក្នុង (Intenal validity )*: គឺជាវិសាលភាពដែលក្នុងនោះ លទ្ធផលស្រាវជ្រាវនៃការសិក្សាស្រាវជ្រាវអាចបកស្រាយដោយត្រឹមត្រូវ (accurate) និងដោយប្រាកដក្នុងខ្លួន (Confident) ។

- *ភាពអាចយកជាការបានខាងក្រៅ* (External validity): គឺជាវិសាលភាពដែលក្នុងនោះលទ្ធផលស្រាវជ្រាវអាចធ្វើឱ្យភាសកម្មបាន (Generalization) ទៅនឹងប្រជាជន (population) និង ឬល័ក្ខខ័ណ្ឌបាន ។

ដើម្បីឱ្យមានវិសាលភាពកាន់តែទូលាយ ភាពអាចយកជាការបានខាងក្នុងជាល័ក្ខខ័ណ្ឌទាមទារ ដំបូងសម្រាប់មានភាពអាចយកជាការបានខាងក្រៅ ពីព្រោះបើលទ្ធផលពុំអាចបកស្រាយបានទេ គេក៏មិនអាចធ្វើឱ្យភាសកម្មអ្វីបានដែរ ។

*** ភាពអាចជឿទុកចិត្តបាននៃការស្រាវជ្រាវវប្បធម៌ ( The Reliability of Cultural Research)**

ភាពអាចជឿទុកចិត្តបាន សំដៅលើភាពមិនផ្លាស់ប្តូរ (Consistency) នៃការស្រាវជ្រាវ (ឬលទ្ធផលស្រាវជ្រាវ) និងវិសាលភាពដែលជាមួយនោះ ការសិក្សា-ស្រាវជ្រាវអាចធ្វើឡើងវិញ ឬចម្លងតាម (replicable) ដោយបានលទ្ធផលដដែល ។ ចំពោះបញ្ហានេះ ជូនកាលគេញែកជាភាពអាចជឿទុកចិត្តបានខាងក្នុង (internal reliability ) និងភាពអាចជឿទុកចិត្តបានខាងក្រៅ (external reliability) ។

ភាពអាចជឿទុកចិត្តបានខាងក្នុង សំដៅទៅលើវិសាលភាព ឬព្រំដែនការប្រមូលទិន្នន័យការវិភាគ និងការបកស្រាយមិនផ្លាស់ប្តូរនៅពេលដែលល័ក្ខខ័ណ្ឌដូចគ្នា ។ ឧទាហរណ៍ បើគេប្រើប្រាស់អ្នកប្រមូលទិន្នន័យច្រើន សំណួររបស់ភាពអាចជឿទុកចិត្តបានខាងក្នុងគឺ " តើអ្នកប្រមូលទិន្នន័យទាំងអស់ព្រមព្រៀងគ្នា ឬទេចំពោះទិន្នន័យដែលបាន ? ។ វិសាលភាពរបស់វាស្ថិតនៅលើការព្រមព្រៀងគ្នាបានគ្នាច្រើន ។ បើខ្វះភាពអាចជឿទុកចិត្តបានខាងក្នុង ទិន្នន័យទាំងនោះ ក្លាយជាចំណុះទៅនឹងអ្នកចុះប្រមូលវាជាជាងតថភាព ដែលកំពុងកើតឡើង ។

ភាពអាចជឿទុកចិត្តបានខាងក្រៅ ទាក់ទងទៅនឹងបញ្ហាថា តើអ្នកស្រាវ

ជ្រាវឯករាជ្យ អាចធ្វើការស្រាវជ្រាវឡើងវិញ ដោយបានលទ្ធផលនៅដដែលដូចគ្នា ឬក៏អត់ ? បើការស្រាវជ្រាវនោះមានភាពអាចជឿទុកចិត្តបានខាងក្រៅ អ្នកស្រាវជ្រាវដែលប្រើវិធីដូចគ្នា និងល័ក្ខខ័ណ្ឌដូចគ្នា នឹងបានលទ្ធផលដូចគ្នាទៅនឹងការស្រាវជ្រាវមុន ។

ភាពអាចជឿទុកចិត្តបាននៃការស្រាវជ្រាវ ជាប់ទាក់ទងទៅនឹងភាពអាចចម្លងតាមបាន ( ពណ៌នាអំពីទម្រង់ការ និងល័ក្ខខ័ណ្ឌ ស្រាវជ្រាវគ្រប់សព្វ ) និងភាពមិនផ្លាស់ប្តូរនៃវិធី ល័ក្ខខណ្ឌ័ និង លទ្ធផលស្រាវជ្រាវ ។

ភាពអាចជឿទុកចិត្តបាន គឺជាលក្ខណៈសម្គាល់ចាំបាច់សម្រាប់ភាពអាចយកជាការបាន ដែលការសិក្សាស្រាវជ្រាវណាក៏ដោយមិនអាចយកជាការបាន ដោយខ្វះភាពជឿទុកចិត្តបានឡើយ ។ ជាសារវ័ន្ត ភាពអាចជឿទុកចិត្តបាន និងភាពអាចយកជាការបាន បង្កើតនូវជំនឿលើការស្រាវជ្រាវ ។

* **ការស្រាវជ្រាវមានសណ្ឋានផ្សេងៗពីគ្នា (Research has a Variety of Forms)**

ឧទាហរណ៍ : សិស្សម្នាក់ពោលថា " ខ្ញុំបានស្រាវជ្រាវខ្លះអំពីប្រពៃណីខ្មែរ " នេះមានន័យថា ÷

- *បើសិស្សបឋមសិក្សា :* គឺគេកំពុងអានសៀវភៅ និយាយពីប្រពៃណីទំនៀមទម្លាប់ខ្មែរ ។
- *បើសិននិស្សិតក្រោយឧត្តមសិក្សាផ្នែកអក្សរសាស្ត្រវិញ :* គេប្រមូលផ្តុំសិក្សាស្រាវជ្រាវលើពិធីបុណ្យផ្សេងៗ និងអត្ថន័យនៃពិធីបុណ្យទាំងនោះ។
- *បើគេជាអ្នកសង្គមសាស្ត្រវិញ:* គេអាចសិក្សាស្រាវជ្រាវអំពីបែបផែនអន្តរកម្មសង្គមទៅលើពិធីប្រពៃណីខ្មែរមួយចំនួន ។

ការកំណត់ និងការពណ៌នាសណ្ឋាន ឬប្រភេទខុសៗគ្នានៃការស្រាវជ្រាវវប្បធម៌ ជំនួយសម្រាប់អភិវឌ្ឍន៍ ការយល់ដឹងអំពីវិសាលភាព នៃការស្រាវជ្រាវវប្បធម៌ ហើយនិងការខុសគ្នាទៅតាមការសិក្សាស្រាវជ្រាវ ។

( នៅមានត )

*ឃើញគេថ្កុំថ្កើង*
*កុំចចើងតាមគេ ហួសមាឌខ្លួន.*
*ប៉ុន្តែ មិនត្រូវបន្ធូរបន្ថយព្យាយាមឡើយ ។*

សម្ដេចព្រះមហាសុមេធាធិបតី សង្ឃនាយក
គណៈមហានិកាយ **ជួន ណាត** ជោតញ្ញាណោ

*ចេះនិយាយស្ដីដូចព្រះ*
*តែចិត្តមានះដូចទេវទត្ត ។*

សម្ដេចព្រះធម្មលិខិត ឧត្ដមប្រឹក្សា
វជិរប្បញ្ញោ **ឈឹ ឯម**

# ការរីកចម្រើននៃពុទ្ធសាសនាក្នុងជីវិតខ្មែរ

(ត) ដោយ : លោកស្រីបណ្ឌិត **ខួត ធីតា**
រាជបណ្ឌិតសភាកម្ពុជា

## គ‸ សាលាធម្មវិន័យ

សាលាធម្មវិន័យទើបនឹងឧបត្តិឡើងក្នុងកម្ពុជរដ្ឋ ក្រោយគេបង្អស់។ សព្វថ្ងៃកំពុងដំណើរការទៅតាមលំដាប់ ដោយអប់រំព្រះភិក្ខុសង្ឃ សាមណេឱ្យសិក្សារៀនសូត្រធម៌ និងវិន័យខាងព្រះពុទ្ធសាសនា ឱ្យបានចេះចាំស្ទាត់ដើម្បីនឹងយកទៅប្រតិបត្តិតាម។

## ឃ‸ សមាគម

### ១. សមាគមមិត្តពុទ្ធិកវិទ្យាល័យ

សមាគមមិត្តពុទ្ធិកវិទ្យាល័យ ( ពីមុនហៅថា សមាគមមិត្តសាលាបាលី ) នេះកើតឡើងដោយលោក **ម៉ៅ ម៉ី** យោក្បាត់ក្រសួងមហាផ្ទៃជាអ្នកផ្ដើមគំនិត បានណាត់ពេលប្រជុំលើកដំបូងនៅថ្ងៃទី ២០ កុម្ភៈ ១៩៤៩ ដើម្បីនឹងតាំងគណៈកម្មាធិការបណ្ដោះអាសន្ន នឹងធ្វើសេចក្ដីព្រាងនៃលក្ខន្តិកៈសមាគមនេះ។ ដល់លក្ខន្តិកៈសម្រេចហើយ បានធ្វើមហាសន្និបាតបោះឆ្នោតលើកទី ១ រើសក្រុមអភិបាល និងបើកមន្ទីរសំណាក់ធ្វើការរហូតដល់ឆ្នាំ ១៩៥៧[១]។

---

១- រ៉ាយ ប៊ុក ព្រះពុទ្ធសាសនា នៃប្រទេសកម្ពុជា ភ្នំពេញ ទំព័រ ២៤

សមាគមពេលនោះមានវត្ថុបំណងប្រាំប្រការ គឺ :

១- រួបរួមសិស្សានុសិស្ស និងមិត្តសាលាបាលីទាំងឡាយដែលមានបំណងលើកតម្កើងភាសា និងអក្សរជាតិ ។

២- ឧបត្ថម្ភអ្នកសិក្សា ភាសាបាលី និងភាសាជាតិដោយគ្រឿងសម្ភារៈសមរម្យ ។

៣- បង្កើតឱ្យមានការបោះពុម្ពទស្សនាវដ្តី សារពត៌មាន និងសៀវភៅផ្សេងៗ ដើម្បីនឹងពង្រីកអក្សរសាស្ត្រខ្មែរ

៤- បង្កើតឱ្យមានបណ្ណាល័យសម្រាប់សមាគម

៥- សង្គ្រោះដល់អ្នកមានប្រាជ្ញាវាងវៃ ដែលចេញទៅសិក្សានៅប្រទេសក្រៅ ។

សមាគមនេះមានដំណើរការតមកបានលទ្ធផលដូចខាងក្រោម :

១- ធ្វើបុណ្យព្រហ្មទាន ចំពោះសិស្សដែលប្រឡងជាប់សញ្ញាប័ត្របាលីជាន់ខ្ពស់ ( ពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត) បួនលើក

២- ចែកគ្រឿងសម្ភារៈ ចំពោះសាលាបាលីរងនៅក្នុងព្រះរាជធានី ១៤ វត្ត ( ១៩៥២) នៅខេត្តកណ្ដាល ៦២ វត្ត ( ១៩៥៣)

៣- ចាត់ចែងនឹងបញ្ជូនភិក្ខុឱ្យសិក្សារៀនសូត្រនៅមហាវិទ្យាល័យដទៃទៀត

៤- បោះពុម្ពផ្សាយទស្សនាវដ្តី « មិត្តសាលាបាលី » ឬ «ពុទ្ធិក-វិទ្យាល័យ »

៥- ស្ថាបនាសាខាសមាគមខេត្តស្រុក ឃុំ ( ១៩ សាខា)

២- ពុទ្ធិកសមាគមពិភពលោកមជ្ឈមណ្ឌលភូមិភាគកម្ពុជរដ្ឋ

ពុទ្ធិកសមាគមពិភពលោកមជ្ឈមណ្ឌលភូមិភាគកម្ពុជរដ្ឋ សមាគមនេះបានដំណើរការមកទល់នឹងមហាសង្គ្រាមលោកលើកទីពីរ ទើបថយកម្លាំងរួចវិនាសសាបសូន្យ ។

ទើបមកដល់ថ្ងៃ ១៤ កញ្ញា ១៩៥២ ក្រោយដែលសម្ដេចព្រះមហាសុមេធាធិបតីសង្ឃនាយក « **ជួន ណាត** » និមន្តត្រឡប់ពីប្រជុំសមាជពុទ្ធសាសនាសកលនៅទីក្រុងកូលុមបូ ( ប្រទេសស៊ីឡង់) នៅខែមិថុនា ១៩៥០ សមាគមនេះក៏ផ្ដួចផ្ដើមឡើងដោយសម្ដេច ជាអ្នកជួយឧបត្ថមមាននាមថា « ពុទ្ធិកសមាគមពិភពលោកមជ្ឈមណ្ឌលភូមិភាគកម្ពុជរដ្ឋ » ។ សមាគមនេះ បានជ្រើសរើសក្រុមអភិបាលបណ្ដោះអាសន្នក្នុងពេលនោះ រួចបានរើសជាស្ថាពរនៅថ្ងៃទី ២៨ ធ្នូ ឆ្នាំ ១៩៥២[២] ។

សមាគមនេះតាំងពីមានដំណើរការមក បានបញ្ជូនសិស្សពីររូបឱ្យទៅរៀននៅអសោការាម ក្នុងសំណាក់ព្រះភិក្ខុ **ម៉ែ លួន** ( ធម្មរាមោ) ជិតទីក្រុង ដេលហី ( ប្រទេសឥណ្ឌា) ។

៣- សមាគមគិលានសង្គ្រោះ ចំពោះព្រះសង្ឃ សមាគមនេះស្ថាបនាពីថ្ងៃទី ២៨ ធ្នូ ១៩៤៩ ហើយបានសាងសង់មន្ទីរពេទ្យព្រះសង្ឃ ហើយបានសម្ពោធនៅថ្ងៃទី ២១ កុម្ភៈ ១៩៥៦ ។

**ខ‸ ទំនាក់ទំនងជាមួយប្រទេសដទៃខាងផ្លូវពុទ្ធសាសនា**

១- សមាជសាកលពុទ្ធសាសនានៃទីក្រុងកូលុមបូ ( ប្រទេសស៊ីឡង់)

១- វ៉ាយ ប៊ុក ព្រះពុទ្ធសាសនា នៃប្រទេសកម្ពុជា ភ្នំពេញ ទំព័រ ២៧២២

សមាជនេះធ្វើនៅទីក្រុងកូលុមបូ (លើកទី ១) ដោយសេចក្តីណែនាំពីសមាគមពិភពលោកនៅទីក្រុងនេះដែលមានលោក **ឧ.ឧ.មលលសេគេរះ** ជាប្រធាន មានប្រទេសក្នុងពិភពលោកជាច្រើន ប្រហែលជាង៤០ បានទៅរួមប្រជុំ ក្នុងពេលនោះផងដែរ។ ប្រទេសកម្ពុជាយើងមានសម្តេចសុមេធាធិបតី «**ជួន ណាត**» ជាប្រតិភូរបស់ប្រទេសយើង ឯកឧត្តម ប្រាក់ សារិន ព្រះគ្រូសូត្រសត្ថា បុណ្យសមាជជាសមាជិក លោក តាន់ ប៊ូរ ហេង លោក បេ យាន ជាអ្នកសង្កេតការ។ កិច្ចប្រជុំគឺធ្វើថ្ងៃ ២៦ ឧសភា ដល់ថ្ងៃទី ៤ មិថុនា ឆ្នាំ ១៩៥០ ។

២- សមាជសាកលពុទ្ធសាសនានៅទីក្រុងតូក្យូ (ប្រទេសជប៉ុន) លើកទីពីរ

សមាជនេះបានធ្វើនៅវត្តហង្គាឃិ (ក្រុងតូក្យូ) នៅថ្ងៃទី ២៥ កញ្ញា ដល់ថ្ងៃទី ១៣ តុលា ១៩៥២។ ប្រទេសទាំងឡាយមាន ប្រទេសឥណ្ឌា ថៃ ភូមា កម្ពុជា វៀតណាម ចិន ជប៉ុន ជាដើម។ ប្រទេសដែលចូលរួមពេលនោះមានចំនួន ៥០ ប្រទេស មានគណៈប្រតិភូចំនួន ១៧០ នាក់។

គណៈប្រតិភូប្រទេសកម្ពុជាយើងគឺ :

ព្រះពោធិវង្ស **ហួត តាត** (វិរិយប្បញ្ញោ) នាយកគណៈប្រតិភូ

ភិក្ខុ **ខៃ សុខ** (និយានប្បទីបោ) សមាជិក

លោក **ឡែមង់ប៉ាន់** អ្នកបកប្រែ

លោក **បេ យាន** ជាអ្នកសង្កេតការ។

គណៈប្រតិភូ បានទៅរួមប្រជុំជាមួយនឹងប្រទេសឯទៀតដើម្បីរិះរកនូវមធ្យោបាយស្ថាបនានូវព្រះពុទ្ធសាសនា ឱ្យបានគ្រប់ប្រទេសក្នុងសាកលលោក ដើម្បី

នឹងរក្សាសន្តិភាពឱ្យបានពាសពេញ ជៀសវាងនូវមហាសង្គ្រាមទីបីតទៅអនាគត[៣] ។

## ច‿ អនុសំវច្ឆរ មហាសន្និបាត

អនុសំវច្ឆរមហាសន្និបាត គឺការប្រជុំរាជាគណៈ និងឋានានុក្រមក្នុងកម្ពុជរដ្ឋ ១ ឆ្នាំ ម្តងនៅរាជធានីភ្នំពេញ ។ ក្នុងពេលនោះត្រូវព្រះសង្ឃនាយកទាំងពីរគណៈដាស់តឿនព្រះសង្ឃឱ្យប្រព្រឹត្តប្រតិបត្តិតាមធម៌វិន័យ បង្ហាញនូវវិធីផ្សេងៗ ដែលនាំឱ្យព្រះពុទ្ធសានា ចំរើនទៅអនាគត ។

ក្រៅពីគោលការណ៍ខាងលើ ប្រទេសកម្ពុជាបានចាត់ព្រះពោធិវង្ស ហួត តាត ចាងហ្វាងពុទ្ធិកវិទ្យាល័យព្រះសុរាម្រិតព្រមទាំងភិក្ខុ បៃល ឡុង (ធម្មវីរិយៈ) និមន្តទៅប្រជុំនៅទីក្រុងតូក្យូ (ប្រទេសជប៉ុន) ដើម្បីសន្តិភាព ។ លោកទាំងពីរបាននិមន្តទៅប្រទេសថៃពីរលើក ដើម្បីពិនិត្យនូវរបៀបសិក្សាខាងព្រះពុទ្ធសាសនា។ សម្តេចព្រះសុមេធាធិបតីសង្ឃនាយក **ជួន ណាត** ទៅប្រជុំសង្គាយនាឯទីក្រុងរង្គូន (ប្រទេសភូមា) និងចូលរួមសមាជពុទ្ធសាសនាសាកលនៅទីក្រុងដដែល។ ព្រះគ្រូសង្ឃសត្ថា បុណ្យសម្ពាជ (ធម្មាភាមោ) ទៅប្រជុំឯពុទ្ធគយា (ប្រទេសឥណ្ឌា) ដើម្បីស្ថាង ព្រះវិហារសម្រាប់ព្រះសង្ឃខ្មែរនៅទីនោះ។ មិនតែប៉ុណ្ណោះ តំណាងប្រទេសកម្ពុជាក៏បានចូលរួមប្រជុំក្នុង **វជ្រពិធី** នៅសញ្ចិ-ភោបាល (ប្រទេសឥណ្ឌា) ព្រមទាំងបានរៀបចំពិធីទទួលព្រះបរមសារីរិកធាតុ ដែលមហាពោធិសមាគម បានដង្ហែរចូលមកប្រតិស្ថាននៅទីក្រុងភ្នំពេញ។

ប្រទេសកម្ពុជាបានរៀបចំទទួលលោក **ម៉ាលៈលៈសេកេរៈ** ប្រធានពុទ្ធិកសមាគមពិភពលោកនៃលង្កាទីប ព្រមទាំងធ្វើពិធីបុណ្យ ព.ស ២៥០០

៣- វ៉ាយ ប៊ុក ព្រះពុទ្ធសាសនា នៃប្រទេសកម្ពុជា ភ្នំពេញ

ព្រះវស្សារបស់ព្រះសម្មាសម្ពុទ្ធនៅអង្គរវត្ត និងសម្ភោធអនុស្សាវរីយ៍តម្កល់ព្រះបរមសារីរិកធាតុភ្នំពេញ ឆ្នាំ ១៩៥៧[៤] ។

**កំណត់** : *នៅប្រទេសខ្មែរយើងរវាងទស្សវត្តទី ៥០ នៃសតវត្សន៍ទី ២០ ព្រះពុទ្ធសាសនាមានចែកធម៌ចាស់ ធម៌ថ្មី ព្រះសង្ឃក៏មានចាស់ មានថ្មីដែរ។ ពាក់កណ្ដាលទស្សវត្សន៍ទី ៥០ នៃសតវត្សន៍ទី ២០ ទើបព្រះពុទ្ធ-សាសនាប្រទេសយើងមានសន្ទុះរីកចំរើន ពិសេសសម័យកាលសម្ដេច* ***ជួន ណាត, ហួត តាត*** *សម្ដេច* ***ឆាំង*** *(ព្រះសុគន្ធ)*

ឯសារពិគ្រោះ

១- វ៉ាយ ប៊ុក ព្រះពុទ្ធសាសនា នៃប្រទេសកម្ពុជា

២- ធម្មសម្បត្តិ ឯកសារព្រះពុទ្ធសាសនាបុរាណ

៣- លី-ហ៊ីណូត៏ ប្រែដោយ ជុំ ម៉ៅ អំពីព្រះពុទ្ធសាសនា ដើមឫសព្រះពុទ្ធសាសនា សេចក្ដីចម្រើននៃព្រះពុទ្ធសាសនា។

(នៅមានត)

៤- វ៉ាយ ប៊ុក ព្រះពុទ្ធសាសនា នៃប្រទេសកម្ពុជា ភ្នំពេញ

# កំណត់សម្គាល់ និង ការប្រើប្រាស់ នាមព្រះមហាក្សត្រ ខ្មែរ នាសម័យបុរាណ ៖ តាមរយៈសិលាចារឹក

**Note on the Name of Ancient Khmer King and Its Orthographical Usage: Through Inscriptions**

ខង់ សុខាវ៉ា
សាស្ត្រាចារ្យដេប៉ាតឺម៉ង់ប្រវត្តិវិទ្យា
នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ

## ៣- អំពីការប្រើប្រាស់នាមព្រះមហាក្សត្រ

នេះជាបញ្ហាចុងក្រោយ និងសំខាន់ សម្រាប់ប្រធានបទនេះ បន្ទាប់ពីយើងស្គាល់បច្ចេកស័ព្ទនាំមុខនាមព្រះមហាក្សត្របុរាណ តាមរយៈសិលាចារឹក ។

ក្នុងការកត់ត្រា ឬ បកប្រែ អសាធារណនាមពីភាសាមួយទៅភាសាមួយទៀត មិនអាចធ្វើឡើងបានត្រឹមត្រូវគ្រប់អន្លើនោះទេ ទោះបីភាសាសំស្ក្រឹត ឬ ភាសាខ្មែរ ។ ហេតុនេះ បើអ្នកស្រាវជ្រាវមិនបានពិនិត្យអោយច្បាស់ នៅពេលកំពុងដំណើរការស្រាវជ្រាវ ដោយផ្ទៀងផ្ទាត់ជាមួយឯកសារជាភាសាខ្មែរអោយបានល្អិតល្អន់ ហើយបែរជាផ្អែកលើឯកសារបរទេសទាំងស្រុងនោះ នៅពេលយកមកសរសេរជាស្នាដៃ ពិតជានាំអោយមានកំហុសមិនខាន ។

កន្លងមក យើងសង្កេតឃើញ អសាធារណនាមមួយចំនួន ឬនរនាមបុគ្គលសំខាន់ៗក្នុងប្រវត្តិសាស្ត្រ មានព្រះមហាក្សត្រជាចម្បង ត្រូវបានគេសរសេរដោយអក្ខរាវិរុទ្ធខុសៗពីគ្នា ដែលប្រការទាំងនេះ ប្រហែលជាកើតមាន ដោយសារតែ

អ្នកស្រាវជ្រាវ ពឹងផ្អែកលើប្រភពឯកសារបរទេស ឬ ឯកសារជាច្រើនទៀត ដែលមិនមែនជាសំណៅឯកសារដើម ឬក៏ជាសំណៅឯកសារដើមដែរ ប៉ុន្តែពាក្យពេចន៍គេប្រើប្រាស់តាមរបៀបបុរាណពេក ហើយដែលគេមិនទាន់ បានសិក្សាដោយពិនិត្យពិច័យល្អិតល្អន់នៅឡើយ ឬម្យ៉ាងទៀត ដោយសារអ្នកស្រាវជ្រាវនោះមិនបានស្គាល់អក្ខរវិធីភាសាសំស្ក្រឹត-ខ្មែរ-បាលី ឬ Phonetic or Roman transliteration ដែលគេបានកត់ត្រា ។

ក្នុងគោលបំណងធ្វើអោយឯកភាព ក្នុងការសរសេរនាមទាំងអស់នោះហើយ ទើបយើងលើកបញ្ហានេះមកនិយាយ ក្រោយពីបានពិនិត្យ ពិចារណា និងផ្ទៀងផ្ទាត់ជាមួយឯកសារដើមជាច្រើន ដែលទាក់ទិនរួចមក ។ ត្បិត នរនាមនីមួយៗ ជាបញ្ហាសំខាន់ វាមិនត្រូវបាននរណាម្នាក់យកមកសរសេរ ម្តងតាមអក្ខរាដូច្នេះ ម្តងដូច្នោះបានទេ កាន់តែសំខាន់ទៅទៀតនោះ នាមរបស់ព្រះរាជាដែលជាមេដឹកនាំកំពូលរបស់ជាតិ និងជាអ្នកទទួលខុសត្រូវធំបង្អស់ ចំពោះជោគវាសនាប្រទេស ក៏ដូចជា បណ្តាមន្ត្រីសំខាន់ៗនៃរជ្ជកាលរបស់ទ្រង់ ។

ដើម្បីកាន់តែងាយចងចាំយើងបានរួបរួមជាបញ្ជីឈ្មោះព្រះរាជាខ្មែរសម័យមុនអង្គរ និងអង្គរ ដែលត្រូវបានស្រង់ចេញពីសិលាចារឹកសាស្ត្រភាសាសំស្ក្រឹត និងភាសាខ្មែរ ព្រម ទាំងឯកសារស្នាដៃនិពន្ធមួយចំនួនទៀត ។

## ក- នាមព្រះមហាក្សត្រនគរភ្នំ

- កៅណ្ឌិន្យទី១ ( អភិសេកជាមួយព្រះនាង សោមា = បឋមក្សត្រខ្មែរ)
  Kauṇḍinya I (Queen Somā) = Kaundinya I (Queen Somā)
  ( គ.ស. ៥២ ?)

មានឯកសារខ្លះសរសេរថា កៅឌិញ្ញ [១] ។

- ស្រីមារៈ Çrimāra (គ.ស. ២២០-២២៨) [២]
- កៅណ្ឌិន្យទី២ Kauṇḍinya II = Kaundinya II (គ.ស. ៤២០)

មានឯកសាខ្លះថា *កៅឌិញ្ញវរ្ម័ន* ។ [៣]

- ស្រីន្ទ្រវម៌ [៤] Çrindravarman (គ.ស. ៤៣០-៤៤០)
- (កៅណ្ឌិន្យ) ជយវម៌ [៥] (Kauṇḍinya) Jayavarman (គ.ស.៤៧០ - ៥១៤) ឯកសារសិលាចារឹកមានត្រឹមតែពាក្យ *ជយវម៌* ប៉ុណ្ណោះ ។
- គុណវម៌ (រជ្ជទាយាទ) Guṇavarman[6] (គ.ស. ៥១៤?)
- រុទ្រវម៌ Rudravarman (គ.ស. ៥១៤-៥៥០) [៧]

---

[1] សូមមើល. រចប *ប្រវត្តិសាស្ត្រខ្មែរ* ទំព័រ ១៧៤។

[2] Correspondent with the King *Fan Shih Man*, voir, *SSIAC:* 28 និង សូមមើល ត្រឹង ងា *ឯកសារជជែល* ទំព័រ ៨៦ ។

[3] សូមមើល. រចប *ឯកសារជជែល* ទំព័រ ១៧៩ ។

[4] មិនមែន *ស្រីឥន្ទ្រវរ្ម័ន* នោះទេ ។

[5] Mahesh Kumar Sharan សរសេរត្រឹមតែ *ជយវរ្ម័ន Jayavarman* ប៉ុណ្ណោះ ដូចគ្នានឹងសិលាចារឹកប្រាសាទប្រាំល្វែងនៅថាប់ម៉ឺយ ប្រទេសវៀតណាមភាគខាងត្បូង ។ បើគាត់អះអាងបែបនេះ ព្រះមហាក្សត្រ ដែលមាននាម *ជយវម៌្ម* នៅសម័យមុនអង្គរមានចំនួនដល់ទៅបីអង្គ ។ ក៏ប៉ុន្តែការដែលដាក់ថែមនាម កៅណ្ឌិន្យ ខាងមុខបែបនេះ ដោយសារផ្អែកលើឯកសារចិនថា *ចៅ យេ ប៉ា ម៉ោ* (=ជយវម៌្ម) មានត្រកូល *គាវ ឆេន យូ* (=កៅណ្ឌិន្យ) ។

[6] តាមសិលាចារឹកប្រាសាទប្រាំល្វែង នៅថាប់ម៉ឺយ ថា *ព្រះអង្គជាអនាគតព្រះរាជា* ។ បើតាមន័យដាច់ៗក្នុងចារឹកត្រង់កន្លែងរលុប ព្រះបិតាព្រះអង្គ(កៅណ្ឌិន្យ *ជយវម៌្ម*) ទំនងជាធ្វើសង្គ្រាមជាមួយ ស្តេច *វីរវម៌្ម* បិតាមហេន្ទ្រវម៌្មទី១?)(*APK I:* 208-9).

តាមឯកសារបណ្ឌិតរស់ ចន្ទ្រាបុត្រ *ប្រវត្តិសាស្ត្រខ្មែរ* ទំព័រ ១៨១ ថា *រុទ្រវ័រន* ។

## ខ- នាមព្រះមហាក្សត្រចេនឡា[៨]

- ស្រុតវម៌ Srutavarman (គ.ស. ៥០០)
- ស្រេស្ឋវម៌ Çreṣthavarmman = Sreshthavarman (គ.ស. ៥៤៥-៥៦០)
- កម្ពុជរាជលក្ស្មី (មហាក្សត្រិយានី) Kambujarājalakṣmī (គ.ស. ៥៦x-៥៨០)

[7] Mahesh Kumar Sharan ជឿថា ព្រះបាទរុទ្រវម៌ ដែលប្រាកដនាមលើសិលាចារឹកក្ដីអង្គ ដោយសារការនិទានរបស់គ្រូពេទ្យហ្លួង*ជយវម៌ទី១* ឈ្មោះ សីហទត្ត មិនមែនជាព្រះរាជានៃនគរភ្នំ។ ហេតុនេះហើយ ទើបគាត់ស្រង់នាមស្ដេចអង្គនេះដាក់ទៅក្នុងរបាក្សត្រខាងចេនឡាវិញ (*SSIAC*: 33)។ បញ្ហានេះ លោក Michael Vickery និយាយបញ្ជាក់ជាច្រើនលើកសារ នៅក្នុងសម្មតិកម្ម នៃការរួបរួមគ្នារវាង*នគរភ្នំ* និង *ចេនឡា* ដែលជាសាមន្តរដ្ឋមួយ ដោយទាញយកភស្ដុតាងនៃ គ្រួសាររបស់ *សីហទត្ត* ដែលមានបុព្វបុរសជាអ្នកបំរើស្ដេច៥អង្គបន្តបន្ទាប់គ្នា ក្នុងនោះ ទី១ គឺព្រះ បាទរុទ្រវម៌ ដែលជាមហាក្សត្រនគរភ្នំ ទី២ ព្រះបាទភវវម៌ទី១ ទី៣ ព្រះបាទមហេន្ទ្រវម៌ ទី៤ ព្រះបាទឥសានវម៌ទី១ និងទី៥ព្រះបាទជយវម៌ទី១ ដែលព្រះមហាក្សត្រ៤អង្គចុងក្រោយនេះ ជា ស្ដេចរដ្ឋចេនឡា ដែលគេថាជាអ្នកវាយយកអាណាចក្រភ្នំតាំងតែពីពាក់កណ្ដាលសតវត្សរ៍ទី៦គ.ស. ដូច្នេះតាមលោក Michael Vickery ព្រះបាទរុទ្រវម៌ គឺជាព្រះរាជានគរភ្នំ ។

[8] ដើមសន្តតិវង្សចេនឡា គឺព្រះឥសី*កម្ពុ* និង *មេរា* តំណាងសូរ្យវង្ស តាមសិលាចារឹកបក្សីចាំក្រុង សតវត្សរ៍ទី១០ ។ ក៏ប៉ុន្តែ នាមព្រះរាជា ដែលគេចាត់ទុកជាអ្នកបង្កបង្កើតរដ្ឋចេនឡាដំបូងគេ គឺ ព្រះបាទ ស្រុតវម៌ និងបុត្ររបស់ព្រះអង្គ ស្រេស្ឋវម៌ ដែលបានបង្កើតរាជធានីស្រេស្ឋបុរៈ រហូតមក ដល់សម័យអង្គរ ឈ្មោះនេះនៅតែឃើញមាន សម្គាល់ជាខេត្តមួយ "ប្រមាន ឬ វិសយ" ស្រេស្ឋបុរ។

## គ នាមព្រះមហាក្សត្រសម័យចេនឡា

- ភវវម៌ទី១ Bhavavarman I (គ.ស. ៥៨០-៥៩៨)
- មហេន្ទ្រវម៌ (ចិត្រសេន) Mahendravarman (Citrasena) (គ.ស.៥៩៨-៦១០) ឯកសារខ្លះដាក់ថា *មហិន្ទ្រវរ៌ន* ឯនាមមុនពេលសោយរាជ្យថា *ចិត្រសេនា* ទៅវិញ ។[៩]
- ឥសានវម៌ Içānavarman I (គ.ស. ៦១០-៦៣៥)
- ភវវម៌ទី២ Bhavavarman II (គ.ស. ៦៣៥-៦៥៧)
- ជយវម៌ទី១ Jayavarmman I (គ.ស. ៦៥៧-៦៨១)
- ជយទេវី (មហាក្សត្រិយានី) Jayadevī (Queen) (គ.ស. ៦៨១-៧១៦)[១០]

### គ-១ នាមព្រះមហាក្សត្រចេនឡាទឹកលិច

- បុស្ករាក្ស[១១] Puṣkarākṣa = Pushkaraksha (គ.ស. ៧១៦-៧៣០) ឯកសារខ្លះសរសេរថា *បុស្សក រ័ក្ស* បែបនេះ ។
- សំភុវម៌ Çamḅhuvarman (គ.ស. ៧៥០)
- រាជេន្ទ្រវម៌ទី១[១២] Rājendravarman (គ.ស. ៧៦០)

---

[9] សូមមើល. រចប *ឯកសារដដែល* ទំព័រ ១៨៥ ។

[10] Voir, *supra.* p. 3.

[11] អានថា *បុស ស្កះ រ៉ាក់* ។

[12] អានថា *រៀច ជេន ទ្រាក់ វ រ៉ាក់* គេមិនអាចកែនាមព្រះអង្គ ដោយសរសេរជា *រាជឥន្ទ្រវរ៌ន* បានទេ ។

ឯកសារខ្លះសរសេរថា *រាជឥន្ទ្រវរ៌្មន* ដោយញែកការធ្វើសន្ធិនៃពាក្យសមាស *រាជេន្ទ្រ* ។

- មហីបតិវរ៌្ម (បុត្រារាជេន្ទ្រវរ៌្មទី១) Mahīpativarman (គ.ស. ៧៨០?)
- ជយវរ៌្មទី១ស្ទួន Jajavarman I bis (គ.ស. ៧៧០-៧៨១)[១៣]

**គ-២ នាមព្រះមហាក្សត្រចេនឡាដីគោក**

- ជយសិង្ហវរ៌្ម Jajasinghavarman [K 404, *C VII:* 73] (គ.ស. ៧xx) មិនមែនសរសេរជា "ជយសិង្ហវរ៌្មន" នោះទេ ។

## ឃ នាមព្រះមហាក្សត្រសម័យអង្គរ

- ជយវរ៌្មទី២ Jayavarman II (គ.ស. ៨០២-៨៥០)
- ជយវរ៌្មទី៣ Jayavarman III (គ.ស. ៨៥០-៨៧៧)
- ឥន្ទ្រវរ៌្មទី១ Indravarmman I (គ.ស. ៨៧៧-៨៨៩)
- យសោវរ៌្មទី១ Yaçovarmman I (គ.ស. ៨៨៩[១៤] -៨៩៩)

---

[13] Voir, *supra.*

[14] Cf, Ak Puok inscrip. K 1051ដែលបញ្ជាក់ថា នៅក្នុងរាជ្យព្រះបាទ *រុទ្រលោក* (Rudra-loka) គឺព្រះបាទ ហរិវរ៌្មទី១ នៅឆ្នាំ៨២១នៃមហាសករាជ គឺគ.ស. ៨៩៩ មានមន្ត្រីសង្ឃជាន់ខ្ពស់ម្នាក់ នាម ចន្ទ្រសិខរព្រាហ្មណ (Vraḥ Kamraten Añ Candraçikhara Vrāhmaṇa) ស្ថាបនាប្រាសាទឥដ្ឋមួយ ប្រតិស្ឋានអាទិទេព*នារាយន* (Vraḥ Kamraten Añ Nārāyana) និងថ្វាយនិធិជាច្រើនដល់ប្រាសាទ ។ ចារឹកនេះសព្វថ្ងៃរក្សាទុកនៅវត្តសម្តេច? (Vat Samdek) ខេត្តបាត់ដំបង ។

- ហសិវម៌ទី១[15] Harṣavarman I = Harshavarman I (គ.ស. ៩៨៩-៩២៥) មានឯកសារខ្លះសរសេរថា *ហរស្សវ៉ារ៍ន* ។
- ឥសានវម៌ទី២ Içānavarman II (គ.ស. ៩២៥-៩២៨)
- ជយវម៌ទី៤ Jayavarman IV (គ.ស. ៩២៥-៩៤១)
- ហសិវម៌ទី២ Harṣavarman II = Harshavarman II (គ.ស. ៩៤១-៩៤៤)
- រាជេន្ទ្រវម៌(ទី២) Rājendravarman (II) (គ.ស. ៩៤៤-៩៦៨) តាមឯកសារបណ្ឌិត រស់ ចន្ទ្រាបុត្រ ទំព័រ២០៧ សរសេរថា *រាជេន្ទ្រវ៉ារ៍ន*
- ជយវម៌ទី៥ Jayavarman V (គ.ស. ៩៦៨-១០០១)
- ឧទយាទិត្យវម៌ទី១[16] Udayādityavarman I (គ.ស.១០០១ - ១០០២) ឯកសារខ្លះសរសេរថា *ឧទ័យទិត្តិយវ៉ារ៍ន* ឬ *ឧទ័យវ៉ារ៍នទី១* ។
- ជយវីរវម៌ Jayavīravarman (គ.ស. ១០០២-១០០៨[17])

---

[15] អានថា *ហាស់ សាក់ វ៉ា ភាក់* បើសរសេរជា *ហរស្សវ៉ារ៍ន* បែបនេះមិនបានទេ ។ សម. រចប *ឯកសារដដែល* ទំព័រ ២០៤ ។

[16] អានថា *ឧ ទៃ យា ទិត ត្យាក់ វ៉ា ភាក់* ព្រះអង្គជាឪពុកមាខាងម្តាយរបស់ព្រះបាទ ជយវម៌ទី៥ (cf, *SSIAC*, 40) ។ គេមិន អាចកែព្រះនាមនេះទៅជា *ឧទ័យទិត្តិយវ៉ារ៍ន* ឬ *ឧទ័យវ៉ារ៍ន* បែបនេះបានទេ ។ សម រចប *ឯកសារដដែល* ទំព័រ ២១១ ។

[17] តាមចារឹកមួយ ដែលរកឃើញនៅប្រាសាទអំពិល ភូមិពងទឹក ស្រុកថ្មពួក ខេត្តឧត្តរមានជ័យ ដោយបណ្ឌិត មីសែលត្រាណេ និងបានចុះលេខ Ka 17 បានអោយដឹងថា នៅមហាសករាជ ៩២៩ ថ្ងៃព្រហស្បតិ ៩រោជខែផល្គុណ ព្រះបាទ ជយវីរវម៌ ស្តេចគង់ប្រថាប់នៅព្រះស្រះស្រង់ ឯ ជយេន្ទ្រគីរី ពេលនោះមានមន្ត្រីម្នាក់នាម វិជយេស្វរវម៌ ថ្វាយលិខិតមួយដល់ព្រះអង្គ បន្ទាប់មក ទ្រង់ក៏បញ្ជាអោយ

- សូរ្យវម៌ ទី១[១៨] Sūryavarman I (គ.ស. ១០០២-១០៥០) ទោះបីពាក្យ *សូរ្យ* (ភាសាសំស្ក្រឹត) និង *សុរិយា* (ភាសាបាលី) មានន័យដូចគ្នា ក៏មិនត្រូវកែនាមដើមនេះ ទៅជា *សុរិយាវ៉ែន* តាមភាសាបាលីបែបនេះបានដែរ ។

- សូរ្យជយវម៌? ឬ ឥស្វយ៌្យជយវម៌ Śuryajayavarman/ Īśvaryya-jayavarman (គ.ស. ១០១២[១៩] -១០xx)

---

គេចារឹកលិខិតនោះទុក គឺសិលាចារឹកនោះឯង ។ ព្រះអង្គត្រូវជាប្អូនប្រុសព្រះ បាទ ឧទយាទិត្យវម៌ទី១ (cf, *Ibid*) ។

18 ច្បាប់ដើមគឺ *សូយ៌្យវម្ម៌* អាចសរសេរជា *សូរ្យវម្ម៌* បែបនេះបាន ។ ប៉ុន្តែ បណ្ឌិត រស់ ចន្ត្រាបុត្រ សរសេរថា *សុរិយាវ៉ែន* ទៅវិញ សម. រចប *ឯកសារដដែល* ទំព័រ ២១២, ២២០ ដែលការសរសេរបែបនេះមិនត្រឹមត្រូវទេ ។

19 សិលាចារឹកគោកក្ឍាង K 1128 (or Ka 59 listed by Michel Tranet) ខេត្តបុរីរម្យ ប្រទេសថៃ ដែលទើបរកឃើញនៅ ឆ្នាំ១៩៨៤ អោយដឹងថា នៅមហាសករាជ៩៣៤ គឺគ.ស. ១០១២ មានព្រះមហាក្សត្រមួយអង្គ នាម *សូយ៌្យជយវម្ម៌ទេវ* ប្រើអោយធ្លាក់?ធ្វើ.... ។ ក៏ប៉ុន្តែ បើតាមបណ្ឌិត ពៅ សាវរស អានព្រះនាមព្រះរាជាអង្គនេះថា *ឥស្វយ៌្យជយវម៌* ទៅវិញ ។ ម្យ៉ាងទៀត យើងមិនដឹងថា ព្រះអង្គឡើងសោយរាជ្យពីឆ្នាំណាដល់ឆ្នាំណានោះទេ ប៉ុន្តែ ប្រហែលជា ស្តេចអង្គនេះហើយ ជាដើមវង្សព្រះរាជានៅមហីធរបុរ ដែលអ្នកសោយរាជ្យជាបន្តបន្ទាប់មកមាន ជយវម៌ទី៦ ធរណីន្ទ្រវម៌ទី១ ជាដើម ។

ម្យ៉ាងទៀតប្រសិនបើ ព្រះបាទ ជយវីរវម៌ និងព្រះបាទសូរ្យវម៌ទី១ ជាព្រះរាជាតែមួយអង្គ ដូចដែលលោក សេដេស តែងតែចោទជាសំណួរ និងវិភាគនាពេលកន្លងមក (ពីព្រោះតែ នាមអគ្គមហេសីរបស់ស្តេចទាំងពីរអង្គនេះដូចគ្នា នាមមន្ត្រីជំនិតមួយចំនួនក៏ដូចគ្នា) នោះឈ្មោះ សូយ៌្យជយវម៌ ឬ ឥស្វយ៌្យជយវម៌ ក្រែងជានាមបញ្ចូលគ្នារវាងឈ្មោះទាំងពីរ ឬក៏ជាព្រះរាជាមួយអង្គផ្សេងទៀត? ។

- ឧទយាទិត្យវម៌ទី២ Udayādityavarman II (គ.ស. ១០៥០[២០] - ១០៦៦) បណ្ឌិត រស់ ចន្ទ្រាបុត្រ ថា *ឧទ័យវរ៌្មនទី២* ។
- ហសិវម៌ទី៣ Harṣavarman III (គ.ស. ១០៦៦-១០៨៥)
- នួបតិន្ទ្រវម៌[២១] Nṛpatindravarman (គ.ស. ១០៨៥-១១១៣)

គេមិនអាចសរសេរ ជា *នរិបតិន្ទ្រវរ៌្មន* បានទេ ។

- ជយវម៌ទី៦ Jayavarman VI (គ.ស. ១០៨០[២២] -១១០៧)
- ធរណិន្ទ្រវម៌ទី១ Dharaṇindravarman I (គ.ស. ១១០៧-១១១៣)

---

[20] សិលាចារឹកស្តុកកក់ធំ K 235D: 81 ថា ព្រះអង្គឡើងសោយរាជ្យនៅមហាសករាជ ៩៧១ (=គ.ស.១០៤៩) តាមចារឹក ប្រាសាទរលុះ ខេត្តបន្ទាយមានជ័យ ក៏បានអោយដឹងដែរថា ព្រះអង្គឡើងសោយរាជ្យនៅមហាសករាជ៩៧១ថ្ងៃ៨រោជខែផល្គុណ (cf, K 219: 1-2, in *C VII:* 45.) ប៉ុន្តែ សិលាចារឹកភ្នំសណ្តក K 194: 9-10 និយាយថា ព្រះអង្គឡើងសោយរាជ្យនៅមហាសករាជ ៩៧២ (=គ.ស.១០៥០) ឃើញពត៌មានបានពីសិលាចារឹកទាំងពីរ ខុសគ្នាមួយឆ្នាំ ។ បើតាមការកត់សម្គាល់របស់យើង ពត៌មានដែលបានពីសិលាចារឹកពីរខាងដើមត្រឹមត្រូវជាង ព្រោះអត្ថបទនោះយ៉ាងយឺតបំផុត គេចារឹកនៅឆ្នាំ១០៥២គ.ស. គឺ ៣ឆ្នាំបន្ទាប់ពីការឡើងសោយរាជ្យរបស់ព្រះអង្គ ។ ចំណែកពត៌មានទី៣ ដែលបានបង្ហាញ ត្រូវបានគេចារឹកយ៉ាងហោចណាស់ក៏ពាក់កណ្តាលទី ១ សតវត្សរ៍ទី១២ ឃើញថាក្រោយរាជ្យព្រះអង្គយ៉ាងយូរ ។ ដោយពិតនោះសិលាចារឹក ប្រាសាទរលុះអោយពត៌មានច្បាស់ជាងគេ ព្រោះបានកត់សំគាល់តាំងអំពីថ្ងៃ និងខែ ដែលព្រះអង្គ ឡើងសោយរាជ្យ ។ ដូច្នេះ យើងអាចគន់គូរដឹងថា ព្រះអង្គពិតជាឡើងសោយរាជ្យនៅ ដើមខែ មីនា ឆ្នាំ ១០៥០ ។

[21] អានថា ន ឬ ប៉ាក់ តិន ទ្រាក់ វ ភ្នាក់ មិនត្រូវសរសេរជា *នរិបតិន្ទ្រវរ៌្មន* នោះទេ ។ សម. រចប *ឯកសារដដែល* ទំព័រ ២១៧) ។

[22] សម. វង់ សុធារ៉ា *ឯកសារដដែល* ទំព័រ ៤៥ ។

- សូរ្យវរ្ម័ទី២ Sūryavarman II (គ.ស. ១១១៣-១១៥០)
- ហស៌វរ្ម័ទី៤ Harṣavarman IV (គ.ស. ១១៥០-១១៥១)[២៣]
- ធរណិន្ទ្រវរ្ម័ទី២ Dharaṇindravarman II (គ.ស.១១៥១-១១៦x)
- យសោវរ្ម័ទី២ Yaçovarman II = Yashovarman II (គ.ស. ១១៦x-១១៦៥)
- ត្រិភុវនាទិត្យវរ្ម័[២៤] Tribhuvanādityavarman (គ.ស. ១១៦៥ - ១១៧៧) មិនអាចសរសេរជា *ត្រីភុវ័នអាទិត្យវរ្ម័ន* បានទេ ។
- ជយវរ្ម័ទី៧ Jayavarman VII (គ.ស. ១១៨១-១២១៨)
- ឥន្ទ្រវរ្ម័ទី២ Indravarman II (គ.ស. ១២២០-១២៤៣)
- ជយវរ្ម័ទី៨ Jayavarman VIII (គ.ស. ១២៤៣[២៥] -១២៩៥)
- ស្រីន្ទ្រវរ្ម័[២៦] Çrīndravarman (គ.ស. ១២៩៥-១៣០៨)

មិនមែន *ឥន្ទ្រវ័រ្មនទីៗ* នោះទេ ព្រះនាមពេញរបស់ព្រះអង្គ យើងបង្ហាញរួច ហើយនៅទំព័រទី ១០ ។

---

[23] ព្រះអង្គត្រូវជាក្មួយព្រះបាទ សូរ្យវរ្ម័ទី២ (cf, *SSIAC:* 40.) ។

[24] អានថា ត្រិ ភុ វ៉ាក់ នៀ ទិត ត្យាក់ វ ភ្រាក់ cf, K 418: 3, in *APK I:* 177 និង សម. រចប *ឯកសារដដែល* ទំព័រ ២២៧ ។

[25] Cf, *SSIAC:* 41and K 569 op. cit.

[26] អានថា ស្រិន ទ្រាក់ វ ភ្រាក់ ។ មិនត្រូវសរសេរជា *ឥន្ទ្រវ័រ្មន* ឬ *ស្រីឥន្ទ្រវ័រ្មន* នោះទេ ។ សម. រចប *ឯកសារដដែល* ទំព័រ ២៤៤ ។

- ស្រីន្ទ្រជយវរ្ម័ន Çrindrajayavarman (គ.ស. ១៣០៨[២៧]-១៣២៧) នាមដើមរបស់ព្រះអង្គនៅក្នុងអត្ថបទភាសាខ្មែរ គឺ *ស្រីស្រីន្ទ្រជយពម្ទិករុណាបពិត្រ*[២៨] ។ ប៉ុន្តែ បើតាមអត្ថបទសំស្ក្រឹត នាមរបស់ព្រះអង្គគឺ ស្រីន្ទ្រជយវរ្ម័ន (រាជ្ញស្រីស្រីន្ទ្រជយវម្មិនះ)[២៩] ។

- ជយវរ្ម័នទី៩ Jayavarman IX (គ.ស. ១៣២៧-១៣៣x) នាមរបស់ព្រះអង្គនៅក្នុងសិលាចារឹក *តរាជ្យវ្រះបាទកម្រតេងអញ ស្រី ជយវម្ទិទេវបរមេគ្វរ*[៣០] និងនាមនៅក្នុងសិលាចារឹកភាសាសំស្ក្រឹតមួយទៀតគឺ ជយវម្មិបរមេស្វរ (ស្រីជយវម្មាទិ បរមេឝ្វរ)[៣១] ។

សម័យអង្គរ មិនមែនបញ្ចប់ត្រឹមរាជ្យព្រះបាទ ជយវរ្ម័នទី៩នេះទេ ដោយសារពត៌មានតាមរយៈសិលាចារឹក ស្ដីអំពីព្រះរាជាត្រូវដាច់ភាគត្រឹមនេះ គ្មានចារឹកសាស្ត្រណាមួយប្រកបដោយពត៌មានវលូនបន្តបន្ទាប់គ្នា ត្រូវបានគេចារ ឡើង ទើបអ្នកស្រាវជ្រាវបារាំង ងាកមកជ្រើសយកឯកសារពង្សាវតារនានា មកជាក់ភ្ជាប់រជ្ជកាលខាងលើ ដែលភាគច្រើននៃអ្នកប្រាជ្ញទាំងនោះ និយមដាក់ព្រះបាទពញាជ័យ ឬតាត្រសក់ផ្អែម ដែលជាព្រះរាជាចេញពីវណ្ណៈកសិករឡើង សោយរាជ្យបន្តវង្សស្តេចអង្គរ (---វម្មទេវ ឬ ---វម្មទេព) ។ បន្ទាប់មក វង្សត្រកូលស្តេច

---

[27] Cf, *SSIAC, op. cit.* ចំណែក លោក សឺដេស ថា រាជ្យព្រះអង្គចាប់ផ្តើមពីឆ្នាំ ១៣០៧ នៃ គ.ស. cf, *APK I:* 159 ។

[28] Cf, K 144:1 in *C VII:* 34.

[29] Cf, K 300B: 93, Abel Bergaigne, *Inscriptions Sanscrites du Cambodge,* 2e fascicule, p. 577, 583.

[30] Cf, K 470: 11 dated probably 1327 A.D in *C II:* 187.

[31] Cf, K 300B: 67, 101, *ibid.*

អង្គនេះ បានឡើងសោយរាជ្យជាបន្តបន្ទាប់ រហូតដល់សព្វថ្ងៃ ។

ចំណែករាជធានីមហានគរដ៏ស្កុកស្កម្ភ រហូតមកដល់រាជ្យព្រះបាទ *ពញា យ៉ាត* នាគ.ស.១៤៣២ ទើបព្រះអង្គចាកចោល ។ ព្រោះតែ ទទួលការគំរាមកំហែងផ្ទៃកសន្តិសុខពីរដ្ឋអយុធ្យារបស់សៀមញឹកញាប់ពេក និងហេតុផលខាងសេដ្ឋកិច្ច ហើយការបោះបង់នេះ ក៏ត្រូវធ្វើឡើងនៅក្រោយពីបានរំដោះចេញពីការត្រួតត្រារបស់សៀមក្នុងពេលថ្មីៗ ដែរ ។

ចំណែកព្រះរាជា ដែលបានសោយរាជ្យក្នុងអំឡុងពេល ១០០ឆ្នាំ ក្រោយពីរាជ្យព្រះបាទជយវម៌ទី៩ យើងក៏មិនបានដឹងច្បាស់ថា មានប៉ុន្មានអង្គនោះដែរ ពីព្រោះឯកសារទាំងនោះ គ្មានចំណុចរួមគ្នាជាច្រើនអន្លើ ។ អ្វីដែល ឯកភាពគ្នានោះចាប់ត្រឹមរាជ្យ ព្រះពញាយ៉ាត តែប៉ុណ្ណោះ ។

## ៤- សេចក្តីសន្និដ្ឋាន

នេះជាវិភាគទានដ៏តិចតួច សម្រាប់ជួយបំភ្លឺផ្លូវដល់អស់លោក អ្នកដែលមានចំណេះដឹងខ្លះក្នុងការអានសិលាចារឹកបុរាណរបស់កម្ពុជា ដើម្បីកត់សម្គាល់ជាពិសេស ទៅលើនាមព្រះរាជា ដែលជាតួអង្គសំខាន់នៃប្រវត្តិសាស្ត្រ និងជាគោលនៃកាលបរិច្ឆេទផងដែរ ។ ត្បិតបើចេះត្រឹមតែអាន ហើយមិនដឹងអំពីឋានន្តរនាម ឬគោរម្យងាររបស់ព្រះរាជា ថាដូចម្តេចនោះទេ វាមិនទាន់មានប្រយោជន៍អាចទាញយកផលខាងប្រវត្តិសាស្ត្របានគ្រប់គ្រាន់ឡើយ ។ វាទាល់តែ លោក អ្នក អាចស្គាល់

យ៉ាងហោចណាស់ មនុស្សសំខាន់ៗនៅក្នុងចារឹកនោះ[៣២] ដូចជា មន្ត្រី ព្រះរាជា សម្តេចសង្ឃខាងព្រហ្មញ្ញ ឬ ពុទ្ធសាសនា ឬ ព្រះអាទិទេព ។

ការស្គាល់បែបនោះ វាក៏នឹងនាំទៅឃើញឈ្មោះពិតប្រាកដរបស់បុគ្គលម្នាក់ៗ និយាយដោយឡែក វានាំអោយស្គាល់ព្រះរាជា ថាតើគេសរសេរនាមរបស់ព្រះអង្គដោយអក្ខរាវិរុទ្ធបែបណា ។

ការស្រាវជ្រាវវិទ្យាសាស្ត្រផ្នែកអ្វីក៏ដោយ រមែងទាមទារសុក្រឹតភាព ជាក់លាក់ ត្រឹមត្រូវ ហេតុនេះនាមរបស់ព្រះមហាក្សត្រ មិនគប្បីអ្នកស្រាវជ្រាវសរសេរផ្លាស់ប្តូរតម្រូវតាមសំនៀងអាន ឬ មួយសរសេរព្រាវៗតាម transliteration ឬឯកសារបរទេសនោះទេ ។ បើយើងត្រូតពិនិត្យលើឯកសារ ដើមឃើញថា ខ្មែរបុរាណ ក៏មិនបានចារឹកនាមរបស់ព្រះរាជាដោយអក្ខរាវិរុទ្ធខុសៗពីគ្នាដែរ ។ ក្នុងករណីស្មេរសម័យថ្មីបារម្ភ ឬ ខ្លាចអ្នកអាន ៗមិនត្រូវ នោះគួរតែ ធ្វើសញ្ញាសម្គាល់ដើម្បីបញ្ជូនអ្នកអានអោយទៅមើលរបៀបអាននៅកន្លែងបន្ទាប់ ឬ នៅជើងទំព័រ ឬកន្លែងណា មួយផ្សេងទៀត តាមតែលទ្ធភាពស្មេរ ។

ម្យ៉ាងទៀត បើនាមដើមសរសេរជាភាសាសំស្ក្រឹត ទោះបីស្មេរយកពាក្យភាសាបាលី ដែលមានន័យដូចគ្នាមកជំនួស ក៏មិនត្រឹមត្រូវដែរ ។

ចំពោះ ពាក្យ "*--វម៌* "នេះ គប្បីជនជាតិខ្មែរទម្លាប់ប្រើឡើងវិញដើម្បីជំនួសពាក្យ "*--វ័ន*" ប្រសិនបើខ្មែរ ចង់លើកតំកើងខ្លួន ជាអ្នកគោរព

---

[32] បើចង់ដឹងពតិមានច្រើនថែមទៀត អំពីឋានន្តរនាម និងស្ថាប័នរដ្ឋបាលនៅសម័យនោះ cf, Sachchidanand Sahai, *Les Institutions Politiques et L'Organisation Administrative du Cambodge Ancien* (VI^e-XIII^e siècles), Paris 1970 et សូមមើល. ឡុង សៀម *"ឋានន្តរនាមសម័យអង្គរ"* ក្នុង *ទស្សនាវដ្តីកម្ពុជសុរិយា* លេខ ១ ឆ្នាំ ១៩៩៧ ទំព័រ ៤១-៦១ ។

និងអោយតម្លៃលើកេរស្នាដៃនៃបុព្វបុរស ។ រីឯពាក្យ "ទេវ" ដែលមានប្រើនៅសម័យអង្គរ មិនគួរយកមកដាក់នោះទេ ។ ប្រសិនបើដាក់ វានឹងនាំអោយមានការរុះរើរបាក្យត្រទាំងអស់ ដែលគេបានដាក់លេខរៀងរួចហើយនោះ និងធ្វើឱ្យប្រវត្តិសាស្ត្រជាតិខ្មែរ កាន់តែស្មុគស្មាញថែមទៀត ។ ការនេះ លោកអ្នកប្រាជ្ញបារាំងធំៗ ធ្លាប់ជួបប្រទះម្តងហើយ នៅពេលគេរកឃើញនាមព្រះរាជា*ជយវម៌្ម* ដែលសោយរាជ្យនៅពាក់កណ្តាលទី២សតវត្សទី៨នៃគ.ស. ។

ដូច្នេះ នាមព្រះមហាក្សត្រទាំងឡាយ និងរជ្ជកាលរបស់ព្រះអង្គ ដែលបានរាយជូនខាងលើ អាចចាត់ទុកជាឯកសារគោលសម្រាប់វិសោធនកម្ម របស់ក្រុមការងារជំនាញនៃរាជបណ្ឌិតសភា ក្នុងការសម្រេចធ្វើឯកភាវូបនីយកម្ម ខាងបច្ចេកពាក្យ និងស័ព្ទប្រវត្តិវិទ្យានៅថ្ងៃអនាគត ។

## អក្សរកាត់ដែលប្រើក្នុងអត្ថបទ

- APK I Articles sur le pays Khmer, tome I (I-II)
- C I Inscriptions du Cambodge, volume I (I-VIII)
- inscrip. Inscription
- Sdok Kak Thom Sdok Kak Thom Inscription, part I-II
- SSIAC Studies in Sanskrit Inscriptions of Ancient Cambodia, by Mahesh Kumar Sharan

រចប ប្រវត្តិសាស្ត្រខ្មែរ: រស់ ចន្ត្រាបុត្រ *ប្រវត្តិសាស្ត្រខ្មែរ ភាគទី១ (ភាគរឿងព្រេងនិទាន និងតាមរយៈសិលាចារឹក)*

## ឯកសារពិគ្រោះជម្រើស


1- Barth, Auguste
1885 *Inscriptions Sanscrites du Cambodge,* t. 27e (1re fascicule), Paris, 180ps.

2- Bergaigne, Abel
1893 *Inscriptions Sanscrites de Campâ et du Cambodge,* t. 27e (2e fascicule),
Paris, pp. 181-629.

3- Chakravarti, Adhir
1980 *THE SDOK KAK THOM INSCRIPTION,* part II, Calcutta.

4- Cœdès, Georges
1937-66.1 *Inscriptions du Cambodge,* Vol. 1-8 (8 volumes), Paris.
1989-92 *Articles sur le Pays Khmer,* tome I-II (2 volumes), éditée par Claude
Jacques, Paris.

5- Institut National de France,
1885-92 –1 *Inscriptions Sanscrites du Cambodge,* (1re Partie) 1re fascicule, Paris.
-2 *Inscriptions Sanscrites de Campâ et du Cambodge,* (1re Partie) 2e fascicule, Paris. (Rubbing image books)

6- Jacques, Claude
1971-92 *Supplément au Tome VIII des Inscriptions du Cambodge,* dans *BEFEO, t. LVIII,* Paris, pp. 177-95.

7- KAMALESWAR Bhattacharya
1991 *Recherches sur le Vocabulaire des Inscriptions Sanskrites du Cambodge,* Paris.

8- Khin, Sok

1977-92 *Deux inscriptions Tardives du Phnom Bâkhêng K 465 et K 285,* dans *BEFEO t. LXV,* Paris, pp.271-80.
1980-92 *L'inscription de Vatta Romlok K 27 et L'inscription de Prah Thom du Kulên K 715,* dans *BEFEO t. LXVII,* Paris, pp.125-34.

9- Finot, Louis, sous les auspice d'Académie des Inscriptions et Belles-Lettres,

1926-31 *Inscriptions du Cambodge*, tome 1-5 (5 volumes), Paris. (Rubbings)

10- Mak, Phoeun

1995 *Histoire du Cambodge de la fin du XVI^e siècle au début du XVIII^e*, Paris, EFEO.

11- Mahaḅidûr, Krassem

1958, 84 *Inscriptions Modernes d'Angkor*, 2nd edition-1958, the Buddhist Institute; 3rd edition, Cedoreck, Paris, 206 pages. (en Khmer)

12- Mahesh Kumar Sharan

1974 *Studies in Sanskrit Inscriptions of Ancient CAMBODIA*, New Delhi.

13- Monier, Monier Williams

1995 *A Sanskrit-English Dictionary*, New Delhi.

14- POU, Saveros

1971 *Recherches sur le Vocabulaire Cambodgien (VII), les doublets d'origine indienne*, dans *Journal Asiatique*, année 1971, pp. 103-38.

1989 *Nouvelles des Inscriptions du Cambodge I*, Paris.

1992 *Dictionnaire Vieux Khmer-Français-Anglais*, Cedoreck, Paris.

1996 *Nouvelles des Inscriptions du Cambodge II*, Paris.

1998 *What is Khmerology?* (Address delivered at the Buddhist Institute and the Ministry of Cults and Religions, Phnom Penh, 1998) through *Kampuja Suriya Review*, Phnom Penh 53rd year, N° 1, 1999, pp. 27-43, and N° 2, pp. 36 -45.

15- R.C. Majumdar

1944 KAMBUJA-DESA or An Ancient Hindu Colony in CAMBODIA, University of Madras.

16- SAHAI, Sachchidanand

1970 Les Institutions Politiques et L'Organisation Administrative du Cambodge Ancien (VI^e-XIII^e siècles), Paris EFEO, vol. LXXV.

17- Vickery Michael

1998 Society, Economics, and Politics in Pre-Angkor CAMBODIA, Tokyo Bunko, Japan.

១៨- ត្រឹង ងា

១៩៧៣ *ប្រវត្តិសាស្ត្រខ្មែរ* ភាគ១ ភ្នំពេញ

១៩៧៤ *ប្រវត្តិសាស្ត្រខ្មែរ* ភាគ២ ភ្នំពេញ

១៩- មីសែល ត្រាណេ

១៩៩៨ *ប្រវត្តិសាស្ត្រកម្ពុជា. អាណាចក្រចេនឡា (ស.វ. ទី៦ ដល់ ទី៨)* ភ្នំពេញ រស់ ចន្ទ្រាបុត្រ

១៩៩៨ *ប្រវត្តិសាស្ត្រខ្មែរ ភាគទី១ (ភាគរឿងព្រេងនិទាន និង តាមរយៈសិលាចារឹក)* ឡាម៉ាត់តង់. ប៉ារី ។

២០- លី គីមឡុង

២១- ១៩៧២ " អ្វីជាកម្លាំងនៃសាមគ្គីខ្មែរសម័យអង្គរ " ក្នុង *ទស្សនាវដ្ដីអក្សរសាស្ត្រ-មនុស្សសាស្ត្រ* ឆ្នាំទី២ លេខ៣ ភ្នំពេញ ទំព័រ ៤៨-៥៥ ។

២២- សូរ អឿ

១៩៩៧ *ប្រវត្តិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា ជាមួយអណ្ណាម និង សៀម ចាប់ពីសតវត្សទី១៦* ភ្នំពេញ ។

២៣- ហ្សុក សឺដេស

*ដើម្បីយល់កាន់តែច្បាស់អំពីអង្គរ* បកប្រែជាភាសាខ្មែរដោយ ម៉ុញ សារី ភ្នំពេញ ១៩៩៩ ។

២៤- សាកលវិទ្យាល័យភូមិន្ទភ្នំពេញ. *ទស្សនាវដ្ដីអក្សរសាស្ត្រ-មនុស្សសាស្ត្រ* លេខពិសេស ខែធ្នូ ១៩៩៨ ទំព័រ ៣៩-៤៨ ។

២៥- ពុទ្ធសាសនបណ្ឌិត្យ *ទស្សនាវដ្ដីកម្ពុជសុរិយា* ភ្នំពេញ លេខ១ ឆ្នាំ១៩៩៧ និង លេខ១-២ ឆ្នាំ១៩៩៩ ។

# រាពណ៍ (ក្រុងរាពណ៍)

ដោយ : ឆន់ ហ៊ិន

ស្ដេចរបស់ពួកខ្មោចបិសាច ពួកព្រាយអសុរកាយ ឬពួកយក្សនៅនគរលង្កា (កោះស្រីលង្កា) ដែលបានបណ្ដេញបងប្អូនរួមឪពុករបស់ខ្លួន គឺព្រះកុវេរៈ(មាតាឈ្មោះឥទាវិទា) ចេញពីនគរលង្កា ។ ក្រុងរាពណ៍ជាបុត្ររបស់ព្រះវិស្រវៈ ជាមួយនាងនិកស្សា បុត្រីរបស់រក្សាសៈ មួយរូបឈ្មោះសុមាលី ។ ក្រុងរាពណ៍ និងព្រះកុវេរៈត្រូវជាចៅរបស់ឫសីបុលច្ឆា បានទទួលការចែកអំណាចគ្នាគ្រប់គ្រង គឺក្រុងរាពណ៍ធ្វើជាស្ដេចពួកខ្មោច ព្រាយបិសាច ដែលហៅថាពួក រក្សាសៈ (ឬរាក្ស័ស) ហើយព្រះកុវេរៈធ្វើជាស្ដេចនៃពួកយក្ស ។ ឫសីបុលច្ឆាមិនមែនគ្រាន់តែជាបុព្វជាបិតារបស់ក្រុងរាពណ៍ប៉ុណ្ណោះទេ ប៉ុន្តែព្រះអង្គក៏ជាអ្នកបង្កើតឱ្យមានពូជពង្សនៃ ពួកខ្មោច, ព្រាយ, បិសាច, អសុរកាយ, អារក្សទឹក, ម្រេញ គង្វាល ។ល។ ផងដែរ ។ តាមការកាន់វត្តប្រតិបត្តិដ៏តឹងរ៉ឹង និងការប្ដេជ្ញាខ្លួនថ្វាយចំពោះព្រះព្រហ្ម ក្រុងរាពណ៍ក៏បានទទួលពរពីព្រះព្រហ្មថា ឱ្យវាមានឫទ្ធិចេស្ដាលើពួកទេពតា និងខ្មោច ព្រាយ បិសាចនានា ប៉ុន្តែ ថា ឱ្យវាស្លាប់ដោយសារស្រីម្នាក់ ។ តាមអានុភាពនៃពរនេះ ក្រុងរាពណ៍អាចប្រែកាឡាខ្លួនទៅជារូបរាងអ្វីក៏បានតាមតែចិត្តវាចង់ ហើយអាចប្រព្រឹត្តនូវរាល់អំពើអាក្រក់សព្វបែបយ៉ាងក្នុងកម្រិតដ៏ខ្ពស់ហួស គឺលើសពីអ្វីដែលពួកយក្ស និងពួកព្រាយបិសាច

ឯទៀតៗអាចធ្វើបាន ។ ក្នុងរឿងរាមាយណៈ មានការពណ៌នាថា ក្រុងរាពណ៍មានក្បាលដប់ មានដៃម្ភៃ មានភ្នែកសម្បុរដូចស្ពាន់ មានធ្មេញភ្លឺដូចជាព្រះចន្ទក្នុងដើមខ្នើត មានរូបដូចជាដុំពពកមួយដុំដ៏ក្រាស់ឃ្មឹក ឬដូចជាភ្នំមួយ ឬដូចជាយមរាជ ដែលកំពុងហាមាត់ប្រុងចាំត្របាក់។ វាមានលក្ខណសម្បត្តិជាស្ដេចគ្រប់គ្រាន់ទាំងអស់ ប៉ុន្តែនៅលើខ្លួនប្រាណរបស់វាមានស្នាកស្នាមជាច្រើន ។ ស្នាកស្នាមទាំងនោះ ជាការបញ្ជាក់ពីការរងរបួស ដែលវាបានទទួលនៅក្នុងការធ្វើសង្គ្រាមជាមួយពួកទេវតា។ មានស្នាមនៅលើខ្លួនវាខ្លះទៀត ដោយមកពីខ្លួនវាត្រូវនឹងកាំរន្ទះរបស់ព្រះឥន្ទ្រា ត្រូវនឹងភ្លុកដំរីរបស់ព្រះឥន្ទ្រាឈ្មោះឰរាវ័ត ត្រូវនឹងចាសជាអាវុធរបស់ព្រះវិស្ណុ ។ វាមានកម្លាំងរហូត ដល់អាចធ្វើឱ្យរញ្ជួយទឹកសមុទ្រ ឬក៏ញែកកំពូលភ្នំឱ្យបែកចេញពីគ្នាបាន ។ វាជាអ្នកបំពានច្បាប់នានា និងពូកែខាងចាប់រំលោភភរិយារបស់មនុស្សម្នាផង ។ ដោយហេតុតែខ្លួនវាធំ ហើយខ្ពស់ដូចភ្នំ បើវាទៅទីណាម្ដងៗ វាតែងធ្វើឱ្យគេខ្លាចនៅទីនោះ សូម្បីតែព្រះអាទិត្យក៏មិនហ៊ានជះកម្ដៅទៅលើវា ព្រះវាយោក៏មិនហ៊ានបក់បោក ព្រះសាគរក៏មិនហ៊ានឱ្យទឹករលកដែរ ។ អំពើអាក្រក់របស់វាញ៉ាំងឱ្យមានសម្រែកសងសឹកយ៉ាងខ្លាំងៗ ដែលបន្លឺឡើងពូរហូតទៅដល់ឋានសួគ៌ា។ ព្រះវិស្ណុក៏ប្រកាសថា ក្រុងរាពណ៍កាន់ឬកក្រអឺតក្រទមហួសពេកណាស់ នឹងសុំឱ្យវាជួយរក្សាមនុស្សសត្វផងក៏មិនបាន គួរតែឱ្យវាស្លាប់ក្នុងកណ្ដាប់ដៃនៃសត្វលោកទាំងអស់នោះ ទៅវិញចុះ ។ ហេតុដូច្នេះហើយ ព្រះវិស្ណុក៏យោនយកកំណើតមកកើតជាព្រះរាមចន្ទ្រក្នុងគោលបំណងដ៏បន្ទាន់បំផុតមួយ គឺកម្ទេចក្រុងរាពណ៍ ។ ដើម្បីឱ្យបានសម្រេចនូវគោលបំណងនេះ ទ័ពស្វា និងទ័ពខ្លាឃ្មុំ

ជាច្រើន ក៏ត្រូវព្រះអង្គបង្កើតឱ្យមានឡើងផងដែរ ។ សង្គ្រាមរវាងព្រះរាម និងក្រុងរាពណ៍ត្រូវផ្ទុះឡើង ដោយសារក្រុងរាពណ៍ត្រូវមោហ៍ចាំង គឺងុបងុលតែជាមួយនឹងតណ្ហាក្រាស់របស់វា។ វាកើតចិត្តប្រតិព័ទ្ធទៅលើព្រះនាងសីតាយ៉ាងខ្លាំង រហូតដល់ទ្រាំលែងបាន វាក៏ចេញចាកពីក្រុងលង្កាយាត្រាសំដៅទៅកាន់អាស្រមរបស់ព្រះរាម តាមការក្លែងខ្លួនធ្វើជាអ្នកបួសដើរបិណ្ឌបាត ។ ក្នុងខណៈដែលព្រះរាមចេញទៅដេញចាប់ប្រើសមាស ក្លែងដោយប្អូនជីដូនមួយរបស់វាឈ្មោះ *មារីចៈ* វាក៏ទៅលួចចាប់បង្ខំយកព្រះនាងសីតាទៅកាន់ក្រុងលង្កាបាត់ទៅ ។ ក្រុងរាពណ៍បង្ខំឱ្យព្រះនាងសីតាព្រមធ្វើជាឯកអគ្គមហេសីរបស់វាទាំងគំរាមថា នឹងសម្លាប់ ឬស៊ីព្រះនាងល្គឹកណាព្រះនាងមិនយល់ព្រមបំពេញបំណងរបស់វាទេ ។ ប៉ុន្តែ ព្រះនាងសីតាប្រកែកជារៀងរាល់លើក ហើយលើកណាក៏ព្រះនាងចេះតែមានវាសនានឹងចៀសផុតពីសេចក្ដីស្លាប់ ឬការរំលោភពីក្រុងរាពណ៍ដែរ ដោយសារតែមានការបន្ទចបង្អាក់ពីភរិយាម្នាក់របស់ក្រុងរាពណ៍ ។ ហនុមានជាអ្នករកព្រះនាងសីតាឃើញនៅឯកោះលង្កា ។ បន្ទាប់ពីព្រះរាមបានទទួលដំណឹងយ៉ាងច្បាស់ពីហនុមានមក ព្រះអង្គក៏ប្រកាសទៅសម្ពន្ធមិត្តរបស់ព្រះអង្គ គឺសុគ្រីព និងហនុមាន ដែលមានទ័ពរបស់គេជាស្វា និងជាខ្លាឃ្មុំ ឱ្យជួយព្រះអង្គ ។ ពួកគេនាំគ្នាសង់ស្ពានមួយធ្វើពីដុំថ្មបណ្ដែតទឹក ដែលពួកគេនាំគ្នាហៅថាស្ពានព្រះរាម (សព្វថ្ងៃស្ពាននេះបានប្រែឈ្មោះថា *ស្ពានអាដាំ*) រួចទើបគេនាំគ្នាលើកទ័ពជាក្បួន ដើរឆ្លងស្ពាននោះទៅកាន់ក្រុងលង្កា ។

មុននឹងសង្គ្រាមផ្ទុះឡើងរវាងក្រុងរាពណ៍ និងព្រះរាមនុំះ ក្រុងរាពណ៍មានទំនាស់មួយយ៉ាងខ្លាំងជាមួយវិភេសន៍ ជាប្អូនបង្កើតរបស់ខ្លួន ។

វិភេសន៍បានផ្ដល់យោបល់ជំទាស់យ៉ាងដាច់អហំការថា មិនត្រូវធ្វើសង្គ្រាមប្រឆាំងនឹងព្រះរាមទេ ព្រោះវិភេសន៍បានប្រមើលមើលឃើញបរាជ័យមកខាងក្រុងរាពណ៍រួចជាស្រេច ហើយតាមបរាជ័យនេះ ក្រុងលង្កាទាំងមូលនឹងត្រូវទទួលរងនូវសេចក្ដីវិនាសខ្ទេចខ្ទីអស់ ហើយអស់រហូតដល់ពូជពង្សយក្សទៀតផង ។ ការលើកយោបល់ជំទាស់ផ្ទួនៗរបស់វិភេសន៍ និងការអះអាងដដែលៗថា ព្រះរាមនឹងទទួលជ័យជម្នះជាដាច់ខាត ដោយវិភេសន៍យោងលើជ័យជម្នះដ៏ធំធេងលើទ័ពយក្សកន្លងមក ធ្វើឱ្យក្រុងរាពណ៍យល់ថា ប្អូនរបស់ខ្លួនកើតចិត្តក្បត់ ចង់ដណ្ដើមយករាជបល្ល័ង្កពីខ្លួន ទើបបានជានិយាយកាន់ជើងសត្រូវ ។ ក្រុងរាពណ៍ខឹងវិភេសន៍យ៉ាងខ្លាំង ទាំងជេរប្រទេចវិភេសន៍ ដោយប្រើពាក្យសម្ដីដ៏សែនធ្ងន់ៗ ។ ការជៀលត្មះ និងការជេរប្រមាថកាតទាននេះ នាំឱ្យវិភេសន៍ទ្រាំលែងបាន ក៏ប្រើសម្ដីទ្រគោះខ្លះៗតបទៅលើក្រុងរាពណ៍វិញ ទាំងបញ្ចប់សេចក្ដីថា ខ្លួនវានឹងក្រុងរាពណ៍ ត្រូវតែចែកផ្លូវគ្នា ។ ដោយហេតុតែវិភេសន៍ដឹងខ្លួនថា ពីពេលនេះទៅ វាគ្មានអ្វីជាទីពឹងទៀតទេ ហើយក៏លែងអាចរស់នៅក្នុងនគររបស់ខ្លួនបានទៀតផង វិភេសន៍ក៏ហោះទៅសុំចុះចូលជាមួយព្រះរាមទៅ ដោយមានសេនាស្មោះត្រង់ចំនួនបួនរូបដង្ហែតាមទៅផង ។

ព្រះរាម និងក្រុងរាពណ៍បើកការប្រយុទ្ធគ្នាយ៉ាងយូរ និងយ៉ាងរបើងរីងរូសដូចគ្នា ពុំមានខាងណាមានប្រៀបជាងខាងណាឡើយ គឺម្ដងខាងព្រះរាមទន់ដៃជាង ម្ដងខាងក្រុងរាពណ៍ទន់ដៃជាង ។ ព្រះរាមបានបញ្ជូនសរដ៏មុតៗ ដូចគ្រាប់ភ្លៀងទៅត្រូវដាច់ក្បាលក្រុងរាពណ៍ធ្លាក់ដល់ដី ប៉ុន្តែក្បាលវាដាច់ពេលណា ក្បាលថ្មីក៏ដុះឡើងវិញភ្លាមដែរ ។ នៅទីបំផុត

ព្រះរាមប្រើសររបស់ព្រះព្រហ្ម បាញ់ចេញទៅទម្លុះដើមទ្រូងធ្លាយនៅខាងខ្នងរបស់ក្រុងរាពណ៍ រួចហោះទៅដល់មហាសមុទ្រ ហើយបត់ត្រឡប់មកយ៉ាងស្អាត ចូលក្នុងបំពង់ព្រួញរបស់ព្រះរាមវិញ ។ របួសដ៏ធ្ងន់ធ្ងរនេះបណ្ដាលឱ្យក្រុងរាពណ៍ដួលផ្ងារជង្គ្រាងនៅលើព្រះធរណី ក្ស័យជីវិតក្នុងពេលនោះទៅ ។ នាងមន្ទោទរីក៏ទៅឱបសពស្វាមីទួញយំជាយោបំ គួរឱ្យអាសូរពន់ពេក ។ ប៉ុន្តែ ក្នុងពេលជាមួយគ្នា នៅនាឋានសួគ៌ានោះ ពួកទេវតាផងទាំងឡាយនាំគ្នាប្រគំតូរ្យតន្ត្រី ដើម្បីសម្ដែងសេចក្ដីរីករាយរបស់ខ្លួន ខ្លះទៀតប្រមូលគ្នាបាចផ្កា ជានិមិត្តរូបនៃសព្ទសាធុការពរ ថ្វាយព្រះរាម ហើយសម្ដែងពាក្យពោលសរសើរថា ព្រះរាមគឺជាព្រះវិស្ណុ ដោយហេតុថា បើព្រះរាមមិនបានសម្លាប់ក្រុងរាពណ៍ទេ ពួកទេពនិករអមរមេឃទាំងអស់គ្នា នឹងត្រូវទទួលរងនូវក្ដីវិនាសជាមិនខានឡើយ ។

ថ្វីបើក្រុងរាពណ៍ជាស្ដេចរបស់ពួកយក្ស. អារុក្ស. អារក្ស និងព្រាយបិសាចអសុរកាយក៏ដោយ ក៏វាជាប់ពូជពង្សជាព្រាហ្មណ៍ដែរ បើគិតទៅតាមបិតារបស់វា ។ វាចេះភាសាសំស្ក្រឹតយ៉ាងពូកែ តែងតែប្រារព្ធពិធីសាសនាតាមគម្ពីរវេទ ។ ហេតុដូច្នេះហើយ ទើបបានជាសពរបស់វាត្រូវបានគេយកទៅបូជា ដូចជាពួកព្រាហ្មណ៍ដែរ ។

មានរឿងមួយទៀតតំណាលថា មានកាលមួយនោះ ក្រុងរាពណ៍បានចាប់យកទេវតាខ្លះមកតម្រូវឱ្យធ្វើការតាមមុខនាទីរបស់ខ្លួន នៅក្នុងវាំងរបស់វា ដូចជាតម្រូវឱ្យព្រះអគ្គីធ្វើជាចុងភៅ ព្រះវរុណជាអ្នកផ្ដល់ទឹក ព្រះកុវេរៈជាអ្នកផ្ដល់លុយ ព្រះវាយុជាអ្នកបោសសម្អាតផ្ទះជាដើម ។ មានរឿងមួយនិទានថា ក្រុងរាពណ៍បានផឹកស្រា ហើយដោយកើតចិត្តជោរជា

មួយនឹងជោគជ័យរបស់ខ្លួន វាក៏ធ្វើដំណើរកម្សាន្តលេង ។ លុះទៅដល់ធានី *មហិស្មតី* របស់ព្រះបាទ *កត្តវិរិយៈ* ដែលមានព្រះហស្តមួយពាន់ ក្រុងរាពណ៍ក៏ត្រូវក្សត្រិយ៍អង្គនេះចាប់បង្ខាំងទុកជាឈ្លើយ បីដូចសត្វធាតុនៅក្បែរបុរីនោះទៅ ។

ឯកអគ្គមហេសីរបស់ក្រុងរាពណ៍ គឺនាង*មន្ទោទរី* ។ មានភរិយាជាច្រើននាក់ទៀត ដែលត្រូវចូលទៅក្នុងភ្នក់ភ្លើងបូជាសពក្រុងរាពណ៍ ដើម្បីស្លាប់រួមជាមួយគ្នានឹងស្វាមីរបស់ខ្លួន ។ បុត្ររបស់ក្រុងរាពណ៍ឈ្មោះ ឥន្ទ្រជិត (ដែលមានឈ្មោះមួយទៀតថា មេឃនាទ), រាពណិ, អ័ក្ស, ត្រីសិរ, ទេវាន្តកៈ, នរាន្តកៈ និង អតិកាយ ។ មានប្រភពខ្លះទៀតអះអាងថា ក្រុងរាពណ៍មានប្រពន្ធជាច្រើនរាប់មិនអស់ កូនក៏មានច្រើនរាប់មិនអស់ដែរ ។ ដោយហេតុ តែវាមានក្បាលដល់ទៅដប់ ទើបក្រុងរាពណ៍មានឈ្មោះផ្សេងៗ ទៀតថា ទសកណ្ឋ (កដប់), ទសមុខ (មុខដប់) ។

មានរឿងមួយទៀតតំណាលថា មានម្តងនោះ ក្រុងរាពណ៍ចេញទៅធ្វើចម្បាំងតតាំងនឹងពួកទេវតា ដោយមានបុត្ររបស់ខ្លួន ឈ្មោះមេឃនាទទៅជាមួយផង ។ នៅក្នុងសង្គ្រាមនោះ មេឃនាទ ដែលចេះវិជ្ជាបំបាំងខ្លួនបានលបលួចទៅចាប់ព្រះឥន្ទ្រាបាន ដោយចងស្លាបសេក ព្រះឥន្ទ្រា រួចនាំយកទៅបង្ខាំងទុកនៅឯកោះលង្កា ។ ពួកទេពវតាបានទៅអង្វរសុំឱ្យព្រះព្រហ្មជួយអន្តរាគមន៍សុំយកព្រះឥន្ទ្រាមកវិញ ។ មេឃនាទយល់ព្រមដោយដាក់លក្ខខណ្ឌសុំឱ្យព្រះព្រហ្មឱ្យពរដល់ខ្លួនវា ដើម្បីឱ្យខ្លួនវាបានជីវិតអមតៈ ប៉ុន្តែ ព្រះព្រហ្មមិនព្រមតាមសំណូមពរនេះទេ គឺព្រមត្រឹមតែប្រទានឈ្មោះឱ្យវាថា "ឥន្ទ្រជិត" ដែលមានន័យថា ជាអ្នកឈ្នះព្រះឥន្ទ្រ

ប៉ុណ្ណោះ ។ មេឃនាទនៅតែមិនព្រម គឺវាទទូចសុំរហូតដល់បានសម្រេចតាមបំណងរបស់វា ។

---

*សត្វដែលនឹងបានរួចចាកទុក្ខ*
*ព្រោះធុញទ្រាន់ផ្លូវមុខ នឹងកើតស្លាប់*
*មានគំនិតដូចសត្វ ទទាជាប់*
*ក្នុងទ្រុងមិនគាប់ ក្តីប្រាថ្នា ។*
*ចេះតែស្ទុះច្រាសច្រាល ដាលចឹកទ្រុង*
*ចង់ឱ្យរលុង នឹងម្ជីម្ជា*
*ស្ទុះចេញឱ្យរួច ហើយនឹងលា*
*ត្រដាងស្លាបវា ហើយហើរទៅ ។*

សម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយក
គណៈមហានិកាយ **ជួន ណាត** ជោតញ្ញាណោ

# ឱសថបុរាណខ្មែរ

(ត)

ដោយ : សួន ឱសថ

## ៤ . ជំពូកស្មៅ

ជាប្រភេទរុក្ខជាតិដុះគ្រប់ទីកន្លែង គ្រប់តំបន់នៅក្នុងប្រទេសកម្ពុជា ដូចជា :

| | | |
|---|---|---|
| - ស្មៅអាចម៍កុក | - ស្មៅក្រវ៉ាញជ្រូក | - ស្មៅជញ្ជៀន |
| - ស្មៅសំបុកមាន់ | - ស្មៅជើងក្រាស់ | - ស្មៅកេរលក |
| - ស្មៅស្រកានាគ | - ស្មៅគង្រ្គាល | - ស្មៅយ៉ាផ្លង |
| - ស្មៅដំណេកទន្សាយ | - ស្មៅតុកកែ | - ស្មៅជញ្ជៀនទឹក |
| - ស្មៅចេក | - ស្មៅបារាំង | - ស្មៅអណ្តាតពស់ |
| - ស្មៅបាក់សង្រែក | - ស្មៅប្រមាត់ដី | - ស្មៅស្លឹកឬស្សី |
| - ស្មៅត្រចៀកក្រាញ់ | - ស្មៅប្រខ្លប( ញី) | - ស្មៅប្រខ្លប( ឈ្មោល ) |
| - ស្មៅក្បាលពស់វែក | - ស្មៅកន្ទុយចចក | - ស្មៅស្លាបទា ( ស) |
| - ស្មៅស្លាបទា( ស្វាយ) | - ស្មៅជន្ទល់ភ្នំ | - ស្មៅទឹកដោះខ្លា |
| - ស្មៅផ្ចិត | - ស្មៅក្របី | - ស្មៅប្រមាត់ថ្លាន់ |
| - ស្មៅកក់ | - ស្មៅក្រចាប់ | - ស្មៅស្រូវ |

## ៥ .ជំពូកបន្លែ

បន្លែជារុក្ខជាតិដែលត្រូវបានយកមកផ្សំជាថ្នាំបានដែរ មុខបន្លែភាគខ្លះដុះឯង និងភាគខ្លះទៀត ត្រូវមានការដាំដុះ ( កសិកម្ម) ដូចជា :

| | | |
|---|---|---|
| - ស្ពៃខៀវ | - ខាត់ណា | - សណ្ដែកគួ |
| - ស្ពៃជើងទា | - ខាត់ណាផ្កា(ស) | - សណ្ដែកបារាំង |
| - ស្ពៃក្រញ៉ាញ់ | - ខាត់ណាផ្កា(ស្វាយ) | - សណ្ដែកហោឡាំងតាវ |
| - ស្ពៃក្ដោប(ស) | - ខ្ទឹមក្រហម | - សណ្ដែកខ្មៅ |
| - ស្ពៃក្ដោប (ស្វាយ) | - ខ្ទឹមស | - សណ្ដែកបណ្ដុះ |
| - ស្ពៃបូគោ | - ខ្ទឹមបារាំង | - សណ្ដែកសៀង |
| - ស្ពៃចង្រឹះ | - ខ្ទឹមគុយទាវ | - សណ្ដែកដី |
| - ដំឡូងជ្វា(ស) | - ម្ទេសត្រាវស្លា | - ក្រអៅឈូក |
| - ដំឡូងជ្វា (ឈាមមាន់) | - ម្ទេសផ្លែថាវ | - ប្រលិត |
| - ដំឡូងដួង | - ម្ទេសការ៉ុត | - ត្រកួន |
| - ដំឡូងកាយពីង | - ម្ទេសឈូក | - កញ្ឆែត |
| - ដំឡូងឈើ | - ម្ទេសខ្ទី | - កំពឹងពួយ |
| - ស្លាបចង្វា | - ម្ទេសប៉ិគួក | - ចន្ទល់ភ្នំ |
| - ត្រគៀត | - ម្ទេសខ្វាយ | - កំប៉ោក |
| - ច្រាច់ | - ម្ទេសរំដេង | - ម្ទេសស (គុយទាវ) |
| - ត្រឡាច | - ម្ទេសម៉្វ | - ម្ទេសដៃនាង (ក្រហម) |
| - ល្ពៅ | - ម្ទេសល្មៀត | - ម្ទេសផ្លោក |
| - ត្រសក់ផ្អែ | - ននោងវែង | - ម្ទេសហាវ៉ៃ |
| - ត្រសក់ស្រូវ | - ននោងជ្រុង | - ម្ទេសអាចម៍សត្វ |
| - ត្រសក់កញ្ចៀប | - វល្លិ៍បាស់ | - ម្ទេសខ្មាំង |
| - ត្រសក់ពស់ | - វល្លិ៍ម្រះ | - ផ្លែពពាយ |

| | | |
|---|---|---|
| - ផ្លែក្រសាំង | - វល្លិជ្រលុង | - ផ្លែសណ្ដាន់ |
| - ផ្លែក្រូចឆ្មា | - ផ្លែក្រូសោច | - ផ្លែម្នាស់ |
| - ផ្លែស៊ូ | - ផ្លែខ្នុរសម្លរ | - ផ្លែល្ហុង (ខ្ចី) |
| - ផ្លែចេកណាំវ៉ា(ខ្ចី) | - ផ្លែត្រប់វែង | - ផ្លែត្រប់ក្រាមរមាស |
| - ផ្លែត្រប់ពុតលំញង | - ផ្លែត្រប់សំបកស្រួយ | - ផ្លែត្រប់ពន្លុង |
| - ទំពាំង | - ស្លឹកងប់ | - ស្លឹកក្រូចសោច |
| - ស្លឹកស្លួត | - ស្លឹកម្រុម | - ស្លឹកម្កាក់ |
| - ស្លឹកសន្ទាន់ | - ត្រួយលាប | - ត្រួយរាំង |
| - ត្រួយអំពិល | - ត្រួយស្វាយ | - ត្រួយស្ពាច់ |
| - ផ្កាសាឡិត | - ផ្កាល្ពុងឈ្មោល | - ផ្កាក្រសាំង |
| - ផ្កាប៉ូយកាក់ | - ផ្កាថ្ម (សមុទ្រ) | - ផ្លែឡាវហាវ |
| - សារាយ (សមុទ្រ) | - សាឡាត់ | - គិនឆាយ |
| - ជីរវ៉ាន់ស៊ុយ | - ជីនាងវង | - ជីរថ្ពល់ត្រី |
| - ជីរអង្កាម | - ជីរលីងលាក់ | - ជីរស្លឹកគ្រៃ(ស្លឹកគ្រៃគ្រឿង) |
| - ផ្សិតចំបើង | - ផ្សិតចេក | - ផ្សិតឫស្សី |
| - ផ្សិតក្រងោក | - ផ្សិតក្រមួន | - ផ្សិតស្វាយ |
| - ផ្សិតកញ្ជូរ | - ផ្សិតផក់ | - ផ្សិតឈ្មូក |
| - ផ្សិតកំប៉ោក | - ផ្សិតត្នោត | - ផ្សិតដូង |
| - ផ្សិតក្រាមរមាស | - ផ្សិតត្រចៀកកណ្ដុរ | - ផ្សិតស្ពាច់ |
| - ផ្ទីស | - ផ្ទីដូង | - ផ្ទីអាចម៍មាន់ |
| - ផ្ទីស្លឹកពណ៌ស្វាយ | - សាឡាត់សង | - ម្អម |

- តាំងអោ - ភ្លៅកង្កែប

## សាឡាត់សង



ឈ្មោះសាមញ្ញ (Cmmon Name): Mug-wort,worm wood

ឈ្មោះ វិទ្យាសាស្ត្រ (Scientific Name): Artemisia Vulgaris, Linn.

ឈ្មោះជាគ្រួសារ (Family Name): Compositae.

លក្ខណៈទូទៅ :

សាឡាត់សងជារុក្ខជាតិបន្លែមួយប្រភេទ មានកំពស់ប្រមាណ ៣០ ស.ម ទៅ ២០០ ស.ម មានការដាំដុះដោយគ្រាប់ ជាដំណាំកសិកម្ម ( រីឯប្រទេសដទៃទៀត មានការដុះឯង ) មានគុម្ពនីមួយៗបែកចេញ ជាដើមច្រើន ស្លឹក ឬត្រួយរបស់វាដូច ផ្កាស្បៃរឿង មានក្លិនក្រអូបឆ្ងុយ គេកាត់ស្លឹក និងត្រួយរបស់វាមកធ្វើជាបន្លែ ចំណែកគល់ដែលនៅ នឹងមានការដុះចេញជាថ្មីទៀត ។

**សារជាតិឱសថ :**

មានរសជាតិល្វីង និងហាងតិចៗ ក្លិនក្រអូប ធាតុមធ្យម ដេញខ្យល់ បំបាត់ការឈឺចុកចាប់ ជួយឃាត់ឈាម ។

**សារៈប្រយោជន៍ជាឱសថ :**

បំបាត់រាល់ការឈឺចាប់ក្នុងសរីរៈ, រលាកតម្រងនោម ( មានឈាមនៅពេលឈឺនោម ), ឈឺចាប់ពេលរដូវមក, រដូវមិនទៀងទាត់ , ជម្ងឺពកក, ធ្លល់ពោះ ( ជួយដេញខ្យល់ ) ។

( នៅមានត)

*រូបកាយ សត្វទាំងឡាយ តែងចាស់*
*ឈឺចាប់ ស្លាប់បាត់, ឯគុណធម៌ពោះមិន*
*ចេះចាស់ ឈឺចាប់ ស្លាប់បាត់ឡើយ ។*

សម្ដេចព្រះមហាសុមេធាធិបតី
វជិរប្បញ្ញោ **ហួត តាត**

# ការបរបាញ់សត្វ

ដោយ : **ខាន ហ៊ន**

នៅតំបន់ព្រៃភ្នំសម្បូរទៅដោយម្រឹគីម្រឹគាបក្សាបក្សី ជាហេតុងាយស្រួលក្នុងការប្រកបមុខរបរចិញ្ចឹមជីវិតរបស់អ្នករស់នៅតំបន់នោះ គេតែងហៅថា " **ការបរបាញ់សត្វ** " ។

មុខរបរប្រមាញ់នេះ មានច្រើនបែបច្រើនយ៉ាង តាមការចូលចិត្តនិងតាមកាលវេលារបស់ប្រជាជន និយាយដោយខ្លីមាន ៤យ៉ាងគឺ :

- ដើរលប
- ចាំ ផ្ទះ
- អន្ទាក់
- អង្គប់

## របៀបដើរលប

គេចេញពីព្រលឹមស្រាង១សំដៅទៅវាលណាដែលធ្លាប់មានសត្វរកស៊ី អាចមានគ្នាពីរនាក់ឬបីនាក់ ឬម្នាក់ឯងក៏មាន ។ គេដើរតាមមាត់ព្រៃមើលទៅវាលល្បាស់ទឹកផ្លែ(១) គេដើរដោយប្រុងប្រយ័ត្ន មិនខាកស្ដោះក្អកកណ្ដាស់ ភ្នែករំពៃមើល

១ - ល្បាស់ទឹកផ្លែ = ព្រៃដែលលាស់ក្នុងរដូវដើមឆ្នាំ ដែលមានទឹកឬមានផ្លែធ្វា-កន្ទួតព្រៃ-ផ្លែពោន (ម្កាក់ព្រៃ) សត្វឈ្លួសច្រើនស៊ី

ទៅទិសដៅ ដែលគេសង្ស័យ ។

ជូនកាលគេបង្ហើរសំឡេងផ្លុំស្លឹកផង "វេត" "វេត" ។ សំឡេងនេះបើមានឈ្លូសក៏មក ខ្លាក៏មក ។ ឈ្លូសស្មានសំឡេងកូនវា ខ្លាស្មានសំឡេងសត្វត្រូវចំណី ។

លុះថ្ងៃក្ដៅគេនាំគ្នាឈប់សម្រាក ។ គេអាចលបបាននៅពេលល្ងាចត្រជាក់ម្ដងទៀត ។ នៅពេលថ្ងៃក្ដៅ សត្វសម្រាក គេតែងហៅថា "សត្វស្រីង"[១] ។ វាអាចចូលសម្រាកក្នុងព្រៃជ្រៅ ឬមាត់ព្រៃជ្រៅ ។ គេអាចដើរចេញពីមាត់វាលទៅរកមាត់ព្រៃ ។

## របៀបចាំ "ឆ្នះ" ឬ ច្រាប[២]

ចំណីសត្វក្រៅពីស្មៅ មានស្លឹកឈើ ផ្លែកន្ទុតព្រៃ សម៉, ចំបក់, អង្គ្រង.ពោន (ផ្លែម្កាក់ព្រៃ) ធ្នា, (ផ្លែដូចអំពិលទឹក) ស្វាយស្រគំ (ផ្លែដូចរំដេញស្លឹកដូចស្លឹកព្រីង ) .... ។

កាលណាគេបានឃើញផ្លែឈើខាងលើ ដែលមានគន្លងសត្វចូលស៊ីយប់ឬថ្ងៃ គេទៅចងឆ្នះចាំផ្លែនោះ ។

*អំពីផ្លែធ្នាក្រញ៉ាញ៉ូ:* ធ្នានេះគេនិយមឱ្យអំណាចព្រោះវា "ធ្វើទុក្ខខ្លាំងណាស់" បើមិនចេះបិទបាំងមន្តអាគមស្ដោះផ្លុំចងព័ទ្ធទេ ( ធ្នាក្រញ៉ាញ៉ូលងណាស់) ។

គេឱ្យអំណាចទៅលើឬស "ផុស" បើមានឫសផុសគេយកកាំបិតមកចាក់ពុំនោះទេគេយកទ្រាំង[៣] ដោតនៅគល់ ។

---

១- សត្វស្រីង = គឺសត្វឈរសម្រាកក្រោមម្លប់ ( ទំពាររអៀង )

២- ច្រាប = គឺជាត្រពាំង កន្លែងដែលមានដីប្រៃ ដែលសត្វចូលចិត្តទៅស៊ី

៣- ទ្រាំង = គឺជាធាងរបស់ដើមខ្ញែង ស្លឹកវាគេយកទៅធ្វើសាស្ត្រាស្លឹករឹត ឬប្រក់ផ្ទះ

ផ្ទះគេមិនបានចងនៅនឹងដើមនេះទេ គេអាចចងដើមណានៅជិតៗនោះ ដោយគេយល់ថា ការចាំផ្ទះមានការលំបាកយ៉ាងនេះ ទើបព្រានធំ មានថ្នាំសម្រាប់រម្ងាប់ព្រៃ មានបាលីចងព្រាយម្រេញគង្វាល ។

*ថ្នាំរម្ងាប់ព្រៃ :*

- ឫសកន្ទុយចចក ៧ ចំណិត
- ឫសព្រះខ្ទប ( ផ្កាលឿង ) ៧ ចំណិត
- ស្លា ........................ ៧ ចំណិត

ទំពាព្រួសទៅលើឫសផុស ឫជុំវិញគល់ឈើចងផ្ទះ

- *បាលីព័ទ្ធសីមា* = ជាលោ មហាជាលោ ។ល ។

## របៀបចាំច្រាប

ធម្មតាសត្វ ម្រឹគ ក្របី ខ្ទីង ទន្សោង ..... ចូលចិត្តលិទ្ធច្រាបណាស់បើមានទឹកល្អក់ៗដក់តាមក្រឡិកក្រឡុក វាក្រេបផឹក .......... ។

ច្រាបណាដែលមានគន្លងសត្វចូលស៊ីច្រើន គេទៅចងផ្ទះចាំកន្លែងនោះអាចចងផ្ទះពីរឫបីតាមការគួរនៃគំនិតគេ ។

ការចាំផ្ទះផ្លែក្តី ច្រាបក្តី ទឹកក្តី តាមការផ្តល់ពត៌មានពីពួកព្រានមានអត្ថន័យដូចគ្នា ។ ដើម្បីការពារសុវត្ថិភាព គេចងចង្កេះគ្នាទៅវិញទៅមកហាមមិនឱ្យឆ្លើយបើមាននរណាគេហៅ មិនឱ្យចុះដី ទោះបីសំឡេងនោះដូចសំឡេងអ្នកណាម្នាក់ក្នុងគ្រួសារនោះក៏ដោយ លុះត្រាតែព្រឹកព្រាង ថ្ងៃរះខ្ពស់ល្មមបាន់ស្មានគ្មានការបំភ័យទេ ទើបអាចនាំគ្នាចុះបាន ។

គេតែងនឹកដល់រឿងនិទានមួយថា "ថ្ងៃមួយព្រានប្រមាញ់ពីរនាក់ទៅចាំផ្លែផ្កាក្រញ៉ាញ់ បានដាក់កិច្ចសន្យាជាមួយគ្នាស្រេចថា " បើមានជាសំឡេងហៅជារូបអ្នក

ណាម្នាក់ក្នុងគ្រួសារយើងក៏ដោយ ក៏មិនត្រូវឆ្លើយ មិនត្រូវចុះ បើមិនទាន់ឃើញថ្ងៃរះមកពីកើត ទេ " ។

លុះយប់ជ្រៅនៅពេលដែលយន់ដំណេកមួយភាំង ព្រាយប្រាបកាឡាខ្លួនជាម្ដាយ ក្មេកមកប្រាប់ថា " ប្រពន្ធកូនឈឺពោះឆ្លងទន្លេ កំពុងស្រែកបម្រះននៀលពេញផ្ទះ មុខជាមានគ្រោះថ្នាក់ដល់កូនប្រពន្ធមិនខាន " ពួសំដីបោកប្រាស់មិនចាំច្បាស់ពាក្យសន្យា ក៏ចុះមកដី ពេលនោះត្រូវបានជាចំណីខ្លាយ៉ាងឆ្ងាញ់ពិសារ ។

ព្រានម្នាក់ភ្ញាក់ដឹងខ្លួន បាត់ព្រានម្នាក់មិនឃើញ កើតមានការព្រួយបារម្ភ ភ័យខ្លាច តែខំពង្រឹងស្មារតីតទល់នឹងឧបសគ្គ ។ ព្រឹកថ្ងៃរះខ្ពស់ទើបចុះដីឃើញតែឈាមនៅពេញពាសក្រោមផ្ទះ ។

## របៀបចាំទឹក

នៅរដូវប្រាំងទឹកថ្ពុក ត្រពាំង អូរតូចតាចបានខះរីងស្ងួតហួតហែងនៅតែតាមកន្លែងខ្ទប ត្រពាំង ធំ ជាំ ។

ពួកព្រានដើរសំដៅទៅរកត្រពាំងឬខ្ទបទាំងនោះ បើមានគន្លងសត្វចូលផឹកគេក៏ចងផ្ទះចាំទីនោះ ។

## របៀបចាំអាចម៍

សត្វកែះ[១] ខ្លាឃ្មុំ មានប្រពៃណីខុសប្លែកពីសត្វដទៃ ។ វាជុះអាចម៍តែមួយកន្លែងទេ ក្នុងមួយជីវិតរបស់វាលើកលែងតែមានភ័យអន្តរាយ ទើបវាផ្លាស់ទីកន្លែងជុះ ។

កាលណាគេបានឃើញអាចម៍វាហើយ គេចាំវាទៅជុះនោះគេនឹងបានជួប

---

១ ‐ សត្វកែះ = ឈ្មោះសត្វចតុប្បាទព្រៃ រូបភាពស្រដៀងនឹងពពែ. រស់នៅតែក្នុងព្រៃភ្នំ

ព្រឹកឬល្ងាចគេចមិនផុតទេ ។ និយាយនេះគឺចំពោះអាចមិដែលវាមកជុះរាល់ថ្ងៃ បើអាចមិចាស់គេមិនចាំទេ ។ បើជាខ្លាឃ្មុំ ទោះជាអាចមិចាស់ក៏គេអាចយក ទៅសួក្រមួនយកទៅលក់ដូរបានដែរ ។

សត្វកែះមានលក្ខណៈពិសេសជាងខ្លាឃ្មុំ វារកស៊ីជិត *ហុង-ប៉ើយ*[១] កាលណាមានអាសន្នគឺព្រានព្រៃរកបាញ់វា។លោតទម្លាក់ ទៅក្នុងហុងជ្រោះនោះ ប្រសិនជាវាបាក់ជើង ......វាអាចលិទ្ធខ្លួនវា ជាដើរបានដូចដើមវិញ ។

## របៀបចាំសំឡាញ

" សំឡាញ " គឺជាខ្សែដែលធ្វើអំពីបណ្តូលខ្ញែង[២] ឬព្រាល- សម្រងពន្លុង ឬស្បៃ ។ គេតភ្ជាប់គ្នាមួយចំរៀក។ អាចបានមួយរយម៉ែត្រ ឬពីររយម៉ែត្រ គេលាត សន្ធឹងកាត់ទទឹងគោកណាមួយដែលគេសម្គាល់ថាមានសត្វរកស៊ីរាល់ថ្ងៃ ហើយព្រាន ពីរនាក់អង្គុយចាំចុង-ដើម ។ ធម្មតាសត្វព្រៃ កាលណាជួបខ្សែកាត់មុខវាយ៉ាងនេះ មិនអាចកន្លងបានទេ គឺត្រូវតែដើរសៀវខ្សែនោះទៅចុង ឬគល់សំឡាញ ពេលនោះ គឺអាចបានដៃព្រាន ព្រៃដែលអង្គុយចាំនៅទីនោះហោង ។

## របៀបចងវាំង[៣] ចាំឈ្លាស់

ក្នុងវាលស្រែណាមួយដែលមានប្រើស រមាំងស៊ីជាប្រចាំហើយច្រើនកន្លែង គេចងវាំងព័ទ្ធជុំវិញស្រែនោះ ដោយទុកតែមួយប្រឡោះសម្រាប់វាចូលស៊ីហើយគេ

---

១ - ហុង-ប៉ើយ = គឺអណ្តូងជ្រៅ ឬ ជ្រោះ ដែលមានច្រាំងចោទខ្លាំង

២ - ខ្ញែង = គឺជារុកជាតិម្យ៉ាងស្រដៀងនិងដើមត្នោត តែមានធាងវែង១ស្លឹកវាយកទៅត្បាញធ្វើ កន្ទេល ឬធ្វើសាស្ត្រាស្លឹករឹត ។

៣ - ចងវាំង = គឺចងខ្សែព័ទ្ធជុំវិញទុកតែកន្លែងចេញ ឬកន្លែងសម្រាប់បាញ់

ចង ផ្ទះចាំនៅទីនោះ បើមិនចូលថ្ងៃនេះ អាចស្អែកទៀតមិនខាន ។

## របៀបលើកព្រៃឬដេញព្រៃ

បើគេបានឃើញកន្លែងជ្រូក ប្រើស រមាំង ក្តាន់ .....ចូលព្រៃតូចៗណាមួយគេនាំគ្នាទៅដេញបង្អើលគេនិយមហៅថា " ដេញព្រៃឬលើកព្រៃ " ក្រុមអ្នកដើររុកព្រៃស្រែកបង្អើល បង្អោឡូឡា វូសវ៉ាស គេនិយមថា " កូនល្បើក " ។ គេដេញពីណាទៅណា ព្រានព្រៃនៅចាំច្រកណា, បើសត្វរត់ទៅចំហើយដៃព្រានព្រៃបាញ់ខុសគេនិយមប្រើពាក្យ "លាកព្រាន"[១] គឺគេនាំគ្នាយកសំបុកអង្រ្កងដែល មានមេនៅតិចឬច្រើន (តាមការនិយម) ទៅវាយលើខ្នងព្រានព្រៃដែលបាញ់ខុសនោះ ។

ខ្លះគ្រាន់តែប្រមាថចង់ឱ្យអង្រ្កងខាំ - ខ្លះវាយទម្លាក់ទឹក ខ្លះទៀតដាក់ត្បោក[២] ព្រាន ។

## របៀបឆ្នុះ

កាលពីមិនទាន់មានភ្លើងចង្កៀងថ្មស្ពុយ.ពិល.កែវ.អាគុយ ចាស់ៗគាត់ប្រើភ្លើងទៀនឬកូនខ្វាន់ដើរតាមក្រោយ ។ របៀបនេះតាមខ្ញុំធ្លាប់ដើរជាមួយលោកតាព្រានអ៊ួង ស្នងតាន់ នៅភូមិចំបក់កោង ឃុំត្បែងពីរស្រុកគូលែន ខេត្តព្រះវិហារ សត្វសាំងជាងកែវ ឱ្យភ្នែកច្បាស់ឃើញខ្លួនវាច្បាស់ ព្រោះវាមើលមិនឃើញមនុស្សដើរទេ ឃើញតែភ្លើងទៀនលើក្បាលមនុស្ស ។

បើសិនប៉ះខ្យល់ ពោលគឺខ្យល់បក់ទៅលើវានាំក្លិនមនុស្សទៅផង ពេលនោះទើបផ្អើល ។

---

១- លាកព្រាន = គឺជាការដាក់ទណ្ឌកម្មព្រានព្រៃ (អ្នកប្រមាញ់) ដើម្បីកុំឱ្យបាញ់ខុសទៀត

២- ត្បោក = ដាក់ឈើចងកៀបក ទាល់តែបាញ់បានសត្វមួយទើបលែង

បច្ចុប្បន្នមានកែវឆ្លុះងាយស្រួលដល់ការបរបាញ់ អាចមើលឃើញពីឆ្ងាយ ពីហាសិបម៉ែត្រទៅមួយរយម៉ែត្រ តែសត្វភ្លាង[១] ជាងទៀន ។

ក្រៅពីការបរបាញ់ ប្រជាកសិករនៅតំបន់ជនបទ មានអាជីវកម្មមួយបែបទៀត ដែលជាទម្លាប់ពីបុព្វកាលយូរលង់ គឺអង្គប់ ។ អង្គប់នេះមានច្រើនប្រភេទគឺ អង្គប់ដៃ ( ជាខ្សែ ) មានពីម្ភៃមេទៅហាសិបមេ .....អង្គប់ដៃតូច .... អង្គប់ដៃទ្រង់ អង្គប់ទ្រុង អង្គប់ធំ ។

តទៅសុំលើកយកពីការធ្វើអង្គប់ធំមកអធិប្បាយ :

## របៀបស្រាស់អង្គប់ធំ

អង្គប់ធំនេះជាមុខរបរមួយរបស់ប្រជាជនតំបន់ព្រៃធំ ដូចជាម្តុំព្រៃស្នាក[២] ព្រៃកួយ ព្រៃអិះ[៣] ព្រៃព្រះរកា ព្រៃឡង់ .... ។

អង្គប់នេះគេតែងស្រះនៅរដូវភ្លៀងធ្លាក់ជោគជាំ ។ មុនចុះដកស្ទូង គេផ្តើមស្រះអង្គប់ធំមួយត្បូងប្រមាណសាមសិបមេឡើង ...... ។

( កាលខ្ញុំនៅភូមិសាគ្រាម ឃុំសាគ្រាមស្រុកស្ទោងខេត្តកំពង់ធំ មានព្រៃធំពីរ គឺខាងលិចភូមិព្រៃអ្នកតាថ្កោលជាប់ទៅព្រៃសង្ខាត ជាតាង ពពក ខ្ទមមាន់ (កទម្ព ) ដង្ហៅថេតព្រៃខាងកើតភូមិ ខាងកើតស្ទឹងក្រសាំង ឬស្ទឹងស្ទោងក្នុងព្រៃកួយ ដង្ហៅអ៊ិត ) ។

## ខ្ញុំសុំនិយាយពីដង្ហៅអ៊ិត

១ - សត្វភ្លាង = គឺសត្វផ្អើល

២ - ព្រៃស្នាក = គឺជាព្រៃដែលស្តុក ឬព្រៃដែលកាប់ចំការហើយមិនបានធ្វើ

៣ - ព្រៃអិះ = គឺជាឈ្មោះព្រៃជ្រៅ

រដូវស្រះអង្គប់ចូលមកដល់ អ្នកស្រុកភូមិ តែងមកផ្ទះដង្វៅអ៊ិតដើម្បីសាកសួរពីការងារនេះ ។ ដូចនេះតាដង្វៅក៏បានផ្សាយដំណឹងត១គ្នា អាចបានកូនសម្រាស់ពី ២៥ ទៅ ៣៥ នាក់ ...។ ខ្ញុំ( ជាវ ហ៊ន ) នៅស្រុកគូលែន ខេត្តព្រះវិហារខ្ញុំបានស្រះអង្គប់ជាមួយ លោកតា លីម នៅព្រៃខ្នារតូច ។

## អំពីខារអង្គប់មេម្នព្រៃ

លោតតា អ៊ិត ប្រើថ្នាំដុសលើគល់ឈើ ឬលើក្បាលដំបូក កូនផ្កាវដុះលើគល់ក្រាក់ បើរកមិនបានមានអ្នកឧបកិច្ចគឺយកកូនត្រប់រំលួយទៅដាំក្បាលដំបូក មុន ៤៥ ថ្ងៃ កូន ផ្កាវក៏ដូចគ្នា ។

*តាស្រី សេក* នៅភូមិពោធិ ឃុំពោធិ ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារមានពោលរួចមកហើយ ។

## ថ្ងៃចេញស្រះអង្គប់

វេលាយប់នោះគេជួបជុំគ្នានៅផ្ទះដង្វៅ អុជធូបទៀន ចងស្លាធមិព្រៃមួយគូនៅមុខផ្ទះដង្វៅ មួយគូទៀតចងនៅហ្នឹងហ៊ីងគ្រូដង្វៅ មានជម៤ ស្លាធមិមួយគូ ។

ក្រោយអុជធូបទៀន សំពះគ្រូប្រកាំ (១) រួចហើយគេអង្វយ សុំអង្វរគ្រូប្រកាំឱ្យជួយក្បៀងសត្វព្រៃចូលអង្គប់របស់ខ្លួន១សន្យាសែនព្រេន...ជាមួយនេះ ; សុំបានសុខសប្បាយក្នុងការស្រាស់សម្រាស់ រំលំមេ ខារមេ កុំឱ្យមានគ្រោះថ្នាក់កូនចៅ ។

## ការរំលំមេ

ដង្វៅចង់បានមេចោលកន្ទុយទៅលើមេដំបងនេះគេហៅ " មេច្បង " បើវារំលំចុងទៅកើតត្រូវស្រាស់ទៅកើតតាមដែរ មិនអាចផ្ទុយពីនេះបានទេ ពុំនោះ

---

១ - គ្រូប្រកាំ = គឺគ្រូមេម្រេញគង្វាល

ត្រូវចោលមេនោះបើមិនបានសមបំណង ។

កាលបើសម្លឹងឃើញមេធំបងហើយ គេអុជធូបចងស្លាធមិព្រៃបែបនេ់ សុំឱ្យដួលចោលកន្ទុយទៅតាមសេចក្តីប្រាថ្នា ។

បន្ទាប់មកដង្ហៅកាប់បីពូថៅខាងពោះ[១] បីពូថៅខាងខ្នងទើបកូនឡៀងជាអ្នកសម្រេច ។

នៅពេលជិតដួល ដង្ហៅដាក់ពងមាន់ ...នៅគល់ បើឈើដួលចុង ដល់ដី គល់វាយបែកពងមាន់ទំនាយថា " អង្គប់នោះបានច្រើន " ។

បើចុងទៅតាមប្រាថ្នាហើយ ដង្ហៅចាប់ផ្តើមរម្ងាប់ព្រៃ មានសូត្ររបៀនខ្សីប១... និងទំពាដើមថ្នាំព្រួសមេច្បង ។

នៅពេលស្រះមេច្បងកូនឡៀងតែងស្រែកហៅខ្លា ប្រើស រមាំង ។ "តែកុំថាដីរ " ដង្ហៅដើរដាក់តម្រុយឱ្យ បើចំលើដើមអង្គាបុសថ្កាស ត្រូវជីកគាស់រំលើងឬសចោលឱ្យអស់ បើអាចវាងបានក៏វាងទៅ ។

ការស្រាស់សម្រាស់អាចបាន ១៥ មេ ឬ ៣៥មេ គេតម្លើងសម្រេច ..... ។

គេធ្វើរោងបាយ៉ាប[២] មួយនៅចំពាក់កណ្តាលខ្សែអង្គប់ ។

- រោងត្រូវបែរមុខទៅកន្ទុយសម្រាស់ត្រូវធ្វើជាពីរថ្នាក់ មានរានប្រកាំមួយទៀតស្ថិតនៅឰសានរោងបាយ៉ាប ( សម្រាប់រៀបសំណែន )

- កូនសម្រាស់ក្នុងពេលស្រាស់ក្តីមិនត្រូវឆ្លងចុះឡើងតាមទំនើងទេ អ្នកនៅខាងក្រៅនៅក្រៅ - អ្នកខាងក្នុង នៅក្នុង មិនកន្លងសម្រាស់ឡើយ ។

– កូនឈើងាប់នៅទទឹងសម្រាស់ត្រូវដកចេញដោយនិយាយថា " ដកចូល

---

១ - ខាងពោះ = គឺខាងដើមដែលទ្រេត

២ - បាយ៉ាប = គឺរោងប្រកាំ រោងអ្នកតា

ឬយកចូល ”

– មិនហុចឱ្យគ្នា មិនត្រូវកន្លងរំលង ឬទម្លុះសម្រាស់ទេ ។

– បើមានសាច់ក៏មិនអាំងនឹងដំបុកដែរត្រូវដោតជន្ទួចបើអាំងបានត្រឹមខ្ទប់តែដំបុតដើមពពេល ។

– បើហូបឆ្អែតហើយត្រូវក្រោកមុនគេប្រាប់ថា ” ហូបមិនឆ្អែតទេ ” លោកតាឱ្យតូចពេក ។

– បើមានកូនក្រឡាន[១] ទៅ ហូបសាច់ច្រើនក្តី តិចក្តីត្រូវឱ្យយកសាច់ទៅផ្ទះប៉ុនគ្នា បើមានផ្ទៃត្រូវឱ្យចំណែកពីរ ។

– ក្នុងថ្ងៃបន្ទាប់នោះអង្គប់ត្រូវសង្កត់សត្វមានផ្ទៃ ( តាមការសង្កេតផ្ទាល់របស់ខ្ញុំ ជាវ ហ៊ាន ) ។

– ខ្នារ ( ឈើសម្រាប់ ៣០ មេឡើង ) និងពួកប្រកាំត្រូវឆ្វាយទុកដាក់លើរានបាយ៉ាបយ៉ាងសក្តិសមគ្មានអង្គុយលើ ឬ ដើរកន្លងទេ ។

– អ្នកត្រូវវេនមើលអង្គប់មានស្នែងប្រកាំមួយ បើមានលាភជ័យបានប្រើសក្តិរមាំង ជ្រូកក្តី ត្រូវផ្លុំស្នែងជាសញ្ញាឱ្យកូនសម្រាស់ដឹង តែត្រូវផ្លុំដាក់កន្ទុយទៅរកកន្ទុយអង្គប់ ។

– រៀងរាល់យប់ត្រូវទៅសំពះប្រកាំ អ្នកខានត្រូវស្តីបន្ទោស ។ បើធ្ងន់បញ្ឈប់ ។

– អង្គប់មិនថ្លោះ. មិនបានសត្វ. លោតរំលង ឬទម្លុះសម្រាស់គេថាមានកូនសម្រាស់ណាម្នាក់ប្រព្រឹត្តខុសបទត្រណម ត្រូវលក់ពិន័យជាសត្វមាន់មួយក្បាលស្រាមួយដប ។

– ពាក្យអាសអាភាសត្រូវហាមឃាត់ក្នុងការទំនាក់ទំនងប្រចាំថ្ងៃ ។ អង្គប់

១ - កូនក្រឡាន = គឺអ្នកក្រៅ

នេះអាចទម្លាក់មេចោល នៅពេលដែលដង្កៅបញ្ជោ ។

‑មេអង្គប់ដាក់នៅសងខាងផ្លូវ តែគោក្របីប្រជាជនមិនជាប់ទេ ។ ឯសត្វព្រៃត្រូវផ្លូវបើកចំហ ( ដាក់ផ្លូវសត្វមិនដាក់ផ្លូវរទេះទេ ) ។

ពិធីស្រាស់អង្គប់ធំចប់ប៉ុណ្ណេះ ។ ពិធីនេះខ្ញុំ *ជាវ‑ហ៊ន* បានចេះចាំពីខ្មោចតាអ៊ិត តាថេត កាលនៅសាគ្រាមស្រុកស្មោងនិងតាលឹមនៅស្រុកគូលែន ។



លោក អ៊ុំ **ជាវ ហ៊ន**
អាយុ ៦៣ ឆ្នាំ
សមាជិកឆ្លើយឆ្លង របស់
វិទ្យាស្ថាន ពុទ្ធសាសនបណ្ឌិត្យ
ជាអ្នកផ្ដល់បទសម្ភាស

កំណាព្យ

# ខ្ញុំចង់រស់...

(បទ កាកគតិ)

ដោយ: ខៀវ បញ្ញាឧត្តម



ចង់រស់ព្រោះគ្មាន ចង់រស់ព្រោះឃ្លាន ចង់រស់ប្រាកដ
ចង់រស់ព្រោះខ្លាច មិនអាចព្រោះអត់ រស់ដោយកម្សត់
ហត់មិនត្អូញត្អែរ ។

ម៉ែដាក់ខ្ញុំចោល ខ្ញុំកកិលដោល រកមនុស្សនៅក្បែរ
ដូលមានជំនួយ បានជួយលើកដែរ គេចោមមើលអែរ
សង្វេគខ្លួនក្រែ ។

ខ្ញុំចង់លះអៀន ចង់ដើរ ចង់រៀន ចង់កែចង់ច្នៃ
ចង់មានគ្រប់សព្វ ប្រអប់ជើងដៃ មានខោអាវថ្លៃ
មានមិត្តស្រីប្រុស ។

| | | |
|---|---|---|
| ចង់សរសេរដែរ | តួអក្សរខ្មែរ | មិនឱ្យមានខុស |
| ចង់ចេះគិតគូរ | ឱ្យត្រូវបណ្ដុះ | ក្នុងនាមកូនប្រុស |
| | ក្រោមដំបូន្មាន ។ | |
| ចង់បានរូបល្អ | ដូចសិល្បករ | ក្នុងព្រេងនិទាន |
| មានសិល្ប៍និយម | អាគមរបៀន | ប្រែក្រឡាបាន |
| | តាមចិត្តប្រាថ្នា ។ | |
| ហ៊ឺ !.. មិនមែនងាយ | រវើរវាយ | មិនឈ្នះវាសនា |
| ប្រហែលបាបធំ | ទើបខ្ញុំមានពៀរ | រងទុក្ខវេទនា |
| | ជាអ្នកសុំទាន ។ | |
| ឈ្លើយ!..កុំតូចចិត្ត | ទុក្ខក្នុងជីវិត | មិនថាក្រ មាន |
| ល្វិតល្វង់ បែកបាក់ | ខ្ជិន ខ្លាក់ ខ្លាច ហ៊ាន | នេះជា "ខន្ធប្រាន |
| | ឬធ្នាលោកិយ " ។ | |



# កិច្ចប្រជុំការងារ ធម្មការ និងសាសនា ជាមួយមន្ត្រីនៃមន្ទីរធម្មការ និងសាសនា ខេត្ត_ក្រុង ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០២

នៅថ្ងៃទីដប់ពីរ ខែ មិថុនា ឆ្នាំ ២០០២ នៅសាលប្រជុំទីស្តីការក្រសួងធម្មការ និងសាសនា បានរៀបចំកម្មវិធីប្រជុំមួយស្តីពីការងារធម្មការ និងសាសនា ចូលរួមដោយមន្ត្រី នៃមន្ទីរធម្មការ និងសាសនា គ្រប់ខេត្ត-ក្រុង ទូទាំងប្រទេស ។

អញ្ជើញជា អធិបតីនៅពេលនោះមាន ÷

- ឯកឧត្តម **ជា សាវឿន** រដ្ឋមន្ត្រី ក្រសួងធម្មការ និងសាសនា
- ឯកឧត្តម **ឈន អឿម** រដ្ឋលេខាធិការ ក្រសួងធម្មការ និងសាសនា
- ឯកឧត្តម **អ៊ិន ទិសារ៉ិម** រដ្ឋលេខាធិការ ក្រសួងធម្មការ និងសាសនា
- ឯកឧត្តម **ដោក ណារិន** អនុរដ្ឋលេខាធិការ ក្រសួងធម្មការ និងសាសនា
- ឯកឧត្តម **គ្រួច សារី** អនុរដ្ឋលេខាធិការ ក្រសួងធម្មការ និងសាសនា
- ឯកឧត្តម **សៅ ទ័ន** អនុរដ្ឋលេខាធិការ ក្រសួងធម្មការ និងសាសនា

អ្នកសម្របសម្រួលកម្មវិធីប្រជុំក្នុងថ្ងៃនោះ គឺលោក **ខួន ទាំន់ចន្ធី** នាយកវិទ្យាស្ថាន ពុទ្ធសាសនបណ្ឌិត្យ ដោយផ្តោតទៅលើរបៀបវារៈដូចខាងក្រោម :

- *ការងារគ្រប់គ្រងវត្ត និងគ្រប់គ្រងព្រះសង្ឃ*
- *ការងារ ពាហិរ សាសនា*
- *ការងារ អភិវឌ្ឍន៍ ពុទ្ធិកសិក្សា*
- *បញ្ហា អធិករណ៍ និងអភិបាលកិច្ចសង្ឃ*

• *ការងារ រដ្ឋបាលទូទៅ*

នាយកមន្ទីរធម្មការ និងសាសនា គ្រប់ខេត្តក្រុងបានឡើងចាប់អារម្មណ៍ និងផ្តល់បទពិសោធន៍យ៉ាងល្អិតល្អន់ ក្នុងកិច្ចការងារ ដែលបានអនុវត្តកន្លងមក ។

ការពិភាក្សាបានសម្រេចឱ្យមន្ទីរធម្មការ និងសាសនា ខេត្ត-ក្រុង តាមដានត្រួតពិនិត្យ ធ្វើឱ្យការអនុវត្តន៍ក្នុងព្រះពុទ្ធសាសនា បានអនុវត្តត្រឹមត្រូវ លើវិស័យខាងក្រោម :

• *ការគ្រប់គ្រងវត្ត និងការគ្រប់គ្រងព្រះសង្ឃ :*

- ពង្រឹងរចនាសម្ពន្ធឱ្យបានគ្រប់លំដាប់ថ្នាក់ ព្រមទាំងផ្សព្វផ្សាយលិខិតបទដ្ឋាន និងសារាចរឱ្យបានច្រើនសម្រាប់អនុវត្ត ។

- ការបំបួសកុលបុត្រ ត្រូវប្រតិបត្តិឱ្យសមស្រប តាមវិន័យប្បញ្ញត្តិពិសេសកុំបំបួស អភព្វបុគ្គល ១១ យ៉ាង ត្រូវយកវិន័យបិដកជាគោល ។

- ត្រូវចេញ ឆាយា សង្ឃដីកា ដោយមានចុះហត្ថលេខាពីឧបជ្ឈាយ៍ត្រឹមត្រូវ និងត្រូវដកយកមកវិញនៅពេលសឹក ។

• *ការងារពាហិរសាសនា :*

- ត្រូវផ្សព្វផ្សាយនិងអនុវត្តទៅតាមច្បាប់រដ្ឋធម្មនុញ្ញ ដែលបានចែងក្នុងមាត្រាទី ៤៣ និងសារាចរអន្តរក្រសួង ដើម្បីប្រជាពលរដ្ឋ ពិសេស អង្គការជំនួយសាសនា ឬសាសនាដ៏ទៃយល់ច្បាស់ពីសិទ្ធិសេរីភាព និងតួនាទីរបស់ខ្លួន ។

• *ការអភិវឌ្ឍន៍ពុទ្ធិកសិក្សា :*

- ការបើកវគ្គបណ្តុះបណ្តាលគ្រូពុទ្ធិកបឋមសិក្សា និងមធ្យមសិក្សាពិសេស ធ្វើវិក្រិតការគ្រូ ភាសាបាលី- សំស្ក្រឹត ជាសំណូមពរ សំខាន់ បន្ទាន់ ។

- ពិនិត្យលទ្ធភាពជ្រើសរើសគ្រូពុទ្ធិក បឋមសិក្សា ចំនួន ៨០ រូប និងគ្រូពុទ្ធិកមធ្យមសិក្សាចំនួន ២០ រូប ក្នុងមួយឆ្នាំ ដើម្បីឱ្យស្របតាមការអភិវឌ្ឍន៍ វិស័យពុទ្ធិកសិក្សា និងកំណើនសិស្ស ។

- ជំរុញ បោះពុម្ពសៀវភៅសម្រាប់គ្រូ ពុទ្ធិកមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ ស្របនឹងកម្មវិធីបង្រៀន ។

● *បញ្ហាអធិករណ៍ និងអភិបាលកិច្ចសង្ឃ :*

- អធិករណ៍ រវាងព្រះសង្ឃ និងព្រះសង្ឃ ពាក់ពន្ធ័ដល់វិស័យសង្ឃ ត្រូវប្រគេនមន្ត្រីសង្ឃ ខេត្ត-ក្រុង ជាអ្នកដោះស្រាយ លើកលែងតែមានសំណូមពរ ឱ្យចូលរួម សហការ រវាងធម្មការ ខេត្ត-ក្រុង និងមន្ត្រីសង្ឃដោះស្រាយរួមគ្នា ។ ករណីពាក់ព័ន្ធដល់ច្បាប់រដ្ឋ និងវិស័យរដ្ឋបាល ព្រមទាំងអធិករណ៍ ដែលពាក់ព័ន្ធដល់ ពុទ្ធបរិស័ទ អាចារ្យ គណកម្មការវត្ត មន្ទីរធម្មការ និងសាសនា ខេត្ត-ក្រុងត្រូវដោះស្រាយ ដោយមានការសហការអំពីមន្ត្រីសង្ឃ ។

នៅទីបញ្ចប់ ឯកឧត្តម **អ៊ុន ទិសាអ៊ុម** រដ្ឋលេខាធិការ ក្រសួងធម្មការ និងសាសនា បានថ្លែងអំណរគុណ លោកនាយក-យករងមន្ទីរធម្មការ និងសាសនា ខេត្ត-ក្រុង ដែលបានយកចិត្តទុកដាក់អនុវត្ត និងផ្តល់បទពិសោធន៍ ដើម្បីបានជាទុនក្នុងការ បដិបត្តិ និងលើកស្ទួយវិស័យព្រះពុទ្ធសាសនា ដែលជាសាសនារបស់រដ្ឋ ។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង ១៨ ^ម^ ប្រកបដោយបរិយាកាសរីករាយ និងភាតរភាពក្រៃលែង ។

ភ្នំពេញ ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០២

លេខាកត់ត្រា

ពៅ សឹម

ទំព័រឆ្លើយឆ្លងជាមួយកម្ពុជសុរិយា



## មិត្តអ្នកអានជាទីមេត្រី

ដោយយល់ឃើញថា អត្ថបទ **មញ្ជូសាវិសុទ្ធិមគ្គមហាដីកា** រៀបរៀងដោយលោក **សួន ឱ្យសថ** ជាអត្ថបទដែលមានកម្រិតខ្ពស់ សម្រាប់បម្រើអ្នកស្រាវជ្រាវ ខាងពុទ្ធសាសនាដែលចេះបាលីជ្រៅជ្រះ ។

ក្រសួងធម្មការ និងសាសនា បានសំណូមពរ. ផ្អាកការចុះផ្សាយអត្ថបទនោះតាមរយៈទំព័រទស្សនាវដ្ដីកម្ពុជសុរិយា ដោយស្នើសុំឱ្យចងក្រងបោះពុម្ពជាសៀវភៅ សម្រាប់ការសិក្សាកម្រិតខ្ពស់ នៅថ្នាក់ពុទ្ធិកឧត្ដមសិក្សាវិញ ។

វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ សូមលើកយកមកចុះផ្សាយ នូវសំណើផ្អាកការចុះផ្សាយរបស់ក្រសួងធម្មការ និង សាសនា នោះទាំងស្រុង ។

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងធម្មការ និង សាសនា**

លេខ : ៣៩៧ ក.ធ.ស

**សូមជម្រាបមក**

លោកនាយកពុទ្ធសាសនបណ្ឌិត្យ

**កម្មវត្ថុ :** ស្នើផ្អាកការចុះផ្សាយអត្ថបទ " **ព្រះបរមត្ថមញ្ជុសា វិសុទ្ធិមគ្គមហាដីកា** " រៀបរៀងដោយលោក សួន ឱសថ ក្នុងទស្សនាវដ្ដីកម្ពុជសុរិយា ។

ចំពោះសេចក្ដីដូចមានចែងក្នុងកម្មវត្ថុខាងលើនេះ ខ្ញុំសូមជម្រាបលោកនាយកថា អត្ថបទមានអត្ថន័យជ្រាលជ្រៅ សម្រាប់អ្នកចេះដឹងភាសាបាលីអ្នកស្រាវ-ជ្រាវខាងពុទ្ធសាសនាមានកម្រិតខ្ពស់ ។ រីឯអ្នកអានទស្សនាវដ្ដី យើងភាគច្រើននាពេលបច្ចុប្បន្ន នៅមានកម្រិតយល់ដឹងក្នុងវិស័យនេះ មិនទាន់ដល់កម្រិតនោះទេ ។

អាស្រ័យហេតុនេះ ខ្ញុំស្នើឱ្យលោកនាយកជម្រាបលោក សួន ឱសថ សុំឱ្យរៀបចំអត្ថបទ " ព្រះបរមត្ថមញ្ជុសា វិសុទ្ធិមគ្គមហាដីកា" ចងក្រងបោះពុម្ពធ្វើសៀវភៅ សម្រាប់បម្រើការសិក្សាកម្រិតខ្ពស់នៅថ្នាក់ ពុទ្ធិកឧត្ដមសិក្សាវិញ ហើយផ្អាកការចុះផ្សាយជាផ្នែក១ខ្ទី១ ក្នុងកម្ពុជសុរិយា ដើម្បីទុកទំព័រចុះផ្សាយអត្ថបទទាំងឡាយ មានអត្ថរសអប់រំចរិយាធម៌ និងសីលធម៌ ក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋយើងជាជំនួសវិញ ។

សូមលោកនាយក ទទួលនូវសេចក្ដី ស្រឡាញ់រាប់អានដ៏ស្មោះសររបស់ខ្ញុំ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០២

ជ. **រដ្ឋមន្ត្រី**

ឯកឧត្ដម **ឈន អៀម**

# សេចក្តីកែតម្រូវអក្ខរាវិរុទ្ធ ត្រង់អន្លើខ្លះនៃអត្ថបទ
# "ការរីកចម្រើននៃព្រះពុទ្ធសាសនា ក្នុងជីវិតខ្មែរ"

| ល.រ | ពាក្យខុស | ពាក្យត្រូវ | បន្ទាត់ | ទំព័រ |
|---|---|---|---|---|
| ១ | សាមណេ | សាមណេរ | ៦ | ៤៩ |
| ២ | បែ លួង | បែល ឡុង | ១៣ | ៥១ |
| ៣ | ភ្នំពេញ ទំព័រ ២៧២២ | ភ្នំពេញ ឆ្នាំ ១៩៥៧ ទំព័រ ២៧-២៨ | ២០ | ៥១ |
| ៤ | ព្រះគ្រូសូត្រសត្ថា បុណ្យ សមាជ | ព្រះគ្រូសង្ឃសត្ថា ប៉ុណ្យ សុម្កាជ | ៥ | ៥២ |
| ៥ | លោក តាន់ ប៊ូរ ហេង | លោក តាន់ ចូ ហេង | ៦ | ៥២ |
| ៦ | (វីរប្បញ្ញោ) | (វិជីរប្បញ្ញោ) | ១៤ | ៥២ |
| ៧ | ជាអ្នកសង្កេតការ | ជាអ្នកសង្កេតការណ៍ | ១៧ | ៥២ |
| ៨ | ទីក្រុងរង្ហូន | ទីក្រុងរង្គូន | ១២ | ៥៣ |
| ៩ | បុណ្យ សម្ជាជ | ប៉ុណ្យ សុម្កាជ | ១៣ | ៥៣ |
| ១០ | ទស្សវត្តទី៥០នៃសតវត្សន៍ ទី ២០ | ទសវត្សទី៥០នៃសតវត្ស ទី ២០ | ៣ | ៥៤ |
| ១១ | ទស្សវត្តទី៥០នៃសតវត្សន៍ ទី ២០ | ទសវត្សទី៥០នៃសតវត្ស ទី ២០ | ៥ | ៥៤ |
| ១២ | ព្រះពុទ្ធសាសនា បុរាណ្យ | ព្រះពុទ្ធសាសនា បុរាណ | ១០ | ៥៤ |

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ



ប្រាសាទបុរាណ ធ្វើអំពីឥដ្ឋ និងថ្មបាយក្រៀម ( ស្វាយរៀង )


ឆ្នាំទី ៥៦ លេខ ៣ ខែ កក្កដា_ សីហា _ កញ្ញា

ព.ស. ២៥៤៦ គ.ស. ២០០២

ភ្នំពេញ

រូបក្របខាងក្រៅៈ *ប្រាសាទបុរាណ ធ្វើអំពីឥដ្ឋ និងថ្មបាយក្រៀម ស្ថិតនៅភូមិព្រៃក្តី ឃុំគគីរ ស្រុករមាសហែក ខេត្តស្វាយរៀង ជាប់នឹងព្រំប្រទល់ប្រទេសវៀតណាម ។*

*តាមការស៊ើបសួរពត៌មាន ពីអ្នកឯកទេសខាងប្រាសាទបុរាណ បានឱ្យដឹងថា ប្រាសាទនេះពុំទាន់បានចុះក្នុងបញ្ជីសារពើភ័ណ្ឌជាតិនៅឡើយទេ ។ ប្រជាពលរដ្ឋដែលរស់នៅទីនោះហៅថា "ទួលប្រាសាទ" ។*

រូបថតៈ ខៀវ បញ្ញារ៉ុឋ

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ

ចេញរាល់ត្រីមាស ពីវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

ចាត់ចែងបោះពុម្ពផ្សាយដោយគណៈកម្មការមួយ មាន :

នាយកការផ្សាយ : **ខូន វ៉ាន់ចន្ទី**

និពន្ធនាយក : **ខៀវ បញ្ញាវុឌ្ឍ**

គណៈកម្មការនិពន្ធ

លោកបណ្ឌិតទស្សនវិជ្ជា **ឆយ យីហ៊ាន** លោក **ម៉ែន ប្រាជ**

លោក **ខង់ សុធារ៉ា** លោក **ឆន់ ហ៊ិន.**

លោក **មៀច ប៉ុណ្ណ** លោក **ពិ ប៊ុន្នីន**

## គណៈកម្មការពិគ្រោះយោបល់

- លោកព្រឹទ្ធាចារ្យ **ឆេង ផុន** ប្រធានមជ្ឈមណ្ឌលវប្បធម៌ និងវិបស្សនា
- ឯកឧត្តម **នុត ណារ៉ាង** ប្រធានមជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ
- ឯកឧត្តម **ជា សាវឿន** រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា
- ឯកឧត្តម **ឈន អឿម** រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា
- លោកបណ្ឌិតសាស្ត្រាចារ្យ **ឡុង សៀម** នាយកវិជ្ជាស្ថានជាតិខាងភាសា
- លោកបណ្ឌិតទស្សនវិជ្ជា **ឆយ យីហ៊ាង** ទីប្រឹក្សារាជរដ្ឋាភិបាល ទទួលបន្ទុកការងារអប់រំ, ព្រឹទ្ធបុរសដេប៉ាតឺម៉ង់ទស្សនវិជ្ជា និងក្រុមការងាររាជបណ្ឌិតសភាកម្ពុជា
- លោកបណ្ឌិត **នេត បារ៉ុម** សកលវិទ្យាធិការរង នៃសកលវិទ្យាល័យភូមិន្ទភ្នំពេញ ។

---


- បោះពុម្ពផ្សាយដោយប្រើថវិកាបានពីការលក់សៀវភៅនានា ដែលក្រុមប្រឹក្សាពិភពលោកដើម្បីសាសនា និងសន្តិភាព ( WCRP ) នៃប្រទេសជប៉ុន បានឧបត្ថម្ភ។
- **The puplication of this issue has been made possible by the fund earned the sale of books supported by the WCRP/Japan.**

# មាតិកាអត្ថបទ

## I. អក្សរសិល្ប៍ពុទ្ធសាសនា :


- ជីវិតមនុស្ស និងបញ្ហា (ត) .................. (ឈន អៀម) ១


## II. អក្សរសាស្ត្រទូទៅ និង អក្សរសិល្ប៍ខ្មែរ :


- អក្សរខ្មែរ........................ (សម្តេច ជួនណាត) ១៣
- អនុសាសន៍ ........................... ១៨
- វប្បធម៌សិល្ប: និងវឌ្ឍនភាពសង្គមខ្មែរ .... (ព្រឹទ្ធាចារ្យ ឆេង ផុន) ២១
- គុណភាពអប់រំ........................ (ឆយ យីហ៊ាង) ៣២
- សីលធម៌ព្រះពុទ្ធសាសនា ....(ត) ............ (ខ្លូត ធីតា) ៤៥
- វិធីសាស្ត្រក្នុងការស្រាវជ្រាវ.....(តចប់) ......... (នេត បារ៉ុម) ៥២
- អត្ថបទសិលាចារឹក បាលីចាស់ជាងគេបំផុត .....(មី សែល ត្រាណេ) ៦៥
- អំពីការបេះឃ្មុំ...................... (មៀច ប៉ុណ្ណ) ៧៣
- ឱសថបុរាណខ្មែរ .....(ត) ............... (សួន ឱសថ) ៨៥


## III. កំណត់ និងប្រវត្តិការណ៍ :


- ទស្សនៈព្រះពុទ្ធសាសនា និងការអភិរក្ស.......... (ឈន អៀម) ៨៨
- សង្ឃប្រកាស............................. ៩៧
- ព្រះរាជក្រឹត្យ ............................ ១០១


## IV. ទំព័រឆ្លើយឆ្លងជាមួយកម្ពុជសុរិយា


- លិខិតថ្លែងអំណរគុណ ...................... ១០៣

# ជីវិតមនុស្ស និង បញ្ហា

(ត)

បណ្ឌិត ក. ស្រី ធម្មានន្ទ

បកប្រែ : **ឈន អៀម**

## ដំបូន្មានរបស់ព្រះពុទ្ធចំពោះគ្រួស្រករ

**ចំពោះភរិយា**

ក្នុងការផ្ដល់ដំបូន្មានដល់ស្ត្រីស្ដីពីតួនាទីក្នុងជីវិតអាពាហ៍ពិពាហ៍. ព្រះពុទ្ធទ្រង់បានសរសើរនូវហេតុដែលថា សន្តិភាព និងសុខដុមភាពនៃគ្រួសារ ឋិតនៅយ៉ាងទូលំទូលាយក្នុងដៃស្ត្រី ។ ដំបូន្មានរបស់ព្រះពុទ្ធអង្គគឺ ជាក់ស្ដែង និងប្រាកដប្រជានៅពេលដែលព្រះអង្គបានពន្យល់អំពីចរិតលក្ខណៈប្រចាំថ្ងៃមួយចំនួន ដែលស្ត្រីម្នាក់ត្រូវបណ្ដុះបណ្ដាលឱ្យមាន ឬមិនត្រូវឱ្យមាន ។ នៅក្នុងឱកាសផ្សេងៗជាច្រើន. ព្រះពុទ្ធបានប្រៀនប្រដៅថា ស្ត្រីជាភរិយា :

- មិនត្រូវចិញ្ចឹមគំនិតអាក្រក់ប្រឆាំងប្ដីរបស់ខ្លួនទេ.
- មិនត្រូវកោងកាច. រឹងរូស ឬត្រួតត្រាលើប្ដីទេ.
- មិនត្រូវចាយវាយខ្ជះខ្ជាយ. ប៉ុន្តែត្រូវចេះសន្សំសំចៃ និងត្រូវរស់នៅក្នុងរង្វង់មធ្យោបាយដែលមាន.
- ត្រូវថែរក្សា និងសន្សំប្រាក់កាស និងទ្រព្យធនរកបានដោយលំបាករបស់ប្ដី.
- ត្រូវប្រុងប្រយ័ត្នជានិច្ច ហើយជ្រះស្រឡះក្នុងចិត្ត និងក្នុងសកម្មភាព.
- ត្រូវស្មោះត្រង់ និងមិនត្រូវចិញ្ចឹមចិត្តគិតផិតក្បត់ប្ដីឡើយ.

- ត្រូវនិយាយពាក្យសំដីពីរោះពិសា និងធ្វើអំពើត្រឹមត្រូវ.
- ត្រូវសប្បុរស ឧស្សាហ៍ និងខ្នះខ្នែងធ្វើការងារ.
- ត្រូវចេះគិតគូរ និងមានចិត្តអាណិតអាសូរចំពោះប្ដី.
- ត្រូវរស់នៅសមរម្យ និងមានសេចក្ដីគោរពពីអ្នកដទៃ.
- ត្រូវមានចិត្តត្រជាក់. ស្ងប់ស្ងៀម និងយោគយល់បំរើមិនគ្រាន់តែក្នុងឋានៈជាប្រពន្ធម្នាក់ប៉ុណ្ណោះទេ ប៉ុន្តែក្នុងឋានៈជាមិត្តម្នាក់ និងជាទីប្រឹក្សាម្នាក់ កាលណាមានការចាំបាច់ ។

យោងតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ. នៅក្នុងរឿងអាពាហ៍ពិពាហ៍. ប្ដីអាចចង់បានប្រពន្ធដែលមានគុណសម្បត្តិដូចតទៅនេះ ÷

‑ **ស្នេហា**

ស្នេហាជ្រាលជ្រៅ និងស្មោះត្រង់ គឺជាការបង្ហាញឱ្យឃើញចំណង់ និងចំណូលចិត្តផ្ទាល់ខ្លួន កើតឡើងខ្លួនឯងប្រកបដោយអារម្មណ៍រំភើបបំផុត ដែលប្ដីចង់បានពីប្រពន្ធរបស់ខ្លួន ។ នេះឯងគឺជាគន្លឹះនៃទំនាក់ទំនងដ៏ស្និតល្មួតទៅវិញទៅមកជាមួយគ្នាអស់មួយជីវិត ហើយក៏ជាមធ្យោបាយបង្កើតជាកូនពូនជាចៅ ដែលគេទាំងពីរនាក់ត្រូវស្រឡាញ់ និងថ្នាក់ថ្នមនៅក្នុងអាយុកាលរបស់ពួកគេ ។ ក្នុងទីនេះស្នេហា មិនកំណត់ត្រឹមន័យស្រឡាញ់ ឬជាប់ជំពាក់ចិត្តប៉ុណ្ណោះទេ. ប៉ុន្តែស្នេហានេះគឺជាគុណភាពនៃសេចក្ដីប្រាថ្នាជ្រួតជ្រាបជ្រៅ ចង់បានសុខមាលភាពពិតប្រាកដដែលប្ដីនាងចង់បាន ។

‑ **យកចិត្តទុកដាក់**

ចេះយកចិត្តទុកដាក់. ភ្ញាក់រលឹក និងរវៀសរវៃ ព្រមទាំងចេះផ្ដល់សេចក្ដីថ្នាក់ថ្នមឥតងាករេ ចំពោះសេចក្ដីត្រូវការរបស់ប្ដីនាង ។

- **ភារពកិច្ចគ្រួសារ**

ក្រៅពីការបំពេញករណីយកិច្ច និងការទទួលខុសត្រូវរបស់គ្រួសារផ្ទាល់ខ្លួនជាប្តីប្រពន្ធហើយ, ភរិយាត្រូវចេះផ្តល់កិត្តិយស និងសេចក្តីគោរពចំពោះឪពុក-ម្តាយក្មេក និងញាតិសន្តានខាងប្តីផងដែរ ហើយត្រូវបម្រើថ្នាក់ថ្នមឪពុកម្តាយក្មេក បីដូចខ្លួននាងបម្រើថ្នាក់ថ្នមឪពុក-ម្តាយផ្ទាល់របស់នាង ។

- **ភក្តីភាព**

ភក្តីភាពតែងឋិតជាប់នឹងភាពបរិសុទ្ធ, ភាពស្មោះត្រង់ និងភាពនឹងនក្នុងចិត្តឥតឃ្លេងឃ្លោងរបស់ភរិយា ។ ភក្តីភាពសំដៅន័យផងដែរ ដល់ភាពជាស្ត្រីគួរជាទីទុកចិត្ត ហើយផ្តល់សេចក្តីស្មោះសរជាប្រចាំដល់ស្វាមីរបស់នាង ។

- **ថែរក្សាកូន**

សេចក្តីស្នេហារបស់ម្តាយ គឺជាគ្រឹះមូលដ្ឋាននៃសេចក្តីស្នេហាទាំងអស់ក្នុងលោក ។ ក្នុងឋានៈជាមាតាដ៏មានភក្តីម្នាក់, នាងជាមាតា តាមរយៈ សភាវគតិរបស់នាងជាម្តាយ សូម្បីតែការងារខ្លះមានគ្រោះថ្នាក់ដល់ជីវិតក្តី ក៏មិនរួញរាដើម្បីការពារកូនតែមួយរបស់នាងដែរ ។

- **សេចក្តីសន្សំសំចៃ**

នៅពេល ដែលភរិយាត្រូវបានប្រគល់ឱ្យការងារជាអ្នកគ្រប់គ្រងផ្ទះហើយ វាជាករណីយកិច្ចរបស់នាងដើម្បីគិតគូរមើលថា តើការចាយវាយប្រាក់កាសសម្រាប់គ្រួសារឋិតនៅក្នុងរង្វង់ថវិកាគ្រួសារដែលប្តីរកបានឬទេ ។ ដើម្បីបំពេញការងារនេះបាន ភរិយាត្រូវចេះសន្សំសំចៃលើការចាយវាយ ហើយអនុវត្តការត្បិតត្បៀតប៉ុន្តែនៅតែរក្សាបានការហូបចុកគ្រប់គ្រាន់ ទោះបីជាត្បិតត្បៀតយ៉ាងនេះក្តី ។

- **ការផ្គត់ផ្គង់ចំណីអាហារ**

ក្នុងឋានៈជាមេផ្ទះ វាជាករណីយកិច្ចរបស់ភរិយាដើម្បីរៀបចំចំណី អាហារមានរសជាតិឆ្ងាញ់ពិសារ សម្រាប់គ្រួសារ ។ អាហារសម្រាប់គ្រួសារ គឺជាព្រឹត្តិការណ៍សំខាន់មួយប្រចាំថ្ងៃ ពិព្រោះវាជួយពង្រីកសុធន្ទៈ និងការរួមរស់នៅជាមួយគ្នា ។

- **ជួយប្ដីឱ្យស្ងប់អារម្មណ៍ពេលគាត់មានសេចក្ដីកង្វល់ចិត្ត :**

ពេលប្ដីត្រឡប់មកផ្ទះវិញក្នុងស្ថានភាពរំជើបរំជួលចិត្ត, ប្រពន្ធត្រូវសម្ដែងអាកប្បកិរិយារួសរាយរាក់ទាក់ ដើម្បីរម្ងាប់អារម្មណ៍ និងលួងលោមប្ដី ។ អាកប្បកិរិយានេះ នឹងជួយសម្រួលស្ថានភាពក្នុងគ្រួសារ ។

- **ភាពផ្អែមល្ហែមក្នុងគ្រប់ស្ថានភាព**

ក្រៅអំពីការសំដែងអារម្មណ៍ជាទីមេត្រី និងឥរិយាបថទន់ភ្លន់, ភរិយាត្រូវមានទឹកមុខញញឹមប្រិមប្រិយ, មានអារម្មណ៍រីករាយជានិច្ច, មានអាកប្បកិរិយារួសរាយ និងទាក់ទាញចិត្ត ។

**<u>ចំពោះប្ដី</u>**

ព្រះពុទ្ធក្នុងពេលមានបន្ទូលតបទៅនឹងស្ត្រីជាមេផ្ទះម្នាក់ថា តើប្ដីគប្បីជួយប្រពន្ធរបស់ខ្លួនយ៉ាងម៉េច, ទ្រង់បានប្រកាសថា ប្ដីគប្បីផ្ដល់កិត្តិយស និងគោរពប្រពន្ធខ្លួនជានិច្ច ដោយត្រូវមានភក្ដីភាពចំពោះប្រពន្ធ, ដោយផ្ដល់ឱ្យប្រពន្ធមានអំណាចចាំបាច់ ដើម្បីគ្រប់គ្រងកិច្ចការផ្ទះសម្បែង និងដោយផ្ដល់ឱ្យប្រពន្ធនូវគ្រឿងអលង្ការសមរម្យ ។ ដំបូន្មាននេះទ្រង់បានប្រទានឱ្យជាងម្ភៃប្រាំសតវត្សកន្លងទៅហើយ ប៉ុន្តែនៅតែត្រឹមត្រូវ រហូតមកដល់សព្វថ្ងៃ ។

អស់កាលជាច្រើនសតវត្សហើយ, សង្គមដែលគ្របដណ្ដប់ដោយបុរសភេទ

បានប្រកាន់ខ្ជាប់នូវរឿងប្រឌិតដែលថា បុរសមានឧត្តមភាពជាងស្ត្រី ប៉ុន្តែព្រះពុទ្ធបានធ្វើឱ្យការកត់សំគាល់មួយនេះប្រែប្រួល ហើយទ្រង់បានលើកស្ទួយឋានៈស្ត្រីឱ្យខ្ពស់ឡើង ដោយគ្រាន់តែផ្តល់ព្រះយោបល់ដ៏សាមញ្ញថា ប្តីគប្បីផ្តល់កិត្តិយស និងគោរពប្រពន្ធរបស់ខ្លួន ។ ការកត់សម្គាល់បែបនេះ អាចជាពាក្យធម្មតាសព្វថ្ងៃនេះ, ប៉ុន្តែកាលណាយើងរំពឹងគិតថា ពាក្យនេះត្រូវបានពោលឡើងនៅក្នុងប្រទេសឥណ្ឌាតាំងពីជាង ២៥០០ ឆ្នាំកន្លងទៅហើយ, ពាក្យនេះមានន័យបដិវត្តមិនតិចទេ !

ប្តីត្រូវមានចិត្តភក្តីចំពោះប្រពន្ធខ្លួន ដែលមានន័យថា ប្តីត្រូវបំពេញនិងទ្រទ្រង់ កាតព្វកិច្ចអាពាហ៍ពិពាហ៍របស់ខ្លួនចំពោះប្រពន្ធ ខ្លួនដូច្នេះធ្វើឱ្យទំនុកចិត្តក្នុងបំណងអាពាហ៍ពិពាហ៍មានចិរភាពឋិតថេរក្នុងគ្រប់ន័យនៃពាក្យ ។

ប្តីក្នុងឋានៈជាអ្នកចិញ្ចឹមគ្រួសារ តែងចាកចេញឆ្ងាយពីផ្ទះជាញឹកញាយ, ហេតុនេះប្តីត្រូវបន្ទុកបណ្តាក់កិច្ចការផ្ទះ ឬកិច្ចការគ្រួសារឱ្យប្រពន្ធ ដែលត្រូវបានចាត់ទុកជាឆ្នាំ ឬជាអ្នកគ្រប់គ្រងទ្រព្យសម្បត្តិរបស់ពួកគេ និងជាអ្នកអភិបាលសេដ្ឋកិច្ចផ្ទះសម្បែង ។

ការផ្តល់គ្រឿងអលង្ការសមរម្យដល់ប្រពន្ធ គប្បីបានជានិមិត្តរូបនៃសេចក្តីស្នេហា. ការថ្នាក់ថ្នម និងការកោតសរសើររបស់ប្តី សំដែងឡើងចំពោះប្រពន្ធ ។ ការអនុវត្តជានិមិត្តរូបនេះ ត្រូវបានគេប្រព្រឹត្តធ្វើមកតាំងពីពេលយូរលង់មកហើយ នៅក្នុងបណ្តាសហគមន៍ពុទ្ធសាសនិក ។

ជាអកុសល សព្វថ្ងៃប្រពៃណីនេះកំពុងឋិតក្នុងគ្រោះថ្នាក់នៃការបាត់បង់តម្លៃ ដោយសារតែមានឥទ្ធិពលបញ្ច្រាសទិស នៃបែបបទជីវភាពសម័យថ្មី ។

សេចក្តីសង្ឃឹមរបស់ប្រពន្ធ អំពីប្តីគឺ :

- **មុទិតា** (Tenderness )

មានភាពទន់ភ្លន់ និងផ្ដល់សេចក្ដីគោរពចំពោះប្រពន្ធ លើគ្រប់កិច្ចការកាលណាត្រូវបំពេញបំណងរបស់នាង ៖

‑ **គារវតា** (courtersy )

មានសេចក្ដីគួរសម, សុភាព រាបសារ, ដាក់ខ្លួនក្នុងការទាក់ទង ឬពិគ្រោះយោបល់ជាមួយប្រពន្ធ ៖

‑ **សមានត្តតា** (Sociability )

មានភាពរីករាយ, រាក់ទាក់, ស្និទ្ធស្នាល និងចុះសម្រុងគ្នាគ្រប់ពេលវេលាជាមួយប្រពន្ធរបស់ខ្លួន ក្នុងពេលមានមិត្តភ័ក្តិ ឬភ្ញៀវរបស់ពួកគេមកលេងផ្ទះ ។

‑ **រក្ខា ឬគុត្តិ** ( ការថែរក្សាឬការគ្រប់គ្រង ) (security )

គោលបំណងធំ ដែលភរិយាម្នាក់ស្វែងរកក្នុងអាពាហ៍ពិពាហ៍របស់នាង គឺការថែរក្សាស្ងួនគ្រង ដែលប្ដីនាងត្រូវផ្ដល់ឱ្យ ។

ក្នុងទិដ្ឋភាពនេះ ប្ដីត្រូវបានប្រពន្ធរំពឹងទុកដូចជាប៉មការពារមួយ ដើម្បីទប់ទល់ការគំរាមគំហែងគ្រប់រូបភាពពីខាងក្រៅមកលើគ្រួសារ និងដើម្បីផ្ដល់ដល់គ្រួសារនូវកិច្ចការពារ និងសន្តិសុខសមស្របគ្រប់ពេលវេលា ។

‑ **អជ្ជវតា** (Fairness)

ក្នុងឋានៈជាស្វាមីមានសេចក្ដីទទួលខុសត្រូវម្នាក់, គេត្រូវចេះលើកលែងទោស, មានសេចក្ដីសន្ដោស និងមានចិត្តអាណិតអាសូរ ក៏ដូចជាមានចិត្តសប្បុរសចំពោះហេតុដែលគួរផ្ដល់សេចក្ដីសង្គ្រោះ ។ ក្នុងឋានៈជាឪពុកម្នាក់, គេត្រូវមានយុត្តិធម៌ និងត្រូវមានសេចក្ដីត្រិះរិះចំពោះសំណូមពររបស់កូនទាំងឡាយ ដែលកាន់តែចម្រើនវ័យធំឡើង ។

‑ **ភក្តីភាព** (Loyalty)

ក្នុងឋានៈជាស្វាមីមានសេចក្តីយោគយល់ម្នាក់. គេត្រូវផ្តល់ភក្តីភាពឥតងាករេចំពោះប្រពន្ធរបស់ខ្លួន ហើយឋិតនៅជាមួយប្រពន្ធខ្លួនជានិច្ច ឆ្លងកាត់ព្យុហ៍ព្យោមា ក្រោមស្ថានភាពវិបត្តិណាមួយប្រឈមមុខគ្រួសារខ្លួន ។

គេត្រូវមានចិត្តនឹងនខ្ជាប់ខ្លួនក្នុងគោលការណ៍របស់ខ្លួន ហើយជាបុរសម្នាក់ ដែលភរិយាមានទំនុកចិត្តទាំងស្រុង អាចពឹងផ្អែកបានក្នុងការប្រឈមមុខចំពោះយថាហេតុអាក្រក់ ។

‑ **ភាពស្មោះត្រង់** (honesty )

ជាប្តីម្នាក់មានស្មារតីទទួលខុសត្រូវ. គេត្រូវស្មោះត្រង់ និងគ្មានគំនិតវៀចវេរជាមួយប្រពន្ធក្នុងគ្រប់ការងារ ដែលប៉ះពាល់ខ្លួនគេផ្ទាល់ និងកូនចៅរបស់គេ ។ គេមិនត្រូវលាក់អាថ៌កំបាំងមិនឱ្យប្រពន្ធដឹងទេ. ពីព្រោះអំពើនេះ នឹងនាំឱ្យរង្គោះរង្គើទំនុកចិត្ត និងជំនឿរបស់នាងចំពោះប្តី ។

‑ **មិត្តភាពល្អ** (Good companionship )

ប្តីគប្បីមានបុគ្គលភាពរួសរាយរាក់ទាក់ ហើយមានសមត្ថភាពចូលចុះជាមួយមនុស្សគ្រប់ប្រភេទ ។ គេត្រូវមានចំណេះសមល្មមដើម្បីអាចចូលរួមក្នុងការសន្ទនាដេញដោលនៅគ្រប់កីរិតនៃសង្គម ហើយជាមនុស្សអាចពឹងពាក់បាន ពេលគេត្រូវការជំនួយ ។ គេត្រូវមានអារម្មណ៍ល្អចេះកំប្លែងធ្វើឱ្យអ្នកស្តាប់ជាប់អារម្មណ៍នាំឱ្យគេចូលចិត្តចងមិត្ត ។

‑ **ការគាំទ្រផ្លូវចិត្ត** (Moral support )

ក្នុងឋានៈជាប្តីមានស្មារតីទទួលខុសត្រូវម្នាក់. គេត្រូវឋិតនៅខាងប្រពន្ធដោយឥតងាករេរហូតអវសាននៃជីវិត ក្នុងការប្រឈមមុខចំពោះយថាហេតុដ៏

អាក្រក់ណាមួយដែលធ្លាក់មកលើនាង ហើយត្រូវផ្ដល់ការគាំទ្រផ្លូវចិត្ត និងការលើកទឹកចិត្តដែលចាំបាច់ដើម្បីជំនះស្ថានភាពបែបនេះ ។

### ចំពោះប្ដី និងប្រពន្ធ

ប្ដីត្រូវបានគេទទួលស្គាល់ជាមេគ្រួសារ វៀរលែងតែគាត់ខ្វះសមត្ថភាពបំពេញករណីយកិច្ចរបស់គាត់ដូចនេះ ។ ទាំងនៅក្នុងច្បាប់សាមញ្ញ ទាំងនៅក្រោមនីតិកម្មសម័យថ្មី ប្ដីតាមគោលការណ៍ច្បាប់ត្រូវឧបត្ថម្ភប្រពន្ធ និងគ្រួសារខ្លួន. ទោះបីមានហេតុជាក់ស្ដែងថា ប្រពន្ធមានទ្រព្យសម្បត្តិ ឬប្រាក់ចំណូលផ្ទាល់ខ្លួនរបស់នាងក្ដី ឬមានសមត្ថភាពចិញ្ចឹមជីវិតផ្ទាល់ខ្លួនរបស់នាងក្ដី ។

សព្វថ្ងៃនេះ ដែលមានភរិយាជាច្រើនចេញធ្វើការ, ការចិញ្ចឹមគ្រួសារនៅតែជាការងាររួម ។ ប្ដីគ្មានហេតុផលដើម្បីគេចវេះករណីយកិច្ចផ្ទះសម្បែង, មិនជួយភរិយា និងមិនបណ្ដុះបណ្ដាលកូននោះទេ, ជាពិសេសកាលណាគ្មានអ្នកបម្រើជួយធ្វើការបែបនេះ ។

ក្រៅអំពីទិដ្ឋភាពចិត្តវេគ និងវិញ្ញាណារម្មណ៍, ប្ដី-ប្រពន្ធត្រូវថែទាំស្ថានភាពរស់នៅប្រចាំថ្ងៃ, ថវិកាគ្រួសារ និងកាតព្វកិច្ចសង្គមថែមទៀត ។

ដូច្នេះ, ការពិគ្រោះយោបល់គ្នាទៅវិញទៅមករវាងប្ដី និងប្រពន្ធលើបញ្ហាទាំងអស់ក្នុងគ្រួសារ នឹងបង្កើតឱ្យមានបរិយាកាសជឿទុកចិត្តគ្នា និងយោគយល់គ្នាមួយ ក្នុងការដោះស្រាយចំណោទអ្វីក៏ដោយ ដែលអាចកើតមានឡើង ។

### ករណីយកិច្ចប្រាំយ៉ាងរបស់ឪពុកម្ដាយ
### ចំពោះកូនរបស់ខ្លួន

ព្រះពុទ្ធបរមគ្រូបានកំណត់ករណីយកិច្ចប្រាំយ៉ាង ដែលឪពុក-ម្ដាយត្រូវ

អនុវត្តចំពោះកូនរបស់ខ្លួន ។

*- ករណីយកិច្ចទីមួយគឺទូន្មានកូនឱ្យជៀសវាងអំពើអាក្រក់*

ផ្ទះគឺជាសាលារៀនដំបូងគេ, ហើយឪពុក-ម្ដាយគឺជាគ្រូទីមួយ ។ តាមធម្មតា កូនទទួលយកមេរៀនដំបូងរបស់គេ ស្ដីពីអំពើល្អ និងអាក្រក់អំពីឪពុកម្ដាយ ។ បើឪពុក-ម្ដាយមានចរិតខ្ជីខ្ជា ដោយផ្ទាល់ក្ដី ឬដោយប្រយោលក្ដី គេមុខជាបានចម្លងចំណេះដឹងដំបូងខាងការនិយាយកុហក, ការបោកបញ្ឆោត, ការវៀចវេរ, ការមួលបង្កាច់, ការសងសិក, ភាពគ្មានសេចក្ដីខ្មាស់អៀន, ភាពគ្មានសេចក្ដីភ័យខ្លាចចំពោះអំពើអាក្រក់ និងសកម្មភាពអសីលធម៌, ដល់កូនរបស់គេនៅក្នុងវ័យក្មេងខ្ចី ។ ចូលចងចាំ ថាក្មេងមានទម្លាប់ត្រាប់តាម ។

ដូច្នេះឪពុក-ម្ដាយ ត្រូវបង្ហាញចរិយាជាគំរូ ហើយមិនត្រូវចម្លងអំពើអាក្រក់បែបនេះ ទៅក្នុងសន្ដានចិត្តងាយជិតដាមរបស់កូនខ្លួនឡើយ ។

*- ករណីយកិច្ចទីពីរ គឺត្រូវអប់រំណែនាំកូនឱ្យធ្វើល្អ*

ឪពុក-ម្ដាយគឺជាលោកគ្រូ - អ្នកគ្រូនៅផ្ទះ, លោកគ្រូ-អ្នកគ្រូ គឺជាឪពុកម្ដាយនៅសាលារៀន ។ ទាំងឪពុកម្ដាយ ទាំងលោកគ្រូ-អ្នកគ្រូមានភារកិច្ចទទួលខុសត្រូវស្មើគ្នា ចំពោះអនាគត និងសុខមាលភាពរបស់ក្មេងដែលក្លាយទៅអ្វី ដែលខ្លួនគេបានហាត់ពត់លត់ដំហើយ ។ គេកំពុងក្លាយ ហើយនឹងក្លាយទៅជាអ្វីដូចមនុស្សពេញវ័យដទៃទៀត ។ គេអង្គុយក្បែរជើងមនុស្សពេញវ័យ ក្នុងអឡុងវ័យផ្ចិតយកអារម្មណ៍របស់គេ ។

គេក្រេបជញ្ជក់យកនូវអ្វីដែលគេចម្លងឱ្យ ។ គេដើរតាមយ៉ាងក្បៀកកិតពីក្រោយ ។ គេទទួលឥទ្ធិពលនៅក្នុងគំនិត ក្នុងពាក្យសំដីនិងក្នុងអំពើរបស់គេ ។ ដោយប្រការយ៉ាងនេះ, ឪពុក-ម្ដាយត្រូវមានករណីយកិច្ចបង្កើតនូវបរិយាកាស

សប្បាយរីករាយបំផុត ទាំងនៅក្នុងផ្ទះទាំងនៅក្នុងសាលារៀន ។

ភាពសាមញ្ញ, ភាពទន់ភ្លន់, សហប្រតិបត្តិការ, ឯកភាព, អត្តបរិច្ចាគ, សុចរិត, ទៀងត្រង់, ការបម្រើ, ជំនឿទុកចិត្តលើខ្លួនឯង, សន្ដោស, ចរិយាឫកពាល្អ ជំនឿសាសនា, និងគុណធម៌ពាក់ព័ន្ធដទៃទៀត គប្បីត្រូវបានផ្សាំភ្ញាស់បណ្ដុះក្នុងយុវសន្តានចិត្តបន្តិចម្ដងៗ ។ ពូជបណ្ដុះផ្សាំភ្ញាស់ដូចនេះ នឹងដុះធំធាត់ឡើងទៅជាដើមឈើមានផ្កាផ្លែល្អ ។

*- ករណីយកិច្ចទីបីគឺត្រូវផ្ដល់ការអប់រំល្អដល់កូន*

ការអប់រំត្រឹមត្រូវល្អ គឺជាមរតកដ៏ប្រសើរ ដែលឪពុក-ម្ដាយចែកទៅឱ្យកូន ។ គ្មានកំណប់ទ្រព្យណាមានតម្លៃជាងឡើយ ។ វាជាពរមហាប្រសើរ ដែលឪពុកម្ដាយបាចសាចទៅលើកូនរបស់ខ្លួន ។

ការអប់រំដែលត្រូវផ្ដល់ទៅឱ្យកូន គួរគប្បីធ្វើតាំងពីវ័យនៅក្មេង ក្នុងបរិយាកាសសាសនាមួយ ដោយហាត់ពត់កូនឱ្យប្រកាន់យកវិន័យថ្លៃថ្នូរជាមនុស្ស និងគុណធម៌មានសន្ដានចិត្តអាណិតអាសូរ ។ ការអប់រំនេះ មានប្រសិទ្ធភាពវែងឆ្ងាយទៅលើជីវភាពរស់នៅរបស់កូន ។

*- ករណីយកិច្ចទីបួនគឺត្រូវគិតគូរឱ្យកូនរៀបអាពាហ៍ពិពាហ៍ជាមួយបុគ្គលសមស្រប*

អាពាហ៍ពិពាហ៍គឺជាសកម្មភាពដ៏ឱឡារិកមួយភ្ជាប់ទៅ នឹងអាយុកាលទាំងមូលរបស់មនុស្សម្នាក់ៗ ។ ការរួមរស់នេះត្រូវតែជាការរួមរស់មួយ ដែលគេមិនអាចរំលាយចោល ដោយងាយស្រួលបានឡើយ ។ ហេតុនេះ, អាពាហ៍ពិពាហ៍ ត្រូវបានគេពិនិត្យមើលអំពីជ្រុងនីមួយៗ និងក្នុងទិដ្ឋភាពរបស់វាទាំងអស់ទាល់តែពេញចិត្តភាគីទាំងអស់ដែលពាក់ព័ន្ធមុនពេលរៀបអាពាហ៍ពិពាហ៍ ។

ការសង្កេតមើលរបស់ឪពុក-ម្ដាយនូវជីវភាពរស់នៅរបស់ដៃគូនៃកូនរបស់គេ គឺមានសារសំខាន់ណាស់ សម្រាប់ជីវភាពអាពាហ៍ពិពាហ៍អនាគតរបស់ពួកគេ ។ នៅពេលឪពុក-ម្ដាយ ត្រូវទទួលយកបែបបទសម័យថ្មី ដូចជាការណាត់ជួបគ្នា ជាដើម, កូនៗត្រូវដឹងច្បាស់ថា ឪពុក-ម្ដាយមានសិទ្ធិតាមឃ្លាំមើលសកម្មភាពរបស់ពួកគេ, ដឹងថាអ្នកណាជាមិត្រ ឬមិនមែនជាមិត្ររបស់ពួកគេ ។ ប៉ុន្តែ, កូនៗក៏ត្រូវមានសិទ្ធិឯកជន និងសេចក្ដីគោរពខ្លួនឯងផងដែរ ។

យោងតាមវប្បធម៌ពុទ្ធសាសនា *ករណីយកិច្ចជំនួសសិទ្ធ* ។ សូមភាគីទាំងពីរកុំចចេសពេក, ប៉ុន្តែត្រូវចេះប្រើបដិភាណៈ (ប្រាជ្ញាវៃឆ្លាត) ប្រកបដោយគតិបណ្ឌិតរបស់ខ្លួន ហើយដោះស្រាយបញ្ហាជាមិត្តភាព ។

បើពុំនោះទេ មុខជានឹងមានបណ្ដាសាទោវិញទៅមកនិងផលវិបាកផ្សេងៗទៀត ។ ជាញឹកញយពេកណាស់,ជម្ងឺ នឹងត្រូវបានឆ្លងទៅកូនចៅផងដែរ ។ គេនិយាយថាក្នុងករណីជាច្រើន មនុស្សដែលប្រព្រឹត្តការបំពារបំពានអ្នកដទៃ គឺជាអ្នកធ្លាប់រងគ្រោះការបំពារបំពានដោយខ្លួនឯង ។

*- ករណីយកិច្ចចុងក្រោយគឺការប្រគល់កេរមរតក ទៅឱ្យកូននៅពេលសមស្រប :*

ឪពុក-ម្ដាយមិនគ្រាន់តែស្រឡាញ់និងថ្នាក់ថ្នមកូនរបស់គេក្នុងអំឡុងកាលដែលកូនរបស់គេឋិតនៅក្រោមអាណាព្យាបាលរបស់គេនៅឡើយប៉ុណ្ណោះទេ ,ប៉ុន្តែបានរៀបចំសម្រាប់សេចក្ដីសប្បាយ និងសេចក្ដីសុខក្នុងពេលអនាគតថែមទៀត ។ ឪពុក-ម្ដាយរកទ្រព្យសម្បត្តិបានមក ដោយកំឡាំងខិតខំមិនខ្លាចនឿយហត់ផ្ទាល់ខ្លួន ហើយប្រគល់ទ្រព្យសម្បត្តិទាំងនោះ ឱ្យជាមរតកទៅកូនរបស់ខ្លួន ដោយគ្មានសេចក្ដីទើសទាល់ ។

ឪពុក-ម្តាយ ដែលចែករំលែកទ្រព្យរបស់ខ្លួនទៅឱ្យកូន. មិនចង់ឱ្យកូនរបស់ខ្លួនចាយខ្ជះខ្ជាយទ្រព្យនោះទេ ប៉ុន្តែឱ្យចេះប្រើទាញយកប្រយោជន៍អំពីមរតកនោះ ដើម្បីលើកស្ទួយកិរិតរស់នៅរបស់គេ ។ នៅក្នុងរឿងនេះ .ខ្សែបន្ទាត់បាតក្រោមគឺ ការគោរពគ្នាទៅវិញទៅមក និងសេចក្តីជាប់ជំពាក់ចំពោះសុខមាលភាពរបស់ឪពុក-ម្តាយ និងកូន ។

*សត្វដែលនឹងបានរួចចាកទុក្ខ*
*ព្រោះធុញទ្រាន់ជូរមុខ នឹងកើតស្លាប់*
*មានគំនិតដូចសត្វទទាជាប់*
*ក្នុងទ្រុងមិនគាប់ក្តីប្រាថ្នា ។*
*ចេះតែស្ទុះច្រាសច្រាលដាលចឹកទ្រុង*
*ចង់ឱ្យរលុងនឹងម្ទីម្ទា*
*ស្ទុះចេញឱ្យរួចហើយ នឹងលា*
*ត្រដាង ស្លាបវាហើយហើរទៅ ។*

សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយក
គណៈមហានិកាយ **ជួន ណាត** ជោតញ្ញាណោ

កំណាព្យ :

# អក្សរខ្មែរ

## កាព្យរំលឹកអំពីអក្សរខ្មែរ

( បទ ពាក្យ ៧ )

*កាព្យរំលឹកអំពីអក្សរខ្មែរ បទពាក្យប្រាំពីរនេះ យើងបានចម្លងចេញពីទស្សនាវដ្តី **ពន្លឺពុទ្ធចក្រ** នៃពុទ្ធិកសមាគមមជ្ឈមណ្ឌលកម្ពុជរដ្ឋ លេខ៣៤ ខែ មេសា ឧសភា មិថុនា ព.ស. ២៥១៣ គ.ស. ១៩៦៩ ទំព័រទី ៧-៨*

- អក្សរខ្មែររុងរឿងដោយសារខ្មែរ ពុំហ៊ានបំបែរឱ្យភ្លាត់ខុស
ជនខ្មែរគ្រប់គ្នាទាំងស្រីប្រុស ពុំហ៊ានបង្ហុសឱ្យខូចបង់ ។
- ជនខ្មែរស្រុះគ្នាលើកតម្កើង ដំឡើងពាក្យពេចន៍ដោយផ្ចិតផ្ចង់
ខ្មែរជាគ្រហស្ថ ខ្មែរជាសង្ឃ ខំប្រឹងតម្រង់អក្សរជាតិ ។
- អក្សរវិបត្តិជាតិវិបត្តិ ខ្ចាយខ្ចាត់រាត់រាយក្លាយឃ្លៀងឃ្លាត
ហេតុនេះខ្មែរយើងកុំរវាត ត្រូវរក្សាជាតិឱ្យរឹងប៉ឹង ។
- បើដឹងមិនដល់កុំធ្វើចេះ ចំណេះតិចតួចស្ទួចស្តើងស្តឹង
បើចង់ច្បាស់លាស់ត្រូវខំប្រឹង កុំដេកសម្ងឹងឱ្យចេះឯង ។
- ចំណេះកើតមានព្រោះការរៀន កម្ជិលអៀនប្រៀនកុំសម្តែង
ធ្វើឱ្យគេស្ញើចគេកោតក្រែង ស្លាក់ស្លែងទេកុំរិះគន់គេ ។
- ត្រូវរិះគន់ខ្លួនឯងជាមុន កុំឱ្យស៊័យស៊ុនខុសទទេ
បើឆ្ងល់ពុំយល់ត្រូវសួរគេ ឥតថោកអ្វីទេថ្លៃទេតើ ។

- បុរាណថាថោកអីនឹងដៃ ថ្លៃអីនឹងមាត់ពោលសើរើ
រៀនទៅសួរទៅទើបគ្រាន់បើ អើពើចង់ចេះប្រសើរណាស់ ។
- ចាស់ថាបើល្ងង់កុំធ្វើចេះ បើមានចំណេះឱ្យជាក់ច្បាស់
បើស្ដើងហើយចង់ឱ្យបានក្រាស់ ត្រូវថែមកម្រាស់ផ្សំសាច់គ្នា ។
- អបស្ដបប៉ះប៉ុនយកកម្រាស់ កុំចាំងកុំច្រាស់ហួសមាត្រា
ប៉ះផ្សំផ្គុំភ្ជិតទើបកើតជា ទោលឬបន្ទារ័មូនជាងមុន ។
- បើចេះអក្សរនិងភាសា នៃជាតិណា១កុំជ្រុលស៊ុន
ងាប់ស័ព្ទប្រែស្រាយក្លាយជាប់កុន សុនត្រុនប្រែស្រាយឃ្លាតក្ដីពិត ។
- កាលដែលប្រារព្ធនឹងប្រែស្រាយ ត្រូវគិតនាយអាយដោយពិនិត្យ
ឱ្យឃើញសេចក្ដីជាខ្មែរពិត សីមប្រែកុំផ្ចិតតាមពាក្យគេ ។
- ត្រូវប្រែឱ្យមកជាសេចក្ដី ដែលខ្មែរប្រុសស្រីអាចរិះរេ
ស្ដាប់យល់មិនឆ្ងល់ទើបហៅប្រែ ត្រឹមត្រូវតាមរូបសេចក្ដីពិត ។
- អ្នករៀនភាសាជនបរទេស ទ្វេធ្វេសដោយការឥតបើគិត
កាលខ្លួនកំពុងរៀនប្រឹងប្រិត ប្រែផ្ចិតឱ្យចំតាមរូបស័ព្ទ ។
- ភ្លេចនឹកគិតមកភាសាខ្លួន ឱ្យយល់សំនួនដែលងាយស្ដាប់
សម្លឹងសង្កេតតែរូបស័ព្ទ ក៏ស្រាប់តែប្រែខុសទាំងស្រុង ។
- អ្នករៀនសំស្រ្កឹត ឬបាលី ប្រែខុសសេចក្ដីព្រោះភ័ន្តផុង
យល់ខុសទទេទាំងដើមចុង ចូលក្នុងរឹងស៊ុងខ្វាសអ្នកផង ។
- *តិដ្ឋ:* បាលីប្រែថា *ឈរ* អ្នករៀនឈ្លក់វរភ័ន្តម្ដង១
ត្រង់មានសេចក្ដីថា *ស្ងួនគ្រង* ប្រែឆ្គងថា *ឈរ* ហៅងាប់ស័ព្ទ ។

- បារាំង *ពាក់គេគេសួរលៅគែត* ខ្មែរឆ្អែតចិត្តជាប់បែរប្រែប្រាប់
អ្នកដែលមិនចេះឱ្យគ្នាស្តាប់ បង្គាប់ថាឱ្យ *គាន់លើក្បាល* ។
- មិនប្រាប់ឱ្យគ្នាដឹងថា *ទូល* នេះហៅថាស្រមូលពុំត្រកាល
ពាក្យខ្មែរថា *ទូល* ក៏លើក្បាល ត្រអាលប្រែខុសពីពាក្យខ្លួន ។
- តែងកាព្យឱ្យត្រូវតាមសម្ពស្ស តាមកាព្យចាស់ៗដែលមានចួន
កុំចេះតែតែងតាមចិត្តខ្លួន ឱ្យកាព្យមានចួនខុសមាត្រា ។
- ពាក្យ *អឺយ* និង *អើយ*[១] សូរផ្សេងគ្នា ដូចជាប្អូន *អើយ*[២] ម្តេច *ឡើយ* ថា
ស្តាប់បងមិនឮឬស្ងួនភ្ងា ធ្វើជាមិនឮព្រោះរឹងខ្លួន ? ។
- *ព្រះបាទសម្តេចព្រះហរិរក្ស* ទ្រង់បានបញ្ជាក់ដោយផ្ទួនៗ
ក្នុងកាព្យព្រះអង្គដែលមានចួន សំនួនសម្ពស្សឥតមានឆ្គង ។
- កវីគួរតែយកតម្រាប់ ពុំគួរប្រញាប់កាត់រំលង
រំលុបបែបនោះមិនត្រាប់ត្រង ខុសពីបំណងអ្នកប្រាជ្ញចាស់ ។
- មានអ្នកតែងកាព្យខ្លះហ៊ានថា ម្តេចមិនវាចារឱ្យជាក់ច្បាស់
ប្រើកិរិយាស័ព្ទខុសណាស់ គួរផ្លាស់សម្តីនេះចោលចេញ ។ ល ។

១- អានថា អ្អើយ កុំថាអើយ ឬអឺយ ឡើយ ។

២- អានថា ប្អូនអ្អើយ ឬ ប្អូនណើយ កុំថា ប្អូនអឺយ

# បទភាគគតិ

- ខ្មែរពីព្រេងនាយ ចង់ឱ្យបានងាយ ប្រើពាក្យរីងៗ
ត្រង់ពាក្យដែលត្រូវ ប្រើ *គ្រឹគ្គ* ឬ *ស្រឹគ្គ* អ្នកអានពុំដឹង
ពាក្យទាំងពីរនេះ ។

- តើ *គ្រឹគ្គ* ឬ *ស្រឹគ្គ*[1] ដោយពុំបានដឹង ព្រោះខ្លួនពុំចេះ
នាំឱ្យច្រឡំ ដ្បិតឥតចំណេះ សំស្រឹតមិនចេះ
ធ្វើម្ដេចនឹងយល់ ។

- ហេតុនេះបានជា ខ្មែរទាំងអស់គ្នា ក្នុងគ្រា *ផ្ទៃឆ្ងល់*
នាំគ្នាលុបតួ គ[2] មិនឱ្យសល់ ថែមទាំងលុបដល់
ម[3] នេះទៅផង ។

- ព្រោះ *ស* ទាំងបី អានពួសម្ដី ដូចគ្នាតែម្ដង
តើទុកធ្វើអ្វី នាំឱ្យតែឆ្គង លប់ចោលរំលង
កុំឱ្យចង្អៀត ។

- ចំណែកខាងលាវ សម័យព្រាវៗ ក៏នាំគ្នាឆ្មៀត
លុបតួអក្សរ *ជប៉ពិរ* បង់សៀត កម្រនឹងឆ្មៀត
បង្កើតវិញបាន ។

- លាវលុបតួ-*ឃ* និងតួ *ឆ-ឈ* វគ្គ-ដប៉ុន្មាន

---

១- សំ. គង្គ > ត្រឹង្គ ; បា. សិង្គ " ស្នែង ; ធ្មុងត្រី " ។

២- .អ.ថ.ស.(ç) ។

៣- អ.ថ.ស.(s )

និងតួ *-ឆ-ភ* គ-ម ពីរប្រាណ បូករួមទៅបាន

*ដប់ពីរ* អក្សរ ។

- សម័យនេះលាវ សរសេរព្រាវៗ អស់ភាពបវរ

ត្រង់ពាក្យប្រើ-*ឃ* ប្រើ-*គ* អក្សរ[1] លាវឃ្លាតអំណរ

រកត្រូវទៅហើយ ។

- ហេតុនោះខ្មែរយើង កុំធ្វើទើងមើង យល់ការឈ្លើយៗ

*គិតលុបអក្សរ* តួខ្លះចោលឡើយ បើលុបធ្លោះហើយ

ទៅជា*មនុស្សព្រៃ* ។

- ប្រទេសធំៗ គេប្រឹងនិយម រាល់យប់រាល់ថ្ងៃ

អក្សរភាសា ជាតិគេឱ្យថ្លៃ កុំឱ្យចង្រៃ

រូបរីតជាតិបាន ។

- *បណ្ឌិត្យសភា* គេលើកឱ្យជា *បណ្ឌិត្យដ្ឋាន*

សម្រាប់ឱ្យជាតិ ឡើងខ្ពស់ថ្កើងថ្កាន ទើបជាតិគេបាន

*ថ្កុំថ្កើងជានិច្ច* ។

វត្តឧណ្ណាលោម ក្រុងភ្នំពេញ.ថ្ងៃទី ២២ មករា ១៩៦៩

*សម្ដេចព្រះសង្ឃរាជ*

***ជួន ណាត*** *ជោតញ្ញាណោ*

---

១- ព្រោះលាវយល់ឃើញថា មានសូរសំឡេងដូចគ្នា ត្រូវលប់ចោលខ្លះទៅ !

*កម្ពុជសុរិយាសូមលើកយកមកចុះផ្សាយនូវអនុសាសន៍*

*នៃសន្និសីទជាតិ*

*ស្តីពីការស្រាវជ្រាវឯកភាព និងអភិវឌ្ឍន៍ភាសាខ្មែរ*

*នៅរាជបណ្ឌិតសភាកម្ពុជា*

**វិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិតសភាកម្ពុជា**

(ថ្ងៃទី ៧-៩ កញ្ញា ២០០២)

## អនុសាសន៍

អង្គសន្និសីទជាតិស្តីពីការស្រាវជ្រាវ ឯកភាពនិងអភិវឌ្ឍន៍ភាសាខ្មែរ មានមតិជាអនុសាសន៍ដូចតទៅ :

១ - គប្បីរក្សាទុកព្យញ្ជនៈខ្មែរទាំង ៣៣តួ ពិសេសអក្សរ ៥តួ ក្នុងវគ្គ "ដ" ស្រៈពេញតួ និងវណ្ណយុត្តិទាំងអស់

២ - គប្បីបង្កើតក្បួនវេយ្យាករណ៍ ត្រឹមត្រូវមួយ

៣ - គប្បីគោរពពាក្យ រក្សាពាក្យ និងប្រើប្រាស់ពាក្យ ដែលមាននៅក្នុងវចនានុក្រមខ្មែររបស់សម្តេចព្រះសង្ឃរាជ ជួន ណាត

៤ - គប្បីបង្កើតគណៈកម្មាធិការជាតិភាសា និងអនុគណៈកម្មការផ្សេងៗ ដែលមានគ្រប់និន្នាការចូលរួម

៥ - គប្បីបង្កើតវចនានុក្រម សទ្ទានុក្រម ដោយផ្អែកលើមូលដ្ឋានឯកភាព

៦ - គប្បីគោរពឃ្លាឃ្លោង ជើងកាព្យតាមក្បួនកំណាព្យខ្មែរ

៧ - គប្បីប្រើភាសាខ្មែរ និងលេខខ្មែរជាផ្លូវការ ទាំងនៅសាលារៀន ទាំងនៅក្នុងស្ថាប័ននានា

៨ - គប្បីប្រើប្រាស់ភាសាខ្មែរច្រើនជាងភាសាបរទេស ក្នុងករណីដែលអាចអនុវត្តបាន

៩ - គប្បីចុះទៅធ្វើការស្រង់មតិ ពីមហាជនគ្រប់មជ្ឈដ្ឋាន មុននឹងសម្រេចថា ត្រូវកែប្រែពាក្យណាមួយ

១០ - គប្បីប្រមូលបញ្ញវន្តខ្មែរទាំងក្នុង និងក្រៅប្រទេស ដែលមានបំណងជួយដោះស្រាយបញ្ហាភាសាខ្មែរ ឱ្យមកចូលជាសមាជិកអចិន្ត្រៃយ៍ ឬ សមាជិកឆ្លើយឆ្លងនៃគណៈកម្មាធិការភាសាជាតិ

១១ - គប្បីបង្កើតពាក្យថ្មីតាមមុខវិជ្ជាឯកទេស ពីព្រោះមុខវិជ្ជានីមួយៗមានបច្ចេកស័ព្ទដោយឡែករបស់វា

១២ - គប្បីមានគណៈកម្មការកណ្ដាលមួយ សម្រាប់ពិនិត្យពាក្យតាមមុខវិជ្ជាឯកទេស បន្ទាប់មកត្រូវផ្សព្វផ្សាយពាក្យទាំងនោះ តាមរយៈបណ្ដាញពត៌មាន ដើម្បីឱ្យបានដល់មជ្ឈដ្ឋានអ្នកប្រើប្រាស់ទូទៅ

១៣ - គប្បីមានកម្មវិធីសន្និសីទភាសាខ្មែរ តាមតម្រូវការជាក់ស្ដែង និងផ្សព្វផ្សាយឱ្យបានទូលំទូលាយតាមបណ្ដាញពត៌មាន

១៤ - គប្បីយកពាក្យបច្ចេកទេស ឬពាក្យដែលមានលក្ខណៈចម្រូងចម្រាសមកសាកល្បងប្រើ ដោយផ្សព្វផ្សាយដល់សាធារណជនឱ្យបានដឹងមុនរួចទើបសម្រេច ជ្រើសយកពាក្យណាមួយជាក្រោយ

១៥ - គប្បីកែលំអ វចនានុក្រម និងសទ្ទានុក្រមដែលបម្រុងនឹងបង្កើតថ្មី ក្នុងរយៈពេលប្រាំឆ្នាំម្ដងៗ

១៦ - គប្បីរក្សាវចនានុក្រមខ្មែរ សទ្ទានុក្រមចាស់ ទុកជាមូលដ្ឋានបង្អែក សម្រាប់ការពិចារណា

១៧ - គប្បីបញ្ចូលពាក្យខ្មែរកម្ពុជាក្រោម និងខ្មែរសុរិន្ទ ក្នុងវចនានុក្រមខ្មែរ ដែលវិទ្យាស្ថានភាសាជាតិបម្រុងនឹងបោះពុម្ពថ្មី

១៨ - គប្បីជួយផ្តល់យោបល់ក្នុងការរកទីតាំងដាក់តួអក្សរខ្មែរ ក្នុងយូនីកូដកុំព្យូរទ័រ (UNICODE)

១៩ - សូមអ្នកបច្ចេកទេសកុំព្យូរទ័រ រៀបចំអក្ខរាវិរុទ្ធខ្មែរឱ្យបានល្អ និងសុំឱ្យមានសញ្ញាប្រាប់កំហុសផង

២០ - គប្បីមានវិធានការត្រួតពិនិត្យការប្រើប្រាស់អក្ខរាវិរុទ្ធ និងភាសាខ្មែរក្នុងបណ្តាញសារពត៌មាន និងការផ្សាយពាណិជ្ជកម្ម

២១ - គប្បីសរសេរអក្សរខ្មែរដោយផ្ចិតផ្ចង់ ពីលើអក្សរបរទេស នៅលើផ្លាកផ្សាយពាណិជ្ជកម្ម

២២ - សូមឱ្យមានច្បាប់ស្តីពីការប្រើប្រាស់ និងអភិវឌ្ឍន៍ភាសាខ្មែរ

# វប្បធម៌សិល្បៈ និងវឌ្ឍនភាព ក្នុងសង្គមខ្មែរ

ដោយ : ព្រឹទ្ធាចារ្យ ឆេង ផុន

## I. ទស្សនៈរួមលើវិស័យវប្បធម៌ខ្មែរ :

វប្បធម៌ និងព្រលឹងខ្មែរ អាចជាមូលដ្ឋាននាំមកនូវសន្តិភាពពិតប្រាកដ និង ការធ្វើឱ្យរស់ឡើងវិញនៅកម្ពុជា ក្នុងតំបន់ និងលើពិភពលោក :

មុននឹងនិយាយអំពីការកសាង និងវឌ្ឍនភាពសង្គម គួរតែពិចារណាអំពីសន្តិភាព និងភាពឯកភាពរបស់ប្រទេសជាតិទាំងមូលសិន ។

យើងខ្ញុំជឿថា វប្បធម៌ និង សិល្បៈជាគ្រឹះឯកភាព និងជាប្រភពនៃសន្តិភាព យូរអង្វែងរបស់ខ្មែរទៅថ្ងៃមុខ ។

ពាក្យអរិយធម៌ ពាក្យវប្បធម៌ វប្បធម៌ស្មារតី វប្បធម៌សម្ភារៈសុទ្ធតែជាពាក្យធំៗ មានន័យទូលាយ ឱបក្រសោបជីវិតទាំងមូល ទំនាក់ទំនងពិភព លោកទាំងមូល ប៉ះពាល់ដល់វាសនាអនាគតរបស់មនុស្សជាតិទាំងមូល ។

អរិយធម៌អង្គរ គឺជាការលូតលាស់ដល់កំពូល នៃសង្គមធម៌ និងវប្បធម៌របស់ប្រទេសខ្មែរនាសតវត្សរ៍ទី១២ ។

ស្នាដៃសិល្បៈខ្មែរទាំងឡាយ ទាំងខាងស្ថាបត្យកម្ម ចម្លាក់ អក្សរ-សាស្ត្រ របាំ និង តន្ត្រី ។ល។ សុទ្ធតែបញ្ជាក់បានពីការលូតលាស់ខាងបញ្ញាញាណ ខាងទេពកោសល្យ ឧបនិស្ស័យ គំនិតច្នៃប្រឌិត សីលធម៌

គុណធម៌ និងគតិបណ្ឌិត គឺជាសមិទ្ធផល នៃជ័យជំនះ លើអាត្មាខ្លួនដោយខ្លួនឯងរបស់ប្រជាជនកម្ពុជា ។ ស្នាដៃទាំង នោះគឺជាសក្ខីភាព នៃការលូតលាស់ ដោយមានផែនការ មានតុល្យភាព សមរម្យ រវាងកាយ ចិត្ត និងបញ្ញា រវាងបុគ្គលធម្មជាតិ និងសង្គម ។ ស្នាដៃទាំងអស់នោះក៏ បញ្ជាក់ផងដែរពីជ័យជំនះលើធម្មជាតិ និងទំនាក់ទំនងរវាងមនុស្ស និងអាត្មាខ្លួន មនុស្ស និងមនុស្ស មនុស្ស និងធម្មជាតិ មនុស្ស និងសង្គម ។

ស្នាដៃទាំងនោះគឺជានិមិត្តរូប នៃកម្លាំងឯកភាព សាមគ្គីភាពផ្ទៃក្នុង និង ជំនឿជឿជាក់លើការគ្រប់គ្រងសង្គមនាសម័យនោះ ។ ឧទាហរណ៏ : ប្រាសាទ បាយន័ មានកំពូល ៤៧ ក្លោងទ្វារ ៥ ។ កំពូលនីមួយៗមានមុខ ៤ ជានិមិត្តរូបនៃគុណធម៌ ៤ យ៉ាង : មេត្តា ករុណា មុទិតា ឧបេក្ខា ។

បាយ័នជារូបមន្តនៃឯកភាព រវាងអំណាចកណ្តាល និងអំណាចតំបន់ អំណាចភូមិភាគ និងអំណាចមូលដ្ឋាន នៅតាមគ្រប់ច្រកចេញចូល នៃប្រទេសទាំងមូល (កំពូលកណ្តាល ជាតំណាងអំណាចកណ្តាល កំពូលខាងៗគឺជាអំណាចតំបន់ ភូមិភាគ ឬមូលដ្ឋាន) ។

ប្រាសាទបាយ័ន គឺជានិមិត្តរូប នៃឯកភាពខាងជំនឿ ទាំងក្នុងព្រះពុទ្ធសាសនា ទាំងព្រហ្មញ្ញសាសនា ឋានលើ ឋានក្រោម និងឋានកណ្តាល ។

ប្រាសាទបាយ័ន គឺជាអង្គឯកភាព នៃសមិទ្ធផលរួម : ស្តេចមើលឃើញស្នាដៃស្តេច រាស្ត្រមើលឃើញស្នាដៃរាស្ត្រ នាម៉ឺនមើលឃើញស្នាដៃនាម៉ឺន រាស្ត្រ សាមញ្ញ ក៏អាចមើលឃើញស្នាដៃរបស់ខ្លួននៅក្នុងនោះដែរ ។

ប្រាសាទបាយ័ន ជាភាពឯកភាព រវាងដោយឡែកនិងទូទៅ រវាងពហុភាព និងឯកភាព ។ ទាំងអស់សុទ្ធតែមានសីលធម៌ និងគុណធម៌ ៤ ដូចៗគ្នា ពីលើដល់ក្រោម ពីក្រោមទៅលើ ពីដោយឡែកទៅទូទៅ និងពីទូទៅមកដោយឡែកគឺ:

១- មេត្តា : លើស្វែងរកសុខឱ្យក្រោម ក្រោមស្វែងរកសុខឱ្យលើ ទូទៅស្វែងរកសុខឱ្យដោយឡែកៗ ស្វែងរកសុខឱ្យទូទៅ ។

២- ករុណា : លើមិនផ្តល់ទុក្ខឱ្យក្រោម ក្រោមមិនផ្តល់ទុក្ខឱ្យលើ អំណាចកណ្តាល មិនផ្តល់ទុក្ខ ឱ្យអំណាចរាយរងៗ មិនផ្តល់ទុក្ខឱ្យ អំណាចកណ្តាល ។

៣-មុទិតា : ចិត្តត្រេកអរតាម មិនច្រណែនលើ មិនស្រណែនក្រោម លើមិនច្រណែនក្រោម ក្រោមមិនច្រណែនលើ ។

៤-ឧបេក្ខា : ចិត្តរាប់អានស្មើភាពគ្នា មិនរើសមុខ មិនប្រកាន់ឋានៈ ទំនាក់ទំនងដោយគ្មានអគតិទាំង ៤ ។

ប្រាសាទបាយ័ន គឺជាភស្តុតាងមួយ ក្នុងចំណោមភស្តុតាងជាច្រើនទៀត នៃគ្រប់ទម្រង់សិល្បៈខ្មែរពីអតីតកាល ដែលនឹងអាចបញ្ជាក់អំពីគ្រឹះសន្តិភាពពិតៗ និង គ្រឹះឯកភាព និងមូលដ្ឋានសម្រាប់អភិវឌ្ឍន៍ប្រទេសកម្ពុជា អភិវឌ្ឍន៍តំបន់ និង ពិភពលោក ។

ធម្មជាតិបង្កើតមនុស្ស ដោយឱ្យភ្ជាប់មកជាមួយមនុស្សនូវចំណុចខ្សោយជាច្រើន ។ ឧទាហរណ៍ : ដីកាព្រះពុទ្ធ " មនុស្សកើតមកពីអវិជ្ជា (ល្ងង់) ទឹក ដី ភ្លើង ខ្យល់ នៅក្នុងខ្លួនមនុស្សជាធាតុល្ងង់ ។ យើងកើតពីពូជល្ងង់រស់នៅក្នុងល្ងង់ ស្លាប់ក្នុងល្ងង់ ហើយកើតមកវិញនៅតែល្ងង់ ។ យើងកើតមកពីពូជស្លាប់ មិនអាចគេចស្លាប់បានទេ តែភាពល្ងង់របស់យើងគិតថាអត់ស្លាប់ ភ្លេចគិតពីស្លាប់ ។ មនុស្ស កើតមកទទេ ហើយស្លាប់ទៅទទេ តែភាពល្ងង់របស់យើង ខំប្រឹងឱ្យមានលោភលន់ កេងប្រវ័ញ្ចដើម្បីមាន តែទីបំផុតនៅតែក្រ ព្រោះស្លាប់ទៅអត់យកអ្វីទៅជាមួយបានឡើយ ។

មនុស្សខ្លាំងពិត គឺមនុស្សឈ្នះខ្លួនឯង (ឈ្នះចំណុចខ្សោយខ្លួនឯង ឈ្នះធម្មជាតិ ឈ្នះសង្គម) ។

អភិវឌ្ឍន៍មនុស្សពិត គឺអភិវឌ្ឍន៍ឱ្យមានតុល្យភាពសមរម្យ រវាងបុគ្គលធម្មជាតិ និងសង្គម រវាងកាយចិត្ត និងបញ្ញា ។

នៅលើលោកនេះគ្មានអ្វីស្ថិតស្ថេរ មិនផ្លាស់ប្តូរ ប្រែប្រួលនោះឡើយ ។ តែការប្រែប្រួលផ្លាស់ប្តូរទាំងអស់នោះ សុទ្ធតែមានហេតុបច្ច័យ និងលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងចាំបាច់សម្រាប់ការប្រែប្រួលនោះ ។ ឧទាហរណ៍ : ពីទឹកត្រជាក់ ទៅចំហាយទឹក :

- ពីទឹកត្រជាក់ ទៅទឹកកក
- ពីពងមាន់ ទៅកូនមាន់
- ពីបរិមាណ ទៅគុណភាព
- ពីអន់ថយ ទៅជឿនលឿន ពីជឿនលឿន ទៅអន់ថយ ។

រាល់ការប្រែប្រួល សុទ្ធតែមានវិបត្តិ មានទំនាស់ ( ក្នុង និង ក្នុង ក្រៅ និង ក្រៅ ក្នុង និង ក្រៅ ) ។ រាល់ទំនាស់សុទ្ធតែមានការលំបាកៗ ជារូបភាពនៃថាមពល ជម្រុញឱ្យមានការរីកចម្រើនក្នុងការផ្លាស់ប្តូរ ។ ហេតុនេះ អភិវឌ្ឍករ ពុំគួរមានការធុញទ្រាន់នឹងការលំបាកឡើយ តែរាល់អភិវឌ្ឍករត្រូវសួរ និងឆ្លើយឱ្យច្បាស់លាស់ថា តើខ្លួនចង់បានអ្វី ចង់ឱ្យទៅជាអ្វី ចង់ធ្វើអីឱ្យទៅជាអ្វី ?

ចង់បានគោ ឯបានជ្រូកក៏បាន ឥតបានក៏បាន ផ្សងព្រេងណាស់ចៃដន្យណាស់ គ្មានផែនការ គ្មានទិសដៅ ។

- មនុស្សពិតដែលខ្លួនចង់បាន ?
- សង្គមពិតដែលខ្លួនចង់បាន ?
- កុំយកជីវិតមនុស្សមកធ្វើពិសោធន៍ច្រើនពេក ។

យកមនុស្សជាបំណង សង្គមជាមធ្យោបាយ ឬក៏យកសង្គមជាបំណង ហើយមនុស្សជាមធ្យោបាយ ។ ឧទាហរណ៍ៈ ស្បែកជើងចង្អៀតពេកដើរមិនរួច រលុងពេកក៏ដើរមិនរួច បើទិញស្បែកជើងហើយចៀរជើងតម្រូវតាម វាហូរឈាម ។

- បុគ្គលជាធំ សង្គមជាធំ ឬធម្មជាតិជាធំ ឬតុល្យភាពសមរម្យរវាងផ្នែកទាំង ៣ ។

- រូបភាពត្រូវបម្រើខ្លឹមសារ ធ្វើឱ្យខ្លឹមសារលូតលាស់រីកចម្រើន ។
- អាវសម្រាប់ការពារខ្លួន បើអាវចង្អៀតខ្លួន នឹងធ្វើឱ្យអាវរហែក

មិនខាន ។

- រូបភាពមិនបម្រើខ្លឹមសារ ខ្លឹមសារធ្វើឱ្យរូបភាពរហែកមិនខាន ។

ការងារវប្បធម៌សិល្បៈ ជាការងារដោយផ្ទាល់ ជាមួយនឹងមនុស្ស រវាងមនុស្ស និង មនុស្សៗ និង វាសនា អនាគតរបស់មនុស្ស ។

- ជាតិមួយមានអរិយធម៌ គឺវប្បធម៌បូកសង្គមធម៌ ។
- ជាតិមួយមានវប្បធម៌ គឺការលូតលាស់កំពូលខាងវប្បធម៌ស្មារតី បូក និង វប្បធម៌សម្ភារៈ ។
- សង្គមមានវប្បធម៌ គឺសង្គម ដែលសម្បូរដោយគ្រួសារ វប្បធម៌ ។
- គ្រួសារមានវប្បធម៌ គឺគ្រួសារសម្បូរដោយបុគ្គលវប្បធម៌ ។
- បុគ្គលមានវប្បធម៌ គឺបុគ្គលដែលលូតលាស់សមរម្យទាំង កាយចិត្ត និងបញ្ញា ។

## II- ទស្សនៈលើការអភិវឌ្ឍន៍រួម ពិសេស លើការអភិវឌ្ឍន៍ មនុស្សពិត ជីវិតពិត សង្គមពិត និង ធម្មជាតិពិត :

បើចង់អភិវឌ្ឍន៍ មនុស្សខ្មែរពិត សង្គមខ្មែរពិត គួរតែស្វែងយល់ ស្វែងស្គាល់ ខ្មែរឱ្យបានច្បាស់លាស់សិន ខ្មែរបច្ចុប្បន្ន ខ្មែរអតីត ខ្មែរអនាគត :

- ខ្មែរជាអ្នកណា ? មកពីណា ? ទៅណា ? កំពុងធ្វើអ្វី ? ដើម្បីអ្វី ?
- អ្នកស្គាល់ខ្លួនឯងច្បាស់ រមែងមិនមានពហុចិត្តឡើយ ។
- អ្នកស្គាល់ខ្លួនឯងច្បាស់ ជាប្រភពនៃថាមពលជម្រុញបុគ្គលឱ្យ

វីកចម្រើន ។

- អ្នកស្គាល់ទីកន្លែង ស្គាល់ពេលវេលា ស្គាល់ប្រាណ ចេះល្មម រមែងដើរ ផ្លូវកណ្តាលឆ្វេងមិនហួស មិនស្តាំហួស ។

- សណ្តាប់ធ្នាប់សេដ្ឋកិច្ច កំណត់សណ្តាប់ធ្នាប់សង្គម ។

- សណ្តាប់ធ្នាប់សង្គម កំណត់សណ្តាប់ធ្នាប់សតិអារម្មណ៍ ហើយជះឥទ្ធិពលប្រតិកម្មទៅវិញទៅមក ។

- បើចង់កែលំអ ឬកសាងមនុស្ស ត្រូវពិចារណាអំពីការកែលំអ និងកសាងមជ្ឈដ្ឋាន ដែលមនុស្សរស់នៅ ។ សង្គមណា មនុស្សនោះ មនុស្សណា ចិត្តគំនិតនោះ ចិត្តគំនិតណា ប្រព័ន្ធត្រិះរិះនោះ ប្រព័ន្ធត្រិះរិះណា សេចក្តីសម្រេចចិត្តនោះ (មនុស្សជាមជ្ឈមណ្ឌលទទួលផង ជាមជ្ឈមណ្ឌលផ្សព្វផ្សាយផង) ។

ជាការធម្មតាទេ សញ្ញាណសង្គម រមែងតែវិវឌ្ឍន៍ ប្រែប្រួលឃឹតជាងស្ថិតស្ថេរសង្គមជានិច្ច ព្រោះភាពប្រឡាក់ប្រឡូស ភាពមិនស្អាតស្អំពីអតីតកាល មិនងាយនឹងលាងជ្រះ ហើយឆាប់ទទួលយកឥទ្ធិពលថ្មីបានងាយស្រួល ដូចជាក្រដាសថ្មី សស្អាតមួយសន្លឹក ដែលទទួលបានពណ៌សម្បុរដ៏មានប្រសិទ្ធិភាពខ្ពស់នោះទេ ។

អតីតកាល មិនមែនសុទ្ធតែអន់ថយ ហើយរាំងស្ទះការរីកចម្រើនទាំងស្រុងនោះឡើយ ។ មានអតីតកាលខ្លះមិនអន់ថយ នៅតែបន្តជម្រុញការរីកចម្រើនទៅអនាគតជានិច្ច ហើយអ្វីដែលយល់ថា ជឿនលឿន និង

រីកចម្រើនទៅអនាគត ក៏មិន សុទ្ធជាមានប្រយោជន៏ដល់បច្ចុប្បន្នដែរ ។

*"បុរាណមិនយឺត សម័យមិនមែនបរទេស "*

ផ្កាទាំងឡាយសុទ្ធតែមានសម្រស់ និងគន្ធពិដោរប្លែកៗពីគ្នា តែគួរតែផ្កាទាំងនេះ មានសិទ្ធិឡើងតុគណៈអធិបតីគ្រប់ៗគ្នា មិនអាចមានអំនួតប្រកាន់ថា ផ្កានេះ ផ្កានោះ ផ្កាក្នុងក្រុង ផ្កាក្នុងសួន មានបុព្វសិទ្ធិពិសេស ឬជាតិមួយ មានបុព្វសិទ្ធិពិសេសរបស់វប្បធម៌ខ្លួន ហើយចាប់បង្ខំឱ្យគេទទួលស្គាល់ឱ្យគេទទួលគោរពតាមនោះឡើយ ។ ជួនកាលផ្កាមួយក្នុងព្រៃភ្នំដ៏សែនជ្រៅ ឬវប្បធម៌របស់ជនជាតិមួយ ដែលមានគ្នាតែ ៣០ នាក់ ក៏អាចមានតម្លៃស្មើនឹងផ្កាក្នុងសួន ឬក៏វប្បធម៌ នៃមហាជនជាតិណាមួយបានដែរ ។

ដូច្នេះ ការអភិវឌ្ឍន៏បុគ្គល ឬការអភិវឌ្ឍន៏ដោយឡែក មិនអាចផ្ដាច់ចេញ ពីការអភិវឌ្ឍន៏រួម ការអភិវឌ្ឍន៍ពិភពលោកបានឡើយ ។

## III- ទិសដៅសាកល្បងអភិវឌ្ឍន៏មនុស្ស សង្គម ធម្មជាតិ

រដ្ឋាភិបាលប្រទេសលូតលាស់ទាំងឡាយសុទ្ធតែមានផែនការ កសាងមនុស្ស អប់រំពលរដ្ឋខុសៗគ្នា តែទោះជាយ៉ាងណាក៏ដោយ ក៏ឥតចាកឆ្ងាយពីក្រឹតក្រមមូលដ្ឋាន នៃវប្បធម៌ឡើយ ។

*តួនាទីវប្បធម៌មាន ៣ :*

១ -រំដោះសតិអារម្មណ៍អន់ថយឱ្យពលរដ្ឋ

- ដោះឱ្យរួចផុតពីភាពល្ងង់ខ្លៅ ពីភាពក្រីក្រ
- បម្រះឱ្យរួចផុតពីភាពកៀបសង្កត់ និងជិះជាន់តាមផ្លូវកាយ ចិត្ត

និងបញ្ហា ។

២ -តួនាទីអប់រំ និង កែប្រែ :

- ពង្រឹងមជ្ឈដ្ឋាន និងប្រសិទ្ធិភាពអប់រំ ព្យាយាមកែប្រែទាំងសង្គម និង មនុស្ស (កែមនុស្សសំដៅកែសង្គម១សំដៅកែមនុស្ស ) ។

៣ -តួនាទីបំពាក់បំប៉ន និងកសាង :

- កសាងមនុស្ស ដោយបំពាក់បំប៉នលោកទស្សនៈថ្មី មនុស្សទស្សនៈថ្មី ជីវទស្សនៈថ្មី ។

*មុខងារវប្បធម៌ ប្រាំ :* នៅទីនេះយើងសូមលើកយកតែមុខងារមួយដែលមានសារៈ និងទំនាក់ទំនង ជាមួយអត្ថបទនេះមកបកប្រែតែប៉ុណ្ណោះ គឺមុខងារ បណ្តុះពុទ្ធិ ។

- អាចារៈវប្បធម៌ និង អាចារៈវឌ្ឍនៈ សំដៅបណ្តុះគតិបណ្ឌិត គុណធម៌ សីលធម៌ ចរិយាធម៌ សុជីវធម៌ សុភាវធម៌ ។

- សមត្ថភាវៈវប្បធម៌ សមត្ថភាវៈវឌ្ឍនៈ សំដៅលើសមត្ថភាពដឹកនាំ សមត្ថភាពគ្រប់គ្រង (ខ្លួនឯង និង សង្គម ) និងសមត្ថភាពវិទ្យាសាស្ត្រ បច្ចេកទេស ។

- លិង្គៈវប្បធម៌ និង លិង្គៈវឌ្ឍនៈ សំដៅលើភាពសមរម្យលើបុរសភាពសមរម្យខាងនារី ទំនាក់ទំនងសមរម្យរវាងបុរស និងនារី (Culture de degenre) ។

- ទស្សនីយវប្បៈ និងទស្សនីយវឌ្ឍនៈ សំដៅលើការរស់នៅ

ហូបចុកសមរម្យ ស្លៀកពាក់សមរម្យ និងស្នាក់នៅសមរម្យ ។

- បញ្ញាវប្ប: និង បញ្ញាវឌ្ឍន: សំដៅកំចាត់គ្រោះអវិជ្ជា កំទេចខ្ទាំងល្ងង់ខ្លៅបង្កើតឥស្សរភាពខាងកាយចិត្ត គំនិត បញ្ញា បំផុសគំនិតច្នៃប្រឌិត កសាងឧប្បនិស្ស័យ និង ទេពកោសល្យ ។

- កាយវប្ប: និងកាយវឌ្ឍន: សំដៅកសាងកាយមនុស្សឱ្យមានសុខភាព សមត្ថភាព និងគុណភាព បរិបូណ៌ ។

- វាចាវប្ប: និងវាចាវឌ្ឍន: សំដៅលើការប្រព្រឹត្តល្អ ដោយវាចារមិនភូតមិនកុហក (ឱ្យទុកដល់អ្នកដទៃ) មិនញុះញង់ (បំបែកបំបាក់អ្នកដទៃ) វាចារទាប គ្រោតគ្រាតច្រាសឆ្អេះ (ប្រមាថអ្នកដទៃ រំខានសេចក្ដីសុខ និងសេចក្ដីស្ងប់អ្នកដទៃ ) វាចារាយមាយឥតប្រយោជន៍ (ប្រឆាំងនឹងការរីកចម្រើន ធ្វើឱ្យ ខាតពេលវេលា ) ។

- ចិត្តវប្ប: និងចិត្តវឌ្ឍន: សំដៅលើការគ្រប់គ្រងចិត្ត និងការអប់រំចិត្ត ជំនះរាល់ចំណុចខ្សោយរបស់ខ្លួន ដោយខ្លួនឯង កំចាត់រាល់គ្រឿងសៅហ្មង កសាងបាននូវចិត្តបរិសុទ្ធ ផូរផង់ ស្អាតស្អំ...។ល...។ល។

តួនាទី ៣ និងមុខងារមួយ ក្នុងមុខងារទាំងប្រាំនេះ គ្រាន់តែជាលក្ខការណ៍ ខ្លះៗសម្រាប់កសាងមនុស្សវប្បធម៌តែប៉ុណ្ណោះ ឯការកសាងសង្គមវប្បធម៌ ឬជាតិ វប្បធម៌ គឺអាស្រ័យលើសមាមាត្រ នៃមនុស្សធម៌ដែលកសាងបានប៉ុណ្ណោះ ។

*កំណត់សម្គាល់ :*

- មនុស្សជាម្ចាស់ប្រវត្តិសាស្ត្រផង ជាផលិតផលនៃប្រវត្តិសាស្ត្រផង ។
- មនុស្សជាម្ចាស់សង្គមផង ជាផលិតផលរបស់សង្គមផង ។
- មនុស្សជាអ្នកកសាងផង និងជាអ្នកបំផ្លាញផង ។

កុំយកចិត្តទុកដាក់កសាងសង្គមដោយបំផ្លាញ បុគ្គល និង ធម្មជាតិ ឬយកចិត្តទុកដាក់បុគ្គលដោយបំផ្លាញបុគ្គល និងសង្គម ។

យើងមិនអាចយកចិត្តទុកដាក់អតីត ដោយបំភ្លេចបច្ចុប្បន្ន និង អនាគត ឬ យកចិត្តទុកដាក់បច្ចុប្បន្នដោយបំភ្លេចអតីត និង អនាគត ឬយកចិត្តទុកដាក់អនាគត ដោយបំភ្លេចអតីត និងបច្ចុប្បន្ន ។

អ្វីៗសុទ្ធតែមានទំនាក់ទំនងរវាងហេតុបច្ច័យ និងផល ការស្គាល់បច្ចុប្បន្នច្បាស់ មិនមានការសង្ស័យលើអតីត និងអនាគតឡើយ ។

# គុណភាពអប់រំ

## Quality of education

ដោយ : នយ យីហ៊ាន
(បណ្ឌិត ទស្សនវិជ្ជា)

វិស័យអប់រំនៅកម្ពុជាធ្លាប់រីកចម្រើន គួរឱ្យកត់សម្គាល់ ។ លុះដល់ ឆ្នាំ ១៩៧០ រដ្ឋប្រហារមួយបានកើតឡើង ហើយធ្វើឱ្យប្រទេសជាតិខ្ទេចខ្ទាំគ្រប់វិស័យ។ ធ្ងន់ធ្ងរជាងនោះទៅទៀត គឺក្នុងអំឡុងឆ្នាំ ១៩៧៥-១៩៧៨ គ្រប់ វិស័យត្រូវបានកែប្រែទៅតាមអ្វីដែលហៅថា *"ឆន្ទៈរបស់អង្គការ"* ដែលក្នុងនោះ វិស័យអប់រំត្រូវលុបបំបាត់ទាំងស្រុង។ ប៉ុន្តែ ចាប់ពីខែមករា ឆ្នាំ ១៩៧៩ មក វិស័យអប់រំ និងវិស័យដទៃទៀតងើបឡើងវិញ ធ្វើឱ្យរចនាសម្ព័ន្ធសង្គមរីកចម្រើនជាបណ្តើរៗ។

ក្រោមសេចក្តីភ្ញាក់រឭកមួយ ដែលពោរពេញដោយមនសិការស្នេហាជាតិ អ្នកអប់រំសម័យ ១៩៧៩ បានអនុវត្តតាមពាក្យស្លោកដែលចែងថា *"អ្នកចេះច្រើនបង្រៀនអ្នកចេះតិច ឯអ្នកចេះតិចបង្រៀនអ្នកមិនទាន់ចេះ"* ។ រដ្ឋាភិបាលសម័យនោះបានលើកពាក្យស្លោកនេះឡើង ដើម្បីទប់ទល់ភាពទ័លច្រកក្នុងប្រព័ន្ធអប់រំ។ គឺពាក្យស្លោកនេះ ហើយដែលរុករានក្នុងពិភពល្ងង់ខ្លៅ ដែលគ្របដណ្តប់លើស្មារតីនៃប្រជាជនកម្ពុជា ដែលទើបនឹងចេញផុតពីរបបប្រល័យពូជសាសន៍ ហើយធ្វើឱ្យសេចក្តីចេះដឹងកាន់តែរីកចម្រើនឡើង។ នេះជាពាក្យស្លោកមួយដែលសម័យនោះមិនអាចបដិសេធបាន ព្រោះបញ្ញវន្តបានស្លាប់ជាច្រើនក្នុងរបបប្រល័យពូជសាសន៍។

សព្វថ្ងៃ តម្រូវការចាំបាច់ និងបន្ទាន់មួយទៀត ដែលកម្ពុជាទទូចចង់បាន

ដើម្បីដណ្តើមជ័យជំនះនៅក្នុងអាស៊ាន (ASEAN) និងនៅក្នុងពិភពលោក គឺ **គុណភាពអប់រំ** ។ នេះជាតម្រូវការបរានុម័ត (objective need) ដែលត្រូវតែបំពេញដោយជៀសមិនផុត ទោះចង់ក្តី ឬមិនចង់ក្តី ប្រសិនបើចង់ឱ្យវិស័យអប់រំ និងវិស័យដទៃទៀតរុងរឿង។ ការមិនអើពើចំពោះគុណភាពអប់រំ មានន័យថា សម្លាប់ស្មារតីមនុស្សខ្មែរ។ ដើម្បីជំរុញវិស័យអប់រំឱ្យមានគុណភាព គួរយើងពិចារណាលើកត្តាសំខាន់ ដូចខាងក្រោម ÷

## ១‐ ការគ្រប់គ្រងដែលមានវិធីវិទ្យាសាស្ត្រចង្អុលទិស

គ្មានការគ្រប់គ្រងណាមួយ ដែលល្អបរិសុទ្ធគ្មានចំណុចខ្វះខាតឡើយ។ បើជៀសកំហុសត្រង់នេះ ពិតជានឹងមានកំហុសត្រង់នោះ។ ការអះអាងថា ការគ្រប់គ្រងបែបនេះល្អឥតខ្ចោះ គឺជាមតិខុសឆ្គង។ កំហុសនោះកើតឡើងដោយចេតនា ឬដោយអចេតនា។ អ្នកគ្រប់គ្រង និងអ្នកត្រូវគ្រប់គ្រង ត្រូវបែងចែកឱ្យច្បាស់រវាងកំហុសដែលកើតឡើងដោយចេតនា និងកំហុសដែលកើតឡើងដោយ អចេតនា ដើម្បីវាយតម្លៃសភាពការណ៍ នៃការគ្រប់គ្រងឱ្យបានត្រឹមត្រូវ។ កំហុសដែលកើតឡើងដោយចេតនា ជាកំហុសដែលមានលក្ខណៈបំផ្លិចបំផ្លាញ។ រីឯកំហុសដែលកើតឡើងដោយអចេតនា ជាកំហុសដែលគ្មានលក្ខណៈបំផ្លិចបំផ្លាញទេ។ អ្នកគ្រប់គ្រងត្រូវមានអាធ្យាស្រ័យល្អ ចំពោះកំហុសប្រភេទទី ២ នេះ។

អ្នកគ្រប់គ្រងត្រូវប្រកបដោយគុណសម្បត្តិមួយចំនួនដូចជា ការដឹកនាំល្អ វិមជ្ឈការបច្ចេកទេសប្រជាធិបតេយ្យ ... ។ អ្នកត្រូវគ្រប់គ្រងត្រូវប្រកបដោយសុឆន្ទៈ សេរីភាព សេចក្តីក្លាហាន ...។ ជីវិតសង្គម អាចប្រព្រឹត្តទៅបានល្អ លុះត្រាតែការងាររួមទាំងឡាយ ត្រូវបានលើកយកមកជជែកវែកញែក ដោយស្រុះ

ស្រួលគ្នា។ អ្នកគ្រប់គ្រងជាអ្នកកាន់ប្រទីបបំភ្លឺផ្លូវ ឯអ្នកត្រូវគ្រប់គ្រងជាមហាជន ដែលធ្វើដំណើរតាមផ្លូវដែលមានពន្លឺ និងបំពេញការងារ ដើម្បីកសាងប្រវត្តិសាស្ត្រ របស់ប្រទេស។ អ្នកគ្រប់គ្រងជាកត្តាជះឥទ្ធិពល ព្រោះដើរតួជាអ្នកបំភ្លឺផ្លូវ។ អ្នកត្រូវគ្រប់គ្រងជាកត្តាកំណត់ ព្រោះដើរតួជាអ្នកអនុវត្ត។ គឺកត្តាកំណត់នេះហើយ ដែលធ្វើឱ្យការងាររបស់ស្ថាប័នឈានទៅដល់គោលដៅ។ ទាំងអ្នកគ្រប់គ្រង និងអ្នកត្រូវគ្រប់គ្រងទាមទារឱ្យមានសេចក្ដីស្មោះត្រង់ និងមានទំនុកចិត្តទៅវិញ ទៅមក។ **អាយ ឈីញ** (I Ching) ទស្សនវិទូចិនបានសរសេរថា *"នៅក្នុងសេចក្ដីស្មោះត្រង់ មានកម្លាំងដែលមកពីខាងក្រៅ ហើយក្លាយជាចំណុចដឹកនាំនៅខាងក្នុង។ កម្លាំងម៉ឺងម៉ាត់ដែលមានលក្ខណៈសកម្មរឹងមាំ ចេះថ្លឹងថ្លែង ឆាប់យល់ដឹង ដែលធ្វើដំណើរចូលទៅក្នុងផ្លូវត្រូវជាបន្តបន្ទាប់ គឺជាបញ្ហារបស់ធម្មជាតិ។ ប្រសិនបើអ្នកបដិសេធអ្វីដែលត្រូវ អ្នកពិតជាខុស ហើយមិនបានទទួលប្រយោជន៍ ទោះទៅដល់ទីណាក៏ដោយ"* (In fidelity, strength comes from outside and becomes the guiding focus within. Being active and robust, firm strength balanced and responsive, succeeding greatly in the right way is the order of Nature. If you deny what is right, you are mistaken and will not benefit from going anywhere.)[១]។ លោកចង់បញ្ជាក់ថា បើយើង មានសេចក្ដីស្មោះត្រង់មហាជនពិតជាគាំទ្រយើងពីគ្រប់ទិសទី ហើយធ្វើឱ្យអ្នកមានសេចក្ដីស្មោះត្រង់នោះ ទទួលជោគជ័យជាបន្តបន្ទាប់ក្នុងការងាររបស់ខ្លួន។

ជាសង្ខេប ការគ្រប់គ្រងដែលមានវិធីវិទ្យាសាស្ត្រ (scientific method) ចង្អុលទិសជាការគ្រប់គ្រង ដែលឥតផ្អែកលើវិធីសិតស្វាញ ដែលមានលក្ខណៈ

---

១- I Ching, *The book of Change,* translated by Thomas Clearly, printed in China on acid-free paper, 1992, page11.

ចចេសរឹងរូស (method of tenacity) ឥតផ្អែកលើវិធីអំណាច (method of authority) ឥតផ្អែកលើវិធីមុនពិសោធន៍ (a priori method) ឡើយ។ នោះជាវិធីទន់ភ្លន់ ចេះបត់បែន ចេះអង្កេត ចេះសង្កេត និងចេះពិចារណា ចេះបោះជំហានទៅមុខ ហើយក៏ចេះដកជំហានថយក្រោយដែរ ដើម្បីកែលំអ និងឈានទៅដល់គោលដៅដែលបានគ្រោងទុក។ ការគ្រប់គ្រង ដែលមានវិធីវិទ្យាសាស្ត្រចង្អុលទិស ជាការគ្រប់គ្រងដែលចេះពិចារណាលើបាតុភូត ដែលកំពុងកើតឡើងរកហេតុទាំងឡាយ ដែលធ្វើឱ្យបាតុភូតនោះកើតឡើង និងបង្ហាញផលវិជ្ជមាន ឬផលអវិជ្ជមាន ដែលបាតុភូតនោះផ្តល់ឱ្យក្នុងបច្ចុប្បន្នកាល និងអនាគតកាល។ ក្នុងការធ្វើអង្កេតពីបញ្ហាអ្វីមួយ **សាគសាន់ដឺរពែរស៍** (Charles Sanders Peirce) តក្កវិទូអាមេរិកបានគូសបញ្ជាក់ពីសារៈប្រយោជន៍ នៃវិធីវិទ្យាសាស្ត្រនោះ។

## ២. កម្មវិធីសិក្សាសមស្របតាមលទ្ធភាពជាក់ស្តែង

កម្មវិធីសិក្សាសមស្របតាមលទ្ធភាពជាក់ស្តែងមានន័យថា យើងត្រូវធ្វើការប្រៀបធៀបកម្មវិធីសិក្សានានា នៅក្នុងប្រទេសជាច្រើន និងយកកម្មវិធីនោះមកអនុវត្តនៅក្នុងប្រទេសយើង សម្រួលទៅតាមលទ្ធភាពរបស់យើង។ យើងមិនអាចធ្វើអ្វីហួសលទ្ធភាព ដែលយើងមានឡើយ។ យើងមិនប្រញាប់ប្រញាល់ពេកតែយើងក៏មិនរង់ចាំរហូតដែរ។ កម្មវិធីសិក្សានេះ គួរតែមានលក្ខណៈប្រហាក់ប្រហែលគ្នា និងគួរតែស្ថិតនៅក្រោមស្ថាប័នមួយ ដើម្បីងាយស្រួលក្នុងការពិនិត្យវាយតម្លៃ។

សព្វថ្ងៃ កម្មវិធីសិក្សានៅកម្ពុជាហាក់ដូចជា មានលក្ខណៈអនាធិបតេយ្យនៅក្នុងគ្រឹះស្ថានឧត្តមសិក្សានានា ទាំងផ្នែករដ្ឋ ទាំងផ្នែកឯកជន។ ឧទាហរណ៍ :

គ្រឹះស្ថានឧត្តមសិក្សាខ្លះប្រើប្រព័ន្ធពិន្ទុ ១០/១០ ខ្លះ ២០/២០ ខ្លះទៀត ១០០/១០០ ។ ម្យ៉ាងទៀត គេសង្កេតឃើញថា ពាក្យ **វិទ្យាស្ថាន** ត្រូវបានប្រើប្រាស់តាមបែបអនាធិបតេយ្យ បណ្ដាលឱ្យពាក្យនេះបាត់បង់និយមន័យដើមរបស់វា ព្រោះពាក្យនេះបម្រើតាំងពីមតេយ្យសិក្សា រហូតដល់ឧត្ដមសិក្សា។ ឧទាហរណ៍ខាងលើនេះបញ្ជាក់ថា ការរីកចម្រើននៃវិស័យអប់រំនៅកម្ពុជាមានលក្ខណៈ ច្របូកច្របល់មួយចំនួនដែលគួរដោះស្រាយបន្ទាន់។ ជាពិសេសនៅឧត្តមសិក្សា មិនមែនជាការលំបាកណាស់ទេ ប្រសិនបើយើងមានសុឆន្ទៈក្នុងការដោះស្រាយដោយផ្អែកលើផលប្រយោជន៍ជាតិជាធំ។

ការពិចារណាដ៏សំខាន់មួយទៀត គឺការពិចារណាចំពោះគ្រឹះស្ថានឧត្តមសិក្សានានា ដែលស្ថិតនៅក្រោមក្រសួងផ្សេងៗគ្នា។ គ្រឹះស្ថានឧត្តមសិក្សាទាំងនោះគឺ ÷

- រាជបណ្ឌិតសភាកម្ពុជា ក្រោមទីស្ដីការគណៈរដ្ឋមន្ត្រី
- សាលាភូមិន្ទរដ្ឋបាល ក្រោមទីស្ដីការគណៈរដ្ឋមន្ត្រី
- សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ក្រោមក្រសួងអប់រំ យុវជន និង កីឡា
- សាកលវិទ្យាល័យវេទមហាឬសី ក្រោមក្រសួងអប់រំ យុវជន និង កីឡា
- វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ក្រោមក្រសួងអប់រំ យុវជន និង កីឡា
- វិទ្យាស្ថានជាតិគ្រប់គ្រង ក្រោមក្រសួងអប់រំ យុវជន និង កីឡា
- មហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្រោមក្រសួងអប់រំ យុវជន និង កីឡា
- មហាវិទ្យាល័យគរុកោសល្យ ក្រោមក្រសួងអប់រំ យុវជន និង កីឡា
- សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ក្រោមក្រសួងសុខាភិបាល

- សាកលវិទ្យាល័យភូមិន្ទកសិកម្ម ក្រោមក្រសួងកសិកម្ម
- សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ក្រោមក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រោមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ ក្រោមក្រសួងធម្មការ និងសាសនា
- វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ក្រោមក្រសួងធម្មការ និងសាសនា

ម្យ៉ាងទៀត នៅមានគ្រឹះស្ថានឧត្តមសិក្សាឯកជនជាច្រើនទៀត ដែលស្ថិតនៅក្រោមក្រសួងអប់រំយុវជន និង កីឡា ដូចជា ÷

- សាកលវិទ្យាល័យនរ័តុន
- សាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា
- សាកលវិទ្យាល័យបញ្ញាសាស្ត្រ
- សាកលវិទ្យាល័យអាស៊ាន
- វិទ្យាស្ថានអន្តរជាតិកម្ពុជា
- វិទ្យាស្ថានបច្ចេកវិទ្យា និងគ្រប់គ្រង
- វិទ្យាស្ថានឯកទេសនៃកម្ពុជា
- សាកលវិទ្យាល័យបៀលប្រាយ ។

ថ្ងៃក្រោយ អាចក្រសួងដទៃទៀត ដូចជាក្រសួងទេសចរណ៍ជាដើម បង្កើតវិទ្យាស្ថាន ឬសាកលវិទ្យាល័យ តាមតម្រូវការរបស់ខ្លួន ។ នោះជាការណ៍ដែលរឹតតែលំបាកស្មុគស្មាញ ដែលតម្រូវឱ្យមានក្រសួងឧត្តមសិក្សាមួយសម្រាប់គ្រប់គ្រង ឬតម្រូវឱ្យមានគណៈកម្មាធិការជាតិឧត្តមសិក្សាសម្រាប់សម្របសម្រួលការងារទាំងអស់នៃ គ្រឹះស្ថានឧត្តមសិក្សា ។ ក្នុងករណីដែលគ្រឹះស្ថានឧត្តមសិក្សានានា ស្ថិត

នៅដាច់ដោយឡែកពីគ្នាបែបនេះ ការបណ្ដុះបណ្ដាលធនធានមនុស្សពិតជាស្ថិតនៅក្នុងផែនការដាច់ដោយឡែកពីគ្នាដែរ។

ក្នុងប្រព័ន្ធអប់រំ នៅប្រទេសខ្លះមានក្រសួងពីរ គឺក្រសួងឧត្ដមសិក្សា និងក្រសួងសិក្សាធិការ។ ដោយសារមានការលំបាកក្នុងផលិតកម្មធនធានមនុស្ស និងក្នុងការបែងចែកធនធានទៅដល់ស្ថាប័ននានា គេក៏បានបង្រួមក្រសួងទាំងពីរមកជាក្រសួងតែមួយ។ តាមពិត គួរយើងមានផែនការរួមមួយក្នុងការបណ្ដុះបណ្ដាលធនធានមនុស្ស។ កង្វះផែនការរួមនេះអាចធ្វើឱ្យវិស័យមួយចំនួនខ្វះធនធានមនុស្សឯវិស័យមួយចំនួនទៀត បែរជាលើសធនធាននោះទៅវិញ។ បញ្ហាដែលគួរបារម្ភបំផុតនោះ គឺការដែលអ្នកមានសញ្ញាប័ត្រខ្ពស់មិនអាចរកការងារបាន ដោយសារការផលិតមានចំនួនច្រើនជាងតម្រូវការ នៅក្នុងវិស័យមួយចំនួន។

ជាសង្ខេប កម្មវិធីសិក្សា គួរមានលក្ខណៈប្រហាក់ប្រហែលគ្នាតាមគ្រឹះស្ថានសិក្សានីមួយៗ ទាំងផ្នែករដ្ឋ ទាំងផ្នែកឯកជន ជាពិសេសនៅក្នុងឧត្ដមសិក្សា។ កម្មវិធីសិក្សានេះមិនអាចស្ថិតនៅជាប់រហូតទេ តែត្រូវកែលំអក្នុងរយៈពេល ២ ឆ្នាំម្ដង តាមលទ្ធភាព និងសមត្ថភាពរបស់គ្រូ។

## ៣‐ បុគ្គលិកសិក្សាប្រកបដោយមនសិការខ្ពស់ និងមានសមត្ថភាពវិទ្យាសាស្ត្របច្ចេកទេស

បុគ្គលិកសិក្សា ‐ គ្រូបង្រៀន និងសាស្ត្រាចារ្យ ‐ ជាមនុស្សដែលតម្រូវឱ្យមានមនសិការខ្ពស់ មានសីលញ្ញាណក្នុងមុខរបររបស់ខ្លួន។ មនសិការនោះជាគន្លឹះសំខាន់បំផុតដែលជំរុញឱ្យបុគ្គលិកសិក្សាមានសីលធម៌វិជ្ជាជីវៈ។ គឺសីលធម៌វិជ្ជាជីវៈនេះហើយដែលជាម៉ែត្រវាស់តម្លៃបុគ្គលិកសិក្សា។ បើខ្វះសីលធម៌វិជ្ជាជីវៈ បុគ្គលិក

សិក្សាមិនគ្រាន់តែបរាជ័យក្នុងមុខរបររបស់ខ្លួនទេ តែធ្វើឱ្យប្រព័ន្ធអប់រំ និងសង្គមទាំងមូលបរាជ័យទៀតផង។ ដោយសារសីលធម៌វិជ្ជាជីវៈ គ្រូបង្រៀនត្រូវមានតួនាទីជាច្រើន។ **អឺរល៍ វី ពុលីយ៉ាស** និង **ជែម ឌី យ៉ង់** (Earl V. Pullias and James D. Young) បានអះអាងថា *"ការបង្រៀនមានតួនាទីជាច្រើន។ គ្រូបង្រៀនត្រូវដើរតួជាមនុស្សច្រើននាក់។ ជួនកាល ការបង្រៀនមានន័យថា ការបង្ហាត់ ការពន្យល់ ឬការនិយាយ។ ប៉ុន្តែ ការបង្រៀនបែបនេះមានតិចតួចណាស់។ ការបង្រៀន គឺការរង់ចាំ ហើយក៏មានរយៈពេលសម្រាប់ធ្វើសកម្មភាពផងដែរ។ គ្រូបង្រៀនតែងតែទាមទារបណ្តុះបណ្តាលតាមស្តង់ដារដែលអ្នកដទៃបង្កើតឡើង តែស្តង់ដារដែលល្អបំផុតនោះ គឺជាស្តង់ដារដែលគ្រូបានបង្កើតសម្រាប់ខ្លួនឯង"* (Teaching is many things. The teacher is many persons. Teaching sometimes means instructing, explaining, or telling, however, very little can be taught in this way. Teaching is waiting, yet there is also a time for action. The teacher is often required to perform according to standards established by others, but the best standard are those the teacher has established for himself.)[២] ។

បុគ្គលិកសិក្សាមិនគ្រាន់តែជាអ្នកបង្រៀន និងជាអ្នកអប់រំប៉ុណ្ណោះទេ។ គេត្រូវដើរតួជាមនុស្សច្រើននាក់ ដូចជា ឪពុកម្តាយ មិត្តភក្តិ មគ្គុទេសក៍ អ្នកស្រាវជ្រាវ ទីប្រឹក្សា អ្នកច្នៃប្រឌិត រដ្ឋអំណាច អ្នកកំចាត់បក្សពួកនិយម អ្នកផ្តល់ទស្សនវិស័យ អ្នកវាយតម្លៃ និងសិល្បករ។ **អឺរល៍ វី ពុលីយ៉ាស** និង **ជែម ឌី យ៉ង់** (Earl V. Pullias and James D. Young) បានបន្ថែមថា *"ហេតុនេះ គ្រូបង្រៀនខ្លួនឯង គឺជាអ្នកសិក្សា។ អ្វីដែលយើងបាន និយាយអំពីការបង្រៀនគ្រាន់*

[២] Earl V. Pullias and James D. Young, *A teacher is many thing,* printed in the United States of America, New York, 1968, page 14.

*តែជាការស្នើនូវអ្វីដែលអាចនិយាយប៉ុណ្ណោះ។ សេចក្តីសង្ឃឹម គឺការគិតផ្សេងៗទៀត ត្រូវបានជ្រើសយកមក ឯការស្រាវជ្រាវដ៏ទូលំទូលាយ ដើម្បីសច្ចភាព និងគតិវិញ្ញូ ត្រូវចាប់ផ្តើមឡើង"* (Thus, the teacher himself is a learner. What we have said about teaching are only suggestions of what might be said. The hope is that other thoughts will be stirred and a more wide-spread search for truth and wisdom began.)[៣] ។ បុគ្គលិកសិក្សាដែលខ្វះការអាន ការសរសេរ ការស្រាវជ្រាវ មានន័យថា អ្នកនោះបណ្តោយខ្លួនក្លាយជាមនុស្សអន់ថយហួសសម័យ បណ្តោយឱ្យវិទ្យាសាស្ត្រឆ្លងផុតឆ្ងាយទៅ ...។ ឥទ្ធិពលរបស់គេនឹងសាបរលាបបន្តិចម្តងៗ នៅចំពោះមុខសិស្ស។ ហេតុនេះ គ្រូបង្រៀន និងសាស្ត្រាចារ្យ ដែលមិនធ្វើការអង្កេត មិនធ្វើការស្រាវជ្រាវ ប្រៀបដូចជាមនុស្សខ្វិន ហើយគ្មានផ្តល់ចំណេះថ្មីទាន់សម័យដល់សិស្ស និស្សិតឡើយ ។

អ្វីដែលយើងបានវិភាគខាងលើអាចផ្ទុយពីសភាពការណ៍ជាក់ស្តែង នៃបុគ្គលិកសិក្សាសព្វថ្ងៃនេះ។ អ្នកបង្រៀន ឬអ្នកអប់រំមួយចំនួនកំពុងធ្វើឱ្យសីលធម៌វិជ្ជាជីវៈរបស់ខ្លួនស្រុតចុះ ឬធ្វើឱ្យបាត់បង់សីលធម៌វិជ្ជាជីវៈនោះ ទាំងស្រុង។ ការណ៍នេះកើតឡើងដោយសារអំពើពុករលួយតិច ឬច្រើន ដោយសារការមិនស្រឡាញ់បុគ្គលិកលក្ខណៈរបស់សិស្សានុសិស្ស ដោយសារការចម្រាញ់យកប្រាក់ពីសិស្ស ការឃ្លាតឆ្ងាយពីមាតាបិតាសិស្ស ហើយធ្វើឱ្យសិស្សលែងគោរពកោតខ្លាចគ្រូវិញ។ គឺជាបញ្ហាខាតបង់ធំណាស់ ជាបញ្ហាដែលធ្វើឱ្យសង្គមរង្គោះរង្គើ ប្រសិនបើបុគ្គលិកសិក្សាបាត់បង់ភាពថ្លៃថ្នូររបស់ខ្លួន។ ក្នុងករណីដែលអ្នកអប់រំលែងអើពើចំពោះសីលធម៌វិជ្ជាជីវៈ លែងរវល់ក្នុងការស្រាវជ្រាវ... ការអប់រំពិតជាបង្វែរទិសដៅរបស់ខ្លួនទៅ

---

[៣] Ibid, page 122.

រកអកុសលកម្មកាន់តែខ្លាំងឡើងៗ ហើយសង្គមក៏ចុះដុនដាបទៅដែរ ដូចក្នុងសម័យសង្គ្រាមជាដើម ។

## ៤‑ សិស្សានុសិស្សដែលមានសេចក្ដីភ្ញាក់រឭកក្នុងការសិក្សា

សេចក្ដីភ្ញាក់រឭកជាសញ្ចេតនាមួយដែលមិនអាចកាត់ថ្លៃបានឡើយ ។ អ្វីដែលល្អបំផុតក្នុងការបណ្ដុះបណ្ដាលបុគ្គលិកលក្ខណៈរបស់បុគ្គល គឺសេចក្ដីភ្ញាក់រឭកក្នុងការសិក្សា។ អំពីការសិក្សានេះ សម្ដេចព្រះសង្ឃរាជ **ជួន ណាត** បានទូន្មានថា *"ចំណេះកើតមានព្រោះការរៀន កម្ជិលអៀនប្រៀនកុំសម្ដែង ធ្វើឱ្យគេស្ញើចគេកោតក្រែង ស្លាក់ស្លែងទេកុំរិះគន់គេ ។ ត្រូវរិះគន់ខ្លួនឯងជាមុន កុំឱ្យស៊យស៊ុនខុសទទេ បើឆ្ងល់ពុំយល់ត្រូវសួរគេ ឥតថោកអ្វីទេតើ"*[៤] ។

អ្វីដែលលំបាកនោះ គឺការបណ្ដុះសេចក្ដីភ្ញាក់រឭករបស់សិស្សានុសិស្ស ។ នៅពេលដែលសិស្សានុសិស្សមាន ការភ្ញាក់រឭកក្នុងការសិក្សាហើយ គ្មានកម្លាំងអាក្រក់ណាមួយអូសទាញគេឱ្យដើរលើផ្លូវខុសឡើយ ហើយពេលនោះ ក៏មានន័យថា គេត្រៀមខ្លួនធ្វើជាពលរដ្ឋដ៏ល្អផងដែរ ។ ការណ៍នេះទាមទារឱ្យគ្រូចេះប្រើវិធីនិងល្បិចដ៏ប៉ិនប្រសប់ ដើម្បីធ្វើឱ្យសិស្សានុសិស្សយល់ថា ការសិក្សាជាមុខរបរចាំបាច់ក្នុងបឋមវ័យរបស់ខ្លួន ។ គរុកោសល្យថ្មីតម្រូវឱ្យសិស្សធ្វើជាមជ្ឈមណ្ឌលក្នុងការសិក្សា ។ សិស្សជាមជ្ឈមណ្ឌលក្នុងការសិក្សាមានន័យថា សិស្សរៀនខ្លួនឯងច្រើនជាងការទទួលយកមេរៀនពីគ្រូ ឯគ្រូជាអ្នកតម្រង់ទិសឱ្យសិស្សរៀន ។ ហេតុនេះ លក្ខណៈវិនិច្ឆ័យមួយ ក្នុងចំណោមលក្ខណៈវិនិច្ឆ័យចម្បងទាំងឡាយ ដើម្បី

---

[៤] គៀត ច័ន្ទធុច. *ទស្សនៈសម្ដេចព្រះសង្ឃរាជ ជួន ណាត ជោតញ្ញាណោ.* គ្មានកាលបរិច្ឆេទបោះពុម្ពផ្សាយ. ទំព័រ១៤

វាយតម្លៃគ្រឹះស្ថានសិក្សាណាមួយថាមានកម្រិតខ្ពស់ ឬមានកម្រិតទាប គឺសកម្មភាពបណ្ណាល័យ។ គេសង្កេតឃើញថា បណ្ណាល័យនៃគ្រឹះស្ថានសិក្សាណាដែលមានអ្នកអានច្រើន គ្រឹះស្ថានសិក្សានោះមានកម្រិតខ្ពស់។ បណ្ណាល័យនៃគ្រឹះស្ថានសិក្សាណាដែលមិនសូវមានអ្នកអាន គ្រឹះស្ថានសិក្សានោះ មានកម្រិតទាប។

បើតាម **លទ្ធិទឡ្ហនិយម** (progressivism) *"ទស្សនវិជ្ជាអប់រំគូសបញ្ជាក់ថា ទំនាក់ទំនងអប់រំត្រូវផ្អែកលើផលប្រយោជន៍ និងចំណូលចិត្តរបស់ក្មេង ហើយសេរីភាពរបស់បុគ្គលដែលជាអ្នកសិក្សាត្រូវផ្អែកលើប្រធានបទ។ ទស្សនវិជ្ជាអប់រំអះអាងថា ការសិក្សាជាដំណើរសកម្មស្វាហាប់ និងអះអាងថា អ្នកសិក្សាសិក្សាបានល្អបំផុត ប្រសិនបើគេជាអ្នកចូលរួមយ៉ាងសកម្មក្នុងដំណើរសិក្សា។ និយាយម្យ៉ាងទៀតថា ក្មេងត្រូវសិក្សាពីអ្វីដែលគេកំពុងរស់នៅ ហើយត្រូវទទួល និងឆ្លើយតបចំពោះពិសោធន៍របស់គេ ដែលផ្អែកលើកម្រិតនៃការយល់ដឹងរបស់គេស្តីពីស្ថានភាពដោយឡែកណាមួយ"* (This philosophy *"philosophy of education"* emphasizes that educational concern must be on the child's interests, desires, and the learner's freedom as an individual rather than on the subject matter. It asserts that learning is a dynamic or active process and a learner learns best if he is an active participant in the learning process. In other words, the child must learn what he lives and must accept and respond to his experiences based on the degrees of his understanding of a particular situation.)[៥] ។

ជាសេចក្តីសន្និដ្ឋាន យើងមិនអាចបំភ្លេចបាននូវបរិមាណនៃវិស័យអប់រំរបស់យើងដែលកំពុងរីកចម្រើន គ្រប់ភូមិសិក្សា - មត្តេយ្យសិក្សា បឋមសិក្សា មធ្យមសិក្សា ឧត្តមសិក្សា ក្រោយឧត្តមសិក្សា - ទាំងផ្នែករដ្ឋ ទាំងផ្នែកឯកជន

---

៥ Cecilio D. Duka, *Philosophy of education,* Rex Printing Company, Manila, Philippines, 2000, page 36.

ឡើយ ។ ការរត់តាមបរិមាណនេះជាតម្រូវការសមស្របតាមនិន្នាការរីកចម្រើននៃប្រទេសយើង។ ប៉ុន្តែ អ្វីដែលយើងព្រួយបារម្ភ គឺគុណភាពអប់រំ។ ជាធម្មតា ដើម្បីឱ្យវត្ថុរីកចម្រើន (វិស័យអប់រំ) បរិមាណ និងគុណភាព ត្រូវដើរទន្ទឹមគ្នា និងជះឥទ្ធិពលទៅវិញទៅមក។ បើបរិមាណលឿនហួសគុណភាព វត្ថុនោះមិនអាចរីកចម្រើនទៅទៀតបានឡើយ ។

ដើម្បីឱ្យគុណភាពអប់រំមានតុល្យភាពជាមួយនឹងបរិមាណអប់រំ យើងបានលើកចំណុចសំខាន់បួនយ៉ាងមកពិចារណាគឺ ÷ ការគ្រប់គ្រងកម្មវិធីសិក្សាសីលធម៌វិជ្ជាជីវៈ និងសមត្ថភាពវិទ្យាសាស្ត្របច្ចេកទេសនៃបុគ្គលិកសិក្សា និងការភ្ញាក់រឭករបស់សិស្សានុសិស្ស។ កត្តាទាំងបួននេះស្ថិតនៅក្នុងចំណងតែមួយ និងជះឥទ្ធិពលទៅវិញ ទៅមក ដែលធ្វើឱ្យចំណងនោះកាន់តែរឹងមាំឡើង។ បើខ្វះកត្តាណាមួយ គុណភាពអប់រំមិនអាចកើតមានឡើយ ។

ដូចយើងបាននិយាយហើយថា គុណភាពអប់រំនៅទីនេះមិនមែនសំដៅតែទៅលើគុណភាពខាងសមត្ថភាព វិទ្យាសាស្ត្របច្ចេកទេសប៉ុណ្ណោះទេ តែសំដៅលើគុណភាពខាងសមត្ថភាពសីលធម៌ផងដែរ។ **សាពួរ រ៉ាសិុច** (Shapour Rassekh) អះអាងថា *"ការអប់រំមានទិសដៅធ្វើឱ្យបុគ្គលិកលក្ខណៈរបស់មនុស្សរីកចម្រើនពេញលេញ និងពង្រឹងការគោរពសិទ្ធិមនុស្ស និងគោរពសេរីភាពចម្បង។ ការអប់រំត្រូវធ្វើឱ្យមានការយល់គ្នា ការអត់ឱនគ្នា និងការរក្សាមិត្តភាពរវាងជាតិពូជ សាសន៍ និងសាសនា ព្រមទាំងសំដៅលើអភិវឌ្ឍន៏សកម្មភាពនៃអង្គការសហប្រជា ជាតិដើម្បីថែរក្សាសន្តិភាព"* (L'éducation doit viser au plein épanouissement de la personnalité humaine et au renforcement du respect des droits de l'homme et des libertés fondamentales. Elle doit favriser la compréhension, la tolérance et l'amitié entre toutes les nations et les groupes raciaux ou religieux, ainsi que le développement des activités des

Nations Unies pour le maintien de la paix.)[៦] ។ ពិតណាស់ វិទ្យាសាស្ត្រខ្វះមនសិការ ជាវិទ្យាសាស្ត្របំផ្លិចបំផ្លាញព្រលឹងមនុស្ស (Science sans conscience n'est que ruine de l'âme.) ។ ព្រំនោលនេះ គួសបញ្ជាក់ច្បាស់ពីតួនាទីដ៏សំខាន់នៃទស្សនវិជ្ជាសីលធម៌នៅក្នុងប្រព័ន្ធអប់រំ ។

---

*ប្រកបដោយកិរិយាមារយាទសមរម្យល្អ និងវិជ្ជាគ្រប់បែប. មាននៅក្នុងផ្ទៃព្រះពុទ្ធសាសនាទាំងអស់ ។ ឧស្សាហ៍រៀនទើបចេះៗ ហើយទើបបានដឹងៗ ហើយទើបបានយល់ច្បាស់ ផ្លូវល្អ អាក្រក់គ្រប់យ៉ាង ។*

សម្តេចក្រុមព្រះ **ស៊ីសុវត្ថិ ‐ មុនីរ៉េត**

---

៦ Shapour Rassekh, *Éducation et Culture de la Paix,* Sélection bibliographique mondiale, IBE data, UNESCO, 1996, page 279.

# សីលធម៌ព្រះពុទ្ធសាសនា និងការប្រតិបត្តិនៅកម្ពុជា
## Buddhist Morality and Praticc in Cambodia

ដោយ ខួត ធីតា
បណ្ឌិតវិទ្យាសាស្ត្រទស្សនវិជ្ជា

### ១. ការអនុវត្តន៍ព្រះពុទ្ធសាសនា ទៅក្នុងសង្គមខ្មែរ

អ្វីដែលហៅថា សង្គមខ្មែរ ? សង្គមខ្មែរ គឺជនជាតិខ្មែរទាំងបុរស-ស្ត្រី ទាំងក្មេង-ចាស់ ទាំងអ្នកមាន-អ្នកក្រ ដែលរស់នៅតាមក្រុង/ខេត្ត/ស្រុក/ឃុំ/ភូមិ ។ ការរីកចំរើននៃសង្គមខ្មែរ រួមទាំងជំហរនៃសង្គមក្តី, វឌ្ឍនភាពនៃសង្គមក្តី ខ្មែរច្រើនយកព្រះពុទ្ធសាសនាជាបង្អែក ជាគោលមូលរបស់សង្គម ។ ជនជាតិខ្មែរ បានយកបុត្រទៅផ្ញើជាមួយលោកគ្រូចៅអធិការ ឬលោកគ្រូសូត្រ ឱ្យរៀនសូត្រ អក្សរខ្មែរ, រៀនច្បាប់ក្រម, ច្បាប់កេរកាល, ច្បាប់ពាក្យចាស់ ជាដើម ។ល ។ ការរៀនគម្ពីរក្បួនច្បាប់ខាងព្រះពុទ្ធសាសនា ព្រះសង្ឃជាគ្រូបាអាចារ្យបង្ហាត់បង្ហាញក្មេងឱ្យរៀនសូត្រ, អប់រំក្មេងឱ្យមានកិរិយាមាយាទត្រឹមត្រូវ ។ ពេលមានគេនិមន្តភិក្ខុសង្ឃទៅចម្រើនព្រះបរិត្ត ឬទេសនា ក្នុងពិធីបុណ្យអ្វីមួយនៅតាមភូមិនីមួយៗ លោកតែងយកក្មេងនោះតាមធ្វើជាវេយ្យាវច្ចករ គឺអ្នកទទួលនូវបច្ច័យដែលឧសក-ឧបាសិកា បានប្រគេនចំពោះសង្ឃ ។

លុះដល់ចម្រើនវ័យ, មានចំណេះវិជ្ជាល្មមបំពេញផ្នួសបាន, គ្រូអាចារ្យនៃក្មេងនោះ បានទទួលការព្រមព្រៀងពីមាតាបិតា ក៏បំបួសក្មេងនោះជាសាមណេរ គឺបព្វជិតពុទ្ធសាសនិកអ្នកកាន់សីល ១០ និងត្រូវសិក្សាឱ្យចេះសាមណេរវិន័យ គឺឱ្យចេះយ៉ាងតិចត្រឹមសិក្ខាបទ ១០, ទណ្ឌកម្ម ១០, នាសនង្គៈ ១០, សេក្ខិយវត្ត ៧៥ សិក្ខាបទ និងខន្ធកវត្ត មានឧបជ្ឈាយវត្ត ជាដើម

រួចបន្តរៀនសូត្រមុខវិជ្ជាធម៌/វិន័យ នៅសាលាធម្មវិន័យ ឬវិជ្ជាផ្លូវធម៌-ផ្លូវលោក នៅសាលាបាលីរង (សាលាពុទ្ធិកបឋមសិក្សា)។ ក្រោយបានបញ្ចប់ការសិក្សាថ្នាក់ពុទ្ធិកបឋមសិក្សាហើយ សាមណេរដែលជាសមណសិស្សអង្គនោះ អាចដាក់ពាក្យសុំប្រឡងចូលរៀននៅពុទ្ធិកវិទ្យាល័យ មានរយៈពេល ៤ ឆ្នាំ នៅខេត្តណាមួយ រហូតអាចបន្តរៀននៅពុទ្ធិកមហាវិទ្យាល័យតទៅទៀត ក្រោយពីបានបញ្ចប់ការសិក្សានៅថ្នាក់មធ្យម ។

លុះដល់អាយុគ្រប់ ២០ ឆ្នាំ សាមណេរនោះអាចនឹងសុំបំពេញផ្នួសជាភិក្ខុភាព មានភេទឧត្តមជាងសាមណេរ. កាន់សីល ៤ និងសិក្ខាបទ ២២៧ ។ ពុទ្ធសាសនិកជនទាំងឡាយ តែងគោរព និងឧបត្ថម្ភភិក្ខុ-សាមណេរ ដោយបច្ច័យ ៤ បច្ច័យណាមួយ តាមសទ្ធា និងលទ្ធភាព ។

លុះពេលដែលព្រះភិក្ខុ-សាមណេរ មានចំណេះវិជ្ជាខាងផ្លូវសាសនាបរិបូរណ៍ ឧបាសក-ឧបាសិកា តែងនិមន្តទៅសំដែងធម៌ទេសនា ។ ពេលខ្លះពួកពុទ្ធមាមកជនបានសវនានូវពាក្យទូន្មានគ្រើនរំលឹកពីព្រះភិក្ខុ-សាមណេរនោះ ពិសេសក្នុងពិធីបុណ្យនីមួយៗ ដែលមាននៅក្នុងសង្កាត់ក្រុង ខេត្ត ស្រុក ឃុំ ភូមិ ដែលមានប្រដៅ ឱ្យចេះធ្វើទាន ឱ្យរៀនរក្សាសីល រៀនធ្វើចិត្តឱ្យនឹង និងរៀនបណ្តុះ បញ្ញាជាដើម ។ល។

ហេតុនេះហើយ ទើបព្រះពុទ្ធសាសនាបានរចនាពួកពុទ្ធសាសនិកជន ឱ្យមានចរិយា មានកិរិយាសុភាព មានសីលធម៌ និងមានសតិប្រាជ្ញា ថ្លៃថ្លា ដែលជាហេតុ អាចជួយឱ្យសង្គមខ្មែរទាំងមូលមានការរីកចំរើនទាំងស្មារតី ទាំងសម្ភារៈ ។

ពុទ្ធសាសនិកជនទាំងឡាយជាគ្រហស្ថ ដែលបានរក្សានិច្ចសីលហើយ. កាលបើមានសទ្ធាជ្រះថ្លាលូតលាស់ចង់រក្សាសីលឱ្យពិសេសជាងនោះទៅទៀត ក៏គួរសមាទានសីល ៨ ដែលជាឧបោសថសីលតាមកាលកំណត់ ក្នុងមួយខែ ៤ ដង

គឺខាងខ្នើត ២ ដង ខាងរនោច ២ ដង ។ ក្នុងថ្ងៃនោះ ខ្លះទៅសុំឧបោសថសិល ឯវត្តអារាម ខ្លះនិមន្តព្រះភិក្ខុសង្ឃមកឱ្យសីលឯគេហដ្ឋាន ។

អ្នកសមាទានឧបោសថសីល ឬសីលប្រាំបី ត្រូវតមដោយវិរតិចេតនា ត្រឹមយប់ ១ ថ្ងៃ ១ ដូចខាងក្រោម :

១ - វៀរមិនសម្លាប់សត្វ

២ - វៀរមិនលួចទ្រព្យគេ

៣ - វៀរមិនធ្វើមេថុនសេវនៈ

៤ - វៀរមិននិយាយកុហក

៥ - វៀរមិនសេពសុរា និងមេរ័យ

៦ - វៀរមិនបរិភោគភោជនាហារ ក្នុងវេលាវិកាល

៧ - វៀរមិនរាំ ច្រៀងប្រគំ មិនមើលល្បែងរបាំ មិនស្តាប់នូវចំរៀងរបាំភ្លេងតន្ត្រី

៨ - វៀរមិនអង្គុយ មិនដេកលើអាសនៈខ្ពស់ហួសប្រមាណ ។

ក្រោយដែលព្រះភិក្ខុនិមន្តស្រស់ស្រូបបបរយាគូ ឬគុយទាវរួចជាស្រេច លោកក៏ប្រទានសិក្ខាបទទាំងប្រាំបី ដោយឧបាសក ឧបាសិការថាតាមលោក រហូតដល់ចប់ ។ ឧបាសក ឧបាសិកា ដែលទៅសុំសិលឯវត្ត ក៏យកម្ហូបអាហារ ទៅប្រគេនព្រះសង្ឃ ព្រមទាំងធូបទៀន ។ ឧបាសក-សិកា ដែលនិមន្តព្រះសង្ឃ មកសុំសីលឯគេហដ្ឋានក៏ត្រូវធ្វើម្ហូបអាហារ ថ្ងៃត្រង់ប្រគេនព្រះសង្ឃឆាន់ ។

លុះចប់ពិធីសុំឧបោសថសីល ព្រះភិក្ខុសង្ឃក៏ទទូលភត្តាហារ និងធ្វើអនុ-មោទនា ( សំដែងសេចក្តីត្រេកអរតាម ) ។

លំដាប់តមក ពួកពុទ្ធសាសនិកជន ក៏ផ្សាយបុណ្យនោះបុព្វការីបុគ្គលគ្រប់យ៉ាង ឱ្យទទូលនូវភាគផល បុណ្យកុសលនេះគ្រប់ៗគ្នា ។

លុះពួកសាសនិកជន ហាត់សូមឧបោសថសីលយូរៗទៅមានចិត្តចង់ធ្វើសមាធិកដ្ឋាន ក៏ស្វែងរកវត្តណា ដែលមានសភាពស្ងប់ស្ងាត់ដូចជាវត្ត ទួលតឹង វត្តពិភទ្ធរង្សីជាដើម ឬវត្តខាងខេត្តក្រៅដូចជាវត្តភ្នំសំបុក (ក្រចេះ) វត្តភ្នំប្រុស (កំពង់ចាម ) វត្តភ្នំសំពៅ វត្តភ្នំធម្មចក្រ (បាត់ដំបង ) ជាដើម ។ ឧបាសក ឧបាសិកា ក៏ស្ថិតនៅតាមតួប ពឹងផ្អែកលើព្រះភិក្ខុសង្ឃ មួយអង្គជាគ្រូអាចារ្យរបស់ខ្លួន ហើយក៏ចម្រើនសមថកម្មដ្ឋាននៅទីនោះ ។ កម្មដ្ឋានទាំងសែសិប ឧបាសក ឧបាសិកា ត្រូវយកកម្មដ្ឋានណាមួយមកភាវនាតាម ចរិតនិស្ស័យរបស់ខ្លួន បើតាមពិតលោកគ្រូនេះឯង ដែលលោកត្រូវរំលែកទៅតាមចរិត ដាក់កម្មដ្ឋានឱ្យភាវនា ។ បើភាវនាទៅហើយ ចិត្តនោះមានស្ថិតនៅនឹងមួយខណៈៗហៅថា ខណិកសមាធិ បើស្ថិតនឹងបានយូរបន្តិចទៅទៀតហៅថា ឧបចារសមាធិ បើស្ថិតនឹងដល់អប្បនាសមាធិ ចិត្តក៏នឹងក្នុងអារម្មណ៍តែមួយឯកឯងហៅថា ឯកគ្គតាសមាធិ ឬឯកគ្គតាចិត្ត ។ លំដាប់តមក ចិត្តក៏ចូលទៅដល់ឈានជាលោកិយ គឺឈានចតុក្កន័យ និងបញ្ចកន័យ ។ ក្នុងពេលនោះ នីវរណធម៌ដែលជាធម៌រាំងរាចិត្ត មិនឱ្យប្រព្រឹត្ត កងការកុសលបាន ក៏ទ្រោបចុះទៅ ។

ការប្រព្រឹត្តទាន សីល ភាវនានេះឯង ដែលរចនាមិនត្រឹមតែបុគ្គលឱ្យមានចរិយាល្អរៀបរយទេ ថែមទាំងចម្រើនដល់គ្រួសារ សង្គមទៀត ចម្រើនទាំងផ្លូវកាយ ទាំងផ្លូវចិត្ត កែប្រែទាំងរូបធម៌ ទាំងនាមធម៌ ទៅកាន់វិវឌ្ឍនធម៌ បើបុគ្គលចម្រើនដុះដាលឡើង សង្គមខ្មែរក៏ចម្រើនតាមលំដាប់ ។

សង្គមខ្មែរ បើប្រព្រឹត្តតាមសេចក្តីទូន្មាន នៃព្រះពុទ្ធសាសនាឱ្យពេញលក្ខណៈនិងបានទៅកាន់ឧត្តមភាពជាមិនខាន ។

សេចក្តីទូន្មាននេះរួបរួមមកមានតែបីយ៉ាងគឺ:

១ - មិនប្រព្រឹត្តនូវបាបអកុសល

២ - ប្រព្រឹត្តតែបុណ្យកុសល

៣ - ធ្វើចិត្តរបស់ខ្លួនឱ្យផូរផង់

បើលោកអ្នកបានប្រព្រឹត្តប្រតិបត្តិតាមធម៌ទាំងបីយ៉ាងខាងលើ លោកអ្នកនឹងបានឃើញច្បាស់នូវធម៌ និងវិន័យព្រះពុទ្ធសាសនាពុំខាន ។

២ - ជីវភាពភិក្ខុសាមណេរក្នុងវត្តអារាម

ព្រះសង្ឃមានពីរខណៈគឺខណៈមហានិកាយ និងគណៈធម្មយុត្តិ ។

ព្រះភិក្ខុសាមណេរ លោកកើតឡើង ម៉ោង ៤ ឬ ៥ ជិតបែកបច្ចូសសម័យលោកក៏និមន្តទៅសូត្រធម៌ថ្វាយបង្គំព្រះរតនត្រ័យក្នុងព្រះវិហារ រួចក៏និមន្តទៅទ្រង់បិណ្ឌបាតតាមច្រកល្ហក វិថីក្នុងក្រុង តាមផ្លូវក្នុងខេត្តក្រៅ ស្រុក ឃុំ ភូមិ ។ ឧបាសក ឧបាសិកា ក៏ក្រោកពីព្រលឹមដាំបាយដាក់បាត ។ នៅប្រទេសកម្ពុជាយើងច្រើនតែដាក់បាយ មិនសូមមានប្រគេនម្ហូបអាហារ មានភិក្ខុសង្ឃអង្គខ្លះ មានញោមឧបត្ថម្ភ ក៏ធ្វើចង្ហាន់ប្រគេន ដល់ពេលជិតថ្ងៃត្រង់ មានកូនសិល្បយួរចានស្រាក់ទៅទទួលចង្ហាន់ពីពុទ្ធសាសនិជនម្នាក់ ដែលគេបានបវរណាលោកជាមុន មានព្រះសង្ឃអង្គខ្លះទៀត ដោយលោកមានកូនសិស្សគណច្រើន ការបិណ្ឌបាតនោះក៏មិនបានអាហារពេញបរិបូរណ៍ ត្រូវចំអិនអាហារនៅទីកុដិទៀត វត្តខ្លះមានយាយជីធ្វើម្ហូបអាហារ សម្រាប់ព្រះសង្ឃឆាន់ទាំងអស់ វត្តខ្លះមានឧបាសក ឧបាសិការ ផ្លាស់វេនគ្នាធ្វើម្ហូបអាហារ ។ ដល់ពេលថ្ងៃឧបោសថសីល ព្រះសង្ឃសំបូរចង្ហាន់ ព្រោះឧបាសកឧបាសិកា ដែលសុំសីលគេយកបាយម្ហូបចំណីគ្រប់យ៉ាងទៅប្រគេនចៅអធិការ១ បែងចែកទៅព្រះភិក្ខុសាមណេរគ្រប់អង្គ ក្នុងវត្តនីមួយ១ ។ ដល់ពេលឆាន់រួច លោកសម្រាកមួយស្របក់ ទើប

និមន្តទៅរៀនសូត្រ ព្រះភិក្ខុសាមណេរក្នុងក្រុង ក៏និមន្តទៅរៀនឯសាលាបាលីរង សាលាធម្មវិន័យ ពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត និងពុទ្ធិកមហាវិទ្យាល័យ ជាបន្ត ។

លុះដល់ពេលល្ងាច ព្រះសង្ឃមិនឆាន់ម្ហូបអាហារទេឆាន់បាន តែទឹកតែ ស្ករ ទឹកក្រូច ជាដើមវៀរលែងតែសុរានិងមេរ័យ ។

ក្នុងពេលដែលឆាន់ ព្រះសង្ឃត្រូវចម្រើនបច្ចវេក្ខណៈពិចារណាម្ហូប អាហារនោះ ឱ្យទៅជាអាហារបដិកូលសញ្ញាទើបឆាន់បាន ។

ពេលយប់ត្រូវរៀនសូត្រធម៌វិន័យ ក្បួនច្បាប់ព្រះពុទ្ធសាសនា ឱ្យចេះ ចាំស្ទាត់មានព្រះបរិត្តជាដើម រួចថ្វាយបង្គំព្រះទើបសឹងបាន ។ ព្រះសង្ឃត្រូវ បំពេញនូវសង្ឃកម្មតាមពុទ្ធានុញ្ញាតមានការសំដែងនូវអាបត្តិជាដើម ។ ម្យ៉ាង ទៀតព្រះសង្ឃត្រូវនៅចាំវស្សាអស់ត្រីមាសក្នុងវត្តណាមួយ តាំងពីថ្ងៃចូលវស្សា រហូតដល់ថ្ងៃចេញវស្សា វៀរតែមានការមមាញឹកជាដើមដូចជា បិតា មាតា ជម្ងឺ ឬគ្រូឧបជ្ឈាយាចារ្យមានរោគាពាធ តែព្រះសង្ឃ ក្នុងពេលនោះមិនត្រូវចេញ ពីវត្ត ដែលខ្លួនចាំព្រះវស្សាលើសពី មួយសប្តាហ៍សោះឡើយ ។ មុននឹងនិមន្ត ទៅលោកត្រូវអធិដ្ឋានថាលោក នឹងនិមន្តវិលត្រឡប់មកកាន់វត្តវិញតាមកំណត់ កាល ។ ក្រៅពីនេះដោយសេចក្តីនិមន្ត នៃឧបាសក ឧបាសិការ ជើងវត្តក្នុងកិច្ច ចម្រើនព្រះបរិត្ត សំដែងធម៌ទេសនា លោកអាចនិមន្តទៅបាន ។

ជួនកាលដោយមានហេតុអ្វីមួយមានរោគាពាធជាដើម ព្រះសង្ឃអង្គ ណាមួយមិនអាចនឹងចូលវស្សាបាន ក្នុងករណីនេះលោកត្រូវចូលវស្សានូវថ្ងៃទី១ នៃ ខែ ស្រាពណ៍ ។

តែព្រះសង្ឃនៅក្នុងវត្តអារាម ដែលនិមន្តចូលចេញពីទីវត្ត ត្រូវឱ្យដំណឹង

ដល់ចៅអធិការវត្ត បើចៅអធិការមិននៅដល់គ្រូសូត្រ ។

ភិក្ខុ ឬសាមណេរអង្គណា ដែលគង់នៅក្រៅវត្ត ឬវត្តឯទៀត ហើយនិមន្តមកសុំគង់នៅវត្តណាមួយផ្សេង ត្រូវសូមអនុញ្ញាតិពីចៅអធិការវត្ត ដែរលោកបម្រុងនឹងគង់នៅ ។ ភិក្ខុអង្គណាដែលប្រព្រឹត្តមោះមិនគប្បីនៅក្នុងវត្តអារាម បើអំពើដែលធ្វើនោះ ជាបទឧក្រិដ្ឋដូចជាអនន្តរិយកម្ម ឬបំបែកសង្ឃឈ្លោះទាស់ទែងគ្នាក្នុងវត្តជាដើម ចៅអធិការវត្តអាចដេញចេញ មិនឱ្យលោកភិក្ខុអង្គនោះគង់នៅវត្តបាន ។

ពោលមកប៉ុណ្ណោះ ដើម្បីឱ្យឃើញថាជីវភាពភិក្ខុសាមណេរ នៅក្នុងវត្តអារាមគ្មានអ្វីក្រៅពីការឆាន់ចង្ហាន់ និងការធ្វើសង្ឃកម្មរៀនសូត្រគម្ពីរបាលីទេ ព្រោះមានឧបាសក ឧបាសិកាជើងវត្តឧបត្ថម្ភ ដោយចតុប្បច្ច័យ គ្រប់ យ៉ាងគឺចិវរប្បច្ច័យការកង្វល់ បលិពោធដោយរក របរទទួលទានគ្មាន ។

# វិធីសាស្ត្រក្នុងការស្រាវជ្រាវ វប្បធម៌ (ប្រពៃណី ទំនៀមទម្លាប់)

(តចប់)

ដោយៈ **បណ្ឌិត នេត បារ៉ុម**

## ២ - ការរៀបចំគម្រោងស្រាវជ្រាវសម្រាប់វិធីសាស្ត្រគុណវិស័យ

ក្រោយពេលកំណត់រកបាននូវបញ្ហាស្រាវជ្រាវ និងពិនិត្យឡើងវិញនូវឯកសារពាក់ព័ន្ធបានខ្លះ អ្នកស្រាវជ្រាវត្រូវអភិវឌ្ឍនូវគម្រោងស្រាវជ្រាវ (Research design) ។ គឺជាផែនការ ឬយុទ្ធសាស្ត្រសម្រាប់ធ្វើការស្រាវជ្រាវ ។

មានរបៀបចែកថ្នាក់ការសិក្សាស្រាវជ្រាវច្រើនយ៉ាង ។ ជាទូទៅ គេពិនិត្យឃើញមានប្រព័ន្ធបីយ៉ាងនៃការចែកថ្នាក់ :

- ទីមួយ គឺចែកថ្នាក់ផ្អែកទៅតាមគោលបំណង ឬ គោលដៅនៃការស្រាវជ្រាវ ។
  ឧទាហរណ៍ ការស្រាវជ្រាវមូលដ្ឋាន និងការស្រាវជ្រាវអនុវត្ត ។
  ទីពីរ ផ្អែកទៅលើដំណៅទិសពីរ ដែលចែកជាចំពាម នឹងគ្នាសម្រាប់ការសិក្សាស្រាវជ្រាវបាតុភូត : ឧទាហរណ៍ ការស្រាវជ្រាវតាមគុណវិន័យ និងបរិមាណវិស័យ ។

- ទីបី ទៅតាមវិធីទូទៅដែលប្រើក្នុងការស្រាវជ្រាវវប្បធម៌ ។

ការស្រាវជ្រាវតាមគុណវិស័យ ពណ៌នាបាតុភូតជាពាក្យសំដីជាជាងចំនួនឬរង្វាស់ ។ ប្រភពរបស់វាជាការវិភាគពណ៌នា ដែលមានលំនាំជាអនុមានញែក

(Inductive) ពិចារណាហេតុផលពីស្ថានភាពជាក់លាក់ទៅជាការសន្និដ្ឋានទូទៅមួយ ។ (Krathworth, 1993)

ការស្រាវជ្រាវតាមបរិមាណវិស័យ ពណ៌នាបាតុភូតជាចំនួន និងវង្វាស់ជាជាងការប្រើពាក្យសំដី ។ វាផ្សាភ្ជាប់ទៅនឹងវិធីអានុមានរូម (Deductive) ពិចារណាហេតុផលពីគោលការណ៍ទូទៅជាស្ថានការណ៍ជាក់លាក់ ហើយមានឫសគល់ជាវិធីវិជ្ជមាន (positism) ដែលផ្សាភ្ជាប់ជិតស្និទ្ធទៅនឹងវិធីវិទ្យាសាស្ត្រជាងការស្រាវជ្រាវតាមគុណវិស័យ ។ (Krathworth,1993)

## ២.១ លក្ខណៈសម្គាល់នៃការស្រាវជ្រាវបែបគុណវិស័យ

លក្ខណៈសម្គាល់សំខាន់ៗមាន :

ក. បាតុភូតទាំងឡាយគប្បីត្រូវពិនិត្យមើលដោយលក្ខណៈទាំងស្រុង (holistically ) ហើយបាតុភូតស្មុគស្មាញមិនអាចកាត់បន្ថយត្រឹមកត្តាខ្លះៗ ឬបែងចែកជាផ្នែកឯករាជ្យពីគ្នាបានទេ ។

ខ. អ្នកស្រាវជ្រាវ ប្រតិបត្តិការជាបែបផែនធម្មជាតិមួយ ដោយសារការគិតគូចំពោះបរិបទ ហើយគប្បីរក្សាការនៅបើកទូលាយអំពីអ្វីដែលនឹងត្រូវសង្កេត ប្រមូល... ដើម្បីចៀសវាងការភ្លេច នូវអ្វីសំខាន់ ។

គ. គឺជាការយល់ដឹង នូវអ្វីដែលត្រូវសិក្សាស្រាវជ្រាវ ហើយការយល់ដឹងនេះត្រូវចាប់យកដើម្បីបាននូវវង្វាស់ត្រឹមត្រូវមួយនៃតថភាព ។ សារៈសំខាន់ គឺការយល់ដឹងដោយការសិក្សាស្រាវជ្រាវ ហើយមិនមែនដាក់ចេញដោយអ្នកស្រាវ-ជ្រាវទេ ។

ឃ. ការសន្មត និងការសន្និដ្ឋានទុកជាមុនគប្បីត្រូវចៀសវាង ដើម្បីគុណប្រយោជន៍ ដល់ការសន្និដ្ឋាន ក្រោយការសិក្សាស្រាវជ្រាវ ។ ការសន្មត និងសន្និដ្ឋានអាចមានការផ្លាស់ប្តូរទៅតាមអ្វីដែលបានមកពីការស្រាវជ្រាវ ។

ង. បាតុភូតទាំងឡាយនៅក្នុងលោកនេះ ត្រូវបានយល់ដឹងដូចគំរូម្យ៉ាង ដែលស្ថាបនាឡើងដោយមិនទាន់ច្បាស់លាស់មួយអាចបត់បែនបានតាមការទស្សន៍ទាយ ហើយមួយទៀតមិនរត់តាមលក្ខណៈមេកានិច នៃច្បាប់ដែលកើតមានទេ ។

## ២.២ ផ្នែកនៃគម្រោងស្រាវជ្រាវនៅក្នុងការស្រាវជ្រាវបែបគុណវិស័យ

- *គំរោងការងារ* (working design) គឺជាផែនការដើមដំបូងដែលជាមួយនោះការស្រាវជ្រាវចាប់ផ្តើម ។ វាជាការសម្រេចអំពីកម្មវត្ថុ/ មុខសញ្ញា ឬ ទីកន្លែង ដើម្បីធ្វើការសិក្សាស្រាវជ្រាវរយៈពេលសម្រាប់ប្រមូលទិន្នន័យ និងអថេរដែលត្រូវយកមកគិត ។

- *សមតិកម្មការងារ* (Working hypothesis) : ការស្រាវជ្រាវបែបគុណវិស័យប្រើប្រាស់ការសាកសួរពតិមានបែបអានុមានញែកចំពោះការប្រមូលទិន្នន័យ នេះមានន័យថា វាចាប់ផ្តើមដោយមិនបានគិតដល់ទ្រឹស្តី ឬសមតិកម្មណាជាមុនទេ ។ អ្នកស្រាវជ្រាវទាំងអស់ តែងរងនូវឥទ្ធិពលនៃសាវតាផ្ទាល់របស់ពួកគេ ហើយពតិមានមួយចំនួននឹងអាចរកបានអំពីបញ្ហាស្រាវជ្រាវ ។ មុនដំបូងបញ្ចូលបញ្ញត្តិជាប្រផ្នូល ដែលមិនទាន់

ជាការសម្តែងនូវសមតិកម្មទេ ។ បន្ទាប់មក បញ្ចូលនូវសំណួរអំពីបញ្ហាស្រាវជ្រាវ ។ អាចមានសំណួរសមតិកម្ម និងបញ្ហាជាប្រថ្នូរជាច្រើន ដែលអាចពិនិត្យឡើងវិញ លុបចោល ឬពង្រីកនៅពេលដំណើរការប្រមូលទិន្ន័យ និងវិភាគ ។

- *ការប្រមូលទិន្នន័យ* (Data collection ) : ការប្រមូលទិន្នន័យអាចជា វិធីអន្តរកម្ម (interactive) ឬ មិនមែនអន្តរកម្ម (noninteractive) ។ បច្ចេកទេសអន្តរកម្មទាក់ទងទៅ នឹងអ្នកស្រាវជ្រាវអន្តរកម្មជាមួយកម្មវត្ថុ ឬមុខសញ្ញាស្រាវជ្រាវ ហើយបច្ចេកទេសមិនមែនអន្តរកម្ម ពុំប្រើអន្តរកម្មបែបនេះទេ ។ ក្នុងចំណោមវិធីប្រមូលទិន្នន័យជាច្រើន វិធីដែលគេច្រើនប្រើជាងគេគឺ ការសង្កេត (observation) សម្ភាស (interview) ប្រមូលនិងពិនិត្យឡើងវិញនូវឯកសារទាក់ទងកំណត់ត្រាគំរូយ៉ាង (specimen records) និងអនុវត្តប្រវត្តិសួរផ្ទាល់មាត់ (oral histories) ។ ការធ្វើសម្ភាសគឺជាឧទាហរណ៍មួយ នៃបច្ចេកទេសប្រមូលទិន្នន័យបែបអន្តរកម្ម ការពិនិត្យឡើងវិញនូវឯកសារទាក់ទង ដូចជាឯកសារប្រវត្តិសាស្ត្រ គឺជាបច្ចេកទេសមិនមែនអន្តរកម្ម ។ម្យ៉ាងវិញទៀត ដើម្បីប្រមូលទិន្នន័យ អ្នកស្រាវជ្រាវអាចជាអ្នកសង្កេតចូលរួម (participant-observer) ឬគ្រាន់តែជាអ្នកសង្កេតធម្មតា ទូទៅប៉ុណ្ណោះ ។

- *ការវិភាគនិងបកស្រាយទិន្នន័យ* (Data Analysis and Interpretation ) ៖ ការវិភាគទិន្នន័យនៅក្នុងការស្រាវជ្រាវបែបគុណវិស័យ ចាប់ផ្ដើមឡើងវិញភ្លាមបន្ទាប់ពីការប្រមូលទិន្នន័យចាប់ផ្ដើម ពីព្រោះអ្នកស្រាវជ្រាវស៊ើបអង្កេតសមតិកម្ម លទ្ធផលដែលមិនបានប្រមើលទុកមុន និងអ្វីដែលស្រដៀងគ្នានេះ ។ នៅពេលដំណើរការ ការស្រាវជ្រាវទិន្នន័យ ដែលប្រមូលបានកាន់តែតិចទៅ ហើយការវិភាគកាន់តែកើនឡើង ។ ជាក់ស្ដែងជំហានទាំងនេះជាន់គ្នា ។

ការវិភាគទិន្នន័យបែបគុណវិស័យ ទាមទារនូវការចាត់ចែងពត៌មាន (information organization) និងការកាត់បន្ថយទិន្នន័យ (Data reduction) ។ ការប្រមូលទិន្នន័យដំបូង អាចផ្ដល់នូវសមតិកម្ម ឬទ្រឹស្ដី ហើយបន្ទាប់មកទិន្នន័យកាន់តែច្រើនអាចត្រូវបានប្រមូលដើម្បីគាំទ្រ ឈប់អះអាង (disconfirm) ឬពង្រីកសមតិកម្ម ឬទ្រឹស្ដី ។ រួមសេចក្ដីមក ការវិភាគនៅក្នុងការស្រាវជ្រាវ បែបគុណវិស័យ គឺជាលំនាំបង្ហិតជិតជាបន្តបន្ទាប់ ឆ្ពោះទៅរកការពិពណ៌នា និងការបកស្រាយដោយត្រឹមត្រូវនូវបាតុភូត ។

## ២.៣ ទស្សនៈវិស័យចំពោះការស្រាវជ្រាវបែបគុណវិស័យ (Perspective for Qualitative Research)

វិធីបង្រួម (Funnel approach) និងវិធីអានុមានញែកវិភាគកែប្រែ (modified analytic induction approach) គឺជាវិធីពីរផ្ទុយគ្នា ដែលយើងអាចយកមកគិតអំពីការអនុវត្តន៍សម្រាប់គម្រោងស្រាវជ្រាវបែបគុណវិស័យ ។

*វិធីបង្រួម* ចាប់ផ្តើមដោយសំណួរស្រាវជ្រាវទូទៅ ដែលផ្តួចផ្តើមការ ស្រាវជ្រាវ ។ អ្នកស្រាវជ្រាវរុករកទីកន្លែង មុខសញ្ញា ប្រភពទិន្នន័យដែលអាចមាន ហើយ និងទម្រង់ការសម្រាប់ការប្រមូលទិន្នន័យ ។ លើមូលដ្ឋាននៃលិទ្ធផលពីការប្រមូលទិន្នន័យដើមដំបូង ក្រុម/ទីកន្លែង/លក្ខខណ្ឌត្រូវបានកំណត់រកដោយជាក់លាក់ជាងទៀត គឺការផ្តល់នូវការផ្តោតអារម្មណ៍កើនឡើងអំពីបាតុភូត ដែលធ្វើការសិក្សាស្រាវជ្រាវ ។ លំនាំនេះ ឆ្ពោះទៅការប្រមូលទិន្នន័យកាន់តែចង្អៀតជាងទៀត ដោយប្រមូលផ្តុំលើទិន្នន័យទាំងនោះ ដែលឆ្លុះបញ្ចាំងនូវបាតុភូតជាក់លាក់ដែលបានលេចឡើង ។ លំនាំនេះអាចរំលីកឡើងវិញដោយកាន់តែផ្តោតឡើងរហូតដល់ការសន្និដ្ឋានបានប្រមូលផ្តុំលើផ្នែកជាក់លាក់មួយ ឬចំនួនកំណត់មួយនៃផ្នែករបស់ការសិក្សាស្រាវជ្រាវ ។ ការប្រមូលទិន្នន័យនៃការវិភាគ និងការបកស្រាយបានក្លាយកាន់តែផ្តោតឡើង តម្រង់ទៅឬបង្រួមពីការចាប់ផ្តើមដែលទូទៅជាងមួយ ។

ផ្ទុយទៅវិញ *វិធីអានុមានវៀកវិភាគកែប្រែ* ចាប់ផ្តើមដោយបញ្ហា ឬសំណួរស្រាវជ្រាវដែលជាក់លាក់ជាង ហើយបន្ទាប់មកខិតខំគ្របដណ្តប់គ្រប់ករណីទាំងអស់នៃបាតុភូត ដែលប្រមូលបានអំពីការសិក្សាករណីខ្លះសមស្របទៅនឹងគំរូខ្លះទៀតក៏មិនសមស្របទៅនឹងគំរូដើមនេះ ។ មានការតាក់តែងឡើងវិញនូវគំរូដើម្បីតម្រូវទៅគ្រប់ករណី ហើយទិន្នន័យកាន់តែច្រើនត្រូវបានប្រមូល រួមទាំងការស្វែងរកករណីដែលមិនសមស្រមទៅនឹងគំរូដើម្បីតាក់តែងឡើងវិញនេះ ។ លំនាំប្រមូលទិន្នន័យ និងការតាក់តែងគំរូឡើងវិញនេះ ចេះតែបន្តរហូតដល់បានការបកស្រាយពន្យល់មួយគ្រប់គ្រាន់ និងសកល សម្រាប់បាតុភូតដែលសិក្សាស្រាវជ្រាវ ។

## ៣. ការស្រាវជ្រាវតាមបែបប្រវត្តិ (Historical Research)

ការស្រាវជ្រាវបែបប្រវត្តិ គឺជាលំនាំដែលមានលក្ខណៈជាប្រព័ន្ធមួយនៃការរុករកហេតុការណ៍ ហើយបន្ទាប់មកគឺប្រើប្រាស់ពត៌មានទាំងនោះដើម្បីពណ៌នាវិភាគ និងបកស្រាយអតីតកាល ។

ការស្រាវជ្រាវបែបប្រវត្តិ មានលក្ខណៈជាវិភាគ ដែលក្នុងនោះអានុមានញែកត្រូវបានប្រើដើម្បីឈានទៅដល់ការសន្និដ្ឋាន ។ ការស្រាវជ្រាវបែបប្រវត្តិផ្អែកយ៉ាងខ្លាំងលើវិធីស្រាវជ្រាវបែបគុណវិស័យ ក៏ប៉ុន្តែវិធីបរិមាណវិស័យ ក៏អាចអនុវត្តទៅក្នុងការស្រាវជ្រាវបែបប្រវត្តិបានដែរ ។ នៅពេលធ្វើការស្រាវជ្រាវ បែបប្រវត្តិការបកស្រាយ (interpretation) គឺជាបដ្សមណ្ឌលនៃលំនាំស្រាវជ្រាវ ។

ប្រភពពត៌មាន ដូចជាប្រភពឯកសារ និងប្រភពផ្សេងៗទៀត ទាមទារឱ្យអ្នកស្រាវជ្រាវត្រូវតែរស់ (sensitive) ទៅនឹងអត្ថិភាពនៃទិន្នន័យដែលពាក់ព័ន្ធ ។ ការស្រាវជ្រាវបែបប្រវត្តិ គឺជាវិទ្យាសាស្ត្រផង និងសិល្បៈផង ។

### ៣.១ ប្រភពពត៌មាននៅក្នុងការស្រាវជ្រាវបែបប្រវត្តិ ( Sources of Information in Historical Research )

*"ប្រភពដើម"* (Primary source) គឺជាគណនីដំបូងដៃ នៃព្រឹត្តិការណ៍ពិសោធន៍ ឬសង្កេតនៅក្នុងការស្រាវជ្រាវ ។

*"ប្រភពបន្ទាប់"* (secondary source) គឺជាគណនីយ៉ាងហោចឃ្លាតចេញមួយជំហានពីព្រឹត្តិការណ៍ពិសោធន៍ ឬសង្កេត ។

ឧទាហរណ៍ ប្រភេទទិន្នន័យដើម និងទិន្នន័យបន្ទាប់ :

| *ទិន្នន័យដើម (Primary data )* | *ទិន្នន័យបន្ទាប់ (Secondary data)* |
|---|---|
| កំណត់ត្រាសម្ភាស | ជីវប្រវត្តិផ្ទាល់ខ្លួន |

| | |
|---|---|
| សង្កេត | ស្ថិតិ |
| កំណត់ត្រាចុះផ្ទាល់ | កំណត់ត្រាប្រវត្តិសាស្ត្រ |
| អង្កេត | ឯកសារផ្លូវការ កាសែត ទូរទស្សន៍ វិទ្យុ |

### ៣.២ វិធីសាស្ត្រនៃការស្រាវជ្រាវបែបប្រវត្តិ (Methodology of Historical Research)

- ការកំណត់រកឱ្យឃើញនូវបញ្ហាស្រាវជ្រាវ
- ការប្រមូល និងវាយតម្លៃឯកសារជាប្រភព
- សំយោគពត៌មាន
- ការវិភាគ ការបកស្រាយ និងការតាក់តែងការសន្និដ្ឋាន

## ៤.ការស្រាវជ្រាវបែបជាតិពន្ធុសាស្ត្រ (Ethnographic Research)

ជាតិពន្ធុសាស្ត្រ (Ethnography) គឺជាវិស័យមួយនៃនរៈវិទ្យា (anthropology) ដែលជាប់ទាក់ទងទៅនឹងការពណ៌នាបែបវិទ្យាសាស្ត្រនៃវប្បធម៌មួយៗ ។

"នរៈវិទ្យា" ជាវិទ្យាសាស្ត្រមួយដែលពាក់ព័ន្ធជាមួយ ដើមកំណើត (origins) អភិវឌ្ឍន៍ និងលក្ខណៈសម្គាល់របស់មនុស្សជាតិ ដែលរួមមានទាំងកត្តាទំនៀមទម្លាប់ (customs) ជំនឿ (beliefs) និងអភិវឌ្ឍន៍វប្បធម៌ ។

លំនាំស្រាវជ្រាវបែបជាតិពន្ធុសាស្ត្រ គឺជាលំនាំដែលផ្តល់នូវការពណ៌នាទាំងស្រុង និងវិទ្យាសាស្ត្រនៃប្រព័ន្ធវប្បធម៌ លំនាំវប្បធម៌ និងបាតុភូតវប្បធម៌ នៅក្នុងរង្វង់បរិបទជាក់លាក់របស់វា ។ គឺជាលំនាំស៊ើបអង្កេតមួយ ដែលដឹកនាំដោយពិសោធន៍/សង្កេត នៅក្នុងការរៀបចំការស្រាវជ្រាវ ។

### ៤.១ លក្ខណះសម្គាល់នៃការស្រាវជ្រាវបែបជាតិពន្ធុសាស្ត្រ

* ធម្មជាតិបាតុភូតសាស្ត្រ (Phenomenological nature ) វិធីបាតុភូត

សាស្ត្រ បញ្ជាក់ថាអត្ថន័យ នៃតថភាពគឺ នៅក្នុងសារៈ (essence) នៅក្នុងភ្នែក (eyes) និងការគិត (minds) របស់អ្នកពិនិត្យមើល (beholders) ជារបៀបដែលបុគ្គលនីមួយៗត្រូវសិក្សាស្រាវជ្រាវយល់ដឹង អំពីបទពិសោធន៍/សង្កេតរបស់ពួកគេ ។

ធម្មជាតិបាតុភូតសាស្ត្រនៃការស្រាវជ្រាវ បែបជាតិពន្ធុសាស្ត្រជាប់ទាក់ទងនឹងបញ្ហា ÷

ក. ការសន្និដ្ឋាន/សន្មតមុនពិសោធន៍/សង្កេត អំពីបាតុភូតដែលត្រូវស្រាវជ្រាវត្រូវជៀសវាង ។

ខ. តថភាពត្រូវពិនិត្យមើលតាមបែបទាំងស្រុង និងជាបាតុភូតស្មុគស្មាញ ។

គ. បែបបទ និងឧបករណ៍ប្រមូលពត៌មាន ត្រូវមានឥទ្ធិពលដោយតិចបំផុតលើបាតុភូតស្រាវជ្រាវ ។

ឃ. ទ្រឹស្តីគប្បីបន្និចចេញពីទិន្នន័យ ដូចជាទ្រឹស្តីមូលដ្ឋាន (Grounded theory) ជាជាងទ្រឹស្តីដែលគិតទុកជាមុន ។

"ទ្រឹស្តីមូលដ្ឋាន" ត្រូវបានបង្កើតឡើងពីទិន្នន័យ ហើយការអភិវឌ្ឍន៍ទ្រឹស្តីមូលដ្ឋានទាមទារការយល់ច្បាស់លាស់ (insight) និងការយល់ដឹង (understanding) ហើយនិងអាចតម្រូវនូវការពិនិត្យឡើងវិញដដែលៗ(repetitive review) នៃទិន្នន័យ ។

* <u>លក្ខណៈតាមធម្មជាតិ</u> (Naturalistic nature)

ការដាក់តាំងតាមធម្មជាតិ គឺពុំមានការធ្វើអ្វីទៅលើអថេរ ពុំមានការប្រដូច ឬទម្រង់បង្ខិតបង្ខំពីខាងក្រៅទៅលើស្ថានការណ៍ ។

ការស្រាវជ្រាវបែបជាតិពន្ធុសាស្ត្រ សម្គាល់ដោយការស្រាវជ្រាវចុះផ្ទាល់ (field research) ដែលពាក្យ "ផ្ទាល់" (field) មានន័យថា ជាស្ថានការណ៍ធម្មជាតិ

ដែលក្នុងនោះការស្រាវជ្រាវធ្វើឡើង ។

* ទស្សនៈវិស័យទាំងស្រុង និងទូទៅ (**Holistic and general perspective**)

ការស្រាវជ្រាវបែបជាតិពន្ធុសាស្ត្រ ធ្វើឡើងតាមទស្សនៈវិស័យទូទៅ និងទាំងស្រុងដោយដំណើរការពីស្ថានភាពសមតិកម្មច្រើនលេចចេញពីទិន្នន័យ ជាជាងការតាក់តែងមុនពេលធ្វើការស្រាវជ្រាវ ។

ការស្រាវជ្រាវបែបជាតិពន្ធុសាស្ត្រ យកចិត្តទុកដាក់លើ " អង្គការ " (Organizations) ឬសហគមន៍ (communities) ដែលមានក្រុមមនុស្សជាកំណត់ធ្វើអន្តរកម្មតាមបែបទៀងទាត់ និងជារចនាសម្ព័ន្ធ ។

"អង្គការ" ដែលមានរចនាសម្ព័ន្ធឋានានុក្រម ត្រូវបានចាត់ដូចជាការផ្សំឡើងពីវប្បធម៌ទាំងឡាយ ហើយវប្បធម៌បង្កើតអង្គការ ។

"សហគមន៍" ត្រូវបានបង្កើតឡើងលើមូលដ្ឋាននៃតម្លៃចែករំលែកគ្នា ជំនឿ និងតម្រូវការ ។

## ៤.២ លំនាំនៃការស្រាវជ្រាវបែបជាតិពន្ធុសាស្ត្រ

លំនាំនៃការស្រាវជ្រាវបែបជាតិពន្ធុសាស្ត្រ គឺជាលំនាំចម្រុះគ្នា(integrated) មួយដែលនៅក្នុងនោះបែបបទទាំងឡាយត្រូវបានប្រព្រឹត្តឡើងស្របៗគ្នា ។

ថ្វីបើការស្រាវជ្រាវបែបជាតិពន្ធុសាស្ត្រ ពុំមានការចែកដំណាក់ការបន្តបន្ទាប់គ្នាអំពីសកម្មភាពឱ្យដាច់ស្រឡះ ក៏មានចំណុចផ្តើម និងចំណុចបញ្ចប់របស់វាដែរ ។

ក. ការកំណត់រកបាតុភូតដើម្បីស្រាវជ្រាវ គឺជាការកំណត់រកនូវបញ្ហាដែលបម្រុងនឹងកើតឡើង ( foreshadowed problem) ។ បញ្ហាទាំងនោះគឺជាកត្តាជាក់លាក់អ្វីមួយចំនួនដែលអនុវត្តទៅនឹងបាតុភូត និងផ្តល់ចំណុចរួមសម្រាប់ការ

ស្រាវជ្រាវ ។ វាបានមកពីការសម្តែងចេញជាទូទៅមួយ នៃបាតុភូតដែលនឹងត្រូវស្រាវជ្រាវ គឺជាចំណុចគោលដៅសម្រាប់ការស្រាវជ្រាវ ។

ខ. ការកំណត់រកមុខសញ្ញាស្រាវជ្រាវ (Identification of subjects) មុខសញ្ញា ឬកម្មវត្ថុដែលនឹងស្រាវជ្រាវ ត្រូវតែកំណត់រកឱ្យឃើញ ហើយជាធម្មតាចាំបាច់ត្រូវបញ្ជាក់អំពីលក្ខខណ្ឌ និងព្រំដែនកំណត់ (restrictions) ដែលការសិក្សាស្រាវជ្រាវអាចធ្វើទៅបាន ។

គ. ការបង្កើតសមតិកម្ម (Hypothesis generation) គឺជាសកម្មភាពបន្តបន្ទាប់ឆ្លងកាត់ការសិក្សាស្រាវជ្រាវបែបជាតិពន្ធុសាស្ត្រ ។ មិនដូចជាការស្រាវស្រាវបែបអង្កេត ឬពិសោធន៍ទេ ដែលសមតិកម្មវាត្រូវបានបញ្ជាក់តាំងពីខាងដើម និងបន្ទាប់មកសាកល្បងនោះទេ ការស្រាវជ្រាវបែបជាតិពន្ធុសាស្ត្រអាចចាប់ផ្តើម ដោយការគ្មានសមតិកម្ម ហើយសមតិកម្មអាចតាក់តែងបាននិងកែប្រែបាន នៅក្នុងពេលដំណើរការស្រាវជ្រាវ ។

ឃ. ការប្រមូលទិន្នន័យ (Data collection)

ការប្រមូលទិន្នន័យ ជាប់ទាក់ទងនឹងការប្រើប្រាស់រូបភាពជាច្រើនមានដូចជា :

- ការសង្កេត (Observation) ដែលជាសកម្មភាពសំខាន់ តាមរយៈការចុះ និងកត់ត្រាផ្ទាល់ដល់កន្លែង (field work and field notes)
- ការសម្ភាស (Interview) ធ្វើឡើងចំពោះមនុស្សគន្លឹះ/សំខាន់
- ការអង្កេតគាំទ្រ (support survey)
- ធនធានឯកសារសរសេរ (written resources) ខិតខំរកប្រភព

ដើម

- ការថតកាសែត្សវីដេអូ រូបថត វត្ថុបុរាណ (artifacts)
- ការប្រើវិធីត្រីកោណ (triangulation) ។

## ៤.៣ បច្ចេកទេសក្នុងការប្រមូលទិន្នន័យមួយចំនួន

ក. ការសង្កេត (Observation)

អ្នកសង្កេតត្រូវខិតខំធ្វើយ៉ាងណាកុំឱ្យគេសម្គាល់បាន ទៅតាមការដែលអាចធ្វើទៅកើត ហើយនិងចុះផ្ទាល់ដល់កន្លែង ។

អ្នកអង្កេត (ទាំងអ្នកអង្កេតចូលរួម) ត្រូវខិតខំសន្ទតតួនាទីរបស់បុគ្គលមួយៗ នៅក្នុងការសិក្សាស្រាវជ្រាវ និងដើម្បីសាកល្បងអំពីការគិត (thoughts) អារម្មណ៍ (feelings) និងអំពើ (actions) របស់ពួកគេ ដើម្បីបង្កើតទិន្នន័យពីទស្សនៈវិស័យរបស់បុគ្គលនីមួយៗទាំងនេះ ដែលកំពុងធ្វើការស្រាវជ្រាវ ។

ការសង្កេតនៅក្នុងការស្រាវជ្រាវបែបជាតិពន្ធុសាស្ត្រ មានលក្ខណៈជាបន្តបន្ទាប់ (continuing) និងទាំងមូល (total) ដោយគ្មានទម្រង់ច្បាស់លាស់ (unstructured) ។ ការកត់ត្រាចុះផ្ទាល់ គប្បីត្រូវសំយោគ និងសង្ខេបភ្លាមៗក្រោយពេលចុះសង្កេតរួច ។

ខ. ការថតវីដេអូ និងថតរូប (videotaping and photographing)

ការថតវីដេអូ/រូបថត មានសារៈប្រយោជន៍បំផុតសម្រាប់ការបង្កើតទ្រឹស្តីមូលដ្ឋាន ។ ចំណុចខ្សោយរបស់វា គឺពិបាកចាប់ជាប់ការពិភាក្សាទាំងអស់បាន ហើយអ្នកស្រាវជ្រាវពិបាកក្លែង ឬលាក់ខ្លួនណាស់ ដើម្បីរក្សាចរិតធម្មជាតិរបស់ពត៌មាន ។ គួរធ្វើឡើងនៅពេល ឬកន្លែងប្រមូលផ្តុំ (compact situations) ។

គ. ការសម្ភាស (Interview )

គេធ្វើឡើងចំពោះតែអ្នកផ្ដល់ពត៌មានសំខាន់ៗ ឬមនុស្សសំខាន់ៗ ប៉ុណ្ណោះ ។ លក្ខណៈសម្គាល់នៃការធ្វើសម្ភាសគឺត្រូវធ្វើឱ្យធម្មតា គ្មានពិធីការ ហើយ សំណួរគួរព្រាងទុកជាមុន ។ អ្នកធ្វើសម្ភាសគេ គប្បីជាមនុស្សឆាប់ចាប់យល់សំដីគេ ចេះបត់បែនទាំងកាយវិការ និងគំនិត និងមានសមត្ថភាពឆ្លងឆ្លើយដើម្បីទាញយក ពត៌មានដែលមានប្រយោជន៍ ។

ឃ. វិធីត្រីកោណ (Triangulation)

វិធីត្រីកោណជាផ្នែកមួយនៃការប្រមូលទិន្នន័យ ហើយអាចធ្វើឡើងជា ច្រើនសណ្ឋាន ។ លក្ខណៈសម្គាល់មូលដ្ឋានរបស់វាគឺបន្សំយុទ្ធសាស្ត្រស្រាវជ្រាវ ខុសៗគ្នាពីរ ឬច្រើន នៅក្នុងការសិក្សាស្រាវជ្រាវនៃផ្នែក ផ្នែកលើពិសោធន៍/ សង្កេតដូចគ្នា ។ វិធីត្រីកោណធ្វើឡើងសម្រាប់វាយតម្លៃទៅលើភាពគ្រប់គ្រាន់ របស់ទិន្នន័យ (sufficiency of the data ) ដើម្បីភាពសមស្របឬមិនសមស្របទៅ នឹងការរួមគ្នា (convergence) នៃប្រភពទិន្នន័យជាច្រើន ឬបែបបទប្រមូលទិន្នន័យ ជាច្រើន ហើយនិងដើម្បីបន្ថែមកម្លាំង (corroboration) ឬបដិសេធនូវទិន្នន័យ ដែលមាន/បាន ។

## ឯកសារពិគ្រោះ

Monette, D.R. Sullivan, T.J. and Dejong. C.R. (1998). Applied Social Research. Fort Worth : Harcourt Brace College.

Neuman, W.L (2000). Social Research Methods. Boston: Allyn and Bacon.

Olivier, P. (1997). Research. U.K. : Teach Yourself Books.

Wiersman, W. (2000). Research Methods in Education. Boston : Allyn and Bacon.

# អត្ថបទសិលាចារឹកបាលីចាស់ជាងគេបំផុត នៃអតីតព្រះរាជាណាចក្រកម្ពុជា (Ka11O)

( ភាគ ១)

ដោយ : **មីសែល ត្រាណេ**

## សេចក្តីផ្តើម

នេះជាផ្ទាំងសិលាចារឹកសរសេរជាភាសាខ្មែរ និងភាសាបាលី ដែលជាមូលដ្ឋានដ៏សំខាន់បំផុតនៃប្រវត្តិសាស្ត្រ នៃព្រះរាជាណាចក្រកម្ពុជា ។ ឯកសារនេះ មិនគ្រាន់តែបង្ហាញនូវចំណាស់នៃលិទ្ធិព្រះពុទ្ធសាសនាថេរវាទ ឬហីនយាន ដែលមានប្រភពចេញពីប្រទេសស្រីលង្កាតែប៉ុណ្ណោះទេ ក៏ប៉ុន្តែជាភស្តុតាងនៃវត្តមាន របស់អក្សរសិល្ប៍បាលី នៅក្នុងអតីតព្រះរាជាណាចក្រកម្ពុជាថែមទៀតផង ។ តាមរយៈឯកសារនេះ យើងអាចកែប្រែទស្សនៈរបស់អ្នកស្រាវជ្រាវបារាំងសែសជំនាន់មុន ដូចជាលោក *ហ្សក សេដេស.ប្រ្លាសលីយេ ប្រ្វាង់ស័រ ប៊ីហ្សូ* ជាដើម ដែលបានសន្និដ្ឋានដោយភ័ន្តច្រឡំថា ជនជាតិខ្មែរបានទទួលលទ្ធិព្រះពុទ្ធសាសនាថេរវាទ ពីជនជាតិមន និងជាពិសេសតាមរយៈជនជាតិសៀមនៅសតវត្សទី ១៣ នៃគ.ស ដែលជាមនុស្សចំណូលថ្មី ក្នុងភូមិភាគឥណ្ឌូចិនយើងនេះ។

## ១. ប្រភពនៃសិលាចារឹក

ផ្ទាំងសិលាចារឹកនេះធ្វើអំពីថ្មខ្សាច់ពណ៌ខៀវ កំពស់ ១ម៉ែត្រ ៧៧ ទំហំ ០.ម៉ ៤០ ។ គេបានយកពីទួលស្រះឈូក(នើនស្រះបូ) ក្នុងបុរិវេណព្រះរថ ឃុំគោកពិប ស្រុកដុងស្រីមហាពោធិ៍ នៅខេត្តបច្ចឹមបុរីបច្ចុប្បន្ន នៅប្រទេសថៃ ។

នៅក្នុងខេត្តនេះ គេឃើញនៅមានជនជាតិខ្មែររស់នៅយ៉ាងច្រើនកុះករនៅឡើយ ថ្វីត្បិតតែទឹកដីនេះ បានក្លាយជាកម្មសិទ្ធិរបស់ប្រទេសសៀមក៏ដោយ ។ សព្វថ្ងៃ សិលាចារឹកនេះត្រូវគេតម្កល់ទុកនៅសារមន្ទីរជាតិនៃវត្តទួលស្រះឈូក នៃខេត្តបច្ចិមបុរី (ប្រាជីនបុរី) ខាងលើនេះ ។

## ២ - កាលបរិច្ឆេទ

សិលាចារឹកនេះ មានកាលបរិច្ឆេទច្បាស់លាស់ គឺត្រូវចារឡើងនៅ ឆ្នាំ៦៨៣ នៃមហាសករាជ ដែលត្រូវនឹងឆ្នាំ ៧៦១នៃគ្រឹះសករាជ ។

ផ្ទាំងសិលាចារឹកនេះ និពន្ធជាភាសាបាលី ជាវគ្គស្ទើល្អ ក្នុងចេតនាជាកុសល ដោយមានរូបរាងត្រង់ ដូចអក្សរបល្លវៈនៅប្រទេសស្រីលង្កានាសម័យបូរាណ ហើយមាន ២៧ បន្ទាត់ ។ ពីបន្ទាត់ទី ១ ដល់បន្ទាត់ទី ៣ និងពីបន្ទាត់ទី ១៧ ដល់បន្ទាត់ទី ២៧ អត្ថបទសរសេរជាភាសាខ្មែរ ។ រីឯចំណែកបន្ទាត់ទី ៤ ដល់បន្ទាត់ទី ១៦ ជាភាសាបាលី ។

## ៣ - ខ្លឹមសារនៃសិលាចារឹក

១ - យោ សព្វលោកមោហិតោ ករុណាធិវាសោ
មោក្ខំករោ រវិកុលំបរ បុណ្ណ ចន្ទោ
ញេយ្យោទធិម សុវិបុលំ សកលំ
វិពុទ្ធោលោកុត្តមំ នមថ តំ សិរសា មុនិន្ទំ

២ - សោបនមាលមមលំ វិនសាល យស្ស
សំសារសាគរ សមុត្តរនាយ សេតុម
សព្វាគតី ភយ វិវជ្ជិត ខេម មគ្គម

៣ - ធេយ្យំ តនប្បមបិ យត្ថ បសន្ន ចិត្តា

ទត្វា នរា ផលមុឡារតរំ លភន្តិតំ

សព្វទា ទសពលេនបិ សុប្បសត្ថំ សង្ឃំ

នមស្សថ សទាមិត បុញ្ញ ខេត្តំ ។

## ៤ - សេចក្ដីប្រែ

សិលាចារឹកបាលីខាងលើនេះ ដែលសរសេរជាពាក្យកាព្យស្តុតិ លើកតម្កើងនូវព្រះគុណព្រះរតនៈត្រៃមានទាំងអស់ ២៧ បន្ទាត់ ។ នេះជាសេចក្ដីប្រែនៃអត្ថបទសរសេរជាអក្សរបាលី :

*១ - ចូរមនស្សការ ដោយសិរសាឱនទាប ចំពោះព្រះមុនីនាថខ្ពស់បំផុតក្នុងលោកកា ដែលជាទីគោរពរបស់មនុស្សក្នុងលោក ទ្រង់ប្រោសក្ដីករុណា ព្រះអង្គជាកន្លែងរំដោះក្ដីងងឹត បីដូចជាច័ន្ទពេញបូរមី ជាពន្លឺសែងអាទិត្យ ជាអ្នកដឹងច្បាស់នូវសមុទ្រនៃវិទ្យាទាំងពួង ។*

*២ - ចូរមនស្សការជានិច្ចចំពោះព្រះធមិ ដែលព្រះមុនីទ្រង់បង្រៀនប្រាប់ព្រះធមិគឺជាជណ្ដើរ និមលឆ្ពោះទៅកាន់តាវតឹង្សសួគ៌ ជាស្ពានឆ្លងផុតពីមហាសមុទ្រនៃវដ្ដសង្សារ និងជាផ្លូវដ៏ស្ងប់ដែលកំចាត់បង់អស់ហើយនូវក្ដីមន្ទិលអាស្រូវ ។*

*៣ - ចូរមនស្សការជានិច្ច ចំពោះព្រះសង្ឃ ដែលជាមហាបុញ្ញាខេត្តទោះបីជាអ្នកណាបានថ្វាយនូវទេយទាន ដោយតិចតួចក្ដី ដោយសេចក្ដីបីតិ ក៏នឹងបានទទួលផលដ៏ច្រើនសន្ធឹក ដោយសារតែព្រះធមិនេះ ព្រះទសពលទ្រង់បានសម្ដែងហើយដោយប្រពៃ ។*

## ៥ - ប្រភពគាថានៃសិលាចារឹក

តាមលោកបណ្ឌិតសាស្ត្រាចារ្យ ស្រីលង្កាម្នាក់ឈ្មោះរោហណៈ ព្រះគាថាបាលីនេះជា "គាថាខ្ទះប្រេង " ឬ "តេលកហគាថា" ពុំ មាននៅក្នុងព្រះគម្ពីរ

ព្រះត្រៃបិតក និងគម្ពីរព្រះអដ្ឋកថាទេ ។ម្យ៉ាងទៀត ព្រះគាថាបាលី "ខ្ចះប្រេង"នេះត្រូវបានតែងឡើងបានប្រសូត្រនៅកោះស្រីលង្កា ហើយបានផ្សព្វផ្សាយមកកាន់តំបន់ខ្មែរបុរាណខាងលើនេះ ។ លោករោហណៈ ក៏បានផ្តល់នូវប្រវត្តិនៃព្រះគាថា ដូចតទៅនេះ :

តាមតំណាលមហាវង្សនិងទសវាហិណី សម័យដែលព្រះបាទកាកវណ្ណតិសៈគ្រងរាជ្យនៅរោហណៈជនបទ ក្នុងអម្លុងពុទ្ធសតវត្សទី ៣ - ៤ មានស្តេចមួយព្រះអង្គទង់ព្រះនាមថា *កល្យាណតិសៈ* សោយរាជ្យនៅនគរកល្យាណី ដែលសព្វថ្ងៃនេះមានឈ្មោះថា ទីក្រុងគូឡូមបូ ។

ព្រះអគ្គមហេសីរបស់ព្រះអង្គមានសាហាយជាមួយព្រះអនុជទើបត្រូវ និរទេស ចេញពីព្រះរាជនគរទៅ ។ ព្រះអនុជក៏បបួលយកព្រះសាហាយបន្លំខ្លួនជាព្រះភិក្ខុ ហើយចូលទៅក្នុងវាំង ដើម្បីយកសារស្នេហាផ្ញើរទៅឱ្យព្រះមហេសី ។ ជានិច្ចកាលព្រះសាហាយបន្លំខ្លួនចូលវាំង តាមព្រះអរហន្ត ហើយធ្វើឱ្យសារស្នេហាធ្លាក់ទៅលើដី ។ ព្រះមហាក្សត្រឃើញ និងយល់ច្រឡំស្មានតែព្រះអរហន្ត ។

## ៦ . សារៈសំខាន់ របស់សិលាចារឹក

ការវិភាគនៃសិលាចារឹកបាលី ដែលផ្ដើមឡើងដោយភាសាខ្មែរបូរាណនេះបានឱ្យដឹងថា អ្នកប្រតិស្ឋានគឺជាជនជាតិខ្មែរមួយរូបឈ្មោះថាពុទ្ធសិរី ។ តាមពិតឈ្មោះពុទ្ធសិរីនេះ គឺជាព្រះនាមរបស់ព្រះមហាថេរៈមួយព្រះអង្គដែរដែលប្រកបដោយបញ្ញាញាណ ខាងវិន័យព្រះពុទ្ធសាសនា លទ្ធិថេរវាទ ប្រមាណជា ១៣សតវត្សមកហើយ ។

ពាក្យសំដីក្នុងសិលាចារឹក ដែលព្រះអង្គបានចារឡើងជាអត្ថបទធម្មនមស្សការដល់ព្រះរតនៈត្រៃទាំងបីប្រការ បានបង្ហាញឱ្យយើងឃើញនូវអត្ថរសដ៏ជ្រាល-

ជ្រៅ ភ្លឺថ្លា ព្រមទាំងចំណេះដឹង និងសមត្ថភាពដ៏ខ្ពង់ខ្ពស់របស់ពុទ្ធសាសនិកខ្មែរនាសម័យបុរេអង្គរក្នុងភូមិភាគនេះ ដែលជាភាគមួយនៃអតីតព្រះរាជាណាចក្រ ចេនឡា ។

ម្យ៉ាងទៀត អត្ថបទខាងលើនេះ ក៏ឆ្លុះបញ្ចាំងឱ្យឃើញដែរថា មនុស្សខ្មែរបុរាណបានមានទំនាក់ទំនងផ្នែកវប្បធម៌សាសនា និងប្រទេសស្រីលង្កា ដែលជាអ្នកប្រតិបត្តិធម៌បដិមោក្ខ បានយ៉ាងធ្លុះធ្លាយ មាំមុតសព្វបែបយ៉ាងទៅហើយ ។ កុំភ្លេចថាវត្ថុបំណងនៃសិលាចារឹក គឺការអូសទាញបុគ្គលគ្រប់រូប ឱ្យមានទឹកចិត្តសទ្ធា ឱ្យកាន់តែជ្រះថ្លាថែមទៀតផង ជាពិសេសក្នុងការបដិបត្តិធម៌ ។

មួយវិញទៀត ការវិភាគអត្ថបទនិពន្ធ បានឱ្យដឹងទៀតថា លក្ខណៈទ្រង់ទ្រាយនៃអត្ថបទមាន ១៤ ឆន្ទ ដែលមានឈ្មោះថា វសន្តតិលកៈ ។ រីឯពាក្យពេចន៍ដែលបានប្រើសម្រាប់ចងក្រងព្រះគាថានេះ ក៏ត្រូវបានជ្រើសរើស ដោយប្រើពាក្យសំដីល្អប្រណិតបរិសុទ្ធ ជ្រះថ្លាក្រៃលែង ហើយបង្កប់នូវអត្ថន័យ អត្ថរស ដ៏ពិរោះពិដោរ ក្បោះក្បាយថែមទៀតផង ។

ដូចសេចក្ដីខាងលើ គេអាចបញ្ជាក់ថា ជនជាតិខ្មែរនៅភូមិភាគឦសាននៃប្រទេសថៃបច្ចុប្បន្ននេះ មានគម្ពីរក្បួនខ្នាតច្បាស់លាស់ សម្រាប់ជំរុញដល់ការរៀនសូត្រព្រះបរិយត្តិធម៌ ដូចជាស័ន្ទសាស្ត្រ និយ័ណ្ឌសាស្ត្រ ឆ័ន្ទសាស្ត្រ អលង្ការសាស្ត្រ ប្រកបដោយលក្ខណៈត្រឹមត្រូវពេញលេញជាទីបំផុត ។

រួមសេចក្ដីមក យើងអាចចាត់ទុកថា សិលាចារឹកសរសេរជាពាក្យកាព្យនេះជាមូលដ្ឋាននៃអក្សរសិល្ប៍ខ្មែរ ដែលពុំធ្លាប់ប្រទេះឃើញមានពីមុនមក ហើយតម្លៃវិសេសវិសាលរបស់សិលាចារឹក គឺស្ថិតនៅលើមូលដ្ឋានសីលធម៌ ដ៏ធំធេង មហិមាឥតគុណនា ឬត្រៃយត្រាន្ត ។

## ៧ - អន្តរស

លទ្ធផល នៃការវិភាគអត្ថបទបាលី ក៏បញ្ជាក់ឱ្យដឹងដែរ នូវវិធីសាស្ត្រដ៏ល្អប្រសើរឥតខ្ចោះ ក្នុងការតែងព្រះគាថានេះ ដោយជនជាតិខ្មែរនាសម័យនោះ ។

ជាបឋមយើងអាចប្រៀបធៀប ឬចាត់ទុកព្រះគាថាបាលីនេះ ទៅនឹងមណីកាដ៏ឆ្លាតវៃមួយ ដែលបាននាំមកនូវរត្នរតន៍ ទំហំតូចធំមាន ១៦៨ គ្រាប់ ។ ទេពកោសល្យស្ថិតនៅលើ ការជ្រើសរើសសម្រាំងយកតែគ្រាប់ណា ដែលមានលក្ខណៈល្អបរិសុទ្ធភ្លឺថ្លាជាងគេបំផុត ដើម្បីយកមករចនា ចរណៃ ដោយក្តីប្រយ័ត្នជាទីបំផុត ។ បន្ទាប់មកគេក៏បានយកមកចងក្រងជាមាល័យរតន៍ ១២ ខ្សែ ដោយនៅខ្សែនីមួយៗត្រូវក្រងភ្ជាប់នឹងរតនៈទាំង ១៤ គ្រាប់ ( ធំ ៧ និងតូច ៧ ) ឱ្យក្លាយទៅជាភួងៗ ដោយភួងនីមួយៗ មាន ៤ ខ្សែ និង ៣ ភួង ។ ជាហេតុដែលធ្វើឱ្យខ្សែនិមួយៗប្រកបដោយសោភ័ណភាពភ្លឺផ្លេក ទៅតាមចង្វាក់នៃដួងរតនៈ ហើយរឹងរស្មីដែលជះចេញពីគ្រាប់រតនៈនីមួយៗនោះ បានរួមផ្តុំគ្នាបញ្ចេញនូវពន្លឺ គួរជាទីសែនមនោរម្យអស្ចារ្យ ។

តាមការប្រៀបផ្ទឹមខាងលើនេះ យើងឃើញព្រះគាថាបាលីនេះ តាមរយៈអក្ខរៈ ១៦៨ តួ បានបញ្ចុះនូវនិមិត្តរូបដ៏ស៊ីជម្រៅ ដោយលើកតម្កើងព្រះគុណនៃព្រះរតនត្រៃ ។ តួអក្ខរៈដែលព្រានប្រដៅយើងឱ្យចេះឱនលំទោន ចំពោះព្រះរតនៈត្រៃ មានតួជាកុសលចេតនា ១៦៨ អក្ខរៈ ជាគរុ ៨៤ អក្ខរៈ ជាលហុ ៨៤ អក្ខរៈ ដោយផ្សំផ្គុំជាកាព្យ កើតជាឆន្ទវសន្តតិលកៈ ១២ បាទ ។ នៅបាទទី ១ មាន ១៤ អក្ខរៈ ជាគរុ ៧ អក្ខរៈ ជាលហុ ៧ អក្ខរៈ រួមមួយបាទ ១៤ អក្ខរៈ ។ ហើយនៅមានការបែងចែកចេញជា ៣ គាថា ថែមទៀតផង : ថ្វាយស្តុតីព្រះពុទ្ធជាអម្ចាស់មួយគាថា ព្រះធម៌មួយគាថា និងព្រះសង្ឃមួយគាថា ។

គម្បីរំលឹកផងដែរថា ការពិពណ៌នាអំពីព្រះគុណមានលក្ខណៈពិរោះរណ្តំ ក្រៃលែង ហើយការតែងប្រកបដោយភាពទេពកោសល្យខ្ពង់ខ្ពស់អស្ចារ្យ បែបនេះ គឺធ្វើឡើងដើម្បីអូសទាញ ពុទ្ធសាសនានិកជន ឱ្យគោរពបដិបត្តិព្រះរតនៈត្រៃ ឱ្យយ៉ាងជាប់លាប់ ប្រយោជន៍ នឹងដល់ត្រើយ នៃព្រះនិព្វាន ពោលគឺសេចក្តីសុខ សេចក្តីចម្រើនអស់ក្តីសៅហ្មងទាំងឡាយ ។

## ៨ ‿ សេចក្តីសន្និដ្ឋាន

ការរកឃើញនូវផ្ទាំងសិលាចារឹកខាងលើនេះ ជាភស្តុតាងថ្មីមួយបង្ហាញឱ្យ យើងឃើញនូវភាពរុងរឿង ថ្កុំថ្កើង នៃលទ្ធិព្រះពុទ្ធសាសនាថេរវាទ ដែល ប្រើភាសាបាលី ជាយាន នៅលើទឹកដីខ្មែរនាសម័យបុរាណ ។ ម្យ៉ាងទៀត តាមរយៈការវិភាគ យើងក៏អាចដឹងទៀតថា ផ្ទាំងសិលាចារឹកបាលីខាងលើនេះ គឺជាមូលដ្ឋាននៃអក្សរសិល្ប៍បាលី យ៉ាងពិតប្រាកដ ដែលគេពុំអាចប្រកែក ឬបដិសេធបាន ។ ដូច្នេះការដែលថាជនជាតិខ្មែរពុំបានស្គាល់ ឬនិយមភាសាបាលី មុនសម័យអង្គរ ជាការខុសឆ្គងមួយ ដែលគេត្រូវតែកែតម្រូវ ។ កុំភ្លេចថា សិលាចារឹកថៃ សរសេរជាបាសាបាលីមុនដំបូងបង្អស់ គឺត្រូវបានចារឡើងនៅ ឆ្នាំ ១៣៦១ នៃ គ.ស ដោយព្រះបាទឮថៃ ។

## ឯកសារយោង

1- ប្រជុំសិលាចារឹក នៃប្រទេសថៃច្បាប់ទី ៣ .ទំព័រទី ១៨០.
ក្រុមសិល្បករ បាងកក

2- **Telakatāhagāthā ratanattayam,Journal of the Pali Text Society,London , 1884 .**



*រូបភាព :*

*សិលាចារឹកទូលស្រះឈូក ឯកសាររបស់ក្រុមសិល្បករថៃ( បណ្ណាល័យជាតិបាងកក)*

# អំពីការបេះឃ្មុំ[១]

ដោយ : **មៀច ប៊ុណ្ណ**

ព្រៃព្រឹក្សាជាច្រើនប្រភេទនៅប្រទេសយើង បានផ្តល់ជម្រកយ៉ាងកក់ក្តៅសម្រាប់ឃ្មុំ ដែលជាភមរជាតិមួយប្រភេទ ក្រេបយកលំអងផ្កាមកច្នៃធ្វើជាទឹកមានរសជាតិផ្អែមឈ្ងុយហើយក្រអូប ។ ជាទូទៅឃ្មុំយកមែកឈើធ្វើជាទីតាំងបង្កងសម្រាប់ភ្ជាប់សំបុក ដើម្បីពង និងបន្តពូជពង្ស ។ ក្រៅពីនេះ ឃ្មុំអាចតាំងទីនៅតាមផ្ទះសម្បែងរបស់មនុស្ស ភ្ជាប់សំបុកវា នៅពីក្រោមផ្ទាំងថ្មធំៗនៅក្នុងព្រៃភ្នំ ។ គេសង្កេតឃើញមានឃ្មុំច្រើនប្រភេទ គឺឃ្មុំព្រៃភ្នំ និងឃ្មុំបឹងតំបន់លិចទឹកព្រមទាំងឃ្មុំនៅទីវាល ។ គេសន្មតឱ្យឈ្មោះឃ្មុំទៅតាមទំហំរបស់សំបុកវាគឺ ឃ្មុំធំ ឃ្មុំចង្អេរ ឃ្មុំត្រចៀកដំរី ឃ្មុំផ្លិត ឃ្មុំបូកគោ ... ។ នៅប្រទេសកម្ពុជាយើង ប្រជាកសិករ ច្រើនស្វែងរកបេះឃ្មុំនៅរដូវប្រាំង[២] នៅពេលដែលបានទំនេរពីការងារ ច្រូតកាត់ប្រមូលផល ទុកដាក់ចប់សព្វគ្រប់ហើយ ។ នៅតំបន់ព្រៃភ្នំ ឃ្មុំច្រើនតែតាំងសំបុកនៅតាមមែកឈើ ដែលមានដើមធំៗ និងខ្ពស់ៗក្នុងគោលបំណងគេចឱ្យផុតពីភ័យន្តរាយផ្សេងៗ ។ ប្រជាកសិករខ្មែរត្រាច់ចរក្នុងព្រៃ ភ្នែករំពៃមើលឃ្មុំនៅតាមចុងឈើ ដែលវាចូលចិត្ត មានជាអាទិ៍ទ្រាង ឆ្លង់ ចំបក់ ផ្ចៀក ឈើទាល ។

---

១- សត្វល្អិត ឋិតក្នុងពូកភមរជាតិ មានទឹកផ្អែម សំណុសសម្រាប់ធ្វើក្រមួន ( វ.ច សម្តេច ជួន ណាត )

២- ខ្មែរមានជំនឿថា ទឹកឃ្មុំខែចេត្រមានគុណភាពពិសេស សម្រាប់យកមកផ្សំធ្វើជាឱសថកែរោគផ្សេងៗ ។ លោកតា គិម ផង់ កាលនៅពីក្មេងគាត់ជាអ្នកបេះឃ្មុំយ៉ាងចំណានម្នាក់នៅក្នុងភូមិ គាត់បាន ឱ្យសម្ភាសន៍ដល់យើងខ្ញុំអំពីរបៀបបេះឃ្មុំនេះ ។

ការបេះឃ្មុំជាជំនាញមួយ មិនមែនថា មនុស្សណាក៏អាចបេះឃ្មុំបានទាំងអស់នោះឡើយ .... ពិសេសឃ្មុំធំ ។ អ្នកបេះឃ្មុំត្រូវមានលក្ខណៈពិសេសខ្លះៗ ដូចជា : ប៉ិនប្រសប់ខាងឡើងដើមឈើ មានចិត្តក្លាហាន មិនរួញរាចំពោះគ្រោះថ្នាក់ ចេះមន្តអាគមផ្សេងៗសម្រាប់ផ្ចាញ់អារក្ស អ្នកតា បង់បត់ ព្រាយ និងបង្ក្រាបឃ្មុំ ចេះប្រើឧបករណ៍បេះឃ្មុំយ៉ាងស្ទាត់ជំនាញ ។

## I - ឧបករណ៍សម្រាប់បេះឃ្មុំ




មនុស្សភាគច្រើន ចូលចិត្តទៅរកឃ្មុំតែម្នាក់ឯង ជាជាងបបួលគ្នាទៅទាំងហ្វូង ដែលអាចនឹងមានផលវិបាកខ្លះៗដូចខាងក្រោមនេះ :

- បានទទួលចំណែកតិច ពីផលដែលទទួលបាន
- បាត់បង់ភាពស្ងប់ស្ងាត់ ជាទំនាស់ដល់ការពិនិត្យ សង្កេតមើលឃ្មុំ និងនាំឱ្យផ្អើលសត្វផ្សេងៗទៀតក្រៅពីឃ្មុំ
- ប៉ះពាល់ដល់គ្រលោមផ្សេៗ ដែលត្រូវកាន់ ក្នុងពេលចូលព្រៃធំៗ ។ អ្នក

បេះឃ្មុំម្នាក់ ត្រូវនាំយកទៅជាមួយខ្លួននូវឧបករណ៍មួយចំនួន ៖

*ក/ គប់ ៖* ផ្សំឡើងដោយមែកឈើស្ងួត តូចៗល្មមប្រវែងប្រមាណមួយព្យាម ចងផ្តុំគ្នាជាបាច់ និងរុំព័ទ្ធពីក្រៅ ដោយស្លឹកឈើស្រស់មួយជាន់ទៀតដើម្បីបង្កលក្ខណៈឱ្យមានផ្សែងច្រើន នៅពេលគេដុតគប់បង្ហើលឃ្មុំ ។ ផ្សែងភ្លើងមានឥទ្ធិពលទៅលើឃ្មុំខ្លាំងណាស់ ។ កាលណាធុំក្លិនផ្សែងគប់ ទ្រនិចវារួញ ហើយពុំអាចទិច[១] មនុស្សបានឡើយ ។

*ខ/ កន្តាងរ៉ាំង ៖* មានរាងជាថ្នក់ដូចកញ្ជើធំមួយ មានទំហំមាត់កាត់ពី ៤៥-ទៅ ៥០ សង្ទីម៉ែត្រ ធ្វើអំពីវល្លិ៍ ឬចម្រៀកផ្តៅ វែងប្រទាក់គ្នាជាក្រឡា ហើយត្រូវបានចងភ្ជាប់នឹងចុងដងឫស្សីមួយកំណាត់ ។ នៅត្រង់ចុងដងឫស្សីនេះដែរ គេបានចងភ្ជាប់ផ្លែកណ្តៀវ ឬត្វាងសម្រាប់កៀវផ្តាច់ក្បាលទឹក ឬផ្លឹតឃ្មុំទម្លាក់បញ្ចូលមកក្នុងកន្តារ៉ាំង ។

*គ/ ពួយ ៖* ជាកំណាត់ឈើរឹងប្រវែង ១២ ទៅ ១៥ សង្ទីម៉ែត្រ ។ អ្នកបេះឃ្មុំចូលចិត្តយកមែកមៀនព្រៃមកធ្វើពួយ ។ ដើម្បីងាយស្រួលបោះបញ្ចូលឱ្យជាប់ទៅក្នុងសាច់ឈើ គេត្រូវសម្រួចចុងម្ខាងនៃពួយ ។

*ឃ/ ខ្សែមួយចង្វាយ ៖* ត្រូវមានខ្សែប្រវែងតិចបំផុត ១៥ ម៉ែត្រ សម្រាប់ចងយោងគប់ ទៅលើដើមឈើផង និងចងកន្តារ៉ាំងសម្រូតដាក់ផ្លិត និងក្បាលទឹកឃ្មុំមកលើដីផង ។

*ង/ ពូថៅ ៖* សម្រាប់បោះពួយឱ្យមុតចូលទៅក្នុងសាច់ឈើ ប្រយោជន៍ នឹង

---

១ - ទ្រនិចឃ្មុំមានលាយទៅដោយពិស ធ្វើឱ្យឈឺចាប់ពើតក្តៅក្រហាយ អស់ពេលជាច្រើនម៉ោងព្រមទាំងធ្វើឱ្យហើមនៅត្រង់ស្នាមទិចទៀតផង ។

ជាន់ឡើងទៅឱ្យដល់ជិតសំបុកឃ្មុំ

*ច/ ទន្ទឹង :* ធ្វើពីវល្លិស្វិតជាប់ល្អ វេញបញ្ចូលគ្នាជាពីរ ឬបីផ្លុង សម្រាប់ចង ព័ទ្ធខ្លួនអ្នកបេះឃ្មុំ ទៅនឹងដើមឈើដែលត្រូវឡើង ដើម្បីធាក់ជ្រែង ចំកោងខ្លួនកុំឱ្យរបូតធ្លាក់ចុះក្រោម នៅពេលគេត្រូវដកដៃទាំងពីរ ពីដើមឈើ មកកាន់ និង វាយពួយ ។

*ឆ/ ចេះបាលីមន្តអាគម :* ដូនតាខ្មែរយើងជឿថា នៅក្នុងព្រៃ មានព្រាយ បង់បត់ អារក្ស អ្នកតា កាន់កាប់និងថែរក្សាការពារឃ្មុំធំៗ ។ ប្រសិនបើយើងមិន ចេះមន្តអាគម សម្រាប់ផ្ចាញ់ កម្ចាត់ពពួកអមនុស្សទាំងនោះទេ អ្នកយកឃ្មុំអាច នឹងរងគ្រោះថ្នាក់ជាច្រើនប្រការ ដូចយ៉ាង :

- ត្រូវឃ្មុំចោមរោមទិច ទាល់តែស្លាប់

- ត្រូវភ្លាត់ជើង របូតដៃធ្លាក់ពីលើចុងឈើស្លាប់

- ត្រូវពពួកអធិភូត ធ្វើកលបញ្ឆោត បណ្ដាលឱ្យឃើញដូចជាប្រពន្ធ កូន ឪពុក ម្ដាយ មកហៅឱ្យចុះពីចុងឈើ ។ ទើបតែចុះមកដល់ពាក់កណ្ដាលដើម ក៏មាន អារម្មណ៍យល់ថាដល់ដីហើយ លុះខ្លួនលែងដៃពីដើមឈើ ក៏របូតដៃធ្លាក់ចុះ ឬមួយ គ្រាន់តែចុះមកដល់ដីភ្លាម សាច់ញាតិ ដែលខ្លួនបានឃើញពីមុន នេះបន្តិច ស្រាប់តែក្លាយទៅជាខ្លា ឬខ្ទិងប្រហារ ស្លាប់តែម្ដងទៅ ... ។

## II. វិធីបេះឃ្មុំ :



អ្នករកឃ្មុំ ត្រាច់ចរកាត់ព្រៃយ៉ាងស្ទៀមស្ងាត់ ភ្នែករំពៃមើលសព្វចុងឈើ ។ កាលណាគេប្រទះឃើញឃ្មុំហើយ គេប្រុងប្រៀប ត្រៀមលក្ខណៈឱ្យបានល្អ ដើម្បីឡើងទៅបេះឃ្មុំ ។ ដំបូង អ្នកបេះឃ្មុំត្រូវពិនិត្យមើលជុំវិញគល់ឈើ ដែលឃ្មុំតាំងលំនៅ ដើម្បីរកព្រីងអណ្តែត[១] ។ ឃើញហើយ គេយកដែកគោល ឬពួយ[២] ទៅបោះត្រីង នៅលើឫសព្រីងអណ្តែតនោះ ប្រយោជន៍បណ្តេញ កម្មាត់ បន្សាប ពួកព្រាយបិសាច ដោយសូត្របាលីយ៉ាងនេះថា :" ឧមៈ លើឡ្វេ លីលៀ "ចំនួន ៣ ចប់ហើយផ្លុំភីតទៅលើស្នាមត្រីងនោះទៅ ។ ធ្វើកិច្ចនេះហើយ[៣] អ្នកបេះឃ្មុំ ស្តាយគប់

---

១ - ឫសឈើដែលលេចធ្លោខ្ពស់ចេញពីដី ជាងឫសឯទៀត ។

២ - ឈើរឹង ១ កំណាត់ប្រវែង ១២ ទៅ ១៣ សង់ទីម៉ែត្រ ដែលគេសម្រួចចុងម្ខាងសម្រាប់បោះបញ្ចូលទៅក្នុងសាច់ឈើ ធ្វើជាកាំ ដើម្បីជាន់ឡើង ឬត្រីងផ្ទាញ់ពពួកអមនុស្ស ។

៣ -មុនប្រវាឡើងដើមឈើ គេត្រូវទះគល់វា ៣ប៉ុងខ្លាំងៗក្នុងន័យសន្ទាប់ បង្ក្រាបព្រាយបិសាច

ដែលដុតឱ្យឆេះជាស្រេច ស្ពាយកន្ទាងវ៉ាង សៀតពូថៅនៅចង្កេះ ច្រកពួយក្នុងថង់មួយស្ពាយនៅលើស្មា ព្រមទាំងស៊កខ្លួនទៅក្នុងទន្លីង រួចពឹងប្រវាំរឡើងដើមឈើបណ្តើរ ភាវនាបាលីយ៉ាងនេះផងថា : "ចតត្តេ កោកា អៈ" ។ បាលីនេះ សម្រាប់បណ្តេញ បង្ក្រាបអស់ព្រាយបិសាច ដែលរក្សាការពារឃ្មុំ ។ ដោយដើមឈើធំ ដែលគេពុំអាចឱបជុំនោះម្យ៉ាង ហើយម្យ៉ាងទៀត ដោយពុំមានមែកសម្រាប់ប្រតោងឡើងនោះ ជាចាំបាច់អ្នកបេះឃ្មុំត្រូវយកពួយពីថង់ យកពូថៅពីចង្កេះ វាយបោះបញ្ចូលទៅក្នុងសាច់ឈើឱ្យជាប់រឹង ល្មមជាន់ឡើងបានមិនរបេះ ។ គេអាចលែងដៃទាំងពីរបានដោយយកខ្នងពឹងនឹងទន្លីងឱ្យតឹង ធាក់ជ្រែងទៅក្រោយ មិនឱ្យរអិលខ្លួនធ្លាក់ចុះក្រោម ។ គេបោះពួយក្នុងចន្លោះល្មម ឈានជាន់ឡើងបានស្រួល ។ ការវាយពួយនេះ ត្រូវបញ្ចប់ នៅពេលដែលគេបានឡើងទៅដល់មែកឈើ ល្មមឈោងដៃ តោងយោងខ្លួនឡើងទៅលើបាន ។ គេឡើងរំកិលតិចៗ ឆ្ពោះទៅកាន់មែកណាដែលនៅជិតឃ្មុំជាងគេ ។ ប៉ុន្តែជួនកាល នៅលើដើមឈើតែមួយនេះ មានសំបុកឃ្មុំរហូតដល់បួន ឬប្រាំ ។ ក្នុងករណីនេះ គេត្រូវបេះឃ្មុំណាដែលនៅដើមផ្លូវមុនគេដោយកត់សម្គាល់ថា ឃ្មុំប្រភេទនេះ ជាអ្នកយាមផ្លូវ ។ តាមទម្លាប់ពីបុរាណ គេត្រូវតែបេះឃ្មុំយាមនេះមុនគេជាចាំបាច់បំផុត ។ ប្រសិនបើគេបែរជាលួករំលងទៅបេះឃ្មុំចុងមែកជាមុននោះ គេពិតជាត្រូវឃ្មុំយាមផ្លូវនេះចោមរោមទិច ស្រោចពេញខ្លួនហើយអាចបណ្តាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរផងក៏សឹងមាន ។ រីឯការបេះឃ្មុំតូចៗដូចជាឃ្មុំត្រចៀកដំរី ឃ្មុំផ្លិត ឃ្មុំបូកគោ ..... គេមិនចាំបាច់ប្រើមធ្យោបាយធំដុំឡើយព្រោះឃ្មុំប្រភេទនេះ ពុំមានខ្មោចព្រាយបិសាចបង់បត់ កាន់ការពារឡើយ ។ ការប្រើគប់ភ្លើងតែមួយមុខប៉ុណ្ណោះ ល្មមគ្រប់គ្រាន់អាចនឹងបណ្តេញមេឃ្មុំឱ្យរត់ចេញអស់ពីសំបុកបាន ។ ហើយបន្ទាប់ពីនេះ គេអាចកាប់បង្គងឃ្មុំ យកទាំងផ្លិត

ទាំងក្បាលទឹកបានយ៉ាងងាយ ។ ចំពោះឃ្មុំផ្លិត បើគេមិនអាចរកគប់បានទេនោះ គេគ្រាន់តែជក់បារី បង្ហុយផ្សែងទៅលើសំបុកនោះ មេឃ្មុំវានិងផ្អើលរួញទ្រនិច ហើរគេចចេញភ្លាមមួយរំពេច ។ បើបេះឃ្មុំបូកគោវិញនោះ ដែលតាំងបង្គងនៅតាមគុម្ពោតព្រៃទាបៗឬនៅតាមដើមស្រូវទុំ នោះគេគ្រាន់តែកាច់សំបុកអង្រួងទៅដាក់ក្បែរបង្គងវា នោះវានឹងស្ទុះហើរព្រោងព្រាត ព្រោះខ្លាចអង្រួងខាំ ។ ក្មេងៗឃ្វាលគោជាពិសេស ហាត់រៀនដកបទពិសោធន៍តាំងពីបេះឃ្មុំតូចតាច បែបនេះ ជាបណ្ដើរៗរៀងទៅ ទម្រាំដល់ធំពេញវ័យ វានឹងមានការស្ទាត់ជំនាញដូចចាស់ជាន់មុនដែរ ។

សូមអនុញ្ញាតបន្ត វិធីបេះឃ្មុំធំវិញ ។ មុនដំបូងគេរុញគប់ ដែលឆេះបញ្ចេញផ្សែងហុយទ្រលោម ឆ្ពោះទៅរកសំបុកឃ្មុំធ្វើឱ្យវាសម្ដែងឫទ្ធិ ដោយធ្វើចលនាកម្រើកស្លាបរីកខ្វាកៗ ហាក់ចង់តប-ត មករកគប់ភ្លើង ឬប្រុងវាយប្រហារមកលើអ្នកឈ្លានពានវាវិញ ។ ប៉ុន្តែដោយពុំអាចធន់ទ្រាំបាន និងផ្សែងខ្ទួលខ្ទាញ់ ហុយកកខាប់ទៅលើពួកវា ឃ្មុំក៏នាំគ្នាហើរចេញពីសំបុក ដោយស្ដាយស្រណោះ អ្វីៗដែលជាទីស្រឡាញ់ស្មើជីវិតរបស់ពួកវាដូចជា ទឹកឃ្មុំ ឃ្លាំងអាហារប្រចាំសំបុក ពង និង កូននៅក្នុងផ្លិត ។ អ្នកបេះឃ្មុំ ឆ្លៀតឱកាសនោះ ក៏យកផ្លែកណ្ដៀវ ឬកាំបិតព្រៃ[១] ទៅកៀរផ្លិតឃ្មុំ បញ្ច្រកមកក្នុងកន្ត្រងរ៉ាង រួចទើបកៀរក្បាលទឹក ដាក់ពីលើផ្លិតទៀត ។ ប្រសិនបើគេត្រូវបេះឃ្មុំច្រើនទៀត គេត្រូវយោងទម្លាក់ផ្លិតនិងក្បាលទឹក ដែលដាក់ពេញ ក្នុងកន្ត្រងរ៉ាងនោះ មកដាក់ឯដី រួចទាញយោងកន្ត្រងរ៉ាងទទេ យកទៅលើដើម្បីទុកដាក់ផ្លិតឃ្មុំ ក្បាលទឹកដែលគេបេះ ជាបន្តបន្ទាប់ ដរាបទាល់តែអស់ឃ្មុំ ។

១ - ឈើ ឬ ឫស្សី ១បន្ទះ បិតឱ្យស្ដើងដូចមុខកាំបិត ទុកសម្រាប់កៀរក្បាលទឹកឃ្មុំ ។

ក្នុងករណីដែលឃ្មុំកាច[១] ខ្លាំងរឹងត្អឹង មិនព្រមហើរឃ្លាតឆ្ងាយពីសំបុក ហើយចេះតែហើរមកចោមរោមអ្នកបេះនោះ គេត្រូវឆ្វាតវាងវៃ យកកាំបិតព្រៃចាក់ទម្លាយក្បាលទឹកបន្តិច ឱ្យទឹកឃ្មុំហៀរខ្លះ១ធ្លាក់មកដី ។ ពេលនោះ ឃ្មុំស្ទុះហើរចុះមកតាមទឹក ជាប្រភពជីវិតរបស់ខ្លួន នៅឯដី ធ្វើឱ្យអ្នកបេះបានរួចផុតពីគ្រោះភ័យ ។ នេះជាល្បិច ជាទេពកោសល្យរបស់អ្នកបេះឃ្មុំ ដែលត្រូវតែមានស្មារតីរឹងមាំ ដើម្បីដោះខ្លួនឱ្យរួចផុតពីគ្រោះថ្នាក់ជាយថាហេតុ គ្រប់ពេលវេលា ។ កាលណាបេះឃ្មុំអស់ហើយ អ្នកយកឃ្មុំ ក៏ចុះពីលើដើមឈើធំនោះ ដោយជាន់លើពួយ ដែលបានបោះនៅពេលឡើង ។ ពេលចុះ គេមិនសូវប្រើទន្លីងទេ ។ ពួយទាំងអស់ត្រូវបានទុកចោលនៅលើដើមឈើ ព្រោះគេប្រើវា តែម្តងប៉ុណ្ណោះ ។ កាលណាត្រូវឡើងបេះឃ្មុំនៅលើដើមឈើណាមួយផ្សេងទៀត គេនឹងធ្វើពួយសារជាថ្មី ។

## III. អំពីប្រយោជន៍នៃឃ្មុំ

*១. លើកសម្រស់បរិដ្ឋាន :* ដំបូងបង្អស់ ឃ្មុំជាធនធានធម្មជាតិមួយប្រភេទរួមចំណែក លើកស្ទួយសម្រស់លម្អដល់បរិដ្ឋាន ព្រៃព្រឹក្សាខ្មែរផងដែរ ។ តើយើងមានអារម្មណ៍រំភើបរីករាយយ៉ាងណាទៅ ប្រសិនបើព្រៃព្រឹក្សារបស់យើង លាន់ឮរងំដោយសូរស័ព្ទឃ្មុំក្រេបលំអងផ្កា តិម្ពន្ធរដូវ ដែលរុក្ខជាតិនានា ចេញផ្កាល្អស្រស់បំព្រង ធ្វើបដិសណ្ឋារកិច្ចដ៏ស្មោះស្ម័គ្រចំពោះភមរី ដែលហើរមកក្រេបទឹកដមរបស់ខ្លួន យកទៅចំរាញ់ធ្វើទឹក ដ៏មានរសជាតិផ្អែម[២] ក្រអែបក្រអូបឈ្ងុយឆ្ងាញ់ឥតឧបមា

---

១ - ប្រភេទឃ្មុំកាច ច្រើនតែធ្វើបង្កងទទឹងថ្ងៃ អ្នកបេះឃ្មុំត្រូវប្រយ័ត្ន និងវាងវៃ ដើម្បីទប់ទល់ជាមុន

២ - នៅក្នុងសំនួនវោហាសព្ទខ្មែរ គេតែងពោលថា : សម្តីផ្អែមដូចទឹកឃ្មុំ ឬ មធុរៈវាចា - អ្នករៀបការថ្មីភ្លក្សរសជាតិ " ច័ន្ទទឹកឃ្មុំ " ។ល។

នោះ ? ពេលត្រឹបផ្កា ឃ្មុំជួយចម្លងគ្រាប់កេសរផ្កាឈ្មោល យកទៅទម្លាក់លើលំអងកេសរផ្កាញី ធ្វើឱ្យផ្កា បង្កបង្កើតទៅជាផ្លែ ។ នេះគឺជាការបន្តពូជមួយបែបដែលមានភមរីជាភ្នាក់ងារ ។

*២. ប្រយោជន៍នៃក្រមួនឃ្មុំ :* ឃ្មុំមានចំណែកផ្សារភ្ជាប់ជាមួយជីវភាពប្រជាជនខ្មែរ អស់ពេលយូរលង់ណាស់មកហើយ ។ មានរឿងព្រេងជាច្រើនបញ្ជាក់អំពីការស្វែងរកក្រមួនឃ្មុំមកចាត់ចែងធ្វើទៀនជ័យ ក្នុងពិធីរៀបអាពាហ៍ពិពាហ៍... ដូចជារឿង "អនអើយស្រីអន" ដែលតួពីរនាក់ជាមិត្តសម្លាញ់នឹងគ្នា "ជ័យ និងសួស្តី" នាំគ្នាទៅបេះឃ្មុំ ។ ពេលនោះសួស្តីក្បត់ជ័យ លួចដកជណ្តើរចេញពីដើមឈើមិនអាចឱ្យជ័យចុះមកបាន ។ ឯខ្លួនវិលត្រឡប់មកផ្ទះរៀបការជាមួយស្រីអនដោយប្រាប់មហាជនថា ជ័យធ្លាក់ពីលើដើមឈើស្លាប់ទៅហើយ... ។ ល ។ ម្យ៉ាងទៀតចាស់ៗតែងនិទានប្រាប់កូនចៅជាន់ក្រោយថា : អ្នកណាបានរកឃើញកន្លែងដែលខ្លាឃ្មុំជុះអាចម៍ [១] អ្នកនោះនឹងក្លាយទៅជាអ្នកមាន ព្រោះអាចម៍ឃ្មុំសុទ្ធតែក្រមួនឃ្មុំ ។

*ក. ធ្វើទៀន :* កាលដើមឡើយ ទៀនគ្រប់យ៉ាងសម្រាប់យកមកអុជបំភ្លឺក្តី ប្រើក្នុងពិធីអាពាហ៍ ពិពាហ៍ បុណ្យទានផ្សេងៗក្តី សុទ្ធតែធ្វើឡើងពីក្រមួនឃ្មុំទាំងអស់ ។

*ខ. រូតចេស :* ស្ត្រីមេផ្ទះនៅស្រុកស្រែចម្ការ យកក្រមួនឃ្មុំមករូតចេសដើម្បីឱ្យរឹងសរសៃ ងាយស្រួលក្នុងការដោតតូចម្ជុល ក៏ដូចជា ជួយការពារចេស កុំ

---

១ - ដោយខ្លាឃ្មុំ ស៊ីតែឃ្មុំជាអាហារ អាចម៍វា សុទ្ធតែក្រមួនឃ្មុំ ពិសេសទៅទៀតវាជុះអាចម៍តែមួយកន្លែង ពុំមានប្រែប្រួលទៅទីណាផ្សេងឡើយ ។

ឱ្យឆាប់ពុក ព្រោះក្រមួនជាសារជាតិទប់ទល់មិនឱ្យជ្រាបទឹក ។

*គ. ធ្វើគ្រឿងក្រអូបតាក់តែងកាយ :* បុព្វបុរសយើង យកក្រមួនសុទ្ធមកធ្វើជាវត្ថុធាតុដើម ក្នុងការផ្សំជាមួយប្រេងដូង និងលំអងផ្កាសុរភី ស្លូ បញ្ចូលគ្នា ធ្វើជាក្រមួនមាត់ សម្រាប់លាប បបូរមាត់ឱ្យសើមស្រស់បស់ផង និងក្រអូបផង ព្រមទាំងសម្រាប់លាបសក់ លាបចិញ្ចើមឱ្យក្រាបរាបល្អ និងមានពណ៌រលើបរលោង ។ គ្រូហ្មមើលជំងឺ ឬបុរសអ្នកលេងខ្លួនពីជំនាន់មុន ច្រើនដាក់ក្រមួនមាត់ក្នុងដន្លាប់ឈើ ឬភ្លុកទុកដាក់ស្នេហ៍ខ្មោច ឬស្នេហ៍មនុស្ស តាមការនិយមរបស់យុគសម័យ ។

*ឃ. សម្រាប់ធ្វើពុម្ព :* ជាងស្មិត ជាងទងខ្លះ ប្រើក្រមួនសម្រាប់សូនធ្វើពុម្ពក្បាច់រចនា ឬពុម្ពបដិមា និងគ្រឿងអលង្ការផ្សេងៗផង ។

*ង. សម្រាប់ពត់ផ្តៅ :* ជាងធ្វើគ្រឿងសង្ហារិមផ្សេងៗអំពីផ្តៅ ប្រើក្រមួនដើម្បីជាជំនួយក្នុងការពត់ផ្តៅកុំឱ្យគ្រេច និងឱ្យវាមានសណ្ឋាន កោង ង ទៅតាមបំណងរបស់គេ នៅពេលដែលគេរោលភ្លើកម្តៅវាដើម្បីឱ្យវាទន់ងាយស្រួលពត់ ។

*៣. ការចម្រាញ់ក្រមួន :* ក្បាលទឹក និងផ្លិតឃ្មុំ ទាំងពីរផ្នែកនេះ សុទ្ធតែត្រូវបានកសាងឡើងអំពីក្រមួន ដែលផលិតចេញពីទឹកមាត់ឃ្មុំ ផ្សំនឹងសារជាតិម្យ៉ាងរបស់វា ។ កាលណាគេច្របាច់យកទឹកឃ្មុំចេញ ពីក្បាលទឹកអស់ហើយ កាកដែលនៅសល់ទាំងប៉ុន្មាន គឺជាក្រមួនលាយឡំដោយលំអង ។ ចំណែកឯផ្លិតឃ្មុំវិញ មានរន្ធមូល តូចប៉ុនចង្កឹះ ។ មេឃ្មុំបានផ្ទុកពងវាំនៅក្នុងរន្ធនេះ ដែលនឹងត្រូវក្លាយជា ដង្កូវ រួចជាកូនឃ្មុំក្នុងរយៈពេលមួយជាកំណត់ ។ ស្ត្រីមេផ្ទះយកផ្លិតឃ្មុំមកគោះឱ្យ ជ្រុះកូន ឬពងឃ្មុំទៅក្នុងឆ្នាំង រួចហើយយកសំបកសំបុកឃ្មុំ ទៅដាក់ដាំស្ងោរ ក្នុងឆ្នាំងមួយ ដុតភ្លើងរំងាស់ឱ្យពុះ មួយសន្ទុះ ទើបលើកឆ្នាំងចេញ ពីចង្ក្រានទុកឱ្យ ត្រជាក់ ។ ប្រមាណមួយម៉ោងក្រោយមក ជាតិក្រមួនសុទ្ធ ដែលរលាយកាលត្រូវ

កម្ដៅក្នុងទឹកពុះនោះ ក៏កកអណ្ដែតទៅលើផ្ទៃទឹក ។ ស្ត្រីជាអ្នកចម្រាញ់ ក៏យកគូថត្រឡោក ទៅផ្ដិលយកក្រមួនសុទ្ធ[១]ជាច្រើនលើកច្រើនសា ដរាបទាល់តែអស់ក្រមួនកកពីឆ្នាំង ទុកសម្រាប់ប្រើប្រាស់ទៅថ្ងៃក្រោយតាមត្រូវការ ។

*៤. អំពីកូនឃ្មុំ:* កូនឃ្មុំជាចំណីអាហារដ៏ឆ្ងាញ់របស់កសិករខ្មែរ នៅជនបទជាពិសេស ។ កូនឃ្មុំលីងលាយជាមួយអំបិល ឬញាំភ្លាលាយជាមួយបន្លែ ក៏ជាមុខម្ហូបដ៏ប្រសើរមួយដែរ ។ ជួនកាលគេបេះផ្លិតឃ្មុំ ជ្រលក់នឹងទឹកឃ្មុំបរិភោគក៏បាន ។

*៥. ទឹកឃ្មុំ :* ទឹកឃ្មុំជាបង្អែមធម្មជាតិមួយប្រភេទ ដែលមានរសជាតិឆ្ងាញ់ជាពិសេស ធ្វើឱ្យមនុស្សក្នុងលោកចាប់ចិត្ត ចាប់អារម្មណ៍យ៉ាងខ្លាំង ។ គេបរិភោគទឹកឃ្មុំលាយជាមួយដំឡូងត្រាវស្ងោរ មានឱជារសណាស់ ព្រមទាំងផ្ដល់នូវកម្លាំងពលំចម្រើនថាមពលឱ្យរាងកាយទៀតផង ។ ទឹកឃ្មុំលាយជាមួយលាជ ក៏ជាបង្អែមមួយច្រើនមាននិទានក្នុងរឿងព្រេងបុរាណខ្មែរ ។ ក្រៅពីនេះ ទឹកឃ្មុំ[២] លាយជាមួយទឹកក្រូចឆ្មារ គឺជាឱសថដ៏មានប្រសិទ្ធិភាពសម្រាប់បំបាត់រោគរាគរូស មូលឬអាសន្នរោគ ។ ថ្នាំគុលិកាផ្សេងៗរបស់ឱសថបុរាណខ្មែរយើង ត្រូវបានលាយជាមួយទឹកឃ្មុំ ដែលមានជាតិស្អិតងាយស្រួលក្នុងការសូនផង ងាយលេបផង ព្រោះ ទឹកឃ្មុំមានរសជាតិផ្អែម ជួយបង្អន់រសជាតិល្វីងនៃឱសថ ។

ការរកឃ្មុំគឺជារបរមួយ ហើយក៏ជាផ្នែកមួយនៃសេដ្ឋកិច្ចគ្រួសារដែរ ។ ប្រជាកសិករ នៅតំបន់ជុំវិញទន្លេសាប តែកាលណាដល់ ខែផល្គុន ឬ ខែចេត្រ ហើយគេនាំគ្នាបររទេះទៅរកឃ្មុំនៅព្រៃរនាម ដើម្បីរកឃ្មុំ ក្នុងបំណងចម្រាញ់ក្រមួន នឹង

---

១ - ក្រមួនសុទ្ធមានពណ៌លឿងភ្លាវ

២ - ទឹកឃ្មុំអាចផ្សំធ្វើឱសថក៏បាន

យកទឹកឃ្មុំ ជាវត្ថុសំខាន់សម្រាប់ឆ្លើយតបទៅនឹងសេចក្ដីត្រូវការរបស់ទីផ្សារ ។ មួយខែក្រោយមក គេត្រឡប់មកភូមិវិញ ដោយផ្ទុកជាមួយ នូវទឹកឃ្មុំជាច្រើនប៉ោត[១] ។ ប្រជាកសិករ អាចទទួលបានផលកម្រៃយ៉ាងគាប់ចិត្ត ពីមុខរបរនេះ ។

នៅប្រទេសមួយចំនួន ប៉ែកបស្ចិម គេប្រកបរបរ ចិញ្ចឹមឃ្មុំ ជាទ្រង់ទ្រាយធំ ក្នុងរូបភាពជា កសិ/ឧស្សាហកម្ម ។នេះគឺជាអាជីវកម្មម្យ៉ាងបែប វិទ្យាសាស្ត្រទំនើប អាចប្រមូលបាន នូវទិន្នផលខ្ពស់ជាងការរកឃ្មុំធម្មជាតិ តាម លំនាំបុរាណ ។

## ពុទ្ធភាសិត

*អ្នកណាល្ងង់ខ្លៅ សម្គាល់ថាខ្លួនល្ងង់ខ្លៅ អ្នកនោះគង់តែនឹងទៅជាអ្នកចេះពុំខាន*

*អ្នកណាល្ងង់ខ្លៅ សម្គាល់ថាខ្លួនចេះដឹង អ្នកនោះនៅតែល្ងង់ខ្លៅអស់មួយជីវិត*

ធម្មបទកថា ពាលវគ្គ

---

១ - គេច្រើននិយមយកទឹកឃ្មុំ ខែចេត្រមកផ្សំធ្វើជាថ្នាំ ពូកែសក្តិសិទ្ធិ ជាងទឹកឃ្មុំយកបានក្នុងខែផ្សេងពីនេះ ។

- តំបន់ព្រៃរនាមសម្បូរឃ្មុំជាងតំបន់ព្រៃភ្នំ ។ ឈើ ១ ដើមមានឃ្មុំនៅពី ១០ ទៅ ១៥ សំបុក ។

# ឱសថបុរាណខ្មែរ

(ត)

**ព៌ុសែន** ( Borneal )

**ព៌ុសែនក្រាម** ( **Borneal Comphor** )




ដោយ : **ស្នួន ឱសថ**

ជាសារជាតិចម្រាញ់ ពីធញ្ញជាតិ តាមតម្រាពីបុរាណ ដែលបានប្រមូលមក ពីលក្ខដ្ឋាននៃ ភេសជ្ជកម្ម ( **ការធ្វើឱសថ** )។ លោកបានចាត់ជាធាតុវត្ថុ បានមកពីការយកធញ្ញជាតិ មានក្លិនក្រអូប មកស្ងោររម្ងាស់ជាមួយគ្រឿងបុប្ផាជាតិផ្សេងទៀត បានជាគ្រាប់ក្រាមៗ មានពណ៌ស ឬពណ៌សក្រហមព្រឿងៗ ។ ប៉ុន្តែនៅពេលបច្ចុប្បន្ន បានមកពីសារជាតិសង្គ្រោះ នឹងមានរសជាតិហឹរជាប់អណ្ដាត ថាជារបស់ចម្រាញ់មកពីធម្មជាតិដែរ និងមិនក្ដៅអណ្ដាត ធ្វើឱ្យត្រជាក់ក្រអប់ប្រមាត់ សម័យមុនភាគច្រើនបុរាណប្រើតែម្ហូបុំណ្ណោះ ។

**សព្វគុណ** : រសក្រអូបត្រជាក់ ព្យាបាលវិលមុខ ធឹងធោង ខ្សោយ-

បេះដូង ប៉ូវបេះដូង ធ្វើឱ្យត្រជាក់ ធ្វើឱ្យភើចេញខ្យល់តាមមាត់ ដេញខ្យល់ ព្យាបាល ចុកសៀតណែន ហើមពោះ ព្យាបាលមុតរបួសថ្មីៗ របួសរ៉ាំរ៉ៃ របួសប្រភេទកាមរោគ របួសលើស្បែករ៉ាំរ៉ៃ ។

## មើមដើងក្លាម

**Euphorbia tirucalli line**



ជារុក្ខជាតិមានដើមឈរត្រង់ខ្នាតតូច កំពស់ ៣ ទៅ ៧ ម៉ែត្រ បែកមែក សាខាជាប់គូដើមមានមែករាងមូលពណ៌ខៀវ ស្លឹកមិនច្រើន ទំហំតូចៗ ខាងចុង ទងមានផ្កាដុះចេញជាកញ្ចុំតាមថ្នាំង នៅចុងមានមែកពណ៌សលាយលឿង ផ្លែតូចៗ មាន ៣ សណ្តានពណ៌ត្នោត មានជ័រពណ៌ស មានប្រសិទ្ធភាពកំចាត់ពិស តែងដុះតាម ព្រៃស្ងួតស្ងួត បន្តពូជដោយគ្រាប់ ឬផ្សាំមែក ។

**សព្វគុណ**

**ស្លឹក និង ឫស** : មានរសប្រហាត បុកលាបកែរោគឫសដូងបាត

**ដើម** : មានរសប្រហាត ដាំទឹកផឹកកែរោគឈឺពោះ រលាកក្រពះ, ព្យាបាលឆ្អឹងបាក់ ព្យាបាលឈឺហើមតាមសន្លាក់ ( **ព្យាបាលខាងក្រៅ** )

**ឫស** : មានរសប្រហាត ដាំទឹកផឹក ព្យាបាលធាតុពិការ ( **ការបាត់បង់ធាតុ ណាមួយ** ) ជួយបន្ទន់លាមក ស្ងោររម្ងាស់ជាមួយទឹកដូង សម្រាប់ព្យាបាលឈឺពោះ

**ជ័រ** : មានរសហឹរក្តៅ មានប្រសិទ្ធិភាពខ្លាំង **លាបលើស្បែក** ព្យាបាលឈឺក ចូលភ្នែកអាចស្រវាំងបាន ។

(នៅមានត)

*កាលបើស្តាប់បានសេចក្តី សូម្បីតែមួយរំពេច*
*ក៏ឈ្មោះថា បានស្តាប់ដោយប្រពៃ ។*

ព្រះពោធិវង្ស **ហួត តាត**

# ទស្សនៈព្រះពុទ្ធសាសនា និង ការអភិរក្ស បរិស្ថានធម្មជាតិ

ដោយ: ឈុន អឿម

លក្ខខ័ណ្ឌឬស្ថានភាពទាំងឡាយ ដែលឋិតនៅជុំវិញយើង ហើយដែលជះឥទ្ធិពលទៅលើការដុះដាល (growth) លូតលាស់ និងការអភិវឌ្ឍនីរីកចម្រើន ត្រូវបានគេស្គាល់ ឬគេហៅថា " បរិដ្ឋាន ", ប៉ុន្តែ ដោយសារបញ្ហាគ្រោះថ្នាក់បរិដ្ឋាន បានកើតមានឡើងយ៉ាងលើសលប់, ទើបការសិក្សាហ្មត់ចត់ស៊ីជម្រៅមួយអំពីប្រធានបទនេះ កើតមានជារូបរាងឡើងក្នុងពេលថ្មីៗនេះ ដែលមានឈ្មោះថា " អេកូឡូស៊ី " (Ecology)។ អេកូឡូស៊ី គឺជាការសិក្សាវិទ្យាសាស្ត្រ ដែលផ្តោតការយកចិត្តទុកដាក់លើការសិក្សាអំពីបែបបទ នៃទំនាក់ទំនងរវាងភូតគាម (plants), សត្វ មនុស្ស និងបរិដ្ឋាន។ និយាយមួយបែបទៀត, អេកូឡូស៊ី គឺការសិក្សាបែបវិទ្យាសាស្ត្រអំពីទំនាក់ទំនងនៃភូតគាម និងសត្វ ចំពោះគ្នាទៅវិញទៅមក និងចំពោះទីជុំវិញរបស់គេ។ នេះគឺជាមុខវិជ្ជាថ្មីមួយ រីកចម្រើននៅក្នុងសតវត្សទី ២០ កន្លងទៅនេះ។ មុខវិជ្ជានេះបានបង្ហាញឱ្យឃើញវែងឆ្ងាយ នូវការជាប់ពាក់ព័ន្ធក្នុងការសិក្សាលក្ខខ័ណ្ឌ ឬស្ថានភាពទាំងឡាយ នៃបរិដ្ឋាន ដូចជាអាកាសធាតុ ដី, ពន្លឺ, ខ្យល់ និងសំណើម។ ដោយហេតុនេះ, អេកូឡូស៊ី អាចជាប់ទាក់ទងគោលការណ៍សិក្សាប្រាំយ៉ាងដូចខាងក្រោមនេះ :

១-អ្វីៗទាំងអស់ ដែលឋិតក្នុងស្ថានភាព ប្រែប្រួលផ្លាស់ប្តូរ

២- អ្វីៗទាំងអស់ ដែលមានអន្តរសម្ព័ន្ធ ឬទំនាក់ទំនងគ្នាទៅវិញទៅមក

៣- គ្មានបញ្ញា (wisdom) ណាមួយប្រសើរលើសបញ្ញារបស់ធម្មជាតិទេ

៤- គ្មានអ្វីមួយ មានអត្ថិភាពឡើង ហើយគ្មានន័យនោះទេ

៥- ជាមូលដ្ឋាន. គ្មានអ្វីមួយមានអត្ថិភាពឡើងហើយជា សំណល់ឥតប្រយោជន៍នោះទេ (waste-matter) ។

ដូច្នេះបើយោងតាមអេកូឡូស៊ីវិទូ ការដុះដាលលូតលាស់ និងការអភិវឌ្ឍន៍ធំធាត់ នៃអ្វីៗទាំងអស់ គឺមានអន្តរសម្ព័ន្ធគ្នាទៅវិញទៅមកប្រកបដោយថាមភាព (dynamic) ហើយអ្វីមួយជាឧបសគ្គរាំងស្ទះដល់ការដុះដាល លូតលាស់ និងអភិវឌ្ឍរីកចម្រើននៃអ្វីៗទាំងអស់នោះ នឹងនាំទៅដល់ភាពប្របូកច្របល់បរិដ្ឋានទាំងស្រុង ។

សព្វថ្ងៃនេះ ការបង្កភាពកខ្វក់ដល់បរិដ្ឋាន បានគំរាមកំហែងដល់សុខភាពមនុស្សទូទៅ នៃប្រជាជាតិជាច្រើនក្នុងពិភពលោក ។ ចាប់តាំងពីពេលវិទ្យាសាស្ត្រ និងបច្ចេកវិជ្ជាបានបង្កើតឱ្យមានប្រតិកម្មជាទំនាស់គ្នាមក នៅក្នុងប្រទេសបានអភិវឌ្ឍហើយ និងប្រទេសកំពុងអភិវឌ្ឍ. ខ្យល់អាកាស. ទឹក. ដី. រុក្ខជាតិ និងចំណីអាហារជាដើម ត្រូវបានប៉ះពាល់ដោយភាពកខ្វក់ជាច្រើនបែបយ៉ាងណាស់ ។ ឧទាហរណ៍ នៅសហរដ្ឋអាមេរិក រោងចក្រធំៗបញ្ចេញកាកសំណល់ពុល. កាកសំណល់គីមី បង្កឱ្យមនុស្សមានជំងឺផ្លូវដង្ហើមរ៉ាំរ៉ៃ. កើតរោគមហារីក. ទារកកើតមកមិនប្រក្រតី. កើតជំងឺសរសៃប្រសាទ (psycho-behavioural shortcomings ) ។ នៅតូក្យូ. ប៉ូលីសចរាចរ ត្រូវស្រូបខ្យល់អុកស៊ីហ្សែនបរិសុទ្ធ អំពីធុងអុកស៊ីហ្សែនរៀងរាល់ពីរម៉ោងម្តង ដើម្បីកម្ចាត់ជាតិពុល កាបោនម៉ូណូក្ស៊ីដ ( carbon monoxide ) ។៧ ។

បញ្ហាទាំងឡាយដែលកើតឡើងនាសម័យបច្ចុប្បន្ន. មិនឋិតនៅតែក្នុងព្រំដែនប្រទេសមួយ ដែលបញ្ហាទាំងឡាយបានកើតឡើងទេ។ បញ្ហាទាំងនោះក្លាយទៅជាបញ្ហាសកល។ ការពង្រីកសកម្មភាពសេដ្ឋកិច្ច ដោយផ្តោតតែលើការលូតលាស់សេដ្ឋកិច្ចសុទ្ធសាធ បានបង្កឱ្យអាកាស ទឹក ត្រី និងចំណីអាហារជាច្រើនមុខទៀត មិនមានលក្ខណៈសមស្របសម្រាប់ការប្រើប្រាស់ ឬបរិភោគរបស់មនុស្ស។ ឧទាហរណ៍ សកម្មភាពឧស្សាហកម្មដុះដាលកំរិតខ្ពស់នៅសហរដ្ឋអាមេរិក បានធ្វើឱ្យប៉ះពាល់ប្រភពផ្តល់ចំណីអាហារនៅឯប្រទេសរុស្ស៊ី ។ យ៉ាងណាមិញ. ស្ទឹងទន្លេនៅសហរដ្ឋអាមេរិកភាគខាងកើត បាននាំយកសំណល់ជាតិពុលឧស្សាហកម្មទៅដល់សមុទ្រអាត្លង់ទិក ហើយបានបំផ្លាញត្រីនៅទីនោះ ដែលពីមុនធ្លាប់តែសម្បូរ។ ថ្មីៗនេះ គេរាយការណ៍ថា ចំណីអាហារសមុទ្រមានជាតិពុលខ្ពស់នៅហុងកុង ហើយលក់នៅក្នុងទីផ្សារហុងកុង ។

បញ្ហាកខ្វក់បរិដ្ឋាន ដែលយើងកំពុងជួបសព្វថ្ងៃ គឺគេមិនដែលបានស្គាល់ ឬដឹងឮ ក្នុងប្រទេសឥណ្ឌា ក្នុងសម័យពុទ្ធកាល នាសតវត្ស ទី ៦ មុនគ្រឹស្តសករាជទេ។ បញ្ហានេះ កើតមានដោយសារតែបច្ចេកវិជ្ជាទំនើប និងឧស្សាហូបនីយកម្មនៃពិភពលោកបច្ចុប្បន្ន។ ប៉ុន្តែ ដោយហេតុថា វិធីដោះស្រាយរបស់ពុទ្ធសាសនាចំពោះបរិដ្ឋានធម្មជាតិ និងទំនាក់ទំនងរបស់មនុស្សចំពោះធម្មជាតិ ដូចមានរៀបរាប់នៅក្នុងគម្ពីរពុទ្ធសាសនា គឺជាវិធីនាំទៅរកការបង្កើតឱ្យមានបរិយាកាសមួយជាសុខដុម ផ្តល់ឱ្យមានសេចក្តីសុខសម្រាប់ជីវិតទាំងអស់នៅលើផែនដីនេះ, គេហាក់ដូចជាមានជំនឿថា ពុទ្ធសាសនាកំពុងជះពន្លឺបង្ហាញលទ្ធភាពដោះស្រាយបញ្ហាវិបត្តិបរិដ្ឋាននេះបាន។ ដោយការរក្សាខ្ជាប់នូវការគោរពខាងអេកូឡូស៊ី, ពុទ្ធសាសនាតែងបណ្តុះបណ្តាលឥរិយាបថជាមិត្តជិតស្និទ្ធជាមួយធម្មជាតិ និងតែងសម្លឹងមើលពី

ជ្រុងមិត្តភាព និងសុខដុមភាពនេះ នូវទំនាក់ទំនងរវាងភូតគាម ( plants ), សត្វ ( animals ) ហើយនិងមនុស្ស ។

ព្រឹត្តិការណ៍ធំៗបីគឺ ប្រសូត្រ, ត្រាស់ដឹង និងបរិនិព្វាន ទៅក្នុងព្រះជីវភាពរបស់ព្រះពុទ្ធ គឺបានប្រព្រឹត្តទៅក្នុងអជ្ឈោកាស (ទីវាលគ្មានបាំងបិទ) ក្រោមដើមឈើ។ ជាញឹកញយណាស់ ព្រះពុទ្ធតែងទូន្មានភិក្ខុសង្ឃឱ្យស្វែងរកទីវាលគ្មានបាំងបិទនៅក្នុងព្រៃ, នៅគល់ឈើ ដើម្បីហ្វឹកហាត់ធ្វើភាវនា។ បរិយាកាសមនោរម្យស្ងប់ស្ងាត់នៅក្នុងបរិដ្ឋានធម្មជាតិ ត្រូវបានចាត់ទុកជាការជម្រុញសម្រាប់ការដុះដាលខាងស្មារតី ( spiritual growth ) ។

ព្រះទ័យជាប់ជំពាក់របស់ព្រះពុទ្ធចំពោះដើមឈើ និងព្រៃ ត្រូវបានបញ្ជាក់យ៉ាងច្បាស់នៅក្នុង**វនរោបសូត្រនៃសំយុត្តនិកាយ** ។ នៅក្នុងព្រះសូត្រនេះ លោកបានពោលថា ការដាំរុក្ខជាតិធ្វើជាសួនឧទ្យាន (អារាមរោបា) និងការដាំព្រៃឈើ (វនរោបា ) គឺជាអំពើកុសល ផ្តល់អានិសង្សឱ្យទាំងថ្ងៃ ទាំងយប់ដល់ម្ចាស់អ្នកដាំដុះ។ ជាភស្តុតាងជាក់ស្តែង, ព្រះពុទ្ធទ្រង់យកព្រះទ័យទុកដាក់ខ្ពស់ណាស់ចំពោះទស្សនវិស័យប្រយោជន៍និយមនៃឈើ និងព្រៃ។ នៅក្នុងគម្ពីរធម្មបទ ពាក្យ " វនៈ " ឬ ព្រៃ ត្រូវបានព្រះពុទ្ធប្រើជាពាក្យមានន័យកំប្លែង ( សិលេសត្ថវចនៈ ) ដែលអាចយកមកអនុវត្តប្រកបដោយអត្ថន័យជ្រាលជ្រៅចំពោះបរិបទពិភពលោកបច្ចុប្បន្ន :

" **វនំ, ឆិន្ទថ-មា-រុក្ខំ វនតោ ជាយតិ ភយំ** "។

ចូរអ្នកកាប់បំផ្លាញព្រៃតណ្ហា (វនៈ ), ប៉ុន្តែ ( កុំកាប់បំផ្លាញ ) ដើមឈើ ( រុក្ខៈ ) ។ ភ័យរមែងកើតចេញពីព្រៃតណ្ហា ។

អ្វីដែលគួឱ្យអៀនខ្មាស់គឺថា ពិភពលោកបច្ចុប្បន្ន កំពុងប្រឡូកក្នុងការកាប់រំលំដើមឈើធ្វើអាជីវកម្មយកប្រយោជន៍បំប៉នតណ្ហា តាមរយៈនេះគេបានបំបាត់

"ព្រៃដើមឈើ "។ អ្វីដែលគេគប្បីធ្វើដោយពិតប្រាកដ គឺការកាប់ផ្តួលរំលំ "ព្រៃធំ និងព្រៃស្បាតនៃតណ្ហា " នៅក្នុងខ្លួនរបស់គេ ដែលបន្តរាំងស្ទាក់ការលូតលាស់ ដុះដាលខាងបញ្ញា និងស្មារតីរបស់គេ។ កាលណា ព្រៃតណ្ហា ត្រូវបានកាប់បំផ្លាញ ហើយ. គេមុខជាលែងគិតដល់ការកាប់ដើមឈើនិមួយៗ នៅក្នុងព្រៃឈើ ពិព្រោះ តែចំណង់លោភលន់ ដែលបានអូសទាញឱ្យកាប់ដើមឈើនោះហើយ។ ដោយហេតុ នេះ. ដំបូន្មានសីលធម៌គឺ " **ចូរកុំកាប់រំលំឈើ. ប៉ុន្តែចូរកាប់រំលំតណ្ហា** "។

ប៉ុន្តែ ការដាំព្រៃឈើ ( វនរោបា ) មានទាក់ទងនឹងទស្សនៈផែនការមេដាំ ដើមឈើ ដែលអ្នកអេកូឡូស៊ីបានគិតគូរ ដើម្បីសង្គ្រោះប្រទេសជាតិ អំពីហានិភ័យ បរិដ្ឋាន ក៏ដូចជាជួយពិភពលោកឱ្យផុតពីការវិនាសអស់ព្រៃឈើ ហើយផលវិបាកនៃ ការវិនាសព្រៃឈើ គឺពិភពលោកក្លាយជាវាលខ្សាច់ហួតហែង។ វិន័យបានហាមភិក្ខុ មិនឱ្យកាប់រំលំដើមឈើ ដោយគេជឿថា ដើមឈើគឺជាសរីរាង្គមានជីវិត។ ព្រះអង្គ បានបញ្ញត្តចំពោះរឿងនេះ ដោយទ្រង់ពន្យល់ថា : " ហេតុអ្វីបានជាមនុស្សកម្លៅ កាប់រំលំ និងញ៉ាំងគេឱ្យកាប់រំលំដើមឈើ។ តាមពិត. គេជឿថា ដើមឈើមាន ជីវិត"។ (**កថំ ហិ នាម មោឃបុរិសោ រុក្ខំ ឆិន្ទិស្សថា បិ ។ ជីវសញ្ញិនោ មនុស្សរុក្ខស្មឹ** )។ បីដូចជាឆ្កែ. គោឈ្មោល. មេគោ. ឬសេះ. ដើមឈើបំរើមនុស្ស ដោយស្ងៀមស្ងាត់ ដោយផ្តល់ឱ្យមនុស្សនូវតម្រូវការជាច្រើន។ ក្រៅពីនេះ ដើមឈើ នៅពេលថ្ងៃស្រូបយកជាតិពុល កាបោនឌីអុក្ស៊ីដ (carbon dioxide) ដែលយើង បញ្ចេញចោល ហើយធ្វើឱ្យបរិដ្ឋានជុំវិញយើងបានបរិសុទ្ធ ដោយបញ្ចេញអុកស៊ី- ហ្សែន ដែលមានសារសំខាន់ក្រៃលែងសម្រាប់ជីវិតយើង។ នេះគឺ ជាការងារដែល រុក្ខជាតិធ្វើពីធ្លាស្ទិកសិប្បនិមិត្តមិនអាចបំពេញបាន។ ដោយហេតុនេះ ភិក្ខុណាកាប់ រំលំដើមឈើ. ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយៈ។

ពុទ្ធសាសនា ចាត់ទុកការកាប់ដើមឈើ សូម្បីតែមួយមែក ដែលផ្ដល់ម្លប់ គឺជាអំពើរមិលគុណ។ នៅក្នុងគម្ពីរ គេបានចាត់ទុកនូវគំរូដំបូងបំផុតរបស់ព្រះពុទ្ធថា នៅក្នុងសប្ដាហ៍ទីពីរ ក្រោយបានត្រាស់ដឹងហើយ, ដើម្បីជាការបង្ហាញនូវកតញ្ញូតា របស់ព្រះអង្គចំពោះពោធិព្រឹក្ស, ព្រះអង្គបានគង់បែរព្រះភក្ត្រឆ្ពោះទៅរកដើម ព្រះពោធិព្រឹក្ស ដោយមិនពព្រិចព្រះនេត្រអស់មួយសប្ដាហ៍ទាំងមូល, ដោយសារតែ ពោធិព្រឹក្សបានផ្ដល់ដល់ព្រះអង្គនូវម្លប់ គ្របការពារព្រះអង្គឱ្យផុតពីកម្ដៅស្ទើរឆេះ ក្នុងរដូវក្ដៅ នាខែឧសភា។

នៅក្នុងព្រះសូត្រទាំងឡាយ ក៏មានឃ្លាដដែលៗ កត់សម្គាល់នូវភាព សុខដុម និងភាពចុះសម្រុងគ្នានៃបរិដ្ឋានថាដូច្នេះ : " ឱ! ទីឋានដ៏ជាទីមនោរម្យ, មានម្លប់ ព្រៃឈើក្រាសឃ្មឹក ជាទីញ៉ាំងចិត្តឱ្យជ្រះថ្លារីករាយ, ឯស្ទឹងក៏បន្តហូរជិត ខាងនោះដែរ " ( **រមណីយោ វត ភូមិភាគោ, បសាទិកោ ច វនសន្ឌោ, នទី ច សន្ទតិ** )។ ព្រះសារិបុត្តត្ថេរ ក៏មានថេរដីកា នៅក្នុងន័យដូចគ្នាសរសើរឧទ្យាន គោសិង្គសាល ថា "ម្នាលអាវុសោ រេវតៈ ឧទ្យានគោសិង្គសាលនាពេលរាត្រីក្រោម ពន្លឺព្រះចន្ទ ជាទីមនោរម្យណាស់។ ដើមសាលព្រឹក្សកំពុងចេញផ្ការីកស្គុះស្គាយ។ គន្ធពិដោរ ដែលរសាត់តាមខ្យល់, ខ្ញុំករុណាយល់ថា ជាទិព្វ " **រមណីយំ អាវុសោ រេវត គោសិង្គសាលវនំ ទោសិនា រត្តិ, សព្វផាលិផុល្លា សាលា, ទិព្វា មញ្ញេ គន្ធា សម្បវន្តិ** )។

ថេរគាថា ដ៏ជាកម្រងគាថា ចងក្រងឡើងដោយព្រះអរហន្តទាំងឡាយ គឺពោរពេញដោយការពណ៌នាអំពីធម្មជាតិ និងបរិដ្ឋាន (ទីជុំវិញ)។ ការពោលកោត សរសើរធម្មជាតិ ដែលឃើញមាននៅក្នុងកម្រងគាថាទាំងនោះអាចទទួលចំណាត់ ថ្នាក់ជាកំណាព្យ (គាថា) ស្ដីពីធម្មជាតិដ៏មានកម្រិតខ្ពស់។ ព្រះថេរៈ កាឡុទាយិ,នៅ

ពេលទូលរំលឹកព្រះពុទ្ធអង្គអំពីពេលវេលាសមស្រប ដើម្បីយាងចេញដំណើរទៅកាន់ទីក្រុងកបិលវត្ថុ, ជារាជធានីកំណើតរបស់ព្រះអង្គ, បានពោលសរសើរធម្មជាតិក្នុងសរទរដូវ (រដូវរំហើយ) ថា :

"ដើមឈើកំពុងរីកផ្កាជាទីមនោរម្យ ផ្សាយគន្ធពិដោរជុំវិញទាំងអស់គ្រប់ទិសទី, រុះរោយលំអងផ្កា, បញ្ចេញផ្លែរយោនរយាន ។ នេះគឺជាពេលត្រូវយាងទៅមុខចាកចេញពីទីនេះ"។

" បពិត្រព្រះអង្គ ឥឡូវដើមព្រឹក្សាប្រែពណ៌លឿងខ្ចី រុះរោយស្លឹកចាស់របស់វា ដើម្បីបញ្ចេញផ្លែ។ ដើមព្រឹក្សាទាំងនោះហាក់ដូចជាភ្លឺចែងចាំងដោយអណ្តាតភ្លើង។ បពិត្រព្រះមហាវីរបុរស, នេះជាពេលវេលា ដែលត្រូវភ្លក្សឱជារសហើយ។

នៅមានព្រះភិក្ខុសង្ឃជាព្រះអរហន្តច្រើនអង្គទៀត បានពោលរៀបរាប់និងសរសើរព្រៃព្រឹក្សា, ពពួករុក្ខជាតិ (flora), និងពពួកបសុសត្វ (fauna), ពពួកបក្សី និងពពួកសត្វពាឡម្រឹគ (beast), ព្រមទាំងទន្លេ-ស្ទឹងកំពុងហូរ និងទឹកកំពុងធ្លាក់ចុះពីជម្រាលភ្នំ ទុកជាគ្រឿងជម្រុញកម្លាំងចិត្ត ដើម្បីស្វះស្វែងសម្រេចសមិទ្ធផលដ៏ឧត្តមរបស់លោកខាងស្មារតី។

**សេនាសនក្ខន្ធកៈ នៃ ចុល្លវគ្គបាលី** បាននិយាយអំពីវិធានការមួយចំនួនដែលព្រះពុទ្ធអង្គបានបញ្ញត្ត ដើម្បីបញ្ចៀសសភាពធ្វើឱ្យកខ្វក់បរិដ្ឋាន និងថែរក្សាសុខភាព និងអនាម័យនៅក្នុងសហគមន៍សង្ឃ។ បទបញ្ញត្តិស្តីពីការបោះចោលកាកសំណល់, ការប្រើប្រាស់បង្គន់, ការកំណត់ទីកន្លែងសម្រាប់ស្រង់ទឹក(ងូតទឹក)ក្តៅ និងបទបញ្ញត្តិស្តីពីការថែរក្សាជូសជុលទ្រទ្រង់វត្តអារាម និងកុដិជាទីស្នាក់អាស្រ័យ, ទាំងអស់គឺសំដៅបញ្ចៀសភាពធ្វើឱ្យកខ្វក់ខ្យល់អាកាស, ទឹក និងទីជុំវិញ។

នៅក្នុងភិក្ខុនីបាតិមោក្ខ, បទបញ្ញត្តិជាក់លាក់ អំពីអាបត្តិបាចិត្តិយៈ ត្រូវបានកំណត់ ដោយយោងទៅដល់ការបោះចោលសម្រាម ឬកាកសំណល់ថា ដូច្នេះ "ភិក្ខុនីអង្គណាបោះចោលទៅខាងក្រៅ ឬប្រើ (អ្នកឯទៀត) ឱ្យបោះចោលទៅខាងក្រៅ នូវលាមក (អាចម៍), ទឹកនោម, សម្រាម ឬសំណល់អាហារ រំលងជញ្ជាំង ឬរំលងរបង, ភិក្ខុនីអង្គនោះ ត្រូវអាបត្តិបាចិត្តិយៈ"។ សិក្ខាបទពីរនៃសេខិយវត្ត ក្នុងភិក្ខុបាតិមោក្ខ ក៏បាននិយាយពីភាពធ្វើឱ្យកខ្វក់ចំណីអាហារ និងទឹកដូច្នេះថា :

"អាត្មាអញនឹងមិនបន្ទោរបង់ (អាចម៍ ឬនោម) ឬខាកស្ដោះ, ប្រសិនមិនមានជំងឺទេ, លើស្រូវសាលី មានពណ៌បៃតងឡើយ"។

"អាត្មាអញនឹងមិនបន្ទោរបង់ (អាចម៍ ឬនោម) ក្នុងទឹកឡើយ"។

នៅក្នុងគន្លងនេះ គេសង្ឃឹមថា ភិក្ខុនឹងប្រតិបត្តិតាមសេខិយសិក្ខាបទ ដើម្បីបញ្ចៀសការធ្វើឱ្យកខ្វក់អាហារ និងទឹក។

គម្ពីរ **ខុទ្ទកវត្ថុក្ខន្ធកៈ** នៃ **ចុល្លវគ្គបាលី** បានហាម ដោយចំៗ នូវការដុតព្រៃថា "ម្នាលភិក្ខុទាំងឡាយ, ចូរអ្នកកុំដុតព្រៃ។ ភិក្ខុណាមួយដុតព្រៃ, ភិក្ខុនោះត្រូវអាបត្តិទុក្កដ" ( **ន ភិក្ខវេ ទាយោ អាលិម្បេតព្វោ។ យោ អាលិម្បេយ្យ អាបត្តិ ទុក្កដស្ស** )។

រឿងជាតក ដូចជារឿង តច្ឆសូករៈ (ជាងឈើ-ជ្រូក), រឿង កុសនាឡៈ (ទងស្មៅកុសៈ) ក៏និយាយអំពីអត្ថប្រយោជន៍ ( Utilitarian value ) នៃដើមឈើសម្រាប់ការរស់រានមានជីវិតរបស់មនុស្សដែរ។ ព្រះបាទអសោក ដោយប្រតិបត្តិតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ, ទ្រង់បានហាមការដុតព្រៃ តាមរយៈព្រះរាជក្រឹត្យឆ្លាក់លើសិលាស្ដម្ភទី ៥, ហើយព្រះអង្គបានដាំដើមឈើតាមបណ្ដោយផ្លូវ ដើម្បីផ្ដល់ម្លប់សម្រាប់អ្នកធ្វើដំណើរជ្រក។

ជាភស្តុតាងជាក់ស្តែង ពុទ្ធសាសនាទទួលស្គាល់តម្លៃនៃជីវិត។ តាមផ្លូវអភិសមាចារ, ទន្ទឹមនឹងពេលដែលបុគ្គលវៀរចាកការសម្លាប់ផ្តាច់ផ្តិលជីវិត, បុគ្គលត្រូវខិតខំ បណ្តុះបណ្តាលសុឆន្ទៈ និងមេត្តាធម៌ចំពោះសព្វសត្វផង (សព្វបាណ-ភូតានុកម្ប)។ មនុស្សបែបនេះ នឹងមិនគិតដល់អំពើធ្វើឱ្យអ្នកដទៃឈឺចាប់ឡើយ។ ជាងនេះទៀត គំនិតអំពីមេត្តាករុណា ដែលពុទ្ធសាសនា បានប្រៀនប្រដៅ នឹងមិនបណ្តោយឱ្យអ្នកណាមួយធ្លាក់ក្នុងការផ្សងព្រេងប្រកបដោយគ្រោះថ្នាក់ ដូចជាភាពធ្វើឱ្យកខ្វក់បរិដ្ឋាននេះជាដើម។

* ខ្ញុំបានសរសេរអត្ថបទនេះ សម្រាប់រួមចំណែកក្នុងសិក្ខាសាលាស្តីពី " **ការចូលរួមគ្រប់គ្រងធនធានធម្មជាតិ** " តាមទស្សនៈពុទ្ធសាសនាមានរយៈពេលមួយថ្ងៃ មុននឹងចាប់ផ្តើមបើកវគ្គបណ្តុះបណ្តាលគ្រូឧទ្ទេស មានរយៈពេល ២១ ថ្ងៃ សម្រាប់ការងារគ្រប់គ្រងធនធានធម្មជាតិថ្នាក់សហគមន៍, ដែលរៀបចំឡើងដោយព្រះតេជព្រះគុណ **ញៀម គឹមតេង** ប្រធានអង្គការ "សន្តិសេនា " នៅវត្តព្រៃធ្លាក់ ខេត្តស្វាយរៀង នាថ្ងៃទី ០៤ ខែមករា ឆ្នាំ ២០០២។

ប៉ុន្តែដោយមានភារកិច្ចចាំបាច់ មិនបានដឹងមុន មិនអាចទៅចូលរួមឧទ្ទេសឯកសារនេះបាន ខ្ញុំក៏បង្វែអត្ថបទ ស្តីពីប្រធានបទនេះមកចុះផ្សាយក្នុង " កម្ពុជសុរិយា " វិញ ដើម្បីជាគុណប្រយោជន៍ដល់ការចេះដឹងរបស់អ្នកអានយើង។

ឈ.អ

# សង្ឃប្រកាស

អនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេស លើកទី ១១ បានប្រារព្ធពិធីបើកនៅសាលសន្និសីទចតុមុខ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះរាជអគ្គមហេសី **នរោត្តម មុនីនាថ សីហនុ** ហើយបានដំណើរការអស់ថេរវេលា ៣ ថ្ងៃ ពីថ្ងៃទី ១៣ ដល់ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០២ នៅក្រសួងធម្មការ និងសាសនា ក្រោមព្រះរាជាធិបតីភាពសម្តេចព្រះសង្ឃរាជទាំងពីរគណៈ ដោយមានមន្ត្រីសង្ឃចំនួន ១២៦ អង្គ ចូលរួមជាសមាជិក និងមន្ត្រីធម្មការ និងសាសនាចំនួន ៨០រូប ជាអ្នកសង្កេតការណ៍ ។ ដោយយោងតាមព្រះរាជបន្ទូលរបស់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា អនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃនេះ បានចេញសង្ឃប្រកាស ដែលមានខ្លឹមសារដូចខាងក្រោម :

**១ ‿ ពង្រឹងការបដិបត្តិធម៌វិន័យ :**

- មន្ត្រីសង្ឃគ្រប់លំដាប់ថ្នាក់ធ្វើជាគំរូក្នុងការគោរព បដិបត្តិត្រឹមត្រូវតាមពុទ្ធប្បញ្ញត្តិពុទ្ធានុញ្ញាត និងអភិសមាចារ ។

- យកព្រះទ័យទុកដាក់ បង្រៀនណែនាំភិក្ខុគ្រប់រូបឱ្យចេះវិធីធ្វើសង្ឃកម្មនានា ចេះសំដែងភិក្ខុបាតិមោក្ខ និងចូលរួមធ្វើឧបោសថកម្ម បានទៀងទាត់តាមកាលកំណត់ក្នុងព្រះវិន័យ ។

- អប់រំណែនាំ ភិក្ខុសាមណេរ ដែលជ្រុលប្រព្រឹត្តខុសឆ្គង ចេះស្ម័យភ្ញាក់រលឹក កែលំអ ខ្លួនឯងដើរត្រូវតាមគន្លងពុទ្ធវិន័យវិញ ។

- ខិតខំអប់រំ ពុទ្ធបរិស័ទ ឱ្យចេះតាំងខ្លួនប្រកបដោយសទ្ធា និងបញ្ញា

ប្រតិបត្តិត្រឹមត្រូវតាមពុទ្ធឱវាទ លះបង់ជំនឿផ្តេសផ្តាស ប្រាសចាកគន្លងព្រះពុទ្ធសាសនាដោយគ្មានហេតុផល ហើយជ្រះថ្លាស្មោះស្ម័គ្រចូលរួមទ្រទ្រង់ ជាតិ សាសនា ព្រះមហាក្សត្រ ។

**២ ៖ ពង្រឹងគុណភាពដឹកនាំ :**

- បន្តពង្រឹងរចនាសម្ពន្ធមន្ត្រីសង្ឃ និងជំរុញការតែងតាំងមន្ត្រីសង្ឃពេញសិទ្ធិឱ្យឆាប់រហ័ស ។

- បំប៉នអំពីតួនាទី ភារកិច្ចបែបបទរដ្ឋបាល ដល់មន្ត្រីសង្ឃ គណៈកម្មការអាចារ្យវត្ត សំដៅគ្រប់គ្រងវត្តអារាម ធានាបានប្រសិទ្ធភាពខ្ពស់ ។

- ត្រូវចារបញ្ជាក់ថា បានសិក្ខ លើសង្ឃដីកា ឬឆាយា នៃបព្វជិតដែលបានលាចាកសិក្ខាបទទៅជាគ្រហស្ថវិញ ។

**៣ ៖ ពង្រឹងគុណភាពពុទ្ធិកសិក្សា :**

- ជំរុញការពង្រីង ពង្រីក ( កម្រង ) ប្រព័ន្ធ សាលាពុទ្ធិកបឋមសិក្សា សាលាធម្មវិន័យ និងមជ្ឈមណ្ឌលវិបស្សនា គ្រប់ស្រុក-ខ័ណ្ឌ ទូទាំងប្រទេស ។

- បន្តការពង្រឹងពង្រីកសហគមន៍សង្ឃ ទ្រទ្រង់ពុទ្ធិកសិក្សា និងពុទ្ធិកសង្គហកុមារ នៅតាមវត្តអារាម ។

- ខិតខំអប់រំកុមារ និងយុវជនកំព្រា ក្រីក្រ ដែលស្នាក់អាស្រ័យនៅក្នុងវត្តអារាម ឱ្យប្រកាន់ខ្ជាប់នូវសណ្តាប់ធ្នាប់ បញ្ចសីល និងចរិយាធម៌ ។

- មន្ត្រីសង្ឃគ្រប់ជាន់ថ្នាក់ មានព្រះគ្រូចៅអធិការជាដើម ទូទាំងប្រទេស ត្រូវធ្វើការបណ្តុះបណ្តាលបព្វជិត និងគ្រហស្ថ ដើម្បីឱ្យទៅជាគ្រូបង្គោល ពុទ្ធិកសង្គហកុមារ ។

**៤ . ព្រះសង្ឃនិងការបោះឆ្នោតគាំទ្រគណបក្សនយោបាយ :**

- ព្រះសង្ឃទាំងបច្ចុប្បន្ន ទាំងអនាគត ត្រូវប្រកាន់គោលជំហរអព្យាក្រឹត មិនចូលរួមបោះឆ្នោតគាំទ្រគណបក្សនយោបាយណាមួយឡើយ ប៉ុន្តែត្រូវរក្សាសិទ្ធិបោះឆ្នោតនេះនៅពេលអនាគត ដែលមានការចាំបាច់បំផុត ។

- ពិនិត្យរារាំងនូវគ្រប់រូបភាពអសកម្ម ដែលឆ្លៀតឱកាសយកព្រះសង្ឃ ឬព្រះពុទ្ធសាសនាទៅប្រើប្រាស់ខុសចាកគន្លងធម៌វិន័យ ។

- មិនអនុញ្ញាតឱ្យមានអន្តរសាសនាណាមួយ ដែលប្រព្រឹត្តប្រាសចាកប្រពៃណី ទំនៀមទម្លាប់ខ្មែរ ចូលមកក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ ។

**៥ . ការទាស់អធិករណ៍ :**

- មន្ត្រីសង្ឃគ្រប់លំដាប់ថ្នាក់ ត្រូវមានកម្មវិធីអប់រំភិក្ខុ សាមណេរ គណៈកម្មការអាចារ្យវត្ត ពង្រឹងសាមគ្គីភាពផ្ទៃក្នុង រារាំងគ្រប់រូបភាពអធិករណ៍ កុំឱ្យកើតមានក្នុងវត្តអារាម ។

- ប្រកាន់ជំហរម្ចាស់ការដោះស្រាយរាល់អធិករណ៍ ដែលជាសមត្ថកិច្ចខ្លួន ដោយប្រកាន់គោលការណ៍ សម្រុះសម្រួលផ្សះផ្សារជាកត្តាគន្លឹះ ។

**៦. ការទាស់អភិបាលកិច្ចសង្ឃ :**

- អភិបាលកិច្ចសង្ឃ ត្រូវចុះស្រាវជ្រាវរាល់បាតុភាព អធិករណ៍ ដែលកើតមានឡើងដោយសហការជាមួយមន្ត្រីសង្ឃ មន្ត្រីធម្មការមូលដ្ឋាន ។

- អភិបាលកិច្ចសង្ឃខេត្ត-ក្រុង គ្រប់លំដាប់ថ្នាក់ ត្រូវសហការជាមួយមន្ត្រីធម្មការ និងសាសនា រាល់ការដោះស្រាយអធិករណ៍ ។

**៧ . អបអរសាទរសន្និសីទកំពូលពុទ្ធសាសនាលើកទី ៣ :**

ចូលរួមអបអរសាទរដោយធ្វើសកម្មភាពជាក់ស្តែង :

- ព្រះមេគណ ឬអនុគណ ត្រូវណែនាំព្រះគ្រូចៅអធិការ ព្រះសង្ឃ ឱ្យរៀបចំវត្តអារាមឱ្យមានអនាម័យ និងដាំកូនឈើឱ្យមានសម្រស់បរិស្ថានធម្មជាតិ គួរជាទីជ្រះថ្លា គោរពបូជារបស់ពុទ្ធបរិស័ទ និងភ្ញៀវទេសចរទូទៅ ។

- ចំពោះវត្តអារាមដែលមានសម្បត្តិវប្បធម៌ ប្រាង្គប្រាសាទ បេតិកភណ្ឌជាតិ រមណីយដ្ឋាន និងតំបន់ទេសចរ ត្រូវខិតខំថែទាំយ៉ាងម៉ឺងម៉ាត់ ធានាបានទាំងរបៀបរៀបរយ ទាំងសុវត្ថិភាព ។

- មន្ត្រីសង្ឃគ្រប់លំដាប់ថ្នាក់ ព្រមទាំងព្រះធម្មកថិក ត្រូវទេសនា ជួយអប់រំបំបាត់អបាយមុខទាំងបីប្រការ (ល្បែង. ស្រា. ស្រី) ដើម្បីឱ្យប្រជាពលរដ្ឋ មានការភ្ញាក់រលឹកកាត់បន្ថយ ដោយស្វ័យប្រវត្តិ ។

សង្ឃប្រកាសនេះ ជាច្បាប់សម្រាប់អនុវត្តនៅគ្រប់វត្តអារាម ទូទាំងព្រះរាជាណាចក្រកម្ពុជា ។

រាល់លិខិតបទដ្ឋានណា ដែលផ្ទុយពីខ្លឹមសារ នៃសង្ឃប្រកាសនេះ ទុកជានិរាករណ៍ ។



ថ្ងៃ ១៣ កើត ខែពិសាខ ពុទ្ធសករាជ ២៥៤៦ ត្រូវនឹងថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០២ នៅវត្តមុនីប្រសិទ្ធិវង្ស មានរៀបចំពិធី ស្រោចស្រប់ព្រះសុគន្ធវារី តែងតាំង ព្រះវិន័យសំវរ **មួង រ៉ា** ព្រះរាជាគណៈចត្វា នៃគណៈមហានិកាយជា សម្តេចព្រះឧត្តមវង្សា ដោយព្រះរាជក្រឹត្យលេខ នស/រកត/០៣០២ របស់ ព្រះករុណាព្រះបាទ **នរោត្តម សីហនុ** ។

ចូលរួមជាអធិបតីក្នុងពិធីនោះមានៈ

- សម្តេចព្រះមហាសុមេធាធិបតី **ទេព វង្ស** ព្រះសង្ឃរាជគណៈមហានិកាយ
- សម្តេច **ហេង សំរិន** អនុប្រធានរដ្ឋសភា
- ឯកឧត្តម **ឈន អៀម** រដ្ឋលេខាធិការ ក្រសួងធម្មការ និងសាសនា ព្រមទាំងឯកឧត្តម លោកជំទាវ មន្ត្រីរាជការ, សិស្សគណ និងពុទ្ធបរិស័ទជាច្រើនរូបទៀត ។

# ព្រះរាជក្រឹត្យ

នស/រកត/០៣០២/

## យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

តែងតាំង

ព្រះវិន័យសំវរ មួង អ៊ំ

ព្រះរាជាគណៈចត្វា នៃគណៈមហានិកាយ

ជា

សម្តេចព្រះឧត្តមវង្សា

នរោត្តម សីហនុ

យោង : ចុតហ្មាយរបស់ព្រះមហាសុមេធាធិបតី សម្តេចព្រះសង្ឃរាជ

គណៈមហានិកាយ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០២ ។

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០២

ទំព័រឆ្លើយឆ្លងជាមួយកម្ពុជសុរិយា



## លិខិតថ្លែងអំណរគុណ

វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ លោក, លោកស្រី ជាសមាជិកឆ្លើយឆ្លង ដែលបានផ្ញើអត្ថបទស្រាវជ្រាវ ដ៏មានសារៈប្រយោជន៍ជាច្រើន មកតម្កល់ទុកជាឯកសារ សម្រាប់ការបោះពុម្ពផ្សាយ។ ទង្វើដ៏ប្រពៃនេះ បានបញ្ជាក់ច្បាស់ពីទឹកចិត្តស្រឡាញ់វប្បធម៌ ប្រពៃណីទំនៀមទម្លាប់ខ្មែរ និងរួមចំណែកថែរក្សាអត្តសញ្ញាណជាតិ ពិសេសទៅទៀតនោះ គឺជាគំរូដ៏ល្អសម្រាប់កូនខ្មែរជំនាន់ក្រោយ ។ យើងខ្ញុំសូមថ្លែងអំណរគុណជាពន្លឹក ជាថ្មីម្តងទៀត ដល់អស់លោក លោកស្រី ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ដើម្បីចូលរួមបន្តគាស់កកាយប្រមែប្រមូលនូវរឿងរ៉ាវប្រវត្តិសាស្ត្រ ទំនៀមទម្លាប់ប្រពៃណីខ្មែរនេះ ដែលបានកប់បាត់យ៉ាងជ្រៅជាច្រើនតំណ។ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យរង់ចាំទទួលដោយរីករាយ នូវអត្ថបទស្រាវជ្រាវថ្មីៗ ទៀត ។

# អត្ថបទដែលទទួលបានលើកទី២

| ល.រ | នាម និង គោត្តនាម | ខេត្ត-ក្រុង | ឈ្មោះអត្ថបទ |
|---|---|---|---|
| ១ | លោក ដាវ ហ៊ន | ព្រះវិហារ | - ប្រវត្តិភូមិព្រះហោះ<br>- ពិធីបុណ្យបូជាសពភូមិត្រាពាំងខ្វែង<br>- ពិធីហៅព្រលឹងភូមិសុច<br>- ពិធីឆាយជាន់ដែក |
| ២- | លោក ម៉ៅ សោភ័<br>លោក រស់ សំណាងណ | ពោធិសាត់ | - មុខរបរកាប់ខ្លឹមច័ន្ទន៍ក្រស្នា របស់អ្នកស្រុកជនជាតិព័រ និងបងប្អូនក្នុងទឹកដីខេត្តពោធិ៍សាត់ |
| ៣- | លោក ជួប ឃាន | ក្រចេះ | - ឈ្នួញទុច្ចរិតជីកគាស់បុរាណវត្ថុ |
| ៤- | លោក អុលសោភ័ណ្ឌ | កំពង់ចាម | - ប្រទាក់ស្នាព្រហ្ម (សូត្រមន្តរំដោះហគ្រោះ) |



*សកម្មភាពចុះស្រាវជ្រាវស្តីអំពី ស្លា មួ*

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ



លោក នូ កន ( ១៨៧៤ - ១៩៤៧ )


ឆ្នាំទី ៥៦ លេខ ៤ ខែ តុលា- វិច្ឆិកា - ធ្នូ

ព.ស. ២៥៤៦ គ.ស. ២០០២

ភ្នំពេញ

រូបក្រុបខាងក្រៅ : **ជីវប្រវត្តិសង្ខេប**

- *កវី* ***នូ កន*** *កើតនៅឆ្នាំ ១៨៧៤ នៅអង្គតាសោម ស្រុកត្រាំកក់ ខេត្ត តាកែវ ។*
- *មាតា នាម* ***នូ*** *បិតា នាម* ***អ៊ុក*** *ជាកសិករ*
- *អាយុ ៩ ឆ្នាំ បានទៅស្នាក់រៀននៅវត្តត្នោត*
- *អាយុ ១៤ ឆ្នាំ បួសជាសាមណេរបានមួយវស្សា*
- *អាយុ ១៧ ឆ្នាំ ចូលធ្វើស្មៀនចៅហ្វាយខេត្តទ្រាំង*
- *ឆ្នាំ ១៨៩១ បានចូលធ្វើការក្នុងក្រុមអាលក្ខណ៍ ក្នុងរាំងបួនឆ្នាំ ហើយនៅធ្វើការក្នុងក្រុមសុរិយោដី. រួចឃ្លាំងប្រាក់ ។*
- *ឆ្នាំ ១៩០២ ប្រឡងជាប់លេខ ១ ជាឡៃត្រេ រាជការបារាំងបានចាត់បន្តវិជ្ជាខាងច្បាប់នៅក្រុងប៉ារីស ។ លុះត្រឡប់មកវិញបានធ្វើជាចៅហ្វាយខេត្ត កំពង់សៀម ចាងហ្វាងសាលាឃុន សាលាឧទ្ធរណ៍ រួចជាភូឈួយ សេនាបតីក្រសួងក្សេត្រាធិការ ។*
- *ឆ្នាំ ១៩៤៥ ជាប់ឆ្នោតជាតំណាងរាស្ត្រ មណ្ឌលកោះសូទិន*
- *ទទួលអនិច្ចកម្មនៅឆ្នាំ ១៩៤៧ នៅលំនៅឋាន ក្រុងកំពង់ចាម ។*

## ស្នាដៃ

*១- រឿង សាមកុក (រឿងប្រែ) ២- រឿង ពិម្ពានិព្វាន (ពាក្យកាព្យ) ៣- រឿង ទាវឯក (ពាក្យកាព្យ) ៤- រឿង តុង ឈិន (ប្រលោមលោកពាក្យរាយ) ៥- រឿង សមុទ្ទជេដ្ឋា (ប្រលោមលោកពាក្យរាយ) ៦- រឿង មហាសុបស្សីតាបស (មិនទាន់បោះពុម្ព) ៧- រឿង គណាវ (មិនទាន់បោះពុម្ព) ។*

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ

ចេញរាល់ត្រីមាស ពីវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

ចាត់ចែងបោះពុម្ពផ្សាយដោយគណៈកម្មការមួយ មាន :

នាយកការផ្សាយ : ខួន វ៉ាន់ចន្ធី

និពន្ធនាយក : ខៀវ បញ្ញាវុឌ្ឍ

គណៈកម្មការនិពន្ធ

លោកបណ្ឌិតទស្សនវិជ្ជា ឆយ យីហ៊ាង លោក ម៉ែន ប្រាង

លោក វង់ សុធារ៉ា លោក ឆន់ ហ៊ិន.

លោក មឿច ប៊ុណ្ណ លោក ពិ ប៊ុន្នីន

គណៈកម្មការពិគ្រោះយោបល់

- លោកព្រឹទ្ធាចារ្យ **ឆេង ផុន** ប្រធានមជ្ឈមណ្ឌលវប្បធម៌ និងវិបស្សនា
- ឯកឧត្តម **នុត ណារ៉ាង** ប្រធានមជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ
- ឯកឧត្តម **ជា សាវឿន** រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា
- ឯកឧត្តម **ឈន អឿម** រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា
- លោកបណ្ឌិតសាស្ត្រាចារ្យ **ឡុង សៀម** នាយកវិជ្ជាស្ថានជាតិខាងភាសា
- លោកបណ្ឌិតទស្សនវិជ្ជា **ឆយ យីហ៊ាង** ទីប្រឹក្សារាជរដ្ឋាភិបាល ទទួលបន្ទុកការងារអប់រំ, ព្រឹទ្ធបុរសដេប៉ាតឺម៉ង់ទស្សនវិជ្ជា និងក្រុមការងាររាជបណ្ឌិតសភាកម្ពុជា
- លោកបណ្ឌិត **នេត បារ៉ុម** សកលវិទ្យាធិការរង នៃសកលវិទ្យាល័យភូមិន្ទភ្នំពេញ ។

---


- បោះពុម្ពផ្សាយដោយប្រើថវិកាបានពីការលក់សៀវភៅនានា ដែលក្រុមប្រឹក្សាពិភពលោកដើម្បីសាសនា និងសន្តិភាព ( WCRP ) នៃប្រទេសជប៉ុន បានឧបត្ថម្ភ។
- **The puplication of this issue has been made possible by the fund earned the sale of books supported by the WCRP/Japan.**

# មាតិកាអត្ថបទ

## I. អក្សរសិល្ប៍ពុទ្ធសាសនា :


- ជីវិតមនុស្ស និងបញ្ហា (ត) .................... (ឈន អៀម) ១


## II. អក្សរសាស្ត្រទូទៅ និង អក្សរសិល្ប៍ខ្មែរ :


- ទស្សនៈជីវិត........................( ព្រឹទ្ធាចារ្យ ឆេង ផុន ) ១៤
- សីលធម៌ វិជ្ជាជីវៈរបស់គ្រូបង្រៀន ........... (ឆយ យីហ៊ាង) ១៩
- ការរីកចម្រើន នៃព្រះពុទ្ធសាសនា (ត) ...........(ខ្ជួត ធីតា ) ៣០
- ប្រវត្តិរបាំក្បាច់បុរាណ.....................(ពេជ្រ ទុំក្រវិល) ៣៦
- ប្រវត្តិប្រាសាទក្រហម ...........................(សុខ ចេង) ៤៥
- មុខរបរកាប់ខ្លឹមចន្ទន៍ក្រស្នា.................... (ម៉ៅ សោភ័ណ) ៥៦
- ការព្យាបាលពិសពស់វែក.......................(មៀច ប៉ុណ្ណ ) ៦៩
- ឱសថបុរាណខ្មែរ ....(ត)................ (សួន ឱសថ ) ៧៣
- កំណាព្យ "មិនមែន" ........................(ខៀវ យ៉ុន) ៧៦


## III. កំណត់ និងប្រវត្តិការណ៍ :


- សន្និសីទកំពូលព្រះពុទ្ធសាសនាពិភពលោកលើកទី ៣ ........... ៧៨
- ព្រះរាជសុន្ទរកថា ................................. ៨៣
- ប្រវត្តិព្រះសក្យមុនីចេតិយ ............................. ៨៧


## IV. ទំព័រឆ្លើយឆ្លងជាមួយកម្ពុជសុរិយា


- លិខិតរបស់លោក ខៀវ យ៉ុន ......................... ៩៤

# ជីវិតមនុស្ស និង បញ្ហា (ត)

បណ្ឌិត ក. ស្រី ធម្មានន្ទ
បកប្រែ ៖ ឈន អៀម

## ការទទួលខុសត្រូវរបស់ឪពុក-ម្តាយក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូនរបស់ខ្លួន

ភាពជាឪពុកម្តាយ គឺមិនដូចជាការងារធម្មតាក្នុងការិយាល័យទេ ។ វាជាការងារគ្មានទីបញ្ចប់ ហើយមិនដែលមានពេលគ្រប់គ្រាន់ ដើម្បីធ្វើការងារឱ្យបានសព្វគ្រប់ទេ ។ មិនគិតថាកូនរបស់លោកអ្នកមានអាយុប៉ុន្មាន, ទើបកើត ឬនៅបៅដោះទេ, វាមិនយូរពេកទេ ដើម្បីដាក់ទារករបស់លោកអ្នកក្នុងអាទិភាពទីមួយ ហើយក្រេបសេចក្តីសប្បាយក្នុងឋានៈជាម្តាយ ឬឪពុក ។ ឪពុកម្តាយជាច្រើនគិតថាមានតែខ្លួនគាត់ប៉ុណ្ណោះ ដឹងថាអ្វីល្អប្រសើរសម្រាប់កូន ហើយដោយហេតុនេះគេមានសេចក្តីសង្ឃឹមចង់បានច្រើនពេកអំពីកូន។ ឪពុកម្តាយទាំងនោះ បង្ខំឱ្យកូនរបស់ខ្លួនទៅរៀន បើទោះបីកូននោះ មិនអាចទទួលការសិក្សាបានក្តី។ នៅពេលជាមួយគ្នា, គេឱ្យកូននោះរៀនរាំរបាំបាឡេ (ក្នុងករណីជាកូនស្រី), រៀនគាយក្វាន់ដូ (ក្នុងករណីជាកូនប្រុស), រៀនភ្លេង, រៀនវិជ្ជាកុំព្យូទ័រ-ល- ។ នៅពីលើកិច្ចការនេះ គេទទូចឱ្យកូនរបស់គេរៀនឱ្យបានពិន្ទុ "A" ក្នុងការប្រឡងរបស់កូន ហើយពូកែឈ្នះគេក្នុងមុខវិជ្ជាទាំងអស់ ។ ក្នុងការប្រណាំងប្រជែងប្តូរផ្តាច់នេះ, គេប្រែក្លាយកូនរបស់គេទៅជាវត្ថុតាំងបង្ហូត, ជាសម្បត្តិទ្រព្យដែលគេមានមោទនភាព ដើម្បីបង្អួត

មិត្រភក្តិរបស់គេ ព្រមទាំងញាតិសន្តាន និងដើម្បីឱ្យអ្នកដទៃនិយាយសរសើរ។

ក្នុងសម័យពីដើម, ជីវិតជាកូនក្មេង និងជាអនីតិជន មិនដែលមាន "ស្ត្រេស" (Tress) ទេ, ពីព្រោះមិនសូវមានសេចក្តីសង្ឃឹមចង់បាន (Expections) ច្រើនពេកដើម្បីបំពេញឡើយ។ ប៉ុន្តែ កុមារសព្វថ្ងៃនេះ, ជាពិសេសកុមារនៅក្នុងតំបន់ទីក្រុង ហាក់ដូចជាមានការងារច្រើនណាស់ត្រូវធ្វើ ហើយប្រណាំងប្រជែងក្នុងន័យដែលកុមារភាពធម្មតារបស់គេត្រូវបាត់បង់។ មនុស្សច្រើនណាស់មិនបានយល់ ដឹងរឿងនេះទេ ក្នុងឋានៈខ្លួនជាឪពុកម្តាយ, ពួកគេមានសិទ្ធិមួយចំនួន ហើយក៏មានការទទួលខុសត្រូវផងដែរ។ កុមារ (ឬក្មេង) ក៏មានសិទ្ធិទទួលខុសត្រូវរបស់ខ្លួនដែរ។ អ្វីដែលយើងមានសព្វថ្ងៃ គឺមនុស្សដែលប្រាថ្នាតាំងខ្លួនជាឪពុក-ម្តាយអស្ចារ្យ (super parents) ប៉ុន្តែក្នុងករណីជាច្រើន កូនមិនបានប្រែក្លាយទៅជាកូនអស្ចារ្យផងទេ។ ដោយហេតុនេះ ឪពុក-ម្តាយ គប្បីជាមនុស្សប្រាកដនិយម និងមានវិចារណញ្ញាណ ត្រិះរិះរកហេតុផល។ គេមិនគប្បីផ្តោតគោលដៅដែលគេដឹងច្បាស់ថា កូនរបស់គេមិនអាចទៅដល់, ដូច្នេះត្រូវចៀសវាងកុំឱ្យមានស្ត្រេស និងការខកចិត្តដ៏មិនចាំបាច់ដល់គ្រួសារ។ ការកសាងគ្រួសារមានសុភមង្គលមួយ គឺជាអភិក្រមបន្ត។

ដូច្នេះ ឪពុកម្តាយ មិនត្រូវយល់ដឹងពេញលេញតែពីនាទី និងការទទួលខុសត្រូវរបស់ខ្លួនប៉ុណ្ណោះទេ, ប៉ុន្តែត្រូវអនុវត្តបច្ចេកទេសសម័យថ្មី ក្នុងការគ្រប់គ្រងកូនឱ្យបានត្រឹមត្រូវផងដែរ។ ចូរចងចាំសុភាសិតរបស់ទស្សនវិទូនៃលទ្ធិតាវ (The Taoist philosopher) គឺលោក ហ្សាង ហ្ស៊ូ (Zhuang Zu) ថា "បើអ្នកមានម្រាមប្រាំមួយ ចូរកុំខិតខំធ្វើវាឱ្យនៅប្រាំ, ហើយបើអ្នកមានម្រាមប្រាំ, ចូរកុំសាកល្បងធ្វើ

វាឱ្យមានប្រាំមួយ ។ ចូរកុំប្រឆាំងធម្មជាតិ ” ។

លោកអ្នកមានបន្ទុកទទួលខុសត្រូវក្នុង ឋានៈជាឪពុក-ម្ដាយ ដែលមានសេចក្ដីជាប់ជំពាក់ ដើម្បីសុខមាលភាព និងការចិញ្ចឹមបីបាច់កូនរបស់លោកអ្នក។ ប្រសិនបើកុមារចម្រើនវ័យធំឡើងទៅជាពលរដ្ឋម្នាក់ មានកម្លាំងមាំមួន មានសុខភាពល្អ និងមានប្រយោជន៍ដល់សង្គម. នោះគឺជាលទ្ធផលនៃសេចក្ដីខិតខំរបស់លោកអ្នក។ ប្រសិនបើកុមារចម្រើនវ័យធំឡើងទៅជាមនុស្សអាវ៉ាសែម្នាក់. នោះគឺលោកអ្នកដែលត្រូវទទួលខុសត្រូវ។ ចូរកុំបន្ទោសអ្នកឯទៀត។ ក្នុងឋានៈជាឪពុក-ម្ដាយ. ការងារនេះ. គឺជាករណីកិច្ចផ្ទាល់របស់លោកអ្នក ដើម្បីនែនាំកូនរបស់លោក-អ្នកឱ្យដើរនៅលើមាគ៌ាល្អត្រឹមត្រូវ។ ទោះបីមានករណីមួយចំនួនតិច នៃយុវវ័យអាវ៉ាសែ មិនអាចកែប្រែបាន. ប៉ុន្តែក្នុងឋានៈជាឪពុក-ម្ដាយ. លោក-អ្នកនៅតែមានបន្ទុកទទួលខុសត្រូវខាងផ្លូវសីលធម៌ ចំពោះចរិយារបស់កូនលោក-អ្នកដែរ។

ការឧបត្ថម្ភ និងការត្រួតមើលរបស់ឪពុក-ម្ដាយ ត្រូវបានកែតម្រូវនៅពេលកូនចម្រើនវ័យធំឡើង។ គោលដៅចុងក្រោយនៃការគ្រប់គ្រងជាឪពុក-ម្ដាយត្រូវប្រែក្លាយជាមិត្តម្នាក់ចំពោះកូន ប៉ុន្តែ ឱ្យស្របទៅនឹងសមត្ថភាពរបស់វាទទួលយកការទទួលខុសត្រូវបានប៉ុណ្ណោះ។ កំហុសមួយ ដែលឪពុក-ម្ដាយ ខ្លះបានប្រព្រឹត្តគឺគេចង់ធ្វើខ្លួនជាមិត្តម្នាក់ចំពោះកូនមានអាយុប្រាំមួយឆ្នាំ។ ប៉ុន្តែ យើងត្រូវការប្រុងប្រយ័ត្នចំពោះអ្វីដែលយើងសំដៅន័យថា មិត្ត។ យើងប្រាកដជាមិនសំដៅន័យថា យើងទុកដាក់កូនម្នាក់ហាក់ដូចជាមនុស្សស្មើគ្នា មានគំនិតចាស់ទុំទេ។ ប៉ុន្តែ គេត្រូវមានសេចក្ដីស្រឡាញ់ ទំនុកចិត្ត និងសេចក្ដីគោរព។ នៅវ័យប៉ុណ្ណោះ, ក្មេងត្រូវ

ការឪពុក-ម្តាយ (ជាអាណាព្យាបាល) មិនត្រូវការមិត្តទេ។ នៅពេលកំពុងកសាងទំនាក់ទំនងសេចក្តីស្រឡាញ់ និងការឧបត្ថម្ភជាមួយកូន១, គេបានតម្រូវឱ្យឪពុក-ម្តាយ ជួយឧបត្ថម្ភកូន១ ឱ្យរីកចម្រើនខាងស្មារតីផងដែរ។

ជាងនេះទៀត លោកអ្នកត្រូវមានពេលសម្រាប់កូនរបស់លោកអ្នក។ ពេលវេលាសម្រាប់ឆ្លើយសំនួររបស់កូន, ជួយឱ្យកូនយល់នូវអច្ឆរិយភាពនៃជីវិត។ លោកអ្នកត្រូវចងចាំក្នុងចិត្តថា លោកអ្នកកំពុងខ្ទប់ដង្ហើមនៃប្រឌិតញាណ (creati vity) ក្នុងចិត្តរបស់កូនលោកអ្នកហើយ, កាលណាលោកអ្នកមិនឆ្លើយតបសំនួរដែលកូនលោកអ្នកកំពុងចោទសួរទេ។ កាលណាក្មេងម្នាក់កំពុងសាកសួរ, តាមពិតវាកំពុងស្វែងរកការឆ្លើយឆ្លង, ដូច្នេះបញ្ហាធំបំផុតកំពុងប្រឈមលោកអ្នក គឺត្រូវឆ្លើយយ៉ាងប្រញាប់ ប្រកបដោយសេចក្តីស្រឡាញ់ ហើយអ្វីទាំងអស់ដែលលោកអ្នក ត្រូវធ្វើគប្បីឱ្យស្របគ្នាជាមួយនឹងចំណង់ចង់ដឹង ចង់ឮ តាមធម្មជាតិនៅក្នុងខ្លួនក្មេង។

ភាពជាអ្នកឆ្លើយតបបានភ្លាម១ គឺមានសារសំខាន់ផងដែរក្នុងការធ្វើឱ្យកូន១ ជាប់ជំពាក់ក្នុងរឿង ហើយអ្នកវិទ្យាសាស្ត្រពូកែ១ បំផុតត្រូវបានគេដឹង ថាជាមនុស្សឆ្លើយតបភ្លាម១ ទៅនឹងសំនួរ។ ប្រសិនបើឪពុក-ម្តាយ មិនដឹងចម្លើយចំពោះសំនួរទេ, គេត្រូវកត់ត្រាចំណាំទុក ដើម្បីរកឱ្យឃើញចម្លើយសម្រាប់កូន១របស់គេជាជំនួសការរលាស់ដៃចោលសំនួរទាំងនោះ ហើយនិយាយប្រាប់កូន១ ថាខ្លួនជាប់រវល់ពេកណាស់, ឬថាវាគ្មានសារសំខាន់អ្វីទេ, ដូច្នេះត្រូវបំបិទមាត់កូន១ទាំងនោះ ហើយរាំងខ្ទប់ការចង់ដឹង ចង់យល់របស់ពួកវា។ លោកអ្នកមានអារម្មណ៍ថា បានប្រព្រឹត្តកំហុសចំពោះការនិយាយប្រាប់កូន១ របស់លោកអ្នក ក្នុងអំឡុងវ័យក្មេងខ្ចី កំពុងចង់ចេះ ចង់ដឹងបំផុត ថា " ចូរកុំសួរច្រើនពេក ! " ។ ក្នុងឋានៈជា

អាណាព្យាបាល និងជាអ្នកទទួលខុសត្រូវម្នាក់. តាមពិតលោកអ្នកគប្បីឆ្លើយតប ដោយភាក់ទាក់ចំពោះចំណង់ចង់ដឹង ចង់ស្គាល់ ជាធម្មជាតិរបស់កូនលោកអ្នក ។

បែបបទវិទ្យាសាស្ត្រ ដើម្បីដោះស្រាយបញ្ហាមួយ គឺត្រូវក្រឡេកមើលបញ្ហា រកឱ្យឃើញទិន្នន័យដែលមាន ហើយបន្ទាប់មកប្រមូលផ្តុំដំណោះស្រាយក្នុងបែបបទមួយទាក់ទងគ្នារលូន។ ធ្វើយ៉ាងដូច្នេះ, ក្មេងដែលមានចំណង់ចង់ដឹង ចង់យល់ នោះនឹងបានទទួលចម្លើយប្រកបដោយភាពអនុគ្រោះនឹងចេះត្រិះរិះ ហើយធ្វើអំពើប្រកបដោយវិទ្យាសាស្ត្រ និងប្រកបដោយប្រឱតញ្ញាណ, ហើយផ្តត់គំនិតនេះនឹងបំរើគេបានល្អ ដល់ពេលគេក្លាយទៅជាមនុស្សពេញវ័យ ។

ជាឧទាហរណ៍, កាលណាលោកអ្នកឱ្យរបស់លេងមួយទៅកូនរបស់លោកអ្នក, លោកអ្នកគប្បីឱ្យរបស់នោះ ប្រកបដោយសេចក្តីស្រឡាញ់ និងសេចក្តីសប្បាយ។ ជាជំនួសអាកប្បកិរិយានេះ, មានឪពុក-ម្តាយខ្លះ មានទំនោរនិយាយទៅរកស្ទើរតែស្រែកគំហកថា: " កុំបើកវាដូចនោះ។ កុំឱ្យបែកបាក់របស់លេង, វាថ្លៃណាស់។ តើឯងដឹងទេថា ឯងមានសំណាងយ៉ាងណាទើបបានរបស់លេងបែបហ្នឹង ? " តើវាយ៉ាងម៉េច ប្រសិនបើកូននោះ បានធ្វើបាក់បែករបស់លេងប្រាកដមែន ? ប្រសិនបើលោកអ្នកអាចមានប្រាក់ទិញរបស់លេងបាន, កូនមុខជានឹងគិតយ៉ាងសមហេតុ-ផលថា វាអាចមានលទ្ធភាពធ្វើឱ្យរបស់លេងបាក់បាន។

ជាជំនួសវិញ លោក-អ្នកអាចរួម ជាចំណែកនៃការរកឃើញរបស់វា ដោយប្រាប់វាថា " មកនេះ កូនសម្លាញ់, ចូរយើងបើកប្រអប់ប្រដាប់លេងជាមួយគ្នា ហើយប្រើពាក្យកំប្លែង ជាជំនួសពាក្យអវិជ្ជមាន។ ចូរឱ្យរង្វាន់ ឬជំនូនប្រកបដោយសេចក្តីសប្បាយ និងសេចក្តីស្រឡាញ់។ លោក-អ្នកអាចធ្វើបាន ប្រសិនបើលោកអ្នក

គ្មានសេចក្តីកង្វល់ និងមានសេចក្តីសប្បាយខ្លួនឯងស្រាប់។ លោកអ្នកត្រូវតែមានចិត្តសប្បាយ ពិព្រោះមានតែឋិតក្នុងស្ថានភាពនៃសុភមង្គលប៉ុណ្ណោះ ទើបគេអាចមានសេចក្តីសុខស្រួល និងសប្បុរសបាន។

មានពេលខ្លះ, ឪពុក-ម្តាយ ត្រូវបានគេស្តីបន្ទោសចំពោះការចម្លងទម្លាប់សង្គមអាក្រក់ដោយមិនដឹងខ្លួនទៅឱ្យកូនរបស់ខ្លួន។ យកជាឧទាហរណ៍, ឪពុក ឬម្តាយម្នាក់ ដែលប្រាប់ឱ្យកូននិយាយថា ឪពុក ឬម្តាយរបស់ខ្លួនមិននៅផ្ទះទេ ក្នុងពេលឆ្លើយតបការហៅតាមទូរស័ព្ទ (ជាអំពើហាក់ដូចជាគ្មានទោស)។ ឪពុក ឬម្តាយនោះបណ្តុះគ្រាប់ពូជកុហក (មុសាវាទ) ដំបូងនៅក្នុងសន្តានចិត្តទន់ខ្ចីរបស់ក្មេង។ ប្រសិនបើអនុញ្ញាតឱ្យរីកស្គុះស្គាយនៅក្នុងបរិដ្ឋានមួយ ដែលមិននាំទៅរកការលើកស្ទួយតម្លៃមនុស្សទេ, កូនក្មេងអាចក្លាយក្នុងពេលអនាគត ទៅជាធាតុបំផ្លិចបំផ្លាញមួយចំពោះសន្តិភាព, សុភមង្គល និងសុខមាលភាព នៃគ្រួសារ និងសង្គម ហើយសំខាន់ជាងនេះទៀត, ចំពោះខ្លួនឯងផ្ទាល់។

ឪពុកម្តាយ និងចាស់ទុំជាច្រើនសព្វថ្ងៃនេះ ត្រូវទទួលខុសត្រូវចំពោះការដាំបណ្តុះគ្រាប់ពូជមុសាវាទ ក្នុងបែបបទផ្សេងៗគ្នាជាច្រើន។ ពួកគេ ឬមួយបានលើកទឹកចិត្តមុសាវាទដោយផ្ទាល់, ឬមួយដោយការប្រព្រឹត្ត ឬនិយាយកុហកដែលបានផ្តួចផ្តើម និងអនុញ្ញាតឱ្យវង្វង់អកុសល (The vicious cycle) នៃការបន្ថយតម្លៃមនុស្សបានរីកចម្រើន។ វាសនារបស់កូនយើង អាចពឹងផ្អែកយ៉ាងច្រើនលើឪពុកម្តាយ និងមនុស្សចាស់ទុំ ជួយអភិវឌ្ឍអាកប្បកិរិយាត្រឹមត្រូវចំពោះសច្ចភាពបំពាក់បំប៉នដោយសីលធម៌ និងការរស់នៅប្រកបដោយសច្ចធម៌។

កុមារៗ រមែងបន្ទរតាមភាសារបស់ឪពុកម្តាយវា។ ដើម្បីបញ្ចៀសការ

ប្រើពាក្យគ្រោតគ្រាត ឬច្រងេងច្រងាង. ឪពុកម្តាយប្រកបដោយការទទួលខុសត្រូវខ្ពស់ គប្បីប្រើពាក្យសំដីផ្អែមល្ហែម ពិព្រោះកុមារទាំងឡាយជាទូទៅតែងចង់ត្រាប់តាមឪពុកម្តាយរបស់គេ។

កូនក្មេងនៅវ័យងាយទទួលអារម្មណ៍រំភើបបំផុត រមែងត្រូវការសេចក្តីស្រឡាញ់, ការថែទាំ, សេចក្តីថ្នាក់ថ្នម និងការយកចិត្តទុកដាក់អំពីឪពុកម្តាយ។ បើគ្មានសេចក្តីស្រឡាញ់ និងការណែនាំរបស់ឪពុកម្តាយទេ, កូននឹងទៅជាពិការខាងអារម្មណ៍ ហើយនឹងមើលឃើញពិភពលោកជាទីកន្លែងធុញថប់ ពិបាករស់នៅ។ ការស្រោចស្រពសេចក្តីស្រឡាញ់របស់ឪពុកម្តាយមួយចំណែក មិនមានន័យថាតម្រូវចិត្តគ្រប់សំណូមពររបស់កូនទេ. ទោះជាសំណូមពរសមហេតុផលក្តី ឬផ្សេងក្តី។ ការថ្នាក់ថ្នមខ្លាំងពេក តាមពិតទៅនឹងធ្វើឱ្យក្មេងខូច។ ម្តាយក្នុងពេលផ្តល់សេចក្តីស្រឡាញ់ និងការគាំពាររបស់ខ្លួន គប្បីជាអ្នកម៉ត់ចត់ និងម៉ឺងមាត់ផងដែរ. ប៉ុន្តែមិនត្រូវរឹងរូសក្នុងការគ្រប់គ្រងកូនទេ។ ចូរបង្ហាញសេចក្តីស្រឡាញ់របស់លោក-អ្នក ដោយកណ្តាប់ដៃមានវិន័យ-កូននឹងយល់អាកប្បកិរិយានេះ។

ឪពុកម្តាយគប្បីចំណាយពេលឱ្យច្រើនជាមួយកូនរបស់ខ្លួន ពង្រឹងគុណធម៌, ជាពិសេសក្នុងអំឡុងឆ្នាំកសាងខ្លួនរបស់គេ (formative years)។ គេត្រូវពិចារណាដើម្បីផ្តល់ឱ្យកូននូវអំណោយនៃការចិញ្ចឹមបីបាច់ជាឪពុកម្តាយល្អ ជាជំនួសអំណោយស្រោចស្រពមកលើកូន ដោយវង្វាន់ជាសម្ភារៈ ។ អំណោយនេះរួមមានការកសាងជំនឿទុកចិត្តលើខ្លួនឯង, ការព្យាយាមនិយាយឆ្លើយឆ្លងជាវិជ្ជមាន (គឺជាពាក្យសំដីពិរោះស្តាប់), ការផ្តល់សេចក្តីស្រលាញ់ឥតល័ក្ខខ័ណ្ឌ, និងការលុបបំបាត់ទិដ្ឋភាពទាំងឡាយរាំងស្កាត់ ការរីកចម្រើនផ្លូវចិត្តរបស់កូន ។ ទាំងអស់នេះគឺជា

អំណោយប្រកបដោយន័យពិត និងស៊ីជម្រៅ ។ ការចិញ្ចឹមបីបាច់ជាឪពុកម្ដាយល្អ (healthy parenting) គឺជាអំណោយថ្លៃថ្លាបំផុត ដែលកូនអាចទទួលយកបាន ហើយឪពុកឬម្ដាយក៏អាចផ្ដល់ឱ្យបាន ។

ជាអកុសល. ក្នុងចំណោមឪពុកម្ដាយសព្វថ្ងៃ. សេចក្ដីស្រលាញ់របស់ឪពុក-ម្ដាយ កំពុងបាត់បង់គួរឱ្យស្ដាយ។ សន្ទុះដ៏ឆ្កួតលេលា ដើម្បីល្បឿនខាងសម្ភារៈ. ចលនាសេរីការ និងចំណង់ប្រាថ្នាដើម្បីសមភាពក្នុងចំណោមភេទ ទាំងអស់នេះ បានផ្ដល់លទ្ធផលឱ្យម្ដាយជាច្រើនរួមដៃជាមួយប្ដីរបស់គេ ចំណាយពេលម៉ោងធ្វើការរបស់គេក្នុងការិយាល័យ និងក្នុងហាងលក់ទំនិញ. ជាជាងចំណាយពេលម៉ោងសេសសល់នៅផ្ទះ ហើយថ្នាក់ថ្នមកូនៗរបស់គេ ។ កូនៗ ត្រូវបានគេទុកចោលឱ្យបងប្អូន. មណ្ឌលថែទាំពេលថ្ងៃ. ឬឈ្នួលបំរើថែទាំជំនួស ។ កូនៗ ទុញទាល់គំនិតចំពោះការខ្វះសេចក្ដីស្រលាញ់ និងការថែទាំថ្នាក់ថ្នមរបស់ម្ដាយ ។

ការផ្ដល់ឱ្យកូននូវរបស់លេងទាន់សម័យគ្រប់យ៉ាង (ទុកជាទ្រង់ទ្រាយមួយនៃសេចក្ដីស្ងប់រម្ងាប់ចិត្ត) ដូចជារថក្រោះ. កាំភ្លើងយន្ត. ឬដាវដែលបង្ខូចដល់កំណាកំណើតចរិយា មិនត្រូវបានគេទូន្មានឱ្យធ្វើទេ យោងតាមចិត្តវិជ្ជា ។ ការផ្ដល់ឱ្យសន្ធឹកសន្ធាប់ដល់កូន នូវរបស់លេងទាំងនេះ មិនអាចជំនួសសេចក្ដីស្រលាញ់ និងសេចក្ដីថ្នាក់ថ្នមដ៏ស្រទន់របស់ម្ដាយបានទេ. ជាលទ្ធផល. កូនត្រូវបានគេបង្រៀនដោយល្ងិតល្ងង់ ឱ្យចេះអត់អោនការឈ្លានពាន និងការបំផ្លិចបំផ្លាញ ជាជំនួសការបង្រៀនឱ្យកូនមានចិត្តសប្បុរស. មានមត្តាធម៌ និងចេះជួយទុក្ខធុរៈអ្នកដទៃ ។ កូន (ទទួលការអប់រំ) បែបនេះ នឹងបង្កើនទំនោរទៅរកភាពកម្រោល ដល់ពេលគេធំឡើង ។ ដោយខ្វះការថ្នាក់ថ្នម និងការទូន្មានណែនាំរបស់ឪពុកតម្ដាយ. គេនឹង

មិនងឿងឆ្ងល់ទេ ប្រសិនបើក្រោយមក កូនធំឡើងប្រែក្លាយទៅជាក្មេងអាវ៉ាសែ ។ ដូច្នេះ តើអ្នកណាត្រូវទទួលការស្តីបន្ទោស ចំពោះការចិញ្ចឹមបីបាច់កូន ខឹលខូច ម្នាក់នេះ ? គឺឪពុកម្តាយ ដោយពិតប្រាកដ !

ម្តាយជាអ្នកធ្វើការ, ជាពិសេសក្រោយពេលធ្វើការប្រចាំថ្ងៃយ៉ាងនឿយហត់នៅក្នុងការិយាល័យ, ជាមួយនឹងការងារប្រចាំថ្ងៃនៅផ្ទះទៀត អាចមានពេលតិចតួចណាស់សម្រាប់កូន ដែលកំពុងច្រហមាត់ចាំទទួលសេចក្តីថែទាំ និងការយកចិត្តទុកដាក់របស់ម្តាយ ។ ឪពុកម្តាយ ដែលមិនមានពេលសម្រាប់កូនៗ របស់ខ្លួននាពេលឥឡូវនេះ មិនគប្បីត្អូញត្អែរទេ នៅពេលក្រោយមកក្នុងជីវិតនេះ កាលណាកូនៗដដែលទាំងនោះ គ្មានពេលសម្រាប់ថែទាំខ្លួនឯងជាឪពុកម្តាយវិញ។ ឪពុកម្តាយដែលប្រកាសថាគេបានចំណាយប្រាក់ច្រើនណាស់ទៅលើកូនរបស់គេ ប៉ុន្តែជាប់រវល់ខ្លាំងពេក មិនគប្បីត្អូញត្អែរទេ កាលណាក្នុងការរស់នៅក្រោយមក កូនៗ"ដ៏ជាប់រវល់"របស់ខ្លួន ដល់វេនសម្រេចចិត្តទុកចោលឪពុកម្តាយទាំងនោះវិញ នៅក្នុង *មណ្ឌលសម្រាប់មនុស្សចាស់ជរា !*

ស្ត្រីភាគច្រើនចេញធ្វើការនាពេលបច្ចុប្បន្ននេះ ដើម្បីឱ្យគ្រួសារ អាចទទួលបានសេចក្តីសប្បាយអំពីអត្ថប្រយោជន៍សម្ភារៈកាន់តែច្រើនឡើង ។ ស្ត្រីទាំងនោះគប្បីពិចារណាដោយម៉ឺងម៉ាត់ នូវដំបូន្មានរបស់លោក គន្ទី សម្រាប់បុរសឱ្យស្វែងរកសេរីភាពផុតពីលោភៈ ជាជាងសេរីភាពផុតពីសេចក្តីត្រូវការ ។ ពិតមែនហើយ, បើពិនិត្យមើលរចនាសម្ព័ន្ធចាត់តាំងសេដ្ឋកិច្ចនាពេលបច្ចុប្បន្ន យើងមិនអាចប្រកែកបានទេថា មាតាមួយចំនួនត្រូវបានបង្ខំចិត្តចេញធ្វើការ ។ ក្នុងករណីនេះ, ឪពុកនិងម្តាយ ត្រូវធ្វើពលិកម្មបន្ថែមលៃទុកពេលវេលារបស់ខ្លួន ដើម្បីប៉ះប៉ូវសម្រាប់អ្វី

ដែលកូន១របស់គេខ្វះ នៅពេលដែលឪពុកម្តាយទាំងនោះមិននៅផ្ទះ ។ ប្រសិនបើឪពុកម្តាយទាំងពីរនាក់ ចំណាយពេលម៉ោងមិនធ្វើការរបស់ខ្លួន នៅផ្ទះជាមួយកូន១របស់ខ្លួន, នោះនឹងមានសុខដុមភាព និងការយោគយល់គ្នារវាងឪពុកម្តាយ និងកូន១។ យើងហៅស្ថានភាពនេះថា "ពេលពង្រឹងគុណធម៌" (quality time) ជាមួយគ្រួសារ ។

កូន១ ដែលទុកដាក់ឱ្យនៅក្រោមការថែទាំរបស់ញាតិ, មណ្ឌលថែទាំពេលថ្ងៃ, ឬឈ្នួលបម្រើ, ក៏ដូចជាកូន១ ដែលទៅរៀនហើយមានសោចូលផ្ទះដោយខ្លួនឯង, ជាញឹកញយណាស់មិនបានក្រេបរសជាតិនៃសេចក្តីស្រលាញ់ និងការថែទាំរបស់ម្តាយទេ។ ម្តាយមានអារម្មណ៍ថាបានប្រព្រឹត្តកំហុស ពិព្រោះខ្វះការយកចិត្តទុកដាក់នេះ, ហើយតែងខិតខំធ្វើការឱ្យកូនស្ងប់ចិត្ត ដោយសុខចិត្តធ្វើតាមការទាមទារគ្រប់យ៉ាងរបស់កូន ។ អំពើបែបនេះគ្រាន់តែបានធ្វើឱ្យកូនខូចប៉ុណ្ណោះ ។

បុរសជាច្រើន តែងឧទ្ទិសថាមពល និងប្រាជ្ញាញាណរបស់ខ្លួនចំពោះការងាររបស់ខ្លួន ហើយដោយប្រការយ៉ាងនេះ តើមានថាមពលអ្វីទៀត ដែលគេរក្សាទុកសម្រាប់គ្រួសារ, នោះគឺជា "សំណល់" សុទ្ធសាធ ។ ក្នុងទីនេះហើយដែលទឡ្ហីករណ៍សម្រាប់ "ពេលពង្រឹងគុណធម៌" ត្រូវមានតួនាទី, តាមធម្មតាចេញពីឪពុកម្តាយមានកំហុស ដែលចង់កែតម្រូវពេលវេលានីមួយ១ ដែលគេមានសេសសល់សម្រាប់កូន១ របស់គេ ។ ការខ្វះចន្លោះមួយ ក្នុងបណ្តាការខ្វះចន្លោះទាំងឡាយនៃទស្សនៈ "ពេលពង្រឹងគុណធម៌" គឺឋិតនៅក្នុងហេតុផលដែលថា សេចក្តីត្រូវការរបស់កូន១ និងភាពទំនេររបស់ឪពុកម្តាយ មិនត្រូវគ្នាជានិច្ចនោះទេ ។ ពេលដែលកូន១ ត្រូវការឪពុកម្តាយ, ឪពុកម្តាយមិននៅផ្ទះ ។

ជាញឹកញាប់ឪពុកម្ដាយតែងឋិតនៅក្នុងស្ថានភាព នៃបញ្ហាមួយមានចុងចំណោទពីរ (ឬឧភតោកោដិបញ្ហា) ។ ដោយរត់ទៅផ្ទះផុតពីការងារប្រចាំថ្ងៃដ៏លំបាក, ឪពុកម្ដាយដ៏ហត់ហេវនៅមានការងារប្រចាំថ្ងៃកំប៉ិកកំប៉ុក ក្នុងគ្រួសារផ្ទាល់របស់ខ្លួននៅរង់ចាំខ្លួនទៀត ។ កាលណាការងារប្រចាំថ្ងៃធ្វើហើយ, វាល្មមដល់ពេលអាហារពេលល្ងាច ហែរហមដោយការមើលទូរទស្សន៍, ហើយពេលវេលាសេសសល់បន្តិចបន្តួច មិនគ្រប់គ្រាន់សម្រាប់ផ្ដល់សេចក្ដីស្រលាញ់ និងសេចក្ដីថ្នាក់ថ្នមកូនឱ្យបានពេញលេញឡើយ ។ សំខាន់ជាងនេះទៀត, ឪពុកម្ដាយមិនបាននៅជិតដើម្បីបន្តផ្ដល់តម្លៃវប្បធម៌, សង្គមធម៌ និងសាសនា ដល់កូនៗ របស់ខ្លួន នៅពេលដែលកូនៗ មានឱកាសសមស្របបំផុតទទួលយកតម្លៃនោះបាន ។ នេះមិនអាចធ្វើបានទៀត ក្នុងអំឡុង "ពេលពង្រីងគុណធម៌" !

ឪពុកម្ដាយដែលជាអ្នកធ្វើការខ្លះ មានរហូតដល់យកការងារទៅធ្វើនៅផ្ទះ ឬមានរហូតដល់នាំយកទៅវិញនូវ ស្ត្រេស (Stress) និងភាពតានតឹង ដែលគេបានប្រមូលយកអំពីកន្លែងធ្វើការ។ ជាលទ្ធផល, ឪពុកម្ដាយទាំងនោះអាចមានចិត្តក្រោធខឹងចំពោះកូន ។

ក្នុងឋានៈជាប្ដី-ប្រពន្ធ, ពួកគេមិនអាចមានពេលគ្រប់គ្រាន់ រស់នៅជុំគ្នា ហើយរឿងនេះអាចមានផលរហូតដល់នាំឱ្យចំណងអាពាហ៍ពិពាហ៍បែកបាក់ ។ គេគប្បីបង្កើនសេចក្ដីភ្ញាក់រលឹកថា ចំណងគ្រួសាររឹងមាំ អាចផ្ដល់វិភាគទានទៅដល់ការធំធាត់ប្រកបដោយសុខភាពល្អរបស់កូន ។

គេអាចនិយាយថា ភាពផ្សេងគ្នាខាងភេទ (ឬខាងហ្សែនជីវ) មានកម្លាំងប្រព្រឹត្ត ទៅក្នុងទំនាក់ទំនងម្ដាយ-ឪពុក/កូន ។ គេនិយាយថា ម្ដាយ និងកូនស្រី

ចំរើនវ័យធំហើយ រមែងឆ្លើយឆ្លងគ្នាញឹកញាយច្រើនជាង សូម្បីក្រោយពេលកូនស្រីមានប្ដី ហើយចាកចេញពីផ្ទះ ទៅហើយក៏ដោយ ។

មួយចំណែកទៀត, វាមានភាពផ្សេងគ្នាសម្រាប់ឪពុក និងកូនប្រុសចម្រើនវ័យធំឡើង។ គេនិយាយថា កូនប្រុស និងឪពុកនិយាយរកគ្នា តែពេលណាចាំបាច់ដាច់ខាតប៉ុណ្ណោះ ហើយច្រើនតែអំពីបញ្ហាមិនធ្ងន់ធ្ងរ ។ ការសន្ទនាអាចដូចជាសម័យប្រជុំចោទ ឆ្លើយមួយ ។

ប្រហែលឪពុកគិតថា កូនប្រុសជាក្មេងធំហើយ វាត្រូវដឹងតួនាទី និងករណីកិច្ចរបស់វានៅក្នុងផ្ទះ, ចំពោះឪពុកម្ដាយ និងនៅខាងក្រៅផ្ទះ ។ ប៉ុន្តែជាមួយម្ដាយវិញ, គឺមានភាពផ្សេងគ្នា-កូនស្រីគឺនៅជា "កូនស្រីដ៏តូចច្រលឹងរបស់ម៉ែ " ជារៀងរហូត ។

ទោះជាអ្វីក៏ដោយ ឪពុកម្ដាយមានតួនាទីសំខាន់មួយ ត្រូវបំពេញក្នុងការចិញ្ចឹមបីបាច់កូន១របស់ខ្លួន ហើយត្រូវចិញ្ចឹមបីបាច់ឱ្យបានល្អ ប្រសិនបើគេចង់ជួយសម្រួលជម្ងឺជាច្រើនកំពុងរាតត្បាតសង្គមរបស់យើង សព្វថ្ងៃនេះ ។ តម្លៃគុណធម៌ល្អ១ មិនអាចយកមកបង្រៀនបានតាមពាក្យសំដីទេ, ប៉ុន្តែតាមរយៈអំពើ ។

ឪពុកម្ដាយ ត្រូវតាំងខ្លួនជាគំរូល្អ ។ ឥរិយាបទឪពុកម្ដាយពីជំនាន់ដើមថា "ឯងត្រូវធ្វើអ្វី១ ដែលឪប្រាប់ឱ្យឯងធ្វើ ហើយមិនមែនអ្វី១ ដែលឪធ្វើទេ", ឥរិយាបទនេះមិនមានសុពលភាពទៀតទេ ។ ឪពុកម្ដាយត្រូវតែជាមនុស្ស មានចរិតត្រឹមត្រូវខ្លួនឯង។ បើយើងចង់ឱ្យកូន១ យើងចាប់ផ្ដើមជីវភាពរស់នៅល្អ ប្រកបដោយតម្លៃគុណធម៌ត្រឹមត្រូវ យើងត្រូវចាប់ចេញដំណើរតាំងពីនៅក្នុងផ្ទះ ។

បើរឿងរ៉ាវកើតមានមិនល្អរវាងកូនប្រុសពេញកម្លោះ និងឪពុករបស់វា

ហើយ. ឪពុកត្រូវចាប់ផ្ដើមពិនិត្យរកមើលចម្លើយនៅក្នុងរង្វង់ពួកគេផ្ទាល់ (គឺរង្វង់ឪពុក-កូន) ។

ឪពុកម្ដាយទាំងពីរនាក់ចាំបាច់ត្រូវធ្វើពលិកម្ម គឺការលះបង់ខ្លះៗ ។ គេគប្បីទុកពេលវេលា ហើយព្យាយាមឱ្យអស់លទ្ធភាពប្រមូលសមាជិកគ្រួសារ ឱ្យចូលរួមក្នុងគ្រប់សកម្មភាព ដែលបានធ្វើដោយបង្កើតឱ្យបានជាសកម្មភាពតម្រង់ទិសគ្រួសារ ។

សារសំខាន់ឋិតនៅលើការកំណត់អាទិភាពរបស់សកម្មភាពឱ្យបានត្រឹមត្រូវ ឧទាហរណ៍ អាទិភាពតម្រង់ទិសឆ្ពោះទៅរកគ្រួសារ និងអាពាហ៍ពិពាហ៍. ដោយប្រការយ៉ាងនេះ គេបង្កើតបាននូវទំនាក់ទំនងគ្រួសារមួយជិតស្និទ្ធស្នាលសម្រាប់បរិដ្ឋានមួយមានសុខដុមភាព ។

(នៅមានត)

# ទស្សនៈជីវិត

ដោយ : **គ្រូឧត្តមាចារ្យ ឆេង ផុន**

## I- ទស្សនៈអំពីជីវិត

- ជីវិត ជាការសង និងការបុល ។
- ជីវិត ជាការចង និងការស្រាយ ។
- ជីវិត ជាការលះហើយទៅ ទៅហើយលះ ។
- ជីវិត បច្ចុប្បន្នជាផលវិបាករបស់កម្ម ពីអតីតកាល ។
- ជីវិត ជាស៊ីងជោរនាច១ ទៅដោយការខឹងក្រោធ និងសេចក្ដីភ័យខ្លាច។
- ជីវិត របស់មនុស្ស រស់នៅបានតែមួយខណៈចិត្ត១ ប៉ុណ្ណោះ ។

-ការស្គាល់បច្ចុប្បន្នកាលច្បាស់ មិនធ្វើឱ្យមានការសង្ស័យលើអតីតកាល និងអនាគតឡើយ ។

- អ្នកយល់ថា ខ្លួនជាមនុស្ស មានទ្រព្យ មានយស ឬជាមនុស្សកំសត់ឥត ទ្រព្យ ឥតយស ឈ្មោះថា ជាមនុស្សលិចលង់ ចាញ់បោកគំនិតខ្លួនឯង ។
- មនុស្សលើកខ្លួន ដាក់ខ្លួន ប្រកាន់ខ្លួន ជាមនុស្សចាញ់បោកខ្លួនឯង ។
- គួរកុំសូវយកចិត្ត ទុកដាក់ទៅលើការប្រមាថ ឬការមើលងាយពីគេមក លើខ្លួន តែគួរយកចិត្តទុកដាក់ ពីការប្រមាថពីខ្លួនឯង លើខ្លួនឯង ឬពីខ្លួនឯងទៅលើអ្នកដទៃ ។
- រឿងរ៉ាវទាំងឡាយនៃជីវិតអតីត បច្ចុប្បន្ន និងអនាគត គឺជាការបន្តគ្នា

នៃចិត្តច្រើនសន្ទឹកសន្ធាប់ ច្រើនប្រភេទ ច្រើនលក្ខណៈ មិនដាច់នៃជាតិថ្មី។

- ពេលវេលាចេះតែរំកិលទៅៗ ឯជីវិតចេះតែរអិលទៅៗ ។
- ពេលវេលាកាន់តែខើច ជីវិតកាន់តែខ្លី ពេលវេលាធ្វើល្អកាន់តែតិច ។
- ពេលវេលា ជាចោរប្លន់ជីវិតដ៏ប៉ិនប្រសប់បំផុត ដោយប្រើកាំបិតលាបទឹកឃ្មុំ ។
- រូបល្អ សម្លេងពិរោះ ក្លិនក្រអូប អាហារឆ្ងាញ់ ភាពស្រណុក ភាពស្រួលសុទ្ធតែជាសំណូករបស់ពេលវេលា សម្រាប់ប្តូរជីវិត ។
- ពេលវេលាចុងក្រោយនៃជីវិតនេះ ជាពេលវេលាដើមនៃជាតិថ្មី ។
- អ្វីៗនៅលើលោកនេះ ហាក់ដូចជារបស់បញ្ឆោតទាំងអស់ ( មាយា ) រលត់កើត កើតរលត់ ឃើញបាត់ បាត់ឃើញ បែកជួប ជួបបែក ។
- ជីវិត គឺជាការធ្វើដំណើរបន្ត ដោយគ្រាន់តែផ្លាស់ប្តូរវិថី និងយានយន្តប៉ុណ្ណោះ ។
- ជីវិតបច្ចុប្បន្ន ដូចជាផ្ទះសំណាក់ប៉ុណ្ណោះ គ្រាន់តែស្នាក់នៅបណ្តោះអាសន្ន និងមិនមានគំនិតហួងហែង តុបតែង ជួសជុល ព្រោះបម្រុងនឹងចេញចោល ។
- លោកិយនេះ ជាកំពង់ផែ សម្រាប់នាវាជីវិត សត្វលោកចូលចត ផ្ទុកផ្ទេរ ផ្លាស់ប្តូរ ទូទាត់ កម្មផល ថ្មីចាស់តែប៉ុណ្ណោះ ។
- ចូររក្សាចិត្តឱ្យបានរាបស្មើ ពិភពលោកទាំងមូលបានរាបស្មើដែរ ។

**✱- ទស្សនៈចំពោះសេចក្តីស្លាប់**

- កាន់តែខ្លាចស្លាប់ សេចក្តីស្លាប់កាន់តែមកជិត ។
- អ្នករៀបចំស្លាប់បានល្អ រៀបចំរស់បានល្អ ។

- ភ័យកាន់តែខ្លាំង ព្រួយកាន់តែច្រើន អាយុកាន់តែខ្លី ។
- អណ្ដាតភ្លើងកាន់តែធំ ប្រេងកាន់តែឆាប់អស់ ។
- កំដៅកាន់តែខ្លាំង សាច់កាន់តែផុយរលួយ ។
- ការរស់ព្រោះតែអាហារ កាយមរណាព្រោះអាហារជាមូលហេតុ ។
- ចិត្តរស់ព្រោះសង្ខារ ចិត្តមរណាព្រោះអាហារជាហេតុ ។
- កង្វល់ និងការភ័យខ្លាច ជាហេតុ និងបច្ច័យ នាំឱ្យវិលវល់ក្នុងវដ្ដសង្សា ។
- អាត្មានិយម ជាឫសគល់នៃជាតិទុក្ខ ជរាទុក្ខ និងមរណៈទុក្ខ ។
- បើយើងទទួលសេចក្ដីស្លាប់ ដោយឧបេក្ខា សេចក្ដីស្លាប់ចូលមករកយើង ដោយឧបេក្ខា ។
- បើយើងទទួលជាតិ ជរា ព្យាធិ មរណៈ ដោយមេត្តា ជាតិ ជរា ព្យាធិ មរណៈ ឥតបញ្ចេញកំហឹងដាក់យើងវិញទេ ។
- អ្នកខ្លាចការពិត រមែងសុបិនឃើញភ័យ ។
- បច្ចុប្បន្នក្លាយទៅជាអតីតកាល រាល់ដង្ហើមចេញចូល ។
- សង្ខារថ្មី ក្លាយទៅជាសង្ខារចាស់ រាល់ខណៈចិត្ត ។
- មនោទ្វារកាន់តែធំ វិថីចិត្តកាន់តែទូលាយ ចិត្តកាន់តែហើម ។
- ហ៊ុងកាន់តែប៉ោង កំហឹងកាន់តែខ្លាំង-កំហឹងកាន់តែខ្លាំង ហ៊ុងកាន់តែប៉ោង ។ ហ៊ុងបែកធ្លាយ សង្ខារ បែកខ័ន្ធ ។
- ភ័យក្នុង ភ័យក្រៅ ភ័យព្រោះខ្លាចស្លាប់ ភ័យភ្លាត់ចំណាប់ ស្លាប់មកដល់មុនភ័យ ។
- លោកៈ គឺបែកធ្លាយ ។ លោកធម៌ គឺធម៌បែកធ្លាយ ។ និន្ទា និងពោលសរសើរ ជាធម៌បែកធ្លាយ លាភៈក៏បែកធ្លាយ អលាភៈក៏បែកធ្លាយ ។

- យើងកើតពីភពបែកធ្លាយ រស់នៅក្នុងបែកធ្លាយ ទីបំផុតយើងនឹងបែកធ្លាយ ។
- កាយយើងជាដុំដីតូច ក្នុងដុំដីធំ ។ ដីជាដុំល្វង់ធំ រូបជាដុំល្វង់តូច ។
- យើងមកពីណា ត្រូវតែទៅទីនោះវិញ ។ មកពីដី ត្រូវទៅជាដីវិញ ។ មកទទេ ទៅវិញក៏ទទេ ។
- បើគ្មានការភ្លេច និងការបាត់ទៅវិញទេ មនុស្សមិនអាចទ្រាំទ្រនឹងជីវិតបានឡើយ ។

**✱_ ទស្សនៈចំពោះការស្មោះត្រង់**

- ភាពស្មោះត្រង់ បង្កើតការស្មោះត្រង់ ។ កុំយកលុយទៅទិញភាពស្មោះត្រង់ ។ កុំយកអំណាចទៅគម្រាមភាពស្មោះត្រង់ ។
- ស្មោះត្រង់ពិត គឺត្រង់ក្នុង ត្រង់ក្រៅ ត្រង់ដើម ត្រង់កណ្ដាល ត្រង់ចុង ត្រង់គ្រប់ទីកន្លែង និងត្រង់គ្រប់ពេលវេលា ។
- ត្រង់ឥតខ្លាច ត្រង់ឥតភ័យ ត្រង់ឥតល្ងង់ ត្រង់ឥតវង្វេង ។
- ត្រង់ឥតគំនុំ ត្រង់ឥតបៀតបៀន ត្រង់ឥតប្រទូស្ត ត្រង់ឥតក្រោធខឹង ។
- ត្រង់ឥតបក្សពួក ត្រង់ឥតញាតិផៅ ត្រង់ឥតផលប្រយោជន៍ផ្ទាល់ខ្លួន ។
- ភាពសង្ស័យ ធ្វើឱ្យភាពបរិសុទ្ធ ល្អក់កករលែងមើលឃើញការពិត ។
- ភាពសង្ស័យ កម្ចាត់អស់ភាពទុកចិត្ត និងភាពស្មោះត្រង់ ។
- ភាពចង្អៀតចង្អល់ ភាពតានតឹង ភាពស្អុះស្អាប់ក្នុងអាកាស កម្ចាត់អស់ភាពស្ងប់ស្ងាត់ ភាពសុខដុមរមនា ។

**✱_ វិធីស្លាប់**

-សម្លាប់លោភៈ ដោយឃើញមរណៈ ( យកទៅជាមួយមិនរួចទេ ) ។

- សម្លាប់តម្រេក ដោយឃើញអសុភ ។
- សម្លាប់ទោសៈ ដោយឃើញមេត្តា ។
- សម្លាប់មោហៈ ដោយឃើញបញ្ញា ។
- សម្លាប់កុហក ដោយនិយាយពិត និយាយត្រង់ ។
- សម្លាប់កំណាញ់ ដោយឱ្យទាន ។
- សម្លាប់ហិង្សា ដោយអហិង្សា ។
- សម្លាប់ពៀរ ដោយមិនចងពៀរ ។
- សម្លាប់ច្រណែន ដោយត្រេកអរតាម ។
- សម្លាប់ប្រកាន់ ដោយឧបេក្ខា ( តាំងចិត្តដោយមិនលំអៀង ) ។
- សម្លាប់ភាពភ្ញាក់ផ្អើល រន្ធត់ញាប់ញ័រ ដោយខន្តី ។
- សម្លាប់ភាពស្ពន់ស្លោរ អន្ទះអន្ទែង ក្ដៅក្រហាយ ដោយវិរិយៈ ( ពេលវេលា ជាឱសថ ជាគ្រូ ) ។

# សីលធម៌វិជ្ជាជីវៈរបស់គ្រូបង្រៀន ក្នុងការបណ្តុះបណ្តាលធនធានមនុស្ស

នយ ឃីហាន
(បណ្ឌិត ទស្សនវិជ្ជា)

គ្រប់វិជ្ជាជីវៈទាំងអស់សុទ្ធតែមានសីលធម៌នៅក្នុងនោះ។ វិជ្ជាជីវៈណាមួយដែលខ្វះសីលធម៌ វិជ្ជាជីវៈនោះនឹងក្លាយជាមូលដ្ឋានបំផ្លាញសង្គម។ អ្នកច្បាប់ អ្នកសារពត៌មាន អ្នកការទូត អ្នកនយោបាយ អ្នកពាណិជ្ជកម្ម ... សុទ្ធសឹងមានក្រមសីលធម៌ជាប្រចាំ ដើម្បីទទួលជោគជ័យក្នុងការងាររបស់ខ្លួន។ កង្វះខាតក្រមសីលធម៌ ចលាចលសង្គមនឹងកើតឡើងដោយជៀសមិនផុត។

នៅទីនេះ យើងនិយាយពីពិភពគ្រូបង្រៀន និងសីលធម៌វិជ្ជាជីវៈរបស់គេ។ សង្គមសព្វថ្ងៃវាយតម្លៃថា សីលធម៌វិជ្ជាជីវៈរបស់គ្រូបង្រៀនកំពុងស្រុតចុះជាបណ្តើរៗ បើប្រៀបធៀបនឹងសម័យមុនឆ្នាំ ១៩៧០។ យើងគួរលើកយកសំនួរបួនមកចោទដូចខាងក្រោម ÷

- តើគ្រូបង្រៀនជាមនុស្សប្រភេទណា ?
- តើសីលធម៌វិជ្ជាជីវៈរបស់គេជាអ្វី ?
- ហេតុអ្វីបានជាសីលធម៌វិជ្ជាជីវៈរបស់គ្រូបង្រៀនស្រុតចុះ ?
- តើគួរធ្វើយ៉ាងដូចម្តេច ដើម្បីស្តារសីលធម៌វិជ្ជាជីវៈនោះឡើងវិញ ?

## I. តើគ្រូបង្រៀនជាមនុស្សប្រភេទណា ?

គ្រូបង្រៀនគ្រប់ភូមិសិក្សាមានឈ្មោះថា *បុគ្គលិកសិក្សា (teaching body)* ឬ *អ្នកអប់រំ (educator)* ។ ភាសិតមួយដែលបញ្ជាក់ពីគុណសម្បត្តិរបស់គ្រូបង្រៀនគឺ *"គ្រូបង្រៀន ជាវិស្វករព្រលឹងជាតិ" (Teacher is a man who form the national soul)* ។ ប្រយោគនេះមានន័យថា ការបណ្តុះបណ្តាលព្រលឹងជាតិត្រូវធ្វើឡើងដោយគ្រូបង្រៀន។ ព្រលឹងជាតិល្អ ឬអាក្រក់ អាស្រ័យដោយបេសកកម្មរបស់គ្រូបង្រៀន។

**គ្រូបង្រៀនមានមុខងារសំខាន់ពីរយ៉ាង ÷**

- ការបង្ហាត់ និងការបង្រៀនចំណេះដឹងទូទៅ និងចំណេះដឹងឯកទេស ;
- ការអប់រំបុគ្គលិកលក្ខណៈរបស់សិស្ស និស្សិត។

### ១~ ការបង្ហាត់ និងបង្រៀនចំណេះដឹងទូទៅ និងចំណេះដឹងឯកទេស

ការបង្ហាត់មានលក្ខណៈទាបជាងការបង្រៀន។ ការបង្ហាត់ ជាការចាប់ផ្តើមមុនដំបូង ដើម្បីឱ្យសិស្សងាយយល់អ្វីដែលគ្រូបង្រៀនចង់បង្ហាញ។ ការបង្រៀនមានលក្ខណៈខ្ពស់ជាងការបង្ហាត់ធ្វើឱ្យសិស្ស និស្សិត យល់អត្ថន័យ និងខ្លឹមសាររបស់មេរៀន។ ការបង្ហាត់ និងការបង្រៀន មានប្រយោជន៍ដូចគ្នា និងជះឥទ្ធិពលទៅវិញទៅមក។ គ្រូត្រូវចេះទាំងពីររបៀប : របៀបបង្ហាត់ និងរបៀបបង្រៀន។ ជាទូទៅ ចំណេះដឹងចែកចេញជាពីរចំណែក គឺចំណេះដឹងទូទៅ (general

knowledge) និងចំណេះដឹងឯកទេស (special knowledge) ។ ចំណេះដឹងទូទៅជាចំណេះដឹងទូលំទូលាយ តែមិនសូវស៊ីជម្រៅ។ ឯចំណេះដឹងឯកទេស ជាចំណេះដឹងចង្អៀត តែស៊ីជម្រៅ។

## ២‿ ការអប់រំបុគ្គលិកលក្ខណៈរបស់សិស្ស និស្សិត

ក្នុងពិភពលោកនេះ គ្មានមនុស្សពីរនាក់ដែលមានធម្មជាតិ (nature) ឬសារជាតិ (essence) ដូចគ្នាបេះបិទទេ។ ហេតុនេះ ចរិតមនុស្សក៏មិនដូចគ្នាដែរ។ ចរិតមនុស្សមានខ្លឹមសារពីរយ៉ាង គឺខ្លឹមសារសង្គម និងខ្លឹមសារ ផ្លូវចិត្ត។

### ក‿ អំពីខ្លឹមសារសង្គមនៃចរិតមនុស្ស

នៅពេលចាប់ផ្ទៃមាតា មនុស្សត្រូវទាក់ទងជាមួយម្តាយ គ្រួសារ សង្គម និងបរិស្ថាន។ បើខ្វះទំនាក់ទំនងនេះ មនុស្សមិនអាចមានគំនិត និងសកម្មភាពជាមនុស្សទេ ឬអាចស្លាប់ទៅវិញក៏សឹងមាន។

### ខ‿ អំពីខ្លឹមសារផ្លូវចិត្តនៃចរិតមនុស្ស

ខ្លឹមសារផ្លូវចិត្តចែកចេញជាបីយ៉ាង គឺ ៖

- ផលប្រយោជន៍ផ្ទាល់ខ្លួន និងគ្រួសារ ផលប្រយោជន៍សហគមន៍ មាតុភូមិអន្តរជាតិ ;
- តម្រូវការសំភារៈ និងតម្រូវការស្មារតី ;
- និន្នាការដែលបង្ហាញថា ចរិតកើតឡើងឯកឯង ឬប្រែប្រួលតាមបរិយាកាសសង្គម តាមលក្ខខណ្ឌនៃ

ជីវភាពប្រចាំថ្ងៃ និងការអប់រំ។ ការអប់រំចែកចេញជាបីផ្នែក គឺការអប់រំរាងកាយ ការអប់រំសមត្ថភាពវិទ្យាសាស្ត្របច្ចេកទេស និងការអប់រំសីលធម៌។ គឺការអប់រំសីលធម៌នេះហើយ ដែលធ្វើឱ្យមនុស្សមានសីលចរិត និងសីលញ្ញាណ[១] ។

---

១- ឆយ យីប៉ាង. *កិច្ចរៀបចំបង្រៀន "ទស្សនវិជ្ជាសីលធម៌ស្ដីពីការបណ្ដុះបណ្ដាលសីលចរិត និងសីលញ្ញាណរបស់មនុស្ស" សម្រាប់បង្រៀន នៅរាជបណ្ឌិតសភាកម្ពុជា (RAoC) និងធ្លាប់បង្រៀននៅសាលាភូមិន្ទរដ្ឋបាល (ERA) សាកលវិទ្យាល័យន័រតុន (NU) វិទ្យាស្ថានសារគមនាគមន៍កម្ពុជា (CCI) និងវិទ្យាស្ថានបច្ចេកទេស និងគ្រប់គ្រង (ITM) ។*

គំនូសបំព្រួញទី ១


ការអប់រំបុគ្គលិក
លក្ខណៈរបស់មនុស្ស
ខ្លឹមសារសង្គម
- រស់នៅជាមួយគ្រួសារ
- រស់នៅក្នុងសង្គម
- រស់នៅក្នុងបរិស្ថាន
ខ្លឹមសារផ្លូវចិត្ត
- ផលប្រយោជន៍
- តម្រូវការ
- និន្នាការ
ផ្ទាល់ខ្លួន និងគ្រួសារ
សហគមន៍ និងមាតុភូមិ
អន្តរជាតិ
សម្ភារៈ
ស្មារតី
កើតឡើងដោយឯកឯង
ប្រែប្រួល
តាមបរិយាកាសសង្គម
លក្ខខណ្ឌនៃជីវភាពប្រចាំថ្ងៃ
ការអប់រំ
រាងកាយ
វិទ្យាសាស្ត្រ
សីលធម៌
សីលចរិត
សីលញាណ

ការបង្ហាត់ និងការបង្រៀន ជាកិច្ចការលំបាកណាស់ហើយ។ ប៉ុន្តែ កិច្ចការដែលលំបាកជាងនេះទៀត គឺការអប់រំបុគ្គលិកលក្ខណៈ ដែលតម្រូវឱ្យពលរដ្ឋមានលក្ខណៈល្អប្រសើរ ឱ្យសិស្ស និស្សិតក្លាយជាទំពាំងស្នងឫស្សី ឱ្យជំនាន់ក្រោយខ្លាំងជាងជំនាន់មុន។ នេះជាគោលបំណងនៃគ្រប់ប្រទេសទាំងអស់ ជាគោលបំណងនៃអង្គការ យូនីសែហ្វ (UNICEF) និងអង្គការយូណេស្កូ (UNESCO) ។

ភារកិច្ចនេះមានការលំបាកមែន តែជាភារកិច្ចថ្លៃថ្នូរ ដែលរដ្ឋាភិបាលនៃប្រទេសនីមួយៗតម្រូវឱ្យធ្វើអាជីវកម្មលើវិស័យអប់រំ។ ក្នុងវិស័យអប់រំគេតែងនិយាយថា " *ដាំដើមឈើ ១០ ឆ្នាំ អាចបានផល បណ្តុះបណ្តាលអប់រំមនុស្ស ១០០ ឆ្នាំ ទើបបានផល* "។ ខ្ញុំមិនយល់បែបនេះទេ។ ខ្ញុំយល់ថា អប់រំមនុស្សចាប់ពីពេលណា គឺចាប់ទទួលផលជាបណ្តើរៗ ពីពេលនោះដែរ។ ឯការអប់រំចែកចេញជាពីរបែប គឺការអប់រំទៅរកផ្លូវល្អ និងទៅរកផ្លូវអាក្រក់។ ម្យ៉ាងទៀត និស្ស័យរបស់មនុស្សពិតជាមានមែន។ នោះជាធម្មជាតិ ដែលជាប់ពីកំណើតរបស់មនុស្ស តែការអប់រំសំខាន់ជាងដូចដែល **អង់តុន ម៉ាការ៉េង់កូ** (Anton Makarenko) គរុកោសល្យវិទូអ៊ុយក្រែនបានពោលថា " *រវាងនិស្ស័យ និងការអប់រំ ការអប់រំមានអាទិភាពជាង* "[២] ។ ដោយមើលឃើញគុណសម្បត្តិនៃអ្នក អប់រំ បណ្ឌិតសាស្ត្រាចារ្យ **ចាន់ រដ្ឋសុផា** នៅមហាវិទ្យាល័យគរុកោសល្យ បានសរសេរអំពីគុណសម្បត្តិនៃបុគ្គលិកសិក្សាដូចខាងក្រោម ÷

« • គុណសម្បត្តិខាងចិត្ត-គរុកោសល្យ

---

[២] ឆយ យីហ៊ាង, (ដូចឯកសារខាងលើ)

- គុណសម្បត្តិខាងវិធីសាស្ត្របង្រៀន
- គុណសម្បត្តិផ្នែកកិរិតវប្បធម៌
- គុណសម្បត្តិខាងបទពិសោធន៍
- គុណសម្បត្តិខាងសេចក្ដីព្យាយាម និងអំណត់ធន់
- គុណសម្បត្តិខាងផ្នែកសិល្បៈគរុកោសល្យក្នុងការបង្រៀន និងអប់រំសិស្ស »[៣] ។

អ្នកអប់រំត្រូវប្រកបដោយគុណសម្បត្តិខាងលើនេះ ទើបអាចអប់រំបានល្អ ទើបធ្វើឱ្យមុខរបររបស់ខ្លួនទទួលជោគជ័យ។ បើខ្វះគុណសម្បត្តិណាមួយ គ្រូបង្រៀនអាចបាត់បង់សេចក្ដីថ្លៃថ្នូររបស់ខ្លួន។

## II. តើសីលធម៌វិជ្ជាជីវៈរបស់គ្រូបង្រៀនជាអ្វី ?

### ១~ វិជ្ជាជីវៈ (Profession)

វិជ្ជាជីវៈ ជាកិច្ចការជាក់លាក់ ដើម្បីធ្វើជាមធ្យោបាយសំរាប់រស់នៅ (la profession est une occupation déterminée dont on peut tirer ses moyens d'existence) ។ វិជ្ជាជីវៈនេះបង្ខំឱ្យគ្រូបង្រៀនយល់ថា *"ប្រព័ន្ធអប់រំទំនើប គំនិតអប់រំទំនើប ការគិតអប់រំទំនើប និងការប្រតិបត្តិ ជាកូនចៅនៃចលនា និងស្នាមដែលមិនមែនគ្រាន់តែកើតមកពីអតីតកាលប៉ុណ្ណោះទេ តែមាននៅក្នុងបច្ចុប្បន្នកាល និងលាតសន្ធឹងទៅដល់ជំនាន់ក្រោយទៀត" (Modern educational systems, ideas, thoughts, and practices are offshoots of movements*

---

៣ ចាន់ រដ្ឋសុផា, *ភារកិច្ចរបស់គ្រូបង្រៀន (Tâches de l'enseignant)*, ភ្នំពេញ, ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០១

*and imprints not only from the past, but even up to now and to some extent the generations to come)*[៤] ។ ហេតុនេះ គ្រូបង្រៀនមិនអាចបំភ្លេចចោលនូវការអប់រំជំនាន់ដើមឡើយ ប្រសិនបើចង់កែទម្រង់ប្រព័ន្ធអប់រំនៅសហកាលនេះ។ ភាពខ្ជិខ្ជា មិនព្យាយាមក្នុងការស្រាវជ្រាវប្រព័ន្ធអប់រំក្នុងអតីតកាល មានន័យថា គ្រូបង្រៀនឥតលើកតម្កើងវិជ្ជាជីវៈរបស់ខ្លួនឡើយ។ **ចច្រ្ជ សាន់តាយ៉ាណា** (George Santayana) បានអះអាងថា *"នរណាបំភ្លេចចោលអតីតកាល អ្នកនោះត្រូវទទួលទណ្ឌកម្មក្នុងការនិយាយតាមឡើងវិញ" (He who forgets the past is doomed to repeat it)*[៥] ។ ដើម្បីរឭកពីអតីតកាលវិញ គ្រូបង្រៀន ត្រូវស្រាវជ្រាវជាចាំបាច់។ នោះហើយជាវិជ្ជាជីវៈរបស់គ្រូបង្រៀន។ គ្មានការស្រាវជ្រាវ គ្រូបង្រៀនប្រៀបដូចជាមនុស្សខ្វិន។

ជាសង្ខេប យើងត្រូវពិចារណាវត្ថុ និងបាតុភូតនានាពីអតីតកាល ពីព្រោះវាជះឥទ្ធិពលដល់បច្ចុប្បន្នកាល និងអនាគតកាល។ ម្យ៉ាងទៀត យើងត្រូវយល់ថា អ្វីដែលយើងកំពុងអនុវត្តសព្វថ្ងៃនេះ ជាលទ្ធផលនៃអ្វីដែលមានកន្លងមក។ អ្វីដែលនឹងអាចមាននៅថ្ងៃស្អែក គឺផ្អែកលើអ្វីដែលយើងកំពុងធ្វើសព្វថ្ងៃ។

## ២. សីលធម៌ (Morale)

សីលធមិ ជាទ្រឹស្តីស្តីពីសកម្មភាពរបស់មនុស្ស ដែលជាទូទៅមានទម្រង់ជានិយាម។ គេអាចបែងចែក សីលធមិជាពីរផ្នែក គឺ សីលធមិនៃកុសល និងសីលធមិ

---

៤ Cecilio D. Duka, *Philosophy of education,* Rex Printing Company, Manila, Philippines, 2000, page 11.

៥ Cecilio D. Duka, Ibid, page 11.

នៃករណីយកិច្ច ។

### ក‿ សីលធម៌នៃកុសល (La morale du Bien)

សីលធម៌នៃកុសលលើកឡើងនូវការកំណត់អំពីអ្វីដែលហៅថា *កុសល* អំពីអ្វីដែលហៅថា គោលដៅរបស់មនុស្ស និងអំពីអ្វីដែលជាមធ្យោបាយសម្រាប់ឈានទៅដល់កុសលនោះ។ កុសលត្រូវបានយល់តាមរបៀបផ្សេងគ្នា ÷ លទ្ធិរីករាយនិយម (hédonisme) យល់ថា កុសលជាសេចក្តីរីករាយ (le plaisir), លទ្ធិសុភមង្គលនិយម (eudémonisme) យល់ថា កុសលជាសុភមង្គល (le bonheur), លទ្ធិផលប្រយោជន៍និយម (utilitarisme) យល់ថា កុសលជាផលប្រយោជន៍ (l'intérêt) ។

### ខ‿ សីលធម៌នៃករណីយកិច្ច (La morale du Devoir)

សីលធម៌នៃករណីយកិច្ច មានន័យថា ការគោរពច្បាប់សីលធម៌ដោយប្រតិបត្តិតាមបញ្ជាដាច់ខាត (impératif catégorique) ។ បញ្ជានេះលេចឡើងជាការចាំបាច់បរានុម័ត ព្រោះវាលេចឡើងដោយខ្លួនឯង និងគ្មានទំនាក់ទំនងជាមួយគោលបំណងផ្សេងទៀតឡើយ។ **កង់** (Kant) បានពោលថា *"ករណីយកិច្ច គឺជាការចាំបាច់ក្នុងការបំពេញសកម្មភាពដោយគោរពច្បាប់" (Le devoir est une nécessité d'accomplir une action par respect pour la loi)*[៦] ។

---

៦ L. M. Morfaux, *Vocabulaire de la philosophie et des sciences humaines*, Armand Colin, Paris, 1980, page 225 (voir morale).

## គំនូសបំព្រួញទី២




Kant : "ករណីយកិច្ច គឺជាការចាំបាច់ក្នុងការបំពេញសកម្មភាពដោយគោរពច្បាប់"

## ៣~ សីលធម៌វិជ្ជាជីវៈរបស់គ្រូបង្រៀន

ដូចយើងបាននិយាយហើយថា " *គ្រូបង្រៀន ជាវិស្វករព្រលឹងជាតិ* " ។ នេះជានាមប្បញ្ញត្តិដែលគរុកោសល្យវិទូក្នុងលោកយល់ឃើញ។ បើតាមទស្សនៈខាងលើគ្រូបង្រៀនមានបេសកកម្មយ៉ាងលំបាក ដោយសារគេត្រូវរួមចំណែកកសាងព្រលឹងជាតិ អត្តសញ្ញាណជាតិ មនោគមវិជ្ជាជាតិប្រកបដោយវឌ្ឍនភាព និងរុងរឿង។ ការធ្លាក់ ទូកង ដែលហៅថា "*ទូកង លឿន*" សម្រាប់ប្រឡងប្រណាំងយកតំណែងជាជ័យលាភីនៅក្នុងពិធីបុណ្យអុំទូក គឺជាការលំបាកស្មុគស្មាញមួយ។ ជាងទូកង ពិតជាមានក្បួនខ្នាតច្បាស់លាស់នៅក្នុងស្មារតីរបស់ខ្លួន។ នោះជាទេពកោសល្យកម្រមានរបស់ជាងទូកង។ ប៉ុន្តែ ការធ្លាក់ទូកងមានលក្ខណៈរូបី ទោះមានការលំបាកស្មុគស្មាញយ៉ាងណាក៏ដោយ។ រីឯការធ្លាក់បុគ្គលដែលជា "*ជាងទូកង*" ឱ្យទៅជាពលរដ្ឋល្អប្រសើរមានលក្ខណៈអរូបី ហើយស្មុគស្មាញជាង "*ជាងធ្លាក់ទូកង*" ធ្លាក់ទូកងច្រើនដងណាស់ ព្រោះពុំទាន់មានទស្សនវិទូណាដែលអាចឱ្យនិយមន័យពិតប្រាកដដល់ពាក្យ "*ធម្មជាតិមនុស្ស*" *(human nature)* ឡើយ។ អំពីធម្មជាតិ

មនុស្ស ទស្សនវិទូខ្លះយល់ឃើញផ្ទុយគ្នា ដូច **ហ្សង់ហ្សាក់រូសូ** (Jean-Jacques Rousseau) ទស្សនវិទូបារាំងយល់ថា មនុស្សមានធម្មជាតិល្អពីកំណើត តែសង្គមធ្វើឱ្យមនុស្សពុករលួយ។ ឯ **តូម៉ាស់ ហូប** (Thomas Hobbes) ទស្សនវិទូអង់គ្លេសយល់ថា មនុស្សមានធម្មជាតិអាក្រក់ពីកំណើតមនុស្សមានធម្មជាតិព្រៃផ្សៃ ជាអត្តទត្ថបុគ្គល អនាធិបតេយ្យពោរពេញដោយមហិច្ឆតាឥតព្រំដែន មនុស្សជាចចកសម្លាប់មនុស្ស។ ចំពោះខ្ញុំវិញ ខ្ញុំយល់ខុសពីទស្សនៈទាំងពីរខាងលើបន្តិច ខ្ញុំយល់ថា មនុស្សមាននិស្ស័យធម្មជាតិល្អ និងអាក្រក់ជាប់ជិតដាមតាំងពីកំណើតមក ដោយមនុស្សរស់នៅក្នុងគ្រួសារ ក្នុងសង្គម និងបរិស្ថាន។ កត្តាទាំងបីនេះសុទ្ធសឹងជះឥទ្ធិពលល្អ អាក្រក់ ទៅដល់ទារក។ ប៉ុន្តែ ខ្ញុំយល់ស្របទាំងស្រុងតាម **អង់តុន ម៉ាការ៉េងកូ** (Anton Makarenko) ដែលលោកបានអះអាងថា បើប្រៀបធៀបរវាងនិស្ស័យ និងការអប់រំ ការអប់រំមានអាទិភាពជាង។ បើតាមន័យនេះ ទារកក្នុងផ្ទៃនៃអ្នកប្រមឹកមិនអាចមិនមាននិស្ស័យស្រវឹងខ្ទបទេ ឯទារកក្នុងផ្ទៃនៃសិល្បការិនី ក៏អាចមាននិស្ស័យសិល្បៈផងដែរ។ ប៉ុន្តែ បើទារកទាំងពីរ ឬកុមារទាំងពីរ ឬយុវ័យទាំងពីរមិនបានស្គាល់កែវស្រា មិនបានស្គាល់ការបណ្ដុះបណ្ដាលសិល្បៈ គេពុំអាចក្លាយជាអ្នកប្រមឹក ឬពុំអាចក្លាយជាសិល្បករ សិល្បការិនីដែរ។ ផ្ទុយទៅវិញ បើគេមាននិស្ស័យជាអ្នកកំប្លែង ហើយត្រូវបានបណ្ដុះបណ្ដាលខាងសិល្បៈកំប្លែងផងដែរ គេនឹងក្លាយជាសិល្បករកំប្លែងដែលមានកម្រិតខ្ពស់។

ការរៀបរាប់ខាងលើនេះគូសបញ្ជាក់ថា គ្រូបង្រៀនសាស្ត្រាចារ្យមិនមែនជាជាងទូកង ឬមិនមែនជាសិល្បករក្នុងន័យសាមញ្ញទេ។ តើគ្រូបង្រៀន សាស្ត្រាចារ្យជាអ្វី ? ដើម្បីយល់អំពីសីលធម៌វិជ្ជាជីវៈរបស់គ្រូបង្រៀន ត្រូវមើលឃើញតួនាទីរបស់គេជាមុនសិន។

(នៅមានត)

# ការរីកចម្រើននៃព្រះពុទ្ធសាសនាក្នុងជីវិតខ្មែរ

(ត)

ដោយ : **បណ្ឌិត ខួត ធីតា**

## ៣-ព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា

ព្រះពុទ្ធសាសនា នៅប្រទេសកម្ពុជាចែកជា គន្ថធុរៈ និងវិបស្សនាធុរៈ ។

គន្ថធុរៈ បានខាងការរៀនសូត្រទ្រឹស្តីព្រះពុទ្ធសាសនា គឺព្រះត្រៃបិដកបានខាងព្រះសូត្រ ព្រះវិន័យ ព្រះអភិធម្ម ។

ដើម្បីនឹងផ្សាយព្រះពុទ្ធសាសនា ឱ្យជ្រួតជ្រាបទៅក្នុងហទយវត្ថុ នៃប្រជារាស្ត្រក្នុងព្រះរាជាណាចក្រកម្ពុជា កុលបុត្រនិមួយៗ ត្រូវតែព្យាយាមរៀនទ្រឹស្តីខាងព្រះពុទ្ធសាសនា ឱ្យចេះចាំ ព្រះបរិយត្តិធម៌ និងព្រះនព្វលោកុត្តរធម៌ ឱ្យបានមុតមាំធមិនមស្គារ ព្រះបរិត្តឱ្យចេះរត់មាត់ ពុទ្ធវចនៈគម្ពីរបាលី ដើម្បីនឹងរកមធ្យោបាយនៃការប្រតិបត្តិតទៅទៀត ព្រោះហេតុដូច្នេះ អ្នកណាចេះបដិវេធធម៌ ជាការប្រសើរតែអ្នកណា ដែលចេះបដិបត្តិធម៌ថែមទៀត ជាការវិសេសវិសាលណាស់ទៅទៀត[១] ។ ប្រសិនបើចេះតែទ្រឹស្តី ហើយមិនបានប្រតិបត្តិ តើទ្រឹស្តីនោះ មានប្រយោជន៍អ្វី ? ចេះគម្ពីរ ៨៤០០០ ព្រះធម្មក្ខន្ធ តែមិនយកធម៌ណាមួយមកជាមូលដ្ឋាននៃការប្រតិបត្តិឈ្មោះថា ល្ងង់ទៅវិញ " អាចារ្យស្លឹករឹត" ។ ម្យ៉ាងទៀតចេះតែទូន្មានប្រដៅអ្នកដទៃ ត្រង់ខ្លួនឯងមិនប្រព្រឹត្តទៅតាមគន្លងធម៌ ប្រព្រឹត្តតែបាបអកុសល

១- រាយប៉ុក ព្រះពុទ្ធសាសនានៃប្រទេសកម្ពុជា ឆ្នាំ ១៩៥៧ ទំព័រ ៦៩-៧០

រហូតយោងខ្លួនមិនផុតពីអបាយភូមិទាំងបួន ។ នេះជាបញ្ហាមួយពិបាកបំផុត ពិបាកត្រង់មនុស្ស មិនសូវប្រើប្រាស់វិចារណញ្ញាណ គេច្រើនប្រើតែតាមទម្លាប់ច្រើនជាង ។ នេះឈ្មោះថា ប្រមាទខ្លួនឯងពេញលក្ខណៈ ហើយអ្នកណាប្រមាទអ្នកនោះ នឹងស្លាប់ នឹងទៅកាន់សេចក្ដីវិនាស សោយទុក្ខលំបាក អស់សែនកល្បសមដូចពុទ្ធភាសិត នៃគម្ពីរធម្មបទខុទ្ទកនិកាយ ទ្វេសហាយិភិក្ខុវត្ថុថា :

ពហុម្បិ ចេ សហិតំ ភាសមានោ ន តក្ករោ ហោតិ នរោ បមត្តោ គោវបាវគាវោ គណយំ បរេសំ នភាគវា សាមញ្ញស្ស ហោតិ ។

បើថាបុគ្គលពោលធម៌ ដែលមានប្រយោជន៍សូម្បីច្រើន តែថាបុគ្គលប្រមាទមិនធ្វើតាមធម៌នោះ គេរមែងថាអ្នកមិនមានចំណែក នៃសាមញ្ញផល ដូចបុគ្គលចិញ្ចឹមគោ កាលរាប់គោទាំងឡាយ ឱ្យដល់ជនទាំងឡាយដទៃ ។

ព្រោះហេតុដូច្នេះ ការចេះតែពុទ្ធភាសិតមួយមាត់ ហើយប្រតិបត្តិតាមប្រសើរជាងអ្នកចេះគម្ពីរ ៨៤០០០ ព្រះធម្មក្ខន្ធ ហើយមិនប្រព្រឹត្តប្រតិបត្តិតាមសមដូចពុទ្ធភាសិតពោលថា :

អប្បម្បិ ចេ សហិតំ ភាសមនោ ធម្មស្ស ហោតិ អនុធម្មចារី រាគញ្ច ទោសញ្ច បហាយ មោហំ សម្បជានោ សុវិមុត្តចិត្តោ អនុបាទិយានោ ឥធ វា ហុរំ វា សភាគវា សាមញ្ញស្ស ហោតិ ។

ថាៈ បើបុគ្គលពោលធម៌ ដែលមានប្រយោជន៍សូម្បីតិច តែជាអ្នកប្រព្រឹត្តធម៌ សមគួរដល់ធម៌ លះរាគៈ ទោសៈ និងមោហៈបាន ជាអ្នកដឹងសព្វគ្រប់ មានចិត្តផុត ហើយដោយល្អ មិនប្រកាន់ក្នុងលោកនេះ ឬក្នុងលោកដទៃ រមែងជាអ្នកមានចំណែកនៃសាមញ្ញផល ។

ដោយហេតុនេះឯង, បានជាទ្រឹស្តីព្រះពុទ្ធសាសនា ត្រូវរៀនឱ្យចេះចាំក៏ពិតមែនហើយ តែត្រូវមានការប្រតិបត្តិអមផង ទើបបានផល បានប្រយោជន៍ គឺថាត្រូវមានវិបស្សនាធុរៈថែមទៀត ។

អ្វីដែលហៅថាវិបស្សនាធុរៈ ? វិបស្សនាធុរៈគឺការធ្វើចិត្តរបស់ខ្លួន ឱ្យផូរផង់ គឺការប្រព្រឹត្តតាមធម៌ និងវិន័យព្រះពុទ្ធសាសនា ប្រៀបដូចថា គន្ថធុរៈ ជាមុខរបស់យើង វិបស្សនាធុរៈជាកញ្ចក់ កញ្ចក់តែងឆ្លុះមុខ ឱ្យឃើញថាមុខស្អាត ឬប្រឡាក់អ្វី សាច់គគ្រើម ឬម៉ដ្ឋជាដើម យ៉ាងណាមិញ គន្ថធុរៈ ដែលជាទ្រឹស្តីព្រះពុទ្ធសាសនា ទុកជាមុខរបស់យើង វិបស្សនាធុរៈជាកញ្ចក់ឆ្លុះឱ្យឃើញ គន្ថធុរៈនោះៗ មានសភាព យ៉ាងណា ។ វិបស្សនាធុរៈជាអ្នកសាកមើល ឱ្យដឹងថាគន្ថធុរៈនោះ បានផលយ៉ាងណាខ្លះ ព្រោះថា គន្ថធុរៈជាបច្ច័យ ឱ្យកើតវិបស្សនាធុរៈ គន្ថធុរៈជាហេតុ វិបស្សនាធុរៈជាផល គន្ថធុរៈជាភ្លើង វិបស្សនាធុរៈជាផ្សែង[២] ។

បើមានតែគន្ថធុរៈ មិនមានវិបស្សនាធុរៈ ប្រៀបដូចជាមានពូថៅគ្មានឈើ បើមិនយកពូថៅទៅពុះឈើ ឱ្យទាល់តែឈើនោះបែក ក៏មិនអាចដឹងនូវសភាពឈើនោះ ជារឹង ឬទន់បាន ។ ព្រោះហេតុដូច្នេះ បើចង់ដឹងថា ពុទ្ធភាសិតណាមួយមានឱជារសយ៉ាងណា ត្រូវយកពុទ្ធភាសិតនោះ ទៅអនុវត្ត តើបានផលល្អ ឬអាក្រក់ ? ព្រះសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់មិនឱ្យអ្នកណាជឿព្រះអង្គភ្លាមទេ ព្រះអង្គគ្រាន់តែជាអ្នកបង្ហាញផ្លូវថា "នេះផ្លូវទៅកាន់ឋានសួគ៌ ស្ថានព្រហ្ម ស្ថានព្រះនិព្វាន នេះជាផ្លូវទៅកាន់អបាយភូមិបួនជាដើម ត្រង់ដើរទៅ ឬមិនដើរទៅកាន់ផ្លូវនោះ ស្រេចនៅលើអ្នកទាំងឡាយ ។ ព្រោះហេតុដូច្នេះត្រូវប្រព្រឹត្តគន្ថធុរៈ និងវិបស្សនាធុរៈទាំងពីរ គឺ

---

២- ជ.ម. ទំព័រ ៧១-៧២

ប្រព្រឹត្ត ទាន សីល ភាវនា ចំពោះគ្រហស្ថ សីលសមាធិ បញ្ញាចំពោះបុព្វជិត ធ្វើចរិយាខ្លួន ឱ្យបានត្រឹមត្រូវ ញ៉ាំងចិត្តរបស់ខ្លួន ឱ្យស្អាតបរិសុទ្ធ ធ្វើនីវរណធម៌ ឱ្យទ្រុតទ្រោមថយចុះ បំផ្លាញអាសវក្កិលេស ឱ្យឆ្ងាយចាកសន្តាន បើកទ្វារព្រះនិព្វាន្ត ឱ្យឃើញភ្លឺត្រចះត្រចង់ដូចបុប្ផាបទុម ពិតមែនតែដុះក្នុងភក់ស្អុយ តែមានក្លិនក្រអូបឈ្ងុយឈ្ងប់ គឺចេះធ្វើកាយកម្មបី វចីកម្មបួន មនោកម្មបី ឱ្យមានរបៀបរាបសា ឱ្យមានប្រយោជន៍ទាំងបី ឱ្យប្រកបការជាកុសល ឱ្យប្រព្រឹត្តតែបុណ្យ លះបាបចោលចេញ ធ្វើសមាធិចិត្ត ចម្រើនមេត្តា ភាវនា ឱ្យទាល់តែចិត្តនោះស្ងប់ស្ងាត់ស្រួលបានសេចក្ដីសុខក្នុងពេលនោះ ដូចពុទ្ធភាសិតសំដែងថា : "ចិត្តំ ទន្តំ សុខាវហំ, កិរិយាហាត់នូវចិត្តបាន១ សេចក្ដីសុខគ្រប់យ៉ាង[៣]" ។

ម្យ៉ាងវិញទៀត ត្រូវសេពគប់បណ្ឌិតអ្នកប្រាជ្ញ ធ្វើតាមពាក្យលោកទូន្មានប្រដៅ ឧស្សាហ៍ស្ដាប់ធម៌ទេសនា ព្យាយាមទៅកាន់ទី ដែលមានសប្បុរស សាកសួរធម៌អាថ៌ ប្រស្នារកខុសត្រូវ បើខ្លួនល្ងង់ត្រូវឱ្យដឹងថាល្ងង់ បើខ្លួនចេះត្រូវឱ្យដឹងថាចេះ ព្រោះថា :

"ចេះ, ខ្ញុំចេះ មិនចេះទេ ខ្ញុំមិនចេះទេ, ទើបហៅថាចេះ" ។

ល្ងង់ធ្វើខ្លួនជាចេះនាំទៅកាន់សេចក្ដីវិនាស ល្ងង់ដឹងថាខ្លួនល្ងង់ ទើបដេញល្ងង់យកចេះមកវិញបាន ចេះធ្វើខ្លួនជាចេះហៅថា ចេះល្មម ចេះធ្វើខ្លួនជាល្ងង់ហៅថាចេះពិត ចេះប្រសើរចេះថ្លៃថ្លា ។

ដោយហេតុនេះឯង បានជាជនជាតិខ្មែរ និយមកាន់ព្រះពុទ្ធសាសនា ព្រោះជាសាសនានាំទៅកាន់ផ្លូវកណ្ដាល មិនតឹងពេក មិនធូរពេក លះបង់កាមសុខ

---

៣ - ជ.ម. ទំព័រ ៧៣

ល្លិកានុយោគ និងអត្តកិលមថ្ងានុយោគ ដែលជាផ្លូវយកកាមជាមូលដ្ឋាន និងធ្វើបាបរូបកាយឥតប្រយោជន៍ ។ ត្រង់នេះចង់បញ្ជាក់អំពីជន ដែលចេះប្រើប្រាស់ព្រះធម៌បានត្រឹមត្រូវមិនមែននិយាយដល់ខ្មែរគ្រប់រូបទេ ។

ផ្លូវកណ្តាល ជាផ្លូវលំបាកមែនពិត តែបើអ្នកណាព្យាយាមត្រាប់ទៅតាមផ្លូវនេះ ពិតមែនតែមានសត្វសាហាវនៅចាំស្កាត់ផ្លូវ ចោរនៅចាំធ្វើបាបអ្នកដំណើរ មានឆ្លងកាត់ស្ទឹងបឹងបួរជាច្រើន មានក្រពើរង់ចាំប្រទុស្ត តែមិនយូរមិនឆាប់គង់អ្នកនឹងបានដល់ប្រភពទឹកថ្លាត្រជាក់ ទឹកអម្រឹត ដែលហូរចេញពីស្ថានព្រះនិព្វានមិនខាន ។

ផ្លូវកណ្តាល ជាផ្លូវទៅកាន់ភូមិមួយ ដែលមិនមានកើត ចាស់ ឈឺ ស្លាប់ ផុតចាកទុក្ខទាំងដប់បីកង បានសេចក្តីសុខ លែងទុក្ខ បានសេចក្តីស្រួលលែងភ័យ បានភ័ក្ត្រីកស្រស់ស្រាយ លែងក្រញូវក្រញូប បានសប្បាយ លែងសោកសង្រេង ។

ផ្លូវកណ្តាល ជាផ្លូវលំបាកជាច្រើន ហើយឡើងទៅលើកំពូលភ្នំដ៏ខ្ពស់បំផុតពីស្ថានមនុស្សលោក អបាយភូមិ ស្ថានសួគ៌ ស្ថានព្រហ្ម ជាផ្លូវចោតបាលថ្ងៃ ភ្លៀងខ្យល់ មានជ្រោះគុហា រអាងជ្រៅ មាននាគមានពិសចាំព្រួសអ្នកដំណើរ ឱ្យស្លាប់តាមរយៈឡើងទៅកាន់គីរីសុវណ្ណដ៏ប្រសើរ គឺព្រះនិព្វាន[៤] ។

បើទុកជាលំបាកយ៉ាងណាក៏ដោយ ជនជាតិខ្មែរ ដោយភាគច្រើនបាននាំគ្នាគ្រាប់ទៅតាមផ្លូវ មជ្ឈិមាបដិបទា ដែលព្រះបរមគ្រូសម្តេចជាម្ចាស់ បានត្រាយទុកហើយបានក្រេបរសជាតិ សេចក្តីសុខតិចច្រើនគ្រប់ៗគ្នា ហើយយល់ថា ធម៌ព្រះអង្គជាសន្ទិដ្ឋិកោ គឺដឹងច្បាស់ ឃើញច្បាស់ ដោយខ្លួនឯងពិតប្រាកដ ។

---

៤- ជ.ម. ទំព័រ ៧៤

ព្រះពុទ្ធសាសនា មានថ្នាក់ទាប កណ្ដាល ខ្ពស់ ក្នុងសង្គមបានជនជាតិខ្មែរពេញចិត្តយកទៅប្រព្រឹត្តប្រតិបត្តិ ដើម្បីបំបាត់នូវ លោភៈ ទោសៈ មោហៈ ដែលជាឫសគល់ នៃបាបអកុសលទាំងឡាយ ការបំពេញនូវទាន សិល ភាវនា អាចញ៉ាំងកាយ វាចា ចិត្ត ឱ្យមានរបៀបរៀបរយ ធ្វើចិត្តឱ្យមានសភាពតក់ស្លុត និងសត្វសង្ខារ លះបង់អាសវក្កិលេស ដែលជាគ្រឿងជ្រមុជសត្វ ឱ្យលិចលង់ទៅក្នុងសមុទ្រសង្សារ ហើយមគ្គជាកុសលបានស្រង់សត្វពីសមុទ្រនោះ ដាក់ទៅខាងត្រើយនាយ គឺព្រះនិញ្វន ។

កំណត់: *ព្រះធម៌ព្រះពុទ្ធមិនមែនសុទ្ធតែរឹងកម្រើសនោះទេ ពុទ្ធសាសនិក គួរតែជ្រើសរើសផ្លូវណាមួយ ប្រកបដោយបញ្ញា មិនថាពេលណា ឬពេលណាទេ ឱ្យតែអ្នកប្រតិបត្តិចេះស្គាល់កាល ស្គាល់គំរិតនៃហេតុការនោះៗ ពិតជាអាចទទួលនូវលទ្ធផលល្អ សម្រាប់ជីវិតជានិច្ច ។*

*ប៉ុន្តែទោះបណ្ដាំព្រះពុទ្ធក្ដី គម្ពីរចងក្រងវិសេសវិសាលរបស់ព្រះពុទ្ធក្ដី មិនប្រាកដជាទទួលបានជោគជ័យទេ ប្រសិនបើអ្នករៀនអ្នកសិក្សា មិនយកទៅប្រើប្រាស់ ឱ្យបានសមស្រប គួរចៀសវាងការប្រតិបត្តិ ទាំងងងឹតងងល់ ។*

*នេះជាអត្ថន័យនៃអត្ថបទរបស់ខ្ញុំ ដែលស្ដីអំពី " ការរីកចម្រើននៃព្រះពុទ្ធសាសនា ក្នុងជីវិតខ្មែរ " ក្នុងកម្ពុជសុរិយា លេខ ៤ ២០០២ នេះ ។*

*(នៅមានត)*

# ប្រវត្តិរបាំក្បាច់បុរាណ

ដោយ : ពេជ្រ ឆុំក្រវិល

នៅប្រទេសកម្ពុជាមានពាក្យពីរម៉ាត់ សម្រាប់សម្គាល់ទម្រង់សិល្បៈទស្សនីយភាព ក្បាច់បុរាណនេះ គឺ:

*១- របាំ ឬល្ខោនក្បាច់បុរាណខ្មែរ*

*២- របាំ ឬល្ខោនព្រះរាជទ្រព្យ*

ឯពាក្យថា របាំ និងល្ខោនក្នុងទីនេះ ក៏សម្រាប់គូសបញ្ជាក់ពីភាពខុសគ្នាខ្លះៗ នៃទម្រង់សិល្បៈនេះ ក្នុងឱកាសសំដែងម្តងៗផងដែរ ។ ឧទាហរណ៍ជាក់ស្តែង កាលណាទម្រង់ក្បាច់បុរាណនេះ សំដែងជាទ្រង់ទ្រាយរបាំដាច់ៗតែឯង ដូចជារបាំជូនពរ របាំអប្សរា របាំទេពមនោរម្យជាដើមនោះ គេច្រើននិយមប្រើពាក្យថា : របាំក្បាច់បុរាណខ្មែរ ឬ របាំព្រះរាជទ្រព្យ ។ ប៉ុន្តែបើទម្រង់ដដែលនេះ សំដែងជាសាច់រឿងផ្សេងៗ ដូចជារឿងរាមកេរ្តិ៍ រឿងព្រះជិនវង្ស រឿងព្រះកេតុមាលា ឬរឿងព្រះថោងនាងនាគ ជាដើមនោះ គេច្រើននិយមហៅថា : ល្ខោនព្រះរាជទ្រព្យ ឬ ល្ខោនក្បាច់បុរាណខ្មែរទេវិញ ។

ចំពោះប្រភព និងកាលបរិច្ឆេទកំណើត នៃទម្រង់សិល្បៈរបាំ ឬល្ខោននេះនៅលើទឹកដីកម្ពុជាវិញ មិនមានឯកសារណានិយាយប្រាប់យើង ឱ្យបានច្បាស់ប្រាកដប្រជាថា កើតនៅខែណា ឬឆ្នាំណាទេ ? ប៉ុន្តែតាមការសិក្សាស្រាវជ្រាវ ដោយពឹងផ្អែកទៅលើការ គាស់កកាយរកវត្ថុបុរាណ ... សិក្សាពីរូបចម្លាក់តាមប្រាសាទបុរាណនានា ... ការសិក្សាសិលាចារឹក និងការសិក្សាអំពីទំនៀមទម្លាប់ ប្រពៃណីផ្សេងៗ នាំ

ឱ្យយើងមានការចាប់អារម្មណ៍យ៉ាងខ្លាំង ហើយសាកល្បងសន្និដ្ឋានថាៈ ទម្រង់សិល្បៈក្បាច់បុរាណនេះ ប្រហែលជាយោនយកកំណើត នៅលើទឹកដី នៃប្រទេសកម្ពុជា តាំងពីសម័យនគរភ្នំ ( ស.វ ទី ១ ដល់ ស.វ ទី ៦ នៃគ.ស ) មកម្ល៉េះ ពីព្រោះ :

ក - នៅចន្លោះឆ្នាំ ១៩៧៩-១៩៩០ ពិតមែនតែបរិយាកាសក្នុងប្រទេសបានប្រសើរជាងមុនខ្លះ ដោយរបបប្រល័យពូជសាសន៍ ប៉ុល-ពត ខ្មែរក្រហមបានដួលរលំផុតទៅហើយ ប៉ុន្តែ សង្គ្រាមរវាងខ្មែរ នឹងខ្មែរ នៅតែបន្តនៅតាមតំបន់ផ្សេងៗ ពិសេសគឺតាមព្រំប្រទល់ខ្មែរ-ថៃ ។ ឆ្លៀតឱកាស ដែលមាតុភូមិនិងប្រជាពលរដ្ឋយើង កំពុងតែជួបការលំបាកនេះ ឈ្មួញទុច្ចរិត ទាំងខ្មែរ ទាំងបរទេស ដែលមានគំនិតខិលខូច ពិសេសគឺចង់បំផ្លាញ ឱ្យអស់សម្បត្តិវប្បធម៌ខ្មែរនោះ បានបំផុសចលនា ដោយអាចិកំបាំង ទិញយកវត្ថុបុរាណ ដែលលួចបានពីកម្ពុជាក្នុងតម្លៃថ្លៃបង្ហួរ ។ គាប់ជួនពេលនោះ ជីវភាពរបស់ប្រជាពលរដ្ឋខ្មែរយើង នៅក្រីក្រលំបាកតោកយ៉ាក រួមផ្សំនឹងការយល់ដឹងនៅមានកម្រិតទាបនៅឡើយ ជនជាតិខ្មែរមួយចំនួន ទាំងជនសាមញ្ញ ទាំងអ្នកមានអំណាច ក៏បានធ្លាក់ចូលក្នុងអន្ទាក់ នៃការបំផ្លាញវប្បធម៌ជាតិរបស់ខ្លួននេះ ដោយមិនដឹងខ្លួន ? ឬក៏ដោយបំពាន ? នៅគ្រប់ទីកន្លែង ដែលមានប្រាសាទបុរាណ ឬក៏តំបន់ប្រវត្តិសាស្ត្រ ទោះនៅក្នុងព្រៃជ្រៅ ឬក៏ក្នុងស្រុកភូមិ ទីប្រជុំជនក្តី គេឃើញមានការលួចគាស់កកាយ លួចយកបដិមា រូបចម្លាក់ ឬវត្ថុបុរាណផ្សេងៗ យ៉ាងសកម្មបំផុត នៅទូទាំងផ្ទៃប្រទេស ... ដូចជានៅខេត្តសៀមរាប ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តព្រះវិហារ ខេត្តកំពង់ធំ កំពង់ចាម កំពង់ស្ពឺ កណ្តាល តាកែវ ។ល។ ក្នុងនោះមានទាំងអង្គរបុរី ដែលមានទីតាំងនៅខេត្តតាកែវ ហើយដែលជារាជធានី ដ៏ចាស់មួយរបស់រាជាណាចក្រនគរភ្នំពីចន្លោះ ស.វ ទី ១ ដល់ ស.វ ទី ៦ នៃគ.ស ក៏ត្រូវបានប្រជាពលរដ្ឋយើងជីកគាស់

កកាយរកវត្ថុបុរាណ យ៉ាងអាណាធិបតេយ្យ និងគគ្រិកគគ្រេងផងដែរ ។



*រូបចម្លាក់ "ស្រីរបាំ" ធ្វើពីដីដុត គាស់យកបានពីក្នុងបរិវេណវត្តត់នូរ*
*(អង្គរបុរី ព្រៃប្បាស់ ខេត្តតាកែវ)*

ក្នុងការគាស់កកាយនេះ វត្ថុបុរាណដែលមានអាយុរាប់ពាន់ឆ្នាំមកហើយ រាប់សិបមុខបានក្លាយទៅជាមុខទំនិញ ដែលត្រូវបញ្ជូនបន្តគ្នាពីដៃអ្នកគាស់ ទៅដៃឈ្មួញកណ្ដាល ហើយទីបំផុតក៏ធ្លាក់ទៅក្នុងកណ្ដាប់ដៃឈ្មួញធំ ដែលភាគច្រើនវត្ថុទាំងនោះ ត្រូវដឹកចេញ ដោយលួចលាក់ទៅលក់ឯបរទេស ។ ក្រៅពីនេះ ក៏មានវត្ថុបុរាណតិចតួចផងដែរ ដែលក្រសួងមានសមត្ថកិច្ចបានឃាត់ទុកបាន ក្នុងនោះក៏សុទ្ធតែជាវត្ថុបុរាណ ដែលមានអាយុរាប់ពាន់ឆ្នាំមកហើយដែរ ដូចជាចម្លាក់លើមាស សន្លឹក សរីទ្ធិ ក្រឡ ពួច រូបបដិមាផ្សេងៗ គ្រឿងតុបតែងលំអកាយ ការពាក់ត្រចៀក ក្រវិល ទុំហូ អង្កាំដែរ កងដៃ កងជើង ចិញ្ចៀន ប្រដាប់ប្រដាប្រើប្រាស់ផ្សេងៗ ក្នុងសម័យនគរភ្នំ ក្នុងនោះយើងបានជួបប្រទះ នឹងរូបស្រីរបាំ ដែលជាចម្លាក់

ដីដុត ហើយនិងរូបស្វា ទំនងជារូប (ហនុមាន) កាន់ដំបងយ៉ាងវែងផងដែរ ។

បើតាមពិតមាន រូបស្រីរបាំ និងរូបហនុមានកាន់ដំបងនេះ ត្រូវគេគាស់យកបានពីក្នុងបរិវេណវត្ត "គំនូរ" ដែលស្ថិតនៅចំកណ្ដាលទីតាំងនៃរាជធានី រាជាណាចក្រនគរភ្នំនោះឯង ហើយក៏ដោយសារតឹកតាងនេះហើយ ដែលនាំឱ្យយើងមានការសង្ស័យថា : របាំក្បាច់បុរាណ ឬរបាំព្រះរាជ្យទ្រព្យនេះ ប្រហែលជាបានចាប់កំណើតនៅលើទឹកដីកម្ពុជានេះ តាំងពីសម័យនគរភ្នំមកម្ល៉េះ ពោលគឺការចម្លងតាមបែបផែនរបាំឥណ្ឌា ដែលទំនាក់ទំនងយ៉ាងជិតស្និទ្ធ និងលទ្ធិព្រាហ្មណ៍ ហើយទំនងជាហូរចូលមកតាមរយៈពួកព្រាហ្មណ៍នោះឯង ដូចជារឿងរាមកេរ្តិ៍ " Ramayana " ដូច្នេះដែរ ។ ប៉ុន្តែបើយើងសាកល្បងពិនិត្យពីរូបភាពស្រីរបាំ នៃរូបចម្លាក់ដីដុតនោះ យើងឃើញហាក់ឃ្លាតឆ្ងាយគ្នាណាស់ ពីរបាំបុរាណខ្មែរសព្វថ្ងៃ ព្រោះថា ទ្រង់ទ្រាយ ឬកាយវិការ នៃស្រីរបាំនោះ មានលក្ខណៈដូចគ្នាបេះបិទ និងរបាំឥណ្ឌាខ្លះ ដែលយើងធ្លាប់ឃើញគេរាំរហូតមកដល់សព្វថ្ងៃនេះ ។ ពិសេសគឺកាយវិការជើងកន្ធែកហាក់សង្កត់ទម្ងន់លើជើងទាំងពីរ ក្នុងលក្ខណៈបន្ទាត់កាច់ "Ligne brisée" ? ហើយចុងជើងទាំងពីរកន្ធែកចេញក្រៅ ។ ឯដៃទាំងពីរលើកឡើងលើខ្ពស់អមសងខាងក្បាល បញ្ចុកកែងដៃ កន្ធែកម្រាមដៃខាងឆ្វេងចេញក្រៅ ឯម្រាមដៃខាងស្ដាំចូលក្នុង ក្នុងកាយវិការប្រើបន្ទាត់កាច់ដូចគ្នាដែរ ។

លក្ខណៈខុសប្លែកគ្នារវាងរូបចម្លាក់ "ស្រីរបាំ" ធ្វើពីដីដុត ដែលយើងបានស្មានថា ជាស្នាដៃ ដែលកើតឡើងក្នុងសម័យនគរភ្នំ ស.វទី១ ដល់ ស.វ ទី៦ នៃគ.ស និងរូបភាពរបាំក្បាច់បុរាណខ្មែរ ឬរបាំព្រះរាជ្យទ្រព្យ ដែលមានបច្ចុប្បន្ននេះ ហើយដែលភាគច្រើន ប្រើកាយវិការ ដោយបន្ទាត់កោង " Linge courbe " នាំឱ្យយើងនឹកឃើញដល់ការរៀនសាងប្រាសាទ របស់ជនជាតិខ្មែរ ដែលទទួលមេរៀនជា

ដំបូងៗមកពីឥណ្ឌា ហើយពីមួយថ្ងៃទៅមួយថ្ងៃ ច្រើនសតវត្សរ៍ទៅ ... ខ្មែរបានស្វែងមករកបុគ្គលិកលក្ខណៈពិសេសរបស់ខ្លួន រហូតដល់អាចកសាងប្រាសាទអង្គរវត្ត ដែលអស់លោកអ្នកជំនាញខាងបុរាណវិទ្យាឥណ្ឌាពោលថា: ប្រហែលជាប្រាសាទខាងព្រហ្មញ្ញសាសនា ដែលធំជាងគេក្នុងពិភពលោកបានថែមទៀតផង ។ ឯទំនាក់ទំនងរបស់ទម្រង់ល្ខោនក្បាច់បុរាណខ្មែរ ឬរបាំព្រះរាជ្យទ្រព្យ ដែលបានយោនកំណើតដោយចម្លងតាមគំរូ នៃរបាំខាងព្រហ្មញ្ញសាសនាឥណ្ឌា ហើយពីមួយថ្ងៃទៅមួយថ្ងៃច្រើនសតវត្សរ៍ទៅបែរមករកលក្ខណៈជាខ្មែរនោះ ក៏គង់មានលំអានវិវត្តន៍រីកចម្រើនមិនខុសអ្វីពីដំណើរវិវត្តន៍ នៃប្រាសាទបុរាណខ្មែរដូច្នេះឡើយ ។

ខ- ចំណុចម្យ៉ាងសំខាន់ទៀត គឺការសិក្សាសិលាចារឹករបស់អ្នកឯកទេសខាងភាសាសំស្ក្រឹត និងខ្មែរបុរាណ ដែលបានរកឃើញឯកសារ ដ៏មានសារៈសំខាន់ជាច្រើនទាក់ទងនឹងប្រវត្តិសាស្ត្រ ជំនឿសាសនា ទំនៀមទម្លាប់ប្រពៃណី វប្បធម៌សិល្បៈ ល្ខោន របាំ តន្ត្រី សព្វបែបយ៉ាង ដែលមានអាយុពីយូរលង់ច្រើនសតវត្សរ៍មកហើយ ហើយសុទ្ធតែជាស្នាដៃរបស់បុព្វបុរស ដូនតាខ្មែរបានបន្សល់ទុកមក ជាក់ស្តែងនៅក្នុងអត្ថបទសិក្សា ដែលមានចំណងជើងថា: Music and Dance in Ancient Cambodia as Evidenced by old Khmer Epigraphy របស់អ្នកស្រី ពៅ សាវរស់ អ្នកស្រីបានដកស្រង់នូវភស្តុតាងជាក់លាក់ ជាពាក្យសំដីឬឈ្មោះ ជាសំស្ក្រឹតនិងខ្មែរបុរាណ ដែលមានចារទុកក្នុងផ្ទាំងសិលាចារឹក មានកាលបរិច្ឆេទត្រឹមត្រូវ ទៅតាមរជ្ជកាលសោយរាជ្យ នៃព្រះមហាក្សត្រខ្មែរនានាច្បាស់លាស់ស្តីអំពីល្ខោនភាណី ដែលប្រហែលជាទម្រង់ល្ខោន " ខោល " សព្វថ្ងៃ... ។ គ្រូភាណីតន្ត្រីការប្រគំគ្រឿងដំ សម្រាប់កំដរល្ខោនភាណី ដែលមានសុទ្ធតែប្រុសៗ ... ។ វង់ភ្លេងមហោរី ដែលប្រហែលក្លាយមកពីពាក្យថា: មនោហោរា មនោហោរី... ។

សិល្បៈការិនីសម្តែងសិល្បៈកក្កតា គួតក្កតា ។ល។ ហើយក្នុងនោះ ក៏មានសិលាចារឹក លេខ K៥៥៧ និង K600 និងសិលាចារឹក លេខ K=១៣៧ រកឃើញក្នុងវត្តគំនូរ អង្គរបុរី ជាសិលាចារឹក ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី ១ ដែលបានរៀបរាប់អំពី ដង្វាយ ជាអ្នកចម្រៀង និងឧបករណ៍ភ្លេង និងរបាំ ចំពោះទេវស្ថាននៅទីនោះ ។ ប្រហែលជាព្រះបាទជ័យវរ្ម័នទី ១ ព្រះអង្គឯងទ្រង់បាន ឧទ្ទិសក្រុមសិល្បៈស្រី "Ballet Girl" ថ្វាយចំពោះអាទិទេពថែមទៀតផង ។

ចំណុចនេះយើងជឿថា : បើព្រះបាទជ័យវរ្ម័នទី ១ (៦៥៥-៦៨១) ជាព្រះរាជាឥសូរនិយមបានឧទ្ទិស "ក្រុមសិល្បៈស្រី" ដល់អាទិទេព ពិសេសគឺព្រះឥសូរ ក្នុងរាជព្រះអង្គនោះ នោះទម្រង់សិល្បៈរបាំស្រីនេះ គង់មានកំណើតយ៉ាងយូរ តាំងពីមុនពេលនោះមិនខាន មុននឹងក្លាយជាដង្វាយ ដ៏គាប់ព្រះទ័យរបស់ព្រះអាទិទេព នោះ ។

គ- រឿងរ៉ាវមួយទៀត ដែលកើតឡើងក្នុងសម័យអាណាចក្រចេនឡា គឺការកកើតជាខ្សែសូរ្យវង្ស ឬអាទិច្ចវង្សគឺវង្សស្រីកម្ពុ ដោយមានការចងសម្ព័ន្ធ របស់ឥសីកម្ពុស្វ័យម្ភូវ និងនាងអប្សរមេរា ដូចមានកត់ត្រាទុកក្នុងសិលាចារឹកបក្សីចាំក្រុង (ស.វ ទី ១០) ដែលបាននិទានថា: ស្តេចខ្មែរយើងមានកំណើតមកពីឥសីកម្ពុស្វ័យម្ភូវ និងនាងអប្សរមេរា ដែលព្រះឥសូរបានប្រទានឱ្យជាមហេសី ។

ព្រឹត្តការណ៍វាយលុកយកនគរហ្វូណន (នគរភ្នំ) ឆ្នាំ ៥០០ ដើម្បីបង្កើតជារាជាណាចក្រខ្មែរ រហូតដល់មានព្រឹត្តការណ៍ ចងភ្ជាប់គ្នារវាងកូនចៅឥសីកម្ពុ ខ្សែសូរ្យវង្ស ខាងផ្នែកចេនឡា ព្រះនាមព្រះបាទភវវរ្ម័ន ទៅនឹងខាងសោមវង្សផ្នែកខាងនគរភ្នំ គឺព្រះនាងកម្ពុរាជលក្សីថែមទៀតនោះ តើមានទាក់ទងអ្វី នឹងកំណើតនៃរបាំស្រីនេះទេ ? តើអប្សរមេរា ដែលព្រះឥសូរប្រទានជាមហេសី ដល់ឥសីកម្ពុ

ស្វ័យម្ភូវក្នុងទីនេះ មានទាក់ទងអ្វី នឹងដើមកំណើតទម្រង់សិល្បៈ ល្ខោន ក្បាច់បុរាណខ្មែរ ឬរបាំព្រះរាជទ្រព្យ ដែលមានសេសសល់រហូតដល់ថ្ងៃនេះ ឬទេ ? ម្យ៉ាងទៀតយើងក៏បានជួបប្រទះផងដែរ នូវគំនិតរបស់អស់លោកអ្នកប្រាជ្ញ អ្នកស្រាវជ្រាវច្រើន ដែលបានពន្យល់ថាៈ ពាក្យថា :កម្ពុជា ឬខ្មែរ ដែលយើងប្រើសព្វថ្ងៃនេះ ក៏គឺជាលទ្ធផល ដែលបានមកពីការចងសម្ព័ន្ធរវាងឥសីកម្ពុជស្វ័យម្ភូវ និងអប្សរមេរានេះដែរ ព្រោះបើយើងអានប្រមៀលពាក្យ កម្ពុ មេរា នេះ បន្តិចម្តងៗ ក៏នឹងបានទៅជាពាក្យខ្មែរដូច : កម្ពុ + មេរា »កម្ពុ មេរ » កម៉ + មេរ » កម្មេរ » ក្មេរ » ខ្មែរ នេះឯង ។

*កាលដែលយើងខ្ញុំលើកយកចំណុច :*

ក- ចម្លាក់រូបស្រីរាំ និងហនុមានកាន់ដំបង ធ្វើអំពីដីឥដ្ឋដុតរកឃើញនៅក្នុងបរិវេណវត្តគំនូរអង្គរបុរី...

ខ- ការសិក្សាអំពីសិលាចារឹក លេខ K=៥៥៧ និង K៦០០ ជាសិលាចារឹកអង្គរបុរី និងសិលាចារឹក K=១៣៧ ដែលបានចែងថាៈ ប្រហែលជាព្រះបាទជ័យវរ្ម័នទី ១ (៦៥៥-៦៨១) បានឧទ្ទិសក្រុមរបាំស្រីថ្វាយព្រះឥសូរ... ។

គ- ព្រឹត្តការណ៍ចងភ្ជាប់គ្នារវាងខ្សែសូរ្យវង្ស ខាងចេនឡា និងខ្សែសោមវង្ស ខាងនគរភ្នំ... ដែលយើងខ្ញុំយល់ថាៈ ជាព្រឹត្តការណ៍ ដែលមានទាក់ទងទៅនឹងការកកើតទម្រង់សិល្បៈរបាំក្បាច់បុរាណ ឬរបាំព្រះរាជទ្រព្យខ្មែរនេះ ព្រោះយើងខ្ញុំមានការសង្ស័យផង និងមានជំនឿផងថាៈ ទម្រង់សិល្បៈនេះ ប្រហែលជាបានយោនយកកំណើតនៅលើទឹកដីកម្ពុជា ដោយចម្លងតាមរបាំ នៃព្រហ្មញ្ញសាសនាឥណ្ឌា នៅក្នុងសម័យហ្វូណន ឬនគរភ្នំ (ស.វទី១ ដល់ ស.វទី៦) ឬយ៉ាងហោចណាស់ក៏ប្រហែលជាកើតនៅសម័យចេនឡា (ស.វទី៧ -ស.វទី៨ នៃគ.ស) ពោលគឺមុនសម័យអង្គរជាក់ជាមិនខាន ។ ម្យ៉ាងទៀតយើងខ្ញុំមានជំនឿផងដែរថា : ក្រោយពីពេលបាន

យោនយកកំណើតមក ទម្រង់សិល្បៈរបាំឬល្ខោនស្រីនេះ ក៏ដូចជាទម្រង់សិល្បៈដទៃទៀតដែរ បានវិវត្តនីរីកចម្រើនរុងរឿងឧត្តុង្គឧត្តម ឬក៏ទ្រុឌទ្រោមរហូតដល់ពេលខ្លះអាប់អោន ស្ទើររលាយបាត់រូបស្របគ្នាតាមដំណើរវិវត្តន៍ នៃប្រវត្តិសាស្ត្រជាតិកម្ពុជាថែមទៀតផង ។ ជាក់ស្តែងមកដល់សម័យអង្គរ ដែលចាប់ផ្តើមឡើងពីរាជព្រះបាទជ័យវរ្ម័នទី២ (៨០២-៨៥០ )ព្រះមហាក្សត្រ ដែលទ្រង់បានរំដោះ កម្ពុជទេសគឺប្រទេសខ្មែរ ឱ្យរួចផុតពីចំណុះរាជវង្សសៃលេន្រ្ទៈ នៃកោះជ្វា ... ដោយបានប្រារព្ធពិធី "ទេវរាជ" លើភ្នំមហេន្រ្ទបពត៌ (ភ្នំគូលែន) ។ ព្រះអង្គបានសាងប្រាសាទភ្នំជាដំបូងបង្អស់នៅទីនោះ គឺ "ព្រះអារាមរោងចិនសព្វថ្ងៃ ?" ដោយព្រះអង្គមានជំនឿមុតមាំលើព្រះឥសូរ ដល់ពេលព្រះអង្គទ្រង់សោយទិវង្គតទៅ នៅហរិហរាល័យ (រលួស )ព្រះអង្គទ្រង់ទទួលព្រះមរណៈនាមថា បរៈមេសូរៈ ។ រហូតមកដល់ព្រះមហាក្សត្រក្រោយៗ ព្រះអង្គជាច្រើនអង្គ ដែលមានជំនឿដូចគ្នាក្តី ឬខុសគ្នាក្តី ដែលបានសាងប្រាសាទជាច្រើន សាងទំនប់ប្រឡាយ និងអាងទឹកធំសម្បើមៗ... កសាងសង្គម និងកសាងវប្បធម៌ ពោលគឺកសាងអារ្យធម៌ខ្មែរ ឱ្យរីកសុះសាយល្បីរន្ទឺ លើពិភពលោកនោះ យើងជឿថា ទម្រង់សិល្បៈរបាំស្រី "របាំក្បាច់បុរាណ"ឬរបាំព្រះរាជ្យទ្រព្យ" របស់ជនជាតិខ្មែរនេះ ក៏បានរីកចម្រើនលូតលាស់ស្របគ្នា នឹងដំណើររីករុងរឿង នៃអារ្យធម៌អង្គរទាំងមូលនេះដែរ ។ ព្រោះបើយើងពិនិត្យមើលរូបចម្លាក់ទាំងឡាយនៅជញ្ជាំងប្រាសាទខ្លះ ដូចជាប្រាសាទបន្ទាយស្រី (ត្រីភូវនមហេស្វរៈ ) ដែលកសាងឡើងដោយព្រាហ្មព្រះគ្រូ យជ្ញនៈវរៈហៈ (Yajnavaraha) ក្នុងគ.ស ៩៦៧ ឬក៏ជញ្ជាំងប្រាសាទ "អង្គរវត្ត " ស្នាព្រះហស្តរបស់ព្រះបាទសុរិយាវរ្ម័នទី ២ (១១១៣-១១៥២) ដែលគេជឿថា ព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យ គោរពសាសនាព្រាហ្មណ៍ គណៈវិស្ណុ ហើយទ្រង់បានលើកតម្កើងសាសនាព្រាហ្មណ៍នេះ ឱ្យ

មានឋានៈជាសាសនាសម្រាប់រដ្ឋ ។ ក្នុងពេល ដែលព្រះអង្គទ្រង់សោយទិវង្គត់ទៅ ព្រះអង្គទ្រង់ទទួលព្រះមរណៈនាមថា : បរមវិស្ណុលោក នោះគេឃើញមានរូបចម្លាក់ទេពអប្សរ គឺស្រីរបាំនៃឋានសួគ៌ តាំងពីអាគារប្រាង្គកំផែងទិសទាំងបួនខាងក្រៅ រហូតដល់បណ្ដាល័យខាងក្នុងបរិវេណកំផែង... រហូតដល់តួប្រាសាទ ដែលមានចម្លាក់ទេពអប្សរនេះ តាំងពីផ្នែកខាងក្រោម រហូតដល់ផ្នែកកំពូលនៃប្រាសាទ ហើយមានចំនួនច្រើនស្ទើររាប់ពុំអស់ អាចសបញ្ជាក់ថា សិល្បៈរបាំស្រី ជាប្រភេទសិល្បៈទេវៈ ឬរបាំនៃព្រះវិហារនេះ មានការរីកចម្រើនរុងរឿងអស្ចារ្យណាស់ ក្នុងពេលវេលានោះ ។

(នៅមានត)

*កុំថ្កោលទោសគេ ពុំពិនិត្យ*
*កុំគិតខ្លួនឯងថាប្រពៃ*
*កុំថ្វេសប្រហែសពាក្យសំដី*
*នាំឱ្យមានភ័យដល់អាត្មា ។*

សម្ដេចព្រះមហាសុមេធាធិបតី សង្ឃនាយក
គណៈមហានិកាយ ជោតញ្ញាណោ **ជួន ណាត**

# ប្រវត្តិប្រាសាទក្រហម

ដោយ : **សុខ ចេខ**



*ទួលប្រាសាទក្រហម (រូបថត មាស សារ៉េត)*

ប្រាសាទក្រហមស្ថិតនៅចម្ងាយ ២០ គម ភាគខាងលិចឈៀងខាងជើង ពីទីក្រុងស្វាយរៀង ប្រាសាទនេះ ស្ថិតនៅក្នុងភូមិខ្នុរខាងជើង ឃុំស្វាយអង្គ ស្រុកស្វាយជ្រំ ។

តាមការស្រាវជ្រាវពីគ្រប់មជ្ឈដ្ឋាន ក្នុងស្រុកបានឱ្យដឹងថា : ប្រាសាទនេះ គេនិយមហៅឈ្មោះថា : *ទួលប្រាសាទ១ អ្នកខ្លះគេហៅថា ប្រាសាទខាងលិច រីឯអ្នកខ្លះទៀត គេហៅថា : ប្រាសាទក្រហម១* ។

ដូច្នេះ យើងសន្និដ្ឋានថា : ប្រាសាទនេះ ពុំទាន់មានឯកសារណាមួយ និយាយឱ្យបានពិតប្រាកដពីឈ្មោះ នៅឡើយទេ ។ ប៉ុន្តែ សព្វថ្ងៃទួលប្រាសាទនេះ

យើងឃើញមានបន្សល់ទុក នូវវត្ថុតាងមួយចំនួន ដែលគួរឱ្យយើង ចាប់អារម្មណ៍ ពីព្រោះនៅលើទួលប្រាសាទនេះ មានសុទ្ធតែកំទេចឥដ្ឋ និងថ្មបាយក្រៀមរាយពាស-ពេញលើទីទួល ព្រមទាំងមានស្លាកស្នាមត្រួទឹក និងបឹងតូចៗ ជាច្រើនព័ទ្ធជុំវិញទៀតផង ហេតុដូច្នេះទើប យើងសន្និដ្ឋាន ឱ្យឈ្មោះប្រាសាទនេះ ថា (ប្រាសាទក្រហមៗទៅ) ។

សព្វថ្ងៃបើយើងឡើងដល់ទីទួលប្រាសាទ យើងបានឃើញទិដ្ឋភាពប្រាសាទនោះ គួរឱ្យស្រងេះស្រងោច ព្រោះមានភាពខ្ពស់ត្រដែត លើសភូមិរបស់អ្នកស្រុក។ បើតាមការប៉ាន់ស្មាន ទំហំបណ្ដោយនៅសព្វថ្ងៃប្រហែល ១០០ ម ទទឹង ៩០ ម កំពស់ ០១ ម នៅចំកណ្ដាលទួលប្រាសាទ យើងនឹងបានជួបប្រទះថ្មបាយក្រៀមមួយផ្ទាំង មានទំហំ ១.២០ ម បួនជ្រុង ហើយនៅចំកណ្ដាលផ្ទាំងថ្មនោះ មានប្រហោងទំហំ ៣៥ម x ៣៥ម (នេះជាហេតុសម្គាល់ទម្រជើងព្រះវិស្ណុឈរ ) ។



*ទម្រព្រះវិស្ណុឈរ (រូបថត មាស សារ៉េត)*

កាលពីទសវត្សទី ៦៣ ទីទួលប្រាសាទនេះ នៅមានទ្រង់ទ្រាយជាច្រើន មានដើមជ្រៃមួយដើមយ៉ាងធំ បែកមែកត្រឈឹងត្រឈៃចំកណ្ដាលទួល ព្រមទាំងដើមសង្កែជាច្រើនទៀត ដុះទ្រុបទ្រុលពាសពេញលើទួល ប៉ុន្តែ សព្វថ្ងៃយើងឃើញមានសេសសល់ តែផ្លូវលំមួយចូលមករកប្រាសាទ ពីទិសខាងលិច ដែលមានទទឹងប្រហែល ២០ម ប៉ុណ្ណោះ ។ នៅកសិណខាងត្បូង, ខាងកើត និងខាងជើង មានគូទឹកយ៉ាងធំ ហើយជ្រៅព័ទ្ធជុំវិញ គូទឹកនេះអាចរក្សាទឹកបានខួបប្រាំង-ខួបវស្សា ទៀតផង ហើយមានទំហំពី ៦០ម ទៅ ៧០ម ។

នៅខាងក្រៅគូទឹកមានកំពែងថ្ម ទំហំ ៨ម កំពស់ ៣ម ព័ទ្ធជុំវិញមួយជាន់ទៀត សម្រាប់ការពារប្រាសាទ បន្ទាប់មកមានប៉មតូចៗ ចំនួន ១២ កន្លែង សម្រាប់ការពារគ្រប់ទិសទាំង ៨ ផង ដែលមានចម្ងាយ ៥០ម ចេញកំពែង ។ រីឯប៉មទាំង ១២នោះ មានឈ្មោះដូចតទៅ ÷

*១- ប៉មខាងកើត : ឈ្មោះថា: ទួលស្វាយ, ទួលស្រែរាន ឬទួលទាហ៊ាន, ទួលពណ្ណរាយ ឬទួលព្រះនារាយណ៍, និងទួលវៀន ។*

*២- ប៉មខាងត្បូង : មានទួលព្រីង, ទួលព្រះធាតុ, និងទួលស្វាយរាំ ឬទួលស្រីរាំ ឬរោងស្រីស្នំ ។*

*៣- ប៉មខាងលិច : មានទួលសាលា (សម្រាប់ប្រជុំការងារ ឬប្រជុំកាត់ក្ដី) ទួលអង្គ្រង ឬទួលព្រះអង្គគ្រង, និងទួលស្រែបង្គន់ (បង្គន់) ។*

*៤- ប៉មខាងជើង : មានទួលឡ ឬទួលកដប, និងទួលព្រះធាតុ ។*

សូមបញ្ជាក់ថា : ទួលព្រះធាតុនេះមានពីរ : ទួលព្រះធាតុមួយសម្រាប់

ដាក់អដ្ឋិធាតុ អ្នកមានឋានៈធំៗ រីឯទួលព្រះធាតុមួយទៀត សម្រាប់ដាក់អ្នកមានឋានៈទាប ។

សព្វថ្ងៃទួលប្រាសាទ ឬប៉មទាំងអស់នោះ ត្រូវទទួលការគំរាមកំហែងយ៉ាងខ្លាំងក្លាពីប្រជាជន ដោយគាត់កាប់ ភ្ជួរ រាស់ ជារៀងរាល់ឆ្នាំ បណ្ដាលឱ្យភាគខ្លះ នៃប្រាសាទស្ទើរតែបាត់រូបរាងទៅហើយ ។

នៅទិសព្វាយ័ព្យនៃប្រាសាទចម្ងាយ ២០០ម មានទួលមួយទៀតឈ្មោះថា *ទួលដូនពែង ឬទួលដូនពេជ្រ ឬ ភ្នំដូនពេជ្រ មានទំហំ* ៥០មx៤០ម និងមានស្រះទឹកមួយធំ ហើយជ្រៅ នៅជាប់មាត់ស្រះនោះ ចម្ងាយ ៣០ម គេបានលើកដីធ្វើជាភ្នំមួយមានកំពស់ ៥ម (ក្នុងទសវត្សទី ៦៥ ភ្នំដីនោះនៅមានរូបរាងនៅឡើយ ) ។ តែបច្ចុប្បន្នប្រជាជន កាប់ពង្រាបរាបអស់ហើយ ។ ទីនោះប្រហែលជាព្រះពន្លាមួយសម្រាប់ស្ដេចចេញទតកំសាន្តជាមួយស្រីស្នំ ដើម្បីលំហែរព្រះកាយយកខ្យល់អាកាសនៅពេលល្ងាចៗ ឬសម្រាប់ទតមើលការប្រណាំងរទេះគោ ឬរទេះសេះ ឬប្រណាំងក្របី នារដូវប្រាំង ។ ចេញពីទួលដូនពែងនោះ ប្រមាណ ១៥០ម ទៀត មានបឹងមួយយ៉ាងធំហើយវែង (អ្នកស្រុកហៅថា បឹងព្រះទន្លេ) ដែលមានបណ្ដោយ ៥០០មx២៧០ម ជម្រៅ ២ម ហើយមានទំនប់ព័ទ្ធជុំវិញយ៉ាងខ្ពស់មានទទឹង ៣០ម (សព្វថ្ងៃទំនប់នេះ នៅមានទ្រង់ទ្រាយដើមនៅឡើយ ) ។

នៅខាងលិចបឹងព្រះទន្លេនេះ មានសេសសល់គ្រឹះព្រះពន្លាមួយទៀត សង់អំពីឥដ្ឋ-ថ្មបាយក្រៀម ។ ព្រះពន្លានេះ សម្រាប់ស្ដេចនិងមន្ត្រី សេនាបតី ទតមើលការប្រណាំងទូក ឬប្រណាំងការហែលទឹកនៅរដូវវស្សា ។

ចំពោះព្រះទន្លេក្ដី គូទឹកក្ដី សព្វថ្ងៃប្រែក្លាយទៅជាត្រពាំង បាក់ធ្លាក់រាប

អស់ទៅហើយ ប្រជាជនយកធ្វើជាកម្មសិទ្ធិរៀង១ខ្លួន បានស្មើរតែគ្រប់មេគ្រួសារ ។

**អំពីបារមីអ្នកថែរក្សាប្រាសាទ :**

តាមមតិរបស់អ្នកផ្តល់ពត៌មានបាននិយាយថា : កាលពីដើមបារមីរបស់អ្នកថែរក្សាប្រាសាទនេះ មានមហិទ្ធិឫទ្ធិខ្លាំងពូកែណាស់ ពីព្រោះមានរូបអ្នកតាមួយ និងរូបយាយទេពមួយ នៅក្នុងអាស្រមលើទួល កាលសម័យអាណានិគមនិយមបារាំង វាយកពោងទៅបោះលើទួល (ដើម្បីបន្សាប ) រួចវាវាយបំបាក់ត្រឹមក ហើយយកក្បាលទាំងពីរនោះ មកទុកនៅវត្តព្រៃធ្លាក់ ស្រុកស្វាយរៀង ។

រីឯព្រះទន្លេ និងគូទឹកនៅជុំវិញប្រាសាទ ក្នុងអំឡុងក្រោយមក ដោយគ្មានអ្នកគ្រប់គ្រងថែរក្សាបណ្តាលឱ្យកាន់តែរាក់ទៅ១ ប្រជាជននៅជិត១នោះ នាំគ្នាទៅស្ទូងខាង១ ។ ចំណែកឯគូទឹក អ្នកទៅស្ទូងបានមានតែអ្នកក្រីក្រ គ្មានគោក្របី តែបើអ្នកមានគោ-ក្របី ទៅភ្ជួរស្ទូងអ្នកតានឹងកាច់ឱ្យឈឺ ឬឱ្យស្លាប់ទាំងមនុស្សទាំងសត្វ ។ រីឯត្រីសាច់នៅជុំវិញប្រាសាទនោះ ប្រជាជនគេមិនហ៊ានរកទទួលទានដែរ គេខ្លាចកើតជម្ងឺដូចជាឃ្លង់. ស្រែងឬជម្ងឺផ្សេង១ទៀត ។ មួយឆ្នាំ១គេនាំគ្នាធ្វើពិធីឡើងអ្នកតាគ្រប់១គ្នា ។

ចំណេរក្រោយមកទៀត ទីតាំងប្រាសាទនោះ ក្លាយទៅជាវត្តអារាម របស់ព្រះពុទ្ធសាសនា មហាយានមួយរយៈខ្លី ចាស់១គាត់និយាយថា : គេឃើញមានព្រះសង្ឃពីរអង្គចាស់១មកធ្វើជុំរុំស្នាក់នៅ ដោយមានតាម្នាក់ឈ្មោះ **ខៀវ** មកជួយបម្រើ បន្ទាប់មកព្រះសង្ឃអង្គនោះ ក៏ចាកចេញពីទីប្រាសាទទៅគង់នៅវត្តកណ្តាលជាប់មាត់ព្រែកខាងជើងវត្តរកា សព្វថ្ងៃ (ប្រហែលជាវត្តសណ្តោកចាស់) ចេញពីវត្តកណ្តាល ក៏ទៅគង់នៅវត្ត តាកុដ ស្រុករំដួល ហើយក៏បាត់ទៅ គ្មាននរណាដឹងថាព្រះសង្ឃពីរអង្គនោះ និមន្តទៅណាទៀតឡើយ ។

## អំពីការធ្វើកំណាយប្រាសាទ



*រូបពីឆ្វេងទៅស្តាំ : លោកតា មាំ តង់ឃី, លោកតា ទេពជា, លោកយាយ ម៉ែន លន់*
*(រូបថត មាស សារ៉េត)*

ក្នុងអំឡុងឆ្នាំ ១៩៤៩ លោកតា ទេព ជា អាយុ ៧៨ ឆ្នាំ នៅភូមិថែងមែង ឃុំអង្គតាសូ ស្រុកស្វាយជ្រំ បានផ្ដល់ពត៌មានថា : មុនធ្វើកំណាយលើទួលប្រាសាទក្រហមនោះ ព្រះតេជព្រះគុណ សំ ហ៊ុន ចៅអធិការវត្តរកា ឃុំអង្គតាសូ បានទៅសុំច្បាប់ពីរ៉េស៊ីដង់បារាំង នៅស្វាយរៀង ដើម្បីសុំគាស់យកថ្មបាយក្រៀម មកធ្វើជាគ្រឹះព្រះវិហារវត្តរកា (កាលនោះ ក្នុងរាជ្យឧកញ៉ា សាអ៊ុំ ចៅហ្វាយស្រុកស្វាយរៀង) បារាំងក៏សម្រេចជាលាយលក្ខណ៍អក្សរ ឱ្យធ្វើកំណាយព្រមទាំងឱ្យឡាន កាំមីញ៉ុងមួយគ្រឿង មកជួយដឹកជញ្ជូនថ្ម ជាច្រើនថ្ងៃទៀតផង ។

សូមបញ្ជាក់ថា:ព្រះតេជព្រះគុណ សំ ហ៊ុន នេះ ជាសង្ឃមានថ្វីដៃ ថ្វីមាត់

មានអ្នកតូច អ្នកធំ គោរពរាប់អាន ព្រមទាំងចេះសិល្បិ៍សាសន៍ ខ្លាំងពូកែទៀតផង ។

មុននឹងធ្វើកំណាយ ព្រះតេជព្រះគុណសំ ហ៊ិន បង្គាប់ឱ្យចាស់ៗ ធ្វើពិធីទេវរាជមួយ តាមលទ្ធិព្រាហ្មណ៍ ថ្វាយអទិទេព អ្នកថែរក្សាទួលប្រាសាទនោះ ចំនួន ៧ ថ្ងៃ ។ ពិធីនោះ មានរៀបចំ បាយសីមួយគូ ចេក មាន់ស្ងោរមួយគូ ដូងមួយគូ និងប្រដាប់ប្រដាផ្សេងៗជាច្រើន ព្រមទាំងលេងភ្លេងខ្មែរ ៧បទ ថែមទៀត ។

បន្ទាប់មកអុជធូបផ្សងក្នុងរយៈពេល ៧ ថ្ងៃ ។ លោកតាបានសុបិន្តឃើញអទិទេពនៅលើទួលនោះ មកចង្អុលប្រាប់កន្លែង ដែលត្រូវគាស់។ ពេលធ្វើកំណាយ លោកតា សំ ហ៊ិន នាំឧបាសកទៅគាស់ តាមសុបិន្តនោះទៅ ។

នៅពេលធ្វើកំណាយពួកគាត់ បានជួបវត្ថុបូរាណជាច្រើនមានរូបវិស្ណុធំៗ៣រូប និងរូបតូចៗ ជាច្រើន ធ្វើអំពីលង្ហិន,សំរឹទ្ធ, ស្ពាន់ ពិសេសបានរូបអ្នកតាថ្មមួយទៀត ហើយពូកែសក្តិសិទ្ធិណាស់ អ្នកស្រុកហៅថា : ( អ្នកតា តិះ មិះ )រូបអង្គុយបញ្ឈរជង្គង់ខាងស្តាំ, បត់ជើងខាងឆ្វេង ដូចរូបស្តេចគម្លង់ ។ ក្រៅពីនេះ ប្រជាជនថានៅមានមាស ពេជ្រ និងបារតទៀតផង ។

ក្រោយមកមានវត្តចារ ដឹកនាំដោយព្រះតេជព្រះគុណ យង់ អ៊ុន ជាព្រះចៅអធិការ,លោកតា យស់ ធូ គ្រូសូត្រស្តាំ ,លោក តាអាចារ្យ តូច អុំ ព្រមទាំងឧបាសក ឧបាសិកា បាននាំគ្នាទៅធ្វើកំណាយនៅប្រាសាទនោះ ដើម្បីយកថ្មបាយក្រៀម មកធ្វើជណ្តើរសាលាឆាន់ និងសេនាសនៈផ្សេងទៀត ។ ពេលធ្វើកំណាយនោះ វត្តចារគាស់បានវត្ថុបូរាណជាច្រើនដែរ ធ្វើអំពីស្ពាន់ លង្ហិន និងបានថ្មកំពូលប្រាសាទ អ្នកស្រុកហៅថា ( ថ្មផ្លែល្មៅ ឬ ថ្មកំពូលប្រាសាទ ) ថ្មនេះ មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តស្វាយរៀង បានយកមករក្សាទុកនៅសារមន្ទីរខេត្តហើយ ។

ក្រៅពីនេះ មានវត្តថ្មី វត្តស្វាយព្រហូត, វត្តស្វាយផ្អែម, វត្តសណ្តោត, វត្តល្វើន, វត្តអន្ទង់, បានមកធ្វើកំណាយបន្តបន្ទាប់គ្នាដែរ ។

ចំពោះវត្ថុបូរាណតូចៗ មួយចំនួន ដែលវត្តរកា និងវត្តចារយកបាននោះ ឮថា លោកចៅហ្វាយខេត្តញាណ-ធៀង បានប្រមូលមករក្សាទុកនៅអាស្រមខាងត្បូង អូតែលខេត្ត ប្រហែលក្នុងឆ្នាំ១៩៥៧ ឬ ១៩៥៨ ម្ល៉េះ ។

ការស្រាវជ្រាវឯកសារ ស្តីពីប្រវត្តិប្រាសាទក្រហម ដែលយើងខ្ញុំបានចងក្រង តាមលំដាប់លំដោយ ហើយប្រកបទៅដោយខ្សែសង្វាក់ ប្រទាក់តគ្នាមកនេះ វាកើតឡើង ដោយស្មារតីព្យាយាម ក្នុងការស្រាវជ្រាវ ពីអ៊ុំចាស់ៗ ជាច្រើននាក់ គឺអ្នកនៅជុំវិញប្រាសាទ ។ ប៉ុណ្ណឹងហើយ យើងខ្ញុំសន្និដ្ឋានថា ប្រវត្តិនេះ មិនទាន់ដល់កម្រិត ដែលចង់បាននោះទេ នៅមានចំណុចខ្លះទៀត ដែលពុំទាន់គ្រប់គ្រាន់ ។

ហេតុនេះ សូមអស់លោកអ្នកចេះដឹងរឿងប្រវត្តិប្រាសាទនេះ ជួយបំពេញទៀតជាការប្រសើរណាស់ ។

***អ្នកផ្តល់ពត៌មាន***

*១ -លោកតា **ឆេត ជា** អាយុ ៧៨ ឆ្នាំ ប្រជាជនភូមិ ចែងម៉ែង ឃុំអង្គតាសូរ*

*២ - លោកតា **ហែម មូ** អាយុ ៧៣ ឆ្នាំ អាចារ្យវត្តរកា ឃុំអង្គតាសូរ*

*៣ - លោកតា **តូច អ៊ុំ** អាយុ ៨០ ឆ្នាំ អាចារ្យវត្ត (ស្លាប់)*

*៤ - លោកតា **ម៉ៅ គង់យី** អាយុ ៧៤ ឆ្នាំ គណៈកម្មការវត្តស្វាយផ្អែម*

*៥ - លោកយាយ **ម៉ែន លន់** អាយុ ៦៥ ឆ្នាំ ប្រជាជនភូមិខ្នុរ*

*៦ - លោកតា **កួច ឆន** អាយុ ៧៥ ឆ្នាំ ប្រជាជនភូមិចែងម៉ែង (អ្នកបានចុះធ្វើអំណោយ ផ្ទាល់) ។*

## ផ្តួចផ្តើមការស្រាវជ្រាវ

លោក អ៊ឹ រី ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តស្វាយរៀង

## អ្នកកែសម្រួល

លោក ចាន់ សុគាត អនុប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ

លោក អ៊ុក គឹមលី អនុប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ



លោក ម៉ែន សឿន ប្រជាជនភូមិខ្នុរខាងជើង ជាជំនួយការស្រាវជ្រាវ



*លោក **សុខ ចេន** ប្រធាន ការិយាល័យបេតិកភ័ណ្ឌ នៃ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ខេត្ត ស្វាយរៀង*


ទួលទេរូប
ទួល ក-ដប
ទួល ធាតុ
ទួល ស្វាយវៀន
ទួល ដូនពែង
ស្រះ ដូនពែង
៥០ម
២៥០ម
ភ្នំដីដូនពេជ្រ
ទួលព្រះអង្គគ្រង ឬទួលអង្គ្រង
កំផែងពទ្ធ័ជុំវិញនៅទសវត្ស ១៩៦០
ស្រះទឹក ឬ អង្គ
ទួលប្រាសាទ
បច្ចុប្បន្ន ត្រពាំង
ស្រះទឹក ឬ អង្គ
បច្ចុប្បន្ននេះគឺ ភ្លឺត្រពាំង
មានទំហំទទឹងជាង៧ម៉ែត្រ
ផ្លូវចូល
ទួល ទាភាន
ទួល ពណ្ណរាយ
ទួល វៀន
ទួល សាលា
ទួលស្វាយរាំ ឬ ស្វាយទាំ
ទួល ព្រះធាតុ
៩០ម
បឹងព្រះទន្លេ
២៧០ ម
បណ្ដោយ ៤៥០
កំណត់សម្គាល់
- នៅល្អ
- ទួល ខូច (បាក់)
- ភ្នំដី ខូច (បាត់)

# មុខរបរកាប់ខ្លឹមចន្ទន៍ក្រស្នា របស់អ្នកស្រុកជនជាតិព័រ និងជង ក្នុងទឹកដីខេត្ត ពោធិ៍សាត់

ដោយ : ម៉ៅ សោភ័ណ
រស់ សំណាង

## សេចក្តីផ្តើម :

ទន្ទឹមនឹងភាពសម្បូរបែបនៃភោគទ្រព្យធម្មជាតិ ដែលលាតសន្ធឹងលើផ្ទៃដី ជួរភ្នំក្រវាញខេត្តពោធិ៍សាត់ តម្រូវការជីវភាពរស់នៅបានជំរុញឱ្យមនុស្សម្នាក្នុងតំបន់ ប្រឹងប្រែងរកគ្រប់វិធី ដើម្បីចម្រាញ់យកផលចំណេញពីកំណាប់ ដ៏ពិសិដ្ឋនេះ ។ ជាការពិតណាស់ សម្រាប់បងប្អូនជនជាតិភាគតិចខ្មែរព័រ និងខ្មែរជង ក្រៅពីមុខរបរបំបែកថ្ម, បេះផ្លែក្រវាញ ,គេនៅមានមុខរបរប្រចាំជីវិតរបស់គេមួយទៀត គឺកាប់ខ្លឹមចន្ទន៍ក្រស្នា ។

កាលណាគេនិយាយអំពីខ្លឹមចន្ទន៍ក្រស្នា គេក៏នឹកឃើញភ្លាមដល់ប្រភេទក្រុមឈើមួយបែប ដែលមានក្លិនក្រអូបប្លែក ហើយក៏ជាប្រភេទឈើពិសេស និងមានតម្លៃខ្ពស់ លើសអស់ក្រុមឈើផងទាំងពួង ។ ដើមចន្ទន៍ក្រស្នាជាប្រភេទឈើដែលមានអំបូរស្រដៀងនឹងដើមគរ "សាច់ស្ពោធ" ដើមធំខ្ពស់ និងមានសន្លឹកស្រដៀងនឹងស្លឹកនៃដើមអាកាសស្បា ហើយឈើប្រភេទនេះ ដុះមានហ្វូង ចែកចេញជាបីផ្នែកខុសគ្នា តាមការសម្គាល់ហៅដូចជា ÷

ដើមឃ្លយ និងដើមម៉ៃហប ដើមដូចគ្នាតែមានសន្លឹកតូចជាង ហើយក្រាស់ជាងដើមចន្ទន៍ក្រស្នាបន្តិចតែប៉ុណ្ណោះ តែជាអម្បូរតែមួយខ្លឹមតែមួយ ។

*** អំពីខ្លឹមចន្ទន៍ក្រស្នា :**

ដើមចន្ទន៍ក្រស្នាមានខ្លឹម ខុសអំពីខ្លឹមនៃដើមឈើផ្សេងៗ ផងទាំងពួងដែលមានដុះខ្លឹមរីកធំពីគល់ឡើង រហូតដល់ចុងនិងមែក ។ រីឯខ្លឹមរបស់ដើមចន្ទន៍ក្រស្នាវិញ សម្រាប់អ្នកស្រុកព្រៃភ្នំគេហៅថា "អង្គលោកចាប់" បានន័យថាមានខ្លឹមដុះ មិនប្រាកដទីកន្លែង ជួនមានស្នាមគួចដុះពកខ្មៅចេញពីមែក ឬ ប្រគាបខ្លះទៀតអាចចេញពីដើម ជួនកាលអាចមានស្នាមដំបៅឈើ របៀបឈើស្អុយប្រហោងក្នុង ខ្លះទៀតគេអាចចំណាំបាននៅលើសន្លឹក គេសម្គាល់លើសន្លឹក ដែលមានសណ្ឋានវេញៗខុសធម្មតា នោះគឺប្រាកដជាមានខ្លឹមហើយ តែមិនប្រាកដថា អង្គលោកនឹងមានចាប់នៅត្រង់ណានៅឡើយទេ ។



*ខ្លឹមចន្ទន៍ក្រស្នាប្រភេទបាក់ខ្នាន*

ខ្លឹមចន្ទន៍ក្រស្នា ចែកចេញជាច្រើនពួក និងច្រើនប្រភេទ ហើយមួយប្រភេទៗ គឺមានតម្លៃខុសៗ គ្នាដូចជា ÷

- *ពពួកឈើលេខ ១* :ប្រភេទឈើកែន ជាឈើតម្លៃខ្ពស់ មានខ្លឹមសាច់ខ្មៅ ណែនតូច ជួនកាលមានប្រហោងដែរ តែប្រហោងតូចលក្ខណៈពិសេស គឺដាក់ត្រាំទឹក លិច ។
- *ពពួកឈើលេខ ២* : ពួកឈើលេខពីរ មានពីរប្រភេទគឺ *ឈើរង និងឈើឡាំ*

  *ក/ ប្រភេទឈើរង* : គឺមានខ្លឹមខ្មៅស្រាល មានប្រហោងធំ

  *ខ/ ប្រភេទឈើឡាំ* : គឺជាឈើ មានខ្លឹមខ្មៅស្រាល ហើយមានលាយសាច់សល្អិតៗ បើដាក់ត្រាំក្នុងទឹក គឺអណ្តែត ។
- *ពពួកឈើលេខ ៣* : ពពួកឈើលេខបី មានបីប្រភេទគឺ *ប៉ាកខ្វាន.តុក និងម៉ៃ.*

  *ក/ ប្រភេទឈើប៉ាកខ្វាន* : ចែកចេញជាពីរគឺប៉ាកខ្វានចាស់ និងប៉ាកខ្វានថ្មី ឈើប្រភេទនេះ មានខ្លឹមពណ៌ខ្មៅលាយសច្រើន ហើយមានប្រហោងធំៗ។

  *ខ/ ប្រភេទឈើតុក* : ប្រភេទឈើតុកនេះ មានបួនប្រភេទគឺ: តុកសុង.តុកភុំ. តុកយក្ស. និងតុកអាចមិដី ។ ឈើប្រភេទនេះ ច្រើនមានខ្លឹមពណ៌សលាយក្រហម ពិសេសគឺមានលាយស្រាយភាគច្រើន ។

  *គ/ ប្រភេទឈើម៉ៃ* : ឈើម៉ៃចែកចេញជាពីរប្រភេទគឺ ម៉ៃព្រង និងម៉ៃហ្វាក ជាប្រភេទឈើមានខ្លឹមក្រហមតិចបំផុត គឺឈើស្រាយពណ៌ស ហើយច្រើនស្រួចចុងស្រួចដើម ។
- *ពពួកឈើលេខ ៤*: ឈើនេះមានតែពីរប្រភេទប៉ុណ្ណោះ គឺមានសាកម៉ាក និងសោងម៉ោង ហើយឈើប្រភេទនេះ គឺជាប្រភេទឈើខ្សោយបំផុត ច្រើនជាឈើធំៗ អាចមានរូបរាងច្រើនសណ្ឋាន ដែលភាគច្រើនគេនិយមយក

ទៅធ្វើជាឧបករណ៍តាំងលំអរផ្ទះ ។

**✱ អំពីឧបករណ៍ប្រើក្នុងការស្វែងរកកាប់ឈើខ្លឹមចន្ទន៍ក្រស្នា**

ក្នុងមុខរបរកាប់ខ្លឹមចន្ទន៍ក្រស្នា ឧបករណ៍ដែលត្រូវប្រើប្រាស់ជាចាំបាច់រួមមានៈ

១ - ពួយៈប្រភេទឧបករណ៍ របៀបដូចស្នឹងគោ សម្រាប់ដំភ្ជាប់នឹងដើមឈើ ធ្វើជាជណ្តើរ ។

២ - ពូថៅ : ជនជាតិព័រ គេហៅថា "បាសេស"

៣ - កាំបិតភ្លាក់ : សជនជាតិប្រើក្នុងព្រៃគេហៅថា "ព្រះខ័ន្ធ"

៤ - ដែកប៊ុងធំ : ពាក្យព័រគេហៅថា ព្រះខ័ន្ធប៊ុង ។ ប៊ុងនេះទៀតសោតមានបី ប្រភេទគឺ : ១ ប៊ុងធំ (ដែកក្រចកធំ ) ២ ប៊ុងតូច (ដែកក្រចកតូចល្មម ) ៣ ប៊ុងកីប គឺជា ដែកក្រចកតូចបំផុត (ដូចដែកក្រចកសម្រាប់ឆ្លាក់រូបទូទៅដែរ ប៉ុន្តែប៊ុងគឺមានដងវែង ងាយកាន់សម្រាប់ឈូសឈើស្រាយចេញអំពីខ្លឹមចន្ទន៍ ។

**✱ របៀបរបបរបស់អ្នកឡើងខ្លឹម :**

បើតាមការរៀបរាប់ត្រួសៗ របស់លោកតាចាស់ៗ ជាជនជាតិភាគតិច ខ្មែរព័រ និងខ្មែរជងដូចជា : -លោកតា ហេង -លោកតា ធុយ -លោកតា ម៉ឺ និងលោកតា លន់ បានឱ្យដឹងថា ÷

កាលសម័យដើមឡើយរបរកាប់ខ្លឹមចន្ទន៍ក្រស្នា គឺជាមុខរបបមួយតូចតាច បន្ទាប់បន្សំទេ ព្រោះខ្លឹម ដែលរកបានមកហើយ គឺពិបាករកទីផ្សារណាស់ ជាពិសេស ច្រើនយក ទៅលក់នៅព្រំដែន ឱ្យឈ្មួញជនជាតិថៃ ជាអ្នកទទួលទិញ ។ លុះសម័យ ក្រោយៗមកទៀត ទើបមានដង្ហៅក្នុងស្រុកទទួលទិញ ដូចនេះរបៀបរបបត្រូវផ្លាស់ប្តូរ ពីការចេញទៅរកខ្លឹម ដោយរៀបចំគ្នាចេញជាក្រុមឯកជនតូចតាច និងរៀបគ្នាចេញជា ក្រុមធំតែទោះជាយ៉ាងណា គេត្រូវរក្សាទំនៀមទម្លាប់ សែនព្រេនសុំទឹកសុំដី សុំការ

អនុញ្ញាតពីម្ចាស់ព្រៃព្រឹក្សាជាមុន មុននឹងចេញទៅប្រកបរបរកាប់ខ្លឹមចន្ទន៍ក្រស្នា ។ ក្នុងការរៀបចំសែនព្រេន បើជាក្រុមឯកជនតូចៗ គឺគេរៀបចំសែនបន្តិចបន្តួច ប៉ុន្តែបើជាក្រុមធំ ដូចជាមានដង្ហៅក្នុងស្រុក គេជាអ្នកចេញមុខរៀបចំនោះ ពិធីគឺគេត្រូវធ្វើធំ សំណែនច្រើន ពិសេសគឺមានការប្រគុំតន្ត្រី ពួយតិញ្ញក្រុក រាំស្នែងទន្សោង និងក្លោកថ្វាយម្ចាស់ព្រៃព្រឹក្សាទៀតផង ជាពិសេសក្រោយ ពីរៀបចំសែនព្រេនចប់សព្វគ្រប់ គ្រឿងសំណែនទាំងអស់ត្រូវចែកកូនឈ្នួលស៊ីផឹករាំលេងសប្បាយ កំសាន្តរហូតដល់ភ្លឺ ឮសូរមាន់រងាវលាយឡំ នឹងសម្លេងបង្កុកស្នែងនៃហ្វូងដីរ ផ្ទៃមេឃក្រហមដេជាសនាទិសបូព៌ាផុតចុងព្រៃ ម្នាក់ៗម្ចីម្នាទីទៃរៀបចំសម្ភារះលើកដាក់ ត្រៀមខ្លួនធ្វើដំណើរតាមក្រោយដីរជាក្រុមៗ ទៅតាមមុខសញ្ញាដូចជាចេញទៅបេះ ផ្លែក្រវាញ, បំបែកថ្មកែវ, និងរកកាប់ខ្លឹមចន្ទន៍ក្រស្នា ....។ រីឯភរិយា ដែលនៅផ្ទះរូតរះ រៀបចំសម្ភារះលើកដាក់ បំពាក់ស្មារតីប្រុងប្រយ័ត្នរក្សាត្រណមតាមពាក្យសំដី ទៅតាមទម្លាប់ជាប្រពៃណីនៃភរិយាគ្រប់លក្ខណ៍របស់អ្នកស្រុកភ្នំ ។ បច្ចុប្បន្នពិធីនេះ សម្រាប់អ្នកស្រុកភ្នំក្រវាញ គេតែងតែធ្វើពិធីសែនព្រេននៅនឹងទីទួលអ្នកតាដីរសប្រចាំស្រុក ហើយទើបនាំគ្នាចេញទៅរកកាប់ខ្លឹមចន្ទន៍ក្រស្នា ។ មេក្រុមនីមួយៗ ដែលត្រូវដឹកនាំទទួលខុសត្រូវ សុខទុក្ខនៅក្នុងក្រុមគឺត្រូវតែចេះ មន្តអាគម អូមអាម បាលីបាគូតិច ឬច្រើន គឺត្រូវតែចេះមិនឱ្យអត់ឡើយ នេះគឺជា ទម្លាប់ ព្រោះថាមុននឹងចេញដំណើរ គឺមេក្រុមត្រូវសូត្របាលីប្រក់ព្រំពល[១] ...ពិសេសទៅដល់ទី វាលណាមួយ ឬភ្នំណាមួយ ក៏ត្រូវចេះសូត្រអង្វរបួងសួងបន្ទន់ចិត្ត អ្នកតាភ្នំ ដើម្បីឱ្យអាណិតអាសូរដល់ក្រុមរបស់ខ្លួន ឯបាលីទាំងនោះ

---

១- ប្រស់ព្រំ : ប្រស់ព្រំ ( អ្នកស្រុកភ្នំក្រវាញ និយាយប្រក់ព្រំ

មានខ្លឹមសារ ដូចតទៅ :

**✱បាលីប្រក់ព្រំពល មុនចេញដំណើរ :**

ជាដំបូងត្រូវសូត្រនមោតស្ស: (បីចប់)

រួចផ្តើមសូត្រ: *អាចអញ្ជើរសព្វទិសសព្វវាល ពលកាលជាថ្ងៃ ម្រឹត្យូវជាកម្ម ព្រះខ្ពាមជាស្នាប ព្រះហ៊ុយមានជាពេជ្រ ឆេះដាច់ ឆេះដល់ ស្វាហោ ឧម: ស្វាហាយ:* ។

(ត្រូវសូត្របីចប់ជាមួយនឹងការបាចសាចទឹក ទៅលើកូនចៅរបស់ខ្លួនដំឡើងឫទ្ធិ)

**✱បាលីវន្ទាអ្នកតាព្រៃភ្នំ :**

នៅពេលដែលក្រុមរបស់គេ ធ្វើដំណើរទៅដល់ភ្នំណាមួយ ឬទីវាលណាមួយ ដែលគេយល់ថាទីនោះ មានអ្នកតា អ្នកដូនរក្សានោះ គេត្រូវធ្វើវន្ទនកិច្ចនោះនៅចំពោះមុខខ្ទមក្តី មិនចំពោះក្តីទៅតាមខ្លឹមសារនៃបាលីថា:

ឧម:គោ យំគោ សព្វីប៉ៃយ:ណាម ប៉ាក្លង់កុណងចៃ គោប៉ៃ គោមីប៉ៃ អ្នកតាអ្នកដូនភ្នំ ឬទីវាល (ខ្ទងភ្នំរកាត ) ខ្ញុំមានកូនចៅ (ចំនួនដែលមាន ) ទើបអញ្ជើញឱ្យគ្រូជូនទៅដល់គោលដៅ ។

- សូត្រចប់សព្វគ្រប់ហើយ ទាំងអស់គ្នាអុជទៀនធូប ហើយចូលទៅវន្ទាគ្រប់ៗគ្នារួចបន្តដំណើរទៅរកគោលដៅបន្តទៀត ។

កាលបើគេធ្វើដំណើរមកដល់ទីព្រៃ ដែលជាគោលដៅបានគ្រោងទុកហើយ កិច្ចការជាដំបូងបំផុតនោះ គឺគេត្រូវរៀបចំពិធីសែនព្រេន សុំការអនុញ្ញាតិជ្រកកោនពីសំណាក់ម្ចាស់ទឹក ម្ចាស់ដីជាមុនសិន ។ ឯសំណែន ដែលត្រូវរៀបចំ គឺត្រូវមានពីរចំណែកផ្សេងពីគ្នា មួយចំណែកសម្រាប់អ្នកតាអ្នកដូនម្ចាស់ទឹក ម្ចាស់ដី មួយចំណែកទៀត គឺសម្រាប់ហ្លួងម្រេញគង្វាល ដែលជាអ្នករក្សាព្រឹក្សព្រៃ

សត្វចតុប្បាទបក្សាបក្សី ទីទួលគ្រប់ចន្លោះនៅក្នុងតំបន់ ដែលគេជឿថា អ្នករក្សាផ្ទាល់ ហើយខ្លាចបំផុតគឺម្រេញគង្វាលនេះឯង ។

**អំពីគ្រឿងសំណែន** : គ្រឿងសំណែនសម្រាប់រៀបចំថ្វាយ ដល់អ្នកតាអ្នកដូន ម្ចាស់ទឹកម្ចាស់ដីរួមមាន ÷

*-ស្លាចមីដៃព្រៃមួយគូ*

*-បង្អែមចំអាបមួយថាស*

*-ទៀនធូប ផ្កា ភ្ញី ( ផ្កាឈើព្រៃដែលមាន )*

*-ជាពិសេសគឺស្រាស..... ។*

*-គ្រឿងសំណែនសម្រាប់ម្រេញគង្វាលក្នុងទីព្រៃមាន ÷*

*-បាយសម្លមួយថាស*

*-គ្រឿងល្បែង "ក្មេងលេង"*

*-ពិសេសបំផុតគឺស្ករគ្រាប់ ( ពីដើមប្រើស្ករផែន ) ។*

ក្រោយពីសែនព្រេនសុំទឹកដីរួចហើយ ទើបគេចាប់ផ្ដើមរៀបចំចាត់ធ្វើជម្រកជាទីសំណាក់រួមគ្នាមួយឡើង ។ រោងដែលធ្វើសម្រាប់ស្នាក់សម័យដើមគេគ្រាន់តែធ្វើតែដំបូល ហើយគេដេកនៅផ្ទាល់នឹងដី ក្រោយមកដោយអាកាសធាតុត្រជាក់ ជួនមានភ្លៀងលិចសើមដីផង គេក្រងកូនឈើតូចៗរាយលើថ្មមបានជាគ្រែមួយយ៉ាងសាមញ្ញ ប៉ុន្តែបច្ចុប្បន្ន គេធ្វើតែរោងហើយ និងធ្វើរដាក់សម្ភារៈប៉ុណ្ណោះដោយគេដេកលើអង្រឹង មិនពិបាកឡើយ ។ រីឯដំបូលរោងគេមិនប្រក់ស្បូវទេព្រោះជាការពិបាកខាតពេលវេលា ដូច្នេះគេច្រើនយកស្លឹកខ្នុងធំៗមកដេរ តម្រៀបលើគ្នាយ៉ាងញឹក ហើយជិតល្អបំផុត ។ គេរៀបចំរួចហើយ ចាប់ពីថ្ងៃដែលគេផ្ដើមធ្វើការ ដើររកដើមចន្ទន៍ក្រស្នា គឺគេផ្ដើមធ្វើដំណើររួមគ្នាតែបីថ្ងៃប៉ុណ្ណោះ គេមិនទាន់

ដើររកបែកគ្នាទេ ក្នុងការចេញដំណើររកឈើចន្ទន៍ក្រស្នា គឺគេឱ្យកូនក្រុមដើរទៅមុន ឯមេក្រុម គេត្រូវធ្វើដំណើរទៅតាមក្រោយ ដើម្បីត្រួតពិនិត្យភាពខុសឆ្គង ។ ធ្វើរបៀបនេះគេឱ្យឈ្មោះថា ការចូលកាន់សីល ចូលកាន់ត្រណមការងារ ។

កាលបើគ្រប់ថ្ងៃកំណត់ហើយ ចាប់ពីថ្ងៃទីបួនទៅគឺគេផ្ដើមធ្វើដំណើរស្វែងរកផ្សេងទៀតហើយ រីឯរោងសំណាក់ធំនេះ គឺគេរក្សាទុកជាទីសំណាក់ជួបគ្នាចុងក្រោយ បានន័យថា គេបានសន្មតគ្នារួចស្រេច ជារយៈកាលនៃការដើររកខ្លឹមនេះត្រូវធ្វើឡើងចំនួនប៉ុន្មានថ្ងៃ ហើយបើដល់ថ្ងៃហើយ ទោះរកបានច្រើន ឬមិនបានក៏ដោយត្រូវតែត្រឡប់មកជួបជុំគ្នាវិញតាមកាល ដែលបានកំណត់ ផ្ទុយទៅវិញកាលបើដល់ថ្ងៃកំណត់ហើយ ហើយប្រែជាបាត់នរណាម្នាក់ មិនឃើញត្រឡប់មកវិញ គេទាំងអស់គ្នាមិនអាចត្រឡប់មកភូមិមុនបានឡើយ នោះមេក្រុមត្រូវចាត់ចែងគ្នា ស្វែងដើររកចំនួនបីថ្ងៃ បើនៅតែមិនឃើញ មិនបានទទួលដំណឹងអ្វីទេ នោះទើបគេសម្រេចចិត្តមកភូមិវិញ ព្រោះគេគិតថា អ្នកដែលបាត់នោះ ប្រាកដជាបានធ្វើខុសត្រណមក្នុងប្រការណាមួយជាក់ជាពុំលែងឡើយ ។ រឿងរ៉ាវបែបនេះ មិនអាចនឹងកើតមានទេសម្រាប់ការប្រកបការងារដូចជាពួកគេ ។ ក្នុងដំណើរស្វែងរកខ្លឹមចន្ទន៍ គឺគេរក្សាត្រណមណាស់ គ្រប់ឥរិយាបថ ដេកដើរឈរអង្គុយ គឺមិនមានការធ្វេសប្រហែសឡើយ ។ ការនិយាយស្ដី គឺគេប្រើពាក្យសច្ចំ ពាក្យសម្រាប់ស្ដេច ចំពោះដើមចន្ទន៍ក្រស្នាដូចជា សម្គាល់ការហៅដើម ( *អង្គលោក* ) ចំពោះខ្លឹម ( *លោកចាប៉ា* បើគេឱ្យបោះពួយឡើង ឬគេកាប់គល់រំលំគេប្រើពាក្យថា ( *គាល់លោក* បើគេត្រូវរំលំដើមនោះ គេប្រើពាក្យ ( *បន្ទំលោក* ឬ ( *ផ្ដេកលោក* ។ល។

ការដើរកាប់ខ្លឹមចន្ទន៍ក្រស្នា ពីសម័យដើមគឺនៅពេល ដែលគេធ្វើដំណើរទៅបានជួប នឹងដើមណាមួយ ដែលធំ ហើយដែលគេសម្គាល់ឃើញថា អាចមានខ្លឹម

( *អង្គលោកចាប់* ) ហើយនោះ គឺត្រូវរៀបចំទីសំណាក់នៅខាងក្រោមដើម ហើយរៀបចំដុត ទៀន ធូប ធ្វើពលីការបួងសួងសុំ ឱ្យអង្គលោកមេត្តាប្រោសប្រទាន ។ កាលបើលោកនឹងប្រទាន គឺនៅពេលរាត្រីស្ងាត់ មានសត្វស្លាប ( តាមការរៀបរាប់គឺមិនដែលមានអ្នកណាម្នាក់ បានឃើញសត្វនោះទេ ) មកចោះ ឬមកទំយំកន្លែងដែលមានអង្គលោកចាប់ ឱ្យយើងបានឃើញនឹងឮ ហើយលោកយាងទៅវិញបាត់ទៅ ។ កាលបើបានដឹង នឹងពិនិត្យឃើញសព្វជ្រុងជ្រោយហើយ នៅពេលព្រឹកព្រាង ទើបគេផ្តើមរៀបចំបោះពួយ ឡើងសំដៅទៅរកគោលដៅ ដែលមានអង្គលោកចាប់ ហើយគេយកប៉ុង ឬបាសេស ( ពូថៅ ) ទៅចោះយក ( យាងអង្គលោក ) ក្រៅពីនោះ គឺគេមិនកាប់បំផ្លាញដើម ឱ្យខូចប្រយោជន៍ធំឡើយ ។ តែមកដល់សម័យបច្ចុប្បន្ននេះ ដើមចន្ទន៍ក្រស្នា ទោះតូចក្តី ធំក្តី ឱ្យតែបានជួបគឺគេកាប់រំលំ ហើយពុះជ្រៀករកមើលខ្លឹមតែម្តង ព្រោះជាការងាយមិនលំបាកច្រើន ដូចនេះហើយ ទើបដើមចន្ទន៍ក្រស្នាហោចទៅៗ លែងមានដុះនៅក្បែរៗភូមិទៀត ។ កាលពីដើម ភូមិដែលសម្បូរមាន÷ *ភូមិកោះពហ៊ូត, ភូមិព្រៃស្រះ, ភូមិម្លូលើ, ភូមិខ្នងមេត្រី, ភូមិដីខ្មៅ, ភូមិអម្ពរក្នុង, ភូមិអម្ពរក្រៅ, ភូមិព្រៃប្រទិព្វ, ភូមិព្រៃតានឹម, ភូមិអូរសូយ* ។ បើគេដើរសសៀរ *តាមប៉ែកខាងលិចវិញមាន÷ ភូមិខ្នងស្រល់, ភូមិវាលភ្នំលោក, ភូមិសាតាំង, ភូមិស្រែបាំង, ភូមិអន្ទង់រីម, ភូមិខ្នែងសោម, ភូមិខ្នងត្រពាំង, ភូមិទឹកផុស, ភូមិអណ្តូងប្រេង, ភូមិសំឡាញតូច, ភូមិសំឡាញធំ.* ។ល។



*អូរសំឡាញ*

**✱អំពីភាពអាថ៌កំបាំង ក្នុងជំនឿទាក់ទងនឹងដើមចន្ទន៍ក្រស្នា :**

-តាមការផ្ដល់បទសម្ភាសពីសំណាក់លោកតាចាស់ៗ ជាជនជាតិភាគតិច បានឱ្យដឹងដែរថា : ចំពោះដើមចន្ទន៍ក្រស្នា ដែលមានដុះនៅលើទឹកដីព្រៃភ្នំ ជួរជើងភ្នំក្រវាញ បើថាសម្បូរដូចជាមិនមែន ហើយបើប្រែជាថាមិនសម្បូរវិញក៏មិនមែនដែរ ព្រោះថា ដើមឈើប្រភេទនេះ មានគេនៅថែរក្សា (តាមជំនឿអរូបិយ) ព្រោះថា មានពេលខ្លះ ដែលយើងដើរក្នុងព្រៃ ឃើញមានកូនដើមចន្ទន៍ក្រស្នាត្រឹមៗជង្គង់ដុះទាំងហ្វូង តែដល់មួយខែក្រោយ ឬមួយឆ្នាំក្រោយគេមករកទៀត គឺពុំឃើញមានឡើយ សូម្បីស្លាកស្នាមបន្តិចក៏មិនឃើញផង ប៉ុន្តែប្រសិនជាលោកប្រទានមកយើងវិញនោះ គឺមើលឃើញតែយើងម្នាក់ឯងគត់ ទោះបីជាមានគ្នាច្រើនដើរជាមួយយ៉ាងណាក៏ដោយ ។ មានម្ដងក្រុមរបស់ពួកគាត់មានមនុស្សចំនួនដប់ប្រាំនាក់នាំគ្នាធ្វើខ្ទមស្នាក់នៅប្រៀបនឹងមាត់ទឹក នៃជ្រលងភ្នំមួយកន្លែង ដែលពួកគាត់រៀបចំ

ទទួលទានបាយ គឺនៅក្រោមដើមចន្ទន៍ក្រស្នាធំមួយមានម្លប់ត្រឈៃ មានមុខកាត់ប្រមាណបីតឹក ។ ពេញមួយខែកន្លះ ម្នាក់ៗរកខ្លឹមឈើបានគគោក ចម្លែកតែគាត់រកមិនបានទាល់តែសោះ (ប្រភេទឈើលេខ១ និងលេខ ២ ) ថ្ងៃមួយ ជាថ្ងៃចុងក្រោយទាំងអស់គ្នា គេនាំគ្នាទៅដេញសត្វ តែលោកតា មិនសប្បាយចិត្ត សំម្រាកក្នុងខ្ទមម្នាក់ឯង ។ ដោយសារការអស់សង្ឃឹម លោកតាសម្រាកយកដៃគងថ្ងាសចោលភ្នែកសម្លឹងសព្វចុងព្រៃ ទេសកាលអ្វីគាត់ភ្ញាក់ព្រើត នឹងដើមចន្ទន៍ក្រស្នាមួយដើមយ៉ាងធំ ដែលកំពុងផ្តល់ម្លប់ឱ្យពួកគាត់ស្នាក់អាស្រ័យ រៀងរាល់ថ្ងៃនេះ ។ គាត់យល់ថា នេះគឺអារុក្ខអារក្សអ្នកតារក្សាព្រៃភ្នំ អាណិតគាត់ប្រោសប្រទាន ឱ្យគាត់ហើយ ។ ហេតុភេទដូចបានរៀបរាប់ទាំងអស់នេះហើយ ដែលធ្វើឱ្យអ្នកស្រុកជនជាតិភាគតិចទាំងអស់មានជំនឿយ៉ាងមុតមាំ ហើយជឿជាក់បំផុតលើភាពអាថិកំបាំងរបស់ព្រៃភ្នំនេះ ។

**✱អំពីប្រយោជន៍ នៃខ្លឹមចន្ទន៍ក្រស្នា :**

សារៈប្រយោជន៍ចាំបាច់នៃខ្លឹមចន្ទន៍ក្រស្នា គឺស្ថិតនៅជាអាថិកំបាំងនៅឡើយសម្រាប់អ្នករក និងអ្នកទិញ គ្មានអ្នកណាម្នាក់ដឹងច្បាស់ឡើយ គេគ្រាន់តែបានដឹងតៗគ្នាមកថា ខ្លឹមចន្ទន៍ក្រស្នាច្រើននាំចេញទៅប្រទេសឥណ្ឌា ពិសេសក្រុមជនជាតិអារ៉ាប់ គេយកទៅស្លចម្រាញ់យកជាតិប្រេង ផ្សំជាមួយនិងវត្ថុធាតុផ្សេងៗទៀត ច្នៃធ្វើជាទឹកអប់ ឬជាប្រេងក្រអូបម្យ៉ាង សម្រាប់បូជាដល់ព្រះអទិទេព នៅក្នុងសាសនារបស់ពួកគេ មតិមួយទៀតដំណាលថា គេជាវយកប្រេងខ្លឹមចន្ទន៍ក្រស្នាទៅសម្រាប់លាបខ្លួនដល់អ្នក ដែលចុះទៅនៅក្នុងអណ្តូងរ៉ែ ។ រីឯខ្លឹមចន្ទន៍ក្រស្នាប្រភេទលេខ ៣ និងលេខ ៤ ច្រើនមានរាងជាមែកឈើ ដើមខ្ពស់ស្រួច រាងស្អាតដូច

នេះភាគច្រើនគេជាវយកទៅធ្វើជាវត្ថុតាំងលំអផ្ទះ ។

**✱វិធីចម្រាញ់ប្រេងខ្លឹមចន្ទន៍ :**

ដើម្បីបានប្រេងខ្លឹមចន្ទន៍ គឺគេត្រូវចំណាយពេលវេលាជាច្រើនថ្ងៃ ។ រីឯខ្លឹម ដែលត្រូវជ្រើសរើសយកមកចម្រាញ់នេះ គេមិនយកពពួកឈើលេខមួយ លេខពីរ និងលេខបីទេ ព្រោះជាឈើមានតម្លៃ គឺគេយកតែឈើ ពពួកលេខបួន ប្រភេទឈើសោងម៉ោង.សាកម៉ាក បើគេប្រើឈើខ្លឹមខ្មៅបន្ថែមនោះ គឺគេប្រើឈើប្រភេទលេខបី ប្រភេទឈើ ម៉ៃហ្វាក និងម៉ៃព្រង (ឈើឆ្លូញ)ខ្មៅច្រើន លាយស ហើយស្រួចចុងស្រួចដើម ។



*ឆ្នាំងចំហុយខ្លឹមចន្ទន៍ក្រស្នា*

ជាដំបូងគឺគេត្រូវយកឈើខ្លឹម ដែលត្រូវចម្រាញ់នោះ មកចិញ្ច្រាំឱ្យខ្ទេច ហើយហាលថ្ងៃឱ្យស្ងួតល្អ រួចទើបយកទៅកិននឹងត្បាល់កិនឱ្យហ្មត់ ស្មើរក្លាយទៅជា

ម្សៅ ហើយគេត្រូវជ្រើសរើសពាងធំល្មម (ប្រហែលចំណុះទឹកមួយម៉ែត្រគូប ) ប្រមូលម្សៅខ្លឹមទាំងអស់យកមកដាក់ក្នុងពាង ហើយចាក់ទឹក (ទឹកធម្មតា) ត្រាំ ។ ក្នុងការត្រាំនេះ គឺគេត្រូវលៃទាំងម្សៅទាំងទឹក ឱ្យស្មើគ្នាពេញមួយពាង ។ ការត្រាំម្សៅខ្លឹមចន្ទន៍ គឺគេត្រូវចំណាយពេលមួយអាទិត្យ ទៅដប់ប្រាំថ្ងៃ ដើម្បីឱ្យកំទេចឈើទាំងអស់ពុកផុយ ក្រោយមក ទើបគេចាត់ចែងរៀបចំពិធីចម្រាញ់យកជាតិប្រេង ។ ក្នុងការចម្រាញ់ គឺគេត្រូវប្រើឆ្នាំងចំហុយខ្លឹមមួយ មានសណ្ឋានដូចឆ្នាំងចំហុយស្រាដែរ គឺមានបំពង់បង្ហូរចំហាយទឹកដូចគ្នា យកទៅដាក់ក្នុងឆ្នាំងតូចមួយទៀត ដែលឆ្នាំងនោះ ត្រូវដាក់ត្រាំជាប់នៅក្នុងទឹកត្រជាក់ ។ ជាតិចំហាយទឹកហូរនាំទៅទាំងជាតិប្រេងធ្លាក់ចូលទៅក្នុងឆ្នាំង ហើយឆ្នាំងទៀតសោតត្រូវមានទុយោបង្ហូរទឹកដែលជាចំហាយបញ្ចេញពីឆ្នាំងតូចមកក្នុងធុង ត្រាំទុកផ្សេងទៀតទុកឱ្យនៅតែជាតិប្រេង ដក់ជាប់នៅក្នុងឆ្នាំងតូច ។ កាលបើទឹកក្នុងធុងពេញហើយ គឺគេត្រូវតែយកទឹកនោះ ទៅដាក់ចូលក្នុងឆ្នាំងចំហុយវិញ គេធ្វើរបៀបនេះ លុះណាតែទឹកទាំងអស់រីងហួតអស់មួយសា ទើបគេត្រូវចាក់ទឹកថ្មី ក្នុងឆ្នាំងចំហុយបន្ថែម ដើម្បីចម្រាញ់ឱ្យអស់ជាតិប្រេង ។ ប្រេងដែលនៅក្នុងឆ្នាំង គេដងដាក់ដបទុកសម្រាប់នាំយកទៅលក់ឱ្យឈ្មួញ ។

# ការព្យាបាលពិសពស់វែក[១]

ដោយ : មៀច ម៉ុណ្ណ

ព្រៃភ្នំក្រវ៉ាញ បឹងបួរ ផ្នុកត្រពាំង និងតំបន់វាលទំនាប នៃស្រុកខ្មែរ សឹងសម្បូរទៅដោយពស់ពិសច្រើនប្រភេទ ក្នុងនោះ ពស់ដែលមានពិសកាចសាហាវ ហើយមានគ្រោះថ្នាក់ជាងគេនោះ គឺពស់វែក ដែលមាន ៣ ប្រភេទ:

ក. *ពស់វែកដំបូក*

ខ. *ពស់វែករនាម*

គ. *ពស់វែកស្រវែង ឬពស់វែកក្របី*

កាលណាវាចឹកមនុស្សណាម្នាក់ វាតែងបញ្ចេញពិសតាមរន្ធចង្កូមដូចម្ជុលចាក់ថ្នាំដូច្នោះដែរ ។ បន្ទាប់ពីពិសពស់រត់សព្វសាយ ពាសពេញសពាង្គកាយនោះ ជនរងគ្រោះនឹងស្លាប់យ៉ាងពិតប្រាកដ ។ បច្ចុប្បន្ននេះ ក្បួនវេជ្ជសាស្ត្របានរកឃើញវ៉ាក់សាំងប្រឆាំងពិសពស់ (Vacin antivenimeux) ដែលមានប្រសិទ្ធិភាពជាទីបំផុត ។ ដោយឡែកនៅកម្ពុជាយើង កាលពីជំនាន់ដើមក្តី ពេលបច្ចុប្បន្ននេះក្តី ស្ទើរតែគ្រប់ជនបទ មានគ្រូហ្ម អាលម្ពាយចេះបង្រ្កាបពិសពស់ ប្រើបាលីមន្តអាគម គួបផ្សំនឹងឱសថខ្លះៗ អាចព្យាបាលពិសពស់នេះឱ្យសះជា បានដូចឱសថទំនើបខាងវេជ្ជសាស្ត្រដែរ ។ ខាងក្រោមនេះលោកតា គីម ផង់ បានឱ្យសម្ភាសន៍ដល់ក្រុមស្រាវជ្រាវយើង

១- ឯកសារ សម្ភាសន៍ជាមួយលោកគ្រូ គិម ផង់ អាយុ ៨៦ ឆ្នាំ នៅស្រុក គិរីវង្ស ខេត្ត តាកែវ ។ អាចមានគ្រូ ពូកែលើសនេះ ហើយប្រើមន្តអាគម ឬ ឱសថប្លែកពីនេះទៀត ... ។

ខ្ញុំ និងសូត្របាលីបណ្តេញ ឬកម្ចាត់ពិសពស់វែក ក៏ដូចជាឱសថសម្រាប់ព្យាបាលខ្លះៗ ផងដែរ "*អហំគ្រុឡោ នាគរាជានោ អហេហិ*" ត្រូវសូត្របាលីនេះ ៣ ចប់ ៧ ចប់ ឬ ៩ ចប់ ទៅតាមកាលដ៏គួរ ដោយអុជធូប ១ សរសៃ ឬ ៣ សរសៃកូរផ្លុំទឹកផ្តិល រួចរលាស់ទៅរកអ្នកជំងឺ ពិសេសផ្លុំត្រង់មុខរបួស ពីលើចុះក្រោម នៅពេលសូត្របាលីបានមួយចប់ ។ ជាមួយនឹងបាលីមន្តគាថានេះដែរ គេត្រូវយកឱសថមួយចំនួនមកប្រើគួបផ្សំជាមួយគឺៈ មើមត្រាវព្រៃ ដុសលាយនឹងស្រាឱ្យផឹកមួយលេប រួចយកមកលាបនៅលើស្នាមរបួសដោយចង្កូមពស់ពិស ។ បើមានការហើមត្រង់អវយវៈ ដែលពស់ចឹក ជាចាំបាច់ គេត្រូវយកថ្នាំនោះមកលាបរឹតពីលើចុះក្រោម ក្នុងន័យបូតបញ្ចេញពិសពស់ឱ្យអស់ពីខ្លួន ។

នៅមានថ្នាំមួយមុខទៀត ដែលអាចយកប្រើក្នុងការកម្ចាត់ឬព្យាបាលពិសពស់វែកគឺៈ យកអាចម៍ក្រៀមមកកម្លោចលាយជាមួយអង្រ្គង[1] លាយជាមួយទឹកឱ្យផឹក ។ ថ្នាំនេះក៏អាចជួយផ្ចាញ់កម្រោល ដែលតែងចូលមកទន្ទ្រានឈ្នានពាន ឱ្យជនរងគ្រោះមានការភិតភ័យ តក់ស្លុតចង់សន្លប់ដោយអំណាចពិសដ៏សាហាវនេះ ។

នៅតាមតំបន់ជនបទខ្លះនៃកម្ពុជា គេតែងប្រទះឃើញមានគ្រូអាលម្នាយ ដែលចេះចាប់ពស់វែក ដោយពុំមានគ្រោះថ្នាក់អ្វីសោះឡើយ ។ គ្រូនេះហាក់មានអានុភាពខ្លាំងពូកែ តាមធម្មជាតិ ឬតាមមន្តអាគម ដែលមានប្រៀបទៅលើពស់វែកដ៏សាហាវ និងគ្រោះថ្នាក់បំផុតនេះ ។ គេអាចបញ្ជាពស់វែកឱ្យមកបឺតយកពិសចេញឱ្យអស់ ពីជនរងគ្រោះ ។ ភ្លាមនោះការចុកចាប់ ក្តៅក្រហល់ក្រហាយ ឆេះឆួលរោលរាលក្នុងខ្លួន ក៏បាត់អស់ទៅក្នុងមួយរយៈពេលខ្លីផងដែរ ។ រីឯនៅប្រទេសកាន់សាសនា

---

១- ជ្រើសយកតែអង្រ្គងនៅដើមកណ្តោលប៉ុណ្ណោះ ។

ឥស្លាមមួយចំនួន ដូចជា ឥណ្ឌា ម៉ារ៉ុក ទុយនីហ្ស៊ី អាល់ហ្សេរី អេហ្ស៊ីប និងបណ្ដាប្រទេស អារ៉ាប់ជាច្រើនទៀត ក៏ឃើញមានគ្រូសិល្ប៍ ចេះមន្តអាគមអាចបញ្ជាពស់ឱ្យរេរាំ ចាក់ក្បាច់ តាមសំឡេងប៉ីម្យ៉ាង ។ គ្រូប្រភេទនេះតែងត្រាច់រង្គាត់ តាមទីប្រជុំជន ឬក្រុងធំៗ ដើម្បីបង្ហាញទស្សនីយភាព ដ៏អស្ចារ្យនេះ ដល់សាធារណជនក្នុងគោលបំណងសុំលុយកាក់សម្រាប់ចិញ្ចឹមជីវិត ។

នៅប្រទេសខ្មែរយើង អ្នកដែលមានអំណោយផលពិសេសពីធម្មជាតិនោះច្រើនតែជាមនុស្សមានអណ្ដាតពាំព្រីង[១] ។ មនុស្សពួកនេះមានឥទ្ធិពល ធ្វើឱ្យពស់ខ្លាច មិនហ៊ានចឹក[២] បើទុកជាចឹកក៏ពុំបណ្ដាលឱ្យមានគ្រោះថ្នាក់អ្វីដែរ ។ សូម្បីតែសត្វឆ្កែ ដែលមានអណ្ដាតពាំព្រីង ក៏រមែងមានប្រៀបខ្លាំងទៅលើពស់ផងដែរ ។ ជនជាតិខ្មែរលើ យកពិសពស់វែកមកត្រាំចុងព្រួញ ដើម្បីបាញ់ប្រហារសត្វម្រឹគឱ្យស្លាប់ភ្លាមនៅនឹងកន្លែង ។ ជួនកាលព្រួញពិសបែបនេះ ក៏ត្រូវបានយកទៅប្រើប្រាស់ក្នុងការប្រយុទ្ធទល់នឹងខ្មាំងសត្រូវផងដែរ ។ នៅប្រទេសអាស៊ីខ្លះ គេយកពិសពស់មកផ្សំធ្វើជាឱសថផ្សេងៗ ។

ទោះបីពស់វែកសាហាវ ដោយសារពិសវាមានគ្រោះថ្នាក់គួរឱ្យព្រឺខ្លាចក្ដី ក៏ពួកវាជាសត្វលម្អដល់បរិដ្ឋាន ហើយអាចរាប់ទុកជាសម្បត្តិជាតិដ៏មានសារៈសំខាន់ផងដែរ ។

---

១ - អណ្ដាតដែលមានស្នាមខ្មៅមួយផ្នែក ឬពាសពេញផ្ទៃអណ្ដាតបែកខាងលើទាំងអស់ ។

២ - ប្រជាជនខ្មែរ តែងលើកពាក្យស្លោកថា: ពស់វែកដំបូក ១ស្រែ. ពស់វែកស្រងែ១ព្យាម.ពស់វែករនាម ប៉ិសស្រួស!



*លោកតា គិម ផង់*
*អាយុ ៨៦ ឆ្នាំ នៅស្រុក គិរីវង្ស*
*ខេត្ត តាកែវ ។*

# ឱសថបុរាណខ្មែរ

(៨)

ដោយ : សួន ឱសថ



**✱វល្លិ៍សាវម៉ាវព្រៃ**

ឈ្មោះសាមញ្ញ : Stinking passion

ឈ្មោះវិទ្យាសាស្ត្រ : Passiflora foetida Linn.

ឈ្មោះជាគ្រួសារ : PASSIFLORACEAE

**លក្ខណៈទូទៅ** : តាមការនិយាយហៅជាទូទៅរបស់ប្រជាជាតិខ្មែរថា "វល្លិ៍សាវម៉ាវព្រៃ"ជាប្រភេទរុក្ខជាតិវល្លិ៍ ដុះវារតោងមែកឈើ មានដុះជាក្រុមៗ គ្រប់ទីកន្លែងក្នុងប្រទេសកម្ពុជា ។ វល្លិ៍របស់វា មានរោមល្អិតៗ នៅតាមវល្លិ៍មានដុះដៃដូចប្រមោយដំរី សម្រាប់ថ្កក់តោងសូទៅតាមមែកឈើ មានស្លឹកឆែកជាបី ដុះរោមភ្លឺពណ៌បៃតងស្រស់ ចំណែកផ្ការបស់វាដុះរាយគ្នាមួយៗ តាមវល្លិ៍មានរោមវែង

ដូចស្លាបមាន់ត្រូវទឹក ដុះក្រសោបត្របកផ្កា។មានពណ៌ស ដុះក្រសោបកេសរ ហើយនៅកណ្ដាលមានបណ្ដូលពកខ្មែងពណ៌ខៀវខ្ចី ។ ផ្លែរបស់វារាងមូលខ្ចីមានពណ៌ខៀវលុះដល់ទុំពណ៌លឿងស្រស់ សាច់ផ្លែក្នុងដូចជាគ្រាប់ជីត្រូវទឹក អាចមានរសជូរ-ផ្អែម ហើយរុក្ខជាតិប្រភេទនេះ បន្តពូជដោយការសាបព្រួសគ្រាប់ ។

**សារជាតិឱសថ** : មានរសជាតិផ្អែមចត់តិច។ រសស្រវឹងពុល ព្រោះមានសារជាតិគីមីធម្មជាតិប្រភេទ សាយអេណូហ្សិននីទិកស៍ គ្លៃកូសាយដ៏ (Cyanogenetic glycoside) ជាសារជាតិបង្កាប់នូវជាតិស្ករលាយជាមួយ Cyanogen ជាសារជាតិមានពិសកាច ព្រោះផ្ទុកនូវ Hydrocyanic acid ក៏បានទៅជា Cyanogen radical (C.N.) ។

សារប្រយោជន៍ជាឱសថ : រុក្ខជាតិទាំងមូលស្ងួត ១៥ ក្រាម ស្ងោរពិសា កំចាត់ពិស. ទល់នោម. បំបាត់ស្លេស្ម. បំបាត់ក្អក. ហើមកូនកណ្ដុល. គ្រុនក្ដៅ. ដេកមិនលក់. ការកង្វល់ក្នុងអារម្មណ៍. ស្លឹកស្រស់បុកឱ្យល្អិតលាយទឹកឱ្យល្មម លាបលើស្បែកព្យាបាល : តាអក. ស្បែកមានខ្ទុះ. រលាកស្បែក. ដំបៅជើងជាដើម ។

## ★ដើមព្នៅ

ឈ្មោះសាមញ្ញ : Bengal quince, Bilak Bael

ឈ្មោះវិទ្យាសាស្ត្រ : Aegle marmelos corr

ឈ្មោះជាគ្រួសារ : RUTACEAE

**លក្ខណៈទូទៅ** : តាមតម្រាសាស្ត្រពីបុរាណ ដើមព្នៅជារុក្ខជាតិមួយដែលអ្នកស្រុកពីបុរាណភាគច្រើន។ ដាំនៅក្បែរផ្ទះ សម្រាប់យកផ្លែធ្វើជាចំណីអាហារផង និងសម្រាប់ធ្វើថ្នាំព្យាបាលរោគផង ។

ដើមព្នៅជារុក្ខជាតិមានកំពស់ពី ១០ ម៉ែត្រ ទៅ ១៥ ម៉ែត្រ មានមែកសាខាធំទូលាយ មានស្លឹកពណ៌បៃតងស្រស់ ក្នុងស្លឹកនីមួយៗ មានទងតែមួយដែកចេញជាបីសន្លឹក នៅតាមមែកបែកចេញជាមែកតូចៗ មានបន្លានៅនឹងគល់នៃមែកតូចៗទាំងនោះ ផ្ការបស់វាពណ៌ស ដុះក្រសោបកេសរដោយជុំវិញ នៅកណ្ដាលកេសរមានបណ្ដូលកេសរមានបណ្ដូលពណ៌លឿងខ្ចី ចំណែកផ្លែរបស់វាមានរាងមូលទ្រវែងដូចពងក្រពើ អស់ធំប៉ុនកំភួនជើង នៅខ្ចីមានពណ៌ខៀវ លុះដល់ទុំលឿងស្រស់ ដូចផ្កាននោងព្រៃ ។

ដើមព្នៅមានផ្លែ ដែលអាចប្រមូលផលបាននៅខែ ៣-៤ ផ្លែចាស់អ្នកស្រុក ស្ងោរពិសារ ឬបេះហាន់ហាលថ្ងៃទុកសម្រាប់ដាំទឹកពិសាដូចតែ និងសម្រាប់យកមកផ្សំជាថ្នាំសម្រាប់ព្យាបាលរោគ ។ ផ្លែទុំសម្រាប់យកមកបរិភោគ ឬឱ្យសត្វដីរស៊ី ។

**សារជាតិឱសថ** : រសជាតិរបស់ផ្លែព្នៅមានសភាពផ្អែម -ហាងតិចៗធាតុក្ដៅមធ្យមមានក្លិនក្រអូបឆ្ងាញ់ ។

**សារប្រយោជន៍ជាឱសថ** : ផ្លែព្នៅប្រើនៅក្នុងប្រភេទឱសថចម្រើនអាយុ (អាយុវឌ្ឍនឱសថ )នឹងលើកកម្លាំង បម្រុងធាតុទាំង ៤ ។ សម្រាប់ព្យាបាលរោគក្រពះ. ទល់ខ្យល់. រាគ. មួល. អាហារមិនរលាយ. បាយមិនបាន. ឈាមលើស. ឈឺក្បាល. ស្រវាំងភ្នែក ។ ឬដើមព្នៅផ្សំជាថ្នាំសម្រាប់ស្ងោរពិសាព្យាបាលរោគពិស ។

# មិនមែន ...

ដោយ: ខៀវ យ៉ុន

១- មិនមែនរូបខ្មៅ ទើបវាក្រ
មិនមែនរូបស ទើបវាមាន
មិនត្រូវនៅឈរ មិនព្រមឈាន
អត់សីលឥតទាន មានមិនគង់ ។

២- មិនមែនរូបស្អាត ទើបរៀនចេះ
មិនខ្មៅក្រញេះ ទើបវាល្ងង់
បើខំជ្រែកភក់ ដូចអន្ទង់
គង់តែផុតជង់ លង់ទ្រនេស ។

៣- មិនមែនរាំរែក ស្រែកថា " ទ័ល "
លក់គោនង្គ័ល ហើយដើរទេស
កសិករត្រូវត្រៀម ពីខែជេស្ឋ
បើប្រហែសធ្វេស លក់ស្រែចាយ ។

៤- មិនមែនទ្រព្យមាន ដោយចៃដន្យ
ដោយអុជធូបបន់ ឪពុកម្ដាយ
កាលដែលមានបាន ដើរស៊ីចាយ
ដល់ពេលអត់បាយ ឱ្យឪជួយ ។

៥- មិនមែនកើតមក យកភោគទ្រព្យ
ជូនឱ្យម៉ែរាប់ ជាភ័ព្វសួយ

ជូន "ខន្ធកំពុក" នាំទុក្ខព្រួយ
ឱ្យឪលើកស្ទួយ ម៉ែថ្នមថ្នាក់ ។
៦- មិនមែនអ្នកឡើង បានត្រឹមបេះ
ឯអ្នកប្រឡេះ បួមត្របាក់
ធ្វើការឥតឆ្កង រងគ្រោះថ្នាក់
អែបអបកបស័ក្តិ ពាក់សង្ហា ។
៧- មិនមែនស្តាយលុយ ដើរអើតល្បែក
រកទិញ " កាមរោគ " ជូនគ្រួសារ
មិនមែនអែនអន តាមបនបារ
ឱបស្រីអកស្រោ ថាឯងគ្រាន់ ។
៨ - មិនមែនលាក់កឹប កេងប្រវ័ញ្ច
ទុកបំប៉ន"អញ" ដើរជិះជាន់
ឱ្យ " អេដ្ស៍ " រលាក " រាគ " បំភ័ន្ត
ឱ្យបាបតាមទាន់ មារចូលជ្រែក
៩- មិនមែនរោគរុក ទុក្ខវេទនា
ពឹងបុត្រ-ភរិយា ជួយរំលែក
ប្រពន្ធអត់លុយ កូនយំស្រែក
ទើបស្រក់ទឹកភ្នែក ខ្លាចប៉ាឆា ។

# សន្និសីទកំពូលព្រះពុទ្ធសាសនា ពិភពលោក លើកទី៣



*ផ្ដិតរូបទុកជាអនុស្សាវរីយ៍ នៅមុខព្រះមហាប្រាសាទទេវាវិនិច្ឆ័យ*

នៅថ្ងៃព្រហស្បតិ៍ ទី៥ ដល់ថ្ងៃទី ៩ ខែធ្នូ ឆ្នាំ ២០០២ ព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសធ្វើជាម្ចាស់ផ្ទះ ក្នុងការរៀបចំសន្និសីទកំពូល ព្រះពុទ្ធសាសនាពិភពលោក លើកទី៣ ដែលមានប្រទេស១៥ចូលរួមគឺ : *ប្រទេស អូស្ត្រាលី, ភូថាន់, កម្ពុជា, ឥណ្ឌា, ជប៉ុន, កូរ៉េ, សាធារណរដ្ឋប្រជាមានិតឡាវ, ម៉ាឡេស៊ី, មីយ៉ាន់ម៉ា, ម៉ុងហ្គោលី, រុស្ស៊ី, សិង្ហបុរី, ស្រីលង្កា, ថៃឡង់, វៀតណាម ។*

ដើម្បីរៀបចំសន្និសីទកំពូលព្រះពុទ្ធសាសនាពិភពលោក លើកទី៣នោះ រាជរដ្ឋាភិបាលកម្ពុជា បានឱ្យមានកិច្ចសហការរវាងក្រសួងធម្មការ និងសាសនា, ក្រសួងព្រះបរមរាជវាំង, ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ, ក្រសួងមហាផ្ទៃ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួងទេសចរណ៍, ក្រសួងពត៌មាន,

ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, ទីស្តីការគណៈរដ្ឋមន្ត្រី, គណៈកម្មការរៀបចំបុណ្យជាតិ និងអន្តរជាតិ, នគរបាលជាតិ, អាកាសចរណ៍ស៊ីវិល, ទីក្រុងសៀមរាប, រាជធានីភ្នំពេញ ។

## ប្រមុខដឹកនាំពុទ្ធសាសនាពិភពលោក

**កម្ពុជា** សម្តេចព្រះមហាសុមេធាធិបតី **ទេព វង្ស** សម្តេចព្រះសង្ឃរាជ គណៈមហានិកាយ, សម្តេចព្រះសុគន្ធាធិបតី **បួរ គ្រី** សម្តេចព្រះសង្ឃរាជ គណៈធម្មយុត្តិកនិកាយ

**ជប៉ុន** ព្រះតេជព្រះគុណបណ្ឌិត **គ្យូសេ អេនស៊ីនជោះ**
ប្រធានសន្និសីទ ព្រះពុទ្ធសាសនាពិភពលោក
សង្ឃស្ថាបនិក និកាយពុទ្ធសាសនាជប៉ុន ណេន ប៊ុតស៊ូស៊ូ
ព្រះតេជព្រះគុណបណ្ឌិត **ស៊ីនកៃ ក្វាំ**
ប្រធានសង្ឃ និកាយពុទ្ធសាសនាជប៉ុន ណេន ប៊ុតស៊ូស៊ូ

**អូស្ត្រាលី** ព្រះតេជព្រះគុណ **អាជាញ ព្រហ្មវង្សោ**
ព្រះចៅអធិការវត្ត ពុទ្ធសាសនា ពោធិញាណ

**ភូថាន់** ព្រះមហាថេរ **ខាំខាំង គេនស្សិន**

**ឥណ្ឌា** ព្រះតេជព្រះគុណ **គូសុក បាកុឡា រិនប៉ូចេ**
ប្រធានសង្ឃនៃព្រះវិហារ ឡាដាកហ៍

**កូរ៉េ** ព្រះតេជព្រះគុណ **លី សាំង អ៊ុង**
ប្រធានជាន់ខ្ពស់នៃព្រះវិហារ ប៊ី ហ្សិយ៉ាង, និកាយពុទ្ធសាសនាកូរ៉េ ឆូហ្សិ

| | |
|---|---|
| **ឡាវ** | ព្រះតេជព្រះគុណ **វិជិត សិទ្ធរាជ** |
| | ប្រធានអង្គការ មិត្តភាពពុទ្ធសាសនា ឡាវ |
| **ម៉ាឡេស៊ី** | ព្រះតេជព្រះគុណបណ្ឌិត **គ. ស្រីធម្មានន្ទ** |
| | សង្ឃនាយកសម្រាប់ម៉ាឡេស៊ី និងសឹង្ហបូរី |
| **ម៉ុងហ្គោលី** | ព្រះមហាថេរ **ខាំបា ឡាម៉ា ឆយជាម** |
| | ប្រធានមជ្ឈមណ្ឌលពុទ្ធសាសនា នៃប្រទេស ម៉ុងហ្គោលី |
| **មីយ៉ាន់ម៉ា** | ព្រះតេជព្រះគុណ **បាដាន់តា គេសារ៉ា** |
| | អនុប្រធាន នៃគណៈកម្មាធិការ សង្ឃនាយករដ្ឋ |
| **រុស្ស៊ី** | ព្រះតេជព្រះគុណ **ដាំបា អាយូសេហ្វ** |
| | ប្រធានសង្ឃជាន់ខ្ពស់ នៃពុទ្ធសាសនា រុស្ស៊ី |
| **សឹង្ហបូរី** | ព្រះតេជព្រះគុណ **វេរគោឌ សារទ** |
| | ប្រធានសង្ឃ នៃពុទ្ធមណ្ឌលវិបស្សនា សឹង្ហបូរី |
| **ស្រីលង្កា** | ព្រះតេជគុណ **ឧឌុគម ស្រី ពុទ្ធរក្ខិត** |
| | មហានាយកថេរ នៃនិកាយអសគិរិយា នៃស្យាមោបាលី មហានិកាយ |
| | ព្រះតេជព្រះគុណ **វេវេលទេនិយេ មេធម្មាលង្ការ** |
| | មហានាយកេ មហាថេរោ |
| | ព្រះតេជព្រះគុណ អគ្គមហាបណ្ឌិត **អាហុង្គល្លេ វិមលានន្ទ តិស្ស មហាថេរោ** |
| **ថៃឡង់ដ៍** | ព្រះតេជព្រះគុណ **ព្រះធម្មវរានុវា** |
| | នាយករង ព្រះសង្ឃ នៃវត្ត បូវនីវេទ |

**វៀតណាម** ព្រះតេជព្រះគុណ **ធិច ចុន ធៀន**

នាយក កិច្ចការពុទ្ធសាសនាអន្តរជាតិ នៃក្រុមប្រឹក្សាប្រតិបត្តិ ពុទ្ធសាសនាវៀតណាម ។

គណៈអធិបតី និងភ្ញៀវកិត្តិយស ចូលរួមក្នុងសន្និសីទកំពូល ព្រះពុទ្ធសសនា ពិភពលោកលើកទី៣នេះ មាន :

**កម្ពុជា**

ព្រះករុណាព្រះបាទ **សម្តេចព្រះនរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

សម្តេចព្រះរាជអគ្គមហេសី **នរោត្តម មុនីនាថ សីហនុ**

សម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា

សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភា

សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ប្រទេសផ្សេងៗ**

ព្រះអង្គម្ចាស់ក្សត្រីយ៍ **ដេចាន់ វ៉ាំងឈុក** នៃប្រទេស ភូថាន់

ស្ត្រីទីមួយ **អូយុនបីឡេជ អាហ្សាជស៊ូរេន** នៃប្រទេស ម៉ុងហ្គោលី

ឯកឧត្តម **ឡាក្សម៉ាន ចាយ៉ាកូឌី** អតីតរដ្ឋមន្ត្រីក្រសួងសាសនា និងជាទីប្រឹក្សា ប្រធានាធិបតី នៃប្រទេស ស្រីលង្កា

ឯកឧត្តម **មន្ត្រី គង់តាវីតាត** ទីប្រឹក្សា សម្របសម្រួល តំណាងក្រសួងមហាផ្ទៃ ប្រទេសថៃ

**ឯកអគ្គរាជទូត_អគ្គរដ្ឋទូត ប្រចាំប្រទេសកម្ពុជា**

| | | |
|---|---|---|
| ស្ថានទូត អូស្ត្រាលី | លោកជំទាវ **លី ហេង ហាន់** | ឯកអគ្គរដ្ឋទូត |
| ស្ថានទូត ឥណ្ឌា | ឯកឧត្តម **ប្រាឌីប គូមា ករាពួរ** | ឯកអគ្គរដ្ឋទូត |
| ស្ថានទូត ជប៉ុន | ឯកឧត្តម **ហ្គោតារ៉ូ អូកាដា** | ឯកអគ្គរាជទូត |
| ស្ថានទូត កូរ៉េ | ឯកឧត្តម **លី វ៉ុនហ៊ីង** | ឯកអគ្គរដ្ឋទូត |
| ស្ថានទូត ឡាវ | ឯកឧត្តម **ឆួន វ៉ុងសាន់** | ឯកអគ្គរដ្ឋទូត |
| ស្ថានទូត ម៉ាឡេស៊ី | ឯកឧត្តម **អះម៉ាត់ អានួរ អាប់ឌុលហាមីត** | ឯកអគ្គរាជទូត |
| ស្ថានទូត មីយ៉ាន់ម៉ា | ឯកឧត្តម **អ៊ូ សរ ឡាមីន** | ឯកអគ្គរដ្ឋទូត |
| ស្ថានទូត រុស្ស៊ី | ឯកឧត្តម **វីកធ័រ សាមយឡិនកូ** | ឯកអគ្គរដ្ឋទូត |
| ស្ថានទូត សិង្ហបូរី | ឯកឧត្តម **វេរស៊្វ៊ី មាធូ** | ឯកអគ្គរដ្ឋទូត |
| ស្ថានទូត ថៃ | ឯកឧត្តម **ឆាតឆាវីត ឆាតសូវ៉ាន់** | ឯកអគ្គរាជទូត |
| ស្ថានទូត វៀតណាម | ឯកឧត្តម **ង៉ូយេន ឌុយហៀង** | ឯកអគ្គរដ្ឋទូត |

*វប្បធម៌ខ្មែរ ដែលបានផ្ដល់ដល់ពិភពលោក នូវទីតាំងប្រវត្តិសាស្ត្រពុទ្ធសាសនា នៃក្រុងអង្គរដ៏ល្បីល្បាញ បានចម្រើនរុងរឿង ទុកជាចំណុចឆ្លងកាត់មួយរវាងអារ្យធម៌បុរាណធំពីររបស់ពិភពលោក គឺអារ្យធម៌ចិន និងអារ្យធម៌ហិណ្ឌូ ។ ផ្អែកលើជំនឿសាសនាដ៏ជ្រាលជ្រៅ វប្បធម៌ឯករបស់ខ្មែរ ប្រកបដោយសោភ័ណភាពឆើតឆាយ បានលូតលាស់ដង្គុំដង្គោល ។*

*ព្រះតេជព្រះគុណបណ្ឌិត **ក្យូសេ អេនស៊ីនដោះ***

*ប្រធានសន្និសីទពុទ្ធសាសនាពិភពលោក*

*ធម្មាចារ្យស្ថាបនិក*

*និកាយពុទ្ធសាសនា ណេនប៊ុតស៊ូស៊ូ នៃប្រទេសជប៉ុន*

# ព្រះរាជសុន្ទរកថា
# នៃ សម្តេចព្រះ នរោត្តម សីហនុ
# ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា
# នៅក្នុងកិច្ចប្រជុំកំពូលព្រះពុទ្ធសាសនាពិភពលោក

ភ្នំពេញ ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០២

សូមក្រាបថ្វាយបង្គំ សម្តេចព្រះសង្ឃរាជ សម្តេចព្រះមហាថេរ ព្រះតេជគុណ ព្រះថេរានុថេរៈ គ្រប់ព្រះអង្គ ដែលជាតំណាងព្រះពុទ្ធសាសនាទូទាំងពិភពលោក ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត.

សូមគោរពឧបាសក ឧបាសិកា ដែលជាតំណាងព្រះពុទ្ធសាសនាទូទាំងពិភពលោក.

សូមគោរព សម្តេច រាជវង្សានុវង្ស ឯកឧត្តម លោកជំទាវ លោក លោកស្រី បងប្អូនជនរួមជាតិ និងប្រិយមិត្តបរទេសទាំងអស់ ជាទីរាប់អានស្រឡាញ់មេត្រី.

នេះជាកិត្តិយសដ៏ធំធេង និងជាប្រវត្តិសាស្ត្រ ដែលព្រះរាជាណាចក្រកម្ពុជា និងប្រជាជនកម្ពុជាបានធ្វើជាម្ចាស់ផ្ទះ កិច្ចប្រជុំកំពូលព្រះពុទ្ធសាសនាពិភពលោក ។

ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំ សូមអនុញ្ញាតសម្តែងការគោរព និងសម្តែង

មនោសញ្ចេតនាយ៉ាងជ្រាលជ្រៅ ចំពោះព្រះតេជគុណបណ្ឌិត KYUSE ENSHIN JOH ប្រធានសង្ឃជាន់ខ្ពស់ នៃគណៈនិកាយព្រះពុទ្ធសាសនា NENBUTSUSHU របស់ជប៉ុន និងចំពោះព្រះតេជគុណគ្រប់ព្រះអង្គ នៃគណៈនិកាយ NENBUTSU SHU ដែលមានចំណែកយ៉ាងធំធេង ក្នុងការរៀបចំកិច្ចប្រជុំដ៏សំខាន់នេះ ។ ព្រះតេជគុណបណ្ឌិត ប្រធានសង្ឃជាន់ខ្ពស់ និងព្រះតេជគុណគ្រប់ព្រះអង្គ និងសមាជិកសមាជិកា ដ៏ឧត្តម នៃគណៈនិកាយ NENBUTSUSHU បាននឹងកំពុងផ្តល់ការជួយឧបត្ថម្ភ ដែលមិនអាចកាត់ថ្លៃបាន អស់រយៈពេលជាច្រើនឆ្នាំ ចំពោះប្រទេសកម្ពុជា ប្រជាជនកម្ពុជា និងចំពោះព្រះពុទ្ធសាសនា នៅក្នុងប្រទេសរបស់ខ្ញុំព្រះករុណា ខ្ញុំ ដែលជាការចូលរួមចំណែក ចំពោះការអភិវឌ្ឍន៍ ឥតឈប់ឈរ និងសមស្របរបស់កម្ពុជា ។

ខ្ញុំព្រះករុណា ខ្ញុំ សូមសម្តែងនូវការគោរព ចំពោះគណៈប្រតិភូដ៏ឧត្តមទាំងឡាយ មកពីប្រទេស អូស្ត្រាលី, ប៊ូតង់, ឥណ្ឌា, កូរ៉េ សាធារណរដ្ឋប្រជាធិប-តេយ្យប្រជាមានិតឡាវ, ម៉ាឡេស៊ីយ៉ា, ម៉ុងហ្គោលី, មីយ៉ាន់ម៉ា, រុស្ស៊ី, សិង្ហបុរី, ស្រីលង្កា, ថៃ, និងវៀតណាម ។

តាំងពីដើមរៀងមក រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា តែងតែគោរព ចំពោះព្រះពុទ្ធសាសនា ដោយលើកតម្កើនព្រះពុទ្ធសាសនា ជាសាសនាចម្បងតែមួយគត់របស់រដ្ឋ ។

ដើម្បីគោរពតាមអត្ថន័យរបស់ព្រះពុទ្ធសាសនា ដែលជាសាសនាដ៏ប្រពៃមួយ បង្រៀនឱ្យចេះអត់អោន ស្រឡាញ់សន្តិភាព ភាតរភាព និងចេះជួយគ្នាទៅវិញទៅមក រដ្ឋ រដ្ឋាភិបាល រាជការរបស់យើង និងមហាក្សត្រ តែងតែបានគោរព និងការពារចំពោះសាសនា និងជំនឿសាសនារបស់ជនរួមជាតិកម្ពុជា ដែលពុំមែនជា

ពុទ្ធសាសនិកជន ព្រមទាំងសាសនា និងជំនឿនៃជនជាតិបរទេស ដែលមកពីប្រទេស ផ្សេងៗ ( ដូចជាសាសនាអ៊ីស្លាម គ្រីស្តសាសនា សាសនាកៅដាយ ជាដើម ) ។

ពុទ្ធសាសនិក អ៊ីស្លាមសាសនិក គ្រីស្តសាសនិក និងសាសនិកដទៃៗទៀត បានរួមរស់ជាមួយគ្នាប្រកបដោយសន្តិភាព និងភាតរភាព ។

រយៈពេល "អន្ធកាល" នៃប្រវត្តិសាស្ត្ររបស់កម្ពុជា ( ដោយមិនរាប់បញ្ចូល អំពើអមិត្ត អំពើឃោឃៅ ឬអំពើល្មោភសង្គ្រាម ដែលបង្កឡើងដោយកម្លាំងបរទេស) គឺជួនពេលគ្នានឹងសម័យ ដែលប្រទេសរបស់យើងមិនបានយកចិត្តទុកដាក់ និង រំលោភលើធម៌វិន័យ និងការប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ ។ ម្យ៉ាងវិញទៀត រយៈពេល ដែលប្រទេសកម្ពុជាមានសន្តិភាព ភាតរភាព ការជួយគ្នាទៅវិញទៅមក វឌ្ឍនភាព និងស្ថេរភាព គឺជួនពេលគ្នានឹងសម័យ ដែលប្រទេសកម្ពុជាមានការគោរព និងអនុវត្តបានខ្ជាប់ខ្ជួន នូវធម៌វិន័យ និងការប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ ។

បច្ចុប្បន្នព្រះពុទ្ធសាសនា កំពុងតែរីកលូតលាស់ឡើងវិញ ដោយសារតែ ព្រះសង្ឃ និងអ្នកកាន់ខ្ជាប់តាមព្រះពុទ្ធសាសនា ជាច្រើនរាប់មិនអស់ ដែលជាអ្នក ធានានូវការអភិវឌ្ឍន៍ដ៏ប្រពៃ និងឥតឈប់ឈរ ចំពោះព្រះពុទ្ធសាសនាយើង ។ ការរីកលូតលាស់នេះ ត្រូវបានឆ្លុះបញ្ចាំងឱ្យឃើញ តាមរយៈការកសាងឡើងវិញ និងការសាងសង់នូវ ព្រះវិហារ សាលារៀន សាកលវិទ្យាល័យពុទ្ធិកៈ មន្ទីរពេទ្យ ។ល។ ការរីកលូតលាស់នេះ ស្តែងចេញយ៉ាងច្បាស់ផងដែរ តាមរយៈកិច្ចប្រឹងប្រែងរបស់ ពុទ្ធសាសនិកជន ក្នុងការកសាងជាតិ ព្រមទាំងការជួយឧបត្ថមតាមគ្រប់រូបភាព ចំពោះជនក្រីក្រ ជនពិការ និងជន ដែលមានវាសនាអភ័ព្វ ។

កិច្ចប្រជុំកំពូលព្រះពុទ្ធសាសនាពិភពលោក នឹងចូលរួមចំណែក ដែលមិន អាចកាត់ថ្លៃបានក្នុងការពង្រឹង និងថែរក្សា ឱ្យបានឋិតថេរ នូវព្រះពុទ្ធសាសនាក្នុង

ប្រទេសកម្ពុជា ក្នុងការអភិវឌ្ឍន៍វចនាសម្ព័ន្ធ និងមធ្យោបាយសំរូលផ្សេងៗ នៅព្រះរាជាណាចក្រកម្ពុជាក្នុងតំបន់ ដែលគោលការណ៍ សីលធម៌ និងសង្គមផ្សារភ្ជាប់ជាមួយព្រះពុទ្ធសាសនា និងក្នុងការលើកស្ទួយចំណេះដឹង អំពីសេចក្ដីប្រៀនប្រដៅដ៏ថ្លៃថ្លា ដែលគ្មានអ្វីប្រៀបផ្ទឹមបានរបស់ព្រះពុទ្ធជាម្ចាស់ ។

តំណាងជនរួមជាតិកម្ពុជាទាំងអស់ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសូមថ្លែងអំណរព្រះរាជគុណ ព្រះគុណ និងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត និងសូមអបអរសាទរយ៉ាងកក់ក្ដៅ ចំពោះតួនាទីដ៏ឧត្តុងឧត្តម ជាប្រវត្តិសាស្ត្រ និងមានសារៈប្រយោជន៍របស់ព្រះអង្គ ព្រះតេជគុណ ព្រះថេរានុថេរៈ ឧបាសក ឧបាសិកា សម្ដេច ទ្រង់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ជនរួមជាតិ និងប្រិយមិត្តបរទេសទាំងអស់ ដែលបានស្ដេចយាង និមន្ត និងអញ្ជើញចូលរួមនៅក្នុងកិច្ចប្រជុំព្រះពុទ្ធសាសនាពិភពលោកដ៏នក្ខត្តប្ញក្សនេះ ។ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំក៏សូមពាំនាំនូវព្រះពរដ៏ស្មោះស្ម័គ្រ របស់សម្ដេចព្រះរាជអគ្គមហេសី **នរោត្ដម មុនិនាថ សីហនុ** និងការថ្វាយប្រគេនជូនពររបស់ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំផ្ទាល់ថ្វាយប្រគេនព្រះអង្គ ព្រះតេជគុណ ព្រះថេរានុថេរៈ និងជូនសម្ដេច ទ្រង់ ឯកឧត្តម លោកជំទាវ លោក លោកស្រី បងប្អូនជនរួមជាតិ និងប្រិយមិត្តបរទេសទាំងអស់ ចំពោះការសម្រេចបានជោគជ័យទាំងស្រុង និងថ្លៃថ្លា នូវការងារដ៏ឧត្តុងឧត្តមនេះ ហើយក៏សូមថ្វាយប្រគេនព្រះពុទ្ធពរប្រាំប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូមអរព្រះរាជគុណ ព្រះគុណ !

សូមអរគុណ !



# ប្រវត្តិព្រះសក្យមុនីចេតិយ



*ព្រះសក្យមុនីចេតិយថ្មី នៅលើភ្នំព្រះរាជទ្រព្យ(ឧដុង្គ)*

## ព្រះសក្យមុនីចេតិយ នៅរាជធានីភ្នំពេញ មុខស្ថានីយ៍រាជាយស្ម័យយាន :

នៅថ្ងៃ ២ រោច ខែ អស្សុជ ឆ្នាំ រោង ចត្វាស័ក ព.ស ២៤៩៥ ត្រូវនឹងថ្ងៃអាទិត្យទី ០៥ ខែ តុលា ឆ្នាំ ១៩៥២, ព្រះរាជាណាចក្រកម្ពុជា បានទទួលព្រះបរមសារីរិកធាតុ និងព្រះអរហន្តធាតុ គឺព្រះអដ្ឋិធាតុនៃព្រះសារីបុត្ត និងព្រះមោគ្គល្លាន ព្រមជាមួយកូនមហាពោធិព្រឹក្សពីរដើម ដែលនាំមកពីប្រទេសឥណ្ឌា ។ ពិធីទទួលព្រះបរមសារីរិកធាតុ និងព្រះអរហន្តធាតុ នៅព្រលានយន្តហោះពោធិ-ចិនតុង ត្រូវបានប្រព្រឹត្តទៅយ៉ាងមហោឡារិក ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់

របស់ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង សម្តេចព្រះ **នរោត្តម សីហនុ** ជាទីសក្ការៈ ។

ព្រះបរមសារីរិកធាតុ និងព្រះអរហន្តធាតុ ត្រូវបានដង្ហែយកមកតម្កល់ទុកនៅក្នុងព្រះវិហារព្រះកែវមរកត នៅវេលាម៉ោង ១០ យប់ ។ ថ្ងៃទី ០៦ ខែតុលា ឆ្នាំ ១៩៥២ សម្តេចព្រះសង្ឃនាយកទាំងពីរគណៈ និមន្តព្រះសារីរិកធាតុ និងព្រះអរហន្តធាតុ ចេញពីព្រះវិហារព្រះកែវមរកត ដង្ហែព័ទ្ធជុំវិញរាជធានីភ្នំពេញ ដល់មុខរាជាយស្ម័យយាន ក៏ដង្ហែព្រះសារីរិកធាតុ និងព្រះអរហន្តធាតុតម្កល់ លើអាសនៈដ៏ប្រសើរមួយ នាកណ្តាលវេទិកាដ៏ល្អប្រណីត ប្រារព្ធពិធីថ្លែងសុន្ទរកថាទៅវិញទៅមក ។ ក្រោយចប់ពិធី ក៏ដង្ហែព្រះសារីរិកធាតុ និង ព្រះអរហន្តធាតុទៅគង់នៅ ព្រះវិហារព្រះកែវមរកតវិញ ។

ចាប់ពីថ្ងៃទី ០៦ ដល់ថ្ងៃទី១០ ខែតុលា ឆ្នាំ ១៩៥២ បើកឱកាសប្រគេនព្រះសង្ឃ ជូនមន្ត្រីរាជការ ពុទ្ធបរិស័ទក្នុងទូទាំងប្រទេសធ្វើការគោរពបូជា តាមសទ្ធាជ្រះថ្លា ។

នៅថ្ងៃទី ១១ ខែ តុលា ឆ្នាំ ១៩៥២ មានប្រារព្ធពិធីជូនដំណើរដង្ហែព្រះបរមសារីរិកធាតុ និង ព្រះអរហន្តធាតុ ត្រឡប់ទៅឥណ្ឌាវិញ ដោយមានក្បួនដង្ហែដ៏មហោឡារិកដូចពេលទទួលដែរ ។ បច្ច័យដែលកើតឡើងពីការបូជាក្នុងពិធីបុណ្យ ៧ យប់ ៧ ថ្ងៃនេះ បានចំនួន ១.៦៦៧.៣០៩៖០០ ។ បច្ច័យទាំងនេះ គណៈកម្មការរៀបចំពិធីបុណ្យ បានបែងចែកជាពីរផ្នែកសំខាន់គឺ : ចំនួន ៩០ ម៉ឺនរៀល សម្រាប់យកទៅកសាងមន្ទីរពេទ្យ សម្រាប់ព្រះសង្ឃ ដែលក្រោយមកមានឈ្មោះថា **មន្ទីរពេទ្យព្រះកុសុមៈ** ។ បច្ច័យចំនួន ២០ ម៉ឺនរៀល សម្រាប់យកទៅចាត់ការស្ថាបនាព្រះមហាចេតិយ នៅមុខស្ថានីយ៍រាជាយស្ម័យយានក្រុងភ្នំពេញ សម្រាប់

តម្កល់ព្រះបរមសារីរិកធាតុ ព្រោះហេតុនោះហើយបានជា ព្រះមហាចេតិយនេះ មានឈ្មោះថា " **ព្រះសក្យមុនីចេតិយ** " ។

ព្រះសក្យមុនីចេតិយនេះ ត្រូវបានប្រារព្ធពិធីសម្ពោធ ជាមួយគ្នានឹងបុណ្យគម្រប់ ២៥០០ ព្រះវស្សានៃព្រះពុទ្ធសាសនា ( បុណ្យពាក់កណ្ដាលសាសនា ) ដែល ប្រព្រឹត្តឡើងអស់រយៈពេល ៧ ថ្ងៃ ៧ យប់ គឺចាប់ពីថ្ងៃអាទិត្យ ១៤ កើត ខែ ពិសាខ ឆ្នាំ រកា នព្វស័ក ព.ស ២៥០០ ត្រូវនឹងថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ១៩៥៧ រហូតដល់ថ្ងៃសៅរ៍ ៥ រោច ខែ ពិសាខ ត្រូវនឹងថ្ងៃទី១៨ ខែ ឧសភា ឆ្នាំ ១៩៥៧ ក្រោមព្រះបរមរាជូបត្ថម្ភ នៃព្រះករុណាជាអម្ចាស់ ជីវិតតម្កល់លើត្បូង , សម្ដេចព្រះមហាក្សត្រីយានី , សម្ដេចព្រះឧបយុវរាជ និងក្នុងការទំនុកបំរុង នៃសម្ដេចព្រះសង្ឃនាយកទាំងពីរគណៈ ។

រីឯព្រះបរមសារីរិកធាតុ ដែលតម្កល់នៅក្នុងព្រះសក្យមុនីចេតិយនា ថ្ងៃបុណ្យគម្រប់ ២៥០០ ព្រះវស្សានោះ ជាព្រះបរមអដ្ឋិធាតុខ្នាតកណ្ដាលមួយព្រះអង្គ ដែលប្រទេសសិរីលង្កាថ្វាយមក ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ** ក្នុងឱកាស ដែលព្រះអង្គជាព្រះរាជប្រតិភូ តំណាងព្រះមហាក្សត្រកម្ពុជា ទ្រង់យាងទៅចូលរួមក្នុងពិធីបុណ្យពុទ្ធាជយន្តិ គឺបុណ្យគម្រប់ ២៥០០ ព្រះវស្សា នៃព្រះពុទ្ធសាសនា នៅប្រទេសសិរីលង្កា ដែលប្រារព្ធធ្វើឡើងកាលពីក្នុងខែ ឧសភាឆ្នាំ ១៩៥៦។ ព្រះបរមសារីរិកធាតុ ដែលគង់ប្រចាំនៅក្នុងព្រះសក្យមុនីចេតិយនេះ ត្រូវបានតម្កល់ទុកនៅក្នុងព្រះកាញ្ចនកោដ្ឋ ( កោដ្ឋមាស ) តូច រួចហើយតម្កល់កោដ្ឋមាសនោះ នៅក្នុងព្រះសក្យមុនីស្តូបរ័ត្ន ( ស្តូបសរិទ្ធ ) រួចទើបយកស្តូបសរិទ្ធទៅតម្កល់នៅក្នុងព្រះសក្យមុនីចេតិយ ។

ព្រះសក្យមុនីចេតិយ មុខស្ថានីយ៍រាជាយស្ម័យយាន រាជធានីភ្នំពេញ ត្រូវបានគណៈកម្មាធិការប្រជាជន រាជធានីភ្នំពេញ ជួសជុលឡើងវិញ នៅឆ្នាំ ១៩៨៨ ។

**ព្រះសក្យមុនីចេតិយនៅវត្តព្រះរាជទ្រព្យ ( ខជុំទ្ព ) :**

នៅក្នុងឆ្នាំ ១៩៩១ , ក្នុងឱកាសមីទ្ទិញមហាជនដ៏ធំមួយ នៅទីលានមុខព្រះបរមរាជវាំង ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង បានទ្រង់ថ្លែងព្រះរាជសុន្ទរកថាទៅកាន់កូនចៅ ចៅទួត របស់ព្រះអង្គ និងសួរសុខទុក្ខ ដោយសេចក្ដីនឹករលឹកយ៉ាងជ្រាលជ្រៅ ។ ឱកាសនោះដែរ ព្រះអង្គទ្រង់បានសព្វព្រះរាជហឫទ័យសំណូមពរឱ្យរាជរដ្ឋាភិបាល កូនចៅ ចៅទួត ទាំងព្រះសង្ឃ-គ្រហស្ថ ជ្រើសរើសទីតាំងឱ្យបានខ្ពស់សមរម្យ គួរដល់ការកសាងព្រះសក្យមុនីចេតិយថ្មី ជាទីគោរពសក្ការៈ នៅរាជធានីភ្នំពេញ ។

ក្រោយបានទទួលព្រះរាជតម្រិះ ដ៏ថ្លៃថ្លារបស់ព្រះករុណា ជាអម្ចាស់ជីវិតតម្កល់លើត្បូង និង សម្ដេចព្រះរាជអគ្គមហេសី ជាទីសក្ការៈ គណៈកម្មការសាងសង់ព្រះសក្យមុនីចេតិយមួយ ត្រូវបានបង្កើតឡើង ដោយឯកឧត្ដមអ្នកឧកញ៉ា ចៅហ្វាវាំង **គង់ សំអុល** ជាប្រធានគណៈកម្មការសាងសង់ មានតំណាងក្រសួងពាក់ព័ន្ធជំនាញមួយចំនួនជាសមាជិក ។ ជាដំបូងគណៈកម្មការនេះ បានជ្រើសរើសយកវត្តភ្នំដូនពេញ រាជធានីភ្នំពេញ ផ្នែកខាងជើងជាទីតាំងសាងសង់ព្រះសក្យមុនីចេតិយថ្មី ។ ពិធីបញ្ចុះបឋមសិលា ក៏បានប្រព្រឹត្តទៅនៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ១៩៩២ ជាកិច្ចចាប់ផ្ដើមនៃការសាងសង់ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង និង សម្ដេចព្រះរាជអគ្គមហេសី ជាទីសក្ការៈ ។ បន្ទាប់មក គណៈកម្មការសាងសង់ ក៏ចាប់ដំណើរការសាងសង់សំណង់ថ្មីនេះ តាមគម្រោងប្លង់ ដែលបានឯកភាពកំណត់ ។

ក្រោយមក ដោយការសិក្សាស្រាវជ្រាវ របស់អ្នកបច្ចេកទេសភូមិសាស្ត្រ អ្នកបុរាណវិទ្យា និងអ្នកឯកទេសហោរាវិទ្យា . ការជ្រើសរើសទីតាំងកសាងព្រះសក្យមុនីចេតិយថ្មី ក៏ត្រូវបានផ្លាស់ប្តូរបន្តបន្ទាប់ រហូតដល់ចុងក្រោយបានសម្រេចកំណត់ជ្រើសរើសយក ទីលើកំពូលភ្នំព្រះរាជទ្រព្យ ជាទីតាំងកសាងព្រះសក្យមុនីចេតិយ តរៀងមក ។ ការជ្រើសរើស សម្រេចយកទីតាំងចុងក្រោយនេះ សមស្របណាស់ ព្រោះជាទីឋានមនោរម្យ ស្ថិតនៅលើកំពូលភ្នំព្រះរាជទ្រព្យ ក្នុងតំបន់រមណីយដ្ឋានរបស់ជាតិផង. ជាទីប្រមូលផ្តុំនៃបេតិកភ័ណ្ឌជាតិផង និងជាទីតាំងនៃអតីតរាជធានីឧដុង្គដ៏មានជ័យ របស់ព្រះរាជាណាចក្រកម្ពុជាយើងផង ។

គណៈកម្មការសាងសង់មួយក៏ត្រូវបានបង្កើតឡើងជាថ្មី ដែលមានសម្តេចព្រះសង្ឃរាជទាំងពីរគណៈ ជាប្រធានកិត្តិយស. សម្តេច **ជា ស៊ីម** .សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** និងសម្តេច **ហ៊ុន សែន** ជាសហប្រធាន និងមានសមាសភាពគណៈកម្មការសាងសង់ចាស់ជាសមាជិក ។

ថ្ងៃ ពុធ ១១ រោច ខែ ជេស្ឋ ព.ស ២៥៤០ ត្រូវនឹងថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ១៩៩៦ ពិធីក្រុងពាលីដ៏ធំមួយសុំទីតាំងសាងសង់ ក៏ត្រូវបានប្រព្រឹត្តទៅក្រោមអធិបតីភាព សម្តេច **ជា ស៊ីម** ប្រមុខរដ្ឋស្តីទី ជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់ របស់ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង និងសម្តេចព្រះរាជអគ្គមហេសី ជាទីសក្ការ

ថ្ងៃ ព្រហស្បតិ៍ ៩ រោច ខែ ទុតិយាសាឍ ព.ស ២៥៤០ ត្រូវនឹងថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ១៩៩៦ ពិធីបញ្ចុះបឋមសិលា នៅលើទីតាំងសង់ព្រះសក្យមុនីចេតីយ៍ថ្មី ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចព្រះរាជអគ្គមហេសី **នរោត្តម មុនីនា ឥសីហនុ** ជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់ ពះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ។

គណៈកម្មការសាងសង់ ក៏បានធ្វើការដេញថ្លៃតាមគោលការណ៍កំណត់ ។ ដំណាក់កាលដំបូង ក្រុមហ៊ុន Pantaocean ក៏ចូលខ្លួនដេញថ្លៃបាន ក្នុងការសាងសង់សំណង់នេះ ហើយក៏បានដំណើរការងាររបស់ខ្លួនជាបន្តបន្ទាប់ ។ ដោយព្រឹត្តិការណ៍ស្រុកទេសមិនអនុគ្រោះ ការសាងសង់ក៏បានផ្អាកមួយរយៈវែងបង្គួរ ។ ក្រោយមក គណៈកម្មការសាងសង់ ក៏បានធ្វើការដេញថ្លៃជាថ្មី ។ ក្រុមហ៊ុន **ខូខជីឈី អ៊ុមភាភា** ទទួលដេញថ្លៃបាន ហើយក៏ដំណើរ ការសាងសង់ផ្នែកតួចេតិយទាំងមូល ។

ដោយការយកអស់ពីកម្លាំងកាយចិត្ត និងសមត្ថភាព ជំនាញអនុវត្តការងារដោយអំណត់ព្យាយាម និងដោយស្មារតីទទួលខុសត្រូវតាមផ្នែករៀងៗខ្លួន របស់គណៈកម្មការសាងសង់ និងតាមគម្រោងប្លង់ ដែលបានកំណត់ការសាងសង់បានរួចរាល់ហើយស្រេចជាស្ថាពរ នៅថ្ងៃ ព្រហស្បតិ៍ ៦ រោច ខែ ស្រាពណ៍ ព.ស ២៥៤៦ ត្រូវនឹងថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០២ និងបានធ្វើពិធីត្រួតពិនិត្យ ប្រគល់ជូនទៅក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដើម្បីទទួលថែរក្សាគ្រប់គ្រង និង ប្រារព្ធពិធីសម្ពោធ ដង្ហែព្រះបរមសារីរិកធាតុ ពីព្រះសក្យមុនីចេតិយចាស់ នៅរាជធានីភ្នំពេញមកតម្កល់ប្រថាប់នៅព្រះសក្យមុនីចេតិយថ្មី ភ្នំព្រះរាជទ្រព្យ ឧដុង្គ ស្រុកពញាឮ ខេត្តកណ្ដាល នៅថ្ងៃ ព្រហស្បតិ៍ ១៥ កើត ខែ មិគសិរ ព.ស ២៥៤៦ ត្រូវនឹងថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០២ ក្រោមព្រះរាជធិបតីភាពរបស់ ព្រះករុណាជាអម្ចាស់ជីវិត តម្កល់លើត្បូង និងសម្ដេចព្រះរាជអគ្គមហេសី ជាទីសក្ការៈ ដោយមានការនិមន្ត យាង និងអញ្ជើញចូលរួមពីសម្ដេចព្រះសង្ឃរាជទាំងពីរគណៈ ព្រះសង្ឃជាច្រើនពាន់អង្គ សម្ដេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា និងលោកជំទាវ , សម្ដេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** និងព្រះអង្គម្ចាស់ក្សត្រី ,សម្ដេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រី និងលោកជំទាវ , ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត ភ្ញៀវអន្តរជាតិ មន្ត្រីរាជការ

អ្នកមុខ អ្នកការ សីលវន្ត សីលវតី និងពុទ្ធបរិស័ទ មកពីគ្រប់ទិសទីក្នុងទូទាំងប្រទេស ។

ព្រះសក្យមុនីចេតិយថ្មី រំលេចដោយក្បាច់រចនា តាមរចនាបទខ្មែរសុទ្ធសាធ ប្រតិស្ឋាននៅលើកំពូលភ្នំ ព្រះរាជទ្រព្យនាអតីតរាជធានីឧដុង្គ ជាទីតម្កល់ព្រះបរម-សារីរិកធាតុ នៃព្រះសក្យមុនីគោតមបរមគ្រូ គឺជាសមិទ្ធផលថ្មីដ៏ប្រណីតមួយ ក្នុងបណ្តាសមិទ្ធផលដ៏ធំឥតមានពីរ ក្នុងប្រវត្តិសាស្ត្រនៃព្រះពុទ្ធសាសនាខ្មែរ ។

ព្រះសក្យមុនីចេតិយថ្មីនេះ កកើតឡើងដោយព្រះរាជតម្រិះ ផ្តួចផ្តើមដ៏ថ្លៃថ្លាប្រកបដោយព្រះញាណ សម្បយុត្តរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះរាជអគ្គមហេសី **នរោត្តម មុនីនាថ សីហនុ** ព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៏ដ៏ឧដុង្គឧត្តម ទ្រង់សព្វព្រះរាជហរទ័យប្រោសព្រះរាជទាន ឱ្យរាជរដ្ឋាភិបាល ជ្រើសរើសទីតាំងកសាង ទុកជាមតិកក្នុង ព្រះពុទ្ធសាសនា សម្រាប់ជាទីគោរពបូជារបស់ពុទ្ធសាសនិកទូទៅ និងសម្រាប់អនាគតវែងឆ្ងាយរបស់ជាតិយើង ។

ចំពោះព្រះសក្យមុនីចេតិយ ដែលបានសាងសង់ថ្មីជាដំបូង នៅវត្តភ្នំ ផ្នែកខាងជើង នៅរាជធានីភ្នំពេញ ក៏បានរួចរាល់ហើយស្រេចជាស្ថាពរដែរ ហើយក៏ត្រូវបានបង្វែធ្វើជាហោត្រៃ សម្រាប់តម្កល់ព្រះត្រៃបិដក ព្រះពុទ្ធបដិមា គម្ពីរដីកាផ្សេងៗ និងបេតិកភ័ណ្ឌពុទ្ធសាសនាវិញ ។

ដោយៈ **ខាំ គាន**

**អ៊ុំ ស៊ូ**

## ទំព័រឆ្លើយឆ្លងជាមួយកម្ពុជសុរិយា



លោកនិពន្ធនាយកទស្សនាវដ្ដីកម្ពុជសុរិយា!

ខ្ញុំបានឃើញអត្ថបទ ដែលស្ដីពី " មុខរបរកាប់ខ្លឹមចន្ទន៍ក្រស្នា របស់អ្នកស្រុកជនជាតិព័រ និងជងក្នុងទឹកដីខេត្តពោធិ៍សាត់ " ដែលតាក់តែងដោយ : លោក ម៉ៅ សោភ័ណ និងលោក រស់ សំណាង សម្រាប់ទស្សនាវដ្ដី "កម្ពុជសុរិយា " លេខ ៤-២០០២ នេះ។

ខ្លឹមសារនៃអត្ថបទនេះ បានទាក់ទាញស្មារតីរបស់ខ្ញុំ ឱ្យចង់ដឹងកាន់តែច្បាស់លះទូលំទូលាយថែមទៀត ។

ខ្ញុំមិនមែនជាប្រជាជនរស់នៅក្នុងខេត្តពោធិ៍សាត់ទេ ប៉ុន្តែបានដឹងច្បាស់ថា នៅភ្នំក្រវាញរបស់ខេត្តនេះ មានភោគទ្រព្យជាធនធានធម្មជាតិ ដែលលើទឹកដីនៃខេត្តឯទៀតមិនមានសោះ ។ នោះគឺ ÷

១- ក្រវាញ

២- ដង្កោ

៣- ក្លាំពាក់

៤- ក្រស្នា

៥- ចន្ទន៍

អ្នកដែលមិនបានដឹងដូចខ្ញុំនេះ ច្រើនតែនិយាយកួបថា ក្រវាញដង្កោ និងថា ចន្ទន៍ក្រស្នា ។ តើក្នុងពុំនោលនេះ មានវត្ថុពីរប្រភេទ ឬ ៤ ប្រភេទផ្សេងគ្នា ។

បើមិនយល់ទាស់ទេ ខ្ញុំសូមរង់ចាំសេចក្ដីបញ្ជាក់ច្បាស់លះទូលំទូលាយ ក្នុងទស្សនាវដ្ដីដដែលនេះ នៅលេខក្រោយទៀត ។

សូមជូនពរ សុខភាពល្អ និងបវរជោគជ័យសិរីសួស្ដី ។

ពីខ្ញុំ: **ខៀវ យ៉ុន**

*បើដឹងថាខ្លួនជាមនុស្សប្រាកដហើយ*

*គប្បីតែប្រព្រឹត្តកាន់តាមធម៌របស់មនុស្ស ។*

ព្រះពោធិវង្ស **ហួត តាត**